# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ភាគ ៤០

## ទុតិយភាគ

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងឯកនិបាត–ទុកនិបាត មាន ១៦ វគ្គ

និង ៣ បណ្ណាសកៈ

ព្រះអដ្ឋកថាកែសេចក្តី ១៨៨ សូត្រ

# អដ្ឋកថា ព្រះសុត្តន្តបិដក

## អង្គុត្តរនិកាយ

ឈ្មោះ

## មនោរថបូរណី

## ភាគ ៤០

## ទុតិយភាគ

ពុទ្ធសករាជ ២៥៥៧

អធិប្បាយ

ក្នុងឯកនិបាត-ទុកនិបាត មាន ១៤ វគ្គ

និង ៣ បណ្ណាសកៈ

ព្រះអដ្ឋកថាកែសេចក្តី ១៨៨ សូត្រ

# អង្គុត្តរនិកាយ ឯកនិបាត ទុតិយភាគ
## រួមមាន
## ឯតទគ្គបាលិ មាន ៣ វគ្គ ៣៣ អង្គ
## និងវគ្គដទៃផ្សេងទៀត ១១ វគ្គ មាន ១៥ អដ្ឋកថា

## ទុកនិបាត មាន ៣ បណ្ណាសកៈ
## មានព្រះអដ្ឋកថាកែសេចក្តី ១៤០ សូត្រ

**ឯតទគ្គភិក្ខុនីបាលិ វគ្គទី ៥**


១ ប្រវត្តិព្រះនាងមហាបជាបតិគោតមីថេរី

២ ប្រវត្តិព្រះនាងខេមាថេរី

៣ ប្រវត្តិព្រះឧប្បលវណ្ណាថេរី

៤ ប្រវត្តិព្រះនាងបដាចារាថេរី

៥ ប្រវត្តិព្រះនាងធម្មទិន្នាថេរី

៦ ប្រវត្តិព្រះនាងនន្ទាថេរី

៧ ប្រវត្តិព្រះនាងសោណាថេរី

៨ ប្រវត្តិព្រះនាងសកុលាថេរី

៩ ប្រវត្តិព្រះនាងកុណ្ឌលកេសាថេរី

១០ ប្រវត្តិព្រះនាងភទ្ទាកាបិលានី ថេរី

១១ ប្រវត្តិព្រះនាងភទ្ទាកច្ចានាថេរី

១២ ប្រវត្តិព្រះនាងកីសាគោតមី

១៣ ប្រវត្តិព្រះនាងសិង្គាលមាតា

## ឯតទគ្គឧបាសកបាលិ វគ្គទី ៦


១ ប្រវត្តិព្រះបុស្សឧបាសក និងភល្លិកឧបាសក

២ ប្រវត្តិព្រះសុទត្តអនាថបិណ្ឌិកគហបតិ

៣ ប្រវត្តិព្រះចិត្តគហបតិ

៤ ប្រវត្តិព្រះហត្ថអាឡវកឧបាសក

៥ ប្រវត្តិព្រះសក្យមហានាម

៦ ប្រវត្តិព្រះឧគ្គគហបតិក្រុងវេសាលី

៧ ប្រវត្តិព្រះឧគ្គគហបតិស្រុកហត្ថិគ្រាម

៨ ប្រវត្តិព្រះសូរអម្ពដ្ឋឧបាសក

៩ ប្រវត្តិព្រះជីវកកោមារភច្ច

១០ ប្រវត្តិព្រះនកុលបិតា


## ឯតទគ្គភិក្ខុនីបាលិ វគ្គទី ៥


១ ប្រវត្តិព្រះនាងសុជាតាសេនិយធីតា

២ ប្រវត្តិព្រះនាងវិសាខាមិគារមាតា

៣-៤ ប្រវត្តិព្រះនាងខុជ្ជុត្តរា និងព្រះនាងសាមាវតី

៥ ប្រវត្តិព្រះនាងឧត្តរានន្ទមាតា

៦ ប្រវត្តិព្រះនាងសុប្បវាសាកោលិយធីតា

៧ ប្រវត្តិព្រះនាងសុប្បិយាឧបាសិកា

៨ ប្រវត្តិព្រះនាងកាតិយានី

៩ ប្រវត្តិព្រះនាងនកុលមាតាគហបតានី

១០ ប្រវត្តិព្រះនាងកាឡី អ្នកស្រុកកុររឃរនគរ


| | | | | | |
|---|---|---|---|---|---|
| **អដ្ឋានបាលិ** | **៣** | **វគ្គ** | **មាន** | **២** | **អដ្ឋកថា** |
| **ឯកធម្មាទិបាលិ** | **៤** | **វគ្គ** | **មាន** | **៩** | **អដ្ឋកថា** |
| **បសាទករធម្មាទិបាលិ** | **៤** | **វគ្គ** | **មាន** | **៤** | **អដ្ឋកថា** |

# ទុកនិបាត


## បឋមបណ្ណាសកៈ

| | | | |
|---|---|---|---|
| កម្មករណវគ្គទី ១ | មាន | ១០ | អដ្ឋកថា |
| អធិករណវគ្គទី ២ | មាន | ១០ | អដ្ឋកថា |
| ពាលវគ្គ ទី ៣ | មាន | ១១ | អដ្ឋកថា |
| សមចិត្តវគ្គ ទី ៤ | មាន | ១០ | អដ្ឋកថា |
| បរិសវគ្គ ទី ៥ | មាន | ១០ | អដ្ឋកថា |

## ទុតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| បុគ្គលវគ្គ ទី ១ | មាន | ១០ | អដ្ឋកថា |
| សុខវគ្គ ទី ២ | មាន | ១៣ | អដ្ឋកថា |
| សនិមិត្តវគ្គ ទី ៣ | មាន | ០៦ | អដ្ឋកថា |
| ធម្មវគ្គ ទី ៤ | មាន | ១០ | អដ្ឋកថា |
| ពាលវគ្គ ទី ៥ | មាន | ០៩ | អដ្ឋកថា |

## តតិយបណ្ណាសកៈ

| | | | |
|---|---|---|---|
| អាសាវគ្គ ទី ១ | មាន | ០៩ | អដ្ឋកថា |
| អាយាចនវគ្គ ទី ២ | មាន | ០៨ | អដ្ឋកថា |
| ទានវគ្គ ទី ៣ | មាន | ១០ | អដ្ឋកថា |
| សន្ថារវគ្គ ទី ៤ | មាន | ១០ | អដ្ឋកថា |

## អដ្ឋកថាមិនសង្គ្រោះក្នុងបណ្ណាសកៈ

អដ្ឋកថា កោធបេយ្យាល អដ្ឋកថា អកុសលបេយ្យាល

អដ្ឋកថា វិនយបេយ្យាល អដ្ឋកថា រាគះបេយ្យាល

# ស្រៈនិស្ស័យ

# *Signes et accents:*



# ស្រៈពេញតួ
## Voyelles.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូប Romain | a | ā | i | ī | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອະ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| សឹង្ហ Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ

# Consonnes.

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក្ក | ខ្ខ | គ្គ | ឃ្ឃ | ង្ង |
| រូប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| ឡាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច្ច | ឆ្ឆ | ជ្ជ | ឈ្ឈ | ញ្ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ສ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| លង្កា Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស ព្រមទាំងបាននូវសេចក្ដី*

រិកកាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ ព្រះសូត្រ គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ សុត្តានុលោម គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្ដីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និងបុព្វាចារ្យជំនាន់ក្រោយ ៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្ដែងធម៌ក្នុងព្រះពុទ្ធសាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះនឹងមានឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់ ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

## និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកប្បាដិហារ្យ ព្រះមានព្រះ-ភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្ម-កថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសិរីៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយ-វាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការ ដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជា

ប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិ-សាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និង ធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូល អាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និ-កាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើង ហើយ ព្រោះបែកចេញមកពីថេរវាទ យ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយ-វាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះ របស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរ អដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ ពុទ្ធគយាដែនមគធៈ ជិត ស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍-សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅ កាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បាន ឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញា ច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហា ព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះ បោះសំឡេងខ្ទរខ្ទារ គ្របសង្កត់របូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្ដើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវក)

ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះ ហើយព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់ កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្លះ ( សិរិកុឋៈ ) ខ្លះ ( សិរិកូដ្ឋៈ ) ខ្លះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនា

សិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបាន
រចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្ដីយ៉ាងល្អប្រសើរ រហូតដល់
ព្រះសង្ឃលង្កាទទួលស្ដាប់នូវសេចក្ដីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ
ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតា
បានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បាន
រចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដង
ទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ
វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរ
ទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរ
ប្រៀបធៀបគ្នាហើយមិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ
ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬ
ដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បី
សម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ
ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្ដីអស្ចារ្យ
នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គ
នេះ ជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ
ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់
លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ

ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរិយៈ ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសះ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

លោកគ្រូវិនិយាចារ្យ គាំ អ៊ីវ

ឧបាសក ក្អាត ហ៊ន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សោម រតនៈ

ឧបាសក ម៉ៅ ផុន

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ឧបាសិកា ប៉ែន រមណី

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសក សំ ឆាយ

ឧបាសក ជា ស៊ីបាន

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសិកា ប៊ុត សេដាដួង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

| | | |
|---|---|---|
| ព្រះភិក្ខុអគ្គទិន្នោ | នូវ ប៉ូរ៉ា | ប្រធានអាស្រម |
| ព្រះភិក្ខុចិត្តរក្ខិតោ | សំ សម្បត្តិ | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ | ផុំ សាវឿន | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ | ផុត តៅ | ធម្មាចារ្យ |

សាមណេរ កោវិទោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន:**

-ព្រះមហាវរក្សត្រ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌


| ឈ្មោះធម៌ | ទំព័រ |
|---|---|
| **ភិក្ខុនីបាលិ វគ្គទី ៥** | |
| ប្រវត្តិព្រះនាងមហាបជាបតិគោតមីថេរី | ០១ |
| ប្រវត្តិព្រះនាងខេមាថេរី | ០៩ |
| ប្រវត្តិព្រះនាងឧប្បលវណ្ណាថេរី | ១៤ |
| ប្រវត្តិព្រះនាងបដាចារាថេរី | ៣១ |
| ប្រវត្តិព្រះនាងធម្មទិន្នាថេរី | ៣៨ |
| ប្រវត្តិព្រះនាងនន្ទាថេរី | ៤៣ |
| ប្រវត្តិព្រះនាងសោណាថេរី | ៤៦ |
| ប្រវត្តិព្រះនាងសកុលាថេរី | ៥០ |
| ប្រវត្តិព្រះនាងភទ្ទាកុណ្ឌលកេសីថេរី | ៥២ |
| ប្រវត្តិព្រះនាងភទ្ទាកាបិលានីថេរី | ៦៥ |
| ប្រវត្តិព្រះនាងភទ្ទាកច្ចានាថេរី | ៦៨ |
| ប្រវត្តិព្រះនាងកីសាគោតមីថេរី | ៧១ |
| ប្រវត្តិព្រះនាងសិង្គាលមាតាថេរី | ៧៧ |
| **ឧបាសកបាលិ វគ្គទី ៦** | |
| ប្រវត្តិព្រះបុស្ស: និងភល្លិកឧបាសក | ៧៩ |
| ប្រវត្តិព្រះសុទត្តអនាបិណ្ឌិកគហបតិ | ៨៣ |
| ប្រវត្តិព្រះចិត្តគហបតិ | ៨៦ |
| ប្រវត្តិព្រះហត្ថអាឡវកឧបាសក | ៩២ |
| ប្រវត្តិព្រះសក្យមហានាម | ៩៩ |
| ប្រវត្តិព្រះឧគ្គគហបតិក្រុងវេសាលី | ១០១ |
| ប្រវត្តិព្រះឧគ្គគហបតិអ្នកស្រុកហត្ថិគ្រាម | ១០៤ |
| ប្រវត្តិព្រះសូរអម្ពដ្ឋឧបាសក | ១០៦ |

ប្រវត្តិព្រះជីវកកោមារភច្ច ១១០
ប្រវត្តិព្រះនកុលបិតាគហបតិ ១១៣

## ខុទ្ទសកបាលិ វគ្គទី ៧

ប្រវត្តិព្រះនាងសុជាតាសេនីយធីតា ១១៦
ប្រវត្តិព្រះនាងវិសាខាមិគារមាតា ១២១
ប្រវត្តិព្រះនាងខុជ្ជុត្តរា និងព្រះនាងសាមាវតី ១៤៣
ប្រវត្តិព្រះនាងឧត្តរានន្ទមាតា ១៨៤
ប្រវត្តិព្រះនាងសុប្បវាសាកោលិយធីតា ១៩៥
ប្រវត្តិព្រះនាងសុប្បិយាឧបាសិកា ១៩៧
ប្រវត្តិព្រះនាងកាតិយានី ២០០
ប្រវត្តិព្រះនាងនកុលមាតាគហបតានី ២០៤
ប្រវត្តិព្រះនាងកាឡី អ្នកស្រុកកុររឃរនគរ ២០៥

## អដ្ឋានបាលិ

**វគ្គទី ១** ពោលដោយឋានៈ និងអឋានៈ ២០៧
**វគ្គទី ២** ពោលដោយឋានៈ និងអឋានៈ ២២៩

## ឯកធម្មាទិបាលិ

**វគ្គទី ១** ពោលដោយអនុស្សតិ ១០ ២៣៩
**វគ្គទី ២** ពោលដោយមិច្ឆាទិដ្ឋិ និងសម្មាទិដ្ឋិ ២៤៧
**វគ្គទី ៣** បុគ្គលតែម្នាក់កើតក្នុងលោកញ៉ាំងលោកឱ្យវិនាស ២៥៤
អដ្ឋកថាសូត្រទី ២ ២៥៥
អដ្ឋកថាសូត្រទី ៣ ២៥៦
អដ្ឋកថាសូត្រទី ៤ ២៥៨
អដ្ឋកថាសូត្រទី ៥ ជាដើម ២៦០

## វគ្គទី ៣

សត្វកើតក្នុងមជ្ឈិមជនបទមានតិច ២៧១

អដ្ឋកថាសូត្រទី ២ ជាដើម ២៧៥

**បសាទករធម្មានិបាលិ**

អដ្ឋកថា បសាទករធម្មាទិវគ្គ ២៨១
អដ្ឋកថា អបរអច្ឆរាសង្ឃាតវគ្គ ២៨៣
អដ្ឋកថា បសាទករធម្មាទិវគ្គ ៣៥១
អដ្ឋកថា អមតវគ្គ ៣៦៧

## ទុកនិបាត បឋមបណ្ណាសកៈ

**កម្មករណវគ្គ ទី ១**

ទោសក្នុងបច្ចុប្បន្ន និងភពខាងមុខ ៣៦៩
សេចក្តីព្យាយាមលំបាក ២ យ៉ាង ៣៧៦
សេចក្តីក្តៅក្រហាយ ២ យ៉ាង ៣៧៨
ធម៌មិនជាទីតាំងនៃសេចក្តីក្តៅក្រហាយ ២ យ៉ាង ៣៨០
គុណនៃធម៌ ២ យ៉ាង ៣៨១
ការពេញចិត្ត និងជឿយណាយក្នុងធម៌ជាបច្ច័យនៃសំយោជនៈ ៣៨៥
ធម៌ខ្មៅ ២ យ៉ាង ៣៨៧
ធម៌ស ២ យ៉ាង ៣៨៨
លោកប្បញ្ញត្តិជាមាតាជាដើមព្រោះធម៌ស ២ យ៉ាង ៣៨៩
វស្សូបនាយិកា ២ យ៉ាង ៣៩០

**អធិករណវគ្គ ទី ២**

ពលៈ ២ យ៉ាង ៣៩២
ពលៈ ២ យ៉ាង (ម្យ៉ាងទៀត) ៣៩៤
ពលៈ ២ យ៉ាង (ម្យ៉ាងទៀត) ៣៩៨
ធម្មទេសនាព្រះតថាគត ២ យ៉ាង ៣៩៩
ហេតុឱ្យអធិករណ៍ប្រព្រឹត្តទៅយូរ និងមិនយូរ ៤០១
ហេតុបច្ច័យឱ្យសត្វចូលដល់ទុគ្គតិ និងសុគតិ ៤០៥
ហេតុបច្ច័យឱ្យសត្វចូលដល់ទុគ្គតិ និងសុគតិ ៤២៨

ទោសរបស់ទុច្ចរិត និងអានិសង្សរបស់សុចរិត ៤៣១
ចូរលះបង់អកុសល ចម្រើនកុសល ៤៣២
ធម៌ជាហេតុឱ្យព្រះសទ្ធម្មវិនាស និងតាំងនៅ ៤៣៣

## ពាលវគ្គ ទី ៣

បុគ្គលពាល ២ ពួក ៤៣៥
បុគ្គល ២ ពួក ពោលបង្កាច់ព្រះតថាគត ៤៣៦
បុគ្គល ២ ពួក ពោលបង្កាច់ និងមិនបង្កាច់ព្រះតថាគត ៤៣៧
បុគ្គល ២ ពួក ពោលបង្កាច់ និងមិនបង្កាច់ព្រះតថាគត ៤៣៨
គតិ ២ យ៉ាងរបស់បុគ្គលមានកម្មលាមក និងមិនលាមក ៤៤១
ឋាន: ២យ៉ាង របស់បុគ្គលទ្រុស្តសីល និងបុគ្គលមានសីល ៤៤៣
ប្រយោជន៍ ២ប្រការ នៃសេនាសនៈស្ងាត់ ៤៤៤
ធម៌ ២យ៉ាង ប្រព្រឹត្តនៅក្នុងចំណែកវិជ្ជា ៤៤៥

## សមចិត្តវគ្គ ទី ៤

ភូមិអសប្បុរស និងសប្បុរស ៤៤៨
បុគ្គល ២ ពួក មិនងាយធ្វើតបទាន ៤៤៩
មិនគួរធ្វើទុច្ចរិត គួរធ្វើសុចរិត ៤៥២
ទក្ខិណេយ្យបុគ្គល ២ ពួក ៤៥៥
បុគ្គលមានសំយោជនៈខាងក្នុង និងខាងក្រៅ ៤៥៦
ហេតុបច្ច័យនៃការវិវាទគ្នា ៤៨៤
បណ្ឌិត និងព្រះថេរៈមិនមែនមនុស្សចាស់ ៤៨៦
ហេតុដែលប្រព្រឹត្តទៅ និងមិនប្រព្រឹត្តទៅដើម្បីប្រយោជន៍ ៤៩០
ការបដិបត្តិខុស និងការបដិបត្តិត្រូវ ៤៩២
ហេតុឱ្យព្រះសទ្ធម្មអន្តរធាន និងតាំងនៅ ៤៩៣

## បរិសវគ្គ ទី ៥

បរិស័ទរាក់ និងបរិស័ទជ្រៅ ៤៩៤
បរិស័ទបែកជាពួក និងបរិស័ទសាមគ្គីគ្នា ៤៩៦
បរិស័ទមិនមានអគ្គបុគ្គល និងបរិស័ទមានអគ្គបុគ្គល ៤៩៨

បរិស័ទមិនមែនជាអរិយៈ និងបរិស័ទជាអរិយៈ ៥០០
បរិស័ទស្រកេកស្រកាក និងបរិស័ទថ្លរថង់ ៥០១
បរិស័ទខុសធំនង់ និងបរិស័ទត្រូវធំនង់ ៥០៣
បរិស័ទធ្ងន់ក្នុងអាមិស និងបរិស័ទធ្ងន់ក្នុងព្រះសទ្ធម្ម ៥០៦
បរិស័ទរាបសា និងបរិស័ទមិនរាបសា ៥១០
បរិស័ទគ្មានធម៌ និងបរិស័ទប្រកបដោយធម៌ ៥១១
បរិស័ទជាអធម្មវាទី និងបរិស័ទជាធម្មវាទី ៥១២


# ទុកនិបាត ទុតិយបណ្ណាសកៈ

## បុគ្គលវគ្គ ទី ១


បុគ្គល ២ ពួកកើតឡើងក្នុងលោក ៥១៤
អច្ឆរិយបុគ្គល ២ ពួក ៥១៥
កាលកិរិយាបុគ្គល ២ ពួក ៥១៦
ថូបារហបុគ្គល ២ ពួក ៥១៧
ព្រះពុទ្ធ ២ ពួក ៥១៨
បុគ្គល ២ ពួកមិនខ្លាចរន្ទះ ៥១៩
កិន្នរឃើញប្រយោជន៍ ២ យ៉ាង ទើបនិយាយ ៥២០
មាតុគ្រាមមិនឆ្អែតក្នុងធម៌ ២ យ៉ាង ៥២២
ការនៅរួមជាមួយអសប្បុរស និងសប្បុរស ៥២៣
អធិករណ៍ធ្វើឱ្យភិក្ខុនៅមិនជាសុខ និងនៅជាសុខ ៥២៥


## សុខវគ្គ ទី ២


អដ្ឋកថាសូត្រទី ១ ៥២៧
អដ្ឋកថាសូត្រទី ២ ៥២៨
អដ្ឋកថាសូត្រទី ៣ ៥២៩
អដ្ឋកថាសូត្រទី ៤ ៥៣០
អដ្ឋកថាសូត្រទី ៥ ៥៣១
អដ្ឋកថាសូត្រទី ៦ ៥៣២
អដ្ឋកថាសូត្រទី ៧ ៥៣៣

អដ្ឋកថាសូត្រទី ៨ ៥៣៤
អដ្ឋកថាសូត្រទី ៩ ៥៣៥
អដ្ឋកថាសូត្រទី ១០ ៥៣៦
អដ្ឋកថាសូត្រទី ១១ ៥៣៧
អដ្ឋកថាសូត្រទី ១២ ៥៣៨
អដ្ឋកថាសូត្រទី ១៣ ៥៣៩

**សនិមិត្តវគ្គ ទី ៣**

អដ្ឋកថាសូត្រទី ១ ៥៤០
អដ្ឋកថាសូត្រទី ២ ជាដើម ៥៤១
អដ្ឋកថាសូត្រទី ៧ ៥៤២
អដ្ឋកថាសូត្រទី ១០ ៥៤៤

**ធម្មវគ្គ ទី ៤**

អដ្ឋកថាសូត្រទី ១ ៥៤៥
អដ្ឋកថាសូត្រទី ២ ៥៤៦
អដ្ឋកថាសូត្រទី ៣ ៥៤៧
អដ្ឋកថាសូត្រទី ៤ ៥៤៨
អដ្ឋកថាសូត្រទី ៥ ៥៤៩
អដ្ឋកថាសូត្រទី ៦-៧ ៥៥០
អដ្ឋកថាសូត្រទី ៨ ៥៥១
អដ្ឋកថាសូត្រទី ៩ ៥៥២
អដ្ឋកថាសូត្រទី ១០ ៥៥៣
អដ្ឋកថាសូត្រទី ១១ ៥៥៤

**ពាលវគ្គ ទី ៥**

អដ្ឋកថាសូត្រទី ១ ៥៥៥
អដ្ឋកថាសូត្រទី ២ ៥៥៦
អដ្ឋកថាសូត្រទី ៣ ៥៥៧

អដ្ឋកថាសូត្រទី ៤ ៥៥៨
អដ្ឋកថាសូត្រទី ៥ ៥៥៩
អដ្ឋកថាសូត្រទី ៦ ៥៦០
អដ្ឋកថាសូត្រទី ៧ ជាដើម ៥៦១
អដ្ឋកថាសូត្រទី ១១ ៥៦២
អដ្ឋកថាសូត្រទី ១២ ៥៦៣

## ទុកនិបាត តតិយបណ្ណាសកៈ

### អាសាវគ្គ ទី ១

អដ្ឋកថាសូត្រទី ១ ៥៦៤
អដ្ឋកថាសូត្រទី ២ ៥៦៥
អដ្ឋកថាសូត្រទី ៣ ៥៦៦
អដ្ឋកថាសូត្រទី ៤ ៥៦៧
អដ្ឋកថាសូត្រទី ៥ ៥៦៨
អដ្ឋកថាសូត្រទី ៦ ៥៦៩
អដ្ឋកថាសូត្រទី ៧ ៥៧០
អដ្ឋកថាសូត្រទី ៨ ៥៧១
អដ្ឋកថាសូត្រទី ៩ ៥៧២

### អាយាចនវគ្គ ទី ២

អដ្ឋកថាសូត្រទី ១ ៥៧៣
អដ្ឋកថាសូត្រទី ២ ជាដើម ៥៧៥
អដ្ឋកថាសូត្រទី ៥ ៥៧៦
អដ្ឋកថាសូត្រទី ៦ ៥៧៨
អដ្ឋកថាសូត្រទី ៧ ៥៧៩
អដ្ឋកថាសូត្រទី ៨ ៥៨០
អដ្ឋកថាសូត្រទី ៩ ៥៨១
អដ្ឋកថាសូត្រទី ១០-១១ ៥៨២

**ឈានវគ្គ ទី ៣**


អដ្ឋកថាសូត្រទី ១ ៥៨៣
អដ្ឋកថាសូត្រទី ២ ៥៨៤
អដ្ឋកថាសូត្រទី ៣ ៥៨៥
អដ្ឋកថាសូត្រទី ៤ ៥៨៦
អដ្ឋកថាសូត្រទី ៥ ៥៨៧
អដ្ឋកថាសូត្រទី ៦ ៥៨៨
អដ្ឋកថាសូត្រទី ៧ ៥៨៩
អដ្ឋកថាសូត្រទី ៨ ៥៩០
អដ្ឋកថាសូត្រទី ៩ ៥៩១
អដ្ឋកថាសូត្រទី ១០ ៥៩២


**សន្ថារវគ្គ ទី ៤**


អដ្ឋកថាសូត្រទី ១ ៥៩៣
អដ្ឋកថាសូត្រទី ២ ៥៩៤
អដ្ឋកថាសូត្រទី ៣ ៥៩៥
អដ្ឋកថាសូត្រទី ៤ ៥៩៦
អដ្ឋកថាសូត្រទី ៥ ៥៩៧
អដ្ឋកថាសូត្រទី ៦ ៥៩៨
អដ្ឋកថាសូត្រទី ៧ ៥៩៩
អដ្ឋកថាសូត្រទី ៨ ៦០០
អដ្ឋកថាសូត្រទី ៩ ៦០១
អដ្ឋកថាសូត្រទី ១០ ៦០២
អដ្ឋកថាសូត្រទី ១១ ៦០៣
អដ្ឋកថាសូត្រទី ១២ ៦០៤


**សមាបត្តិវគ្គ ទី ៥**


អដ្ឋកថាសូត្រទី ១ ៦០៥
អដ្ឋកថាសូត្រទី ២ ៦០៦

| | |
|---|---|
| អដ្ឋកថាសូត្រទី ៣ | ៦០៧ |
| អដ្ឋកថាសូត្រទី ៤ | ៦០៨ |
| អដ្ឋកថាសូត្រទី ៥ | ៦០៩ |
| អដ្ឋកថាសូត្រទី ៦–៧ | ៦១០ |
| អដ្ឋកថាសូត្រទី ៨ | ៦១១ |
| អដ្ឋកថាសូត្រទី ៩ | ៦១២ |
| អដ្ឋកថាសូត្រទី ១០ | ៦១៣ |
| អដ្ឋកថាសូត្រទី ១១ | ៦១៤ |
| អដ្ឋកថាសូត្រទី ១២ | ៦១៥ |
| អដ្ឋកថាសូត្រទី ១៣ | ៦១៦ |
| អដ្ឋកថាសូត្រទី ១៤ | ៦១៧ |
| អដ្ឋកថាសូត្រទី ១៥ | ៦១៨ |
| អដ្ឋកថាសូត្រទី ១៦ | ៦១៩ |
| អដ្ឋកថាសូត្រទី ១៧ | ៦២០ |

**អដ្ឋកថា មិនសង្គ្រោះចូលក្នុងបណ្ណាសកៈ**

| | |
|---|---|
| អដ្ឋកថា កោធបេយ្យាល | ៦២១ |
| អដ្ឋកថា អកុសលបេយ្យាល | ៦២៣ |
| អដ្ឋកថា វិនយបេយ្យាល | ៦២៤ |
| អដ្ឋកថា រាគបេយ្យាល | ៦២៥ |

# ព្រះសុត្តន្តបិដក
# អង្គុត្តរនិកាយ ឯកនិបាត-ទុកនិបាត
# ឈ្មោះ
# មនោរថបូរណី
# ទុតិយភាគ
# ភាគ ៤០

## អដ្ឋកថាឯតទគ្គវគ្គទី ៥

### អដ្ឋកថាសូត្រទី ១
### “ រឿងព្រះនាងមហាបជាបតិគោតមី ”

*សូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *បទថា* ***យទិទំ មហាបជាបតិគោតមី*** *(ព្រះនាងមហាបជាបតិគោតមីភិក្ខុនី) ទ្រង់សម្តែងថា ព្រះនាងមហាបជាបតិគោតមីថេរី ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកមានរាត្រីយូរ ក្នុងបញ្ញាកម្មរបស់ព្រះនាង មានរឿងពោលតាមលំដាប់ដូចតទៅនេះ ៖*

បានឮថា ព្រះនាងមហាបជាបតិគោតមី កាលព្រះពុទ្ធព្រះនាម **បទុមុត្តរ** បដិសន្ធិក្នុងត្រកូល នាក្រុងហង្សវតី សម័យតមក កំពុងស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីសាវិកាដែលមានរាត្រីយូរ ក៏ធ្វើកុសលដ៏ក្រៃលែងទៅ ប្រាថ្នាតំណែងនោះ ។ នាងថ្វាយទាន រក្សាសីលរហូតអស់មួយជីវិត ចុតិចាកភពនោះហើយ កើតក្នុងទេវលោក ចុតិចាកទេវលោកក្នុងមួយពុទ្ធន្តរទៀត ទៅកើតជាប្រធានទាសី ក្នុងចំនួនទាសី ៥០០ នាក់ ក្នុងក្រុងពារាណសី ។ គ្រានោះជាសម័យចូលវស្សា ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ចុះចាកពីញកភ្នំនន្ទមូលកៈ ទៅព្រៃឥសិបតនៈ ត្រាច់បិណ្ឌបាត ក្នុងក្រុងហើយត្រឡប់មកព្រៃឥសិបតនៈ ត្រិះរិះថា គួរយើងនឹងសូមហត្ថកម្មដើម្បីធ្វើកុដិសម្រាប់ចាំវស្សា ។ ព្រោះហេតុអ្វី ។ ព្រោះនឹងចាំវស្សាក្នុងរដូវភ្លៀង ទាំងបដិបត្តិនាលកប្បដិបទា ចាំបាច់ត្រូវនៅក្នុងសេនាសនៈប្រចាំ ដែលប្រក់បាំងដោយគ្រឿងប្រក់បាំង ៥ យ៉ាងណាមួយ ។ សមពិតដូចព្រះពុទ្ធតម្រាស់នេះថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានសេនាសនៈ មិនគប្បីនៅចាំវស្សា ភិក្ខុណាល្មើសត្រូវអាបត្តិទុក្កដ” ដូច្នេះ ។ ព្រោះហេតុនោះ កាលជិតរដូវភ្លៀង (ចូលវស្សា) បើបានសេនាសនៈនោះជាការល្អ បើមិនបាន ត្រូវស្វែងរកហត្ថកម្មធ្វើ កាលមិនបានហត្ថកម្ម ក៏គប្បីធ្វើដោយខ្លួនឯង ។ ភិក្ខុ

មិនមានសេនាសនៈ មិនគួរនៅចាំវស្សា ។ នេះជាធម្មតាប្រពៃណី ។ ព្រោះហេតុនោះ ព្រះបច្ចេកពុទ្ធទាំងនោះគិតថា យើងចាំបាច់ត្រូវស្វែងរកហត្ថកម្មធ្វើ ទើបដណ្តប់ចីវរចូលកាន់ព្រះនគរវេលាល្ងាច ឈរនៅត្រង់ទ្វារផ្ទះរបស់សេដ្ឋី ។ នាងទាសីប្រធាន កាន់ឆ្នាំងទឹកកំពុងដើរទៅកំពង់ទឹក ឃើញពួកព្រះបច្ចេកពុទ្ធដើរចូលព្រះនគរ ។ សេដ្ឋីស្តាប់ហេតុដែលព្រះបច្ចេកពុទ្ធទាំងនោះមកហើយ ក៏ពោលថា "ខ្ញុំមិនមានវេលា មេត្តាទៅចុះ" ។

លំដាប់នោះ ទាសីប្រធាន កាន់ឆ្នាំងទឹកចូលទៅ ឃើញព្រះបច្ចេកពុទ្ធទាំងនោះកំពុងដើរចេញពីព្រះនគរ ទើបដាក់ឆ្នាំងទឹកចុះ នមស្ការ ហើយសួរថា "ហេតុអ្វីលោកម្ចាស់ទាំងឡាយ ពេលចូលទៅហើយក៏ចេញមកវិញ? លោកឆ្លើយថា "យើងនាំគ្នាមក ក៏ដើម្បីសូមហត្ថកម្មសាងកុដិសម្រាប់នៅចាំវស្សា" ។ នាងទើបសួរថា "បានទេ លោកម្ចាស់" ។ ឆ្លើយថា "មិនបានទេ ឧបាសិកា" ។ នាងសួរថា ចាំបាច់ឬដែលអ្នកធំៗ ប៉ុណ្ណោះទើបធ្វើកុដិបាន ឬសូម្បីអ្នកក្រលំបាកក៏ធ្វើបាន? លោកឆ្លើយថា "នរណាៗ ក៏ធ្វើបាន" ។ នាងទើបពោលថា "សាធុ លោកម្ចាស់ ពួកខ្ញុំនឹងជួយគ្នាធ្វើ សូមមេត្តាទទួលអាហាររបស់ខ្ញុំក្នុងថ្ងៃស្អែកនេះ" និមន្តហើយ ក៏កាន់ឆ្នាំងទឹកដាក់ទុកត្រង់ផ្លូវកំពង់ទឹកដែលមក ហើយពោលនឹងនាងទាសីទាំងឡាយថា "ពួកអ្នកនាងចូលនៅត្រង់នេះសិន" វេលាដែលទាសីទាំងនោះមក ក៏

ពោលថា "ពួកនាងទាំងឡាយ ពួកយើងនឹងធ្វើការងារជាទាសីសម្រាប់បុគ្គលដទៃ រហូតទៅឬ ឬថា ប្រាថ្នានឹងផុតអំពីជាទាសីគេ? ពួកទាសីក៏ឆ្លើយថា "ពួកយើងប្រាថ្នារួចផុតក្នុងថ្ងៃនេះឯង ម៉ែម្ចាស់" ។ នាងទើបពោលថា បើដូច្នោះ ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដែលនៅមិនទាន់បានហត្ថកម្ម យើងក៏និមន្តឲ្យឆាន់ក្នុងថ្ងៃស្អែកនេះហើយ ពួកនាងចូរឲ្យស្វាមីរបស់ពួកនាង ថ្វាយការងារហត្ថកម្មមួយថ្ងៃចុះ ។ ពួកទាសីក៏ទទួលថា "សាធុ" ហើយប្រាប់ពួកស្វាមី វេលាដែលគេចេញមកពីព្រៃវេលាល្ងាច ។ ស្វាមីទាំងនោះ យល់ព្រមហើយមកប្រជុំគ្នាត្រង់ទ្វារផ្ទះទាសីប្រធាន ។ គ្រានោះ ប្រធានទាសីទើបពោលថា បាទាំងឡាយ ស្អែកនេះពួកអ្នកចូរថ្វាយហត្ថកម្មដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ហើយប្រាប់អានិសង្ស គម្រាមអ្នកដែលមិនចង់ធ្វើដោយឱវាទធ្ងន់ៗ ឲ្យមនុស្សគ្រប់ៗ រូបព្រមទទួល ។ ស្អែកឡើង នាងថ្វាយអាហារដល់ព្រះបច្ចេកពុទ្ធហើយ ឲ្យការកំណត់ណាត់ដល់កូនទាសីគ្រប់រូប ។ ក្លាមនោះឯង កូនទាសីទាំងនោះក៏នាំគ្នាចូលព្រៃ រួបរួមទព្វសម្ភារៈហើយ សាងកុដិម្ដងមួយខ្នងៗ ជារយខ្នង ចាត់ចែងបរិវេណមានទីចង្ក្រមជាដើម ដាក់គ្រែ តាំង ទឹកឆាន់ ទឹកប្រើជាដើមទុក ថ្វាយព្រះបច្ចេកពុទ្ធទាំងឡាយ ទទួលបដិញ្ញានឹងនៅចាំវស្សាក្នុងទីនោះអស់ត្រៃមាស ឲ្យចាត់ចែងវេនថ្វាយអាហារ ។ ទាសីណាមិនអាចថ្វាយក្នុងថ្ងៃជាវារៈរបស់ខ្លួនបាន ទាសីប្រធានក៏នាំអាហារពីផ្ទះ

ខ្ញុំនឹងថ្វាយជំនួសទាសីនោះ ។ ទាសីប្រធានទំនុកបម្រុងមករហូតអស់ត្រៃមាសយ៉ាងនេះ ឲ្យទាសីម្នាក់ៗ ចាត់ចែងសំពត់សាជកម្នាក់មួយផ្ទាំង ។ រួមជាសំពត់សាជកសាច់គ្រោតគ្រាត ៥០០ ផ្ទាំង ។ នាងឲ្យផ្លាស់ប្តូរសំពត់សាជកសាច់គ្រោតគ្រាតទាំងនោះ ធ្វើជាត្រៃចីវរថ្វាយព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ ព្រះបច្ចេកពុទ្ធទាំងឡាយទៅកាន់ភ្នំគន្ធមាទន៍ផ្លូវអាកាសទាំងដែលទាសីទាំងនោះឃើញហើយនុ៎ះឯង ។

ទាសីទាំងនោះគ្រប់ៗ គ្នាធ្វើកុសលរហូតអស់ជីវិត ក៏ទៅកើតក្នុងទេវលោក ។ បណ្តាទាសីទាំងនោះ ទាសីប្រធានចុតិចាកភពនោះហើយ មកកើតក្នុងផ្ទះរបស់ប្រធានជាងតម្បាញ មិនឆ្ងាយអំពីក្រុងពារាណសី ។ តមកថ្ងៃមួយព្រះបច្ចេកពុទ្ធ ៥០០ អង្គ បុត្រនាងបទុមវតី ដែលព្រះរាជាក្រុងពារាណសីនិមន្តទុក មកដល់ទ្វារព្រះរាជនិវេសន៍មិនជួបមនុស្សណាៗ ទើបត្រឡប់ចេញទៅផ្លូវទ្វារក្រុង ទៅកាន់ស្រុកជាងតម្បាញនោះ ។ ស្ត្រីនោះឃើញព្រះបច្ចេកពុទ្ធទាំងឡាយនឹកអាណិត ក៏ថ្វាយបង្គំគ្រប់អង្គហើយថ្វាយអាហារ ។ ព្រះបច្ចេកពុទ្ធទាំងឡាយឆាន់អាហារស្រេចហើយ ក៏ទៅកាន់ភ្នំគន្ធមាទន៍វិញ ។

សូម្បីស្ត្រីនោះធ្វើកុសលរហូតអស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សហើយបដិសន្ធិក្នុងផ្ទះរបស់មហាសុប្បពុទ្ធ ក្រុងទេវទហៈ មុនព្រះសាស្តារបស់យើងឧប្បត្តិ ។ ព្រះញាតិថ្វាយព្រះនាមរបស់ព្រះនាងថា **គោតមី** ជាកនិដ្ឋភគិនី

របស់ព្រះនាងមហាមាយា (ព្រះពុទ្ធមាតា) ។ ពួកព្រាហ្មណ៍ដែលជំនាញមន្តត្រួតមើលព្រះលក្ខណៈហើយ ព្យាករណ៍ថា ទារកដែលនៅក្នុងព្រះគភ៌របស់ព្រះនាងទាំងពីរព្រះអង្គ នឹងជាស្តេចចក្រពត្តិ ។ ព្រះបាទសុទ្ធោទនមហារាជទ្រង់មង្គលអភិសេកនឹងព្រះនាងទាំងពីរព្រះអង្គ វេលាដែលទ្រង់ចម្រើនវ័យហើយ ទ្រង់នាំទៅនៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គ ។ តមក ព្រះពោធិសត្វរបស់យើងចុតិចាកសួគ៌ជាន់តុសិត ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាមាយាទេវី ។ ក្នុងថ្ងៃទី ៧ តាំងពីថ្ងៃដែលព្រះពោធិសត្វប្រសូតិហើយ ព្រះនាងមហាមាយាទេវីក៏សុគត កើតក្នុងសួគ៌ជាន់តុសិត ។ ព្រះបាទសុទ្ធោទនមហារាជ ក៏ទ្រង់ស្ថាបនាព្រះនាងមហាបជាបតីគោតមី ព្រះមាតុច្ឆា (ម្តាយមីង) របស់ព្រះមហាសត្វ ទុកក្នុងតំណែងព្រះអគ្គមហេសី ។ វេលានោះ នន្ទកុមារក៏ប្រសូតិ ។ ព្រះនាងមហា-បជាបតី ទ្រង់ប្រគល់ព្រះនន្ទកុមារដល់កិលៀងចិញ្ចឹម ទ្រង់ចិញ្ចឹមបីបាច់ព្រះពោធិ-សត្វដោយព្រះអង្គឯង ។ សម័យតមក ព្រះពោធិសត្វស្តេចចេញមហាភិនេស្រ្កម៍ត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ទ្រង់អនុគ្រោះលោក ស្តេចដល់ក្រុងកបិលភស្តុស្តេចចូលទៅបិណ្ឌបាតក្នុងព្រះនគរ ។ គ្រានោះ ព្រះបាទសុទ្ធោទនមហារាជពុទ្ធបិតា ទ្រង់ស្តាប់ធម្មកថាត្រង់ចន្លោះថ្នល់ ក៏ជាព្រះសោតាបន្ន ។ លុះថ្ងៃទី ២ ព្រះនន្ទកុមារក៏ទ្រង់ផ្នួស ។ ថ្ងៃទី ៧ ព្រះរាហុលក៏ទ្រង់ព្រះផ្នួស ។ តមក ព្រះ

សាស្តា ទ្រង់អាស្រ័យក្រុងវេសាលីប្រថាប់នៅក្នុងកូដាគារសាលា ។ សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ធ្វើឲ្យច្បាស់ព្រះអរហត្តហើយបរិនិព្វាន ក្រោមព្រះមហាសេ្វតឆត្រ ។

គ្រានោះ ព្រះនាងមហាបជាបតី កើតមានព្រះហឫទ័យនឹងទ្រង់ព្រះផ្នួស ។ បន្ទាប់ពីនោះ នាងបាទបរិចារិកា របស់ព្រះកុមារ ៥០០ ព្រះអង្គ ដែលស្តេចចេញទ្រង់ព្រះផ្នួស កាលចប់កលហវិវាទសូត្រ ត្រង់មាត់ស្ទឹងរោហិណី គ្រប់គ្នាមានចិត្តតែមួយថា ពួកយើងនឹងចូលទៅគាល់ព្រះនាងមហាបជាបតី ហើយបួសក្នុងសំណាក់ព្រះសាស្តាទាំងអស់គ្នា ទើបឲ្យព្រះនាងមហាបជាបតីជាប្រធាន បំណងនឹងទៅគាល់ព្រះសាស្តា ។ ព្រះនាងមហាបជាបតីទ្រង់ទូលសូមបព្វជ្ជាចំពោះព្រះសាស្តា គ្រាដំបូងប៉ុណ្ណោះក៏មិនបាន ។ ព្រោះហេតុនោះ ព្រះនាងទើបត្រាស់ហៅជាងកោរកាត់មក ហើយឲ្យកាត់ព្រះកេសា ទ្រង់គ្រងសំពត់កាសាយៈ (សំពត់ជ្រលក់ទឹកអម្ចត់) ទ្រង់នាំពួកសាកិយានីទាំងអស់នោះ ស្តេចដល់ក្រុងវេសាលី ឲ្យព្រះអានន្ទត្ថេរទូលអង្វរព្រះទសពល ក៏ទ្រង់បានបព្វជ្ជាឧបសម្បទា ដោយគរុធម៌ ៨ ប្រការ ។ ចំណែកពួកសាកិយានីទាំងអស់ ក៏បានឧបសម្បទាព្រមគ្នា ។ នេះជាសេចក្តីសង្ខេបក្នុងរឿងនេះ ។ ចំណែករឿងពិស្តារមកហើយក្នុងព្រះបាលី ។ ក៏ព្រះនាងមហាបជាបតី លុះទ្រង់ឧបសម្បទាយ៉ាងនេះហើយ ចូលគាល់ព្រះសាស្តា

ថ្វាយបង្គំហើយ ប្រថាប់ក្នុងទីសមគួរម្ខាង វេលានោះព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសព្រះនាង ព្រះនាងទទួលកម្មដ្ឋានក្នុងសំណាក់ព្រះសាស្តាតែមួយជង់ ក៏បានសម្រេចព្រះអរហត្ត ។ ភិក្ខុនី ៥០០ រូបក្រៅពីនោះ ក៏សម្រេចព្រះអរហត្ត កាលចប់នន្ទកោវាទសូត្រ ។ រឿងនេះកើតឡើងដោយប្រការដូច្នេះ ។ តមកខាងក្រោយព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងឯតទគ្គៈច្រើនតំណែង ទើបទ្រង់ស្ថាបនាព្រះនាងមហាបជាបតី ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកា ដែលជារត្តញ្ញូ (ដឹងរាត្រីយូរ) ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## “ប្រវត្តិព្រះនាងខេមាថេរី”

*ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៥០] បទថា* ***ខេមា*** *បានដល់ ភិក្ខុនីមានឈ្មោះយ៉ាងនេះ ។ ក៏ឯតាំងពីនេះទៅ ខ្ញុំនឹងមិនពោលថា នេះគឺរឿងដែលនឹងពោលតាមលំដាប់ក្នុងបញ្ហាកម្មរបស់ព្រះនាង ដូច្នេះ នឹងពោលប្រការដែលគួរនឹងពោលទាក់ទងជាមួយអភិ-និហារជាដើមទៅទុកគ្រប់កន្លែង ។*

*ដូចបានស្តាប់មក ក្នុងអតីតកាល សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *នាងខេមានេះ ក៏កើតទាក់ទងនឹងអ្នកដទៃ ក្នុងក្រុងហង្សវតី ។ តមក ថ្ងៃមួយនាងជួប* ***ព្រះសុជាតត្ថេរី*** *អគ្គសាវិការបស់ព្រះដ៏មានព្រះភាគនោះ កំពុងត្រាច់បិណ្ឌបាត ទើបថ្វាយនំដុត ៣ ដុំ ក្នុងថ្ងៃនោះឯង ក៏ចាត់ចែងក្នុងផ្ទះរបស់ខ្លួនហើយថ្វាយទានដល់ព្រះថេរី តាំងសេចក្តីប្រាថ្នាថា ខ្ញុំគប្បីមានបញ្ញាច្រើនដូចព្រះនាង ក្នុងពុទ្ធុប្បាទកាលក្នុងអនាគត ។ ជាអ្នកមិនប្រមាទក្នុងកុសលកម្មទាំងឡាយដរាបអស់មួយជីវិត ត្រាច់រង្គាត់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប គ្រាព្រះពុទ្ធព្រះនាមថា* ***កស្សបៈ*** *ក៏បដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ ជា*

ព្រះធីតាក្នុងរវាងបងប្អូនព្រះនាង ៧ ព្រះអង្គ ទ្រង់ប្រព្រឹត្តកុមារីព្រហ្មចរិយ ក្នុងព្រះរាជនិវេសន៍អស់ ២០.០០០ ឆ្នាំ រួមជាមួយបងប្អូនព្រះនាងទាំងនោះ សាងបរិវេណទីប្រថាប់នៅរបស់ព្រះទសពល វិលវល់នៅក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ។ ក្នុងពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងរាជត្រកូល នាក្រុងសាគលៈដែនមទ្ទៈ ព្រះញាតិថ្វាយព្រះនាមរបស់ព្រះនាងថា **ខេមា** ព្រះនាងមានព្រះឆវីវណ្ណនៃព្រះវរកាយរលោងដូចទឹកមាស ពេលចម្រើនព្រះជន្ម ស្ដេចក៏ទៅនៅក្នុងព្រះរាជនិវេសន៍ (ជាព្រះទេវី) របស់ព្រះបាទពិម្ពិសារ ។ កាលព្រះតថាគតទ្រង់ប្រថាប់នៅក្រុងរាជគ្រឹះ ក្នុងព្រះវេឡុវ័នវិហារ ព្រះនាងទ្រង់ស្ដាប់ថា គេថា ព្រះសាស្ដាទ្រង់សម្ដែងទោសក្នុងរូប ជាអ្នកស្រវឹងក្នុងរូបឆោម មិនហ៊ានទៅគាល់ព្រះទសពល ព្រោះទ្រង់ខ្លាចថា ព្រះសាស្ដាទ្រង់សម្ដែងទោសក្នុងរូបរបស់ព្រះនាង ។ ព្រះរាជាទ្រង់ព្រះតម្រិះថា យើងជាអគ្គឧបដ្ឋាករបស់ព្រះសាស្ដា តែអគ្គមហេសីរបស់អរិយសាវកដូចយើង ក៏មិនទាន់ទៅគាល់ព្រះទសពល ប្រការនេះ យើងមិនពេញចិត្តឡើយ ។ ទើបទ្រង់ឲ្យពួកកវីប្រព័ន្ធគុណសម្បត្តិរបស់ព្រះវេឡុវ័នរាជឧទ្យានត្រាស់បង្គាប់ថា ពួកអ្នកចូរច្រៀងជិតៗ ទីព្រះនាងខេមាទេវីឲ្យទ្រង់បានឮ ។ ព្រះនាងទ្រង់ស្ដាប់ពាក្យពណ៌នាគុណរបស់ព្រះរាជឧទ្យាន ក៏មានព្រះបំណងស្ដេចនឹងទៅ ទើបក្រាបទូលសាកសួរព្រះរាជា ។ ស្ដេចទ្រង់ត្រាស់ថា ទៅឧទ្យានក៏បាន

តែមិនគាល់ព្រះសាស្តាមិនបាន ត្រឡប់មកវិញ ព្រះនាងមិនថ្វាយពាក្យគបចំពោះព្រះរាជា ស្តេចក៏ទៅ ។ ព្រះរាជាត្រាស់បង្គាប់ពួករាជបុរសដែលទៅជាមួយព្រះនាងថា បើព្រះទេវីកាលនឹងត្រឡប់ពីឧទ្យាន គាល់ព្រះទសពលបានយ៉ាងនេះ ក៏ជាបុណ្យ បើមិនគាល់ ពួកអ្នកក៏ចូរប្រើរាជអាជ្ញាសម្តែងចំពោះព្រះនាង ។ គ្រានោះ ព្រះនាងស្តេចរីករាយក្នុងព្រះរាជឧទ្យានដរាបអស់ថ្ងៃ កាលស្តេចត្រឡប់ក៏មិនគាល់ព្រះទសពល ផ្តើមនឹងស្តេចត្រឡប់ ។ តែពួករាជបុរសនាំព្រះនាងទៅកាន់សំណាក់ព្រះសាស្តា ទាំងដែលព្រះនាងមិនពេញព្រះទ័យ ។

ព្រះសាស្តាទ្រង់ឃើញព្រះនាងកំពុងស្តេចមក ទើបទ្រង់ប្រើពុទ្ធឫទ្ធិនិម្មិតទេពអប្សរមួយអង្គ ដែលកំពុងកាន់ផ្លិតស្ទឹកត្នោតបក់ថ្វាយ ។ ព្រះនាងខេមាទេវីឃើញទេពអប្សរនោះហើយ ទ្រង់ត្រិះរិះថា យើងវិនាសហើយ ពួកស្ត្រីដែលប្រៀបដូចទេពអប្សរបែបនេះ ឈរមិនឆ្ងាយពីព្រះទសពល សូម្បីយើងនឹងជាបរិចារិការបស់ស្ត្រីទាំងនោះ ក៏មិនជាគួឡើយ ក៏ព្រោះហេតុអ្វី ទើបយើងទោមនស្សដោយចិត្តដែលគិតអាក្រក់ ព្រោះអាស្រ័យសេចក្តីស្រវឹង ហើយក៏កាន់យកនិមិត្តនោះឈរទតព្រះនេត្រស្ត្រីនោះ ។ កាលព្រះនាងពិចារណាស្ត្រីនោះនុ៎ះឯង តែដោយកម្លាំងអធិដ្ឋានរបស់ព្រះតថាគត ស្ត្រីនោះកន្លងបឋមវ័យទៅ ហើយតាំងនៅក្នុងមជ្ឈិមវ័យ កន្លងមជ្ឈិមវ័យទៅ តាំងនៅក្នុងបច្ឆិមវ័យ ដូច្នោះ ប្រាកដជាអ្នកមាន

ស្បែកជ្រីវជ្រួញ សក់ស្កូវ ធ្មេញបាក់ហើយ ។ បន្ទាប់ពីនោះ កាលព្រះនាង កំពុងមើលទុំះឯង ស្ត្រីនោះក៏ដួលចុះ ព្រមទាំងផ្ទិតស្លឹកត្នោត ។ លំដាប់នោះ ព្រះនាងខេមា កាលអារម្មណ៍នោះមកកាន់វិថី ព្រោះជាអ្នកសម្បូរដោយបុព្វហេតុ ទើបទ្រង់ត្រិះរិះយ៉ាងនេះថា សរីរៈដែលមានសភាពយ៉ាងនេះ ក៏ដល់សេចក្ដីវិបត្តិ យ៉ាងនេះបាន សូម្បីសរីរៈរបស់យើង ក៏នឹងមានគតិយ៉ាងនេះដូចគ្នា ។ ខណៈ ដែលព្រះនាងមានការត្រិះរិះយ៉ាងនេះ ព្រះសាស្ដាទើបត្រាស់ព្រះគាថាក្នុងធម្មបទ នេះថា

យេ រាគរត្តានុបតន្តិ សោតំ សយំ កតំ មក្កដកោវ ជាលំ
ឯតម្បិ ឆេត្វាន បរិព្វជន្តិ អនបេក្ខិនោ កាមសុខំ បហាយ ។
ជនពួកណាត្រូវរាគៈជ្រលក់ហើយ រមែងធ្លាក់ទៅតាមក្រសែ
ដូចពីងពាងធ្លាក់ទៅតាមសរសៃសំណាញ់ដែលខ្លួនឯងធ្វើទុក
ជនទាំងនោះ កាត់ក្រសែនោះបានហើយ មិនជាប់ជំពាក់ លះ
កាមសុខចេញ រមែងបួស ដូច្នេះ ។

ចប់ព្រះគាថា ព្រះនាងដែលប្រថាប់ក្នុងឥរិយាបថឈរទុំះឯង ក៏សម្រេច ព្រះអរហត្តព្រមដោយបដិសម្ភិទា ធម្មតាថា អ្នកនៅគ្រប់គ្រងផ្ទះ សម្រេចព្រះ-អរហត្ត នឹងត្រូវបរិនិព្វាន ឬនឹងបួសក្នុងថ្ងៃនោះឯង ។ ក៏ព្រះនាងដឹងថា អាយុ

សន្ធាររបស់ព្រះនាងនៅប្រព្រឹត្តទៅបាន ទ្រង់ត្រិះរិះថា យើងនឹងឲ្យព្រះរាជាទ្រង់អនុញ្ញាតការបួស ទើបស្តេចត្រឡប់ទៅកាន់ព្រះរាជនិវេសន៍ មិនថ្វាយបង្គំព្រះរាជាប្រថាប់ឈរ ។ ព្រះរាជាក៏ទ្រង់ជ្រាបដោយសញ្ញាណ គឺ ព្រះអាការថា ព្រះនាងគង់នឹងសម្រេចអរិយធម៌ហើយ ។ ព្រះរាជាទើបត្រាស់ចំពោះព្រះនាងថា ព្រះទេវីនាងទៅគាល់ព្រះសាស្តាឬ? ទូលថា មហារាជ ខ្ញុំប្រព្រឹត្តទស្សនៈដូចដែលព្រះអង្គទ្រង់ឃើញហើយ ខ្ញុំបានធ្វើព្រះទសពលឲ្យជាអ្នកដែលខ្ញុំឃើញដោយល្អហើយ សូមទ្រង់មេត្តាអនុញ្ញាតការបព្វជ្ជាដល់ខ្ញុំចុះ ។ ព្រះរាជាត្រាស់ថា ល្អណាស់ព្រះទេវី ទ្រង់នាំទៅកាន់សំណាក់ភិក្ខុនីដោយអង្រឹងមាស ឲ្យព្រះនាងព្រះផ្នួស ។ គ្រានោះ ភាពដែលព្រះនាងមានព្រះបញ្ញាច្រើន ប្រាកដថា ឈ្មោះព្រះខេមាថេរីសម្រេចព្រះអរហត្តទាំងដែលនៅក្នុងភេទគ្រហស្ថ ក្នុងប្រការនេះមានរឿងដូច្នេះ ។ តមកខាងក្រោយ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវនវិហារ កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនា **ព្រះខេមាថេរី** ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកា អ្នកមានបញ្ញាច្រើន ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## "ប្រវត្តិព្រះនាងឧប្បលវណ្ណាថេរី"

*ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៥០] បទថា **ឧប្បលវណ្ណា** បានដល់ ព្រះថេរីមានឈ្មោះយ៉ាងនេះ ក៏ព្រោះប្រកបដោយពណ៌សម្បុរដូចត្របកផ្កាឧប្បល ។*

*បានឮថា ព្រះនាងឧប្បលវណ្ណាថេរីនោះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានបដិសន្ធិក្នុងត្រកូល នាក្រុងហង្សវតី ក្រោយមក ទៅកាន់សំណាក់ព្រះសាស្ដាព្រមទាំងមហាជន កំពុងស្ដាប់ធម៌ ឃើញព្រះសាស្ដាទ្រង់បានស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកមានឫទ្ធិ ទើបថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ប្រាថ្នាតំណែងនោះ ។ នាងធ្វើកុសលជាបអស់មួយជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស គ្រាព្រះពុទ្ធព្រះនាមថា **កស្សបៈ** បានបដិសន្ធិក្នុងរាជនិវេសន៍របស់ព្រះរាជាព្រះនាមថា កិកិ នាក្រុងពារាណសី ជាព្រះធីតាក្នុងរវាងបងប្អូនព្រះនាង ៧ ព្រះអង្គ ប្រព្រឹត្តព្រហ្មចរិយរហូតអស់ ២០.០០០ ឆ្នាំ ធ្វើបរិវេណថ្វាយភិក្ខុសង្ឃ ។ កើតក្នុងទេវលោក ចុតិចាកទេវលោកនោះ ទៅកាន់មនុស្សលោកទៀត កើតក្នុងអាវាស*

របស់អ្នកធ្វើការងារដោយដៃខ្លួនឯងចិញ្ចឹមជីវិត ក្នុងស្រុកមួយកន្លែង ថ្ងៃមួយ នាងទៅកាន់ខ្ទមស្រែ ឃើញផ្កាឈូករីកអំពីព្រឹកក្នុងស្រះមួយកន្លែងរវាងផ្លូវ ចុះស្រះនោះ ហើយបេះផ្កាឈូកនោះ និងស្លឹកឈូកមកដើម្បីដាក់លាច បានក្តិចគួរស្រូវសាលីជិតស្រែ អង្គុយក្នុងខ្ទមស្រែហើយបានលីងជាលាចរាប់បាន ៥០០ គ្រាប់ ។ ខណៈនោះ ព្រះបច្ចេកពុទ្ធមួយអង្គចេញចាកនិរោធសមាបត្តិឯភ្នំគន្ធមាទន៍ មកឈរមិនឆ្ងាយពីនាង ។ នាងក្រឡេកឃើញព្រះបច្ចេកពុទ្ធ ក៏កាន់ផ្កាឈូកព្រមទាំងលាចអំពីខ្ទម ដាក់លាចក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ បិទបាត្រដោយផ្កាឈូក ហើយថ្វាយ ។ គ្រានោះ កាលព្រះបច្ចេកពុទ្ធទៅបានបន្តិច នាងក៏គិតថា ធម្មតាពួកបព្វជិតមិនត្រូវការផ្កាឈើ យើងនឹងទៅយកផ្កាឈើមកប្រដាប់ ហើយទៅយកផ្កាឈើអំពីដៃព្រះបច្ចេកពុទ្ធ ហើយគិតទៀតថា បើលោកម្ចាស់មិនត្រូវការផ្កាឈើសោត លោកម្ចាស់នឹងមិនឲ្យដាក់ផ្កាឈើនោះទុកលើបាត្រ លោកម្ចាស់នឹងត្រូវការដោយពិត ហើយក៏ដាក់លើបាត្រវិញសូមខមាទោស ហើយធ្វើសេចក្តីប្រាថ្នាថា លោកម្ចាស់ ដោយផលានិសង្សនៃលាចទាំងនេះ សូមឲ្យខ្ញុំមានបុត្រស្មើនឹងចំនួនលាច ដោយផលានិសង្សរបស់ផ្កាឈូក សូមផ្កាឈូកចូរផុសឡើងគ្រប់ៗ ជំហានរបស់ខ្ញុំ ក្នុងទីដែលកើតហើយ ។ ទាំងដែលនាងឃើញហើយនុ៎ះឯង ព្រះបច្ចេក-ពុទ្ធក៏ទៅកាន់ភ្នំគន្ធមាទន៍ផ្លូវអាកាស ដាក់ផ្កាឈូកនោះទុកសម្រាប់ជូតជើង ជិត

ជណ្ដើរដែលព្រះបច្ចេកពុទ្ធទាំងឡាយជាន់ត្រង់ញកក្ដីទន្ទម្ពូលកៈ ដោយផលនៃទាន នោះ នាងបានបដិសន្ធិក្នុងទេវលោក ។ ចាប់ផ្ដើមតាំងពីវេលាដែលនាងកើត ផ្កាឈូកខ្ចាតធំក៏ផុសឡើងគ្រប់ៗ ជំហានរបស់នាង ។

នាងចុតិចាកទេវលោកនោះហើយ ក៏កើតនៅក្នុងផ្កាឈូក ក្នុងស្រះឈូក មួយកន្លែងជិតជើងភ្នំដែលតាបសមួយអង្គអាស្រ័យនៅ ។ តាបសនោះទៅកាន់ ស្រះពីព្រឹកព្រលឹម ដើម្បីលុបលាងមុខ ឃើញផ្កាឈូកនោះហើយ ក៏គិតថា ផ្កា នេះធំជាងផ្កាដទៃៗ ផ្កាដទៃៗ រីក ផ្កានេះនៅតែក្ដោប ប្រាកដជាមានហេតុក្នុងផ្កា នោះ ទើបចុះទៅក្នុងទឹកចាប់ផ្កានោះ ។ ពេលតាបសនោះចាប់ប៉ុណ្ណោះ វាក៏រីក ។ តាបសឃើញក្មេងស្រីដេកនៅខាងក្នុងផ្កាឈូក ក៏មានសេចក្ដីស្រឡាញ់ដូចជាធីតា ផ្ដើមតាំងពីបានឃើញ ទើបនាំទៅបណ្ណសាលាព្រមទាំងផ្កាឈូក ឲ្យដេកលើគ្រែ ។ ខណៈនោះ ដោយបុញ្ញានុភាពរបស់នាង ទឹកដោះក៏កើតត្រង់ម្រាមមេដៃតាបស ។ តាបសនោះ កាលផ្កាឈូកនោះស្វិត ក៏នាំផ្កាឈូកដទៃមកជំនួស ដើម្បីឲ្យក្មេងស្រី នោះដេក ។ រាប់តាំងពីក្មេងស្រីនោះអាចរត់លេងទៅមកបាន ផ្កាឈូកក៏ផុសគ្រប់ៗ ជំហាន ។ សម្បុរពណ៌នៃសរីរៈរបស់នាង ដូចជាផ្កាឈូក ។ ក្មេងស្រីនោះ មាន ពណ៌សម្បុរល្អលើសសម្បុររបស់មនុស្ស តែមិនល្អលើសសម្បុរទេវតា ។ កាល បិតាទៅស្វែងរកផលាផល ក្មេងស្រីនោះក៏ត្រូវទុកឲ្យនៅឯបណ្ណសាលា ។

កាលវេលាចម្រើនវ័យហើយ ថ្ងៃមួយ កាលបិតាទៅស្វែងរកផលាផល ព្រានព្រៃម្នាក់ឃើញនាងក៏គិតថា ដែលឈ្មោះថា ពួកមនុស្សរូបរាងយ៉ាងនេះមិនមាន ចាំយើងត្រូតមើលសាកសួរនាង ហើយអង្គុយរង់ចាំការមករបស់តាបស ។ កាលបិតាត្រឡប់មក នាងក៏ដើរតាមផ្លូវខាងក្រោយសួនទទួលផលាផលពីដៃរបស់តាបសនោះមកដោយខ្លួនឯង ហើយសម្ដែងវត្តដែលខ្លួនគប្បីធ្វើដល់តាបសដែលអង្គុយចុះហើយ ។ គ្រានោះ ព្រានព្រៃក៏ដឹងថា នាងជាមនុស្ស ទើបថ្វាយបង្គំតាបសហើយអង្គុយចុះ តាបសទទួលដោយផ្លែឈើ មើមឈើ និងទឹកផឹក ហើយសួរថា បុរសដ៏ចម្រើន លោកនឹងសម្រាកក្នុងទីនេះ ឬនឹងទៅ ។ គេឆ្លើយថា នឹងទៅលោកម្ចាស់ នៅក្នុងទីនេះនឹងធ្វើអ្វីបាន ។ តាបសហាមថា ហេតុដែលលោកឃើញហើយនេះ កុំនិយាយប្រាប់នរណាឡើយ ។ គេទទួលថា បើលោកម្ចាស់មិនបំណង នឹងនិយាយទៅធ្វើអ្វី ហើយថ្វាយបង្គំតាបស ធ្វើគ្រឿងសម្គាល់ដោយមែកឈើ ស្នាមជើង និងគ្រឿងសម្គាល់ត្រង់ដើមឈើទុក ក្នុងវេលាដែលនឹងមកទៀត ទើបចៀសចេញទៅ ។

នាយព្រានព្រៃនោះទៅក្រុងពារាណសី គាល់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា ហេតុអ្វី អ្នកទើបមក ។ ក្រាបទូលថា បពិត្រទេវៈ ខ្ញុំព្រះអង្គជាព្រានព្រៃរបស់ព្រះអង្គ ជួបឥត្ថីរតនៈដែលគួរអស្ចារ្យត្រង់ជើងភ្នំ ទើបមកគាល់ព្រះអង្គ ហើយ

ទូលរឿងទាំងអស់ថ្វាយ ។ ព្រះរាជាស្តាប់ពាក្យរបស់នាយព្រានព្រៃនោះហើយ ស្តេចប្រញាប់ទៅកាន់ជើងភ្នំ តាំងបន្ទាយសម្រាកក្នុងទីមិនឆ្ងាយ ទើបស្តេចយាង ព្រមដោយនាយព្រានព្រៃ និងពួករាជបុរសដទៃៗ ស្តេចទៅទីនោះ វេលាតាបស អង្គុយឆាន់អាហារ ទ្រង់អភិវាទបដិសណ្ឋារៈហើយប្រថាប់អង្គុយ ព្រះរាជាទ្រង់ ដាក់គ្រឿងបរិក្ខារសម្រាប់អ្នកបួសទុកទៀបជើងតាបស ត្រាស់ថា លោកម្ចាស់ ពួកយើងនឹងធ្វើអ្វីត្រឹមតែម្យ៉ាងក៏នឹងទៅ តាបសទូលថា មេត្តាប្រោសស្តេចទៅចុះ មហាបពិត្រ ។ ស្តេចត្រាស់ថា លោកម្ចាស់ ខ្ញុំនឹងទៅ បានជ្រាបថា បរិស័ទជា សត្រូវនៅជិតលោកម្ចាស់មាន បរិស័ទនោះ បានឈ្មោះថា ជាអ្នកធ្វើឲ្យការបដិ-បត្តិយឺតយូរសម្រាប់អ្នកបួសទាំងឡាយ សូមបរិស័ទនោះចូរចេញទៅជាមួយខ្ញុំចុះ លោកម្ចាស់ ។ តាបសទូលថា ដែលឈ្មោះថា ចិត្តរបស់ពួកមនុស្សក្រោចណាស់ អ្នក ស្ត្រីនេះនឹងនៅកណ្តាលពួកមនុស្សច្រើនៗ ដូចម្តេចបាន ។ ព្រះរាជត្រាស់ លួងលោមថា លោកម្ចាស់ តាំងពីខ្ញុំពេញចិត្តនាង ក៏នឹងតាំងនាងទុកក្នុងតំណែង ជាប្រធានរបស់មនុស្សដទៃៗ ហើយទំនុកបម្រុងទុក ។ តាបសស្តាប់ព្រះរាជ-តម្រាស់ហើយ ក៏ហៅធីតា ដោយឈ្មោះដែលតាំងទុកកាលនៅតូចថា **បទុមវតី** កូន ។ ដោយហៅពាក្យត្រឹមតែម្តង នាងក៏ចេញមកពីបណ្ណសាលាឈរសំពះបិតា ។ បិតាទើបពោលនឹងនាងថា កូនអើយ កូនចម្រើនវ័យហើយ គង់នឹងនៅក្នុងទីនេះ

មិនជាសុខ ផ្ដើមពីព្រះរាជាទ្រង់ជួបហើយ ចូរទៅជាមួយព្រះរាជាចុះណាកូន ។ នាងទទួលពាក្យបិតាថា ចា៎លោកពុក ថ្វាយបង្គំបិតា ហើយដើរទៅទាំងសេចក្ដីយំសោក ។ ព្រះរាជាទ្រង់ព្រះតម្រិះថា យើងនឹងយកចិត្តបិតារបស់ស្ដ្រីនេះ ទើបដាក់នាងទុកលើគំនរកហាបណៈ ហើយទ្រង់ធ្វើអភិសេក ។

ចាប់តាំងពីព្រះរាជាទ្រង់នាំនាងមកដល់នគររបស់ព្រះអង្គហើយ ក៏ទ្រង់មិនពេញព្រះទ័យនឹងស្ដ្រីដទៃៗ ឡើយ ទ្រង់អភិរម្យជាមួយព្រះនាងប៉ុណ្ណោះ ។ ពួកស្ដ្រីដទៃៗ ក៏ច្រណែន បំណងនឹងធ្វើព្រះនាងឲ្យបែកគ្នាជាមួយព្រះរាជា ទើបនាំគ្នាក្រាបទូលថា បពិត្រព្រះមហារាជ ស្ដ្រីនេះមិនមែនជាតិជាមនុស្សទេព្រះអង្គ ផ្កាឈូកទាំងឡាយដែលប្រាកដនៅក្នុងទីដែលពួកមនុស្សត្រាច់ទៅ ព្រះអង្គធ្លាប់ជួបឬទេ ស្រីនេះប្រាកដជាយក្ខិនីដោយពិត ទ្រង់បណ្ដេញវាឲ្យចេញទៅព្រះអង្គ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ស្ដ្រីទាំងនោះ ក៏ទ្រង់នៅស្ងៀម ។ លុះសម័យតមកស្រុកជាយដែនមានការកម្រើក ព្រះនាងបទុមវតីក៏ទ្រង់ព្រះគភ៌ចាស់ ព្រោះដូច្នោះព្រះរាជាទើបទ្រង់ទុកព្រះនាងក្នុងព្រះនគរ ស្ដេចទៅកាន់ស្រុកជាយដែន ។ គ្រានោះស្ដ្រីទាំងនោះ ទើបឲ្យទ្រព្យដល់ស្រីស្នំដែលនៅបម្រើព្រះនាងបង្គាប់ថា នាងចូរនាំទារករបស់ព្រះនាងក្នុងពេលប្រសូតិហើយ ចេញទៅ ចូរយកកំណាត់ឈើមួយលាបឈាមហើយដាក់ក្នុងទីជិតជំនួស ។ មិនយូរប៉ុន្មានព្រះនាងបទុមវតី ក៏ប្រសូតិ

ព្រះមហាបទុមកុមារនៅក្នុងព្រះគភ៌ព្រះអង្គតែមួយព្រះអង្គ ។ ក្រៅពីនោះ ទារក ៤៩៩ ព្រះអង្គ ក៏កើត ដោយសំសេទជកំណើត (កើតអំពីញើស) ក្នុងខណៈដែលព្រះមហាបទុមកុមារចេញចាកគភ៌របស់ព្រះមាតាហើយ ខណៈនោះ ស្ត្រីស្នំបម្រើព្រះនាងដឹងថា ព្រះនាងបទុមវតីមិនទាន់មានសតិ ក៏យកកំណាត់ឈើមួយលាបឈាមហើយដាក់ជិតព្រះនាង បានក៏ឲ្យសញ្ញាកំណត់ណាត់ដល់ស្ត្រីទាំងនោះ ស្ត្រីទាំង ៥០០ នាក់ ម្នាក់ៗ ក៏ទទួលទារកមួយព្រះអង្គ បញ្ជូនទៅសំណាក់របស់ពួកជាងក្រឡឹង ឲ្យនាំប្រអប់ទាំងឡាយមក ហើយឲ្យទារកតែមួយអង្គដេកក្នុងប្រអប់នោះ ធ្វើត្រាជាគ្រឿងសម្គាល់ទុកពីខាងក្រៅ ។ ចំណែកព្រះនាងបទុមវតី រឭកដឹងព្រះកាយហើយ សួរស្រីស្នំនោះថា ខ្ញុំប្រសូតិបុត្រហើយឬ ស្រីនោះក្រាបទូលព្រះនាងថា ព្រះនាងនឹងបានទារកអំពីណា មានតែទារកដែលចេញចាកព្រះគភ៌ព្រះនាងយ៉ាងនេះ ហើយក៏ដាក់កំណាត់ឈើដែលប្រឡាក់ឈាមទុកខាងព្រះភ័ក្ត្រ ។ ព្រះនាងទតឃើញហើយ ក៏ស្ងុតព្រះហឫទ័យ ត្រាស់ថា នាងចូរប្រញាប់យកកំណាត់ឈើនោះពុះចោលទៅ បើនរណាគេឃើញនឹងត្រូវខ្មាសគេពុំខាន ។ ស្ត្រីនោះស្តាប់ព្រះរាជសវនីយ៍ក៏ធ្វើជាប្រាថ្នាល្អ ពុះកំណាត់ឈើហើយដាក់ចង្ក្រានភ្លើង ។

ចំណែកព្រះរាជាស្តេចត្រឡប់ចាកស្រុកជាយដែនហើយ រង់ចាំនក្ខត្តឫក្ស ក៏បានតាំងបន្ទាយសម្រាកក្រៅព្រះនគរ គ្រានោះ ស្ត្រី ៥០០ នាក់ ក៏មកទទួលព្រះ

រាជា ក្រាបទូលថា បពិត្រព្រះមហារាជ ព្រះអង្គគង់នឹងទ្រង់មិនជឿខ្ញុំព្រះអង្គទាំងឡាយថា កាលខ្ញុំព្រះអង្គក្រាបទូលដូចជាមិនមានហេតុ សូមទ្រង់មេត្តាសាកសួរស្ត្រីស្នំបម្រើព្រះមហេសីមើល ព្រះទេវីប្រសូតិជាកំណាត់ឈើ ព្រះរាជាទ្រង់សាកសួរហេតុនោះហើយ ទ្រង់ព្រះតម្រិះថា ព្រះនាងប្រហែលជាមិនមែនជាតិមនុស្សទេ ដូច្នេះ ហើយទ្រង់បណ្តេញព្រះនាងចេញពីព្រះរាជនិវេសន៍ ។ ពេលព្រះនាងស្តេចចេញចាកព្រះរាជនិវេសន៍ប៉ុណ្ណោះ ផ្កាឈូកទាំងឡាយក៏អន្តរធានទៅ ព្រះសរីរៈក៏មានពណ៌សម្បុរប្រែកទៅ ព្រះនាងទ្រង់ដំណើរទៅតាមផ្លូវតែមួយព្រះអង្គឯង គ្រានោះ ស្រីមានវ័យចំណាស់ម្នាក់ ក្រឡេកឃើញព្រះនាងក៏កើតស្រឡាញ់ក្នុងព្រះនាងហាក់ដូចជាធីតា ទើបនិយាយថា កូនស្រីទៅទីណា ព្រះនាងត្រាស់ថា ខ្ញុំជាអ្នកដំណើរ កំពុងត្រាច់ដើររកទីនៅ ស្ត្រីជរានិយាយថា មកនៅទីនេះចុះ ហើយឲ្យទីនៅ ចាត់ចែងអាហារឲ្យសោយ ។

កាលព្រះនាងនៅក្នុងទីនោះដោយទំនងនេះ ស្ត្រី ៥០០ នាក់នោះ ក៏រួមគំនិតគ្នាក្រាបទូលព្រះរាជាថា បពិត្រមហារាជ កាលព្រះអង្គប្រថាប់សម្រាកនៅឯបន្ទាយ ពួកខ្ញុំព្រះអង្គមានសេចក្តីប្រាថ្នាថា កាលរាជារបស់ពួកខ្ញុំព្រះអង្គឈ្នះសង្គ្រាមត្រឡប់មក នឹងទ្រង់លេងកីឡាផ្លូវទឹក ជាពលីកម្មដល់ទេវតាប្រចាំទន្លេគង្គា សូមទេវៈមេត្តាប្រោសប្រកាសឲ្យជ្រាបរឿងនេះចុះ ព្រះអង្គ ព្រះរាជារីករាយព្រះ

ហឫទ័យដោយពាក្យទូលរបស់ស្ត្រីទាំងនោះ ស្តេចទ្រង់ទៅលេងកីឡាផ្លូវទឹកក្នុងទន្លេគង្គា ស្ត្រីទាំងនោះកាន់ប្រអប់ពីអ្នកដែលរក្សាទុកយ៉ាងល្អទៅកាន់ទន្លេ ដណ្តប់បិទបាំងប្រអប់ទាំងនោះ ធ្វើជាធ្លាក់ទឹក ហើយទម្លាក់ចោលប្រអប់ទាំងនោះទៅ ប្រអប់ទាំងនោះមករួមគ្នាទាំងអស់វិញ ហើយជាប់នៅក្នុងសំណាញ់ដែលគេរាំងទុកខាងក្រោមក្រសែទឹក ។ តពីនោះ វេលាដែលព្រះរាជាទ្រង់លេងកីឡាផ្លូវទឹកស្តេចឡើងហើយ រាជបុរសទាំងឡាយក៏លើកសំណាញ់ឡើង ឃើញប្រអប់ទាំងនោះ ទើបនាំទៅកាន់រាជតំណាក់ ព្រះរាជាទតឃើញប្រអប់ទាំងឡាយ ទើបត្រាស់សួរថា អ្វីក្នុងប្រអប់ គេក្រាបទូលថា មិនទាន់ជ្រាបទេព្រះអង្គ ស្តេចទ្រង់ឲ្យបើកប្រអប់ទាំងនោះត្រួតមើល ទ្រង់ឲ្យ បើកប្រអប់ដាក់ព្រះមហាបទុមកុមារជាដំបូងក្នុងថ្ងៃនេះ ព្រះកុមារទាំងអស់ផ្ទុំនៅក្នុងប្រអប់ទាំងឡាយ ទឹកដោះក៏កើតត្រង់ម្រាមមេដៃ ដោយបុញ្ញឫទ្ធិ ស្តេចសក្កទេវរាជបង្គាប់ឲ្យចារឹកអក្សរទុកខាងក្នុងប្រអប់ដើម្បីកុំឲ្យព្រះរាជាសង្ស័យថា ព្រះកុមារទាំងនេះមិនប្រសូតិក្នុងព្រះគភ៌របស់ព្រះនាងបទុមវតី ជាឱរសរបស់ព្រះបាទក្រុងពារាណសី គ្រានោះស្ត្រី ៥០០ នាក់ ដែលជាសត្រូវរបស់ព្រះនាងបទុមវតី ដាក់ព្រះកុមារទាំងនោះទុកក្នុងប្រអប់ហើយ យកទៅបោះចោលក្នុងទឹក សូមព្រះរាជាមេត្តាជ្រាបហេតុនេះ ពេលបើកប្រអប់ ព្រះរាជាទ្រង់អានអក្សរទាំងឡាយហើយ ទតឃើញទារកទាំងឡាយ ទ្រង់លើកព្រះមហា-

បទុមកុមារឡើង ត្រាស់បង្គាប់ថា ចូរប្រញាប់ទឹមរថ ថ្ងៃនេះយើងនឹងចូលទៅក្នុងព្រះនគរ ធ្វើឲ្យជាទីស្រឡាញ់សម្រាប់មេផ្ទះពួកខ្លះ ហើយស្ដេចឡើងប្រាសាទ ទ្រង់ដាក់ថង់ទ្រព្យ ១.០០០ កហាបណៈ ទុកលើ.កដំរី ប្រោសឲ្យវាយស្គរប្រកាសថា បើអ្នកណាបានឃើញព្រះនាងបទុមវតី អ្នកនោះចូរទទួលថង់ទ្រព្យ ១.០០០ កហាបណៈនោះចុះ ៗ

ព្រះនាងបទុមវតី ទ្រង់បានឮពាក្យប្រកាសនោះហើយ បានឲ្យសញ្ញាដល់មាតាថា ម៉ែ ចូរទទួលថង់ទ្រព្យ ១.០០០ កហាបណៈ ពី.កដំរីចុះ ៗ ស្ត្រីជរាពោលថា ម៉ែមិនអាចទទួលទ្រព្យនោះបានទេ ៗ សូម្បីកាលមាតាបដិសេធ ២-៣ ដង ព្រះនាងក៏ត្រាស់ថា ម៉ែនិយាយអ្វី ទទួលយកចុះ ៗ ស្រីជរាគិតថា កូនរបស់យើងគង់ជួបព្រះនាងបទុមវតី ព្រោះដូច្នោះ ទើបពោលថា ទទួលយកក៏បាន ៗ ស្រីជរានោះគិតថា អ្វីក៏ដោយចុះ ទើបសម្រេចចិត្តដើរទៅយកថង់ទ្រព្យ ១.០០០ កហាបណៈ ៗ ខណៈនោះ មនុស្សទាំងឡាយនាំគ្នាសួរស្ត្រីជរានោះថា អ្នកម៉ែឃើញព្រះនាងបទុមវតីទេឬ ៗ ស្រីជរាឆ្លើយថា ខ្ញុំមិនឃើញទេ តែកូនស្រីរបស់ខ្ញុំឃើញ ៗ មនុស្សទាំងនោះសួរថា ក៏កូនស្រីរបស់អ្នកម៉ែនៅទីណា ហើយក៏ដើរទៅជាមួយស្ត្រីជរានោះ ចាំព្រះនាងបទុមវតីបាន ក៏នាំគ្នាក្រាបទៀបយុគលបាទ ៗ ក្នុងវេលានោះ ស្ត្រីជរានោះក៏ចន្លុលថា នេះព្រះនាងបទុមវតីទេវី ហើយពោលថា

ខ្ញុំជាស្រីធ្វើកម្មធ្ងន់ណាស់ដល់ព្រះមហេសីរបស់ព្រះរាជា ឲ្យនៅប្រាសចាកការរក្សាក្នុងទីបែបនេះ ។ រាជបុរសទាំងនោះ យកវាំងននលោមព័ទ្ធជានិវេសន៍របស់ព្រះនាងបទុមវតី ចាត់ចែងកងរក្សាទុកជិតទ្វារហើយ ក៏ក្រាបទូលចំពោះព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនសុវណ្ណសីវិកា (អង្រឹងមាស) ទៅទទួល ។ ព្រះនាងត្រាស់បង្គាប់ថា យើងនឹងមិនទៅយ៉ាងនេះទេ បើពួកលោកក្រាលកម្រាលដ៏វិចិត្រដោយសំពត់សំបកឈើដ៏ល្អ តាំងពីទីនៅរបស់យើងដរាបដល់ព្រះរាជនិវេសន៍ ឲ្យមានពិតានសំពត់ដ៏វិចិត្រដោយផ្កាយមាសទុកខាងលើ ហើយបញ្ជូនអាភរណៈគ្រប់យ៉ាងដើម្បីប្រដាប់មក យើងនឹងដើរទៅដោយជើង អ្នកព្រះនគរនឹងឃើញសម្បត្តិរបស់យើងយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរធ្វើតាមការពេញចិត្តរបស់បទុមវតីចុះ ។ តពីនោះ ព្រះនាងបទុមវតីទ្រង់ត្រិះរិះថា យើងនឹងប្រដាប់គ្រឿងប្រដាប់គ្រប់យ៉ាងដើរទៅព្រះរាជនិវេសន៍ ហើយស្ដេចធ្វើដំណើរ ។ គ្រានោះ ផ្កាឈូកទាំងឡាយក៏ជ្រែកកម្រាលដ៏វិចិត្រដោយសំពត់សំបកឈើយ៉ាងល្អ ផុសឡើងក្នុងទីគ្រប់ជំហានទ្រព្រះបាទរបស់ព្រះនាង ។ ព្រះនាងគ្រាស់ម្ដែងសម្បត្តិរបស់ព្រះនាងដល់មហាជនហើយ ស្ដេចឡើងកាន់ព្រះរាជនិវេសន៍ ប្រោសប្រទានកម្រាលដ៏វិចិត្រទាំងអស់ជាតម្លៃចិញ្ចឹមដល់ស្ដ្រីជរានោះ ។

ព្រះរាជាត្រាស់ឲ្យហៅស្ត្រី ៥០០ នាក់មក ហើយត្រាស់ថា ម្នាលទេវី យើង

ឱស្ត្រីទាំងនេះជាទាសីរបស់នាង ។ ព្រះនាងទូលថា ថ្វាយព្រះពរ នាងខ្ញុំម្ចាស់សូមឲ្យទ្រង់ប្រកាសឲ្យអ្នកក្រុងទូទៅបានជ្រាបថា ស្ត្រីទាំងនេះ ព្រះអង្គបានព្រះរាជទានដល់នាងខ្ញុំហើយ ។ ព្រះរាជាក៏ឲ្យវាយស្គរប្រកាសថា ស្ត្រី ៥០០ នាក់ ដែលប្រទូសចំពោះព្រះនាងបទុមវតី យើងឲ្យជាទាសីរបស់ព្រះនាងតែមួយអង្គ ។ ព្រះនាងបទុមវតីនោះ ទ្រង់ជ្រាបថា ក្នុងទូទាំងនគរបានដឹងថា ស្ត្រីទាំងនោះជាទាសីហើយ ទើបទូលសួរព្រះរាជាថា បពិត្រទេវៈ នាងខ្ញុំម្ចាស់នឹងធ្វើទាសីរបស់នាងខ្ញុំម្ចាស់នេះ ឲ្យជាអ្នកគ្មានបំណុលបានទេ ថ្វាយព្រះពរ ។ ព្រះរាជាត្រាស់បង្គាប់ថា ទេវីនាងត្រូវការក៏បាន ។ ព្រះនាងក្រាបទូលថា បើដូច្នោះ សូមបានទ្រង់មេត្តាប្រោសឲ្យហៅអ្នកវាយស្គរប្រកាស បង្គាប់ឲ្យគេវាយស្គរប្រកាសទៀតថា ពួកទាសីដែលព្រះអង្គព្រះរាជទានដល់ព្រះនាងបទុមវតី ព្រះនាងធ្វើឲ្យជាអ្នកគ្មានបំណុលទាំងអស់ ៥០០ នាក់ហើយ ។ កាលស្ត្រីទាំងនោះជាអ្នកគ្មានបំណុលហើយ ព្រះនាងក៏ប្រគល់ព្រះឱរស ៤៩៩ ព្រះអង្គ ឲ្យស្ត្រីទាំងនោះចិញ្ចឹមរក្សា ចំណែកព្រះអង្គឯង ទ្រង់ទទួលចិញ្ចឹមរក្សាចំពោះព្រះមហាបទុមកុមារប៉ុណ្ណោះ ។ កាលដល់វេលាព្រះរាជ-កុមារទាំងនោះទ្រង់លេងបាន ព្រះរាជាក៏ប្រោសឲ្យសាងកន្លែងលេងផ្សេងៗ ទុកក្នុងព្រះរាជឧទ្យាន ។ ព្រះរាជកុមារទាំងនោះ មានព្រះជន្មបាន ១៦ វស្សា គ្រប់ព្រះអង្គក៏នាំគ្នាចុះលេងក្នុងស្រះបោក្ខរណីមង្គល ដែលពេញពាសដោយបទុមក្នុង

ព្រះរាជឧទ្យាន ទ្រង់ឃើញបទុមផ្កាថ្មីរីក ផ្កាចាស់កំពុងជ្រុះចាកទង ក៏ពិចារណា ឃើញថា ផ្កាបទុមនេះមិនមានចិត្តគ្រប់គ្រង នៅតែប្រសព្វជរាបែបនេះ នឹងចាំបាច់ ពោលទៅថ្វីដល់សរីរៈរបស់ពួកយើងហ្ន៎ សូម្បីសរីរៈនេះ ក៏គង់នឹងមានគតិយ៉ាងនេះ ដូចគ្នា ហើយទ្រង់កាន់យកជាអារម្មណ៍ គ្រប់ព្រះអង្គក៏ញុំាងបច្ចេកពុទ្ធញាណ បាន នាំគ្នាឡើងអំពីទឹក ប្រថាប់អង្គុយពត់ភ្នែនត្រង់ត្របកផ្កាបទុម ខណៈនោះ ពួករាជ-បុរសដែលទៅជាមួយព្រះរាជកុមារទាំងនោះដឹងថា ដល់វេលាល្ងាចហើយ ទើប ទូលថា លោកកូន សូមទ្រង់ប្រោសជ្រាបនូវវេលារបស់ព្រះអង្គ ។ ព្រះរាជកុមារ ទាំងអស់នោះក៏ទ្រង់ស្ងៀម ។ រាជបុរសទាំងនោះ ក៏នាំគ្នាទៅក្រាបទូលព្រះរាជាថា បពិត្រទេវៈ ព្រះរាជកុមារទាំងឡាយប្រថាប់អង្គុយក្នុងត្របកផ្កាបទុម កាលពួកខ្ញុំ ព្រះអង្គក្រាបទូល ក៏ទ្រង់មិនថ្លែងព្រះវាចាឡើយ ។ ព្រះរាជាត្រាស់ថា ពួកអ្នក ចូរឲ្យពួកគេអង្គុយតាមពេញចិត្តចុះ ។ ព្រះរាជកុមារទាំងនោះ បានទទួលរក្សា រហូតអស់មួយយប់ទល់ភ្លឺ ក៏ប្រថាប់អង្គុយក្នុងត្របកផ្កាបទុមទំនងនោះឯង ដរាប អរុណរះ ពួករាជបុរសក៏ត្រឡប់ទៅ ស្អែកឡើង ទើបនាំគ្នាចូលទៅគាល់ទូលថា សូមទេវៈទាំងឡាយទ្រង់ជ្រាបវេលាចុះ ព្រះអង្គ ។ គ្រប់ព្រះអង្គត្រាស់ថា ពួក យើងមិនមែនទេវៈទេ ពួកយើងឈ្មោះថា ព្រះបច្ចេកពុទ្ធ ។ ពួកគេក្រាបទូលថា បពិត្រព្រះអយ្យបុត្តទាំងឡាយ ព្រះអង្គត្រាស់ព្រះតម្រាស់ធ្ងន់ណាស់ ព្រះអង្គ ។

ធម្មតាថា ព្រះបច្ចេកពុទ្ធទាំងឡាយមិនដូចជាព្រះអង្គទេ ត្រូវមានសក់ និងពុកមាត់ពុកចង្កា ២ អង្គុលី ព្រមទាំងបរិក្ខារ ៨ ចំណែកប៉ុណ្ណោះព្រះអង្គ ។ ព្រះរាជកុមារទាំងនោះ យកព្រះហស្តស្ទាបព្រះសិរសា ។ ភ្លាមនោះឯង ភេទគ្រហស្ថក៏អន្តរធានបាត់ទៅ ។ ក្លាយជាអ្នកមានបរិក្ខារ ៨ ប្រដាប់ព្រះវរកាយ ហើយក៏ស្ដេចទៅកាន់ញកភ្នំនន្ទមូលកៈ ទាំងដែលមហាជនកំពុងសម្លឹងមើលនុ៎ះឯង ។

ចំណែកព្រះនាងបទុមវតី ក៏ទ្រង់សោកសៅព្រះហឫទ័យថា យើងមានកូនច្រើន តែក៏នៅប្រាសចាកគ្នាទៅ ។ ស្ដេចទិវង្គតដោយព្រះរោគនោះឯង កើតក្នុងត្រកូលរបស់អ្នកធ្វើការដោយដៃខ្លួនឯងចិញ្ចឹមជីវិត ក្នុងស្រុកជិតទ្វារក្រុងរាជគ្រឹះ ។ តមក នាងមានស្វាមីហើយ ថ្ងៃមួយ កំពុងនាំបបរទៅឲ្យស្វាមី ក៏ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ នៅក្នុងចំនួនបុត្រទាំងនោះរបស់ខ្លួន ដែលកំពុងហោះក្នុងវេលាស្វែងរកអាហារ ទើបប្រញាប់ទៅប្រាប់ស្វាមីថា លោកប្ដីចូរមើលព្រះបច្ចេកពុទ្ធជាម្ចាស់ ជួយនិមន្តលោកមក យើងនឹងថ្វាយអាហារ ។ ស្វាមីនិយាយថា ដែលឈ្មោះថា ពួកសត្វក៏ហើរទៅយ៉ាងនោះ នោះមិនមែនព្រះបច្ចេកពុទ្ធទេ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ក៏ចុះក្នុងទីមិនឆ្ងាយអំពីអ្នកទាំង ២ នោះ ដែលកំពុងនិយាយគ្នា ។ ស្ត្រីនោះក៏ថ្វាយភោជន គឺ បាយ និងរបស់បរិភោគសម្រាប់ខ្លួនក្នុងថ្ងៃនោះ ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយនិមន្តថា ស្អែកនេះ លោកម្ចាស់ទាំង ៨ អង្គ សូម

មេត្តាទទួលអាហាររបស់ខ្ញុំម្ចាស់ផង ។ ព្រះបច្ចេកពុទ្ធទាំងនោះពោលថា ល្អណាស់ ឧបាសិកា ឧបាសិកាមានសក្ការៈ និងមានអាសនៈ ៨ កន្លែងប៉ុណ្ណោះ ក៏ពេលឃើញព្រះបច្ចេកពុទ្ធអង្គដទៃៗ បន្ថែមច្រើនឡើងៗ ក៏ចូរតាំងចិត្តរបស់ឧបាសិកាទុក ។ ថ្ងៃស្អែក នាងក៏ក្រាលអាសនៈទុក ៨ កន្លែង អង្គុយចាត់ចែងសក្ការៈសម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គ ។ ព្រះបច្ចេកពុទ្ធទាំងឡាយដែលទទួលនិមន្ត ទើបឲ្យសញ្ញាដល់ពួកព្រះបច្ចេកពុទ្ធក្រៅពីនោះថា អ្នកនិរទុក្ខទាំងឡាយ ថ្ងៃនេះកុំទៅទីដទៃ ចូរជួយគ្នាសង្គ្រោះញោមមាតារបស់ពួកលោកចុះ ។ ស្តាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធ ៨ អង្គនោះហើយ គ្រប់អង្គក៏ហោះទៅព្រមគ្នា ប្រាកដនៅត្រង់ទ្វារផ្ទះរបស់មាតា ។ សូម្បីនាងឃើញព្រះបច្ចេកពុទ្ធចំនួនច្រើនជាងសញ្ញាដែលបានទទួលគ្រាដំបូង ក៏មិនបានញាប់ញ័រ ។ និមន្តគ្រប់អង្គចូលទៅផ្ទះឲ្យគង់លើអាសនៈ ។ កាលព្រះបច្ចេកពុទ្ធកំពុងគង់តាមលំដាប់ អង្គទី ៩ ក៏និម្មិតអាសនៈបន្ថែម ៨ ទៀត ខ្លួនលោកក៏គង់លើអាសនៈទីឆ្ងាយ ។ ផ្ទះក៏រីកតាមអាសនៈបន្ថែមឡើង ។ កាលព្រះបច្ចេកពុទ្ធគ្រប់អង្គគង់យ៉ាងនោះហើយ ស្ត្រីនោះ ក៏ថ្វាយសក្ការៈដែលចាត់ចែងទុកសម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គ ដរាបគ្រប់ល្មមដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ហើយនាំយកផ្កាឈូកទាំង ៨ ផ្កា ដែលនៅក្នុងដៃ ដាក់ទុកទៀបព្រះបាទរបស់ព្រះបច្ចេកពុទ្ធដែលនិមន្តមកប៉ុណ្ណោះ ពោលអធិដ្ឋានថា លោកម្ចាស់ សូមសម្បុរកាយ

របស់ខ្ញុំម្ចាស់ ចូរដូចជាសម្បុរខាងក្នុងត្របកផ្កាឈូកទាំងនេះ ក្នុងទីដែលខ្ញុំម្ចាស់កើតហើយកើតទៀតចុះ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ទ្រង់អនុមោទនាដល់មាតាហើយក៏ទៅកាន់ភ្នំគន្ធមាទន៍ ។

សូម្បីស្ត្រីនោះ បានធ្វើកុសលរហូតអស់ជីវិត ចុតិចាកពីកពនោះហើយកើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងត្រកូលសេដ្ឋី នាក្រុងសាវត្ថី ។ ក៏ព្រោះនាងមានពណ៌សម្បុរស្មើដោយផ្កាឧប្បល ។ បិតាមាតាទើបនាមរបស់នាងថា **ឧប្បលវណ្ណា** ។ កាលនាងចម្រើនវ័យ ព្រះរាជាទូទៅជម្ពូទ្វីបក៏បញ្ជូនមនុស្សទៅកាន់សំណាក់សេដ្ឋីសូមនាង មិនមានរាជាព្រះអង្គណាដែលមិនបញ្ជូនមនុស្សទៅសូមទេ ។ តពីនោះ សេដ្ឋីគិតថា យើងមិនអាចឃាមចិត្តរបស់មនុស្សគ្រប់គ្នាបាន តែចាំយើងធ្វើឧបាយមួយ ទើបហៅធីតាមកសួរថា កូនបួសបានទេ ។ ព្រោះហេតុដែលនាងជាអ្នកមានជាតិចុងក្រោយ ពាក្យរបស់បិតានោះទើបដូចជាប្រេងរំងាស់ ១០០ ដង ស្រោចលើសីរសៈ ។ ព្រោះហេតុនោះ នាងទើបពោលនឹងបិតាថា បួសបានលោកពុក ។ សេដ្ឋីនោះ ទើបធ្វើសក្ការៈដល់នាងហើយនាំទៅកាន់សំណាក់ភិក្ខុនីឲ្យបួស កាលនាងបួសថ្មីៗ ដល់វេរៈក្នុងរោងឧបោសថ ។ នាងតាំងប្រទីប បោសរោងឧបោសថ កាន់យកនិមិត្តត្រង់អណ្តាតប្រទីបពិចារណារឿយៗ ក៏ធ្វើឈាន មានតេជោកសិណជាអារម្មណ៍ឲ្យឈានកើតឡើង

ហើយធ្វើឈាននោះឲ្យជាបាទ ក៏សម្រេចព្រះអរហត្ត ។ ព្រមដោយព្រះអរហត្ត-ផលនុ៎ះឯង ក៏ជាអ្នកជំនាញក្នុងការសម្តែងឫទ្ធិផ្សេងៗ ។ តមក ក្នុងថ្ងៃដែលព្រះសាស្តាទ្រង់ធ្វើយមកបាដិហារ្យ ព្រះនាងក៏បន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងធ្វើបាដិហារ្យថ្វាយ ។ ព្រះសាស្តាទ្រង់ធ្វើហេតុនេះ ឲ្យជាអត្ថុប្បត្តិ (ហេតុកើតរឿង) ប្រថាប់គង់ក្នុងព្រះជេតវនមហាវិហារ កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីនេះ ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកមានឫទ្ធិ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## “ប្រវត្តិព្រះនាងបដាចារាថេរី”

*ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *ដោយបទថា* ***វិនយធរានំ យទិទំ បដាចារា*** *បដាចារាភិក្ខុនី ប្រសើរជាងភិក្ខុនីដែលទ្រទ្រង់វិន័យ ។*

*ដូចបានស្តាប់មក ព្រះថេរីនោះ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *បាន បដិសន្ធិក្នុងត្រកូល នាក្រុងហង្សវតី ។ តមក កំពុងស្តាប់ព្រះធម៌ទេសនារបស់ ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាខាងទ្រទ្រង់វិន័យ ធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ នាងធ្វើកុសលដរាបអស់មួយជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស លុះមកដល់សម័យព្រះពុទ្ធព្រះនាមថា* ***កស្សបៈ*** *បានបដិសន្ធិក្នុង ព្រះរាជនិវេសន៍របស់ព្រះបាទកិកិ ជាធីតាមួយព្រះអង្គក្នុងចំណោមបងប្អូនព្រះនាង ៧ ព្រះអង្គ ប្រព្រឹត្តព្រហ្មចរិយនៅដល់ ២០.០០០ ឆ្នាំ សាងបរិវេណថ្វាយភិក្ខុសង្ឃ កើតក្នុងទេវលោកទៀត សោយសម្បត្តិអស់មួយពុទ្ធន្តរ ។ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងត្រកូលសេដ្ឋី នាក្រុងសាវត្ថី ។*

តមក នាងចម្រើនវ័យហើយ បានធ្វើការស្រឡាញ់លួចលាក់ជាមួយអ្នកបម្រើម្នាក់ក្នុងផ្ទះ ។ ខាងក្រោយកំពុងនឹងមានស្វាមីដែលមានជាតិស្មើគ្នា (កាលជាខាងក្រោយ មាតាបិតារបស់នាងបានសម្រេចចិត្តលើកនាងឲ្យទៅបុរសកំលោះម្នាក់ដែលមានជាតិត្រកូលស្មើគ្នា)[១] នាងទើបបានធ្វើការណាត់ជាមួយបុរសដែលលួចលាក់នោះថា តាំងពីថ្ងៃស្អែកនេះទៅ អ្នកមិនបានឃើញខ្ញុំ សូម្បីនឹងប្រហារ ១០០ ដង បើអ្នកនៅស្រឡាញ់ខ្ញុំ ចូរនាំខ្ញុំចេញទៅឥឡូវនេះ ។ បុរសនោះបានស្តាប់ហើយក៏ព្រមព្រៀង ហើយក៏កាន់យកវត្ថុមានតម្លៃល្មមសមគួរនឹងទៅ នាំនាងចេញទៅចម្ងាយ ៣-៤ យោជន៍ពីព្រះនគរ អាស្រ័យនៅក្នុងស្រុកមួយ ។ តមកខាងក្រោយ នាងតាំងគភ៌ កាលគភ៌ចាស់ទើបពោលថា ទីនេះមិនសមគួរដល់យើង ខ្ញុំនឹងទៅផ្ទះត្រកូលនាយ ។ គេក៏និយាយបណ្តោះបណ្តៃថា ថ្ងៃនេះនឹងទៅ ស្អែកនេះនឹងទៅ តែក៏មិនបានទៅដរាបកន្លងវេលាទៅ ។ នាងដឹងហេតុរបស់ស្វាមីនោះគិតថា ស្វាមីនេះល្ងង់ខ្លៅទើបមិននាំយើងទៅ កាលស្វាមីនោះចេញទៅក្រៅផ្ទះ ទើបដើរទៅតែម្នាក់ឯង ដោយបំណងនឹងត្រឡប់ទៅកាន់ត្រកូល ។ ស្វាមីត្រឡប់មកមិនឃើញនាងក្នុងផ្ទះ ទើបសួរអ្នកដែលស្និទ្ធស្នាលគ្នា ដឹងថា នាងត្រឡប់ទៅកាន់ត្រកូល ក៏គិតថា នាងជាធីតានៃត្រកូល អាស្រ័យយើងមិនមានទីពឹងឡើយ

---

១- សេចក្តីក្នុងអដ្ឋកថា ដូចមានខាងដើម ឯក្នុងវង់ក្រចកជាសេចក្តីដែលប្រែក្នុងប្រវត្តិពុទ្ធសាវិកា។

ទើបដើរតាមស្នាមជើងដរាបទាន់ នាងក៏ប្រសូតិបុត្រក្នុងចន្លោះផ្លូវនុ៎ះឯង ។ ទាំងពីរ ស្វាមីភរិយាប្រឹក្សាគ្នាថា ប្រយោជន៍ដែលយើងគប្បីដើរផ្លូវ ក៏សម្រេចហើយក្នុង រវាងផ្លូវ យើងនឹងទៅធ្វើអ្វី ទើបនាំគ្នាត្រឡប់ ។ នាងក៏តាំងគភ៌ទៀត ។ គប្បី ធ្វើរឿងឲ្យពិស្តារតាមន័យមុននុ៎ះឯង ។

តែក្នុងរវាងផ្លូវ ពេលនាងប្រសូតិបុត្រ ភ្លៀងក៏ធ្លាក់មកទាំង ៤ ទិស នាង ទើបពោលនឹងស្វាមីថា នាយ មិនមែនវេលាទេ ភ្លៀងក៏ធ្លាក់មកទាំង ៤ ទិស ចូរ ព្យាយាមធ្វើទីនៅសម្រាប់ខ្លួនយើងចុះ ។ ស្វាមីទទួលថា នឹងធ្វើឥឡូវនេះ បាន យកកំណាត់ឈើមកធ្វើខ្ទម គិតថា នឹងរកស្មៅមកប្រក់បាំង ទើបកាត់ស្មៅត្រង់ ជើងដំបូកធំមួយកន្លែង ។ ពេលនោះ ពស់វែកដែលដេកក្នុងដំបូកក៏ខាំជើងគេ ។ បុរសអ្នកនោះ ក៏ដួលចុះទីនោះឯង ។ សូម្បីនាងគិតថា គេនឹងមក ។ រង់ចាំដរាប អស់មួយយប់ ក៏គិតទៀតថា គេគង់នឹងគិតថា យើងនេះជាស្រីអនាថា ពឹងមិន បាន ហើយលះបង់យើងចោលទុកក្នុងផ្លូវក៏គេចទៅ លុះភ្លឺច្បាស់ ក៏ស្រវាក្រោក ឡើង សម្លឹងមើលតាមស្នាមជើង ឃើញស្វាមីដួលចុះត្រង់ជើងដំបូក ក៏យំរៀបរាប់ ថា ព្រោះយើងគេទើបស្លាប់ ហើយយកកូនតូចបីដៃម្ខាង ដៃម្ខាងទៀតដឹកដៃកូនធំ ដើរទៅតាមផ្លូវ ក្នុងរវាងផ្លូវជួបស្ទឹងដែលមានទឹករាក់ៗ មួយខ្សែ គិតថា យើងមិន អាចនាំកូនទៅម្តងទាំងពីរនាក់ ទើបដាក់កូនធំទុកត្រើយនេះ នាំកូនតូចទៅត្រើយ

ឯណោះ ឲ្យដេកលើខ្នើយចាស់ៗ ហើយឆ្លងស្ទឹងបំណាននឹងមកនាំកូនម្នាក់ទៀត ។ វេលាដែលនាងមកដល់កណ្តាលស្ទឹង ស្ទាំងមួយក្បាលក៏មកឆាបយកក្មេងទៅដោយសម្គាល់ថា ជាដុំសាច់ ។ នាងក៏លើកដៃដេញស្ទាំង ។ កូនធំ ឃើញនាងធ្វើដៃយ៉ាងនោះ សម្គាល់ថា ម៉ែហៅ ក៏ចុះឆ្លងស្ទឹងធ្លាក់ទៅក្នុងក្រសែទឹក ក៏អណ្តែតទៅតាមក្រសែទឹក ។ កាលនាងឆ្លងមិនទាន់ដល់ទុំរឯង ស្ទាំងក៏ឆាបយកកូនតូចនោះទៅ ។ នាងសោយសោកដ៏ខ្លាំងក្លា ក្នុងរវាងផ្លូវក៏ដើរច្រៀងរៀបរាប់ដូច្នេះថា

**ឧភោ បុត្តា កាលកតា បន្ថេ មយ្ហំ បតី មតោ ។**

បុត្រពីរនាក់ក៏ស្លាប់ ស្វាមីយើងក៏ស្លាប់ហើយត្រង់ផ្លូវ ។

នាងរៀបរាប់យ៉ាងនេះរហូតដល់ក្រុងសាវត្ថី ទៅរកអ្នកដែលធ្លាប់ស្គាល់គ្នារបស់ត្រកូល ក៏កំណត់ចាំផ្ទះរបស់ខ្លួនមិនបាន ដោយអំណាចសេចក្តីសោក-សៅ សាកសួរថា ទីត្រង់នេះ មានត្រកូលឈ្មោះយ៉ាងនេះ ផ្ទះនៅឯណា ។ មនុស្សទាំងឡាយពោលថា នាងសួរដល់ត្រកូលនោះធ្វើអ្វី ផ្ទះជាទីនៅរបស់អ្នកទាំងនោះរលំហើយ ព្រោះខ្យល់ដ៏ខ្លាំង អ្នកទាំងនោះក្នុងផ្ទះនោះស្លាប់អស់ហើយ គេដុតអ្នកទាំងនោះលើជើងថ្ករតែមួយ ទាំងតូចទាំងអ្នកធំ មើលចុះ ផ្សែងភ្លើងប្រាកដនៅឡើយ ។ នាងស្តាប់ពាក្យប្រាប់ហើយ ក៏និយាយថា ពួកលោកនិយាយអ្វី ក៏ទ្រទ្រង់សំពត់ស្លៀករបស់ខ្លួនទុកមិនបាន ទំនងដូចថ្ងៃដែលកើតទុំរឯង លើកដៃ

ទាំងពីរទូញយំ ដើរទៅកន្លែងជើងថ្ករដុតពួកញាតិ ស្រែកយំរៀបរាប់រហូតគ្រប់គាថាថា

**ឧភោ បុត្តា កាលកតា  បន្ថេ មយ្ហំ បតី មតោ**

**មាតា បិតា ច ភាតា ច  ឯកចិត្តកស្មឹ ឌយ្ហរេ ។**

បុត្រពីរនាក់ក៏ស្លាប់ ស្វាមីយើងក៏ស្លាប់ត្រង់ផ្លូវ មាតា

បិតា និងបងប្រុស គេក៏ដុតលើជើងថ្ករតែមួយ ។

ទាំងហែកសំពត់ដែលអ្នកដទៃឲ្យចេញទៀត ។ គ្រានោះ មហាជនក៏ដើរហែហមនាងក្នុងទីឃើញហើយ ។ មនុស្សទាំងឡាយទើបដាក់ឈ្មោះនាងថា **បដាចារា** ព្រោះនាង បដាចារានេះវៀរការស្លៀកសំពត់ដើរទៅ ។ មួយទៀត ព្រោះហេតុដែលប្រាកដឡើងថា នាងមានអាចារៈដែលមិនមានសេចក្តីខ្មាស ព្រោះជាអ្នកអាក្រាតកាយ ដូច្នោះ មនុស្សទាំងឡាយទើបដាក់ឈ្មោះនាងថា **បដាចារា** ។ ព្រោះមានអាចារៈដែលធ្លាក់ទៅហើយ ។ ថ្ងៃមួយ កាលព្រះសាស្តាទ្រង់កំពុងសម្តែងធម៌ដល់មហាជន នាងក៏ចូលទៅក្នុងព្រះវិហារឈរខាងក្រោយបរិស័ទ ព្រះសាស្តាទ្រង់ផ្សាយព្រះមេត្តាត្រាស់ថា ប្អូនស្រី ចូរត្រឡប់មានសតិ ប្អូនស្រី ចូរត្រឡប់មានសតិចុះ ។ ព្រោះស្តាប់ព្រះពុទ្ធតម្រាស់ ហិរិឱត្តប្បៈមានកំលាំងក៏ត្រឡប់មានមក ។ នាងក៏អង្គុយចុះត្រង់ទីនោះឯង ។ បុរសម្នាក់ដែលឈរមិនឆ្ងាយ ក៏បោះ

សំពត់ស្លៀកទៅឲ្យ ។ នាងស្លៀកសំពត់នោះហើយក៏ស្តាប់ធម៌ ។ ព្រោះចរិយារបស់នាង ព្រះសាស្តាទើបត្រាស់ព្រះគាថាក្នុងព្រះធម្មបទ ដូច្នេះថា ៖

ន សន្តិ បុត្តា តាណាយ   ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស   នត្ថិ ញាតីសុ តាណតា ។

មិនមានបុត្រនឹងជួយបាន បិតាក៏មិនបាន ផៅពង្សក៏មិនបាន
កាលបុគ្គលត្រូវសេចក្តីស្លាប់គ្របសង្កត់ហើយ ពួកញាតិក៏
ជួយមិនបានឡើយ ។

ឯតមត្ថវសំ ញត្វា   បណ្ឌិតោ សីលសំវុតោ
និព្វានគមនំ មគ្គំ   ខិប្បមេវ វិសោធយេ ។

បណ្ឌិតដឹងសេចក្តីពិតប្រការនេះហើយ សង្រួមក្នុងសីល
គប្បីប្រញាប់ស្រួសរាន់ជម្រះផ្លូវទៅព្រះនិព្វានតែម្យ៉ាង ។

ចប់ព្រះគាថា នាងក៏តាំងនៅក្នុងសោតាបត្តិផល ទាំងដែលឈរ ទើបចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលសូមបួស ។ ព្រះសាស្តាទ្រង់ទទួលការបួសរបស់នាងថា ទៅសំណាក់ភិក្ខុនីបួសចុះ ។ លុះនាងបួសហើយ មិនយូរប៉ុន្មានក៏សម្រេចព្រះអរហត្ត រៀនពុទ្ធវចនៈ ។ ព្រះនាងជាអ្នកជំនាញក្នុងវិន័យបិដក ។ ខាងក្រោយ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវនវិហារ កាលទ្រង់ស្ថាបនាពួក

ភិក្ខុនីទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះនាងបដាចារាថេរី ទុកក្នុងតំណែងឯតទគ្គៈប្រសើរជាងពួកភិក្ខុនីជាសាវិកាខាងទ្រទ្រង់វិន័យ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## “ប្រវត្តិព្រះធម្មទិន្នាថេរី”

*ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *ដោយបទថា* ***ធម្មកថិកានំ*** *លោកសម្តែងថា ព្រះធម្មទិន្នាថេរី ប្រសើរជាងពួកភិក្ខុនីជាសាវិកា ដែលជាធម្មកថិក ។*

*បានឮថា សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *ព្រះនាងកើតក្នុងត្រកូលដែលអាស្រ័យគេក្នុងក្រុងហង្សវតី បានធ្វើកុសលដ៏ក្រៃលែងដល់ព្រះសុជាតត្ថេរៈ អគ្គសាវករបស់ព្រះដ៏មានព្រះភាគព្រះនាមថា បទុមុត្តរៈ ហើយប្រាថ្នាតំណែងនោះ ព្រះនាងធ្វើកុសលរហូតអស់ជីវិត បានទៅកើតក្នុងសួគ៌ ។ គប្បីជ្រាបដូចអភិនិហាររបស់ព្រះខេមាថេរី ។ លុះក្រោយមក សម័យព្រះពុទ្ធព្រះនាមថា* ***បុស្សៈ*** *នាងក៏មករស់នៅក្នុងផ្ទះរបស់អ្នកធ្វើការងារ ដែលត្រូវតែងតាំងទុកក្នុងតំណែងជាធំក្នុងរឿងទាន របស់បងប្អូន ៣ នាក់ ផ្សេងមាតារបស់ព្រះសាស្តា ត្រូវបង្គាប់ថា ចូរឲ្យមួយ តែក៏ឲ្យពីរ ។ នាងថ្វាយទានគ្រប់យ៉ាងមិនបន្ថយយ៉ាងនេះ កន្លងកប្បទី ៩២ សម័យព្រះពុទ្ធព្រះនាមថា* ***កស្សបៈ*** *បានបដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ ជារាជធីតាមួយព្រះអង្គក្នុងចំណោមបងប្អូនព្រះនាង ៧*

ព្រះអង្គ ប្រព្រឹត្តព្រហ្មចរិយអស់ ២០.០០០ ឆ្នាំ សាងបរិវេណទៅថ្វាយព្រះភិក្ខុសង្ឃ វិលវល់នៅក្នុងទេវតា និងមនុស្សមួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះបានបដិសន្ធិក្នុងត្រកូលមួយ ។

ក្រោយមក នាងក៏វិសាខសេដ្ឋីជាស្វាមី ។ ឯវិសាខសេដ្ឋីលោកជាសម្លាញ់របស់ព្រះបាទពិម្ពិសារ ទៅគាល់ព្រះទសពលលើកដំបូងជាមួយព្រះបាទពិម្ពិសារស្ដាប់ធម៌ហើយតាំងនៅក្នុងសោតាបត្តិផល តមក ក៏ធ្វើឲ្យច្បាស់ព្រះអនាគាមិ-ផល ។ ថ្ងៃនោះ វិសាខសេដ្ឋីត្រឡប់មកផ្ទះ កាលព្រះនាងធម្មទិន្នា ដែលឈរត្រង់ក្បាលជណ្ដើរហុចដៃមក ក៏មិនចាប់ដៃឡើងប្រាសាទឡើយ សូម្បីកំពុងបរិ-ភោគក៏មិនប្រាប់ថា ចូរឲ្យវត្ថុនេះ ចូរនាំវត្ថុនេះមក នាងធម្មទិន្នាកាន់វែកនៅបម្រើហើយគិតថា សេដ្ឋីនេះកាលយើងហុចដៃឲ្យចាប់ ក៏មិនចាប់ កាលបរិភោគក៏មិននិយាយចរចាអ្វី យើងមានទោសកំហុសអ្វីឬហ្ន៎ លុះសេដ្ឋីបរិភោគហើយ នាងទើបសួរថា លោកម្ចាស់ ខ្ញុំមានកំហុសអ្វីឬ ។ សេដ្ឋីពោលថា ធម្មទិន្នា នាងមិនមានកំហុសអ្វីទេ ចាប់ពីថ្ងៃនេះទៅ ខ្ញុំមិនគួរអង្គុយ មិនគួរឈរ មិនគួរឲ្យនាំអាហារមកទំពារ មកបរិភោគជិតៗ នាង ដោយសេចក្ដីរីករាយទេ បើនាងប្រាថ្នាក៏ចូរនៅក្នុងផ្ទះនេះ បើមិនប្រាថ្នាក៏ចូរកាន់យកទ្រព្យតាមសេចក្ដីត្រូវការ ហើយត្រឡប់ទៅត្រកូលដើមវិញចុះ ។ នាងពោលថា អ្នកស្វាមី បើដូច្នេះ ខ្ញុំមិនយកក្បាលទូល

គំនរសំរាម ដែលប្រៀបផ្ទឹមដូចទឹកមាត់ដែលលោកស្តោះចោលហើយបានទេ ។ សូមតែលោកអនុញ្ញាតឲ្យខ្ញុំបានបួសចុះ ។ វិសាខសេដ្ឋីពោលថា ប្រពៃហើយធម្មទិន្នា ហើយក្រាបទូលព្រះរាជា យកអង្រឹងមាសបញ្ជូននាងធម្មទិន្នាទៅសម្នាក់ភិក្ខុនីដើម្បីបួស ។ នាងបួសហើយគិតថា ពីមុនសេដ្ឋីនេះនៅគ្រប់គ្រងផ្ទះ ក៏ធ្វើទីបំផុតទុក្ខបាន ចាប់តាំងពីបានបួសហើយ សូម្បីយើងក៏គួរនឹងធ្វើទីបំផុតទុក្ខបាន ទើបចូលទៅរកឧបជ្ឈាយ៍អាចារ្យពោលថា ម៉ែម្ចាស់ ចិត្តរបស់ខ្ញុំបង្អោនទៅក្នុងទីដែលធ្លាប់ទៅរឿយៗ ខ្ញុំនឹងទៅកាន់អាវាសជិតស្រុក ។ ព្រះថេរីទាំងឡាយមិនអាចហាមចិត្តរបស់នាងបាន ព្រោះនាងចេញបួសពីត្រកូលធំ ទើបនាំនាងទៅកាន់អាវាសជិតស្រុក ។ ព្រោះហេតុដែលនាងធ្លាប់ពិចារណាសង្ខារដែលទុក្ខបៀតបៀនហើយក្នុងអតីតកាល មិនយូរប៉ុន្មាន នាងក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។

គ្រានោះ ព្រះធម្មទិន្នាថេរីត្រិះរិះថា កិច្ចរបស់យើងដល់ទីបំផុតហើយ នៅក្នុងទីនេះនឹងមានប្រយោជន៍អ្វី យើងនឹងទៅក្រុងរាជគ្រឹះ ពួកញាតិជាច្រើនអាស្រ័យយើងក្នុងទីនោះនឹងនាំគ្នាធ្វើបុណ្យ ។ ហើយក៏នាំព្រះថេរីទាំងឡាយត្រឡប់មកកាន់ព្រះនគរ ។ វិសាខឧបាសកដឹងថា នាងត្រឡប់មក ក៏ប្រញាប់ទៅ សង្ស័យថា នាងគង់នឹងអផ្សុកទេដឹង វេលាល្ងាចក៏ចូលទៅកាន់សំណាក់នាង ថ្វាយបង្គំហើយ

អន្តរាយក្នុងទីដ៏សមគួរមួយ គិតថា នឹងសួរដល់សេចក្តីដែលនាងអផ្សុក មិនសមគួរ ទើបសួរបញ្ហាដោយអំណាចបញ្ចក្ខន្ធជាដើម ។ ព្រះធម្មទិន្នាថេរី ក៏វិសជ្ជនាបញ្ហាដែលវិសាខឧបាសកសួរហើយ ដូចយកព្រះខ័នកាត់ទងឈូកដូច្នោះ ។ ឧបាសកដឹងថា ព្រះធម្មទិន្នាថេរីមានញាណក្លៀវក្លា ទើបសួរបញ្ហាដោយអាការគ្រប់យ៉ាងក្នុងមគ្គ ៣ តាមលំដាប់ក្នុងឋានៈដែលខ្លួនសម្រេចហើយ ទាំងសួរបញ្ហាក្នុងអរហត្តមគ្គ ដោយអំណាចការរៀនសូត្រ ព្រះធម្មទិន្នាថេរីក៏ដឹងថា ឧបាសកនេះមានវិស័យត្រឹមតែអនាគាមិផលប៉ុណ្ណោះ គិតថា ឥឡូវនេះ ឧបាសកនឹងត្រាច់ហួសវិស័យរបស់ខ្លួនហើយ ទើបធ្វើឲ្យឧបាសកនោះត្រឡប់ ពោលថា វិសាខៈ លោកមិនទាន់អាចកំណត់ទីបំផុតនៃបញ្ហាទាំងឡាយបាន វិសាខៈ ក៏លោកញុំាងចំណង់ប្រាថ្នាព្រហ្មចរិយៈដែលឈានចុះកាន់ព្រះនិព្វាន មានព្រះនិព្វានជាខាងមុខ មានព្រះនិព្វានជាទីបំផុត វិសាខៈ លោកចូរទៅគាល់ព្រះដ៏មានព្រះភាគទូលសួរសេចក្តីនោះ ព្រះមានព្រះភាគទ្រង់ព្យាករណ៍យ៉ាងណា ក៏គប្បីចាំទុកយ៉ាងនោះ ។ វិសាខឧបាសកចូលទៅគាល់ព្រះសាស្តា ក៏ក្រាបទូលន័យនៃបុច្ឆា និងវិសជ្ជនាថ្វាយគ្រប់ប្រការ ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់វិសាខឧបាសកនោះហើយ ត្រាស់ថា ធីតារបស់តថាគតមិនមានតណ្ហាក្នុងខន្ធទាំងឡាយ ទាំងអតីត បច្ចុប្បន្ន និងអនាគត ហើយត្រាស់ព្រះគាថាក្នុងព្រះធម្មបទ ដូច្នេះថា ៖

*យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ*
*អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។*

*បុគ្គលណាមិនមានកិលេសជាគ្រឿងកង្វល់ ទាំងក្នុងអតីត ទាំងក្នុង*
*អនាគត ទាំងក្នុងបច្ចុប្បន្ន តថាគតហៅបុគ្គលនោះដែលមិនមាន*
*កិលេសជាគ្រឿងកង្វល់ មិនប្រកាន់មាំ ថាជាព្រាហ្មណ៍ ដូច្នេះ ។*

បន្ទាប់ពីនោះ ក៏ប្រទានសាធុការដល់ព្រះធម្មទិន្នាថេរី ហើយត្រាស់ចំពោះវិសាខឧបាសកថា វិសាខៈ ធម្មទិន្នាភិក្ខុនីជាបណ្ឌិត ធម្មទិន្នាភិក្ខុនីមានបញ្ញាច្រើន វិសាខៈ បើអ្នកគប្បីសួរសេចក្តីនោះដល់តថាគត ក៏តថាគតគប្បីព្យាករណ៍សេចក្តីយ៉ាងនោះ ដូចធម្មទិន្នាភិក្ខុនីព្យាករណ៍ទុកហើយ សេចក្តីនោះក៏ជាយ៉ាងនោះ អ្នកចូរចងចាំសេចក្តីនោះទុកយ៉ាងនោះចុះ ។ រឿងនេះតាំងឡើងដោយប្រការដូច្នេះ ។ តមក ព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតវនវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទ្រង់នាំចូលវេទល្លសូត្រនេះឯង ឲ្យជាអត្ថុប្បត្តិ “ហេតុកើតរឿង” ទើបទ្រង់ស្ថាបនាព្រះថេរីទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាដែលជាធម្មកថិក ក្នុងព្រះសាសនានេះ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ៦

## “ប្រវត្តិព្រះនន្ទាថេរី”

ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥០] ដោយបទថា **ឈាយីនំ យទិទំ នន្ទា** ទ្រង់សម្ដែងថា ព្រះនន្ទាថេរី ប្រសើរលើសពួកភិក្ខុនីសាវិកាអ្នកត្រេកអរក្នុងឈាន ។

ដូចបានស្ដាប់មក ព្រះនន្ទាថេរីនោះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានបដិសន្ធិក្នុងត្រកូល ក្នុងក្រុងហង្សវតី ។ តមក កំពុងស្ដាប់ធម្មកថា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរលើសពួកភិក្ខុនីសាវិកា អ្នកត្រេកអរក្រៃលែងក្នុងឈាន ទើបធ្វើកុសលដ៏ក្រៃលែងឡើងប្រាថ្នាតំណែងនោះ ។ បន្ទាប់ពីនោះ នាងក៏វិលវល់នៅក្នុងទេវតា និងមនុស្សរហូតអស់សែនកប្ប បានបដិសន្ធិក្នុងព្រះគភ៌របស់ព្រះមហាបជាបតីគោតមី មុនព្រះសាស្ដារបស់យើងឧប្បត្តិ ។ ព្រះញាតិថ្វាយព្រះនាមព្រះនាងថា **នន្ទា** ។ ហៅថា **រូបនន្ទា** ។ តមក ព្រះនាងបានឈ្មោះថា **ជនបទកល្យាណី** ព្រោះទ្រង់មានព្រះរូបឆោមល្អឆ្នើម ។ កាលព្រះទសពលរបស់យើងទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ស្ដេចយាងមកក្រុងកបិលពស្ដុ តាមលំដាប់ ទ្រង់ឲ្យព្រះនន្ទ និងព្រះ

រាហុលបួស ហើយស្តេចចៀសចេញទៅ ។ វេលាព្រះបាទសុទ្ធោទនមហារាជ បរិនិព្វានហើយ ព្រះនាងទ្រង់ជ្រាបថា ព្រះនាងមហាបជាបតីគោតមី និងព្រះមាតារបស់ព្រះរាហុល ស្តេចទ្រង់ចេញព្រះផ្នួសក្នុងសំណាក់ព្រះសាស្តា ទ្រង់ត្រិះរិះថា តាំងពីព្រះមាតាមហាបជាបតីគោតមី និងព្រះមាតាព្រះរាហុលទ្រង់ព្រះផ្នួសហើយ យើងនឹងមានការធ្វើអ្វីនៅក្នុងទីនេះ ទើបទៅសំណាក់ព្រះនាងមហាបជាបតីគោតមី ហើយក៏ទ្រង់ព្រះផ្នួស ។ ចាប់តាំងពីថ្ងៃដែលទ្រង់ព្រះផ្នួស ទ្រង់ជ្រាបថា ព្រះសាស្តាទ្រង់តិះដៀលរូប ទើបមិនទៅគាល់ព្រះសាស្តា ដល់វេលាទទួលព្រះឱវាទ ក៏ប្រាប់ភិក្ខុនីអន្តដទៃទៅ ហើយឲ្យនាំព្រះឱវាទមក ។ ព្រះសាស្តាទ្រង់ជ្រាបថា ព្រះនាងស្រវឹងក្នុងព្រះរូបឆោម ទើបត្រាស់ថា ភិក្ខុនីទាំងឡាយត្រូវមកទទួលឱវាទដោយខ្លួនឯង ឲ្យភិក្ខុនីអន្តដទៃទៅជំនួសមិនបាន ។ បន្ទាប់ពីនោះ ព្រះនាងរូបនន្ទាកាលមិនឃើញផ្លូវដទៃ ក៏ទៅទទួលព្រះឱវាទទាំងដែលមិនចង់ ។

ព្រះសាស្តា ទ្រង់និម្មិតរូបស្រីម្នាក់ដោយពុទ្ធឫទ្ធិ តាមចរិតរបស់ព្រះនាង ទ្រង់ធ្វើឲ្យដូចជាកាលស្រីនោះចាប់ផ្លិតស្លឹកត្នោតបក់ថ្វាយ ។ ព្រះនាងរូបនន្ទាឃើញស្រីនោះហើយ គិតថា យើងស្រវឹងព្រោះមិនមែនជាហេតុ ទើបមិនមក ។ សូម្បីស្រីនេះ ក៏បានស្និទ្ធស្នាលក្នុងសំណាក់ព្រះសាស្តា រូបរបស់យើងមិនដល់ចំណែកទី ១៦ នៃរូបរបស់ស្រីនេះ យើងមិនដឹងអ្វីសោះ ទើបយូរមកហើយបានជាមិនមក

កាន់យកឥត្ថីនិម្មិតនោះឯង ឈរពិចារណាមើល ។ ព្រោះព្រះនាងសម្បូរណ៍ដោយបុព្វហេតុយ៉ាងនោះ ព្រះសាស្តាទើបត្រាស់ព្រះគាថាក្នុងព្រះធម្មបទថា ***អដ្ឋីនំ នគរំ កតំ*** (ធ្វើឲ្យជានគរនៃឆ្អឹងទាំងឡាយ) ជាដើម ហើយត្រាស់ព្រះសូត្រថា ៖

***ចរំ វា យទិ វា តិដ្ឋំ និសិន្នោ ឧទ វា សយំ***

ដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តី ជាដើម ។

ព្រះនាងអស់សេចក្តីប្រាថ្នាក្នុងរូបនោះឯង សម្រេចព្រះអរហត្ត ។ រឿងនេះក្នុងទីនេះ លោកមិនបានធ្វើឲ្យពិស្តារ ព្រោះដូចគ្នានឹងរឿងរបស់ព្រះខេមាថេរី ។ តាំងពីនោះមក ព្រះរូបនន្ទាថេរីក៏បានសម្រេចធុរៈរវាងភិក្ខុនីអ្នកត្រេកអរក្រៃលែងក្នុងឈាន ។ ក្រោយមក ព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវនវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះនាងនន្ទាថេរី ទុកក្នុងតំណែងឯតទគ្គៈប្រសើរលើសពួកភិក្ខុនីជាសាវិកា ដែលជាអ្នកត្រេកអរក្នុងឈាន ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## “ប្រវត្តិព្រះសោណាថេរី”

*ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *បទថា* ***អារទ្ធវីរិយានំ យទិទំ សោណា*** *ទ្រង់សម្តែងថា ព្រះនាងសោណាថេរី ប្រសើរជាងពួកភិក្ខុនីជាសាវិកា អ្នកប្រារព្ធសេចក្តីព្យាយាម ។*

*បានឮថា* ***ព្រះសោណាថេរី*** *នេះ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *បានបដិសន្ធិក្នុងត្រកូល ក្នុងក្រុងហង្សវតី តមក កំពុងស្តាប់ធម៌របស់ព្រះសាស្តា ឃើញព្រះសាស្តាកំពុងទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកប្រារព្ធសេចក្តីព្យាយាម បានធ្វើកុសលដ៏ក្រៃលែង ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សរហូតអស់សែនកប្ប ។ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងត្រកូលមួយ នាក្រុងសាវត្ថី តមក នៅក្នុងឃរាវាសវិស័យ បានមានបុត្រធីតាច្រើន ក៏ឲ្យបុត្រគ្រប់គ្នាតាំងនៅក្នុងឃរាវាស-វិស័យដោយឡែកអំពីគ្នា ចាប់តាំងពីនោះ បុត្រទាំងនោះគិតថា ស្ត្រីម្នាក់នេះនឹងធ្វើអ្វីដល់ពួកយើង គ្រប់គ្នាមិនសម្គាល់ស្ត្រីដែលមកសំណាក់ខ្លួនថា ជាមាតា ។ នាងសោណាអ្នកមានបុត្រច្រើន ដឹងថា ពួកបុត្រមិនគោរពខ្លួន គិតថា យើងនឹងធ្វើអ្វី*

ដោយយកវាសវិស័យ ដូច្នេះ ហើយទើបចេញបួស ។ គ្រានោះ ភិក្ខុនីទាំងឡាយ ដាក់ទណ្ឌកម្មនាងថា ភិក្ខុនីរូបនេះមិនដឹងកិច្ចវត្ត ធ្វើកិច្ចដែលមិនគួរ ។ ពួកបុត្រធីតាជួបនាងត្រូវទណ្ឌកម្ម ក៏នាំគ្នានិយាយចំអកឡកឡឺយក្នុងទីជួបថា ស្រ្តីនេះមិនដឹងសូម្បីត្រឹមតែសិក្ខា រហូតរាល់ថ្ងៃនេះ ។ នាងបានឮពាក្យនិយាយរបស់បុត្រធីតាទាំងនោះ ក៏កើតសេចក្តីសង្វេគ គិតថា យើងគួរធ្វើការជម្រះគតិរបស់ខ្លួន ទើបទន្ទេញអាការ ៣២ ទាំងក្នុងទីអង្គុយ ទាំងក្នុងទីឈរ ។ ពីមុនប្រាកដឈ្មោះថា ព្រះសោណាថេរីអ្នកមានបុត្រច្រើន យ៉ាងណា ខាងក្រោយមកក៏ប្រាកដឈ្មោះថា ព្រះសោណាថេរីអ្នកប្រារព្ធសេចក្តីព្យាយាមច្រើន យ៉ាងនោះ ។ ក្រោយមកថ្ងៃមួយ ពួកភិក្ខុនីទៅវិហារប្រាប់ថា នាងសោណា ដាំទឹកថ្វាយភិក្ខុនីសង្ឃ ។ សូម្បីនាងក៏ដើរចង្រ្កមត្រង់រោងភ្លើងមុនទឹកក្តៅ ទន្ទេញអាការ ៣២ ចម្រើនវិបស្សនា ។ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិ ត្រាស់ព្រះគាថាព្រមទាំងឱភាសដូច្នេះថា ៖

យោ ច វស្សសតំ ជីវេ អបស្សំ ធម្មមុត្តមំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ធម្មមុត្តមំ ។

បុគ្គលឃើញធម៌ឧត្តម មានជីវិតរស់នៅមួយថ្ងៃប្រសើរជាង
បុគ្គលមិនឃើញធម៌ឧត្តម មានជីវិតរស់នៅសូម្បី ១០០ ឆ្នាំ ។

ចប់ព្រះគាថា នាងក៏សម្រេចព្រះអរហត្ត គិតថា យើងសម្រេចព្រះអរ-

ហត្ថហើយ បុគ្គលដើរមកមិនពិចារណាមុន និយាយអ្វីៗ មើលងាយយើង ក៏នឹងប្រសព្វបាបដ៏ច្រើន ព្រោះហេតុនោះ យើងគួរធ្វើហេតុដែលគេគប្បីកំណត់ដឹងបាន នាងទើបលើកកំសៀវទឹកឡើងតាំងលើចង្ក្រានភ្លើង មិនដាក់ភ្លើងពីខាងក្រោម ។ ពួកភិក្ខុនីមកឃើញតែចង្ក្រាន មិនឃើញភ្លើង ក៏ពោលថា ពួកយើងប្រាប់ឲ្យស្រ្តីចាស់នេះដាំទឹកថ្វាយភិក្ខុនីសង្ឃ សូម្បីថ្ងៃស្អីនេះ នាងក៏នៅមិនទាន់ដាក់ភ្លើងក្នុងចង្ក្រាន ។ នាងទើបពោលថា ម៉ែម្ចាស់ ព្រះនាងត្រូវការងូតទឹក ដោយទឹកក្តៅដោយភ្លើងឬ មេត្តាកាន់យកទឹកចាកពីភាជនៈហើយងូតចុះ ។ ភិក្ខុនីទាំងនោះទើបទៅ ដោយសម្គាល់ថា នឹងមានហេតុក្នុងរឿងនេះ ។ យកដៃលូកចុះក្នុងទឹក ក៏ដឹងថា ទឹកក្តៅ ទើបនាំថ្នាំងទឹកមួយមកលាយទឹក ។ កាលកាន់យកទឹកទៅហើយ ទឹកក៏ត្រឡប់ពេញទៀត ។ ខណៈនោះភិក្ខុនីទាំងអស់ក៏ដឹងថា នាងបានតាំងនៅក្នុងព្រះអរហត្ត ភិក្ខុនីដែលទាបជាងក៏ក្រាបចុះថ្វាយបង្គំទៀបជើងដោយបញ្ចង្គប្រតិស្ឋាន សូមខមាទោសមុនថា ម៉ែម្ចាស់ ពួកយើងមិនពិចារណាហើយពោលស៊ីកសៀត ម៉ែម្ចាស់ សូមម៉ែម្ចាស់មេត្តាអត់ទោសដល់ពួកយើងផងចុះ ។ ចំណែកពួកព្រះថេរីដែលចាស់ជាង ក៏អង្គុយប្រហោងសូមខមាទោសថា មេត្តាអត់ទោសផងចុះ ម៉ែម្ចាស់ ។ ចាប់តាំងពីនោះ គុណរបស់ព្រះថេរីក៏ប្រាកដថា ព្រះថេរីសូម្បីបួសវេលាចាស់ ក៏បានតាំងនៅក្នុងផលដ៏ប្រសើរក្នុងកាលមិនយូរ ព្រោះជាអ្នកប្រារព្ធសេចក្តី

ព្យាយាម ។ ខាងក្រោយមក ព្រះសាស្ដាប្រថាប់គង់ក្នុងព្រះជេតវនវិហារ កាល ទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះនាង សោណាថេរីទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកា អ្នកប្រារព្ធ សេចក្ដីព្យាយាម ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## "ប្រវត្តិព្រះសកុលាថេរី"

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥០] បទថា **ទិព្វចក្ខុកានំ យទិទំ សកុលា** ទ្រង់ត្រាស់ថា ព្រះនាងសកុលាថេរី ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកមានចក្ខុទិព្វ ។

បានឮថា **ព្រះនាងសកុលាថេរី** នេះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី ។ តមក កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកមានទិព្វចក្ខុ ធ្វើកុសលដ៏ក្រៃលែង ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សរហូតអស់សែនកប្ប ។ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូល ក្រុងសាវត្ថី តមក ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ។ បានសទ្ធាហើយក៏បួស មិនយូរប៉ុន្មាន ក៏សម្រេចព្រះអរហត្ត ។ តាំងពីនោះមក ព្រះនាងក៏ជាអ្នកជំនាញក្នុងទិព្វចក្ខុ ។ ក្រោយមក ព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវនវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងឯតទគ្គៈផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះថេរីនេះទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកា

*អ្នកមានចក្ខុទិព្វ ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

## “ប្រវត្តិព្រះភទ្ទាកុណ្ឌលកេសាថេរី”

*ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៥០] បទថា **ខិប្បាភិញ្ញានំ** ទ្រង់ត្រាស់ថា ព្រះភទ្ទាកុណ្ឌលកេសាថេរី ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកត្រាស់ដឹងរហ័ស ។*

*បានឮថា ព្រះភទ្ទាកុណ្ឌលកេសា នេះ កាលព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងផ្ទះត្រកូល ក្នុងក្រុងហង្សវតី ស្តាប់ធម៌របស់ព្រះសាស្តាហើយ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកត្រាស់ដឹងរហ័ស ទើបធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សរហូតអស់សែនកប្ប កាលនៃព្រះពុទ្ធព្រះនាមថា **កស្សបៈ** ជាព្រះធីតាមួយព្រះអង្គក្នុងរវាងបងប្អូនព្រះនាង ៧ ព្រះអង្គ ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ ។ សមាទានសីល ១០ ប្រព្រឹត្តកុមារីព្រហ្មចរិយអស់ ២០.០០០ ឆ្នាំ សាងបរិវេណថ្វាយសង្ឃ វិលវល់នៅក្នុងទេវតា និងមនុស្សមួយពុទ្ធន្តរ ។ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងត្រកូលសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ។ បិតាមាតាតាំងឈ្មោះនាងថា **ភទ្ទា** ។*

ក្នុងថ្ងៃដូចគ្នានោះឯង បុត្របុរោហិតក៏កើតក្នុងព្រះនគរនោះ ។ វេលាគេកើត អាវុធទាំងឡាយក៏ឆេះសន្ធោសន្ធៅទូទាំងព្រះនគរ តាំងពីព្រះរាជនិវេសន៍ជាដើមទៅ ។ បុរោហិតក៏ទៅរាជត្រកូលពីព្រឹកព្រលឹម ទូលសួរព្រះរាជាដល់ការផ្ទំជាសុខ ។ ព្រះរាជាត្រាស់ថា យើងនឹងដេកជាសុខបានអំពីណា អាចារ្យ យើងឃើញអាវុធទាំងឡាយក្នុងរាជនិវេសន៍ឆេះសន្ធោសន្ធៅរហូតមួយយប់ទល់ភ្លឺ ក្នុងថ្ងៃនេះ នឹងត្រូវប្រសព្វភ័យឬ ។ បុរោហិតក្រាបទូលថា បពិត្រមហារាជ ព្រះអង្គមេត្តាកុំទ្រង់ព្រះតម្រិះព្រោះប្រការនោះជាបច្ច័យឡើយ អាវុធទាំងឡាយមិនមែនឆេះសន្ធោសន្ធៅតែក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គប៉ុណ្ណោះ ទូទាំងព្រះនគរក៏ជាយ៉ាងនេះដែរ ព្រះអង្គ ។ ត្រាស់សួរថា ព្រោះហេតុអ្វី អាចារ្យ ។ ក្រាបទូលថា ក្នុងផ្ទះខ្ញុំព្រះអង្គ ក្មេងប្រុសកើតដោយឫក្សចោរ គេកើតនឹងជាសត្រូវទូទាំងព្រះនគរ ។ នោះជាបុព្វនិមិត្តរបស់គេ តែព្រះអង្គមិនមានអន្តរាយទេ តែបើទ្រង់នឹងព្រះបំណងក៏ទ្រង់ឲ្យសម្លាប់គេចុះ ។ ត្រាស់ថា កាលគេមិនបៀតបៀន យើងក៏មិនត្រូវសម្លាប់ទេ ។ បុរោហិតគិតថា បុត្រយើងកាន់យកឈ្មោះរបស់ខ្លួនមកផង ទើបតាំងឈ្មោះគេថា **សត្តុកៈ** ។ នាងភទ្ទាក៏ចម្រើនវ័យក្នុងផ្ទះសេដ្ឋី ។ សត្តុកៈក៏ចម្រើនក្នុងផ្ទះបុរោហិត ។ តាំងពីគេអាចលេងរត់លេងបាន គេនឹងនាំគ្រប់វត្ថុដែលគេជួបក្នុងទីដែលទៅ មកទុកពេញផ្ទះបិតាមាតា ។ បិតានិយាយចំពោះគេសូម្បីទាំង ១.០០០

ហេតុ ក៏ហាមប្រាមគេមិនបាន ។ តមក បិតាដឹងថា ហាមគេមិនបានដោយអាការទាំងពួង ទើបឲ្យសំពត់ខៀវដល់គេ ២ ផ្ទាំង ឲ្យគ្រឿងឧបករណ៍កាត់ជញ្ជាំង និងសិឃាតកយន្ត (ទំពក់កែច្នៃ) ទុកក្នុងដៃ ហើយបោះបង់គេទៅ ដោយពោលថា ឯងចូរចិញ្ចឹមជីវិតដោយការងារនេះចុះ ។ តាំងពីថ្ងៃនោះមក គេក៏គ្រវែងទំពក់ (នាំខ្លួន) ឡើងទៅលើប្រាសាទរបស់ត្រកូលទាំងឡាយ កាត់ប្រហោង (ទី.តផ្ទះ) លួចទ្រព្យរបស់ដែលគេរក្សាទុកក្នុងត្រកូលអ្នកដទៃ ដូចខ្លួនឯងរក្សាទុក ហើយក៏ទៅ ។ ទូទាំងព្រះនគរ ដែលឈ្មោះថា ផ្ទះខ្នងណាដែលគេមិនបានលួច មិនមានឡើយ ។ ថ្ងៃមួយ ព្រះរាជាស្តេចយាងទៅក្នុងព្រះនគរដោយរាជរថ ទើបត្រាស់សួរសារថីថា ហេតុដូចម្តេចហ្ន៎ ក្នុងផ្ទះនោះៗ ក្នុងព្រះនគរនេះ ទើបប្រាកដមានប្រហោងទាំងនោះ ។ សារថីក្រាបទូលថា បពិត្រទេវៈ ក្នុងព្រះនគរនេះ មានចោរឈ្មោះសត្តុកៈ កាត់ជញ្ជាំងផ្ទះលួចយកទ្រព្យរបស់ត្រកូលទាំងឡាយ ព្រះអង្គ ។ ព្រះរាជាទើបត្រាស់បង្គាប់ឲ្យរកនាយនគរបាល ហើយត្រាស់សួរថា គេថា ក្នុងព្រះនគរនេះមានចោរឈ្មោះយ៉ាងនេះ ហេតុអ្វី អ្នកទើបមិនចាប់វា ។ នាយនគរបាលក្រាបទូលថា បពិត្រទេវៈ ពួកខ្ញុំព្រះអង្គមិនដែលជួបចោរនោះ ព្រមទាំងភស្តុតាងនោះទេ ព្រះអង្គ ។ ត្រាស់បង្គាប់ថា បើថ្ងៃនេះ អ្នកជួបចោរនោះ ចូរចាប់ បើមិនចាប់ យើងនឹងដាក់អាជ្ញាអ្នក ។ នាយនគរបាលទូលទទួលថា ករុណាព្រះអង្គ ។

នាយនគរបាលបង្គាប់ឲ្យមនុស្សទូទាំងព្រះនគរ ដើរស៊ើបរកដរាបចាប់ខ្លួនចោរដែល កាត់ជញ្ជាំងផ្ទះលួចទ្រព្យគេ ព្រមទាំងភស្តុតាងនោះបាន នាំទៅបង្ហាញដល់ព្រះ រាជា ។ ព្រះរាជាត្រាស់បង្គាប់ថា ចូរនាំចោរនេះចេញតាមផ្លូវទ្វារទិសខាងត្បូង ហើយប្រហារចុះ ។ នាយនគរបាលទទួលព្រះរាជឱង្ការហើយ វាយចោរនោះ ១.០០០ ដង គ្រប់ៗ ផ្លូវបែកជាបួន ឲ្យនាំខ្លួនទៅតាមផ្លូវទ្វារទិសខាងត្បូង ។

សម័យនោះ កន្យាធីតាសេដ្ឋី បើកសីហបញ្ជរ (បង្អួច) មើល ព្រោះសំឡេង កោលាហលរបស់មហាជន ឃើញសត្តុកៈចោរ ត្រូវគេនាំទៅសម្លាប់ ក៏យកដៃទាំង ពីរផ្ទប់ទ្រូង ទៅដេកផ្កាប់មុខលើទីដេកដ៏មានសិរី ។ ក៏នាងជាធីតាតែមួយរបស់ ត្រកូលនោះ ។ ដោយហេតុនោះ ពួកញាតិរបស់នាងទើបទ្រាំមិនអាចឃើញមុខ ដែលស្រពាប់ស្រពោនសូម្បីបន្តិចបាន ។ គ្រានោះ មាតាឃើញនាងដេកលើទី ដេក ទើបសួរនាងថា កូនអើយ ឯងធ្វើអ្វី ។ នាងតបត្រង់ៗ ថា ម៉ែ ខ្ញុំជួបចោរ ដែលគេកំពុងនាំទៅសម្លាប់ កាលបានគេមកទើបនឹងរស់នៅបាន កាលខ្ញុំមិនបាន ស្លាប់វិញប្រសើរ ។ មាតាបិតាបានលួងលោមដោយប្រការផ្សេងៗ ក៏មិនអាច ឲ្យនាងព្រមបាន ទើបសម្រេចថា រស់នៅល្អជាងស្លាប់ ។ គ្រានោះបិតារបស់នាង ទើបទៅរកនាយនគរបាល សូក ១.០០០ កហាបណៈ ហើយប្រាប់ថា ធីតារបស់ យើងមានចិត្តជាប់ជំពាក់ក្នុងចោរ មេត្តាចូរលែងចោរនេះ ដោយឧបាយយ៉ាងណា

មួយចុះ ។ នាយនគរបាលទទួលមាត់សេដ្ឋីថា បាន ហើយនាំចោរបង្វិលបង្អែ បង្អន់ទៅផ្លូវនេះផ្លូវនោះខ្លះ ដរាបព្រះអាទិត្យលិច កាលព្រះអាទិត្យលិចហើយ ក៏ឲ្យនាំយកចោរម្នាក់ពីពួកចោរចេញមកធ្វើជាចោរ ដោះលែងសត្តុកៈចោរចេញពីគ្រឿងចង នាំទៅកាន់ផ្ទះសេដ្ឋី ហើយយកគ្រឿងចងនោះចងចោរម្នាក់ទៀត នាំចេញទៅតាមផ្លូវទ្វារទិសខាងត្បូង ប្រហារជីវិត (ជំនួស) ។ ឯពួកទាសៈរបស់សេដ្ឋីក៏នាំសត្តុកៈចោរមកកាន់ផ្ទះរបស់សេដ្ឋី ។ សេដ្ឋីឃើញគេហើយគិតថា យើងនឹងធ្វើធីតារបស់យើងឲ្យពេញចិត្ត ទើបឲ្យពួកទាសៈយកទឹកក្រអូបងូតសត្តុកៈចោរ ហើយឲ្យតុបតែងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់ប្រភេទ នាំទៅកាន់ប្រាសាទ ។ នាងកុណ្ឌលកេសីគិតថា សេចក្តីត្រិះរិះរបស់យើងសម្រេចហើយ ទើបតែងខ្លួនឲ្យស្រស់ប្រិមប្រិយ៍ដោយគ្រឿងអលង្ការច្រើនប្រភេទចាំបម្រើគេ ។

សត្តុកៈចោរ កាលកន្លងមកបាន ២-៣ ថ្ងៃ គិតថា គ្រឿងប្រដាប់របស់នាងនឹងជារបស់យើង យើងគួរនឹងកាន់យកគ្រឿងអាភរណៈនេះដោយឧបាយខ្លះ ហើយចេញ ដូច្នេះហើយ ពេលដល់វេលាអង្គុយជិតគ្នាយ៉ាងមានសេចក្តីសុខ ទើបនិយាយនឹងនាងកុណ្ឌលថា យើងមានរឿងដែលនឹងនិយាយមួយ ។ ធីតាសេដ្ឋីត្រេកអររីករាយដូចជាបានលាភទាំងពាន់ ទើបឆ្លើយថា លោកបង យើងស្និទ្ធស្នាលគ្នាហើយ លោកបងចូរប្រាប់មកចុះ ចោរពោលថា នាងគិតថា ចោរនេះបានជីវិតមក

ព្រោះអាស្រ័យនាង តែយើងពេលត្រូវចាប់នោះ បានអង្វរទេវតាដែលស្ថិតនៅត្រង់ភ្នំចោលចោរថា បើខ្ញុំនឹងបានជីវិត ខ្ញុំនឹងថ្វាយពលីកម្មចំពោះលោក យើងបានជីវិតព្រោះអាស្រ័យទេវតានោះ សូមនាងចូរប្រញាប់ឲ្យចាត់គ្រឿងពលីកម្មចុះ ។ នាងភទ្ទាគិតថា យើងនឹងធ្វើឲ្យគេពេញចិត្ត ក៏បង្គាប់ឲ្យចាត់ចែងគ្រឿងពលីកម្មប្រដាប់ដោយគ្រឿងប្រដាប់គ្រប់ប្រភេទ ឡើងអង្គុយក្នុងរថជាមួយគ្នាទៅកាន់ជ្រោះចោលចោរជាមួយស្វាមី ផ្ដើមសួឡើងភ្នំទៅដោយគិតថា យើងនឹងធ្វើពលីកម្មដល់ទេវតាប្រចាំភ្នំ ។ សត្តុកៈចោរគិតថា កាលឡើងទៅទាំងអស់គ្នាយើងនឹងមិនមានឱកាសកាន់យកគ្រឿងអាភរណៈរបស់នាងបាន ទើបឲ្យនាងភទ្ទានោះឯងកាន់ភាជនៈគ្រឿងសែន ហើយឡើងភ្នំទៅ ។ គេនិយាយពាក្យធ្វើហាក់ដូចជានិយាយនឹងនាងភទ្ទា និយាយជជែកគ្នាទៅ ដោយហេតុនោះឯង នាងទើបមិនដឹងសេចក្ដីប្រាថ្នារបស់ចោរ ។ ពេលនោះ ចោរទើបនិយាយចំពោះនាងថា ប្អូនភទ្ទា នាងចូរដោះសំពត់ដណ្ដប់របស់នាងចេញ ហើយយកគ្រឿងប្រដាប់ដែលប្រដាប់ត្រង់កាយខ្ចប់ទុកក្នុងទីនេះ ។

នាងភទ្ទា លោកប្ដី ខ្ញុំមានកំហុសអ្វីឬ ។

ចោរ នែនាងល្ងង់ ក៏នាងសម្គាល់ថា យើងមកដើម្បីធ្វើពលីកម្មឬ សេចក្ដីពិត យើងនឹងខ្វះថ្លើមថ្វាយដល់ទេវតានេះ តែយើងមានបំណងនឹងយកគ្រឿង

អាករណៈរបស់នាងដោយអានពលីកម្ម ទើបបានមក ។

នាងកុម្ភា លោកប្តី គ្រឿងប្រដាប់ជារបស់នរណា ខ្ញុំជារបស់នរណា ។

ចោរ យើងមិនដឹង របស់របរនាងក៏ជាចំណែកមួយ របស់របរយើងក៏ជាចំណែកមួយ ។

នាងកុម្ភា ល្អហើយលោកបង តែសូមឲ្យលោកបងចូរធ្វើសេចក្តីបំណងរបស់ប្អូនមួយឲ្យបរិបូណ៌សិន សូមលោកបង ឲ្យប្អូនបានឱបបងទាំងខាងមុខ និងខាងក្រោយដោយទំនងដែលតែង្ខួនហើយយ៉ាងនេះសិន ។

ចោរក៏យល់ព្រមថា ធ្វើចុះ ។

នាងជ្រាបថា ចោរព្រមហើយក៏ឱបខាងមុខហើយ ក៏ធ្វើជាឱបខាងក្រោយទើបធាក់គេធ្លាក់ជ្រោះទៅ ។ គេកាលធ្លាក់ចុះទៅ ក៏បែកខ្ទេចក្នុងអាកាសទុំះឯង ។

ទេវតាដែលស្ថិតនៅត្រង់ភ្នំ ឃើញនាងធ្វើឲ្យចោរបែកខ្ទេចហើយ ទើបបានពោលគាថាដោយបំណងនឹងសរសើរ មានដូច្នេះថា

ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថី ច បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា
ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថី ច បណ្ឌិតា ហោតិ មុហុត្តម្បិ ចិន្តយេ ។

បុរសនោះមិនមែនជាបណ្ឌិត ចេញទៅក្នុងទីគ្រប់កន្លែង តែស្ត្រីអ្នកមានវិចារណញ្ញាណក្នុងទីនោះៗ ក៏ជាបណ្ឌិតបាន បុរសនោះមិនមែនជាបណ្ឌិត ចេញទៅក្នុងទីគ្រប់កន្លែង តែស្ត្រីមានបញ្ញាសូម្បីតែមួយភ្លែត ក៏ជាបណ្ឌិតបាន ។

លំដាប់នោះ នាងភទ្ទាទើបគិតថា យើងមិនអាចនឹងត្រឡប់ទៅផ្ទះដោយទំនងនេះបាន យើងទៅពីទីនេះហើយនឹងបួសតែម្យ៉ាង ទើបបានទៅកាន់អារាមរបស់ពួកនិគ្រន្ថសូមបព្វជ្ជាចំពោះពួកនិគ្រន្ថ ទីនោះពួកនិគ្រន្ថទាំងនោះ ពោលនឹងនាងថា នឹងបួសដោយទំនងណា ។

វត្ថុណាជារបស់ប្រសើរបំផុតក្នុងបព្វជ្ជារបស់លោក សូមលោកចូរធ្វើវត្ថុនោះនុ៎ះឯង ។

ពួកនិគ្រន្ថទទួលថា ល្អហើយ ទើបយកជាងត្នោតដកសក់របស់នាង ហើយឲ្យបួស ។ សក់កាលនឹងដុះឡើងទៀត ក៏ដុះឡើងជាវង់មូលស្រដៀងក្រវិល ដុះជាជុំឡើងមក ។ ព្រោះហេតុនោះ នាងទើបកើតមានឈ្មោះថា **កុណ្ឌលកេសា** ។ នាងរៀនសិល្បៈគ្រប់យ៉ាងក្នុងទីដែលខ្លួនបួសហើយ លុះជ្រាបថា គុណវិសេសក្រៃលែងជាងនេះរបស់ពួកនិគ្រន្ថទាំងនេះមិនមាន ទើបត្រាច់ទៅកាន់គាម និគមរាជធានី បណ្ឌិតមានក្នុងទីណាៗ ក៏ទៅក្នុងទីនោះៗ ហើយរៀនសិល្បៈដែលបណ្ឌិត

ទាំងនោះដឹងគ្រប់យ៉ាង ។ តមក មនុស្សទាំងឡាយដែលអាចនឹងឲ្យពាក្យឆ្លើយដល់នាងបានមិនមាន ព្រោះនាងជាអ្នកបានសិក្សាមកក្នុងទីជាច្រើន ។ នាងមើលមិនឃើញនរណាដែលអាចនឹងពោលនឹងខ្លួនបាន ចូលទៅកាន់ស្រុកណា ក៏ធ្វើគំនរខ្សាច់ទុកត្រង់ទ្វារស្រុកនោះ ហើយកាច់មែកព្រីងទុកលើគំនរខ្សាច់នោះឯង ឲ្យសញ្ញាដល់ពួកក្មេងៗ ដែលឈរក្នុងទីជិតដោយនិយាយថា នរណាដែលអាចឆ្លើយវាទៈរបស់យើងបាន អ្នកនោះ ចូរជាន់មែកឈើនេះ ។ សូម្បីរហូតដល់អស់សប្តាហ៍ក៏មិនមានអ្នកជាន់ ។ ហើយនាងក៏កាន់យកមែកឈើនោះចៀសចេញទៅ ។

ក្នុងសម័យនោះ ព្រះដ៏មានព្រះភាគរបស់យើងស្តេចឧប្បត្តិឡើងហើយក្នុងលោក ទ្រង់អាស្រ័យក្រុងសាវត្ថី ស្តេចប្រថាប់នៅព្រះជេតវន ។ ចំណែកនាងកុណ្ឌលកេសា ក៏ទៅដល់ក្រុងសាវត្ថីតាមលំដាប់ កាលចូលទៅខាងក្នុងនគរហើយក៏កាច់មែកឈើដោតទុកលើគំនរខ្សាច់ដូចទំនងដើមនុ៎ះឯង ហើយឲ្យសញ្ញាដល់ពួកក្មេងៗ ហើយទើបចូលទៅ ។

ក្នុងសម័យនោះ កាលភិក្ខុសង្ឃចូលទៅហើយ ព្រះធម្មសេនាបតីទើបចូលទៅកាន់នគរតែមួយអង្គឯងប៉ុណ្ណោះ ឃើញមែកព្រីងត្រង់គំនរខ្សាច់ហើយសួរថាព្រោះហេតុអ្វី ទើបគេដោតមែកព្រីងនេះទុក ពួកក្មេងៗ ប្រាប់ហេតុនោះទាំងអស់ ។ ទើបពោលថា នៃក្មេងទាំងឡាយ បើដូច្នោះពួកឯងចូរយកមែកព្រីងនេះចេញ មក

ជាន់ចុះ ។ បណ្ដាក្មេងទាំងនោះ ពួកខ្លះស្ដាប់ពាក្យព្រះថេរៈហើយ មិនហ៊ានជាន់ ពួកខ្លះក៏ជាន់ក្មាមៗ នោះឯង ធ្វើឲ្យខ្ទេចខ្ទីទៅ ។ នាងកុណ្ឌលកេសាបរិភោគអាហារហើយ ដើរចេញទៅឃើញមែកឈើត្រូវជាន់ ទើបសួរថា នេះជាការធ្វើរបស់នរណា ។ ពួកក្មេងៗ ទើបប្រាប់ការដែលព្រះធម្មសេនាបតីឲ្យពួកគេធ្វើ ដល់នាង ។ នាងទើបគិតថា ព្រះថេរៈនេះកាលមិនដឹងកម្លាំងរបស់ខ្លួន នឹងមិនហ៊ានឲ្យជាន់មែកឈើនេះ ព្រះថេរៈនេះជាអ្នកធំដោយពិត តែសូម្បីយើងនៅជាអ្នកតូច នឹងមិនល្អ យើងគួរចូលទៅក្នុងស្រុក ហើយឲ្យសញ្ញាដល់ពួកបរិស័ទ ហើយបានធ្វើដូច្នោះ ។ គប្បីជ្រាបថា ក្នុងនគរដែលជាទីអាស្រ័យនៅនៃត្រកូលដល់ ៨០.០០០ ត្រកូល មនុស្សទាំងអស់ទាំងឯង រមែងបានដឹងដូចគ្នា ។

ចំណែកព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ ទើបគង់ត្រង់គល់ឈើមួយកន្លែង ។ ពេលនោះ នាងកុណ្ឌលកេសាមានមហាជនហែហម ដើរទៅកាន់សំណាក់របស់ព្រះថេរៈ ធ្វើបដិសណ្ឋារៈហើយ ឈរក្នុងទីដ៏សមគួរមួយ សួរថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់ឲ្យគេជាន់មែកឈើនេះឬ ។

ព្រះសារីបុត្រ មែនហើយ យើងឲ្យជាន់ ។

នាងកុណ្ឌ បើដូច្នោះ សូមលោកម្ចាស់ និងព្រះគុណម្ចាស់មកដោះស្រាយវាទៈនឹងគ្នា ។

ព្រះសារីបុត្រ បានប្អូនស្រី ។

នាងកុណ្ឌលកេសា នរណានឹងសួរ នរណានឹងឆ្លើយ ។

ព្រះសារីបុត្រ សេចក្តីពិតពាក្យសួរជារបស់យើង តែនាងចូរសួរវត្ថុដែលនាងដឹងចុះ ។

នាងសួរលទ្ធិតាមដែលខ្លួនដឹងមកទាំងអស់ តាមដែលព្រះថេរៈបានឮ ។ ព្រះថេរៈក៏ពោលដោះស្រាយបានទាំងអស់ ។ លុះនាងសួរហើយសួរទៀត ដរាបអស់ទើបបានស្ងៀម ។ លំដាប់នោះ ព្រះថេរៈទើបពោលនឹងនាងថា នាងសួរយើងអស់ហើយ សូម្បីយើងក៏នឹងសួរនាងមួយប្រការ ។

នាងកុណ្ឌលកេសា សួរចុះ លោកម្ចាស់ ។

ព្រះសារីបុត្រ ដែលឈ្មោះថា មួយ គឺអ្វី ។

នាងកុណ្ឌលកេសាឆ្លើយថា ខ្ញុំមិនដឹងទេ ។

ព្រះសារីបុត្រ នាងមិនដឹងសូម្បីហេតុត្រឹមតែប៉ុណ្ណេះ នាងនឹងដឹងអ្វីយ៉ាងដទៃនោះ ។

នាងក្រាបទៀបជើងទាំងពីររបស់ព្រះថេរៈ ឆ្លើយប្រាប់ថា ខ្ញុំសូមដល់លោកម្ចាស់ជាសរណៈ ។

ព្រះសារីបុត្រ នឹងដល់យើងជាសរណៈមិនបាន បុគ្គលដែលប្រសើរបំផុត

ក្នុងលោកព្រមទាំងទេវលោក ប្រថាប់នៅទីនវិហារជិតៗ នេះឯង សូមនាងចូរដល់ព្រះអង្គជាសរណៈចុះ ។

នាងភទ្ទា ខ្ញុំម្ចាស់នឹងធ្វើយ៉ាងនោះ ។

ពេលល្ងាច ក្នុងវេលាដែលព្រះសាស្តាទ្រង់សម្តែងធម៌ ទើបទៅកាន់សម្នាក់របស់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយបានឈរក្នុងទីសមគួរមួយ ។ ព្រះសាស្តាត្រាស់ព្រះគាថាក្នុងធម្មបទតាមសេចក្តីសមរម្យនឹងចរិយារបស់នាងដែលធ្លាប់ពិចារណាឃើញសង្ខារដែលទុក្ខបៀតបៀនហើយ តទៅថា ៖

សហស្សម្បិ ចេ គាថា អនត្ថបទសញ្ហិតា

ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ

បើគាថាដែលមិនប្រកបដោយបទដែលមានប្រយោជន៍ សូម្បី

១.០០០ គាថាក៏ដោយ គាថាតែមួយដែលបុគ្គលស្តាប់ហើយ

ស្ងប់រម្ងាប់បាន ប្រសើរជាង ដូច្នេះ ។

ក្នុងវេលាចប់ព្រះគាថា នាងក៏បានសម្រេចព្រះអរហត្តទាំងដែលឈរនុ៎ះឯងព្រមទាំងបដិសម្ភិទា ទើបទូលសូមបព្វជ្ជា ។ ព្រះសាស្តាទ្រង់ទទួលឲ្យនាងបព្វជ្ជាហើយ ។ នាងទៅកាន់សំណាក់ភិក្ខុនីបួសហើយ ។ ក្នុងកាលតមកកើតការសន្ទនាគ្នាឡើងត្រង់កណ្តាលបរិស័ទទាំង ៤ ថា នាងភទ្ទាកុណ្ឌលកេសាធំដ៏ក្រៃលែងហ្ន៎

*សម្រេចព្រះអរហត្តក្នុងវេលាចប់គាថាត្រឹមតែ ៤ បទ ។ ព្រះសាស្តាទ្រង់ធ្វើហេតុនោះឲ្យជាអត្ថុប្បត្តិ (ហេតុកើតរឿង) ហើយទ្រង់ស្ថាបនាព្រះថេរីទុកក្នុងតំណែងឯតទគ្គៈប្រសើរជាងភិក្ខុនីជាសាវិកា អ្នកត្រាស់ដឹងរហ័ស ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## “ប្រវត្តិព្រះនាងភទ្ទកាបិលានីថេរី”

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥០] ដោយបទថា **បុព្វេនិវាសំ អនុស្សរន្តីនំ** ទ្រង់ត្រាស់ថា ព្រះភទ្ទកាបិលានីថេរី ជាកំពូលលើពួកភិក្ខុនីជាសាវិកា អ្នកមានបុព្វេនិវាសញ្ញាណ តាមរឭកខន្ធសន្តានដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនបាន ។

បានឮថា កាលព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** នាងកើតក្នុងផ្ទះនៃត្រកូលក្នុងក្រុងហង្សវតី ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ កំពូលលើពួកភិក្ខុនីជាសាវិកាអ្នកមានបុព្វេនិវាសញ្ញាណ ទើបធ្វើកុសលកម្មឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ នាងវិលវល់ស្លាប់កើតទៅក្នុងទេវតា និងមនុស្សទាំងឡាយអស់សែនកប្ប កាលព្រះពុទ្ធមិនទាន់ឧប្បត្តិឡើង បានបដិសន្ធិក្នុងត្រកូល នាក្រុងពារាណសី បានឈ្មោះគ្នានឹងប្អូនស្រីរបស់ខ្លួន កាលដែលប្អូនស្រីនោះថ្វាយបិណ្ឌបាតចំពោះព្រះបច្ចេកពុទ្ធ ក៏គិតថា នាងនេះថ្វាយបិណ្ឌបាតចំពោះព្រះបច្ចេកពុទ្ធហើយនឹងឲ្យយើងធ្លាក់នៅក្នុងអំណាចរបស់ខ្លួន ដូច្នេះ ហើយទើបយកបាត្រពីព្រះហស្តរបស់

ព្រះបច្ចេកពុទ្ធ ចាក់អាហារចោល យកភក់ដាក់ដរាបពេញ ហើយថ្វាយ ។ មហាជន នាំគ្នាតិះដៀលថា នាងនេះជាពាល ហើយនិយាយថា នាងឈ្មោះនឹងស្រីណា មិនធ្វើអ្វីដល់ស្រីនោះ ព្រះបច្ចេកពុទ្ធធ្វើអ្វីខុសចំពោះនាងឬ ។ នាងខ្មាសដោយពាក្យនិយាយរបស់អ្នកទាំងនោះ ទើបទទួលបាត្រមកជាថ្មី ចាក់ភក់ចេញលាងឲ្យស្អាត អប់ដោយគ្រឿងក្រអូប ដាក់អាហារមានរសឆ្ងាញ់ ៤ យ៉ាង រហូតពេញ ហើយដាក់បាត្រដ៏ស្អាតនោះដោយទឹកដោះថ្លាមានពណ៌ដូចត្របកផ្កាឈូកដែលធ្លុះមុខបាន ទុកលើដៃរបស់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាទុកថា បិណ្ឌបាតនេះកើតមានពន្លឺភ្លឺល្អ យ៉ាងណា សូមឲ្យសរីរៈរបស់ខ្ញុំម្ចាស់មានពន្លឺភ្លឺល្អ ដូច្នោះចុះ ។ រឿងទាំងអស់នេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងរឿងរបស់ព្រះមហាកស្សបត្ថេរ ។

ចំណែកព្រះមហាកស្សបត្ថេរកាន់យកផ្លូវស្តាំ ទៅកាន់ដើមជ្រៃឈ្មោះ ពហុបុត្តៈ ដែលជាសំណាក់របស់ព្រះទសពល ។ នាងកុណ្ឌកាបិលានីកាន់យកផ្លូវឆ្វេង បានទៅកាន់អារាមរបស់ពួកបរិព្វាជក ព្រោះហេតុដែលការបព្វជ្ជាមាតុគ្រាម ព្រះដ៏មានព្រះភាគមិនទាន់ទ្រង់បានអនុញ្ញាត ។ តមក កាលព្រះនាងមហាបជាបតីគោតមីទ្រង់បានបព្វជ្ជាហើយ នាងទើបបានបព្វជ្ជា និងឧបសម្បទាក្នុងសំណាក់របស់ព្រះថេរី ក្នុងកាលតមក ញុំាងវិបស្សនាកម្មដ្ឋានហើយបានសម្រេចព្រះអរហត្ត

ទើបជាអ្នកមានសេចក្តីជំនាញក្នុងបុព្វេនិវាសញ្ញាណ ។ លំដាប់នោះ ព្រះសាស្តា ប្រថាប់គង់ក្នុងព្រះជេតវ័ន កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះថេរីទុកក្នុងតំណែងឯតទគ្គៈ កំពូលលើសពួកភិក្ខុនីជាសាវិកា ដែលមានបុព្វេនិវាសញ្ញាណ ដោយប្រការដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

## “ប្រវត្តិព្រះភទ្ទាកច្ចានាថេរី”

*ក្នុងសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *ដោយបទថា* ***មហាភិញ្ញាប្បត្តានំ*** *ទ្រង់ត្រាស់ថា ព្រះភទ្ទាកច្ចានា-ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកសម្រេចអភិញ្ញាធំ ។ ពិតណាស់ ព្រះពុទ្ធមួយព្រះអង្គ មានអ្នកដែលសម្រេចអភិញ្ញាធំបាន ៤ នាក់ សាវកដ៏សេសមិនមានការសម្រេចទេ ។ ព្រោះសាវកដ៏សេស រមែងអាចរឭកជាតិបានត្រឹមមួយសែនកប្បប៉ុណ្ណោះ ក្រៃលែងជាងនោះរឭកមិនបាន ។ តែលោកដែលបានសម្រេចអភិញ្ញាធំរមែងរឭកជាតិបានមួយអសង្ខេយ្យក្រៃលែងដោយសែនកប្ប ។ ក្នុងសាសនារបស់ព្រះសាស្ដារបស់ពួកយើង បុគ្គល ៤ នាក់ទាំងនេះ គឺ ព្រះអគ្គសាវក ២ រូប ព្រះពាកុលត្ថេរៈ ព្រះនាងភទ្ទាកច្ចានាថេរី អាចរឭកជាតិបានប្រមាណប៉ុណ្ណោះ ។ ព្រោះដូច្នោះ ព្រះថេរី ទើបឈ្មោះថា ប្រសើរបំផុតលើពួកភិក្ខុនីជាសាវិកាអ្នកមានអភិញ្ញាធំ ។ ព្រះនាងមានព្រះនាមថា* ***ភទ្ទាកច្ចានា*** *ក៏ពណ៌សម្បុរនៃសរីរៈរបស់ព្រះនាងនោះ មានពណ៌ដូចមាសប្រភេទល្អទីបំផុត ។ ព្រោះដូច្នោះ ព្រះនាងទើបរាប់ថា ជាអ្នកល្អស្អាតដោយពិត នេះជាព្រះនាមរបស់ព្រះមាតារបស់ព្រះរាហុល ។*

សូម្បីព្រះនាង សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** បានបដិសន្ធិក្នុងផ្ទះត្រកូល នាក្រុងហង្សវតី ក្នុងកាលតមក ស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើពួកភិក្ខុនីជាសាវិកាអ្នកសម្រេចអភិញ្ញាធំ ទើបធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ នាងវិលវល់ស្លាប់កើតក្នុងទេវតា និងមនុស្សលោករហូតអស់សែនកប្បក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងព្រះរាជនិវេសន៍ព្រះបាទសុប្បពុទ្ធ ។ ពួកព្រះញាតិថ្វាយព្រះនាមថា **ភទ្ទាកច្ចានា** ។ ព្រះនាងចម្រើនវ័យហើយ បានអភិសេកជាមហេសីព្រះពោធិសត្វ ។ តមកព្រះនាងបានប្រសូតិព្រះឱរសព្រះនាមថា ព្រះរាហុលកុមារ ។ ក្នុងថ្ងៃដែលព្រះរាហុលកុមារប្រសូតិហើយ ព្រះពោធិសត្វស្តេចទ្រង់ចេញព្រះផ្នួស ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណត្រង់គល់ដើមពោធិ កាលនឹងធ្វើការអនុគ្រោះមនុស្សលោក ស្តេចមកដល់ក្រុងកបិលភស្តុដោយលំដាប់ ទ្រង់បានធ្វើការសង្គ្រោះព្រះញាតិ តមក កាលព្រះបាទសុទ្ធោទនមហារាជបរិនិព្វានហើយ ព្រះនាងមហាបជាបតីគោតមី ព្រមទាំងមាតុគ្រាម ៥០០ នាក់ សូមបព្វជ្ជាក្នុងសំណាក់របស់ព្រះសាស្តា ។ ព្រះមាតារបស់ព្រះរាហុលក្តី ព្រះនាងរូបនន្ទាជនបទកល្យាណីក្តី ក៏នាំគ្នាទៅកាន់សំណាក់របស់ព្រះថេរី បួសហើយ ។ នាងចាប់ផ្តើមតាំងពីបួសហើយ បានប្រាកដឈ្មោះថា **ភទ្ទាកច្ចានាថេរី** ។ តមកព្រះនាង

ចម្រើនវិបស្សនាសម្រេចព្រះអរហត្តហើយ ក៏ជាអ្នកជំនាញក្នុងអភិញ្ញាទាំងឡាយ ក្នុងខណៈអន្តរាយចម្រើនតែម្តង ហើយរឭកជាតិបានដល់មួយអសង្ខេយ្យក្រៃលែងដោយសែនកប្ប កាលគុណ គឺ សេចក្តីល្អនោះរបស់ព្រះនាងប្រាកដច្បាស់ហើយ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវ័ន កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងឯតទគ្គៈផ្សេង ៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីទុកក្នុងតំណែងឯតទគ្គៈកំពូលលើពួកភិក្ខុនីជាសាវិកាដែលសម្រេចអភិញ្ញាធំ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១១

# អដ្ឋកថាសូត្រទី ១២

## “ប្រវត្តិព្រះកីសាគោតមីថេរី”

*ក្នុងសូត្រទី ១២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *ដោយបទថា* ***លូខចីវរធរានំ*** *ទ្រង់សម្ដែងទុកថា នាងកីសាគោតមីកំពូលលើពួកភិក្ខុនីដែលជាសាវិកាអ្នកទ្រទ្រង់សំពត់បង្សុកូល ដែលប្រកបដោយសេចក្ដីសៅហ្មង ដូច្នេះ ។ នាងមានឈ្មោះថា គោតមី តែគេហៅថា* ***កីសាគោតមី*** *ព្រោះព្រះនាងជាមនុស្សស្គម និងរាងស្ដើង ។*

*ព្រះនាងកាលព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *បានកើតក្នុងផ្ទះត្រកូល នាក្រុងហង្សវតី ស្ដាប់ធម៌ទេសនារបស់ព្រះសាស្ដាហើយ ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកទ្រទ្រង់ចីវរសៅហ្មង ទើបធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ ព្រះនាងវិលវល់ទៅក្នុងទេវតា និងមនុស្សរហូតអស់សែនកប្ប ។ ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងត្រកូលអ្នកក្រខ្សត់ ក្នុងក្រុងសាវត្ថី វេលាចម្រើនវ័យហើយក៏បានស្វាមីនៅគ្រប់គ្រងផ្ទះ ។ ពួកជនក្នុងត្រកូលនោះមើលងាយនាងថា ជាធីតារបស់ត្រកូលអ្នកក្រខ្សត់ ។ តមកនាងបានប្រសូតិបុត្រម្នាក់ ។ ពេលនោះ ជនទាំង*

ឡាយទើបបានធ្វើសេចក្តីលើកតម្កើងនាង ។ ក៏បុត្ររបស់នាងតាំងនៅក្នុងវ័យល្មម នឹងរត់លេងបានក៏ស្លាប់ទៅ សេចក្តីសោកសៅក៏បានកើតឡើងដល់នាង ។ នាងគិតថា យើងអស់លាភ និងសក្ការៈក្នុងផ្ទះនេះហើយ ចាប់តាំងពីវេលាដែលបុត្រកើតមកទើបបានសក្ការៈ ជនទាំងនេះទើបព្យាយាមទុកបុត្ររបស់យើងចោលខាងក្រៅ ដូច្នេះ ទើបពបុត្រដើរទៅតាមលំដាប់ទ្វារផ្ទះដោយនិយាយថា សូមពួកលោកចូរឲ្យថ្នាំដល់បុត្ររបស់យើងផង ដូច្នេះ ។ ពួកមនុស្សក្នុងទីដែលជួបនោះៗ ឯងម្នាក់ៗ ដៃធ្វើការចំអកឡកឡឺយថា ថ្នាំសម្រាប់អ្នកស្លាប់ហើយ នាងធ្លាប់ឃើញពីទីណា ។ នាងមិនបានយល់អត្ថន័យនៃពាក្យនិយាយរបស់ពួកគេឡើយ ។ លំដាប់នោះ មនុស្សឆ្លាតម្នាក់ឃើញនាង ហើយគិតថា នាងនេះមានចិត្តរវើរវាយ (ឆ្កួត) ព្រោះសេចក្តីសោកសៅដល់បុត្រ តែថ្នាំសម្រាប់បុត្ររបស់នាងនោះបុគ្គលដទៃមិនដឹងទេ ព្រះទសពលប៉ុណ្ណោះទ្រង់នឹងជ្រាប ដូច្នេះហើយ ទើបពោលយ៉ាងនេះថា នាងអើយ ថ្នាំសម្រាប់បុត្ររបស់នាងអ្នកដទៃដែលដឹងមិនមានទេ ព្រះទសពលទ្រង់ជាកំពូលបុគ្គលក្នុងលោក ព្រមទាំងទេវលោកប្រថាប់នៅក្នុងវិហារជិតៗ នេះឯង សូមនាងចូរទៅទូលសួរមើលចុះ ។ នាងគិតថា មនុស្សនេះនិយាយពិត ទើបពបុត្រទៅឈរក្នុងទីខាងក្រោយបរិស័ទ ក្នុងវេលាដែលព្រះតថាគតប្រថាប់គង់លើពុទ្ធាសនៈ ហើយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សូមព្រះអង្គមេត្តាប្រទាន

ថ្នាំដល់បុត្ររបស់ខ្ញុំព្រះអង្គផងចុះ ដូច្នេះ ។

ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់នាង ហើយត្រាស់ថា ម្នាលគោតមី នាងមកទីនេះដើម្បីត្រូវការថ្នាំ ឈ្មោះថា ធ្វើល្អហើយ នាងចូរចូលទៅកាន់នគរ ដើរទៅទូទាំងនគរតាំងពីខាងចុងស្រុកទៅ ក្នុងផ្ទះណាមិនធ្លាប់មានអ្នកស្លាប់ ចូរនាំយកគ្រាប់ស្ពៃពីផ្ទះនោះមក ដូច្នេះ ។ នាងទូលថា ព្រះករុណាព្រះអង្គ ដូច្នេះ មានចិត្តត្រេកអរ ចូលទៅខាងក្នុងនគរ ពេលដល់ផ្ទះដំបូងក៏និយាយថា ព្រះទសពលទ្រង់មានព្រះតម្រាស់ឲ្យរកគ្រាប់ស្ពៃមក ដើម្បីប្រយោជន៍ប្រើជាថ្នាំដល់កូនរបស់យើង សូមពួកលោកចូរឲ្យគ្រាប់ស្ពៃដល់យើងចុះ ដូច្នេះ ។ ពួកមនុស្សទាំងឡាយបាននាំមកឲ្យនាង ដោយនិយាយថា យកចុះគោតមី ។

គោតមី ៖ ខ្ញុំម្ចាស់មិនអាចយកបានដោយទំនងនេះ ក្នុងផ្ទះនេះឈ្មោះថា មិនធ្លាប់មានមនុស្សស្លាប់ទេឬ ។

អ្នកស្រុក ៖ ម្នាលនាងគោតមី នាងនិយាយអ្វី អ្នកណានឹងអាចរាប់អ្នកដែលស្លាប់ហើយក្នុងផ្ទះនេះបាន ។

គោតមី ៖ បើដូច្នោះ ព្រះទសពលទ្រង់ត្រាស់ឲ្យខ្ញុំទទួលគ្រាប់ស្ពៃនោះពីផ្ទះដែលមិនធ្លាប់មានមនុស្សស្លាប់ ។ នាងដើរទៅផ្ទះទី ៣ ដោយទំនងនេះឯង ហើយគិតបានថា ក្នុងនគរទាំងអស់ក៏នឹងមានទំនងនេះដូចគ្នា ព្រះពុទ្ធទ្រង់អនុគ្រោះ

ដោយប្រយោជន៍ នឹងទ្រង់ឃើញហេតុនេះហើយ ដូច្នេះ បានកើតសេចក្ដីសង្វេគ ចេញទៅខាងក្រៅនគរនោះឯង ទៅកាន់ព្រៃចោលសាកសពខ្មោចស្រស់ យកដៃចាប់បុត្រ ហើយនិយាយថា នែកូនតូច ម៉ែគិតថា សេចក្ដីស្លាប់នេះកើតឡើងដល់អ្នកប៉ុណ្ណោះ ប៉ុន្តែថា សេចក្ដីស្លាប់នេះមិនមែនមានដល់កូនតែម្នាក់ នេះជាធម្មតាមានដល់មហាជនទូទៅ ដូច្នេះ ហើយទើបលះបង់កូនក្នុងព្រៃចោលសាកសពខ្មោចស្រស់ ហើយពោលគាថានេះថា ៖

ន គាមធម្មោ នោ និគមស្ស ធម្មោ
ន ចាបិយំ ឯកកុលស្ស ធម្មោ
សព្វស្ស លោកស្ស សទេវកស្ស
ឯសេវ ធម្មោ យទិទំ អនិច្ចតា ។

ធម៌នេះឯង គឺ សេចក្ដីមិនទៀង មិនមែនធម៌របស់អ្នកស្រុក
មិនមែនធម៌របស់អ្នកនិគម ទាំងមិនមែនធម៌របស់ត្រកូលមួយ
ផង តែជាធម៌របស់លោកទាំងអស់ ព្រមទាំងទេវលោក ។

ក៏គ្រាពោលយ៉ាងនេះហើយ នាងបានទៅកាន់សំណាក់របស់ព្រះសាស្ដា ។ ពេលនោះ ព្រះសាស្ដាត្រាស់ថា ម្នាលគោតមី នាងបានគ្រាប់ស្ពៃមកហើយឬ ។

គោតមី ៖ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនត្រូវការនឹងប្រើគ្រាប់ស្ពៃ

ទេ តែសូមព្រះអង្គទ្រង់ប្រទានទីពឹងដល់ខ្ញុំព្រះអង្គផង ។

លំដាប់នោះ ព្រះសាស្តាត្រាស់គាថាក្នុងធម្មបទដល់នាងថា ៖

តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ

សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុរមែងនាំយកនរជន ដែលស្រវឹងក្នុងកូន និងសត្វ អ្នកមាន

ចិត្តជំពាក់នៅក្នុងអារម្មណ៍ផ្សេងៗ ទៅ ដូចអន្លង់ទឹកធំ ហូរនាំ

យកអ្នកស្រុកដែលដេកលក់ហើយទៅ ដូច្នោះ ។

ចប់ព្រះគាថា នាងទាំងដែលឈរទ្រុះឯង តាំងនៅក្នុងសោតាបត្តិផល ទូលសូមបព្វជ្ជាហើយ ។ ព្រះសាស្តាទ្រង់អនុញ្ញាតការបព្វជ្ជា ។ នាងធ្វើប្រទក្សិណព្រះសាស្តា ៣ ជុំ ថ្វាយបង្គំហើយទៅកាន់សំណាក់ភិក្ខុនី បានបព្វជ្ជា និងឧបសម្បទាហើយ មិនយូរប៉ុន្មានធ្វើកម្មក្នុងយោនិសោមនសិការ ចម្រើនវិបស្សនា លំដាប់នោះ ព្រះសាស្តាបានត្រាស់ព្រះគាថាព្រមដោយថ្លែងឱកាស (រស្មី) ដល់នាងថា ៖

យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ

ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ

ក៏បុគ្គលណាមិនឃើញអមតបទ សូម្បីមានជីវិតតាំងនៅ ១០០ ឆ្នាំ

ជីវិតរបស់បុគ្គលឃើញអមតបទត្រឹមតែមួយថ្ងៃ ប្រសើរជាងដូច្នេះ ។

ចប់ព្រះគាថា នាងក៏សម្រេចអរហត្ត ជាអ្នកក្រៃលែងក្នុងការប្រើប្រាស់បរិក្ខារ ដណ្តប់ចីវរប្រកបដោយសេចក្តីសៅហ្មង ៣ យ៉ាង ត្រាច់ទៅ ។ តមកព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវ័ន កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នកទ្រទ្រង់ចីវរសៅហ្មង ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១២

# អដ្ឋកថាសូត្រទី ១៣

## “ប្រវត្តិព្រះសិង្គាលមាតាថេរី”

*ក្នុងសូត្រទី ១៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥០] *ដោយបទថា* ***សទ្ធាធិមុត្តានំ*** *ទ្រង់សម្ដែងថា ព្រះសិង្គាមាតាថេរី ប្រសើរជាងពួកភិក្ខុនីសាវិកាអ្នករួចផុតកិលេសដោយសទ្ធា ។*

*ដូចបានស្ដាប់មក សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *ព្រះនាងកើតក្នុងផ្ទះត្រកូល ក្នុងក្រុងហង្សវតី កាលស្ដាប់ធម៌របស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកភិក្ខុនីជាសាវិកាអ្នករួចផុតចាកកិលេសដោយសទ្ធា ទើបធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ នាងវិលវល់ទៅក្នុងទេវតា និងមនុស្សរហូតអស់មួយសែនកប្បក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋីក្នុងក្រុងរាជគ្រឹះ បានស្វាមីដែលមានត្រកូល មានជាតិស្មើគ្នា ប្រសូតិបុត្រម្នាក់ ។ ជនទាំងឡាយតាំងឈ្មោះឲ្យកូនរបស់នាងថា សិង្គាលកុមារ ។ ព្រោះហេតុនោះឯង សូម្បីនាងក៏មានឈ្មោះថា* ***សិង្គាលមាតា*** *។ ថ្ងៃមួយ នាងស្ដាប់ធម្មកថារបស់ព្រះសាស្ដាហើយ មានសទ្ធាទៅសំណាក់របស់ព្រះសាស្ដា ក៏បព្វជ្ជាហើយ តាំងពីបួសហើយក៏បានសទ្ធិន្ទ្រិយ*

ដ៏ក្រៃលែង ។ នាងទៅកាន់វិហារដើម្បីត្រូវការស្តាប់ធម៌ កំពុងឈរសម្លឹងមើល ព្រះសិរីសម្បត្តិរបស់ព្រះទសពល គ្រាន់តែឯង ព្រះសាស្តាទ្រង់ជ្រាបថា នាងជាអ្នកតាំងមាំក្នុងលក្ខណៈនៃសទ្ធាហើយ ទ្រង់សម្តែងធម៌ជាទីតាំងនៃសេចក្តីជ្រះថ្លា ទ្រង់ធ្វើឲ្យជាទីសប្បាយតែម្យ៉ាង ព្រះថេរីនោះក៏ធ្វើសទ្ធាលក្ខណៈនុ៎ះឯងឲ្យជាធុរៈ ក៏បានសម្រេចព្រះអរហត្តទៅ ។ លំដាប់នោះ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះជេតវ័ន កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីក្នុងតំណែងប្រសើរជាងពួកភិក្ខុនីសាវិកា អ្នករួចផុតចាកកិលេសដោយសទ្ធា ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថាថេរីបាលី ប្រដាប់ដោយសូត្រ ១៣ សូត្រ

## ចប់អដ្ឋកថាវគ្គទី ៥

## ចប់ប្រវត្តិព្រះភិក្ខុនីសាវិកាឯតទគ្គៈ ១៣

# ឧបាសកបាលិ

## អដ្ឋកថាវគ្គទី ៦

## អដ្ឋកថាសូត្រទី ១

### “ប្រវត្តិបុស្ស: និងភល្លិកឧបាសក”

*សូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥១] *បទថា* ***បឋមំ សរណំ គច្ឆន្តានំ*** *លោកសម្តែងថា អ្នកជំនួញ ២ នាក់ គឺ* ***តបុស្ស: ១ ភល្លិក: ១*** *ប្រសើរជាងពួកឧបាសកជាសាវករបស់តថាគត អ្នកដល់សរណៈមុនបុគ្គលទាំងពួង ។*

*បានឮថា ឈ្មួញទាំងពីរនាក់នេះ សម័យព្រះសម្ពុទ្ធព្រះនាមថា* ***បទុមុត្តរ:*** *បានបដិសន្ធិក្នុងត្រកូល ក្នុងក្រុងហង្សវតី តមក បានស្តាប់ធម៌ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកពីរនាក់ទុកក្នុងតំណែងឯតទគ្គៈ ជាអ្នកប្រសើរជាងពួកឧបាសកអ្នកដល់សរណៈជាដំបូង ទើបធ្វើកុសលឲ្យក្រៃលែងទៅដើម្បីប្រាថ្នាតំណែងនោះ ។ គេទាំងពីរវិលវល់ស្លាប់កើតទៅក្នុងទេវតា និងមនុស្សអស់សែនកប្ប មកកើតក្នុងផ្ទះកុដុម្ពិក: ក្នុងអសិតញ្ជននគរ មុនព្រះពោធិសត្វរបស់យើង*

ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ បងប្រុសមានឈ្មោះថា **តបុស្សៈ** ។ ប្អូនប្រុសឈ្មោះថា **ភល្លិកៈ** ។ សម័យតមក ពួកគេនៅគ្រប់គ្រងផ្ទះ ទឹមរទេះ ៥០០ ត្រាច់ធ្វើជំនួញអស់វេលាយូរ ។

ក្នុងសម័យនោះព្រះពោធិសត្វរបស់ពួកយើង ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ប្រថាប់នៅត្រង់ដើមពោធិ ៧ សប្តាហ៍ ក្នុងសប្តាហ៍ទី ៨ ប្រថាប់នៅត្រង់ដើមប្រេស ។ ក្នុងសម័យនោះ ឈ្មួញទាំងពីរនាក់នោះ បានមកដល់ស្ថានទីនោះ ព្រមទាំងរទេះប្រមាណ ៥០០ ។ មាតារបស់ឈ្មួញពីរនាក់នោះ កើតជាទេវតានៅក្នុងដងផ្លូវនោះក្នុងអត្តភាពជាប់គ្នា ៥ អត្តភាព ។ ទេវតាគិតថា ឥឡូវនេះព្រះសម្ពុទ្ធគួរនឹងបានទទួលព្រះក្រយាហារ ព្រោះតពីនេះទៅ ព្រះអង្គមិនបានព្រះក្រយាហារ នឹងមិនអាចតាំងព្រះជន្មនៅបាន ។ មួយទៀត បុត្ររបស់យើងទាំងពីរនេះ ក៏ធ្វើដំណើរតាមស្ថានទីនេះ ។ ថ្ងៃនេះ បុត្រទាំងពីរនោះ គួរបានថ្វាយបិណ្ឌបាតចំពោះព្រះពុទ្ធទាំងឡាយ ដូច្នេះហើយ ទើបបានធ្វើឲ្យគោដែលអូសរទេះទាំង ៥០០ រទេះ ឈប់មិនដើរទៅមុខ ។ ពួកអ្នកជំនួញនិយាយថា មានរឿងអ្វីហ្ន៎ ទើបនាំគ្នាពិនិត្យមើលនិមិត្តផ្សេងៗ ។ ពេលនោះ ទេវតានោះជ្រាបថា គេទាំងពីរលំបាក ទើបចូលសណ្ឋិតក្នុងរាងកាយរបស់បុរសម្នាក់ ហើយពោលថា ព្រោះហេតុអ្វីពួកលោកនាំគ្នាលំបាក មិនមានយក្ខណាមកធាតៅ មិនមានខ្មោចណាមកធាតៅ

មិនមាននាគមកតាំងទៅពួកលោកទេ តែយើងជាមាតារបស់ពួកលោកក្នុងអត្តភាព ទី ៥ កើតជាកុម្ភទេវតានៅក្នុងទីនេះ នុ៎ះព្រះទសពល ប្រថាប់នៅត្រង់ដើមប្រេស ពួកអ្នកចូរថ្វាយបិណ្ឌបាតជាលើកដំបូងចំពោះព្រះអង្គចុះ ដូច្នេះ ។ ពួកគេបានស្តាប់ ពាក្យរបស់ទេវតានោះហើយ មានចិត្តត្រេកអរ យកសដូវផង់ និងសដូវដុំ ដាក់ ជាសមាសនាំទៅកាន់សំណាក់របស់ព្រះសាស្តា ហើយក្រាបទូលថា សូមព្រះអង្គ មេត្តាទ្រង់ទទួលភោជននេះចុះ ព្រះអង្គ ។ ព្រះសាស្តាទ្រង់បានពិចារណាមើល អាចិនបដិបត្តិរបស់ព្រះពុទ្ធទាំងឡាយក្នុងអតីត ។ លំដាប់នោះ ស្តេចមហារាជ ទាំង ៤ អង្គ បង្អោនថ្វាយបាត្រ ៤ ធ្វើដោយថ្មចំពោះព្រះអង្គ ។ ព្រះសាស្តា ត្រាស់ថា សូមផលដ៏ច្រើនចូរសម្រេចដល់អ្នកទាំងពីរចុះ ហើយទ្រង់អធិដ្ឋានបាត្រ ទាំង ៤ ឲ្យជាបាត្រតែមួយប៉ុណ្ណោះ ។ ក្នុងខណៈនោះ ឈ្មួញទាំងពីរនាក់នោះ ទើបយកសដូវផង់ និងសដូវដុំ ដាក់ក្នុងបាត្ររបស់ព្រះតថាគត ក្នុងវេលាដែល ព្រះអង្គសោយស្រេចហើយ ថ្វាយទឹក ក្នុងវេលាសម្រេចកត្តកិច្ចហើយ ថ្វាយបន្តំ អង្គុយក្នុងដែលសមគួរម្ខាង ។ ពេលនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់គេ ទាំងពីរ ។ ក្នុងវេលាចប់ទេសនា គេទាំងពីរតាំងនៅក្នុងសរណៈ (**ទ្វេវាចិកៈ**) ដែលបន្ទឺវាចាដល់ព្រះពុទ្ធ និងព្រះធម៌ ទាំងពីរប៉ុណ្ណោះ ថ្វាយបង្គំព្រះសាស្តាហើយ មានបំណងនឹងទៅកាន់នគររបស់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន

សូមព្រះអង្គមេត្តាប្រទានចេតិយសម្រាប់បូជាដល់ពួកខ្ញុំព្រះអង្គផង ។ ព្រះសាស្តាទ្រង់យកព្រះហស្តស្ទាំស្ទាបព្រះសិរសា ហើយប្រទានសរសៃព្រះកេសធាតុ ៨ សរសៃដល់ជនទាំងពីរ ជនទាំងពីរនោះ ដាក់ព្រះកេសធាតុទុកក្នុងប្រអប់មាស នាំទៅកាន់នគររបស់ខ្លួន ឲ្យបញ្ចុះព្រះកេសធាតុរបស់ព្រះពុទ្ធដែលនៅមានព្រះជន្មទុកត្រង់ទ្វារអសិតញ្ជននគរ ក្នុងថ្ងៃឧបោសថ ក៏មានរស្មីពណ៌និលថ្លៃងចេញមកពីព្រះចេតិយ រឿងនេះកើតឡើងដោយទំនងនេះ ។ ក៏ក្នុងកាលតមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពន កាលទ្រង់ស្ថាបនាឧបាសកទាំងឡាយទុកក្នុងតំណែងផ្សេងៗតាមលំដាប់ ទើបទ្រង់ស្ថាបនាជនទាំងពីរនាក់នេះ ទុកក្នុងតំណែងឯតទគ្គៈដែលប្រសើរជាងឧបាសកទាំងឡាយ អ្នកដល់សរណៈមុន នោះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## “ប្រវត្តិសុទត្តអនាថបិណ្ឌិកគហបតី”

*ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥១] *បទថា* ***ទាយកានំ*** *លោកសម្តែងថា អនាថបិណ្ឌិកគហបតី ឈ្មោះ* ***សុទត្តៈ*** *ប្រសើរជាងពួកឧបាសកអ្នកត្រេកអរក្រៃលែងក្នុងទាន ។*

*ដូចព្ទមក សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *គហបតីនោះ កើតក្នុងផ្ទះត្រកូលក្នុងក្រុងហង្សវតី កាលស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកថ្វាយទាន ទើបធ្វើកុសលដ៏ក្រៃលែងបំណងតំណែងនោះ ។ គេវិលវល់ទៅក្នុងទេវតានិងមនុស្សរហូតអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បានមកកើតក្នុងផ្ទះរបស់* ***សុមនសេដ្ឋី*** *នាក្រុងសាវត្ថី ។ ជនទាំងឡាយតាំងឈ្មោះដល់គេថា* ***សុទត្តៈ*** *តមកគេតាំងនៅក្នុងយរាវាសវិស័យ ជាអ្នកឲ្យទាន ជាទានបតី ទើបបានឈ្មោះថា* ***អនាថបិណ្ឌិកៈ*** *ជាឈ្មោះដែលគេបានប្រាថ្នាហើយ ព្រោះគុណនោះឯង គេប្រើរទេះ ៥០០ រទេះ ផ្ទុកទំនិញទៅកាន់ផ្ទះរបស់សេដ្ឋីដែលជាសម្លាញ់របស់ខ្លួន ក្នុងក្រុងរាជគ្រឹះ បានព្ទថា ព្រះដ៏មានព្រះភាគ ស្តេចឧប្បត្តិឡើងហើយក្នុងទីនោះ ក្នុង*

វេលាជិតភ្លឺ បានចូលទៅគាល់ព្រះសាស្តាតាមផ្លូវទ្វារដែលបើកទុកដោយអំណាចរបស់ទេវតា ស្តាប់ធម៌ហើយតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃទី ២ ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ទទួលបដិញ្ញារបស់ព្រះសាស្តា ដើម្បីស្តេចយាងមកកាន់ក្រុងសាវត្ថីក្នុងចម្ងាយផ្លូវ ៤៥ យោជន៍ ក្នុងរវាងផ្លូវ ឲ្យទានដោយទ្រព្យរាប់សែន ឲ្យសាងវិហារក្នុងចន្លោះផ្លូវគ្រប់ៗ យោជន៍ ក្រាលព្រះជេតពនដោយកម្រាលប្រាក់រាប់កោដិ ទិញទីដីដោយទ្រព្យ ១៨ កោដិ សាងវិហារដោយទ្រព្យ ១៨ កោដិ កាលសាងវិហារស្រេចហើយ ឲ្យទានតាមដែលត្រូវការ ដល់បរិស័ទ ៤ ក្នុងវេលាមុនអាហារ និងក្រោយអាហារ ធ្វើបុណ្យឆ្លងវិហារដោយទ្រព្យ ១៨ កោដិ ។ ការធ្វើបុណ្យឆ្លងវិហារអស់វេលា ៩ ខែ ទើបស្រេច ។ អាចារ្យពួកខ្លះទៀតពោលថា ក្នុងវេលា ៥ ខែ ។ តែប្រការប្រកែកគ្នារបស់អាចារ្យទាំងនោះមិនមាន ។ គេលះបង់ទ្រព្យ ៥៤ កោដិ ដោយអាការយ៉ាងនេះ ធ្វើទានបែបនេះ ឲ្យប្រព្រឹត្តទៅក្នុងផ្ទះរបស់ខ្លួនរហូតអស់កាលជានិច្ច ។ រាល់ៗ ថ្ងៃ មានស្លាក-ភត្ត ៥០០ កន្លែង , មានបក្ខិកភត្ត ៥០០ កន្លែង , មានស្លាកយាគូ ៥០០ កន្លែង , មានបក្ខិយយាគូ ៥០០ កន្លែង , មានធុវភត្ត ៥០០ កន្លែង , មានស្លាកភត្តសម្រាប់ភិក្ខុអាគន្តុកៈ ៥០០ កន្លែង , មានភត្តសម្រាប់ភិក្ខុដែលត្រៀមនឹងធ្វើដំណើរ ៥០០ កន្លែង , មានភត្តសម្រាប់ភិក្ខុឈឺ ៥០០ កន្លែង , មានភត្តសម្រាប់ភិក្ខុដែល

ថែរក្សាកិច្ចឈើ ៥០០ កន្លែង , មានអាសនៈ ៥០០ កន្លែង ក្រាលទុកជាប្រចាំជានិច្ចក្នុងផ្ទះនោះឯង ។ ក្នុងកាលតមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពន កាលទ្រង់ស្តាបនាឧបាសកទាំងឡាយក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្តាបនាលោកទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងឧបាសកទាំងឡាយអ្នកថ្វាយទាន ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## “ប្រវត្តិចិត្តគហបតី”

*ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥១] *ដោយបទថា* ***ធម្មកថិកានំ*** *លោកសម្តែងថា ចិត្តគហបតីប្រសើរជាងពួកឧបាសកដែលជាធម្មកថិក ។ បានឮថា គ្រាព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *គេកើតក្នុងត្រកូលក្នុងក្រុងហង្សវតី តមក បានស្តាប់ធម្មកថា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងឧបាសកដែលជាធម្មកថិក ទើបធ្វើកុសលយ៉ាងក្រៃលែងប្រាថ្នាតំណែងនោះ ។ គេវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប គ្រាព្រះពុទ្ធព្រះនាមថា* ***កស្សបៈ*** *កើតក្នុងផ្ទះនៃនាយព្រានម្រឹគ តមក ក្នុងវេលាដែលគេអាចធ្វើការងារក្នុងព្រៃបាន ថ្ងៃមួយពេលភ្លៀងធ្លាក់ ក៏កាន់យកលំពែងទៅដើម្បីនឹងសម្លាប់ម្រឹគ ចូលទៅក្នុងព្រៃកំពុងសម្លឹងរកមើលម្រឹគ ឃើញភិក្ខុមួយរូបស្លៀកដណ្តប់សំពត់បង្សុកូល គ្របសិរសៈអង្គុយនៅលើផ្ទាំងថ្មត្រង់ញកភ្នំកើតឯងមួយកន្លែង កើតសេចក្តីត្រិះរិះថា ភិក្ខុមួយអង្គនេះនឹងអង្គុយធ្វើសមណធម៌ ដូច្នេះ ប្រញាប់ប្រញាល់ទៅផ្ទះ ឲ្យគេអាំងសាច់ដែលបានមកត្រង់ចង្ក្រានមួយ ដាំស្លត្រង់ចង្ក្រានមួយ ឃើញភិក្ខុពីររូបត្រាច់បិណ្ឌ-*

បាត ទើបទទួលបាត្ររបស់លោក និមន្តឲ្យគង់លើអាសនៈដែលបានរៀបចំទុក ឲ្យទទួលអាហារ ហើយបង្គាប់អ្នកដទៃថា ពួកអ្នកចូរទំនុកបម្រុងលោកម្ចាស់ ខ្លួនឯងក៏ដាក់បាយក្នុងថ្នាំង យកស្លឹកឈើចងមាត់ថ្នាំង ហើយកាន់ថ្នាំងដើរទៅ តាមផ្លូវ ក៏កាច់ផ្កាឈើច្រើនប្រភេទ រហូតដល់កន្លែងដែលព្រះថេរៈគង់ ដាក់ថ្នាំងចុះក្នុងទីដែលសមគួរមួយ ហើយពោលថា លោកម្ចាស់ សូមមេត្តាសង្គ្រោះខ្ញុំផងចុះ ទទួលបាត្ររបស់ព្រះថេរៈមក ហើយដាក់បាយដរាបពេញទុកក្នុងដៃព្រះថេរៈ បូជាព្រះថេរៈដោយផ្កាឈើដែលផ្សេងគ្នាទាំងនោះ ឈរក្នុងទីដ៏សមគួរមួយ ហើយពោលថា ក្នុងទីណាដែលខ្ញុំកើតហើយ សូមបណ្ណាការ ១.០០០ ចូរមកដល់ខ្ញុំ សូមភ្លៀងផ្កាឈើ ៥ ពណ៌ ចូរធ្លាក់ចុះ ដូចជាការបូជាដោយផ្កាឈើ ព្រមទាំងបិណ្ឌបាតមានរសឆ្ងាញ់ ហើយធ្វើចិត្តឲ្យរីករាយ ។ ព្រះថេរៈឃើញឧបនិស្ស័យរបស់គេហើយ បានឲ្យកម្មដ្ឋាន មានអាការ ៣២ ជាអារម្មណ៍ ។ គេធ្វើកុសលដរាបអស់ជីវិត ក៏ទៅកើតក្នុងទេវលោក ។ ក្នុងទីដែលលោកកើត ភ្លៀងផ្កាឈើទិព្វធ្លាក់ចុះមានប្រមាណត្រឹមជង្គង់ ទាំងខ្លួនឯងក៏ប្រកបដោយយសក្រៃលែងជាងទេវតាអន្តដទៃៗ ។

គេវិលវល់នៅក្នុងទេវតា និងមនុស្សមួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ ក៏កើតក្នុងត្រកូលសេដ្ឋី ក្នុងនគរមច្ឆិកាសណ្ឌៈ ដែនមគធៈ ។ វេលាគេកើត ភ្លៀងផ្កាឈើ ៥ ពណ៌ ធ្លាក់ចុះប្រមាណត្រឹមជង្គង់ទូទាំងព្រះនគរ ។ គ្រានោះ បិតាមាតា

របស់គេគិតថា បុត្ររបស់យើងនាំឈ្មោះរបស់ខ្លួនមកដោយខ្លួនឯង សូម្បីក្នុងថ្ងៃកើត ទូទាំងព្រះនគរក៏វិចិត្រដោយផ្កាឈើ ៥ ពណ៌ ទើបតាំងនាមគេថា **ចិត្តកុមារ** ។ តមក គេតាំងនៅក្នុងយកវ៉ាសវិស័យ កាលបិតាស្លាប់ទៅ ក៏បានតំណែងជាសេដ្ឋីក្នុងនគរនោះ ។ សម័យនោះ ព្រះថេរៈឈ្មោះថា **មហានាម** ក្នុងចំណោមព្រះថេរបញ្ចវគ្គិយ និមន្តទៅដល់នគរមច្ឆិកាសណ្ឌៈ ចិត្តគហបតីជ្រះថ្លាក្នុងឥរិយាបថរបស់លោក ទើបទទួលបាត្រនាំមកកាន់ផ្ទះ បូជាដោយបិណ្ឌបាត កាលលោកឆាន់ស្រេចហើយ ក៏នាំទៅកាន់ឧទ្យានឈ្មោះ **អម្ពាដការាម** សាងទីនៅថ្វាយព្រះថេរៈក្នុងទីនោះ បានអារាធនាលោកឲ្យទទួលបិណ្ឌបាតក្នុងផ្ទះខ្លួនជានិច្ច ។ សូម្បីព្រះថេរៈឃើញឧបនិស្ស័យរបស់ចិត្តគហបតីនោះ កាលសម្តែងធម៌ ទើបសម្តែងចំពោះតែសឡាយតនវិភង្គប៉ុណ្ណោះ ។ មិនយូរប៉ុន្មាន ចិត្តគហបតីក៏សម្រេចព្រះអនាគាមិផល ។ ព្រោះលោកមានការពិចារណាឃើញសង្ខារ ដែលទុក្ខបៀតបៀនហើយក្នុងកពមុន ។ តមកថ្ងៃមួយ ព្រះឥសិទត្តត្ថេរៈមកនៅក្នុងទីនោះ កាលសម្រេចការឆាន់ក្នុងផ្ទះរបស់សេដ្ឋីហើយ ត្រូវព្រះថេរៈ (មហានាម) សួរ មិនអាចដោះស្រាយបញ្ហា និមន្តទុក ទើបវិសជ្ជនាបញ្ហាដល់ឧបាសក កាលលោកជ្រាបថាជាសម្លាញ់កាលនៅគ្រហស្ថអំពីមុន គិតថា ឥឡូវនេះ មិនគួរនៅក្នុងទីនេះ ទើបចៀសចេញទៅតាមសប្បាយ ។ ថ្ងៃស្អែក ចិត្តគហបតី ទើបអង្វរព្រះមហាកស្សបត្ថេរ[១] ជា

ភិក្ខុចាស់ ដើម្បីធ្វើឥទ្ធិបាដិហារ្យ ។ សូម្បីព្រះថេរៈ ក៏សម្ដែងបាដិហារ្យ ដែលសម្រេចដោយតេជោសមាបត្តិ គិតថា ឥឡូវនេះ មិនសមគួរនៅក្នុងទីនេះ ហើយក៏ចៀសចេញទៅតាមសប្បាយ ។

តមកថ្ងៃមួយ ព្រះអគ្គសាវកទាំងពីរ មានភិក្ខុ ១.០០០ រូបជាបរិវារ ទៅកាន់អម្ពាដការាម ។ ចិត្តគហបតីក៏ត្រៀមសក្ការៈយ៉ាងធំសម្រាប់ព្រះអគ្គសាវកទាំងពីរនោះ ។ ព្រះសុធម្មត្ថេរៈ កាលរុះរានចិត្តគហបតីនោះ ទើបជេរសេដ្ឋីដោយវាទៈថា នាយទំលាយល្វ ត្រូវសេដ្ឋីនោះដេញចេញ ក៏ទៅសំណាក់ព្រះសាស្ដា បានឱវាទ តាំងនៅក្នុងឱវាទព្រះទសពល សូមខមាទោសចិត្តគហបតី ហើយនៅក្នុងអម្ពាដការាមនោះឯង ចម្រើនវិបស្សនាហើយក៏សម្រេចព្រះអរហត្ត ។ គ្រានោះឧបាសកគិតថា យើងមិនបានជួបព្រះទសពលអស់កាលដ៏យូរមកហើយ តែកាលយើងទៅគាល់ព្រះសាស្ដា មិនគួរទៅដៃទទេ ទើបឲ្យវាយស្គរប្រកាសថា នរណាបំណងនឹងគាល់ព្រះទសពល អ្នកទាំងនោះ ចូរយករទេះ ៥០០ ផ្ទុកប្រេង ទឹកឃ្មុំ ទឹកអំពៅទៅជាមួយយើង ក៏មានបរិស័ទ ២.០០០ នាក់ ហែហម នាំគ្នាទៅគាល់ព្រះសាស្ដា ។ តាមផ្លូវគ្រប់ៗ យោជន៍ ពួកទេវតាក៏នាំគ្នាតាំងគ្រឿងបណ្ណាការទុក ។ ចិត្តគហបតីនោះ ទៅកាន់សំណាក់ព្រះសាស្ដា ថ្វាយបង្គំព្រះសាស្ដាដោយ

---

១ ព្រះមហានាមត្ថេរ ។

បញ្ចង្គប្រតិស្ឋាន ។ ខណៈនោះ ភ្លៀងផ្កាឈើ ៥ ពណ៌ ក៏ធ្លាក់ចុះមកពីអាកាស ។ ព្រះសាស្តាទ្រង់ត្រាស់សឡាយតនវិកន្ត ប្រោសមនុស្សទាំងនោះ តាមអធ្យាស្រ័យរបស់ចិត្តគហបតី ។ ចិត្តគហបតីនោះ សូម្បីថ្វាយទានចំពោះព្រះទសពលត្រឹមកន្លះខែ ស្រូវអង្ករ ប្រេង ទឹកឃ្មុំ និងទឹកអំពៅជាដើម ដែលនាំមកពីផ្ទះរបស់ខ្លួន ក៏មិនបានអស់ទៅ ។ គ្រឿងបណ្ណាការដែលអ្នកក្រុងរាជគ្រឹះបញ្ជូនទៅ ក៏នៅត្រឹមតែល្មម ។ ចិត្តគហបតីនោះ គាល់ព្រះសាស្តាហើយ កាលនឹងត្រឡប់ទៅក្រុងរបស់ខ្លួន ក៏បានថ្វាយវត្ថុគ្រប់យ៉ាង ដែលនាំមកដោយរទេះទាំងឡាយដល់ភិក្ខុសង្ឃ ។ ពួកទេវតាក៏ជួយគ្នាធ្វើរតនៈ ៧ ប្រការ ដាក់ពេញរទេះដែលទទេ ។ ក្នុងចំណោមមហាជនក៏កើតការនិយាយគ្នាឡើងថា ចិត្តគហបតី សម្បូរអ្នកការធ្វើសក្ការៈនិងការរាប់អានណាស់ហ្ន៎ ។ ព្រះសាស្តាទ្រង់ស្តាប់រឿងនោះ ទើបត្រាស់ព្រះគាថាក្នុងព្រះធម្មបទ ដូច្នេះថា ៖

សទ្ធោ សីលេន សម្បន្នោ  យសោ ភោគសមប្បិតោ
យំ យំ បទេសំ ភជតិ  តត្ថ តត្ថេវ បូជិតោ ។

បុគ្គលអ្នកមានសទ្ធា ដល់ព្រមដោយសីល ប្រកបព្រមដោយយស
និងភោគសម្បត្តិ ទៅកាន់ប្រទេសណាៗ គេក៏រមែងបូជាក្នុងប្រទេស
នោះៗ ។

តាំងពីនោះមក ចិត្តគហបតីនោះ ក៏មានឧបាសកដែលជាអរិយសាវក ៥០០ នាក់ហែហម ។ តមកខាងក្រោយ ព្រះសាស្តាកាលទ្រង់ស្ថាបនាពួកឧបាសកទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទ្រង់ធ្វើកថាឈ្មោះ **ចិត្តសំយុត្ត** ឲ្យជាអត្ថុប្បត្តិ ទើបទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈ ដែលប្រសើរជាងពួកឧបាសកអ្នកជាធម្មកថិក ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## “ប្រវត្តិហត្ថកអាឡវកឧបាសកអ្នកក្រុងអាឡវី”

ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ៖

[១៥១] ដោយបទថា **ចតូហិ សង្គហវត្ថូហិ** លោកសម្ដែងថា ហត្ថអាឡវកឧបាសក ជាអ្នកប្រសើរជាងពួកឧបាសកអ្នកសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ យ៉ាង ។

បានឮថា ហត្ថអាឡវកឧបាសកនេះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល នាក្រុងហង្សវតី តមក ស្ដាប់ធម្មកថារបស់ព្រះសាស្ដា បានឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសកម្នាក់ ដែលប្រកបដោយសង្គហវត្ថុ ៤ ទុកក្នុងតំណែងឯតទគ្គៈ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ គេវិលវល់នៅក្នុងទេវតា និងមនុស្សរហូតអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះរាជាអាឡវកៈ ក្រុងអាឡវី ដែនអាឡវី ស្អែកឡើង ក៏ត្រូវបញ្ជូនទៅឲ្យអាឡវកយក្ខ ព្រមដោយថាសអាហារ ។ ក្នុងរឿងនោះមានរឿងពោលតាមលំដាប់ ដូច្នេះ ។

បានឮមកថា ថ្ងៃមួយ ព្រះរាជាអាឡវកៈប្រពាតព្រៃដើម្បីបរបាញ់ ស្ដេច

តាមម្រឹគមួយក្បាល សម្លាប់បានហើយ កាត់ជា ២ កំណាត់ ចងទុកត្រង់ចុងធ្នូ ស្ដេចយាងត្រឡប់មកវិញ មានព្រះវរកាយនឿយហត់ព្រោះខ្យល់ និងកំដៅថ្ងៃ ទើបស្ដេចចូលទៅប្រថាប់ក្រោមដើមជ្រៃដែលមានម្លប់ជាទីសប្បាយ ។ ខណៈនោះ ព្រះរាជាបន្ទោបង់សេចក្ដីនឿយហត់បានមួយស្របក់ហើយ ទើបស្ដេចយាងចេញ ទេវតាដែលស្ថិតនៅនឹងដើមជ្រៃក៏ចាប់ព្រះហស្តព្រមទាំងពោលថា ឈប់ ឈប់ លោកត្រូវជាអាហាររបស់យើង ។ ព្រោះត្រូវចាប់យ៉ាងមាំ ព្រះរាជាស្ដេចក៏ទ្រង់មិនឃើញឧបាយយ៉ាងដទៃ ទើបត្រាស់ថា យើងនឹងបញ្ជូនភាជន៍អាហារ ព្រមទាំងមនុស្សម្នាក់ៗ ឲ្យដល់លោករាល់ថ្ងៃ ស្ដេចក៏ត្រឡប់ទៅកាន់ព្រះនគរ តាំងពីនោះមក ទ្រង់ក៏បញ្ជូនភាជន៍អាហារព្រមទាំងមនុស្សម្នាក់ៗ អំពីគុក ។ ដោយទំនងនេះឯង កាលមនុស្សក្នុងគុកអស់ហើយ ពួកមនុស្សចាស់ៗ ក៏ត្រូវចាប់បញ្ជូនទៅ សេចក្ដីភិតភ័យក៏កើតឡើងក្នុងក្រុង ។ ពួករាជបុរសចាប់មនុស្សទាំងនោះមិនបាន ក៏ផ្ដើមចាប់ពួកក្មេងតូចៗ ។ តាំងពីនោះមក ម្ដាយរបស់ក្មេងៗ និងស្ត្រីមានគភ៌ក្នុងព្រះនគរក៏នាំគ្នាទៅកាន់រដ្ឋដទៃ ។

សម័យនោះ ព្រះសាស្ដាទ្រង់ពិចារណាមើលលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃមគ្គផល ៣ របស់អាឡវកកុមារ ទ្រង់ព្រះតម្រិះថា កុមារម្នាក់នេះ តាំងសេចក្ដីប្រាថ្នាទុកមកអស់សែនកប្ប ចុតិចាកទេវលោកហើយ កើត

ក្នុងព្រះរាជនិវេសន៍របស់ព្រះរាជាអាឡវកៈ ព្រះរាជាកាលមិនបានអ្នកដទៃ ក៏ចាប់ព្រះកុមារទៅព្រមទាំងភាជន៍អាហារក្នុងថ្ងៃស្អែកនេះ ដូច្នេះហើយ ក្នុងវេលាល្ងាច ទើបព្រះមានព្រះភាគបន្ទំព្រះអង្គទៅកាន់ទីនៅរបស់អាឡវកយក្ខ ។ សូមយក្ខដែលមានឈ្មោះ គទ្រភៈ ជាអ្នករក្សាទ្វារ ដើម្បីស្តេចចូលទៅកាន់ទីនៅរបស់យក្ខ ។ គទ្រភយក្ខនោះទូលថា បពិត្រព្រះមានព្រះភាគ សូមស្តេចយាងចូលទៅចុះ ចំណែកខ្ញុំព្រះអង្គមិនប្រាប់អាឡវកយក្ខ មិនគួរទេ ទើបបានទៅកាន់សំណាក់អាឡវកយក្ខដែលបានទៅកាន់សមាគមយក្ខក្នុងហិមវន្តប្រទេស ។ សូម្បីព្រះសាស្តា ស្តេចក៏ចូលទៅដល់ទីនៅហើយ ក៏ទ្រង់ប្រថាប់លើបល្ល័ង្ក ទីអង្គុយរបស់អាឡវកយក្ខ ។ សម័យនោះ សាតាគិរយក្ខ និងហេមវតយក្ខ កំពុងធ្វើដំណើរទៅកាន់សមាគមយក្ខកន្លងផ្លូវខាងលើទីនៅរបស់អាឡវកយក្ខ កាលទៅទៀតមិនបាន ក៏នឹកថា មានហេតុអ្វីហ្ន៎ ឃើញព្រះសាស្តាប្រថាប់ក្នុងភពរបស់អាឡវកយក្ខ ក៏ចូលទៅគាល់ព្រះសាស្តាថ្វាយបង្គំហើយ ទើបទៅកាន់សមាគមយក្ខ ប្រកាសសេចក្តីត្រេកអរដល់អាឡវកយក្ខថា អាឡវកៈ លោកមានលាភធំហើយ ដែលព្រះមានព្រះភាគជាអគ្គបុគ្គលក្នុងលោកព្រមទាំងទេវលោក ប្រថាប់ក្នុងទីនៅរបស់លោក ចូរទៅស្តាប់ធម៌ក្នុងសំណាក់ព្រះសាស្តាចុះ ។ អាឡវកយក្ខស្តាប់ពាក្យរបស់យក្ខទាំងពីរនោះហើយ ក៏គិតថា យក្ខទាំងពីរនេះនិយាយថា ព្រះសមណៈត្រងោលមួយរូប

អន្ទុយលើបល្ល័ង្ករបស់យើង ក៏មិនពេញចិត្ត ក្រេវក្រោធយ៉ាងខ្លាំង និយាយថា ថ្ងៃនេះ យើងនឹងសមណៈរូបនេះ នឹងត្រូវធ្វើសង្គ្រាមជាមួយគ្នា ពួកលោកចូរជាសម្លាញ់យើងក្នុងសង្គ្រាមនោះ ហើយក៏លើកជើងខាងស្តាំជាន់កំពូលភ្នំទំហំប្រមាណ ៦០ យោជន៍ ។ កំពូលភ្នំនោះ ក៏បែកជាពីរចំណែក ។ តាំងពីនោះ គប្បីពោលរឿងការច្បាំងរបស់អាឡវកយក្ខឲ្យពិស្តារ ។

ក៏អាឡវកយក្ខ សូម្បីច្បាំងជាមួយព្រះតថាគតដោយអាការផ្សេងៗ រហូតអស់មួយយប់ទល់ភ្លឺ ក៏មិនអាចធ្វើអ្វីបាន ទើបចូលទៅរកព្រះសាស្តាសួរបញ្ហា ៨ ប្រការ ព្រះសាស្តាក៏ទ្រង់វិសជ្ជនា ។ ចប់ទេសនា អាឡវកយក្ខក៏បានតាំងនៅក្នុងសោតាបត្តិផល ។ លោកអ្នកប្រាថ្នានឹងពោលឲ្យពិស្តារ គប្បីត្រូតមើលក្នុងអដ្ឋ-កថាអឡវកសូត្រ ។ ក្នុងថ្ងៃស្អែក កាលអរុណរះ វេលានាំកាជន៍អាហារទៅ ពួករាជបុរសមិនឃើញក្មេងដែលគួរនឹងចាប់ទូទៅក្នុងព្រះនគរ ទើបក្រាបទូលចំពោះព្រះរាជា ព្រះរាជាត្រាស់ថា បាអើយ ក្មេងមាននៅក្នុងទីមិនគួរនឹងចាប់បាន មិនមែនឬ ។ ពួកគេក្រាបទូលថា យ៉ាងនោះហើយ ព្រះអង្គ ថ្ងៃនេះ រាជឱរសប្រសូតក្នុងរាជត្រកូល ព្រះអង្គទើបត្រាស់ថា បាចូរយកទៅ កាលយើងនៅមានជីវិត នឹងបានកូនទៀត ចូរបញ្ជូនក្មេងនោះទៅព្រមជាមួយកាជន៍អាហារ ។ កាលព្រះទេវីទ្រង់ព្រះកន្សែង រាជបុរសទាំងនោះ ក៏នាំព្រះកុមារទៅដល់ទីនៅរបស់អាឡវកយក្ខ

ព្រមទាំងភាជន៍អាហារ ពោលថា សូមទទួលយកនូវចំណែករបស់លោកចុះ ។ អាឡវកយក្ខស្តាប់ពាក្យរបស់បុរសទាំងនោះហើយ ក៏នឹកខ្មាសខ្លួនឯង ព្រោះខ្លួនជាព្រះអរិយសាវកហើយ បានតែអង្គុយឱនមុខ ។ លំដាប់នោះ ព្រះសាស្តាត្រាស់ចំពោះគេថា អាឡវកៈ ឥឡូវនេះ អ្នកមិនមានកិច្ចដែលនឹងត្រូវខ្មាសទេ ចូរបីក្មេងដាក់លើដៃតថាគតមក ។ ពួករាជបុរស ក៏ដាក់អាឡវកកុមារក្នុងដៃអាឡវកយក្ខៗ ក៏បីក្មេងដាក់ទុកក្នុងព្រះហស្តរបស់ព្រះទសពល ។ ចំណែកព្រះសាស្តាទ្រង់ទទួលហើយ ក៏ទ្រង់ដាក់ទុកក្នុងដៃអាឡវកយក្ខវិញ ។ អាឡវកយក្ខលើកក្មេងដាក់ទុកក្នុងដៃរបស់ពួករាជបុរស ។ ព្រោះព្រះកុមារនោះ ចាកអំពីដៃមួយទៅកាន់ដៃមួយទៀត ដូចពោលមកនេះ ទើបនាំគ្នាតាំងព្រះនាមកុមារនោះថា **ហត្ថអាឡវកៈ** ។ គ្រានោះ រាជបុរសទាំងនោះមានសេចក្តីត្រេកអរ នាំព្រះកុមារនោះទៅកាន់សំណាក់ព្រះរាជា ។ ព្រះរាជាទតឃើញព្រះកុមារនោះ ទ្រង់ជ្រាបថា ថ្ងៃនេះ អាឡវកយក្ខមិនទទួលភាជន៍អាហារ ទើបត្រាស់សួរថា ហេតុអ្វីពួកអ្នកទើបនាំគ្នាមកយ៉ាងនេះ ។ ពួកគេក្រាបទូលថា មហាបពិត្រ សេចក្តីត្រេកអរ និងសេចក្តីចម្រើនមានដល់រាជត្រកូលហើយ ព្រះសាស្តាប្រថាប់ក្នុងភពរបស់អាឡវកយក្ខ ទ្រង់ទូន្មានអាឡវកយក្ខឲ្យគេតាំងនៅក្នុងភាវៈជាឧបាសក ទ្រង់ប្រោសឲ្យអាឡវកយក្ខឲ្យព្រះកុមារដល់ពួកខ្ញុំព្រះអង្គ ព្រះអង្គ ។ សូម្បីព្រះសាស្តា ក៏ទ្រង់

ឲ្យអាឡវកយក្ខកាន់បាត្រចីវរ ស្តេចបែរព្រះភ័ក្ត្រកាន់នគរអាឡវី ។ អាឡវកយក្ខនោះ កាលនឹងចូលកាន់ព្រះនគរ ក៏មានសេចក្តីខ្មាស គិតនឹងត្រឡប់ថយក្រោយ ព្រះសាស្តាទ្រង់ក្រឡេកមើល ហើយត្រាស់សួរថា ខ្មាសឬអាឡវកៈ ។ គេទូលថា ព្រះអង្គ អ្នកនគរអាស្រ័យខ្ញុំព្រះអង្គ ទើបទាំងម្តាយ ទាំងកូន ទាំងប្រពន្ធ នាំគ្នាស្លាប់ ពួកគេឃើញខ្ញុំព្រះអង្គហើយ នឹងប្រហារដោយកំណាត់ឈើខ្លះ ដុំដីខ្លះ ធ្នូខ្លះ ព្រោះហេតុនោះ ខ្ញុំព្រះអង្គទើបនឹងថយត្រឡប់ ព្រះអង្គ ។ ព្រះសាស្តាត្រាស់លួងលោមថា អាឡវកៈ មិនអីទេ កាលអ្នកទៅជាមួយតថាគតនឹងអស់ភ័យ មកទៅជាមួយតថាគត ប្រថាប់ឈប់ត្រង់ជង់ព្រៃមិនឆ្ងាយពីព្រះនគរ ។ សូម្បីព្រះរាជាអាឡវកៈ ក៏ទ្រង់នាំអ្នកព្រះនគរចេញទៅទទួលព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ក៏សម្តែងធម៌ប្រោសបរិស័ទដែលមកដល់ ។ ចប់ទេសនា ពួកសត្វ ៨៤.០០០ ក៏បានផឹកនូវទឹកអម្រឹត ។ អ្នកក្រុងអាឡវីទាំងនោះ នាំគ្នាទៅកាន់ទីនៅរបស់អាឡវកយក្ខ ក្នុងជង់ព្រៃនោះឯង ចាត់ចែងពលីកម្មរាល់ៗ ឆ្នាំ ។ សូម្បីអាឡវកយក្ខ ក៏សង្គ្រោះអ្នកនគរដោយធម្មរក្សា ។

អាឡវកកុមារនោះ កាលចម្រើនវ័យហើយ ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ក៏ត្រាស់ដឹងមគ្គ និងផល ៣ មានឧបាសកដែលជាអរិយសាវក ៥០០ នាក់ ហែហមគ្រប់វេលា ។ តមកថ្ងៃមួយ គេចូលទៅគាល់ព្រះសាស្តា ព្រមទាំង

ឧបាសក ៥០០ នាក់ ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្ដា ទតឃើញគេមានវិន័យល្អ ទើបត្រាស់សួរថា អាឡវកៈ អ្នកមានបរិស័ទដ៏ច្រើន អ្នកសង្គ្រោះគ្នាយ៉ាងណា ។ គេក្រាបទូលថា បពិត្រព្រះមានព្រះភាគ កាលគេត្រេកអរដោយការឲ្យ ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការឲ្យ កាលគេត្រេកអរដោយការនិយាយគួរស្រឡាញ់ ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការនិយាយគួរស្រឡាញ់ កាលគេត្រេកអរឲ្យជួយធ្វើកិច្ចការដែលកើតឡើងឲ្យសម្រេច ខ្ញុំព្រះអង្គក៏នឹងសង្គ្រោះដោយការជួយធ្វើកិច្ចការដែលកើតឡើងឲ្យសម្រេច កាលគេត្រេកអរដោយការឲ្យដាក់ខ្លួនស្មើគ្នា ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការដាក់ខ្លួនស្មើគ្នា ព្រះអង្គ ។ រឿងដែលកើតឡើងយ៉ាងនេះ ។ តមកខាងក្រោយ ព្រះសាស្ដាប្រថាប់ក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសកទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាហត្ថអាឡវកឧបាសកទុកក្នុងតំណែងឯតទគ្គៈ ដែលប្រសើរជាងពួកឧបាសកអ្នកសង្គ្រោះបរិស័ទដោយសង្គហវត្ថុ ៤ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## “ប្រវត្តិព្រះសក្យមហានាម”

*ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ៖*

[១៩១] *ដោយបទថា* ***បណីតទាយកានំ*** *លោកសម្ដែងថា ព្រះសក្យមហានាម ប្រសើរជាងពួកឧបាសកអ្នកថ្វាយទានដែលមានរសប្រណីត ។ ដូចបានស្ដាប់មក សក្យមហានាមនោះ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *កើតក្នុងត្រកូលក្នុងក្រុងហង្សវតី កំពុងស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកថ្វាយទានដែលមានរសប្រណីត ។ ទើបធ្វើកុសលឲ្យក្រៃលែង ប្រាថ្នាតំណែងនោះ ។ លោកវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងសក្យរាជត្រកូល ក្នុងក្រុងកបិលកស្ដុ ទ្រង់ចម្រើនវ័យហើយ តាំងនៅក្នុងព្រះសោតាបត្តិផល ដោយការគាល់ព្រះទសពលគ្រាដំបូងប៉ុណ្ណោះ ។ តមកសម័យមួយ ព្រះសាស្ដាស្ដេចចាំវស្សាក្នុងក្រុងវេរញ្ជា ហើយស្ដេចទៅក្រុងកបិលកស្ដុ ដោយលំដាប់ ប្រថាប់ក្នុងនិគ្រោធារាម ព្រះបាទមហានាមទ្រង់ជ្រាបថា ព្រះសាស្ដាស្ដេចមក ទើបចូលទៅគាល់ ថ្វាយបង្គំហើយ ប្រថាប់អង្គុយក្នុងទីដ៏សមគួរមួយ ក្រាបទូលព្រះសាស្ដាយ៉ាងនេះថា បពិត្រព្រះដ៏មានព្រះភាគ ខ្ញុំព្រះអង្គបានស្ដាប់*

មកថា គេថាភិក្ខុសង្ឃលំបាកដោយការត្រាច់សូមអាហារក្នុងក្រុងវេរញ្ជា សូមព្រះអង្គទ្រង់ប្រទានបេ្កជ្ជា ទ្រង់មេត្តាឲ្យខ្ញុំព្រះអង្គទំនុកបម្រុងភិក្ខុសង្ឃរហូតអស់ ៤ ខែចុះ ខ្ញុំព្រះអង្គនឹងបញ្ចុះឱជៈចូលទៅក្នុងសរីរៈរបស់ភិក្ខុសង្ឃ ព្រះអង្គ ។ ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព ព្រះបាទមហានាម ទ្រង់ជ្រាបថា ទ្រង់ទទួលហើយ តាំងពីថ្ងៃស្អែក ក៏ទំនុកបម្រុងភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយភោ-ជនដ៏ប្រណីត និងរបស់មានរសឆ្ងាញ់ ៤ ប្រភេទ ជាដើម ទទួលបេ្កជ្ជាទំនុកបម្រុង ៤ ខែទៀត ត្រូវជា ៨ ខែ ហើយទទួលបេ្កជ្ជាទំនុកបម្រុងទៀត ៤ ខែ ឈ្មោះថាទ្រង់ទំនុកបម្រុងគ្រប់មួយឆ្នាំ ។ ព្រះសាស្តាមិនបានប្រទានបដិញ្ញាទទួលអារាធនាបន្តអំពីនោះ ។ ចំណែកព្រះបាទមហានាម ទ្រង់ធ្វើសក្ការៈដល់ភិក្ខុសង្ឃដែលមកដល់ តៗ មក ដោយទំនងនេះឯង ។ កិត្តិនោះ របស់មហានាមសក្យៈ ក៏ខ្ចរខ្ចាយទៅទូទាំងជម្ពូទ្វីប ។ រឿងកើតឡើងយ៉ាងនេះឯង ។ តមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនវិហារ ទើបទ្រង់ស្ថាបនាព្រះសក្យមហានាម ទុកក្នុងតំណែងឯតទគ្គៈប្រសើរជាងពួកឧបាសក អ្នកថ្វាយទានដែលមានរសប្រណីត ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## ប្រវត្តិឧគ្គគហបតីអ្នកក្រុងវេសាលី

ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥១] ដោយបទថា **មនាបទាយកានំ** លោកសម្តែងថា **ឧគ្គហបតី** អ្នកក្រុងវេសាលី ប្រសើរជាងពួកឧបាសកអ្នកថ្វាយភោជនដែលពេញចិត្ត ។

ដូចបានស្តាប់មក ឧគ្គហបតីនោះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល នាក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកមួយរូបទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកថ្វាយភោជនដែលពេញចិត្ត បានធ្វើកុសលដ៏ក្រៃលែងប្រាថ្នាតំណែងនោះ ។ លោកវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី នៅក្រុងវេសាលី ។ វេលាលោកកើត មានឈ្មោះមិនពិតប្រាកដ ។ តែតមក រាងកាយរបស់លោកខ្ពស់ឡើង ៗ ស្រស់ល្អដូចសសរខឿនដែលតុបតែងហើយ ដូចផ្ទាំងសំពត់ដែលវិចិត្រដោយក្បាច់ដែលគេលើកឡើង ។ ទាំងគុណទាំងឡាយរបស់លោកក៏ខ្ពស់ខ្ពង់ទៅ ។ លោកទើបឈ្មោះថា **ឧគ្គសេដ្ឋី** ព្រោះរាងកាយ និងគុណទាំងពីរនេះ ខ្ពស់ខ្ពង់ទៅ ។ ឧគ្គហបតីនេះ តាំងនៅក្នុង

សោតាបត្តិផល ដោយការគោល់ព្រះទសពលគ្រាដំបូងប៉ុណ្ណោះ តមក ក៏ធ្វើឲ្យជាក់ច្បាស់មគ្គ និងផល ៣ ។ វេលាចាស់ លោកទៅក្នុងទីស្ងាត់អង្គុយគិតថា វត្ថុណាៗជាទីស្រឡាញ់ ជាទីពេញចិត្តរបស់យើង យើងនឹងថ្វាយវត្ថុនោះៗ ឯង ចំពោះព្រះទសពល យើងបានស្តាប់ពាក្យនេះក្នុងទីចំពោះព្រះភ័ក្ត្រព្រះសាស្តាថា បុគ្គលអ្នកថ្វាយរបស់ដែលពេញចិត្ត រមែងបានរបស់ដែលពេញចិត្ត ដូច្នេះ ។ គ្រានោះលោកត្រិះរិះយ៉ាងនេះថា ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់យើងខ្វះទេហ្ន៎ នឹងស្តេចគប្បីមកកាន់ទ្វារនិវេសន៍ ។ សូម្បីព្រះសាស្តា ក៏ទ្រង់ជ្រាបចិត្តរបស់លោក មានភិក្ខុសង្ឃ៥០០ហែហម ស្តេចមកប្រាកដត្រង់ទ្វារនិវេសន៍រំពេចនោះឯង ។ លោកជ្រាបថាព្រះសាស្តាស្តេចយាងមកហើយ ក៏ប្រញាប់ប្រញាល់ដើរទៅកាន់សំណាក់ព្រះទសពល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយទទួលបាត្ររបស់ព្រះសាស្តា អារាធនាព្រះសាស្តាចូលទៅក្នុងផ្ទះ ហើយអារាធនាព្រះសាស្តាប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរដែលចាត់ចែងទុក អារាធនាភិក្ខុសង្ឃគង់លើអាសនៈដ៏សេស បានថ្វាយភោជនដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយអាហារមានរសប្រសើរផ្សេងៗគ្រាសម្រេចភត្តកិច្ច អង្គុយក្នុងទីដ៏សមគួរមួយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់មកចំពោះព្រះភ័ក្ត្រ ទទួលមកចំពោះព្រះភ័ក្ត្រព្រះមានព្រះភាគថា បុគ្គលដែលថ្វាយរបស់ជាទីពេញចិត្ត រមែងបានរបស់ដែលជា

ទីពេញចិត្ត ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន វត្ថុណាៗ ដែលជាទីពេញចិត្តរបស់ខ្ញុំព្រះអង្គ វត្ថុនោះៗ ខ្ញុំព្រះអង្គបានថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ធ្វើព្រះសាស្ដាឲ្យទ្រង់ជ្រាបហើយ រាប់តាំងអំពីនោះទៅ ក៏ថ្វាយវត្ថុដែលពេញចិត្តដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ក៏រឿងទាំងអស់នោះ មកហើយក្នុងឧគ្គសូត្របញ្ចកនិបាតនោះឯង ។ រឿងនេះកើតឡើងយ៉ាងនេះ ។ តមកខាងក្រោយ ព្រះសាស្ដាប្រថាប់នៅក្នុងព្រះជេតពនវិហារ ទ្រង់បានស្ថាបនាឧបាសកម្នាក់នេះទុកក្នុងតំណែងឯតទគ្គៈ ប្រសើរបំផុតជាងពួកឧបាសក អ្នកថ្វាយភោជនដែលជាទីពេញចិត្ត ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## ប្រវត្តិឧគ្គតគហបតីអ្នកស្រុកហត្ថិគ្រាម

ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥១] ដោយបទថា **សង្ឃុបដ្ឋាកានំ** លោកសម្តែងថា **ឧគ្គតគហបតី** អ្នកស្រុកហត្ថិគ្រាម ប្រសើរជាងពួកឧបាសកអ្នកឧបដ្ឋាកភិក្ខុសង្ឃ ។

ដូចបានស្តាប់មក ឧគ្គតគហបតីនោះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល នាក្រុងហង្សវតី តមក ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកមួយនាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកឧបដ្ឋាកភិក្ខុសង្ឃ ធ្វើកុសលដ៏ក្រៃលែង ប្រាថ្នាក្នុងតំណែងនោះ ។ លោកវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទ-កាលនេះ កើតក្នុងត្រកូលសេដ្ឋី ស្រុកហត្ថិគ្រាម ។ ពួកញាតិបានតាំងនាមថា **ឧគ្គតកុមារ** ។ តមក លោកតាំងនៅក្នុងយកាវាសវិស័យ បិតាបានធ្វើមរណៈភាពទៅ ក៏បានតំណែងជាសេដ្ឋី ។ សម័យនោះ ព្រះសាស្តាទ្រង់មានភិក្ខុសង្ឃហែហម ស្តេចបានចារិកទៅដល់ស្រុកហត្ថិគ្រាម ប្រថាប់នៅក្នុងឧទ្យាននាគកវនៈ គ្រានោះ ឧគ្គតសេដ្ឋីនេះ ស្រវឹងទឹកស្រវឹងអស់ ៧ ថ្ងៃ ត្រូវពួកអ្នករបាំ រាំហែហមទៅកាន់

ឧទ្យាននាគកវនៈនោះឯង លុះឃើញព្រះទសពល ហិរិឱត្តប្បៈដ៏មានកម្លាំងក៏កើតឡើង ។ កាលគេចូលគាល់ព្រះសាស្តា ភាពស្រវឹងសុរា ក៏បាត់ទៅអស់ ។ គេថ្វាយបង្គំព្រះសាស្តា ហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ គ្រានោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់គេ ។ ចប់ទេសនា គេក៏ត្រាស់ដឹងមគ្គ និងផល ៣ ។ តាំងពីនោះមក គេក៏លះបង់ពួកអ្នករបាំ និងការរាំច្រៀង ដោយពោលថា ពួកអ្នកចូរទៅតាមសេចក្តីពេញចិត្តចុះ ។ ជាអ្នកត្រេកអរក្រៃលែងក្នុងទាន ថ្វាយទានដល់ភិក្ខុសង្ឃប៉ុណ្ណោះ ។ ទេវតាមករកក្នុងចន្លោះរាត្រី ហើយប្រាប់ដល់សេដ្ឋីថា លោកសេដ្ឋី ភិក្ខុអង្គឯណោះមានវិជ្ជា ៣ ភិក្ខុអង្គឯណោះមានអភិញ្ញា ៦ អង្គឯណោះមានសីល អង្គឯណោះទ្រុស្តសីល ។ គេស្តាប់ពាក្យរបស់ទេវតានោះហើយ ក៏ដឹងគុណតាមសេចក្តីនោះឯង ។ តែគេក៏ថ្វាយទេយ្យធម៌ដោយចិត្តស្មើតែម្យ៉ាង សូម្បីអង្គុយនៅក្នុងសំណាក់ព្រះសាស្តា ក៏ពោលតែគុណនោះឯង ។ តមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនវិហារ ទ្រង់ស្ថាបនាគហបតីនោះ ទុកក្នុងតំណែងឯតទគ្គៈ ជាអ្នកប្រសើរជាងពួកឧបាសកដែលជាអ្នកឧបដ្ឋាកដល់ភិក្ខុសង្ឃ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## ប្រវត្តិសូរអម្ពដ្ឋឧបាសក

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥១] ដោយបទថា ***អវេច្ចប្បសន្នានំ*** លោកសម្តែងថា ***បុរពន្ធសេដ្ឋីឧបាសក*** (បាលីថា សូរអម្ពដ្ឋៈ) ប្រសើរជាងពួកឧបាសកអរិយសាវកដែលជ្រះថ្លាមិនញាប់ញ័រ ។

ដូចបានស្តាប់មក ឧបាសកនេះ សម័យព្រះសម្ពុទ្ធព្រះនាមថា ***បទុមុត្តរៈ*** កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី ស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកដែលជ្រះថ្លាមិនញាប់ញ័រ បានធ្វើកុសលដ៏ក្រៃលែង ប្រាថ្នាតំណែងនោះ ។ គេវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី ។ ពួកញាតិបានតាំងនាមថា ***បុរពន្ធៈ*** ។ តមក គេចម្រើនវ័យ តាំងនៅក្នុងយាវាសវិស័យ ជាឧបដ្ឋាករបស់ពួកអន្យតិរ្ថិយ៍ ។ គ្រានោះ ព្រះសាស្តាទ្រង់ត្រួតមើលលោកវេលាជិតភ្លឺ ទ្រង់ឃើញហេតុនៃសោតាបត្តិមគ្គរបស់គេ ទើបស្តេចទៅដល់ទ្វារនិវេសន៍ ក្នុងវេលាបិណ្ឌបាត ។ គេឃើញព្រះទសពល ទើបគិតថា

ព្រះសមណគោតមទ្រង់ឧប្បត្តិក្នុងត្រកូលធំ និងជាអ្នកដែលមហាជនស្គាល់យ៉ាង ច្រើនក្នុងលោក ព្រោះហេតុនោះ ការមិនទៅកាន់សំណាក់របស់ព្រះសមណគោតម នោះ មិនសមគួរ ។ គេទើបទៅកាន់សំណាក់ព្រះសាស្តា ក្រាបត្រង់ព្រះយុគលបាទ ទទួលបាត្រហើយអារាធនាឲ្យស្ដេចយាងចូលទៅផ្ទះ អារាធនាព្រះអង្គប្រថាប់លើ បល្ល័ង្កមានតម្លៃច្រើន ថ្វាយភិក្ខា កាលសម្រេចភត្តកិច្ច ទើបអង្គុយក្នុងទីដែល សមគួរមួយ ព្រះសាស្តាទ្រង់សម្តែងធម៌តាមអំណាចចរិយារបស់គេ ។ ចប់ទេសនា គេក៏តាំងនៅក្នុងសោតាបត្តិផល សូម្បីព្រះសាស្តាទ្រង់ទូន្មានគេហើយ ស្ដេចក៏យាង ទៅព្រះជេតពនវិហារ ។ លំដាប់នោះ មារគិតថា ឈ្មោះថា បុរពន្ធ:នេះ ជាសម្បត្តិ របស់យើង តែព្រះសាស្តាស្ដេចទៅផ្ទះគេថ្ងៃនេះ ទ្រង់បានធ្វើឲ្យមគ្គប្រាកដ ព្រោះ ស្តាប់ធម៌របស់ព្រះសាស្តាឬទេហ្ន៎ សូម្បីយើងនឹងដឹងថា គេរួចផុតពីវិស័យរបស់ យើង ឬមិនទាន់រួចផុត ទើបនិម្មិតរូបស្រដៀងព្រះទសពល ទាំងទ្រទ្រង់ចីវរ ទាំង ប្រដាប់បាត្រ ធ្វើដំណើរដោយអាកប្បកិរិយារបស់ព្រះពុទ្ធ ទ្រទ្រង់ព្រះលក្ខណ: ៣២ ប្រការ បានប្រថាប់ឈរជិតទ្វារផ្ទះរបស់បុរពន្ធឧបាសក ។ សូម្បីបុរពន្ធឧបា- សក ដឹងថា ព្រះទសពលស្ដេចមកទៀតហើយ ក៏គិតថា ធម្មតាការយាងទៅរបស់ ព្រះពុទ្ធទាំងឡាយមិនពិត មិនមានឡើយ ហេតុអ្វីហ្ន៎ ទើបស្ដេចត្រឡប់មកវិញ ដូច្នេះ ទើបប្រញាប់ចូលទៅកាន់សំណាក់ព្រះពុទ្ធអង្គដោយសម្គាល់ថា ព្រះទសពល

ថ្វាយបង្គំហើយ ឈរក្នុងទីដ៏សមគួរមួយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ធ្វើភត្តកិច្ចស្រេចហើយក្នុងផ្ទះរបស់ខ្ញុំព្រះអង្គ ទ្រង់អាស្រ័យអ្វី ទើបស្តេចមកទៀត ។ មារពោលថា ម្នាលបុរពន្នៈ យើងកាលពោលធម៌មិនទាន់បានពិចារណា ទើបពោលពាក្យមួយ ការពិត យើងពោលថា បញ្ចក្ខន្ធទាំងអស់ មិនទៀង ជាទុក្ខ ជាអនត្តា តែសេចក្តីពិត មិនមែនទាំងអស់នោះទេ ព្រោះថា ខន្ធពួកខ្លះ ទៀង តាំងមាំ ស្ថិតស្ថេរ មាន ។ ពេលនោះ បុរពន្នឧបាសកគិតថា រឿងនេះជារឿងធ្ងន់ណាស់ ធម្មតាថា ព្រះពុទ្ធទាំងឡាយ ត្រាស់ជាពាក្យពីរមិនមាន ។ ទើបពិចារណាថា ដែលឈ្មោះថា មារជាសត្រូវរបស់ព្រះទសពល បុគ្គលនេះពិតជាមារ ទើបពោលថា លោកជាមារឬ ។ ពាក្យដែលព្រះអរិយសាវកពោល ប្រៀបដូចជាយកពូថៅគាស់ធ្មេញមារនោះ ។ ព្រោះហេតុនោះ មារទើងតាំងនៅដោយភាវៈរបស់ខ្លួនមិនបាន ទើបពោលថា មែន បុរពន្នៈ យើងជាមារ ។ បុរពន្នឧបាសក ទើបលើកម្រាមដៃចង្អុលពោលថា មារទាំង ១០០ ទាំង ១.០០០ ក៏មកធ្វើសទ្ធារបស់យើងឲ្យញាប់ញ័រមិនបានទេ ។ ព្រះទសពលមហាគោតម កាលទ្រង់សម្តែងធម៌ដល់យើង ក៏ទ្រង់សម្តែងធម៌ដាស់ឲ្យយើងភ្ញាក់ថា សង្ខារទាំងពួងមិនទៀង ។ លោកកុំឈរនៅជិតទ្វារផ្ទះរបស់យើង មារស្តាប់ពាក្យរបស់បុរពន្នឧបាសកនោះហើយ ក៏ថយក្រោយ មិនអាចនិយាយតបបាន ហើយអន្តរធានទៅ

ក្នុងទីនោះឯង ។ សូម្បីបុរពន្ធឧបាសក វេលាល្ងាច ក៏ចូលទៅគាល់ព្រះសាស្ដា ក្រាបទូលកិរិយាដែលមារធ្វើ ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន មារព្យាយាមធ្វើសទ្ធារបស់ខ្ញុំព្រះអង្គឲ្យញាប់ញ័រ ព្រះសាស្ដាទ្រង់ធ្វើហេតុនោះឯង ឲ្យហេតុកើតរឿង ទើបទ្រង់ស្ថាបនាបុរពន្ធឧបាសកទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកជ្រះថ្លាមិនញាប់ញ័រ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

## ប្រវត្តិពេទ្យជីវកកោមារភច្ច

*ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៥១] បទថា **បុគ្គលប្បសន្នានំ** លោកសម្ដែងថា ពេទ្យជីវកកោមារភច្ច ប្រសើរជាងពួកឧបាសកអ្នកប្រកបដោយសេចក្ដីជ្រះថ្លាក្នុងបុគ្គល ។*

*ដូចបានស្ដាប់មក ពេទ្យជីវកនោះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី កំពុងស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកជ្រះថ្លាក្នុងបុគ្គល ធ្វើកុសលដ៏ក្រៃលែង ហើយប្រាថ្នាតំណែងនោះ ។ លោកវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់ស្ត្រី ឈ្មោះសាលវតី អាស្រ័យរូបចិញ្ចឹមជីវិត អាស្រ័យអភ័យរាជកុមារនៅក្នុងក្រុងរាជគ្រឹះ ។ ឈ្មោះថា ស្ត្រីអ្នកអាស្រ័យរូបចិញ្ចឹមជីវិត វេលាប្រសូត បើជាបុត្រប្រុស ក៏បោះបង់ចោល បើបុត្រជាស្រី ក៏ចិញ្ចឹមទុក ។ ដូច្នោះនាងទើបយកកញ្ច្រែដាក់ក្មេងប្រុសនោះចោលត្រង់គំនរសំរាម ។ គ្រានោះ អភ័យរាជកុមារ ស្ដេចទៅកាន់ទីចូលគាល់ ទតឃើញក្មេងប្រុសនោះ ទើបត្រាស់សួរថា នាយ*

អ្វីនោះ ហ្វូងក្អែកទើបចោមរោមដូច្នេះ ទ្រង់បញ្ជូនពួករាជបុរសទៅ កាលគេក្រាបទូលថា ទារក ព្រះអង្គ ។ ត្រាស់សួរថា នៅរស់ឬ នាយ ។ ទ្រង់បានជ្រាបថា នៅរស់ ព្រះអង្គ ។ ទើបទ្រង់ប្រោសឲ្យនាំទៅចិញ្ចឹមខាងក្នុងបុរីរបស់ព្រះអង្គ ។ គេនាំគ្នាតាំងនាមលោកថា **ជីវក** ។ ពេលអាយុបាន ១៦ ឆ្នាំ ក៏ទៅក្រុងតក្កសិលា រៀនវិជ្ជាពេទ្យ បានលាភសក្ការៈពីសំណាក់ព្រះបាទពិម្ពិសារដែលទ្រង់ប្រទាន បានធ្វើព្រះរោគរបស់ព្រះបាទចណ្ឌបជ្ជោតឲ្យជា ជរាបទ្រង់នៅជាសុខ ស្តេចទ្រង់បានបញ្ជូនស្រូវ ៥០០ រទេះ កហាបណៈ ១៦.០០០ និងគូសំពត់ដែនកាសី ដែលប្រមាណតម្លៃមិនបាន ទាំងសំពត់បរិវាររាប់ចំនួន ១.០០០ ទ្រង់ព្រះរាជទានដល់ពេទ្យជីវកនោះ ។ សម័យនោះ ព្រះសាស្តាទ្រង់អាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅត្រង់ភ្នំគិជ្ឈកូដ ។ ពេទ្យជីវកផ្សំភេសជ្ជៈ ទូលថ្វាយដល់ការបន្ទោបង់នូវធាតុមិនស្មើគ្នាក្នុងព្រះវរកាយចំពោះព្រះសាស្តា ហើយគិតថា បច្ច័យ ៤ ជារបស់យើងមានហើយដូច្នេះ ទើបអារាធនាឲ្យព្រះសាស្តាប្រថាប់នៅក្នុងវិហាររបស់ខ្លួន ផ្សំថ្នាំថ្វាយ បង្អែនគូសំពត់នោះថ្វាយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាទ្រង់ប្រើប្រាស់គូសំពត់នេះ ហើយបានថ្វាយសំពត់ ១.០០០ ផ្ទាំង ដែលបានមក ព្រមទាំងគូសំពត់នោះ ដល់ព្រះភិក្ខុសង្ឃ ។ នេះជាសេចក្តីសង្ខេបក្នុងរឿងពេទ្យជីវក-កោមារភច្ចនោះ ។ ចំណែកសេចក្តីពិស្តារ រឿងពេទ្យជីវក មកហើយក្នុងខន្ធក-

*វិន័យ ។ តមក ព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតពនវិហារ ទើបទ្រង់ស្ថាបនាពេទ្យជីវកកោមារភច្ចទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកអ្នកជ្រះថ្លាក្នុងបុគ្គល ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## ប្រវត្តិនកុលបិតាគហបតី

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥១] បទថា **វិស្សាសិកានំ** លោកសម្តែងថា នកុលបិតាគហបតី ប្រសើរជាងពួកឧបាសកអ្នកពោលពាក្យដោយសេចក្តីស្និទ្ធស្នាល ។

បានស្តាប់មកថា គហបតីនោះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល នាក្រុងហង្សវតី កំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាអ្នកប្រសើរជាងពួកឧបាសកអ្នកស្និទ្ធស្នាល ក៏ធ្វើកុសលដ៏ក្រៃលែង ហើយប្រាថ្នាតំណែងនោះ ។ លោកវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ ក៏កើតក្នុងត្រកូលសេដ្ឋី ក្នុងនគរសុំសុមារគិរី ដែនភគ្គៈ ។ សូម្បីព្រះសាស្តា ដែលមានភិក្ខុសង្ឃហែហមហើយ ស្តេចចារិកទៅដល់នគរនោះ ប្រថាប់នៅត្រង់ភេសកឡាវ័ន ។ គ្រានោះ នកុលបិតាគហបតីនេះ ក៏ទៅគាល់ព្រះសាស្តា ព្រមជាមួយពួកអ្នកសុំសុមារគិរីនគរ ដោយការគាល់ជាគ្រាដំបូងប៉ុណ្ណោះ គេ និងភរិយា ក៏តាំងក្នុងសេចក្តីសម្គាល់ថា ព្រះទសពលជាបុត្ររបស់ខ្លួន ទើបក្រាបចុះត្រង់ព្រះ

យុគលបាទរបស់ព្រះសាស្តា ក្រាបទូលថា កូនអើយ កូនលះបង់ចោលពុកម៉ែចេញទៅរហូតអស់វេលាប៉ុណ្ណោះ ត្រាច់ទៅនៅទីណា ។ ន័យថា នកុលបិតាគហបតីនេះ សូម្បីក្នុងជាតិមុនៗ ក៏បានជាបិតាព្រះទសពល ៥០០ ជាតិ ជាឪពុកមា ៥០០ ជាតិ ជាជីតា ៥០០ ជាតិ ជាអ៊ំ ៥០០ ជាតិ ។ នកុលមាតា ក៏បានជាមាតា ៥០០ ជាតិ ជាម្តាយមីង ៥០០ ជាតិ ជាជីដូន ៥០០ ជាតិ ជាម្តាយធំ ៥០០ ជាតិ ។ ដូច្នោះ ព្រោះមានសេចក្តីស្រឡាញ់ដែលជាប់តាមមករហូតអស់កាលដ៏យូរ ពេលឃើញព្រះទសពល ក៏សម្គាល់ថាជាបុត្រ ទើបទ្រាំនៅមិនបាន ។ ព្រះសាស្តាមិនបានត្រាស់ថា ចូរចៀសចេញទៅ ដរាបដល់ចិត្តរបស់អ្នកទាំងពីរនោះ មិនទាន់ដឹងខ្លួន ។ គ្រានោះ គ្រាអ្នកទាំងពីរនោះត្រឡប់បានសតិដូចដើមហើយ ព្រះសាស្តាទ្រង់ជ្រាបអាសយៈ គឺ អធ្យាស្រ័យរបស់ពួកសត្វអ្នកមានចិត្តជាកណ្តាលហើយ ទើបទ្រង់សម្តែងធម៌ ។ កាលចប់ទេសនា អ្នកទាំងពីរក៏តាំងនៅក្នុងព្រះសោតាបត្តិផល ។

តមក វេលាទ្រង់ព្រះជរា ព្រះសាស្តាស្តេចក៏យាងទៅកាន់នគរភគ្គៈទៀត ។ អ្នកទាំងពីរនោះ ជ្រាបថា ព្រះសាស្តាស្តេចយាងមក ក៏ចូលទៅគាល់ ថ្វាយបង្គំ ដោយបញ្ចង្គប្រតិស្ឋាន អារាធនាដើម្បីសោយក្នុងថ្ងៃស្អែក ក្នុងថ្ងៃស្អែកឡើង ក៏អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយភោជនមានរសប្រណីតផ្សេងៗ ក្នុង

និវេសន៍របស់ខ្លួន ព្រះសាស្តាសោយស្រេចហើយ ក៏ចូលទៅក្នុងទីជិត អង្គុយក្នុងទីសមគួរមួយ ។ លុះអង្គុយរៀបរយហើយ នកុលបិតាគហបតី ទើបបានក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ និងនកុលមាតាគហបតានី ធ្វើការងារជាមួយគ្នាគ្រាជាកម្លោះក្រមុំ ខ្ញុំព្រះអង្គមិនបានគិតថា នកុលមាតាគហបតានីនឹងក្បត់ចិត្តសូម្បីតាមផ្លូវចិត្តឡើយ ដូច្នោះ នាងនឹងក្បត់ចិត្តតាមផ្លូវកាយដូចម្តេច ខ្ញុំព្រះអង្គប្រាថ្នានឹងជួបគ្នាទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត ព្រះអង្គ ។ នកុលមាតាគហបតានី ក៏ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ និងនកុលបិតាគហបតី ធ្វើការងារជាមួយគ្នាកាលនៅជាកម្លោះក្រមុំ ខ្ញុំព្រះអង្គមិនបានគិតថា នកុលបិតាគហបតីនឹងក្បត់ចិត្តសូម្បីតាមផ្លូវចិត្ត ដូច្នោះ គេនឹងក្បត់ចិត្តតាមផ្លូវកាយបានដូចម្តេច ។ ខ្ញុំព្រះអង្គប្រាថ្នានឹងជួបគ្នា ទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត ព្រះអង្គ ។ តមកខាងក្រោយ ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសកទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទ្រង់នាំរឿងរបស់អ្នកទាំងពីរឲ្យជាអត្ថុប្បត្តិ ហើយទ្រង់ស្ថាបនា នកុលបិតាគហបតីទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសកដែលជិតស្និទ្ធ ដូច្នេះឯង ។

ចប់អដ្ឋកថាឧបាសកបាលី ប្រដាប់ដោយ ១០ សូត្រ

## ចប់អដ្ឋកថាវគ្គទី ៦

# ឧបាសិកាបាលិ

## អដ្ឋកថាវគ្គទី ៧

## អដ្ឋកថាសូត្រទី ១

### “ប្រវត្តិនាងសុជាតាសេនិយធីតា”

*សូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥២] *បទថា* ***បឋមំ សរណំ គច្ឆន្តីនំ*** *លោកសម្តែងថា ធីតារបស់សេនីយៈ ឈ្មោះ* ***សុជាតា*** *ប្រសើរជាងពួកឧបាសិកាអ្នកតាំងនៅក្នុងសរណៈមុនអ្នកដទៃទាំងអស់ ។*

*សួម្បីនាង សម័យព្រះពុទ្ធនាមថា* ***បទុមុត្តរៈ*** *កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី តមក នាងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកដល់សរណៈមុនឧបាសិកាទាំងពួង ទើបធ្វើកុសលដ៏ក្រៃលែង ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប កើតក្នុងគ្រួសាររបស់កុដុម្ពិកៈឈ្មោះសេនីយៈ ក្នុងតំបន់ឧរុវេលាសេនានិគម មុនព្រះសាស្តារបស់យើងកើត ចម្រើនវ័យហើយ បានធ្វើសេចក្តីប្រាថ្នាទុកត្រង់ដើមជ្រៃមួយដើមថា បើនាងខ្ញុំមានស្វាមីជា*

អ្នកមានត្រកូលស្មើគ្នា បានបុត្រប្រុសក្នុងផ្ទៃដំបូង នឹងធ្វើនូវពលីកម្មប្រចាំឆ្នាំ ។ សេចក្ដីប្រាថ្នារបស់នាងក៏សម្រេច ។

កាលព្រះមហាសត្វទ្រង់ធ្វើទុក្ករកិរិយាគ្រប់ឆ្នាំទី ៦ ក្នុងថ្ងៃវិសាខបុណ្ណមី នាងគិតថា នឹងធ្វើពលីកម្មពីព្រឹកព្រលឹម ទើបក្រោកឡើងវេលាជិតភ្លឺ ហើយប្រើឲ្យគេរឹតទឹកដោះគោ ។ ពួកកូនគោក៏មិនទៅ កាន់យកកន្សោមដោះរបស់ពួកមេគោ ។ ពេលយកកាជនៈថ្មីៗ ចូលទៅត្រងជិតដោះ តំណក់ទឹកដោះក៏ស្រក់មកតាមធម្មតារបស់ខ្លួន នាងសុជាតាឃើញសេចក្ដីអស្ចារ្យនោះ ក៏កាន់យកទឹកដោះដោយដៃខ្លួនឯង ដាក់កាជនៈថ្មីថែមទៀត ។ កាលបាយមធុបាយាសកំពុងរំងាស់ពពុះធំៗ ក៏ផុលឡើង វិលជុំវិញទៅខាងស្ដាំៗ តំណក់មធុបាយាស សូម្បីមួយតំណក់ក៏មិនបានខ្ទាតចេញខាងក្រៅ ។ ស្ដេចមហាព្រហ្មបាំងឆត្រការពារ ។ ស្ដេចលោកបាលទាំង ៤ កាន់ព្រះខ័នតាំងការរក្សា ។ ស្ដេចសក្កៈរបួមរក្សាឧសភ្លើង ។ ពួកទេវតានាំឱជៈក្នុងទ្វីបទាំង ៤ មកដាក់ក្នុងមធុបាយាសនោះ ។ ក្នុងថ្ងៃនោះឯងនាងសុជាតា ឃើញសេចក្ដីអស្ចារ្យទាំងនេះ ទើបហៅនាងបុណ្ណទាសីមកប្រាប់ថា នាងបុណ្ណៈ ថ្ងៃនេះ ទេវតារបស់យើងគួរជ្រះថ្លាពេកណាស់ រហូតវេលាប៉ុណ្ណេះ ។ ខ្ញុំមិនធ្លាប់ឃើញសេចក្ដីអស្ចារ្យបែបនេះឡើយ ចូរនាងប្រញាប់ទៅបដិបត្តិទេវស្ថាន ។ នាងបុណ្ណទាសី ទទួលថា ប្រពៃហើយអ្នកនាងម្ចាស់ ក៏ប្រញាប់ប្រញាល់

ទៅកាន់គល់ដើមឈើ ។ ចំណែកព្រះពោធិសត្វ រង់ចាំវេលាស្វែងរកអាហារ ក៏ស្តេចទៅប្រថាប់អង្គុយត្រង់គល់ដើមឈើតាំងពីព្រឹកព្រលឹម ។ នាងបុណ្ណៈដើរទៅដើម្បីនឹងបោសសំអាតត្រង់គល់ឈើ ក៏មកប្រាប់នាងសុជាតាថា ទេវតាប្រថាប់នៅត្រង់ដើមឈើហើយ ។ នាងសុជាតាពោលថា នាងដ៏ចម្រើន បើនាងនិយាយពិត នាងក៏នឹងជាអ្នកជា ហើយប្រដាប់គ្រឿងប្រដាប់គ្រប់យ៉ាង ចាត់ចែងមធុបាយាសយ៉ាងល្អក្នុងថាសមាសមានតម្លៃមួយសែន យកថាសមាសមួយផ្សេងទៀតធ្វើជាគម្រប ហើយគ្របដោយសំពត់ស ព្យួរដោយកម្រងក្រអូប កម្រងផ្កាទុកជុំវិញលើកឡើងដើរទៅ ជួបព្រះមហាបុរស ក៏កើតបីតិយ៉ាងខ្លាំង បន្ទន់ខ្លួនចុះតាំងពីទីដែលបានជួប ដាក់ថាសចុះពីសីរសៈ បើកគម្របចេញ ហើយដាក់មធុបាយាសព្រមទាំងថាសទុកក្នុងព្រះហស្តរបស់ព្រះមហាបុរស ថ្វាយបង្គំហើយ ពោលថាសូមមនោរថរបស់លោក ចូរសម្រេចដូចមនោរថរបស់ខ្ញុំម្ចាស់ដែលសម្រេចហើយចុះ ហើយក៏ចៀសចេញទៅ ។

ព្រះពោធិសត្វ ស្តេចទៅកាន់ច្រាំងស្ទឹងនេរញ្ជរា ទ្រង់ដាក់ថាសមាសទុកត្រង់មាត់ច្រាំង ចុះស្រង់ទឹកហើយស្តេចឡើង ទ្រង់ពូតជាដុំបាន ៤៩ ដុំ ទ្រង់សោយមធុបាយាសហើយ ទ្រង់បណ្តែតថាសមាសចុះក្នុងស្ទឹង ស្តេចឡើងកាន់ពោធិមណ្ឌស្ថាន តាមលំដាប់ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ប្រថាប់ត្រង់ពោធិមណ្ឌ-

ស្ថាន កន្លងទៅ ៧ សប្តាហ៍ ទ្រង់ប្រកាសព្រះធម្មចក្រដ៏ប្រសើរក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ឃើញឧបនិស្ស័យរបស់ក្មេងឈ្មោះយស ដែលជាបុត្ររបស់នាងសុជាតា ទើបស្តេចទៅប្រថាប់ត្រង់គល់ឈើមួយដើម ។ សូម្បីយសកុលបុត្រឃើញនាងបម្រើដេកអាក្រាតកាយក្នុងកាលកន្លងរាត្រី កើតសេចក្តីសង្វេគ និយាយថា វឹកវរណាស់ហ្ន៎ ប្រឫកប្រឫល់ណាស់ហ្ន៎ ហើយចេញចាកនិវេសន៍ ដើរទៅកាន់សំណាក់ព្រះសាស្តា ឯក្រៅព្រះនគរ ស្តាប់ធម៌ទេសនាហើយ ត្រាស់ដឹងមគ្គផល ៣ ។ ខណៈនោះ បិតារបស់គេដើរតាមស្នាមជើងគេ ទៅគាល់ព្រះមានព្រះភាគ ទូលសួររឿងរបស់យសកុលបុត្រ ។ ព្រះសាស្តាទ្រង់បិទបាំងយសកុលបុត្រទុក ទ្រង់សម្តែងធម៌ ចប់ទេសនា សេដ្ឋីក៏តាំងនៅក្នុងព្រះសោតាបត្តិផល ។ ចំណែក យសៈ សម្រេចព្រះអរហត្ត ។ ព្រះមានព្រះភាគត្រាស់ចំពោះគេថា ចូរជាភិក្ខុចុះ ។ ក្លាមនោះឯង ភេទគ្រហស្ថរបស់គេក៏វិនាសទៅ គេបានជាអ្នកប្រដាប់បាត្រ និងចីវរសម្រេចដោយឫទ្ធិ ។ សូម្បីបិតារបស់លោក ក៏និមន្តព្រះសាស្តា ។ ព្រះសាស្តាទ្រង់មានព្រះយសកុលបុត្រជាបច្ឆាសមណៈ ជាប់តាមទៅខាងក្រោយ ស្តេចទៅផ្ទះរបស់សេដ្ឋីនោះ សោយភត្តាហារស្រេចហើយ ទ្រង់ក៏សម្តែងធម៌ប្រោស ចប់ទេសនា នាងសុជាតាមាតា និងភរិយាចាស់របស់ព្រះយស ក៏តាំងនៅក្នុងព្រះសោតាបត្តិផល ។ ក្នុងថ្ងៃនោះ នាងសុជាតា និងស្ត្រីកូនប្រសារ ក៏តាំងនៅក្នុង

**គោវាចិកសរណៈ** គឺ ដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃទាំង ៣ ជាសរណៈ ។ នេះជាសេចក្តីសង្ខេបក្នុងរឿងនោះ ។ ចំណែកសេចក្តីពិស្តាររឿងនេះ មកហើយក្នុងគម្ពីរខុទ្ទកៈ ។ ខាងក្រោយតមក ព្រះសាស្តាកាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាឧបាសិកាម្នាក់នេះ ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកដល់សរណៈមុនគេ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## “ប្រវត្តិនាងវិសាខាមិគារមាតា”

ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ៖

[១៥២] ដោយបទថា **ទាយិកានំ** លោកសម្តែងថា **នាងវិសាខាមិគារមាតា** ប្រសើរជាងពួកឧបាសិកាដែលត្រេកអរក្រៃលែងក្នុងការថ្វាយទាន ។

ដូចបានស្តាប់មក នាងវិសាខានោះ សម័យព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី តមក កំពុងស្តាប់ព្រះធម៌ទេសនាព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាមួយនាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាដែលត្រេកអរក្នុងការថ្វាយទាន ទើបធ្វើកុសលដ៏ក្រៃលែង ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងសម័យព្រះពុទ្ធព្រះនាមថា **កស្សបៈ** កើតជារាជធីតាប្អូនពៅគេនៃព្រះរាជធីតាបងប្អូន ៧ ព្រះអង្គ ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកឹកិ ។ ក៏គ្រានោះ ព្រះរាជធីតាបងប្អូន ៧ ព្រះអង្គ គឺ សមណី សមណគុត្តា ភិក្ខុនី ភិក្ខុទាសិក ធម្មា សុធម្មា និង សង្ឃទាសី គ្រប់ ៧ អង្គ ។ ព្រះរាជធីតាទាំងនោះ ក្នុងពុទ្ធកាលនេះ បានមកជាព្រះនាងខេមា ព្រះនាងឧប្បលវណ្ណា ព្រះនាងបដាចារា ព្រះនាងគោតមី ព្រះនាង

ធម្មទិន្នា ព្រះនាងកិសាគោតមី ព្រះនាងកុណ្ឌលកេសា និងនាងវិសាខា ជាគម្រប់ ៧ ។

បណ្ដាព្រះរាជធីតាទាំងនោះ ព្រះនាងសង្ឃទាសីរីលរល់នៅក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់នាងសុមនទេវី ភរិយារបស់ធនញ្ជ័យសេដ្ឋី បុត្ររបស់មេណ្ឌកសេដ្ឋី នាកភទ្ទិយនគរ ដែនអង្គៈ ។ មាតាបិតាបានតាំងឈ្មោះនាងថា **វិសាខា** ។ វេលានាងមានអាយុបាន ៧ ខួប ព្រះទសពលទ្រង់ឃើញឧបនិស្ស័យសម្បត្តិរបស់សេលព្រាហ្មណ៍ និងពួកសត្វដែលនឹងត្រាស់ដឹងដទៃៗ ទៀត ទ្រង់មានភិក្ខុសង្ឃជាបរិវារ ស្ដេចចារិកទៅដល់នគរនោះ ក្នុងដែននោះ ។

សម័យនោះ មេណ្ឌកគហបតី ជាប្រធានរបស់ពួកអ្នកមានបុណ្យច្រើន ៥ នាក់ គ្រងតំណែងសេដ្ឋី ។ ពួកអ្នកមានបុណ្យច្រើន ៥ នាក់ គឺ មេណ្ឌកសេដ្ឋី ១ ភរិយារបស់គេឈ្មោះចន្ទបទុមា ១ បុត្ររបស់គេឈ្មោះធនញ្ជ័យ ១ ភរិយារបស់ធនញ្ជ័យនោះ ឈ្មោះសុមនទេវី ១ ទាសៈរបស់មេណ្ឌកសេដ្ឋី ឈ្មោះបុណ្ណៈ ១ ។ មិនមែនតែមេណ្ឌកសេដ្ឋីតែម្យ៉ាងទេ សូម្បីក្នុងរាជអាណាចក្ររបស់ព្រះបាទពិម្ពិសារ ក៏មានបុគ្គលដែលមានភោគសម្បត្តិរាប់មិនបាន ៥ នាក់ដែរ គឺ ជោតិកៈ ជដិលៈ មេណ្ឌកៈ បុណ្ណៈ និងកាកពលិយៈ ។ បណ្ដានាក់ទាំង ៥ នោះ មេណ្ឌកសេដ្ឋីនេះ ជ្រាបថា ព្រះទសពលស្ដេចមកដល់នគររបស់ខ្លួន ទើបហៅ កុមារី

វិសាខា ជីតាធនញ្ជ័យសេដ្ឋី ដែលជាបុត្រមក ហើយបង្គាប់យ៉ាងនេះថា ចៅ ជាមង្គលទាំងចៅ ទាំងតា ចៅចូរនាំរទេះ ៥០០ ព្រមទាំងក្មេងស្រី ៥០០ នាក់ បរិវាររបស់ចៅមានទាសី ៥០០ នាក់ជាបរិវារ ចូរធ្វើការទទួលព្រះទសពល ។ នាងស្តាប់ពាក្យរបស់ជីតា ក៏បដិបត្តិតាម ។ តែព្រោះនាង ជាអ្នកឆ្លាតក្នុងហេតុ និងមិនមែនហេតុ នាងក៏ទៅដោយយាន កាលទៅដល់ហើយ ក៏ចុះចាកពីយាន ដើរទៅចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ឈរក្នុងទីដ៏សមគួរមួយ ។ គ្រានោះព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសតាមចរិយារបស់នាង ។ ចប់ទេសនា នាងក៏តាំងនៅក្នុងសោតាបត្តិផល ព្រមទាំងក្មេងស្រី ៥០០ នាក់ សូម្បីមេណ្ឌកសេដ្ឋី ក៏ចូលទៅគាល់ ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសតាមចរិយារបស់សេដ្ឋីនោះ ។ ចប់ទេសនា មេណ្ឌកសេដ្ឋីក៏តាំងនៅក្នុងសោតាបត្តិផល អារាធនាព្រះសាស្តា ដើម្បីសោយក្នុងថ្ងៃស្អែក ។ ថ្ងៃស្អែក ក៏អង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីតក្នុងនិវេសន៍របស់ខ្លួន បានថ្វាយមហាទានដោយឧបាយនោះ កន្លះខែ ។ ព្រះសាស្តាប្រថាប់នៅក្នុងភទ្ទិយនគរ តាមពុទ្ធអធ្យាស្រ័យហើយក៏ស្តេចយាងទៅ ។ គប្បីវិសជ្ជនាកថាមគ្គដទៃតពីនេះ ហើយពោលរឿងការកើតរបស់នាងវិសាខា ។

ពិតហើយ ក្នុងក្រុងសាវត្ថី ព្រះបាទកោសលទ្រង់បញ្ជូនរាជសាសន៍ទៅ

កាន់សំណាក់របស់ព្រះបាទពិម្ពិសារថា ក្នុងរាជាណាខេត្តរបស់ខ្ញុំ ឈ្មោះថា ត្រកូលដែលមានភោគសម្បត្តិរាប់មិនបាន មិនមានឡើយ ត្រកូលដែលមានភោគសម្បត្តិរាប់មិនបានរបស់ព្រះអង្គ មានហើយ សូមបានទ្រង់មេត្តាបញ្ជូនត្រកូលដែលមានភោគសម្បត្តិរាប់មិនបាន ឲ្យខ្ញុំផងចុះ ។ ព្រះរាជាទ្រង់ប្រឹក្សាជាមួយពួកអាមាត្រ ។ ពួកអាមាត្រប្រឹក្សាគ្នាថា មិនអាចបញ្ជូនត្រកូលធំៗ ទៅ តែយើងនឹងបញ្ជូនចំពោះបុត្រសេដ្ឋីម្នាក់ទៅបាន ទើបអង្វរធនញ្ជ័យសេដ្ឋី បុត្រមេណ្ឌកសេដ្ឋី ។ ព្រះរាជាទ្រង់ស្តាប់ពាក្យប្រឹក្សារបស់អាមាត្រទាំងនោះ ក៏ទ្រង់បញ្ជូនធនញ្ជ័យសេដ្ឋីទៅ ។ គ្រានោះ ព្រះបាទកោសល ព្រះរាជទានតំណែងសេដ្ឋីឲ្យគេនៅក្នុងនគរសាកេត ឆ្ងាយពីក្រុងសាវត្ថី ៧ យោជន៍ ។ ក៏ក្នុងក្រុងសាវត្ថី បុត្ររបស់មិគារសេដ្ឋី ឈ្មោះបុណ្ណវឌ្ឍនកុមារ ចម្រើនវ័យហើយ ។ ខណៈនោះ បិតារបស់គេដឹងថា បុត្ររបស់យើងចម្រើនវ័យហើយ ជាសម័យដែលនឹងត្រូវចងដោយយាវាសវិស័យ ទើបបញ្ជូនមនុស្សដែលឆ្លាតទាំងឡាយក្នុងហេតុ និងមិនមែនហេតុទៅ ដោយបង្គាប់ថា ពួកអ្នកចូរស្វែងរកក្មេងស្រីក្នុងត្រកូលដែលមានជាតិស្មើនឹងយើង ។ មនុស្សទាំងនោះ មិនជួបក្មេងស្រីដែលត្រូវចិត្តខ្លួនក្នុងក្រុងសាវត្ថី ទើបនាំគ្នាទៅកាន់នគរសាកេត ។

ថ្ងៃនោះឯង នាងវិសាខាមានស្រីក្រមុំ ៥០០ នាក់ ដែលមានវ័យស្របាល

គ្នាហៃហាម នាំគ្នាទៅកាន់បឹងធំមួយកន្លែងដើម្បីលេងនក្ខត្តឫក្ស ។ មនុស្សទាំងនោះក៏ត្រាច់ទៅខាងក្នុងនគរ មិនបានជួបក្មេងស្រីដែលត្រូវចិត្តខ្លួន ទើបឈរក្រៅទ្វារក្រុង ។ ខណៈនោះ ភ្លៀងចាប់ផ្តើមធ្លាក់ ។ ពួកក្មេងស្រីដែលចេញទៅជាមួយនាងវិសាខា ក៏ប្រញាប់ចូលសាលា ព្រោះខ្លាចទទឹកទឹកភ្លៀង ។ មនុស្សទាំងនោះមិនជួបក្មេងស្រីតាមដែលប្រាថ្នា ក្នុងរវាងក្មេងស្រីទាំងនោះ ។ តែនាងវិសាខានៅខាងក្រោយក្មេងស្រីទាំងអស់នោះ ត្រូវភ្លៀងទទឹកសើមជោក ចូលទៅកាន់សាលាព្រោះមិនប្រញាប់ដើរ ។ មនុស្សទាំងនោះ ឃើញនាងហើយក៏គិតថា ក្មេងស្រីម្នាក់នេះស្អាតក្រៃលែងជាងក្មេងស្រីដទៃៗ ក៏រូបនេះ ជាវត្ថុដែលស្រីពួកខ្លះគាក់តែងបាន ដូចជាងធ្វើរថ គាក់តែងកង់រថបានដូច្នោះ ទើបពោលទៅថា យើងនឹងត្រូវដឹងថា ក្មេងស្រីនេះនិយាយពីរោះឬទេ ដូច្នោះ ទើបពោលនឹងនាងថា នាងតូចនាងដូចជាស្ត្រីដែលមានវ័យធំហើយ ដូច្នោះ ។ នាងទើបសួរថា លោក ពួកលោកឃើញអ្វីទើបពោល ។ អ្នកទាំងនោះឆ្លើយថា ក្មេងស្រីដែលលេងជាមួយនាង គ្រប់គ្នា គេប្រញាប់ចូលសាលា ព្រោះខ្លាចទទឹកភ្លៀង ចំណែកនាងដូចស្ត្រីចាស់ មិនប្រញាប់ប្រញាល់ មិនខ្លាចទទឹកសំពត់ បើដំរី ឬសេះដេញតាមនាងយ៉ាងនេះ នាងនឹងធ្វើដូចម្តេច ។ នាងពោលថា លោកពូ ដែលឈ្មោះថា សំពត់រកបានមិនលំបាកក្នុងត្រកូលរបស់ខ្ញុំរកបានងាយទេ ចំណែកស្រីចម្រើនវ័យហើយ ក៏ដូចជាទំនិញ

ដែលគេលក់ កាលដៃ ឬជើងបាក់ទៅ អ្នកទាំងឡាយឃើញស្រីដែលមានរាងកាយ ខូចខាត ក៏រង្កៀស ស្តោះទឹកមាត់ហើយគេចចេញទៅ ព្រោះហេតុនោះ ខ្ញុំទើបដើរ សន្សឹមៗ មក ។

មនុស្សទាំងនោះគិតថា ឈ្មោះថា ស្រីក្នុងជម្ពូទ្វីបនេះមិនមាន នឹងប្រៀប ជាមួយក្មេងស្រីនេះមិនមាន ដែលនឹងប្រៀបទាំងរូបកាយ ទាំងពាក្យនិយាយ ដឹង ហេតុ និងមិនមែនហេតុ ហើយទើបនិយាយ ដូច្នេះ ហើយក៏បោះកម្រងផ្កាទៅលើ នាង ។ ខណៈនោះ នាងវិសាខាគិតថា យើងមិនត្រូវគេហួងហែងមកអំពីមុន តែឥឡូវនេះ យើងត្រូវគេហួងហែងហើយ ទើបអង្គុយចុះលើផែនដីដោយអាការ ដូចដែលត្រូវគេនាំទៅហើយ ។ គ្រានោះ មនុស្សទាំងឡាយ ទើបយករាំងនន លោមព័ទ្ធនាងទុកត្រង់ទីនោះឯង ។ នាងដឹងថា គេរក្សាទុក ក៏មានពួកទាសីហែហម ត្រឡប់ទៅផ្ទះ ។ មនុស្សរបស់មិគារសេដ្ឋីទាំងនោះ ក៏នាំគ្នាទៅសំណាក់ធនញ្ជ័យ សេដ្ឋីព្រមជាមួយនាង កាលសេដ្ឋីសួរថា នាយ ពួកលោកជាអ្នកស្រុកណា ក៏ ឆ្លើយថា ពួកខ្ញុំជាមនុស្សរបស់មិគារសេដ្ឋី នាក្រុងសាវត្ថី ជ្រាបថា ផ្ទះលោកម្ចាស់ មានកុមារចម្រើនវ័យហើយ លោកទើបបញ្ជូនពួកខ្ញុំមក ។ ធនញ្ជ័យសេដ្ឋីពោល ថា ល្អហើយនាយ សេដ្ឋីរបស់ពួកលោក ប្រៀបជាមួយយើង ខាងភោគសម្បត្តិ មិនបានក៏ពិត តែក៏ស្មើគ្នាដោយជាតិ ។ ធម្មតាថា បុគ្គលដែលព្រមព្រៀងគ្នាដោយ

អាការគ្រប់យ៉ាង រកបានលំបាក ។ ពួកអ្នកចូរទៅប្រាប់លោកសេដ្ឋីថា យើងព្រម ទទួលហើយ ។ អ្នកទាំងនោះ ស្តាប់ពាក្យរបស់ធនញ្ជ័យសេដ្ឋីនោះហើយ ក៏ត្រឡប់ទៅក្រុងសាវត្ថី បង្ហាញភាពត្រេកអរ និងសេចក្តីចម្រើនដល់មិគារសេដ្ឋីហើយ ពោលថា លោកម្ចាស់ ពួកយើងបានក្មេងស្រីក្នុងផ្ទះរបស់ធនញ្ជ័យសេដ្ឋីហើយ ។ មិគារសេដ្ឋីស្តាប់ដូច្នោះ ក៏ត្រេកអរថា ពួកយើងបានក្មេងស្រីក្នុងផ្ទះរបស់ត្រកូលធំ ទើបបញ្ជូនដំណឹងទៅប្រាប់ធនញ្ជ័យសេដ្ឋីភ្លាមថា ឥឡូវនេះ យើងនឹងនាំក្មេងស្រីមក មេត្តាធ្វើកិច្ចដែលគួរធ្វើចុះ ។ សូម្បីធនញ្ជ័យសេដ្ឋី ក៏បញ្ជូនដំណឹងតបមិគារសេដ្ឋីថា រឿងនេះមិនជាការធ្ងន់សម្រាប់យើងឡើយ សូមលោកសេដ្ឋីមេត្តាធ្វើកិច្ចដែលគួរធ្វើសម្រាប់ខ្លួនចុះ ។ មិគារសេដ្ឋី ទើបទៅចូលគាល់ព្រះបាទកោសល ក្រាបទូលថា បពិត្រទេវៈ ក្មេងស្រីដែលមានកិរិយាជាមង្គលដល់ខ្ញុំព្រះអង្គមានហើយ ក្មេងស្រីនោះ ឈ្មោះវិសាខា ធីតារបស់លោកធនញ្ជ័យសេដ្ឋី ខ្ញុំព្រះអង្គនឹងនាំមកឲ្យដល់បុណ្ណវឌ្ឍនកុមារ ជាទាសៈរបស់ព្រះអង្គ សូមទ្រង់ប្រោសអនុញ្ញាតឲ្យខ្ញុំព្រះអង្គទៅនគរសាកេតចុះ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា ល្អហើយលោកសេដ្ឋី សូម្បីយើង ក៏គួរនឹងទៅផងមិនមែនឬ ។ សេដ្ឋីក្រាបទូលថា បពិត្រទេវៈ ខ្ញុំព្រះអង្គនឹងរាប់រងបុគ្គលដូចជាព្រះអង្គបានដូចម្តេច ។ ព្រះរាជា មានព្រះរាជបំណងទ្រង់សង្គ្រោះត្រកូលធំ ទ្រង់ទទួលថា ណ្ហើយចុះ លោកសេដ្ឋី យើងនឹង

ទៅជាមួយ ហើយក៏ស្តេចទៅកាន់នគរសាកេតព្រមជាមួយមិគារសេដ្ឋី ។

ធនញ្ជ័យសេដ្ឋីដឹងថា មិគារសេដ្ឋីនាំព្រះបាទកោសលមកផង ទើបចេញទៅទទួលស្តេច នាំព្រះរាជាទៅកាន់និវេសន៍របស់ខ្លួន ។ ក្លាមនោះឯង ក៏ចាត់ស្ថានទីនៅ និងកម្រងផ្កា របស់ក្រអូបជាដើមទុកសព្វគ្រប់ សម្រាប់ព្រះរាជា សម្រាប់ទាហានរបស់ព្រះរាជា និងសម្រាប់មិគារសេដ្ឋី ដឹងកិច្ចគ្រប់យ៉ាងដោយខ្លួនឯងថា វត្ថុនេះគួរបានដល់ អ្នកនេះ វត្ថុនេះគួរបានដល់ អ្នកនេះ ។ ជននោះៗ ក៏គិតថា លោកសេដ្ឋីធ្វើសក្ការៈដល់យើងក្រៃលែង ។ តមកថ្ងៃមួយ ព្រះរាជាទ្រង់បញ្ជូនដំណឹងទៅប្រាប់ធនញ្ជ័យសេដ្ឋីថា លោកសេដ្ឋី មិនអាចនឹងទំនុកបម្រុងពួកយើងបានយូរឡើយ សូមលោកសេដ្ឋីកំណត់វេលាដល់ក្មេងស្រីនឹងទៅចុះ ។ សូម្បីធនញ្ជ័យសេដ្ឋី ក៏បញ្ជូនដំណឹងថ្វាយព្រះរាជាថា ឥឡូវនេះ ជារដូវភ្លៀងមកដល់ហើយ ទាហានរបស់ព្រះអង្គនឹងត្រាច់ទៅរហូតអស់ ៤ ខែ គង់មិនបាន កិច្ចណាៗ គួរនឹងបាន កិច្ចទាំងអស់នោះជាភាពរបស់ខ្ញុំព្រះអង្គ សូមទេវៈមេត្តាស្តេចទៅក្នុងវេលាដែលខ្ញុំព្រះអង្គបញ្ជូនធីតាទៅ តែម្យ៉ាងចុះ ព្រះអង្គ ។ រាប់អំពីនោះមក នគរសាកេត ក៏បានដូចជាស្រុកដែលមាននក្ខត្តឫក្សជានិច្ច ។ កន្លងទៅ ៣ ខែ ដោយអាការយ៉ាងនេះ ។ គ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍ សម្រាប់ធីតារបស់ធនញ្ជ័យសេដ្ឋីក៏នៅមិនសម្រេច ។ គ្រានោះ ពួកនាយប្រចាំការងារ ក៏មកប្រាប់

ធនញ្ជ័យសេដ្ឋីថា ដែលឈ្មោះថា វត្ថុដែលមិនមានសម្រាប់ជនទាំងនោះ មិនមានទេ តែឧសប្រើដាំស្ល សម្រាប់ទាហានមានមិនគ្រប់គ្រាន់ ។ ធនញ្ជ័យសេដ្ឋីទើបបង្គាប់ថា បាអើយ ទៅរុះរើរោងដំរី រោងសេះ យកឈើមកប្រើការដាំស្លចុះ ។ កាលដាំស្លយ៉ាងនេះ កន្លងទៅកន្លះខែអំពីនោះ ពួកមេការក៏មកប្រាប់ទៀតថា ឧសមិនគ្រប់គ្រាន់ ។ ធនញ្ជ័យសេដ្ឋីក៏បង្គាប់ថា បាអើយ ក្នុងវេលានេះយើងរកឧសមិនបាន ពួកលោកចូរបើកឃ្លាំងសំពត់ យកសំពត់ប្រភេទដែលគ្រោតគ្រាត មកជាជ្រលក់ក្នុងធុងប្រេង ប្រើការដាំស្លអាហារចុះ ។ កាលដាំស្លដោយទំនងនេះ ក៏អស់វេលាគ្រប់ ៤ ខែ ។ បន្ទាប់ពីនោះ ធនញ្ជ័យសេដ្ឋីដឹងថា គ្រឿងប្រដាប់មហាលតាបសាធន៍សម្រាប់ធីតាធ្វើស្រេចហើយ ទើបបង្គាប់ថា ស្អែកនេះ យើងនឹងបញ្ជូនធីតាទៅ ទើបហៅធីតាចូលមកអង្គុយជិត បានឲ្យឱវាទថា កូនអើយ ធម្មតាថា ស្ត្រីនៅក្នុងត្រកូលស្វាមី គួរនឹងសិក្សាមារយាទយ៉ាងនេះ យ៉ាងនេះ ។ មិគារសេដ្ឋីអង្គុយនៅខាងក្នុងបន្ទប់ក៏បានឮឱវាទរបស់ធនញ្ជ័យសេដ្ឋី ។ សូម្បីធនញ្ជ័យសេដ្ឋីក៏ឱវាទធីតាយ៉ាងនេះថា កូនអើយ ធម្មតាថា ស្ត្រីដែលនៅក្នុងត្រកូលបិតារបស់ស្វាមី ភ្លើងក្នុងក៏មិនគប្បីនាំចេញ ភ្លើងក្រៅក៏មិនគប្បីនាំចូល គប្បីឲ្យដល់អ្នកដែលគួរឲ្យ មិនគប្បីឲ្យដល់អ្នកដែលមិនគួរឲ្យ គប្បីឲ្យទាំងដល់អ្នកដែលគួរឲ្យ ទាំងដល់អ្នកដែលមិនគួរឲ្យ គប្បីអង្គុយជាសុខ គប្បីបរិភោគជាសុខ គប្បី

ដេកជាសុខ គប្បីបម្រើភ្លើង គប្បីនមស្ការទេវតាខាងក្នុង លុះឲ្យឱវាទ ១០ យ៉ាង នេះ ដូច្នេះហើយ ស្អែកឡើង ក៏ប្រជុំនាយកងគ្រប់កង ចាត់កុដុម្ពិកៈ ៨ នាក់ ក្នុងពួកសេនារបស់ព្រះរាជា ជាអ្នកធានា ហើយពោលថា បើកំហុសកើតដល់ធីតា របស់យើងក្នុងទីដែលទៅហើយសោត ពួកលោកគប្បីជម្រះ ហើយឲ្យធីតាប្រដាប់ ដោយគ្រឿងប្រដាប់មហាលតាបសាធន៍ មានតម្លៃ ៩ កោដិ ឲ្យទ្រព្យ ៥៤ រទេះ ជាតម្លៃសម្រាប់គ្រឿងក្រអូប សម្រាប់គ្រឿងលាយទឹកងូត ឲ្យទាសីរូបស្អាតជាប់ ប្រណិបត្តិក្នុងវេលាធ្វើដំណើរប្រចាំ ៥០០ នាក់ រថទឹមសេះអាជានេយ្យ ៥០០ គ្រឿង សក្ការៈគ្រប់យ៉ាង មួយមុខ ១០០ ។ បង្ហាញដល់ព្រះបាទកោសល និង មិគារសេដ្ឋីជ្រាបហើយ វេលាធីតាទៅ ហៅអ្នកគ្រប់គ្រងក្រោលគោមក ប្រាប់ថា បាអើយ ក្នុងទីដែលធីតាយើងទៅហើយ ត្រូវត្រៀមគោទុក ដើម្បីធីតាយើងត្រូវ ការផឹកទឹកដោះ , ឲ្យត្រៀមគោប្រើទុក ដើម្បីធីតាយើងត្រូវការទឹមយាន ព្រោះ ហេតុនោះ ពួកអ្នកគប្បីបើកទ្វារក្រោលគោក្នុងផ្លូវដែលធីតាយើងទៅ យកគោប្រើ ៨ ក្បាល ដែលធាត់ៗ ចាត់ជាមេហ្វូង ដល់ញកក្ដីឈ្មោះឯណោះ មានម្រឹគ ប្រមាណ ៣ គាវុត កាលហ្វូងគោដល់ទីនោះហើយ គប្បីវាយស្គរជាសញ្ញា ឲ្យ បើកទ្វារក្រោលគោ ។ អ្នកទាំងនោះទទួលពាក្យរបស់សេដ្ឋីថា ល្អហើយ ហើយ បដិបត្តិតាមពាក្យបង្គាប់នោះ ។ កាលទ្វារក្រោលបើកចេញហើយ មេគោទាំងឡាយ

ដែលជាត់ៗ ក៏ចេញទៅ តែកាលទ្វារបិទ ពួកគោដែលហ្វឹកហើយ គោមានកម្លាំង និងគោកាច ក៏លោតផ្លោះចេញទៅខាងក្រៅ ហើយដើរតាមផ្លូវទៅ ព្រោះកម្លាំងបុណ្យរបស់នាងវិសាខា ។

គ្រានោះ វេលាដល់ក្រុងសាវត្ថី នាងវិសាខាគិតថា យើងនឹងអង្គុយក្នុងយានដែលបិទបាំងចូលទៅ ឬឈរលើរថចូលទៅ ទើបល្អហ្ន៎ ។ ខណៈនោះ នាងត្រិះរិះថា កាលយើងចូលទៅដោយយានដែលបិទបាំង សេចក្ដីវិសេសរបស់គ្រឿងប្រដាប់មហាលតាបសាធនៈ ក៏រាប់ថា មិនមានអ្នកណាដឹង នាងសម្ដែងខ្លួនទូទៅនគរ ឈរលើរថចូលកាន់ព្រះនគរ ។ អ្នកក្រុងសាវត្ថី ឃើញសម្បត្តិរបស់នាងវិសាខាហើយ នាំគ្នាពោលថា គេថា ស្ត្រីម្នាក់នេះឈ្មោះនាងវិសាខា និងសម្បត្តិបែបនេះ ក៏សមគួរដល់នាងនោះឯង នាងចូលទៅផ្ទះមិគារសេដ្ឋី ដោយសម្បត្តិដ៏ធំដោយប្រការដូច្នេះ ។ ក៏ក្នុងថ្ងៃនាងមកដល់ អ្នកក្រុងទូទៅបាននាំគ្នាបញ្ជូនគ្រឿងបណ្ណាការតាមកម្លាំង អាចពោលបានថា ធនញ្ជ័យសេដ្ឋីរបស់យើងបានធ្វើសក្ការៈយ៉ាងធំដល់អ្នកដែលមកដល់នគររបស់ខ្លួន ។ នាងវិសាខាប្រាប់ឲ្យ ឲ្យគ្រឿងបណ្ណាការតបដល់អ្នកក្រុងដែលបញ្ជូនទៅ ទូទៅក្នុងត្រកូលរបស់គេក្នុងនគរនោះឯង ។

ខណៈនោះ លំដាប់នៃចំណែកករាត្រី មេសេះមួយក្បាល ក៏បានកើតកូន ។ នាងទើបប្រើឲ្យពួកទាសីកាន់គប់ភ្លើងទៅទីនោះ ឲ្យងូតទឹកក្ដៅដល់មេសេះ ប្រើ

ប្រេងលាបខ្លួនឲ្យមេសេះ ហើយក៏ត្រឡប់ទៅទីនៅរបស់ខ្លួន ។ ចំណែកមិគារសេដ្ឋី ធ្វើការឆ្លងអាវាហមង្គលដល់បុត្រ ៧ ថ្ងៃ មិនបានគិតដល់ព្រះតថាគតសូម្បីទ្រង់ប្រថាប់នៅវិហារជិតនោះ គម្រប់ ៧ ថ្ងៃ អញ្ជើញពួកអាចេលក៍ ឲ្យអង្គុយពេញទូទាំងនិវេសន៍ បញ្ជូនដំណឹងប្រាប់នាងវិសាខាថា ធីតារបស់យើងចូរមកសំពះព្រះអរហន្តទាំងឡាយ ។ នាងជាព្រះអរិយសាវិកាថ្នាក់សោតាបន្ន បានឮថា ព្រះអរហន្តទាំងឡាយ ដូច្នេះ ក៏មានចិត្តត្រេកអរ ដើរទៅកាន់ទីអង្គុយរបស់អាចេលក៍ទាំងនោះ សម្លឹងមើលអាចេលក៍ទាំងនោះហើយ គិតថា អាចេលក៍ទាំងនេះមិនមែនព្រះអរហន្ត ទើបតិះដៀលថា ហេតុអ្វីលោកពុក ទើបឲ្យហៅខ្ញុំមកកាន់សំណាក់របស់ពួកអ្នកដែលគ្មានហិរិឱត្តប្បៈ ដូច្នេះ ហើយក៏ត្រឡប់ទៅទីនៅរបស់ខ្លួនវិញ ។ ពួកអាចេលក៍ឃើញនាងហើយ ទាំងអស់គ្នាក៏តិះដៀលសេដ្ឋីក្នុងរំពេចនុ៎ះឯងថា គហបតីលោករកស្រីដទៃមិនបានឬ ហេតុអ្វីលោកទើបនាំស្រីបែបនេះ ដែលជាសាវិការបស់ព្រះសមណគោតម ជាកាឡកិណីធំ ឲ្យចូលក្នុងផ្ទះ ចូរប្រញាប់នាំស្រីនោះចេញពីផ្ទះនេះទៅ ។ លំដាប់នោះ សេដ្ឋីគិតថា យើងមិនអាចបណ្តេញស្រីនេះចេញពីផ្ទះទៅតាមពាក្យរបស់អាចេលក៍ទាំងនេះបានទេ ព្រោះស្រីនេះជាធីតារបស់ត្រកូលធំ ទើបពោលថា លោកអាចារ្យទាំងឡាយ ដែលឈ្មោះថា កម្មោះក្រមុំទាំងឡាយគប្បីធ្វើដោយការដឹងខ្លួនខ្លះ ទាំងមិនដឹងខ្លួនខ្លះ សូមពួកលោកស្ងៀមចុះ ហើយក៏

បញ្ជូនពួកអាចេលក៏ត្រឡប់ទៅ ហើយអង្គុយលើគ្រែធំ នាងវិសាខាកាន់ស្លាបព្រាមាសអង្គៀស លោកក៏បរិភោគបាយមធុបាយាសមានទឹកតិចក្នុងថាសមាស ។

សម័យនោះ ព្រះថេរៈអ្នកកាន់បិណ្ឌបាតជាវត្ត ត្រាច់ទៅបិណ្ឌបាតមកដល់ទ្វារផ្ទះរបស់សេដ្ឋី ។ នាងវិសាខាឃើញព្រះថេរៈហើយ គិតថា មិនគួរប្រាប់បិតាស្វាមី ដូច្នេះ ទាំងលោកសេដ្ឋីក៏ឃើញព្រះថេរៈនោះដែលមិនទាន់ចេញទៅ គង់នៅឈរយ៉ាងនោះ ។ តែសេដ្ឋីនោះជាបុគ្គលពាល សូម្បីឃើញព្រះថេរៈ ក៏ធ្វើដូចជាមិនឃើញ ឱនមុខបរិភោគបាយមធុបាយាសរឿយៗ ទៅ ។ នាងវិសាខាក៏ដឹងបានថា បិតាស្វាមីរបស់យើងសូម្បីឃើញព្រះថេរៈ ក៏មិនធ្វើអាការដឹង ទើបចូលទៅរកព្រះថេរៈ ពោលថា សូមលោកម្ចាស់ទៅខាងមុខសិនចុះ បិតាស្វាមីរបស់ខ្ញុំម្ចាស់ កំពុងស៊ីបុណ្យ ។ សេដ្ឋីនោះ វេលាដែលពួកនិគ្រន្ថពោលគ្រាមុន ក៏អត់ទ្រាំបាន តែក្នុងខណៈដែលនាងវិសាខាពោលថា ស៊ីបុណ្យចាស់ ក៏ដាក់ដៃចុះ បង្គាប់ថា ពួកអ្នកឯងចូរនាំបាយបាយាសនេះចេញពីទីនេះទៅ និងចូរនាំស្រីនេះចេញពីផ្ទះនេះទៅ ព្រោះថា ស្រីម្នាក់នេះធ្វើឲ្យយើងឈ្មោះថា ជាអ្នកស៊ីរបស់មិនស្អាតក្នុងផ្ទះមង្គលបែបនេះ ។ ប៉ុន្តែថា ក្នុងនិវេសន៍នោះឯង ទាសៈ និងកម្មករជាដើមទាំងអស់ជាសម្បត្តិរបស់នាងវិសាខា មិនមាននរណាៗ អាចនឹងចាប់ដៃជើងនាងបាន ដែលឈ្មោះថា អ្នកអាចនឹងពោលដោយមាត់ក៏មិនមាន ។ កាលនាងវិសាខា

ស្តាប់ពាក្យរបស់បិតាស្វាមីហើយ ពោលថា លោកពុក ពួកយើងនឹងមិនចេញទៅដោយហេតុត្រឹមតែប៉ុណ្ណេះទេ ខ្ញុំក៏មិនត្រូវបានលោកនាំមកពីកំពង់ទឹក ដូចពួកកុម្ភទាសី ធម្មតាថា ពួកធីតារបស់មាតាបិតាដែលនៅមានជីវិត រមែងមិនចេញទៅដោយហេតុត្រឹមតែប៉ុណ្ណេះ មួយទៀត ដោយហេតុត្រឹមតែប៉ុណ្ណេះនេះឯង ក្នុងថ្ងៃដែលខ្ញុំមកក្នុងទីនេះ បិតារបស់ខ្ញុំក៏ឲ្យហៅកុដុម្ពិកៈ ៨ នាក់ មកប្រាប់ថា បើកំហុសកើតព្រោះធីតារបស់យើង ពួកលោកចូរជួយគ្នាជម្រះ ហើយក៏ប្រគល់ខ្ញុំទុកក្នុងដៃរបស់កុដុម្ពិកៈ ៨ នាក់នោះ សូមលោកពុកឲ្យហៅកុដុម្ពិកៈ ៨ នាក់ នោះមកឲ្យគេជម្រះថា ជាកំហុស ឬមិនមែនកំហុសរបស់ខ្ញុំទេ ។ លំដាប់នោះ សេដ្ឋីគិតថា ក្មេងស្រីនេះនិយាយល្អ ទើបឲ្យហៅកុដុម្ពិកៈ ៨ នាក់មក ប្រាប់ថា ក្មេងស្រីនេះ ហៅយើងដែលអង្គុយក្នុងផ្ទះមង្គលក្នុងថ្ងៃដែលគម្រប់ ៧ ថ្ងៃថា ជាអ្នកស៊ីរបស់មិនស្អាត ។ កុដុម្ពិកៈ ៨ នាក់នោះ ទើបសួរនាងថា គេថាយ៉ាងនេះពិតឬនាង ។ នាងឆ្លើយថា លោកអ៊ំ បិតាស្វាមីរបស់ខ្ញុំ នឹងត្រូវការស៊ីរបស់មិនស្អាតខ្លួនឯង ខ្ញុំមិនបាននិយាយឲ្យឆ្លើយ៉ាងនោះទេ ។ កាលព្រះថេរៈដែលកាន់បិណ្ឌបាតជាវត្តមួយរូបឈរជិតទ្វារផ្ទះ បិតានេះកំពុងបរិភោគមធុបាយាសមានទឹកតិច មានចិត្តមិនរវល់នឹងព្រះថេរៈនោះឡើយ ដោយហេតុនេះ ខ្ញុំទើបនិយាយប៉ុណ្ណេះថា សូមលោកម្ចាស់ទៅខាងមុខសិនចុះ បិតាស្វាមីរបស់ខ្ញុំម្ចាស់មិនធ្វើបុណ្យក្នុងអត្តភាពនេះ កំពុងស៊ីបុណ្យចាស់ ។ កុដុម្ពិកៈ ៨ នាក់ទើបពោលថា នាងមិនមានកំហុស

ក្នុងប្រការនេះ ធីតារបស់យើងនិយាយមានហេតុ ហេតុអ្វីលោកទើបក្រោធហ្ន៎ ។ សេដ្ឋីពោលថា បាអើយ កំហុសនោះមិនមានក៏ហើចុះ តែក្មេងស្រីនេះក្នុងថ្ងៃដែលមក ក៏មិនយកចិត្តដាក់ក្នុងបុត្រយើង បានទៅកាន់ទីតាមខ្លួនឯងប្រាថ្នា ។ កុដុម្ពិក: ៨ នាក់ សួរថា គេពោលយ៉ាងនោះពិតឬនាង ។ នាងឆ្លើយថា លោកអើ ខ្ញុំមិនទៅកាន់ទីដែលខ្លួនពេញចិត្ត តែក្នុងផ្ទះនេះ កាលមេសេះមួយសែនកើតកូន ខ្ញុំគិតថា មិនធ្វើការយកចិត្តទុកដាក់ ហើយអង្គុយព្រងើយ មិនសមគួរ ទើបឲ្យពួកទាសីកាន់គប់ភ្លើងទៅទីនោះ ទើបប្រាប់ឲ្យថែរក្សាមេសេះដែលកើតកូននោះ ។ កុដុម្ពិក: ៨ នាក់ ពោលថា លោកសេដ្ឋី ធីតារបស់យើងបានធ្វើកិច្ចការសូម្បីពួកទាសីត្រូវធ្វើក្នុងផ្ទះ លោកឃើញទោសអ្វីក្នុងប្រការនេះ ។ សេដ្ឋីពោលថា បាអើយ នោះជាគុណ គឺ សេចក្ដីល្អក៏ពិត តែបិតារបស់ក្មេងស្រីនេះ កាលឲ្យឱវាទក្នុងថ្ងៃដែលមកក្នុងទីនេះ ក៏ពោលថា ភ្លើងក្នុងមិនគួរនាំចេញ ។ កុដុម្ពិក: ៨ នាក់សួរនាងថា គេថាយ៉ាងនោះពិតឬនាង ។ នាងឆ្លើយថា លោកអើ បិតារបស់ខ្ញុំមិនបាននិយាយសំដៅដល់ភ្លើងនោះទេ តែរឿងសេចក្ដីកំបាំងយ៉ាងណារបស់មនុស្សស្រីមានមាតាស្វាមីជាដើម កើតឡើងខាងក្នុងនិវេសន៍ រឿងសេចក្ដីកំបាំងនោះ មិនគួរប្រាប់ដល់ពួកទាស: និងទាសី ព្រោះថារឿងបែបនោះ មានតែនឹងផ្សាយចេញទៅជាការឈ្លោះគ្នា ព្រោះដូច្នោះ បិតារបស់ខ្ញុំសំដៅដល់ប្រការនេះ ទើបនិយាយ ។ សេដ្ឋីពោល

ថា សំឡាញ់ ប្រការនោះជាយ៉ាងនោះក៏ពិត តែបិតារបស់ក្មេងស្រីនេះពោលថា ភ្លើងក្រៅមិនគួរនាំចូលទៅខាងក្នុង ក៏កាលភ្លើងក្នុងរលត់ទៅហើយ យើងមិននាំភ្លើងខាងក្រៅចូលមកបានឬ ។ កុដុម្ពិកៈ ៨ នាក់ សួរនាងថា គេថាយ៉ាងនោះពិតឬនាង ។ នាងឆ្លើយថា បិតារបស់ខ្ញុំមិនបាននិយាយសំដៅដល់ភ្លើងនោះទេ តែកំហុសណា ដែលពួកទាសៈ និងកម្មករនិយាយគ្នា កំហុសនោះ មិនគួរប្រាប់ដល់អ្នកខាងក្នុង ។ល។ សូម្បីពាក្យណា លោកពុកពោលថា គប្បីឲ្យដល់អ្នកគួរឲ្យប៉ុណ្ណោះ ពាក្យនោះលោកក៏ពោលសំដៅថា គប្បីឲ្យដល់ពួកអ្នកដែលខ្ចីគ្រឿងប្រើប្រាស់ ហើយនាំមកសងវិញប៉ុណ្ណោះ ។ សូម្បីពាក្យថា **យេ ន ទេន្តិ** លោកក៏ពោលសំដៅន័យថា មិនគប្បីឲ្យដល់ពួកអ្នកដែលខ្ចីគ្រឿងប្រើប្រាស់ហើយ មិននាំមកសងវិញនោះឯង ។ ចំណែកបទនេះថា **ទទន្តស្សាបិ អទទន្តស្សាបិ ទាតព្វំ** លោកពោលសំដៅន័យថា កាលញាតិមិត្តធ្លាក់ខ្លួនលំបាកមកដល់ហើយ គេនឹងអាចសង ឬមិនអាចសងបានក៏ដោយ ក៏គួរឲ្យប៉ុណ្ណោះ ។ បទនេះថា **សុខំ និសីទិតព្វំ** លោកពោលក្នុងន័យថា កាលឃើញមាតាបិតាស្វាមីហើយ មិនគួរអង្គុយព្រងើយក្នុងទីដែលខ្លួនគួរក្រោកឈរឡើង បទថា **សុខំ ភុញ្ជិតព្វំ** លោកពោលសំដៅន័យថា មិនបរិភោគមុនមាតាបិតាស្វាមី និងស្វាមី គួរក្រឡេកមើលលោកទាំងនោះសិនដឹងថា លោកទាំងនោះបានហើយ ឬមិនទាន់បានអ្វី ទើបខ្លួនឯងបរិភោគក្នុងពេល

ក្រោយ ៗ បទថា **សុខំ និបជ្ជិតព្វំ** លោកពោលសំដៅដល់ប្រការនេះថា មិនគប្បី ឡើងទីដេកហើយដេកមុន មាតាបិតាស្វាមី និងស្វាមី ត្រូវធ្វើវត្តបដិបត្តិដែលសមគួរ ធ្វើដល់លោកទាំងនោះហើយ ខ្លួនឯងទើបគួរដេកក្នុងពេលក្រោយ ៗ បទថា **អគ្គិ បរិចរិតព្វោ** លោកពោលសំដៅដល់ប្រការនេះថា គួរនឹងឃើញទាំងបិតាមាតាស្វាមី ទាំងស្វាមី ដូចជាគំនរភ្លើង និងដូចពពារពស់ ៗ សេដ្ឋីពោលថា នោះក៏ជាគុណ ក៏ពិតហើយ តែបិតារបស់ក្មេងស្រីនេះ ឲ្យទមស្ការទេវតាខាងក្នុង ប្រយោជន៍អ្វី ក្នុងឱវាទនេះ ៗ កុដុម្ពិកៈទាំង ៨ នាក់ សួរនាងថា គេថាយ៉ាងនោះពិតឬនាង ៗ នាងឆ្លើយថា ពិតហើយ លោកអ៊ំទាំងឡាយ បិតារបស់ខ្ញុំពោលពាក្យនេះ សំដៅ យ៉ាងនេះ តាំងពីឃើងនៅគ្រប់គ្រងផ្ទះតាមប្រពៃណី ឃើញអ្នកបួសមកដល់ទ្វារ ផ្ទះរបស់ខ្លួនហើយ ត្រូវថ្វាយរបស់ទំពារ របស់បរិភោគដែលមាននៅក្នុងផ្ទះ ដល់ ពួកអ្នកបួសហើយ ខ្លួនឯងទើបគួរបរិភោគ ៗ គ្រានោះ កុដុម្ពិកៈទាំងនោះទើបសួរ សេដ្ឋីនោះថា លោកសេដ្ឋី លោកឃើញពួកអ្នកបួសហើយ នឹងពេញចិត្តថា មិន គួរឲ្យឬ ៗ លោកសេដ្ឋីរកមិនឃើញពាក្យឆ្លើយតបយ៉ាងដទៃ ទើបបានតែអង្គុយ ឱនមុខ ៗ

គ្រានោះ ពួកកុដុម្ពិកៈទើបសួរសេដ្ឋីនោះថា កំហុសយ៉ាងដទៃរបស់ធីតា យើង នៅមានទៀតឬ ៗ ឆ្លើយថា មិនមានទេសំឡាញ់ ៗ សួរថា ព្រោះហេតុអ្វី

លោកទើបបណ្តេញធីតា ដែលមិនមានកំហុសចេញពីផ្ទះ ដោយមិនមានហេតុ ។ ខណៈនោះ នាងវិសាខាពោលថា មិនទាន់គួរទៅតាមពាក្យរបស់បិតាស្វាមីខ្ញុំទេ តែថ្ងៃដែលខ្ញុំមក បិតាខ្ញុំ ប្រគល់ខ្ញុំទុកក្នុងដៃពួកលោកដើម្បីជម្រះការខុសត្រូវរបស់ខ្ញុំ ឥឡូវនេះខ្ញុំទៅបានស្រួលហើយ ទើបបង្គាប់ពួកទាសី និងទាសៈឲ្យធ្វើការត្រៀមយានជាដើម ។ គ្រានោះ សេដ្ឋីនាំកុដុម្ពិកៈទាំងនោះ ទៅនិយាយចំពោះនាងថា នាងពុកមិនដឹង ទើបនិយាយទៅ ចូរលើកទោសឲ្យពុកចុះ ។ នាងពោលថា លោកទាំងឡាយ ខ្ញុំគប្បីអត់ទោសដល់ពួកលោកបាន នឹងអត់ទោសឲ្យហើយ តែខ្ញុំជាធីតារបស់លោកសេដ្ឋីអ្នកជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធសាសនា ខ្ញុំមិនអាចវៀរភិក្ខុសង្ឃចេញបាន បើខ្ញុំបានទំនុកបម្រុងភិក្ខុសង្ឃតាមការពេញចិត្តរបស់ខ្ញុំ ខ្ញុំទើបនៅ ។ សេដ្ឋីពោលថា កូន កូនចូរទំនុកបម្រុងពួកសមណៈរបស់កូនតាមសេចក្តីពេញចិត្តចុះ ។ ដូច្នោះ នាងវិសាខាទើបឲ្យនិមន្តព្រះទសពល អារាធនាភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន គង់ពេញនិវេសន៍ក្នុងថ្ងៃស្អែក ។ សូម្បីបរិស័ទរបស់អាជីវកអាក្រាត ដឹងថា ព្រះសាស្តាស្តេចយាងទៅផ្ទះមិគារសេដ្ឋី ក៏ទៅទីនោះ នាំគ្នាអង្គុយព័ទ្ធជុំវិញផ្ទះ ។ នាងវិសាខាឲ្យទឹកទក្ខិណោទកហើយ បញ្ជូនដំណឹងប្រាប់ថា សក្ការៈគ្រប់យ៉ាងចាត់ចែងហើយ សូមបិតាស្វាមីរបស់យើងមេត្តាមក អង្គាសចំពោះព្រះទសពល ។ សេដ្ឋីនោះស្តាប់ពាក្យរបស់នាងវិសាខាហើយ ក៏ពោលថា សូមធីតា

របស់យើងអង្គាសព្រះសម្មាសម្ពុទ្ធចុះ ។ នាងវិសាខា កាលអង្គាសព្រះទសពល ដោយកត្តាហារដែលមានរសប្រណីតផ្សេងៗ ហើយ លុះសម្រេចកត្តកិច្ចហើយ ក៏បញ្ជូនដំណឹងទៅទៀតថា សូមបិតាស្វាមីរបស់យើងមេត្តាមកស្តាប់ធម្មកថារបស់ព្រះទសពល ។ លំដាប់នោះ សេដ្ឋីនោះក៏ទៅដើម្បីប្រាថ្នានឹងស្តាប់ធម្មកថា ថាឥឡូវនេះ ឈ្មោះថាការមិនទៅ ជាហេតុមិនសមគួរឡើយ ពួកអាជីវកអាក្រាត ក៏ពោលថា លោកកាលស្តាប់ធម៌របស់ព្រះសមណគោតម ក៏ចូរអង្គុយស្តាប់ខាងក្នុងវាំងនន ហើយក៏នាំគ្នាទៅមុន បាំងវាំងននទុក ។ មិគារសេដ្ឋីទៅអង្គុយក្នុងវាំងនន ។

ព្រះតថាគតទ្រង់ព្រះតម្រិះថា ទោះសេដ្ឋីនេះអង្គុយក្នុងវាំងននក្តី ក្រៅផ្ទះក្តី ក្រៅផ្ទាំងថ្មក្តី ឬក្រៅចក្រវាឡក្តី តថាគតអាចនាំគេឲ្យបានឮសំឡេងតថាគតបាន ទើបត្រាស់ធម្មកថា ដូចជាចាប់ដើមស្វាយអង្រួនឲ្យផ្លែដែលមានពណ៌ដូចមាសជ្រុះចុះហើយ ដូច្នោះ ចប់ទេសនា សេដ្ឋីក៏តាំងនៅក្នុងសោតាបត្តិផល បើកវាំងននឡើង ថ្វាយបង្គំព្រះបាទារបស់ព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន ។ ក្នុងសំណាក់ព្រះសាស្តានុ៎ះឯង ក៏ស្ថាបនានាងវិសាខាទុកក្នុងតំណែងមាតារបស់ខ្លួនថា នាងចូរជាមាតារបស់យើងចាប់តាំងពីថ្ងៃនេះទៅ ។ តាំងពីនោះមក នាងវិសាខា ទើបមានឈ្មោះថា **មិគារមាតា** ។

ថ្ងៃមួយ កាលនក្ខត្តឫក្សស្រម័យដំណើរទៅក្នុងព្រះនគរ នាងវិសាខា ក៏គិតថា មិនមានគុណក្នុងការនៅក្នុងព្រះនគរ ទើបហែហមដោយទាសី ដើរទៅស្តាប់ធម្មកថារបស់ព្រះសាស្តា តែនឹកគិតថា ទៅសំណាក់ព្រះសាស្តា ទាំងភេទដែលមានគ្រឿងគ្របដណ្តប់មិនគួរ ទើបដោះគ្រឿងប្រដាប់មហាលតាបសាធន៍ចេញ ប្រគល់ទុកក្នុងដៃទាសី ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តាត្រាស់ធម្មកថា ។ ចប់ព្រះធម៌ទេសនារបស់ព្រះសាស្តា នាងទើបថ្វាយបង្គំព្រះទសពល ហើយដើរបំណងមកកាន់ព្រះនគរ ។ សូម្បីទាសីនោះមិនទាន់កំណត់ស្ថានទីនាងដាក់គ្រឿងប្រដាប់ដែលខ្លួនទទួលទុក ទើបដើរត្រឡប់ទៅ ដើម្បីរកគ្រឿងប្រដាប់ ។ ខណៈនោះ នាងវិសាខាទើបសាកសួរទាសីនោះថា នាងទុកគ្រឿងប្រដាប់ត្រង់ណា ។ ទាសីឆ្លើយថា ត្រង់បរិវេណព្រះគន្ធកុដិ នាងម្ចាស់ ។ នាងវិសាខាពោលថា ណ្ហើយចុះ នាងចូរទៅនាំមក ផ្តើមតាំងពីនាងដាក់របស់ទុកក្នុងបរិវេណព្រះគន្ធកុដិហើយ ឈ្មោះថា ការឲ្យនាំរបស់ត្រឡប់មកវិញមិនសមគួរដល់យើង ព្រោះហេតុនោះ យើងនឹងលះបង់គ្រឿងប្រដាប់មហាល-តាបសាធន៍នោះ ធ្វើជាទណ្ឌកម្ម តែកាលគ្រឿងប្រដាប់នោះបានរក្សាទុក ភិក្ខុទាំងឡាយក៏គង់ជាកង្វល់ ។ ស្អែកឡើង ព្រះសាស្តាមានភិក្ខុសង្ឃជាបរិវារ ស្តេចយាងដល់ទ្វារនិវេសន៍របស់នាងវិសាខា ក៏ក្នុងនិវេសន៍បានរៀបចំអាសនៈទុកជាប្រចាំ ។

នាងវិសាខាទទួលបាត្ររបស់ព្រះសាស្តា អារាធនាឲ្យស្តេចចូលផ្ទះ ឲ្យប្រថាប់គង់លើអាសនៈដែលរៀបចំទុកហើយនុ៎ះឯង កាលព្រះសាស្តាសោយស្រេចហើយ ក៏នាំគ្រឿងប្រដាប់នោះទៅដាក់ទុកជិតព្រះបាទារបស់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គថ្វាយគ្រឿងប្រដាប់នេះចំពោះព្រះអង្គ ។ ព្រះសាស្តាត្រាស់ហាមថា ដែលឈ្មោះថា គ្រឿងប្រដាប់រមែងមិនសមគួរដល់ពួកអ្នកបួស ។ នាងវិសាខាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹង តែខ្ញុំព្រះអង្គនឹងចំណាយគ្រឿងប្រដាប់នេះ យកទ្រព្យមកសាងព្រះគន្ធកុដិជាទីប្រថាប់សម្រាប់ព្រះអង្គ ។ គ្រានោះ ព្រះសាស្តាក៏ទ្រង់ទទួលដោយតុណ្ហី សូម្បីនាងវិសាខានោះ ក៏ចំណាយគ្រឿងប្រដាប់នោះ យកទ្រព្យ ៩ កោដិ មកសាងព្រះគន្ធកុដិ ជាទីប្រថាប់សម្រាប់ព្រះតថាគតក្នុងវិហារ ឈ្មោះថា **បុព្វារាម** ប្រដាប់ដោយបន្ទប់ ១.០០០ ។

ក៏និវេសន៍របស់នាងវិសាខា វេលាព្រឹកក៏ក្ញុំទ្រលួលដោយសំពត់កាសាវៈសម្បូរទៅដោយអ្នកស្វែងបុណ្យ ។ ក្នុងផ្ទះរបស់នាងវិសាខានោះ ក៏ចាត់ចែងទានទុកគ្រប់សព្វ ដូចក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីដែរ ។ នាងវិសាខានោះ វេលាព្រឹក ក៏ធ្វើអាមិសសង្គ្រោះដល់ព្រះភិក្ខុសង្ឃ ខាងក្រោយអាហារក៏ឲ្យអ្នកបម្រើកាន់ភេសជ្ជៈ ថ្នាំ និងទឹកអដ្ឋបានទៅកាន់វិហារប្រគេនដល់ព្រះភិក្ខុសង្ឃ ស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ហើយក៏ត្រឡប់មកវិញ ។ ខាងក្រោយតមក

*ព្រះសាស្តា កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនានាងវិសាខាមិគារមាតាទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកថ្វាយទាន ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣-៤

## "ប្រវត្តិនាងខុជ្ជុត្តរា និងនាងសាមាវតី"

*ក្នុងសូត្រទី ៣ និងទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥២] *ដោយបទថា* ***ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា មេត្តាវិហារីនំ យទិទំ សាមាវតី*** *លោកសម្តែងថា នាងខុជ្ជុត្តរា ប្រសើរជាងពួកឧបាសិកាជាពហុស្សុត ។ នាងសាមាវតី ប្រសើរជាងពួកឧបាសិកាអ្នកមានប្រក្រតីនៅដោយមេត្តា ។*

*បានឮថា ស្ត្រីនាងទាំងពីរ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *បានបដិសន្ធិក្នុងត្រកូល ក្នុងក្រុងហង្សវតី តមកគិតគ្នាថា នឹងស្តាប់ធម្មកថារបស់ព្រះសាស្តា ទើបនាំគ្នាទៅវិហារ ។ នាងទាំងពីរនោះ នាងខុជ្ជុត្តរា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអរិយសាវិកាដែលជាពហុស្សុត ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាក្នុងតំណែងនោះ ។ នាងសាមាវតី ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាមួយនាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអរិយសាវិកាអ្នកនៅដោយមេត្តា ទើបធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ កាលនាងទាំងពីរធ្វើកុសលរហូតអស់ជីវិត ក៏កើតក្នុងទេវលោក វិលវល់នៅក្នុងទេវតា និងមនុស្សទាំងឡាយ ។*

វេលាក៏កន្លងទៅអស់សែនកប្ប ។

គ្រានោះ មុនព្រះសាស្តារបស់យើងកើតឡើង ។ កើតអហិវាតករោគឡើង ក្នុងដែនអល្លកប្បៈ ក្នុងផ្ទះមួយខ្នងៗ មនុស្ស ១០ នាក់ខ្លះ ២០ នាក់ខ្លះ ៣០ នាក់ខ្លះ ក៏ស្លាប់ព្រមៗ គ្នាទុំះឯង ។ ចំណែកមនុស្សដែលទៅក្រៅដែន ក៏រួចជីវិត ។ បុរសម្នាក់ដឹងរឿងនោះហើយ ក៏នាំបុត្រភរិយារបស់ខ្លួនទៅក្រៅដែន ដោយសំដៅនឹងទៅកាន់ដែនដទៃ ។ គ្រានោះ ស្បៀងធ្វើដំណើរដែលយកមកពីផ្ទះរបស់បុរសនោះ មិនទាន់ផុតផ្លូវកន្តារផង ក៏អស់ទៅ ។ កម្លាំងពលំរាងកាយរបស់ពួកគេ ក៏ថយចុះ ។ មាតាពបុត្រទៅបានបន្តិច បិតាក៏ពបុត្រទៅ បានបន្តិច គ្រានោះ បិតារបស់បុត្រនោះទើបគិតថា កម្លាំងរបស់ពួកយើងក៏ថយចុះហើយ នឹងពបុត្រដើរទៅមិនអាចផុតផ្លូវកន្តារបាន ។ បុរសនោះមិនឲ្យភរិយាដឹង ក៏ដាក់ឲ្យបុត្រអង្គុយត្រង់ផ្លូវ ធ្វើដូចជាទៅរកទឹក ហើយក៏ធ្វើដំណើរទៅតែម្នាក់ឯង ។ គ្រានោះ ភរិយាឈរចាំគេមក មិនឃើញបុត្រក្នុងដៃក៏ពោលថា បុត្រខ្ញុំទៅណាហើយ គេនិយាយលួងលោមថា នាងត្រូវការបុត្រធ្វើអ្វី យើងនៅមានជីវិតនឹងបានបុត្រទៀត នាងពោលថា បុរសនេះចិត្តអាក្រក់ណាស់ហ្ន៎ ហើយពោលថា លោកទៅចុះ ខ្ញុំមិនទៅជាមួយលោកទេ , គេពោលថា នាង ខ្ញុំមិនពិចារណាបានធ្វើទៅហើយ ចូរលើកទោសនោះដល់ខ្ញុំចុះ ហើយក៏នាំបុត្រទៅ ។ គេទាំងនោះ ផុតផ្លូវកន្តារនោះហើយ វេលាល្ងាច

ក៏ដល់ស្រុកពួកអ្នកចិញ្ចឹមគោក្នុងតំបន់មួយ ។

ថ្ងៃនោះ ពួកអ្នកស្រុកចិញ្ចឹមគោ ចម្អិនបាយាសមិនមានទឹក ឃើញគេទាំងនោះ ក៏គិតថា អ្នកទាំងនោះពិតជាស្រេកឃ្លាន ទើបយកបាយាសដាក់ពេញភាជន៍ធំ ចាក់ទឹកដោះពេញបោយទៅឲ្យ កាលអ្នកទាំងនោះបរិភោគបាយបាយាសនោះ ស្ត្រីនោះក៏បរិភោគល្មមប្រមាណ ចំណែកបុរសបរិភោគហួសប្រមាណ មិនអាចឲ្យភ្លើងធាតុរំលាយបាន ក៏ស្លាប់ក្នុងវេលារំលងអាធ្រាត កាលមុនពេលស្លាប់ ព្រោះនៅមានសេចក្តីអាល័យក្នុងអ្នកទាំងនោះ ទើបបដិសន្ធិក្នុងផ្ទៃមេសុនខក្នុងផ្ទះរបស់ពួកអ្នកចិញ្ចឹមគោ ។ មិនយូរប៉ុន្មាន មេសុនខក៏កើតកូន អ្នកចិញ្ចឹមគោឃើញកូនសុនខនោះ មានលក្ខណៈល្អ ក៏ថែទាំចិញ្ចឹមដោយដុំបាយ ទើបនាំកូនសុនខដែលកើតសេចក្តីស្រឡាញ់ក្នុងខ្លួនត្រាច់ទៅជាមួយគ្នា ។

តមកថ្ងៃមួយ ព្រះបច្ចេកពុទ្ធមួយអង្គមកដល់ទ្វារផ្ទះរបស់អ្នកចិញ្ចឹមគោ ក្នុងវេលាស្វែងរកអាហារ អ្នកចិញ្ចឹមគោនោះ ឃើញព្រះបច្ចេកពុទ្ធអង្គនោះហើយ ក៏ថ្វាយអាហារ ទទួលបដ្ឋាករបស់ព្រះបច្ចេកពុទ្ធដែលនឹងអាស្រ័យខ្លួន ព្រះបច្ចេក-ពុទ្ធ ក៏គង់នៅក្នុងដងព្រៃមួយកន្លែង មិនឆ្ងាយត្រកូលអ្នកចិញ្ចឹមគោ អ្នកចិញ្ចឹមគោទៅសំណាក់ព្រះបច្ចេកពុទ្ធ ក៏នាំសុនខនោះទៅជាមួយ ក៏វាយដើមឈើ ឬផ្ទាំងថ្មដើម្បីដេញសត្វកាច ក្នុងទីនៅនៃសត្វកាចរវាងផ្លូវ សូម្បីសុនខនោះ ក៏កំណត់វិធី

ធ្វើរបស់អ្នកចិញ្ចឹមគោនោះទុក តមកថ្ងៃមួយ អ្នកចិញ្ចឹមគោអង្គុយក្នុងសំណាក់ព្រះបច្ចេកពុទ្ធ ពោលថា លោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនបានមកគ្រប់ពេល តែសុនខនេះឆ្លាត ដោយសញ្ញាដែលសុនខនេះមកហើយ ក៏នឹងមកកាន់ទ្វារផ្ទះរបស់ខ្ញុំបានថ្ងៃមួយ អ្នកចិញ្ចឹមគោនោះ ក៏បញ្ជូនសុនខទៅ ដោយពោលថា ឯងចូរនាំព្រះបច្ចេកពុទ្ធមក សុនខនោះស្តាប់ពាក្យរបស់អ្នកចិញ្ចឹមគោនោះ ក៏ទៅក្នុងវេលាបិណ្ឌបាត្រ ក៏យកទ្រូងក្រាបទៀបព្រះបាទព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធដឹងថា សុនខនេះមកសំណាក់យើងហើយ ក៏កាន់បាត្រចីវរធ្វើដំណើរទៅ តែលោកបំណងសាកល្បងសុនខនោះ ទើបគេចចេញធ្វើដំណើរដទៃវិញ សុនខក៏ឈរខាងមុខ ស្រែកកៀងឲ្យទៅផ្លូវដែលទៅកាន់ផ្ទះអ្នកចិញ្ចឹមគោ ក៏ក្នុងទីណា អ្នកចិញ្ចឹមគោវាយដើមឈើ ឬផ្ទាំងថ្ម ដើម្បីបណ្តេញសត្វកាច សុនខដល់ទីនោះហើយ ក៏បន្លឺសំឡេងព្រុសខ្លាំងៗដោយសំឡេងរបស់សុនខនោះ សត្វកាចទាំងឡាយក៏គេចចេញទៅ សូម្បីព្រះបច្ចេកពុទ្ធក៏ឲ្យដុំបាយដែលត្រជាក់ៗ ដល់សុនខនោះ ក្នុងវេលាឆាន់ស្រេចហើយ សូម្បីសុនខនោះ ក៏ស្រឡាញ់យ៉ាងខ្លាំងក្នុងព្រះបច្ចេកពុទ្ធដោយសេចក្តីប្រាថ្នាក្នុងដុំបាយអ្នកចិញ្ចឹមគោថ្វាយសំពត់ល្មមដល់ការធ្វើចីវរបាន ៣ ផ្ទាំង ដល់ព្រះបច្ចេកពុទ្ធរហូតដល់អស់ត្រៃមាស ហើយពោលថា លោកម្ចាស់ បើលោកម្ចាស់ពេញចិត្តក៏សូមនៅក្នុងទីនេះ តែបើមិនពេញចិត្តទេ សូមមេត្តាទៅតាមសប្បាយចុះ ព្រះបច្ចេក-

ពុទ្ធសម្ដែងអាការថា នឹងទៅ អ្នកចិញ្ចឹមគោជូនដំណើរព្រះបច្ចេកពុទ្ធហើយ ក៏វិលត្រឡប់ សុនខដឹងថា ព្រះបច្ចេកពុទ្ធទៅទីដទៃ ក៏កើតសេចក្ដីសោកយ៉ាងខ្លាំង ព្រោះស្រឡាញ់ បេះដូងក៏បែក ហើយស្លាប់ទៅកើតក្នុងសួគ៌ជាន់តាវត្តិង្ស ។ ក៏ព្រោះដែលសត្វកាចគេចចេញ ព្រោះសុនខនោះធ្វើសំឡេងខ្លាំងៗ ក្នុងវេលាទៅជាមួយព្រះបច្ចេកពុទ្ធ សំឡេងរបស់ទេវបុត្រនោះ កាលនិយាយនឹងពួកទេវតា ទើបគ្របសង្កត់សំឡេងទេវតាទាំងអស់ ដោយហេតុនោះឯង ទេវបុត្រនោះទើបបានឈ្មោះថា ឃោសកទេវបុត្រ ក៏កាលឃោសកទេវបុត្រនោះ សោយសម្បត្តិក្នុងតាវត្តិង្សនោះ ព្រះរាជាព្រះនាមថា ឧទេន សោយរាជសម្បត្តិក្នុងក្រុងកោសម្ពី នាឋានមនុស្ស រឿងរបស់ព្រះបាទឧទេន គប្បីជ្រាបដោយន័យដែលពោលទុកហើយ ក្នុងអដ្ឋកថាពោធិរាជកុមារសូត្រ នុ៎ះឯង ។

កាលព្រះបាទឧទេននោះគ្រងរាជ្យ ឃោសកទេវបុត្រ ក៏ចុតិ បានបដិសន្ធិក្នុងគភ៌របស់ស្ត្រីដែលអាស្រ័យរូបចិញ្ចឹមជីវិតម្នាក់ ក្នុងក្រុងកោសម្ពី កន្លងទៅ ១០ ខែ នាងក៏ប្រសូតបុត្រ ដឹងថា ជាប្រុសក៏លះបង់ចោលត្រង់គំនរសម្រាម ។ ខណៈនោះ អ្នកបម្រើរបស់កោសម្ពិកសេដ្ឋី កំពុងដើរទៅផ្ទះសេដ្ឋីពីព្រឹកព្រលឹម សង្ស័យថា វត្ថុនេះជាអ្វីហ្ន៎ ដែលពួកក្អែកចោមរោមហើយ ក៏ចូលទៅ ឃើញទារកគិតថា ទារកនេះជាអ្នកមានបុណ្យ ទើបបញ្ជូនទារកទុកក្នុងដៃបុរសម្នាក់ឲ្យនាំទៅ

កាន់ផ្ទះ (ខ្លួន) ហើយក៏ទៅផ្ទះសេដ្ឋី ចំណែកសេដ្ឋីកំពុងទៅកាន់រាជត្រកូល ក្នុងវេលាចូលគាល់ ជួបបុរោហិតក្នុងវាងផ្លូវ ក៏សួរថា ថ្ងៃនេះ ផ្កាយឫក្សអ្វី បុរោហិតនោះឈរត្រង់ទីនោះឯង ក៏គណនាហើយពោលថា ផ្កាយឫក្សឈ្មោះឯណោះ ទារកដែលកើតតាមផ្កាយឫក្សនេះ ក្នុងថ្ងៃនេះ នឹងបានតំណែងសេដ្ឋីក្នុងនគរនេះ សេដ្ឋីនោះស្តាប់ពាក្យរបស់បុរោហិតនោះហើយ ក៏ប្រញាប់បញ្ជូនមនុស្សទៅកាន់ផ្ទះថា បុរោហិតនេះមិននិយាយជាពាក្យពីរ ភរិយារបស់យើងមានគភ៌ចាស់ហើយ ពួកអ្នកចូរពិនិត្យមើលនាង តើប្រសូតហើយឬនៅ អ្នកទាំងនោះទៅដឹងហើយក៏ពោលថា លោកម្ចាស់ លោកស្រីមានគភ៌ចាស់មែន តែមិនទាន់ប្រសូត ។ សេដ្ឋីទើបបង្គាប់ថា បើដូច្នោះ ពួកអ្នកចូរទៅរកទារកដែលកើតក្នុងថ្ងៃនេះ ក្នុងនគរនេះ អ្នកទាំងនោះស្វែងរក ក៏ជួបទារកនោះក្នុងផ្ទះ របស់អ្នកបម្រើរបស់សេដ្ឋីនោះ ហើយប្រាប់ដល់សេដ្ឋី ។ សេដ្ឋីពោលថា នាយ បើដូច្នោះ ពួកអ្នកចូរទៅហៅអ្នកបម្រើមក អ្នកទាំងនោះក៏ហៅអ្នកបម្រើមក សេដ្ឋីសួរគេថា ផ្ទះអ្នកមានទារកឬ គេឆ្លើយថា មានលោកម្ចាស់ សេដ្ឋីប្រាប់ថា អ្នកចូរឲ្យទារកនោះដល់យើងចុះ ។ គេថា ឲ្យមិនបានទេលោកម្ចាស់ ។ សេដ្ឋីពោលថា អ្នកទទួលទ្រព្យ ១.០០០ ហើយឲ្យមកចុះ ។ អ្នកបម្រើនោះគិតថា ទារកនេះនឹងរស់ ឬស្លាប់ ប្រការនេះក៏ដឹងដោយលំបាក ដូច្នេះទើបទទួលទ្រព្យ ១.០០០ ហើយឲ្យទារកទៅ ។

លំដាប់នោះ សេដ្ឋីគិតថា បើភរិយាយើងប្រសូតធីតា ក៏នឹងធ្វើទារកនេះឲ្យជាបុត្រ បើប្រសូតបុត្រ ក៏នឹងធ្វើទារកនេះឲ្យស្លាប់ លុះគិតហើយ ក៏ចិញ្ចឹមទារកទុកក្នុងផ្ទះ ។ គ្រានោះ ភរិយារបស់សេដ្ឋីនោះក៏ប្រសូតបុត្រ ដោយកន្លងទៅ ២-៣ ថ្ងៃ អំពីនោះ សេដ្ឋីក៏គិតនឹងឲ្យពួកគោជាន់ទារកនោះឲ្យស្លាប់ ទើបបង្គាប់ថា ពួកឯងចូរយកទារកនេះទៅដេកត្រង់ទ្វារក្រោល មនុស្សទាំងឡាយក៏ឲ្យទារកនោះដេកត្រង់ទ្វារក្រោលនោះ ។ គ្រានោះ គោឧសភៈមេហ្វូងចេញទៅមុន ឃើញទារកនោះ ក៏ឈរពាំងទុកក្នុងចន្លោះជើងទាំង ៤ ដោយបំណងថា គោដទៃៗ នឹងមិនជាន់ទារកនោះ ។ ដោយអាការយ៉ាងនេះ ខណៈនោះ អ្នកចិញ្ចឹមគោជួបទារកនោះ គិតថា ទារកនេះសូម្បីតែសត្វតិរច្ឆានក៏ស្គាល់គុណ ពិតជាអ្នកមានបុណ្យច្រើន យើងនឹងចិញ្ចឹមទារកនោះ ហើយក៏នាំទៅកាន់ផ្ទះខ្លួន ។

ចំណែកសេដ្ឋីជ្រាបថា ទារកនោះមិនទាន់ស្លាប់ បានឮថា ពួកអ្នកចិញ្ចឹមគោនាំទៅ ក៏ឲ្យទ្រព្យ ១.០០០ ហើយឲ្យគេយកទៅចោលនៅព្រៃស្មសាន ។ វេលានោះ អ្នកចិញ្ចឹមពពែក្នុងផ្ទះសេដ្ឋី អាស្រ័យព្រៃស្មសាន ក៏ដេញមេពពែឲ្យទៅស៊ីក្នុងទីនោះ មេពពែមួយក្បាល ព្រោះបុណ្យរបស់ទារក កាលទៅ ក៏ចេញពីផ្លូវ ទៅឲ្យទារកបៅដោះ ហើយក៏ទៅ កាលត្រឡប់ពីទីនោះ ក៏ទៅឲ្យទារកនោះបៅដោះទៀត អ្នកចិញ្ចឹមពពែគិតថា មេពពែនេះចៀងចូលទីនេះតាំងពីព្រឹក ព្រោះហេតុអ្វី

ហ្ន៎ ទើបដើរទៅពិនិត្យមើល ក៏ដឹងដល់ទារកនោះថា ទារកនេះជាអ្នកមានបុណ្យច្រើន សូម្បីតែសត្វតិរច្ឆានក៏ដឹងគុណ ចាំយើងនឹងចិញ្ចឹមទារកនោះទុក ហើយនាំទៅផ្ទះ ។

ចំណែកសេដ្ឋី ក៏ឲ្យពិចារណាមើលទៀតថា ទារកនោះស្លាប់ ឬមិនស្លាប់ ដឹងថា អ្នកចិញ្ចឹមពពែទទួលទុក ក៏ឲ្យទ្រព្យ ១.០០០ បន្ទាប់ថា ស្អែកនេះ បុត្រនាយកងរទេះម្នាក់ នឹងចូលមកកាន់នគរនេះ ពួកអ្នកចូរនាំទារកនេះទៅដាក់ទុកត្រង់ផ្លូវរទេះ រទេះនោះក៏មុខជានឹងកិនឲ្យស្លាប់ យ៉ាងនេះ ពួកគោក្នុងរទេះជំបូងរបស់នាយកងរទេះ កាលឃើញទារកដែលគេដាក់ទុកត្រង់ផ្លូវរទេះនោះ ក៏ឈរយកជើងទាំង ៤ ពាំងដូចសសរទប់ការពារ ដូច្នោះ ។ នាយកងរទេះសង្ស័យថា នោះជាអ្វី ក៏ដឹងហេតុដែលគោទាំងនោះឈប់ ឃើញទារក ហើយយល់ថា ទារកមានបុណ្យច្រើន គួរចិញ្ចឹមទុក ទើបនាំទៅជាមួយ ។

ចំណែកសេដ្ឋី ក៏ឲ្យពិនិត្យមើលថា ក្មេងនោះស្លាប់ ឬមិនស្លាប់ត្រង់ផ្លូវរទេះ ជ្រាបថា នាយកងរទេះបានយកទៅ ក៏ឲ្យទ្រព្យ ១.០០០ ដល់នាយកងរទេះនោះ បន្ទាប់ឲ្យបោះទៅក្នុងជ្រោះក្នុងទីមិនឆ្ងាយព្រះនគរ ទារកនោះ កាលធ្លាក់ទៅក្នុងជ្រោះនោះ ក៏ធ្លាក់ចុះត្រង់រោងជាងតម្បាញក្នុងទីធ្វើការងាររបស់ពួកជាងតម្បាញ ដែលប្រៀបដូចបានទទួលសម្ផស្សដោយសំឡី ១០០ ជាន់ ព្រោះអានុភាពបុណ្យរបស់

ទារកនោះ ។ គ្រានោះ មេជាងតម្បាញដឹងថា ទារកនេះមានបុណ្យ គួរចិញ្ចឹមទុក ទើបនាំទារកនោះទៅផ្ទះ ។

សេដ្ឋីឲ្យស្វែងរកក្នុងទីដែលទារកធ្លាក់ជ្រោះ នោះថា ស្លាប់ ឬមិនស្លាប់ ជ្រាបថា មេជាងតម្បាញនាំយកទៅ ក៏ឲ្យទ្រព្យ ១.០០០ ដល់មេជាងតម្បាញនោះ ឲ្យនាំទារកមក ។ តមក ទាំងបុត្ររបស់សេដ្ឋី ទាំងទារកនោះ ទាំងពីរនាក់ ក៏បាន ចម្រើនវ័យ ។

សេដ្ឋីក៏គិតរកឧបាយដែលនឹងឲ្យឃោសកកុមារស្លាប់ ទើបទៅផ្ទះជាងឆ្នាំង របស់ខ្លួន និយាយជាសេចក្តីកំបាំងថា សំឡាញ់ ផ្ទះខ្ញុំមានក្មេងត្រកូលថោកទាប ម្នាក់ គួរធ្វើយ៉ាងណាឲ្យក្មេងនោះស្លាប់ ជាងឆ្នាំងនោះក៏បិទត្រចៀកទាំងពីរ ពោល ថា មិនគួរនិយាយពាក្យដែលធ្ងន់បែបនេះ តពីនោះ សេដ្ឋីគិតថា ជាងឆ្នាំងនេះមិន ធ្វើព្រោះមិនបានអ្វី ទើបពោលថា ណ្ហើយចុះ សំឡាញ់ ចូរយកទ្រព្យ ១.០០០ ហើយធ្វើការងារនេះឲ្យសម្រេច ដែលឈ្មោះថា សំណូក រមែងទម្លាយវត្ថុដែល ទម្លាយមិនបានងាយ ព្រោះហេតុនោះ ជាងឆ្នាំងនោះបានទ្រព្យ ១.០០០ ហើយ ក៏ទទួល ហើយពោលថា លោកម្ចាស់ ខ្ញុំនឹងដុតភ្លើងចង្ក្រានដុតឆ្នាំងក្នុងថ្ងៃឯណោះ សូមលោកម្ចាស់ ចូរបញ្ជូនទារកនោះទៅក្នុងថ្ងៃឯណោះ វេលាឯណោះ ។ ចំណែក សេដ្ឋីទទួលពាក្យរបស់ជាងឆ្នាំងនោះហើយ រាប់ថ្ងៃតាំងពីថ្ងៃនោះ ដឹងថា ថ្ងៃដែល

ជាងធ្មាំងកំណត់ទុកមកដល់ហើយ ក៏ឲ្យហៅឃោសកកុមារមក ប្រាប់ថា កូនអើយ ពុកត្រូវការភាជនៈចំនួនច្រើន ក្នុងថ្ងៃឯណោះ ឯងចូរទៅរកជាងធ្មាំង ប្រាប់ថា បាន ឮថា មានការងារដែលបិតាយើងនិយាយទុកដល់លោក ថ្ងៃនេះ សូមលោកចូរធ្វើ ការងារនោះឲ្យសម្រេច ឃោសកកុមារទទួលពាក្យរបស់សេដ្ឋីនោះថា បាទលោក ពុក ហើយក៏ចេញទៅ ។ ខណៈនោះ ក្នុងរវាងផ្លូវ កូនរបស់សេដ្ឋីកំពុងលេង ល្បែងឈូស ទើបប្រញាប់ទៅនិយាយថា បង ខ្ញុំកំពុងលេងជាមួយពួកក្មេងៗ ត្រូវ គេយកឈ្នះប៉ុណ្ណេះ បងចូរយកឈ្នះគេឲ្យខ្ញុំ ។ ឃោសកកុមារ ពោលថា ឥឡូវ នេះ ឱកាសរបស់បងមិនមាន លោកពុកប្រើបងទៅរកជាងធ្មាំងដោយកិច្ចប្រញាប់ ។ កូនសេដ្ឋីនិយាយថា បង ខ្ញុំទៅជំនួស បងចូរលេងជាមួយក្មេងទាំងនេះ នាំជោគត្រឡប់ មកឲ្យខ្ញុំ ឃោសកកុមារពោលថា បើដូច្នោះ ប្អូនទៅចុះ ហើយប្រាប់ដំណឹងដែល បិតាប្រាប់ដល់ខ្លួនដល់ប្អូនប្រុសនោះ ហើយក៏លេងជាមួយពួកក្មេងៗ ឯប្អូនប្រុស ទៅរកជាងធ្មាំងហើយប្រាប់ដំណឹងនោះ ។ ជាងធ្មាំងពោលថា ប្រពៃហើយ យើង នឹងធ្វើការងារឲ្យសម្រេច ហើយឲ្យក្មេងនោះចូលទៅក្នុងបន្ទប់ យកកាំបិតដ៏មុត កាត់ជាចំណែកតូចៗ ដាក់ក្នុងធ្មាំង បិទមាត់ធ្មាំងជិតទុកចន្លោះភាជនៈ ហើយដុត ចង្ក្រានដុតធ្មាំង ឃោសកកុមារលេងឈ្នះជាច្រើន ក៏អង្គុយចាំប្អូនមក គេដឹងថា ប្អូនយឺតយូរ ក៏ទៅកាន់ទីមួយនៃផ្ទះជាងធ្មាំង ក្នុងទីណាៗ ក៏មិនជួប គិតថា ប្អូននឹង

ត្រឡប់ទៅផ្ទះហើយ ទើបត្រឡប់ទៅផ្ទះ ។ សេដ្ឋីឃើញគេដើរមកពីចម្ងាយ ក៏សង្ស័យថា នឹងមានហេតុអ្វីឬហ្ន៎ យើងបង្គាប់វាទៅរកជាងធ្នាំង ដើម្បីឲ្យសម្លាប់វាឲ្យស្លាប់ ឥឡូវនេះ ក្មេងនោះ នៅមកក្នុងទីនេះទៀត ។ គេមកដល់ ទើបសួរថា ឯងមិនទៅរកជាងធ្នាំងទេឬកូន ឃោសកៈ ទើបប្រាប់ហេតុដែលខ្លួនត្រឡប់ និងហេតុដែលប្អូនប្រុសទៅ សេដ្ឋីស្តាប់ពាក្យគេហើយ ហាក់ដូចជា ត្រូវផែនដីធំបាក់សង្កត់ ១០០ ដង ចិត្តក៏ត្រឡប់ ហើយសួរថា ឯងនិយាយអ្វីយ៉ាងនេះ ហើយក៏ប្រញាប់ទៅរកជាងធ្នាំង និយាយដោយពាក្យដែលមិនគួរនិយាយ ក្នុងសំណាក់អ្នកដទៃថា មើលចុះៗ ជាងធ្នាំងពោលថា លោកឲ្យមើលអ្វី ការងារនោះសម្រេចហើយ តពីនោះ លោកសេដ្ឋីក៏ត្រឡប់ទៅផ្ទះ ។

តាំងពីនោះមក រោគផ្លូវចិត្តក៏កើតដល់លោកសេដ្ឋី សម័យនោះ សេដ្ឋីនោះបរិភោគមិនបានដោយរោគផ្លូវចិត្តនោះ គិតថា គួរនឹងឃើញសេចក្តីវិនាសរបស់សត្រូវនៃបុត្រយើងដោយឧបាយណាមួយ ទើបសរសេរសំបុត្រមួយច្បាប់ហៅនាយឃោសកៈមកប្រាប់ដោយមាត់ថា ឯងចូរកាន់សំបុត្រនេះទៅរកអ្នកធ្វើការរបស់ពុកដែលនៅស្រុកឈ្មោះឯណោះ ចូរប្រាប់ថា លោកចូរប្រញាប់ធ្វើរឿងដែលមាននៅក្នុងសំបុត្រ ក្នុងរវាងផ្លូវ ចូរទៅកាន់ផ្ទះសេដ្ឋីម្នាក់ ឈ្មោះគាមិកសេដ្ឋី ជាសម្លាញ់របស់ពុក បរិភោគអាហារហើយប្រញាប់ទៅ ហើយបានប្រគល់សំបុត្រ

ឲ្យទៅ ឃោសកៈថ្វាយបង្គំសេដ្ឋីហើយ ទទួលសំបុត្រចេញទៅ ក្នុងរវាងផ្លូវ ទៅដល់ទីនៅរបស់គាមិកសេដ្ឋីហើយ សួរដល់ផ្ទះរបស់សេដ្ឋី ឃើញគាមិកសេដ្ឋីនោះ ដែលអង្គុយនៅក្រៅទ្វារ កំពុងឲ្យជាងតុបតែងពុកមាត់ បានសួរថា បាអើយ ឯងមកពីណា ទើបឆ្លើយថា លោកអើ ខ្ញុំជាបុត្រកោសម្ពិកសេដ្ឋី ។ គាមិកសេដ្ឋីនោះ ក៏ត្រេកអរថា បុត្រសេដ្ឋីសម្លាញ់យើង ។ ខណៈនោះ ទាសីម្នាក់របស់ធីតាសេដ្ឋី នាំផ្កាឈើមកឲ្យធីតាសេដ្ឋី ។ លំដាប់នោះ សេដ្ឋីទើបពោលនឹងទាសីនោះថា ការងារនោះទុកសិនចុះ ចូរលាងជើងឲ្យឃោសកៈ និងរៀបចំទីដេកឲ្យផង ។ ទាសីនោះក៏ធ្វើតាមពាក្យបង្គាប់ ហើយទៅផ្សារ នាំផ្កាឈើមកឲ្យធីតាសេដ្ឋី ។ ធីតាសេដ្ឋីឃើញទាសីនោះហើយក៏បន្ទោសនាងថា ថ្ងៃនេះ ហេតុអ្វីនាងបង្អែបង្អង់នៅខាងក្រៅយូរម្ល៉េះ ហើយពោលទាំងក្រោធទៀតថា នាងរវល់ធ្វើអ្វីក្នុងទីនោះ រហូតវេលាប៉ុណ្ណេះ ទាសីពោលថា នាងម្ចាស់កុំពោលដូច្នោះ ខ្ញុំមិនធ្លាប់បានឃើញកូនកំលោះរូបស្អាតបែបនេះឡើយ គេជាប្រុសកំលោះម្នាក់ ជាបុត្រសេដ្ឋីសម្លាញ់បិតារបស់នាងម្ចាស់ ខ្ញុំមិនអាចពោលដល់រូបសម្បត្តិរបស់គេបាន ខ្ញុំកំពុងតែទៅនាំផ្កាឈើមក លោកសេដ្ឋីក៏ប្រើឲ្យខ្ញុំលាងជើងប្រុសកំលោះនោះ ឲ្យរៀបចំទីដេកឲ្យ ដោយហេតុនោះ ខ្ញុំទើបនៅខាងក្រៅយូរយ៉ាងនេះ ។ ធីតាសេដ្ឋីនោះ ធ្លាប់បានជាករិយារបស់ប្រុសកំលោះនោះក្នុងអត្តភាពទី ៤ ព្រោះហេតុនោះ តាំងពីបានស្តាប់

ពាក្យរបស់ទាសីនោះ ក៏ក្មេចស្មារតីមិនដឹងខ្លួនថាឈរ ឬអង្គុយ នាងក៏នាំទាសីនោះ ទៅកាន់ទីនាយឃោសកៈនោះដេក សម្លឹងមើលគេកំពុងដេកលក់ ឃើញសំបុត្រ ត្រង់ជាយសំពត់ សង្ស័យថា នោះជាសំបុត្រអ្វី មិនដាស់គេឲ្យភ្ញាក់ ចាប់សំបុត្រ យកមកអាន ក៏ដឹងថា បុរសនេះកាន់សំបុត្រដើម្បីសម្លាប់ខ្លួនឯង ទើបហែកសំបុត្រ នោះ ៗ កាលឃោសកៈមិនទាន់ភ្ញាក់ ក៏សរសេរសំបុត្រជាថ្មីថា លោកចូរបញ្ជូន ដំណឹងរបស់យើងទៅថា យើងបញ្ជូនបុត្រទៅកាន់សំណាក់គាមិកសេដ្ឋីសម្លាញ់ យើងមានធីតាចម្រើនវ័យហើយ លោកចូរប្រញាប់ប្រមូលទ្រព្យ ដែលកើតក្នុង អាណាបរិវេណរបស់យើង កាន់យកធីតារបស់គាមិកសេដ្ឋី ធ្វើពិធីមង្គលដល់បុត្រ របស់យើង ដោយទ្រព្យគ្រប់យ៉ាងមួយមុខៗ ១០០ កាលពិធីមង្គលស្រេចហើយ លោកចូរបញ្ជូនដំណឹងឲ្យយើងជ្រាបថា ធ្វើមង្គលហើយដោយវិធីនេះ យើងនឹង ដឹងកិច្ចដែលគប្បីធ្វើដល់លោកក្នុងទីនេះ ប្រថាប់ត្រាសំបុត្រនោះហើយ ក៏ចងទុក ត្រង់ជាយសំពត់ដូចដើម ឃោសកៈនោះ នៅក្នុងផ្ទះគាមិកសេដ្ឋីនោះអស់មួយថ្ងៃ ស្អែកឡើង ក៏លាសេដ្ឋីទៅកាន់ស្រុករបស់អ្នកធ្វើការងារ ប្រគល់សំបុត្រនោះឲ្យ អ្នកធ្វើការងារអានសំបុត្រហើយ ក៏ឲ្យប្រជុំអ្នកស្រុក ពោលថា លោកទាំងឡាយ កុំកន្លល់ឡើយ លោកម្ចាស់របស់យើងបញ្ជូនដំណឹងមកកាន់សំណាក់យើងថា ចូរ នាំក្មេងស្រីមកដោយទ្រព្យគ្រប់យ៉ាងមួយមុខៗ ១០០ ដល់បុត្រអ្នកចម្បងរបស់ខ្លួន

ពួកលោកចូរប្រញាប់ប្រមែប្រមូលទ្រព្យដែលកើតក្នុងទីនេះមក ហើយក៏ចាត់ការពិធីមង្គលដោយគ្រឿងសក្ការៈគ្រប់យ៉ាង បញ្ជូនដំណឹងដល់គាមិកសេដ្ឋី ឲ្យទទួលហើយ ឲ្យសម្រេចក្នុងការងារមង្គលដោយទ្រព្យគ្រប់យ៉ាងមួយមុខៗ ១០០ ហើយបញ្ជូនសំបុត្រដល់កោសម្ពិកសេដ្ឋីថា[១] ខ្ញុំដឹងដំណឹងក្នុងសំបុត្រដែលលោកបញ្ជូនមកហើយ ក៏ធ្វើកិច្ចយ៉ាងនេះៗ ស្រេចហើយ ។

សេដ្ឋីស្តាប់ដំណឹងនោះហើយ ដូចត្រូវដុតក្នុងគំនរភ្លើងដូច្នោះ ឈឺចិត្តធ្លាក់លោហិតព្រោះអំណាចដែលគិតថា ឥឡូវនេះយើងគ្មានសង្ឃឹមទេ ដូច្នេះ ក៏ឲ្យមនុស្សហៅឃោសកៈមក ដោយគិតឃើញឧបាយមួយ បំណងថា នឹងធ្វើមិនឲ្យឃោសកៈជាម្ចាស់ទ្រព្យសម្បត្តិរបស់ខ្លួន តាំងពីពិធីមង្គលសម្រេចហើយ ក៏បញ្ជូនដំណឹងទៅថា ហេតុអ្វីបុត្ររបស់យើងទើបនៅខាងក្រៅ ចូរប្រញាប់ត្រឡប់មកចុះ កាលឃោសកៈទទួលដំណឹងហើយ ក៏គិតនឹងទៅ ។ ធីតាសេដ្ឋីគិតថា ស្វាមីនេះល្ងង់ខ្លៅមិនដឹងទេថា សម្បត្តិនេះអាស្រ័យយើងទើបបានមក គួរយើងនឹងធ្វើអ្វីខ្លះ ហើយក៏ធ្វើឧបាយហាមក្នុងការទៅរបស់គេ តពីនោះ ទើបពោលនឹងស្វាមីថា លោកប្តីកុំប្រញាប់ប្រញាល់ពេក ខ្ញុំក៏នឹងទៅស្រុករបស់លោកប្តីដែរ ធម្មតាថា អ្នកទៅ គួរនឹងត្រៀមកិច្ចការរបស់ខ្លួនហើយទើបទៅ ចំណែកកោសម្ពិកសេដ្ឋីដឹងថា បុត្រនោះ

១ ជាមនុស្សម្នាក់ មានឈ្មោះដូចគ្នានឹងកោសម្ពិកសេដ្ឋីដែរ ។

យឺតយូរ ក៏បញ្ជូនដំណឹងទៅទៀតថា ហេតុអ្វីបុត្រយើងទើបនៅយូរម្ល៉េះ យើងមានរោគធ្លាក់លោហិត គប្បីអ្នកមកជួបយើងខណៈដែលនៅរស់ ។ វេលានោះ ធីតា-សេដ្ឋីក៏ប្រាប់ដល់ស្វាមីនោះថា សេដ្ឋីនោះមិនមែនបិតារបស់លោកប្តីទេ លោកប្តីនៅយល់ថាជាបិតា សេដ្ឋីនោះបញ្ជូនសំបុត្រដល់អ្នកបម្រើដើម្បីឲ្យគេសម្លាប់លោកប្តី ខ្ញុំទើបប្តូរសំបុត្រនោះ សរសេរសេចក្តីជាថ្មី ធ្វើសម្បត្តិនេះឲ្យកើតដល់លោកប្តី សេដ្ឋីនោះហៅលោកប្តីទៅ បំណងនឹងធ្វើលោកប្តីមិនឲ្យជាបុត្រប៉ុណ្ណោះ លោកប្តីចូររង់ចាំការស្លាប់របស់សេដ្ឋីនោះសិន ។

គ្រានោះ ឃោសកៈមិនទៅក្នុងកាលដែលសេដ្ឋីនោះនៅរស់ តែកាលបានដឹងថាលោកសេដ្ឋីឈឺធ្ងន់ហើយ ទើបទៅនគរកោសម្ពី សូម្បីធីតាសេដ្ឋីក៏ចាំឲ្យសញ្ញានៅខាងក្រៅដល់ស្វាមីនោះថា លោកប្តីកាលបើចូលទៅ ក៏ចាត់ចែងរក្សាទុកសព្វគ្រប់កិច្ចការផ្ទះ ទើបចូលទៅ ខ្លួនឯងក៏ទៅព្រមជាមួយឃោសកៈ លើកដៃទាំងពីរឡើង ធ្វើជាស្រែកយំទៅជិតសេដ្ឋី ដែលដេកនៅក្នុងទីស្មើរងនឹត យកក្បាលបោកត្រង់ទ្រូង សេដ្ឋីនោះក៏ធ្វើកាលៈដោយការបោកនោះឯង ព្រោះគេអស់កម្លាំង ។ ឃោសកកុមារក៏ធ្វើសរីរកិច្ចរបស់បិតា ឲ្យប្រាក់ដល់អ្នកជិតខាងថា ពួកលោកចូរប្រាប់ថា ខ្ញុំជាបុត្រតែមួយរបស់សេដ្ឋី បន្ទាប់ពីនោះ ថ្ងៃទី ៧ ព្រះរាជាទ្រង់ត្រិះរិះថា គួរនឹងបាននរណាម្នាក់ ដែលគួរដល់តំណែងសេដ្ឋី ទើបទ្រង់បញ្ជូនរាជបុរស

ទៅត្រួតពិនិត្យថា សេដ្ឋីមានបុត្រ ឬមិនមានបុត្រ ។ ពួកអ្នកជិតខាងសេដ្ឋី ក៏ក្រាបទូលដល់ព្រះរាជថា សេដ្ឋីមានបុត្រ ព្រះរាជាទ្រង់ទទួលហើយ ក៏បានព្រះរាជទានតំណែងសេដ្ឋីដល់គេ គេក៏ឈ្មោះថា **ឃោសកសេដ្ឋី** ។ គ្រានោះ ភរិយាក៏ពោលនឹងស្វាមីថា លោកប្តី លោកកើតមកក៏ទន់ទាប ខ្ញុំក៏កើតក្នុងត្រកូលក្រលំបាក យើងបានសម្បត្តិបែបនេះ ក៏ដោយអំណាចកុសលដែលយើងធ្វើជាមួយគ្នាក្នុងកាលមុន សូម្បីឥឡូវនេះ យើងក៏នឹងធ្វើកុសល ។ ស្វាមីក៏យល់ព្រមថា ប្រពៃណាស់ប្អូនស្រី ក៏លះបង់ទ្រព្យ ១.០០០ កហាបណៈ រាល់ថ្ងៃ តាំងទានទុកជាប្រចាំ ។

ក្នុងសម័យនោះ បណ្តាជនទាំងពីរនោះ **នាងខុជ្ជុត្តរា** ចុតិចាកទេវលោក បានបដិសន្ធិក្នុងគភ៌របស់មេដោះ ក្នុងផ្ទះរបស់ឃោសកសេដ្ឋី វេលាដែលកើត នាងមានខ្នងគម ព្រោះដូច្នោះ អ្នកទាំងឡាយទើបតាំងឈ្មោះថា **ខុជ្ជុត្តរា** ។

ចំណែកនាងសាមាវតី ចុតិចាកពីទេវលោកហើយ បដិសន្ធិក្នុងផ្ទះរបស់ភទ្ទវតិយសេដ្ឋី ដែនភទ្ទវតិយៈ ។ តមក នគរនោះកើតឆាតកភ័យ មនុស្សទាំងឡាយភ័យខ្លាចការអត់ឃ្លាន ទើបបំបែកគ្នាទៅកាន់ទីដទៃៗ ។ គ្រានោះ ភទ្ទវតិយ-សេដ្ឋី ប្រឹក្សាជាមួយភរិយាថា ប្អូនអើយ ឆាតកភ័យនេះមិនទាន់ប្រាកដដល់យើងនៅឡើយ យើងនឹងទៅរកឃោសកសេដ្ឋីសម្លាញ់យើងក្នុងក្រុងកោសម្ពី សម្លាញ់នោះជួបយើងគង់នឹងមិនស្គាល់ ន័យថា សេដ្ឋីនោះ បានជាសម្លាញ់ដែលមិនធ្លាប់

ឃើញគ្នាជាមួយឃោសកសេដ្ឋីនោះ ព្រោះហេតុនោះ ទើបពោលយ៉ាងនេះ ។ កុទុវតិយសេដ្ឋីនោះ ឲ្យមនុស្សដ៏សេសត្រឡប់ទៅវិញ ក៏នាំភរិយា និងធីតា ធ្វើដំណើរទៅក្រុងកោសម្ពី អ្នកទាំងបីប្រសព្វទុក្ខដ៏ច្រើនក្នុងរវាងផ្លូវ ក៏ទៅដល់ក្រុងកោសម្ពីតាមលំដាប់ ស្នាក់អាស្រ័យនៅក្នុងសាលាមួយខ្នង ។ ចំណែកឃោសកសេដ្ឋី ឲ្យគេចាត់មហាទានដល់ពួកមនុស្សកំព្រា អ្នកដើរផ្លូវឆ្ងាយ ស្មូម និងយាចក ជិតទ្វារផ្ទះរបស់ខ្លួន ។ គ្រានោះ កុទុវតិយសេដ្ឋីនេះ ក៏គិតថា យើងមិនអាចសម្តែងខ្លួនដល់សេដ្ឋីសម្លាញ់ ដោយភេទរបស់មនុស្សកំព្រានេះបានឡើយ កាលយើងស្លៀកដណ្តប់ល្អជាប្រក្រតីហើយ ទើបនឹងទៅជួបសេដ្ឋី សូម្បីទាំងពីរនាក់ ក៏បញ្ជូនធីតាទៅរោងទានរបស់ឃោសកសេដ្ឋី ដើម្បីនាំអាហារមកឲ្យខ្លួន ធីតានោះក៏កាន់ភាជន៍ទៅរោងទាន ឈរខ្មាសនៅត្រង់កន្លែងមួយ អ្នកចាត់ចែងទានឃើញនាង ក៏គិតថា បុគ្គលដទៃៗ ធ្វើសំឡេងដូចជាអ្នកនេសាទដែលដណ្តើមគ្នាទិញ និងលក់ត្រីក្នុងទីប្រជុំជន បានហើយក៏ទៅ ចំណែកក្មេងស្រីនេះ នឹងជាកុលធីតា ព្រោះដូច្នោះ ឧបធិសម្បទារបស់នាងទើបមាន ទើបសួរនាងថា នាងតូច ហេតុអ្វី នាងទើបមិនទទួលដូចអ្នកដទៃៗ ។ នាងឆ្លើយថា លោកអ៊ំ ខ្ញុំនឹងធ្វើការច្រៀតច្រៀតគ្នាដូច្នេះ បានដូចម្តេច ។ គេសួរថា នាងតូច ពួកនាងមានប៉ុន្មាននាក់ ។ នាងឆ្លើយថា ៣ នាក់ លោកអ៊ំ ។ គេក៏ឲ្យបាយ ៣ ដុំ នាងក៏ជូនបាយនោះដល់មាតាបិតា បិតាឃ្លាន

មកយូរពេក បរិភោគហួសប្រមាណក៏ស្លាប់ទៅ ។ ស្អែកឡើង នាងក៏ទៅទទួលបាយមក ២ ដុំប៉ុណ្ណោះ ថ្ងៃនោះភរិយាសេដ្ឋីក៏ស្លាប់ទៀត ក្នុងវេលាកន្លងអធ្រាត្រ ព្រោះលំបាកដោយអាហារ និងព្រោះសោកសៅដល់សេដ្ឋីដែលស្លាប់ ។ ថ្ងៃស្អែកឡើង ធីតាសេដ្ឋីទទួលដុំបាយតែមួយដុំប៉ុណ្ណោះ អ្នកចាត់ចែងទាន ពិចារណាមើលកិរិយារបស់នាង ទើបសួរថា នាង ថ្ងៃដំបូងនាងទទួលដុំបាយ ៣ ដុំ ស្អែកទទួល ២ ដុំ ថ្ងៃនេះទទួលដុំបាយតែមួយដុំប៉ុណ្ណោះ តើមានហេតុអ្វីកើតឡើងឬ នាងទើបប្រាប់ដល់ហេតុការណ៍នោះ គេសួរថា នាង នាងជាអ្នកស្រុកណា នាងក៏ប្រាប់ហេតុ-ការណ៍សព្វគ្រប់ ។ គេពោលថា នាង បើដូច្នោះ នាងក៏ជាធីតាសេដ្ឋីរបស់យើង យើងមិនមានក្មេងស្រីដទៃៗ ទេ នាងចូរជាធីតាយើងតាំងពីឥឡូវនេះចុះ ហើយក៏ទទួលនាងទុកជាធីតា ។

នាងបានឮសំឡេងអឺងកងក្នុងរោងទាន ក៏សួរថា លោកអុំ ហេតុអ្វីទើបមានសំឡេងខ្លាំងៗ ដូច្នេះ ។ គេក៏ឆ្លើយថា នាង ក្នុងរវាងមនុស្សដ៏ច្រើន មិនអាចធ្វើឲ្យមានសម្លេងតិចបានទេ ។ នាងពោលថា លោកអុំ ខ្ញុំដឹងឧបាយក្នុងរឿងនេះ ។ គេសួរថា គួរធ្វើដូចម្ដេចនាង ។ នាងប្រាប់ថា លោកអុំ លោកអុំចូរធ្វើរបងព័ទ្ធជុំវិញ ទុកទ្វារ ២ ឲ្យតាំងភាជនៈ (ចែកទាន) ទុកខាងក្នុង ឲ្យអ្នកចូលទៅទ្វារមួយទទួលអាហារហើយឲ្យចេញទៅក្នុងទ្វារមួយ ។ គេយល់ព្រមថា ប្រពៃណាស់នាង

ហើយក៏ឲ្យធ្វើយ៉ាងនោះ ។ តាំងពីថ្ងៃនោះមក រោងទានក៏មានសំឡេងស្ងៀមស្ងាត់ ។ ឃោសកសេដ្ឋីធ្លាប់បានឮសំឡេងអឺងកងក្នុងរោងទានមកពីមុន ។ គ្រានោះ កាលមិនបានឮសំឡេងនោះ ទើបហៅអ្នកចាត់ចែងទានមកសួរថា ថ្ងៃនេះលោកចាត់ចែងគេឲ្យទានហើយឬ គេឆ្លើយថា ឲ្យទានហើយ លោកម្ចាស់ ។ សេដ្ឋីសួរថា បើដូច្នោះហេតុអ្វី ទើបមិនបានឮសំឡេងក្នុងរោងទានដូចពីមុន ។ គេឆ្លើយថា ពិតហើយលោកម្ចាស់ ខ្ញុំមានធីតាម្នាក់ ខ្ញុំធ្វើតាមឧបាយដែលនាងប្រាប់ ទើបធ្វើរោងទានមិនឲ្យមានសំឡេង ។ សេដ្ឋីសួរថា អ្នកមិនដែលមានធីតាទេ អ្នកបានធីតាមកពីណា ។ អ្នកចាត់ការទាននោះ ក៏ប្រាប់រឿងដែលបានធីតាមក គ្រប់យ៉ាងដល់សេដ្ឋី ព្រោះមិនអាចនឹងលាក់បាំងបាន ។ សេដ្ឋីពោលថា សំឡាញ់ ហេតុអ្វីអ្នកទើបបានធ្វើកម្មធ្ងន់យ៉ាងនេះ មិនប្រាប់រឿងធីតាដែលនៅក្នុងសំណាក់ខ្លួនដល់យើង ធ្វើឲ្យវេលាយូរត្រឹមនេះ អ្នកចូរប្រញាប់នាំនាងទៅផ្ទះយើង ។ អ្នកចាត់ការទាននោះ ស្តាប់ពាក្យសេដ្ឋីហើយ ក៏ឲ្យនាំនាងទៅទាំងដែលខ្លួនមិនចង់ ដូច្នោះ ។ តាំងពីនោះមកលោកសេដ្ឋីក៏តាំងនាងទុកក្នុងតំណែងធីតា គិតថា នឹងទុកដូចជាធីតា ទើបចាត់ស្រីក្រមុំ ៥០០ នាក់ ដែលមានវ័យជំទង់ដូចគ្នា ពីត្រកូលដែលមានជាតិស្មើនឹងខ្លួនមកជាបរិវាររបស់នាង ។

តមកថ្ងៃមួយ ព្រះបាទឧទេនស្តេចយាងត្រួតពិនិត្យព្រះនគរ ទ្រង់ទតឃើញ

នាងសាមាវតីនោះ មានស្រីក្រមុំទាំងនោះហែហមកំពុងលេង ត្រាស់សួរថា ក្មេងស្រីនេះរបស់អ្នកណា ទ្រង់ជ្រាបថា ធីតារបស់ឃោសកសេដ្ឋី ត្រាស់សួរថា មិនទាន់មានស្វាមីទេឬ កាលគេទូលថា មិនទាន់មានស្វាមីទេ ទើបត្រាស់បង្គាប់ថា ពួកអ្នកចូរទៅប្រាប់សេដ្ឋីថា ព្រះរាជាមានព្រះរាជបំណងធីតារបស់លោក ។ សេដ្ឋីស្តាប់ហើយ ប្រាប់គេថា យើងមិនមានក្មេងស្រីដទៃៗ មិនអាចឲ្យធីតាតែម្នាក់មានស្វាមីបានទេ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ ត្រាស់បង្គាប់ឲ្យសេដ្ឋី និងភរិយាឲ្យនៅក្រៅផ្ទះ ឲ្យបិទទ្វារប្រថាប់ត្រាគ្រប់ខ្នងផ្ទះ ។ នាងសាមាវតី ចេញទៅលេងក្រៅស្រុក លុះត្រឡប់មកឃើញបិតាមាតាអង្គុយនៅក្រៅផ្ទះ ទើបសួរថា ពុកម៉ែហេតុអ្វីទើបមកអង្គុយទីនេះ ។ សេដ្ឋី និងភរិយាក៏ប្រាប់ហេតុការណ៍នោះ ។ នាងទើបពោលថា ពុកម៉ែ កុំទូលតបព្រះរាជាយ៉ាងនេះ ឥឡូវនេះ ចូរឲ្យទូលយ៉ាងនេះថា ធីតារបស់យើងមិនអាចនៅតែម្នាក់ឯងជាមួយស្វាមីបាន បើព្រះអង្គទ្រង់ឲ្យស្រីក្រមុំ ៥០០ នាក់ បរិវាររបស់នាងនៅផង នាងទើបនឹងនៅបាន ។ សេដ្ឋីពោលថា ល្អណាស់កូន ពុកមិនដឹងចិត្តរបស់កូន សេដ្ឋី និងភរិយាទើបក្រាបទូលយ៉ាងនោះ ព្រះរាជាទ្រង់ជ្រះថ្លា ត្រាស់ថា ១.០០០ នាក់ ក៏ដោយចុះ ចូរនាំមកទាំងអស់ ។ គ្រានោះ សេដ្ឋី និងភរិយាទើបនាំធីតានោះ មានស្រី ៥០០ នាក់ ជាបរិវារទៅកាន់ព្រះរាជនិវេសន៍ ដោយមង្គលនក្ខត្តឫក្សដ៏ចម្រើន ព្រះរាជាក៏ទ្រង់ធ្វើស្រី ៥០០

នាក់ ជាបរិវាររបស់នាង ហើយទ្រង់ធ្វើអភិសេកឲ្យនាងនៅក្នុងប្រាសាទមួយខ្នង ។

ក៏សម័យនោះ ក្នុងក្រុងកោសម្ពី មានសេដ្ឋី ៣ នាក់ គឺ ឃោសកសេដ្ឋី កុក្កុដសេដ្ឋី និងបាវារិកសេដ្ឋី ជាសម្លាញ់នឹងគ្នា ។ សេដ្ឋីទាំង ៣ នាក់ ក៏បានទំនុកបម្រុងតាបស ៥០០ រូប សូម្បីពួកតាបសក៏នៅក្នុងសំណាក់សេដ្ឋីទាំង ៣ នាក់នោះ ៤ ខែ នៅព្រៃហិមវន្ត ៨ ខែ ។ តមកថ្ងៃមួយ តាបសទាំងនោះ មកពីព្រៃហិមវន្ត ស្រេកឃ្លានជាខ្លាំងព្រោះលំបាកក្នុងផ្លូវកន្តារ ទើបនាំគ្នាទៅកាន់ដើមជ្រៃធំមួយដើម បំណងនឹងទទួលការសង្គ្រោះពីសំណាក់ទេវតាដែលស្ថិតនៅត្រង់ដើមជ្រៃធំនោះ ហើយក៏អង្គុយចុះទៅ ។ ទេវតាក៏បង្អោនដៃដែលប្រដាប់ដោយគ្រឿងប្រដាប់គ្រប់យ៉ាង បង្ហូរថ្វាយទឹកបានៈដែលគួរដល់ការផឹកជាដើម ដល់តាបសទាំងនោះ ដើម្បីបន្ទោបង់សេចក្តីនឿយហត់ ។ តាបសទាំងនោះចម្លែកចិត្ត ព្រោះអានុភាពរបស់ទេវតា ទើបសួរថា ទេវតា លោកធ្វើកម្មអ្វី ទើបបានសម្បត្តិនេះ ។ ទេវតាប្រាប់ថា ព្រះមានព្រះភាគព្រះនាមថា ពុទ្ធ ទ្រង់ឧប្បត្តិហើយក្នុងលោក ឥឡូវនេះព្រះអង្គប្រថាប់នៅក្រុងសាវត្ថី គហបតីឈ្មោះអនាថបិណ្ឌិកៈ ជាឧបដ្ឋាកព្រះអង្គថ្ងៃឧបោសថ អនាថបិណ្ឌិកសេដ្ឋីនោះ ឲ្យតម្លៃអាហារប្រចាំថ្ងៃដល់អ្នកបម្រើរបស់ខ្លួន ហើយឲ្យគេរក្សាឧបោសថ យើងចូលទៅដើម្បីត្រូវការអាហារព្រឹក ក្នុងវេលាថ្ងៃក្នុងថ្ងៃមួយ មិនឃើញអ្នកបម្រើណាៗ ធ្វើការងារឡើយ ទើបសួរថា ហេតុអ្វី

ថ្ងៃនេះអ្នកបម្រើទាំងឡាយមិនធ្វើការងារ អ្នកទាំងនោះទើបប្រាប់រឿងនោះដល់ខ្ញុំ ពេលនោះ ខ្ញុំពោលថា ឥឡូវនេះក៏វេលាកន្លងទៅកន្លះថ្ងៃហើយ ខ្ញុំអាចរក្សាឧបោសថកន្លះថ្ងៃបានឬទេ ។ ពេលនោះ អ្នកទាំងនោះក៏ប្រាប់ដល់សេដ្ឋី ហើយសេដ្ឋីពោលថា រក្សាកន្លះថ្ងៃក៏បាន ខ្ញុំស្តាប់ពាក្យនោះហើយ ក៏សមាទានឧបោសថកន្លះថ្ងៃ ធ្វើកាលៈក្នុងថ្ងៃនោះឯង ហើយក៏បានសម្បត្តិនេះ ។ គ្រានោះ ពួកតាបសទាំងនោះកើតបីតិបាមោជ្ជៈថា គេថា ព្រះពុទ្ធទ្រង់ឧប្បត្តិហើយក្នុងលោក សូម្បីបំណងនឹងទៅពីទីនោះកាន់ក្រុងសាវត្ថី ក៏គិតថា ពួកសេដ្ឋីអ្នកឧបដ្ឋាកយើងមានឧបការៈច្រើន ចាំយើងប្រាប់រឿងនោះដល់សេដ្ឋីទាំងនោះ ទើបនាំគ្នាទៅក្រុងកោសម្ពី ពួកសេដ្ឋីធ្វើសក្ការៈបូជាជាច្រើន ទើបប្រាប់ថា ពួកយើងនឹងទៅក្នុងថ្ងៃនេះឯង ។ ពួកសេដ្ឋីតបថា លោកម្ចាស់ ពួកលោកប្រញាប់ណាស់ឬ កាលមុនលោកម្ចាស់នៅ ៤-៥ ខែ ទើបទៅ ទើបប្រាប់រឿងនោះ ។ កាលពួកសេដ្ឋីប្រាប់ថា លោកម្ចាស់ បើដូច្នោះពួកខ្ញុំក៏នឹងទៅជាមួយដែរ ក៏ប្រាប់ថា ពួកយើងនឹងទៅ ពួកលោកមកក៏មកចុះ ហើយទៅដល់ក្រុងសាវត្ថី បួសក្នុងសំណាក់ព្រះមានព្រះភាគ ហើយក៏សម្រេចព្រះអរហត្ត ។

ចំណែកសេដ្ឋីទាំងនោះ មានរទេះ ៥០០ ជាបរិវារ ដល់ក្រុងសាវត្ថីក្នុងខាងក្រោយ តាំងទីសម្រាកក្នុងទីមិនឆ្ងាយព្រះជេតវនវិហារ ចូលទៅគាល់ព្រះសាស្តា

ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា ទ្រង់សម្តែងធម៌ដោយអំណាចចរិយារបស់អ្នកទាំងនោះ ចប់ទេសនា សេដ្ឋីទាំង ៣ នាក់ក៏តាំងនៅក្នុងសោតាបត្តិផល អារាធនាដើម្បីសោយក្នុងថ្ងៃស្អែក ថ្វាយមហាទានដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធទ្រង់ជាប្រធានក្នុងថ្ងៃស្អែក អារាធនាដើម្បីសោយក្នុងថ្ងៃនេះ ដោយទំនងនោះឯង ថ្វាយខន្ធាវារភត្តទាន (ទានរបស់អ្នកតាំងបន្ទាយសម្រាក) អស់កន្លះខែ ទើបទូលអង្វរព្រះសាស្តាដើម្បីស្តេចមកកាន់នគររបស់ខ្លួន ។ ព្រះសាស្តាត្រាស់ថា ព្រះតថាគតទាំងឡាយត្រេកអរក្នុងផ្ទះស្ងាត់ ដូច្នេះ ។ សេដ្ឋីទាំងនោះក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គជ្រាបហើយ ហើយក្រាបទូលថា សូមព្រះអង្គមេត្តាស្តេចមកតាមដំណឹងដែលពួកខ្ញុំព្រះអង្គបញ្ជូនមកចុះ ថ្វាយបង្គំព្រះសាស្តា ធ្វើប្រទក្សិណ ៣ ជុំវិញហើយ ត្រឡប់ទៅនគររបស់ខ្លួនទាំង ៣ នាក់ក៏ឲ្យសាងព្រះវិហារក្នុងឧទ្យានរបស់ខ្លួន វិហារដែលឃោសកសេដ្ឋីសាង ឈ្មោះថា **ឃោសិតារាម** ដែលកុក្កុដសេដ្ឋីសាង ឈ្មោះថា **កុក្កុដារាម** ដែលបាវារិកសេដ្ឋីសាង ឈ្មោះថា **បាវារិកម្ពវ័នវិហារ** ។ សេដ្ឋីទាំងនោះ ឲ្យសាងវិហារស្រេចហើយបញ្ជូនទូតទៅទូលព្រះសាស្តាថា សូមព្រះសាស្តាមេត្តាស្តេចយាងមកព្រះនគរនេះ ដើម្បីសង្គ្រោះពួកខ្ញុំព្រះអង្គផង ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា ស្តេចនឹងទៅកាន់ក្រុងកោសម្ពី មានភិក្ខុសង្ឃ

ពួកធំជាបរិវារ ស្តេចចេញចារិក ទ្រង់ឃើញឧបនិស្ស័យព្រះអរហត្តរបស់មាគ-ណ្ឌិយព្រាហ្មណ៍ ក្នុងវាងផ្លូវ ទើបវៀរការស្តេចទៅក្រុងកោសម្ពី ស្តេចទៅកាន់និគមឈ្មោះថា កម្មាសធម្មៈ ដែនកុរុ ។ សម័យនោះ មាគណ្ឌិយព្រាហ្មណ៍ បម្រើភ្លើងនៅក្រៅស្រុករហូតអស់មួយយប់ទល់ភ្លឺ ព្រឹកឡើង ទើបចូលមកក្នុងស្រុក ។ ស្អែកឡើង សូម្បីព្រះសាស្តា ក៏ស្តេចចូលទៅបិណ្ឌបាតក្នុងស្រុក ដើរជ្រួសផ្លូវគ្នា ទ្រង់សម្តែងព្រះអង្គដល់មាគណ្ឌិយព្រាហ្មណ៍ ។ មាគណ្ឌិយព្រាហ្មណ៍នោះ ឃើញព្រះទសពល ក៏គិតថា យើងដើរស្វែងរកក្មេងកម្លោះ ដែលសក្តិសមនឹងរូបសម្បត្តិធីតារបស់យើង អស់វេលាប៉ុណ្ណេះ កាលបើបានហើយ យើងក៏ប្រាថ្នាបព្វជ្ជាដូចបុគ្គលនេះកាន់យកដូច្នេះដូចគ្នា តែបព្វជិតនេះ ល្អស្អាត សមនឹងធីតារបស់យើងពិតៗ ទើបប្រញាប់ត្រឡប់ទៅផ្ទះ ។ ន័យថា ព្រាហ្មណ៍នោះ ជាវង្សបព្វជិតវង្សមួយមកពីមុន ដោយហេតុនោះ ពេលឃើញបព្វជិតប៉ុណ្ណោះ ចិត្តរបស់គេទើបបង្អោនទៅ ព្រាហ្មណ៍ប្រឹក្សាជាមួយនាងព្រាហ្មណីថា ប្អូនអើយ ខ្ញុំប្រាថ្នាការបព្វជ្ជាយ៉ាងនេះ ខ្ញុំមិនធ្លាប់ជួបបព្វជិតបែបនេះ ជាភេទព្រាហ្មណ៍មានពណ៌សម្បុរដូចមាសសក្តិសមនឹងធីតាពិតៗ ចូរប្រញាប់តែងខ្លួនធីតារបស់នាងចុះ ។ កាលព្រាហ្មណីកំពុងតែងខ្លួនធីតា ព្រះសាស្តាក៏ទ្រង់សម្តែងព្រះចេតិយ គឺ ស្នាមព្រះបាទទុកក្នុងទីដែលគេជួបព្រះអង្គ ស្តេចក៏យាងចូលទៅខាងក្នុងព្រះនគរ ។ ខណៈនោះ ព្រាហ្មណ៍

នាំជីតាព្រមទាំងនាងព្រាហ្មណីមកកាន់ទីនោះ ត្រួតពិនិត្យមើលទីជុំវិញ ព្រោះគេមកវេលាដែលព្រះសាស្តាស្តេចយាងចូលទៅក្នុងស្រុក មិនឃើញព្រះទសពល ក៏បរិភាសនាងព្រាហ្មណីថា ការធ្វើរបស់នាងនេះ ឈ្មោះថា ល្អមិនមានឡើយ ព្រោះនាងវលវល់តែបង្អែបង្អង់ ទើបបព្វជិតនោះចេញទៅបាត់ ។ ព្រាហ្មណ៍ពិនិត្យមើលត្រង់ទីព្រះសាស្តាស្តេចទៅថា បព្វជិតទៅហើយ ឈ្លើយចុះ ទៅផ្លូវណា ឬទៅផ្លូវនេះ ក៏ជួបព្រះចេតិយ គឺ ស្នាមព្រះបាទ ពោលថា នាងដ៏ចម្រើន នេះស្នាមជើងបុរសនោះ គេមុខជានឹងទៅផ្លូវនេះ ។ ខណៈនោះ នាងព្រាហ្មណីឃើញព្រះចេតិយ គឺ ស្នាមព្រះបាទរបស់ព្រះសាស្តា គិតថា តាព្រាហ្មណ៍នេះ ជាមនុស្សល្ងង់ណាស់ មិនដឹងអត្ថសូម្បីត្រឹមតែការព្យាយាមរបស់ខ្លួន ទើបធ្វើការចំអកឡកឡឺយ និយាយនឹងព្រាហ្មណ៍នោះថា ព្រាហ្មណ៍ លោកល្ងង់យ៉ាងនេះហើយ នៅមកនិយាយថា យើងនឹងឲ្យជីតាដល់បុរសបែបនោះ ។ ព្រោះថា ធម្មតា ស្នាមជើងរបស់បុរសដែលរាគៈជ្រលក់ហើយ ទោសៈប្រទូសរ៉ាយហើយ មោហៈឲ្យវង្វេងហើយ មិនដូច្នោះឡើយ មើលចុះព្រាហ្មណ៍ នោះជាស្នាមជើងរបស់ព្រះសព្វញ្ញុពុទ្ធ អ្នកមានដំបូលបើកហើយក្នុងលោក ។

រត្តស្ស ហិ ឧក្កុដិកំ បទំ ភវេ

ទុដ្ឋស្ស ហោតិ អាវកឌ្ឍិតំ បទំ

*មុឡ្ហស្ស ហោតិ សហសានុបីឡិតំ*

*វិវដច្ឆទស្ស ឥទមីទិសំ បទន្តិ ។*

*ពិតណាស់ ស្នាមជើងរបស់អ្នកត្រូវរាគៈជ្រលក់ហើយ*

*គប្បីជាស្នាមជើងផតកណ្តាល ស្នាមជើងរបស់អ្នកដែល*

*ត្រូវទោសៈប្រទូសរ៉ាយហើយ ជាស្នាមជើងជុចខាងចុង*

*ស្នាមជើងរបស់អ្នកដែលត្រូវមោហៈឲ្យវង្វេងហើយ គប្បី*

*ជាស្នាមជើងដែលសង្កត់កែងចុះ នេះជាស្នាមជើងរបស់*

*បុគ្គលដែលមានដំបូលបើកហើយនោះឯង ។*

*កាលនាងព្រាហ្មណីនិយាយយ៉ាងនោះ ព្រាហ្មណ៍នោះ ក៏មិនស្តាប់ពាក្យ ត្រឡប់ជាពោលថា នាងជាស្រីមាត់អាក្រក់ ។ កាលទាំងពីរនាក់ស្វាមីភរិយាឈ្លោះប្រកែកគ្នាទុំះឯង ព្រះសាស្តាស្តេចត្រាច់ទៅបិណ្ឌបាត ព្រមនឹងភិក្ខុសង្ឃ សោយស្រេចហើយ ទើបស្តេចចេញទៅ ជិតផ្លូវដែលព្រាហ្មណ៍ល្មមឃើញបាន ។ ព្រាហ្មណ៍ក្រឡេកឃើញព្រះសាស្តាស្តេចមកពីចម្ងាយ ក៏ប្រាប់នាងព្រាហ្មណី ញញឹមញញែមនិយាយថា បុគ្គលនេះ គឺ បុរសនោះឯង ទើបឈរត្រង់ព្រះភ័ក្ត្រទូលថា បព្វជិតដ៏ចម្រើន ខ្ញុំដើររកលោកតាំងពីព្រឹក ។ ក្នុងជម្ពូទ្វីបនេះ មិនមានស្ត្រីណាមានរូបល្អស្មើនឹងធីតារបស់ខ្ញុំ សូម្បីបុរសក៏មិនមានអ្នកណាមានរូបល្អស្មើនឹងលោក ខ្ញុំ*

ឲ្យធីតារបស់ខ្ញុំ ដើម្បីលោកនឹងបានថែរក្សា លោកទទួលនាងទៅចុះ ។ គ្រានោះព្រះសាស្តាទើបត្រាស់ចំពោះព្រាហ្មណ៍នោះថា ព្រាហ្មណ៍ សូម្បីតែពួកទេពធីតានៅក្នុងសួគ៌ជាន់កាមាវចរ មានរូបឆោមប្រសើរបំផុត មានពណ៌សម្បុរផ្សេងៗ គ្នាមកឈរក្នុងសំណាក់ ពោលពាក្យដើម្បីលួងលោមតថាគត តថាគតក៏មិនប្រាថ្នានឹងចាំបាច់ពោលថ្វី ដល់ធីតារបស់លោកថា តថាគតនឹងទទួល គ្រាត្រាស់ហើយទើបត្រាស់ព្រះគាថានេះថា

ទិស្វាន តណ្ហំ អរតិញ្ច រាគំ
នាហោសិ ឆន្ទោ អបិ មេថុនស្មឹ
កិមេវិទំ មុត្តករីសបុណ្ណំ
បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ ។

ព្រោះឃើញនាងតណ្ហា នាងអរតី នាងរាគា សូម្បីសេចក្តីពេញចិត្តក្នុងមេថុន ក៏មិនមានឡើយ សរីរៈនេះ ពេញទៅដោយឧច្ចារបស្សាវៈទាំងនោះឯង សូម្បីតែជើង តថាគតក៏មិនប្រាថ្នានឹងប៉ះពាល់នាង ។

នាងមាគណ្ឌិយាគិតថា ធម្មតាបុគ្គលដែលមិនត្រូវការ និយាយបដិសេធថា កុំឡើយ ប៉ុណ្ណោះក៏គួរ តែបព្វជិតនេះ ធ្វើសរីរៈរបស់យើងឲ្យជាទីពេញទៅ

ដោយឧច្ចារបស្សាវៈ ហើយនៅនិយាយថា សូម្បីតែជើងក៏មិនប្រាថ្នានឹងប៉ះពាល់ ។ យើងកាលបានតំណែងដ៏ធំណាមួយ នឹងមើលទីបញ្ចប់របស់បព្វជិតនោះ ហើយបានចងអាឃាតទុក ។ ព្រះសាស្តាទ្រង់មិនបានដាក់ព្រះទ័យចំពោះនាង ទ្រង់ផ្តើមព្រះធម៌ទេសនា អនុគ្រោះព្រាហ្មណ៍ ដោយអំណាចចរិយារបស់គេ ។ ចប់ទេសនា ពីរនាក់ស្វាមីភរិយាក៏តាំងនៅក្នុងអនាគាមិផល ហើយត្រិះរិះថា ឥឡូវនេះយើងមិនត្រូវការគ្រប់គ្រងផ្ទះទេ ទើបឲ្យមាគណ្ឌិយព្រាហ្មណ៍ដែលជាឪពុកមា ទទួលធីតាទុក ទាំងពីរនាក់ក៏បួស ហើយសម្រេចព្រះអរហត្ត ។ គ្រានោះ ព្រះបាទឧទេនទ្រង់បានធ្វើការនិយាយព្រមព្រៀងជាមួយមាគណ្ឌិយព្រាហ្មណ៍ដែលជាឪពុកមា ហើយទ្រង់នាំនាងមាគណ្ឌិយាទៅកាន់ព្រះរាជនិវេសន៍ ដោយព្រះរាជនុភាព ទ្រង់ក៏អភិសេកនិងព្រះរាជទានប្រាសាទផ្សេង ដើម្បីព្រះនាងមាគណ្ឌិយានឹងស្ត្រីជាបរិវារ ៥០០ ។

ចំណែកព្រះសាស្តា ស្តេចចារិកដោយលំដាប់ មកដល់ក្រុងកោសម្ពី ។ ពួកសេដ្ឋី (៣ នាក់) ដឹងថា ព្រះសាស្តាស្តេចយាងមក ទើបចេញទៅទទួលស្តេចថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងទីដ៏សមគួរមួយ ក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន វិហារទាំង ៣ នេះ ខ្ញុំព្រះអង្គសាងចំពោះព្រះអង្គ សូមទ្រង់មេត្តាប្រោសទទួលវិហារទាំងឡាយ ដើម្បីសង្គ្រោះសង្ឃដែលចារិកមកពីទិសទាំង ៤ ចុះ ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ទទួលវិហារទុក ។

សូម្បីសេដ្ឋីទាំងនោះ ក៏អារាធនាព្រះសាស្តាដើម្បីសោយអាហារក្នុងថ្ងៃស្អែក ថ្វាយបង្គំហើយក៏ត្រឡប់ទៅកាន់ស្រុកវិញ ។ ចំណែកព្រះនាងមាគណ្ឌិយា ទ្រង់ជ្រាបថា ព្រះសាស្តាស្តេចមក ទើបឲ្យហៅពួកអ្នកលេងដែលជាអ្នកស្មាក់ផ្លូវមក ហើយឲ្យថ្លៃឈ្នួលដល់អ្នកលេងទាំងនោះ ត្រាស់បង្គាប់ថា ពួកអ្នកចូរជេរព្រះសមណ-គោតមដោយទំនងយ៉ាងនេះ ហើយក៏បញ្ជូនទៅ ។ អ្នកលេងទាំងនោះ ក៏ជេរព្រះសាស្តាព្រមទាំងភិក្ខុសង្ឃ វេលាស្តេចចូលខាងក្នុងស្រុក ដោយការជេរមានប្រការផ្សេងៗ ។ ព្រះអានន្ទក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន យើងកុំនៅក្នុងទីដែលគេជេរបែបនេះអី នឹងទៅនគរដទៃ ។ ព្រះដ៏មានព្រះភាគត្រាស់ថា អានន្ទ ធម្មតា ព្រះតថាគតរមែងមិនញាប់ញ័រដោយលោកធម៌ ៨ ប្រការ សំឡេង (ជេរ) នេះ ក៏នឹងប្រព្រឹត្តទៅមិនលើសពី ៧ ថ្ងៃ ទណ្ឌៈណាមួយនឹងធ្លាក់ទៅលើពួកអ្នកជេរនុ៎ះឯង អ្នកកុំវិតក្កអ្វីឡើយ ។ ចំណែកសេដ្ឋីរបស់នគរទាំង ៣ នាក់នោះ ទូលព្រះមានព្រះភាគសូមស្តេចចូលទៅ ដោយសក្ការៈដ៏ធំ ថ្វាយមហាទាន ។ សេដ្ឋីទាំងនោះថ្វាយទានតៗ គ្នា រហូតកន្លងវេលាអស់មួយខែ ។ គ្រានោះ សេដ្ឋីទាំងនោះក៏ត្រិះរិះយ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់ឧប្បត្តិមក ដើម្បីអនុគ្រោះលោកទាំងពួង យើងនឹងឲ្យឱកាសដល់បុគ្គលដទៃផង ។ សេដ្ឋីអ្នកក្រុងកោ-សម្ពីនោះ ទើបឲ្យឱកាសដល់ប្រជាជន តាំងពីនោះមក អ្នកក្រុងទាំងឡាយ ទើប

ថ្វាយមហាទាន ដោយចាត់ចែងជាខ្សែមនុស្សរួមថ្នល់ ខ្សែមនុស្សរួមគណៈ ។

តមកថ្ងៃមួយ ព្រះសាស្តាមានភិក្ខុសង្ឃហែហម ប្រថាប់ក្នុងផ្ទះរបស់មេជាង ធ្វើផ្កាឈើ ខណៈនោះនាងខុជ្ជុត្តរា ស្រីបម្រើព្រះនាងសាមាវតី នាំកហាបណៈ ៨ កហាបណៈទៅផ្ទះនោះ ដើម្បីត្រូវការផ្កាឈើ ។ មេជាងធ្វើផ្កាឈើឃើញនាង ក៏ពោលថា នាងឧត្តរា ខ្ញុំមិនមានវេលាធ្វើផ្កាឈើឲ្យនាងទេ ខ្ញុំអង្គាសព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន សូម្បីនាង ក៏ចូរជាសម្លាញ់ក្នុងការអង្គាសផង ។ ដោយអាការយ៉ាងនេះ តាំងពីនេះទៅ នាងក៏នឹងរួចផុតពីការត្រូវខ្វល់ខ្វាយបម្រើដល់អ្នកដទៃ ។ បន្ទាប់ពីនោះ នាងខុជ្ជុត្តរា បរិភោគអាហារដែលខ្លួនបានហើយ ក៏ធ្វើការខ្វល់ខ្វាយក្នុងរោងអាហារដើម្បីព្រះពុទ្ធទាំងឡាយ ។ នាងរៀនធម៌ដែលព្រះសាស្តាត្រាស់ដោយអំណាចឧបនិសន្នកថា ទុកបានទាំងអស់ តែស្តាប់អនុមោទនាហើយ ក៏តាំងនៅក្នុងសោតាបត្តិផល ។ នាងឲ្យ ៤ កហាបណៈក្នុងថ្ងៃដទៃៗ ទទួលផ្កាឈើទាំងឡាយហើយក៏ទៅ តែក្នុងថ្ងៃនោះ មិនកើតចិត្តគិតចង់បានក្នុងទ្រព្យរបស់អ្នកដទៃ ព្រោះជាអ្នកឃើញសច្ចៈហើយ ទើបឲ្យអស់ទាំង ៨ កហាបណៈ ហើយដាក់ផ្កាឈើពេញកន្ត្រក នាំផ្កាឈើទៅសំណាក់ព្រះនាងសាមាវតី ។ លំដាប់នោះ ព្រះនាងត្រាស់សួរនាងថា នាងឧត្តរា ក្នុងថ្ងៃមុនៗ នាងនាំផ្កាឈើមកមិនច្រើនឡើយ តែថ្ងៃនេះ ផ្កាឈើច្រើនម្ល៉េះ ព្រះរាជារបស់យើងទ្រង់ពេញចិត្តខ្លាំងឡើងឬ ។ នាង

មិនបិទបាំងកម្មដែលខ្លួនធ្វើពីមុន ព្រោះជាអ្នកមិនត្រូវនិយាយកុហក ប្រាប់រឿងទាំងអស់ កាលត្រូវសួរថា ព្រោះហេតុអ្វី ថ្ងៃនេះទើបនាំមកច្រើន ទើបពោលយ៉ាងនេះថា ថ្ងៃនេះ ខ្ញុំម្ចាស់ស្តាប់ធម៌របស់ព្រះទសពល ធ្វើឲ្យច្បាស់អមតធម៌ហើយ ព្រោះហេតុនោះ ខ្ញុំម្ចាស់ទើបមិនកុហកពួកព្រះនាងម្ចាស់ ។ ស្ត្រីទាំងឡាយស្តាប់ពាក្យនោះហើយ ពោលថា នាងឧត្តរា នាងចូរឲ្យអមតធម៌ដែលនាងបានហើយដល់ពួកយើងផង ហើយក៏នាំគ្នាលូកដៃចេញសូមគ្រប់អ្នក ។ នាងទើបពោលថា ព្រះនាងម្ចាស់ ឲ្យយ៉ាងនោះមិនបានទេ តែខ្ញុំម្ចាស់នឹងសម្តែងធម៌ដល់ព្រះនាងតាមទំនងដែលព្រះសាស្តាត្រាស់ហើយ កាលហេតុរបស់ខ្លួនមានហើយ ពួកនាងនឹងបានធម៌នោះ ។ ស្ត្រីទាំងឡាយពោលថា បើយ៉ាងនោះ ចូរពោលចុះនាងឧត្តរា ។ នាងពោលថា នឹងពោលយ៉ាងនោះមិនបានទេ ចូរបោត់អាសនៈឲ្យខ្ពស់ដល់ខ្ញុំម្ចាស់ ពួកនាងចូរអង្គុយអាសនៈក្រោម ស្ត្រីសូម្បីទាំង ៥០០ នាក់នោះ ក៏ឲ្យអាសនៈដែលខ្ពស់ដល់នាងខុជ្ជុត្តរា ចំណែកខ្លួនឯងអង្គុយអាសនៈដែលទាប ។ សូម្បីនាងខុជ្ជុត្តរាតាំងនៅក្នុងសេក្ខប្បដិសម្ភិទា សម្តែងធម៌ដល់ស្ត្រីទាំងនោះ ។ ចប់ទេសនា ស្ត្រីទាំងអស់ មានព្រះនាងសាមាវតីជាព្រះប្រធាន ក៏តាំងនៅក្នុងសោតាបត្តិផល ។ តាំងពីនោះមក ស្ត្រីទាំងនោះក៏ឲ្យនាងខុជ្ជុត្តរា រួចពីមុខនាទីអ្នកបម្រើ ហើយពោលថា នាងស្តាប់ធម្មកថារបស់ព្រះសាស្តា ហើយនាំមកឲ្យពួកយើងស្តាប់ ។ តាំងពី

នោះមក សុម្បីនាងខុជ្ជុត្តរាក៏បានធ្វើយ៉ាងនោះ ។

សួរថា ក៏ព្រោះហេតុអ្វី នាងខុជ្ជុត្តរានេះ ទើបកើតជាទាសី ។ ឆ្លើយថា ដូចបានស្តាប់មក នាងខុជ្ជុត្តរា ក្នុងសាសនាព្រះពុទ្ធព្រះនាមថា **កស្សបៈ** បានឲ្យសាមណេរីមួយរូបបម្រើខ្លួន ដោយកម្មនោះ នាងទើបកើតជាទាសីរបស់អ្នកដទៃអស់ ៥០០ ជាតិ ។ សួរថា ព្រោះហេតុអ្វី ទើបជាស្រីគម ។ ឆ្លើយថា បានឮថា កាលព្រះពុទ្ធមិនទាន់ឧប្បត្តិ នាងនៅក្នុងរាជនិវេសន៍របស់ព្រះបាទក្រុងពារាណសី ឃើញព្រះបច្ចេកពុទ្ធមួយអង្គ ប្រចាំរាជត្រកូលជាអ្នកគម ទើបធ្វើការចំអកឡកឡឺយចំពោះមុខពួកស្ត្រីដែលនៅជាមួយនឹងខ្លួន ដើរធ្វើអាការជាមនុស្សគម ។ ព្រោះហេតុនោះ នាងទើបកើតជាស្រីគម ។ សួរថា ក៏នាងធ្វើបុណ្យអ្វីទើបកើតជាអ្នកមានបញ្ញា ។ ឆ្លើយថា បានឮថា កាលព្រះពុទ្ធមិនទាន់ឧប្បត្តិ នាងកើតហើយនៅក្នុងរាជនិវេសន៍របស់ព្រះបាទក្រុងពារាណសី ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ កាន់បាត្រដែលពេញដោយបាយបាយាសក្តៅ និមន្តចេញពីរាជនិវេសន៍ទៅ ពោលថា លោកម្ចាស់ មេត្តាឈប់ត្រង់នោះសិន ហើយទើបដើរទៅ ដោះមាសដែលពាក់ត្រង់ម្រាមដៃ (ចិញ្ចៀន) ៨ វង់ ថ្វាយទៅ ។ ដោយផលនៃកម្មនោះ នាងទើបកើតមកជាអ្នកមានបញ្ញា ។

គ្រានោះឯង ស្ត្រី ៥០០ នាក់ ជាបរិវាររបស់ព្រះនាងសាមាវតី សុម្បី

ត្រាស់ដឹងសច្ចៈហើយ ក៏មិនបានទៅសំណាក់របស់ព្រះសាស្តាគាល់ព្រះសម្ពុទ្ធតាមកាលដែលសមគួរ ព្រោះព្រះរាជាទ្រង់មិនមានសទ្ធា ។ ព្រោះហេតុនោះ កាលព្រះទសពលស្តេចព្រះរាជដំណើរក្នុងរវាងថ្នល់ កាលបង្អួចទាំងឡាយមានមិនល្មម ស្ត្រីទាំងនោះទើបចោះប្រហោងក្នុងបន្ទប់របស់ខ្លួនតាមសម្ល័ងមើល (ព្រះសាស្តា) ។ តមកថ្ងៃមួយ ព្រះនាងមាគណ្ឌិយា ស្តេចដំណើរចេញចាកជាន់ប្រាសាទរបស់ព្រះនាង ទៅកាន់ទីនៅរបស់ស្ត្រីទាំងនោះ ឃើញប្រហោងបន្ទប់ ទើបទ្រង់សួរថា នេះជាអ្វី កាលស្ត្រីទាំងនោះមិនដឹងរឿងក្នុងការចងអាឃាតចំពោះព្រះសាស្តា របស់ព្រះនាងមាគណ្ឌិយា ទើបទូលថា ព្រះសាស្តាស្តេចមកព្រះនគរនេះ ពួកយើងឈរត្រង់នោះ ទើបបានឃើញ និងបូជាព្រះសាស្តា ព្រះនាង ។ ទ្រង់គិតថា ស្ត្រីទាំងនេះជាឧបដ្ឋាយិការបស់ព្រះសមណគោតមនោះ យើងនឹងដឹងកិច្ចដែលគប្បីធ្វើដល់ស្ត្រីទាំងនេះ ហើយក៏ទៅក្រាបទូលព្រះរាជាថា បពិត្រព្រះមហារាជ ស្ត្រីទាំងនេះព្រមទាំងព្រះនាងសាមាវតី ប្រាថ្នាចេញទៅខាងក្រៅ គេនឹងធ្វើជីវិតរបស់ព្រះអង្គឲ្យស្លាប់ក្នុង ២-៣ ថ្ងៃនេះឯង ព្រះអង្គ , ព្រះរាជាទ្រង់មិនជឿថា ស្ត្រីទាំងនោះនឹងធ្វើយ៉ាងនោះ សូម្បីកាលព្រះនាងមាគណ្ឌិយាទូលទៀត ក៏ទ្រង់នៅតែមិនជឿនុ៎ះឯង ។ គ្រានោះ សូម្បីកាលព្រះនាងក្រាបទូលដល់ ៣ ដង ព្រះរាជាក៏ទ្រង់មិនបានជឿ ។ ព្រះនាងមាគណ្ឌិយាទើបក្រាបទូលថា បពិត្រព្រះមហារាជ បើព្រះ

អង្គទ្រង់មិនជឿ សូមព្រះអង្គទៅកាន់ទីនៅរបស់ស្ត្រីទាំងនោះ ហើយទ្រង់ដេញដោល សួរមើល ព្រះអង្គ ។ ព្រះរាជាស្ដេចទៅ ឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ត្រាស់សួរថា អ្វីនេះ កាលគេក្រាបទូលសេចក្ដីនោះ ក៏ទ្រង់មិនបានក្រោធនឹងស្ត្រីទាំងនោះ មិនត្រាស់អ្វី ត្រឹមតែត្រាស់បង្គាប់ឲ្យបិទប្រហោងទាំងនោះឯង ។ ព្រះនាងមាគណ្ឌិយាត្រាស់ថា ព្រះនាងសាមាវតីព្រមទាំងបរិវារ មិនមានសេចក្ដីហួងហែង ឬសេចក្ដីស្រឡាញ់ក្នុងព្រះអង្គ កាលបង្អួចមានមិនល្មម ទើបចោះប្រហោងទាំងនោះ ធ្វើឱកាសសម្លឹងមើលព្រះសមណគោតម ដែលស្ដេចយាងក្នុងវាំងផ្ទាល់ ។ តាំងពីនោះមក ព្រះរាជា ទើបប្រោសឲ្យធ្វើបង្អួចក្រឡាសំណាញ់ទុកក្នុងប្រាសាទរបស់ស្ត្រីទាំងនោះ ។

ព្រះនាងមាគណ្ឌិយានោះ មិនអាចធ្វើព្រះរាជាឲ្យទ្រង់ក្រោធដោយហេតុនោះបាន ទើបក្រាបទូលថា ទេវៈ ស្ត្រីទាំងនោះមានសេចក្ដីស្រឡាញ់ ឬមិនមានសេចក្ដីស្រឡាញ់ក្នុងព្រះអង្គ យើងនឹងដឹងគ្នា សូមព្រះអង្គមេត្តាបញ្ជូនមាន់ ៨ ក្បាលទៅឲ្យស្ត្រីទាំងនោះចម្អិនថ្វាយព្រះអង្គចុះ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យនោះហើយ ត្រាស់បង្គាប់ថា ចូរចម្អិនមាន់ទាំងនេះ ទ្រង់បញ្ជូនមាន់ ៨ ក្បាល ដល់ព្រះនាងសាមាវតី ។ ព្រះអរិយសាវិកា ដែលជាសោតាបន្ន ដឹងថា មាន់នៅរស់នឹងចម្អិនបានដូចម្ដេច ទើបត្រាស់បដិសេធថា កុំឡើយ មិនប្រាថ្នាសូម្បីតែនឹងយកព្រះហស្ត

ចាប់កាន់ ។ ព្រះនាងមាគណ្ឌិយាក្រាបទូលថា ប្រការនោះលើកទុកក៏បាន មហារាជ សូមទ្រង់ប្រោសបញ្ជូនមាន់ទាំងនេះឯង ដើម្បីចម្អិនថ្វាយព្រះសមណគោតម ។ ព្រះរាជាក៏ទ្រង់ធ្វើយ៉ាងនោះ ។ ព្រះនាងមាគណ្ឌិយាទ្រង់ឲ្យអ្នកសម្លាប់មាន់ក្នុងចន្លោះផ្លូវហើយ បញ្ជូនទៅ ដោយត្រាស់បង្គាប់ថា ព្រះនាងសាមាវតី ចូរចម្អិនមាន់ទាំងនេះថ្វាយព្រះសមណគោតម ។ ព្រះនាងសាមាវតី ទ្រង់ពេញព្រះទ័យយ៉ាងនោះ ព្រោះទ្រង់ពេញព្រះទ័យចំពោះព្រះទសពល ទើបចម្អិន (ស្ល) មាន់បញ្ជូនទៅថ្វាយចំពោះព្រះទសពល ។ ព្រះនាងមាគណ្ឌិយាទូលថា ទ្រង់ទតចុះមហារាជ ដូច្នេះ ក៏មិនអាចធ្វើព្រះរាជាឲ្យទ្រង់ក្រោធបានដោយហេតុត្រឹមប៉ុណ្ណោះ ។

ក៏ព្រះបាទឧទេន ប្រថាប់នៅក្នុងទីនៅរបស់បណ្ដានាងទេវីទាំងនោះ ក្នុងមួយព្រះអង្គៗ ៧ ថ្ងៃ ។ ចំណែកព្រះនាងមាគណ្ឌិយានេះ ប្រើឲ្យមនុស្សយកកូនពស់វែកមួយក្បាលដាក់ក្នុងស្នុកឫស្សី ទុកក្នុងទីនៅរបស់ខ្លួន ។ ព្រះរាជាស្ដេចទៅដល់កន្លែងណាមួយ ក៏ទ្រង់កាន់ពិណឈ្មោះ **ហត្ថិកន្ត:** ។ វេលាព្រះរាជាស្ដេចមករកខ្លួន ព្រះនាងមាគណ្ឌិយាក៏ដាក់កូនពស់នោះទុកខាងក្នុងពិណ ឲ្យបិទប្រហោង ។ ក្រាបទូលថា ព្រះមហារាជ វេលាស្ដេចទៅរកនាងសាមាវតី ដែលឈ្មោះថា នាងសាមាវតីពេញចិត្តព្រះសមណគោតម មិនបាននាំព្រះអង្គធ្វើការណាមួយឡើយ ក៏គិតតែនឹងឲ្យទោសព្រះអង្គប៉ុណ្ណោះ សូមព្រះអង្គទ្រង់កុំប្រមាទឡើយ ។ ព្រះរាជា

ទ្រង់យាងដល់ទីនៅរបស់ព្រះនាងសាមាវតី ប្រថាប់នៅ ៧ ថ្ងៃ បានស្តេចត្រឡប់ទៅនិវេសន៍របស់ព្រះនាងមាគណ្ឌិយាទៀត ៧ ថ្ងៃ ។ កាលព្រះរាជាស្តេចកំពុងមក ព្រះនាងមាគណ្ឌិយាធ្វើដូចជាទូលថា មហារាជ ព្រះនាងសាមាវតីមិនរកកំហុសរបស់ព្រះអង្គទេឬ ទទួលពិណពីព្រះហស្តរបស់ព្រះរាជាមកអង្រួន ត្រាស់ថា មហារាជ អ្វីនៅខាងក្នុងនេះ ព្រះអង្គ ហើយធ្វើឱកាសឲ្យពស់ចេញទៅ ស្រែកថា ពស់នៅខាងក្នុង ហើយទម្លាក់ពិណចោល គេចចេញទៅ ។ វេលានោះ ព្រះរាជាទ្រង់ស្តីបន្ទោសដោយសេចក្តីក្រេវក្រោធ ដូចភ្លើងឆេះព្រៃឫស្សីដូច្នោះ និងដូចជាចង្ក្រានភ្លើងដាក់គ្រាប់អំបិលចុះទៅដូច្នោះ ត្រាស់បង្គាប់ថា ចូរហៅសាមាវតី និងបរិវារមក ។ ពួករាជបុរសក៏ទៅហៅ ។ ព្រះនាងសាមាវតីទ្រង់ជ្រាបថា ព្រះរាជាទ្រង់ក្រោធ ទើបឲ្យសញ្ញាដល់ពួកស្ត្រីទាំងនោះ ត្រាស់ថា ព្រះរាជាទ្រង់បំណងនឹងសម្លាប់ពួកយើង ទើបហៅមក ថ្ងៃនេះ ពួកយើងចូរផ្សាយមេត្តាចំពោះព្រះរាជារហូតអស់មួយថ្ងៃ ។ ព្រះរាជាទ្រង់ហៅស្រីទាំងនោះ ឲ្យគ្រប់អ្នកឈររៀងគ្នា ទ្រង់ចាប់ធ្នូដងធំ ទ្រង់ស៊កកូនធ្នូលាបដោយថ្នាំពិស ប្រថាប់ឈរទាញធ្នូពេញទំហឹង ។ ខណៈនោះ ស្ត្រីទាំងអស់នោះមានព្រះនាងសាមាវតីជាប្រធាន ក៏នាំគ្នាផ្សាយមេត្តាដោយចំពោះ ។ ព្រះរាជាក៏មិនអាចបាញ់កូនធ្នូ និងដោះកូនធ្នូចេញបាន ។ ព្រះសេទោក៏ហូរចេញចាកព្រះវរកាយ ព្រះវរកាយញ័រ ព្រះខេឡៈហូរចេញចាកព្រះឱស្ឋ

ទ្រង់មិនឃើញទីពឹងដែលគប្បីពឹងបាន ។ លំដាប់នោះ ព្រះនាងសាមាវតីក្រាបទូលព្រះរាជាថា មហារាជ ទ្រង់លំបាកឬ ព្រះអង្គ ព្រះរាជាត្រាស់ថា ពិតហើយទេវី បងលំបាក ។ ល្អហើយ នាងចូរជាទីពឹងរបស់បងផង ។ ព្រះនាងសាមាវតីក្រាបទូលថា មហារាជ សូមព្រះអង្គទ្រង់បែរកូនធ្នូចុះទៅដីចុះ ព្រះអង្គ ។ ព្រះរាជាទ្រង់ក៏បដិបត្តិតាម ។ ព្រះនាងអធិដ្ឋានថា សូមកូនធ្នូចូររបូតចាកព្រះហស្តរបស់ព្រះរាជា ។ ខណៈនោះកូនធ្នូក៏របូត ។ ក្នុងខណៈនោះឯង ព្រះរាជាទ្រង់មុជចុះក្នុងទឹក ស្តេចមកទាំងដែលព្រះកេសាសើម ព្រះភូសាសើម ក្រាបចុះទៀបព្រះបាទព្រះនាងសាមាវតី ត្រាស់ថា លើកទោសឲ្យបងចុះ ទេវី បងមិនបានពិចារណាក៏ធ្វើកម្មនោះ តាមពាក្យរបស់ពួកមនុស្សដែលនឹងឲ្យបងបែកគ្នា ។ ព្រះនាងត្រាស់ថា ទេវៈ នាងខ្ញុំម្ចាស់សូមអត់ទោសថ្វាយម្ចាស់បងហើយ ។ ព្រះរាជាត្រាស់ថា ល្អណាស់ទេវី ប្រការនេះក៏ជាការដែលនាងលើកទោសឲ្យបងហើយ ហើយត្រាស់ទៀតថា តាំងពីពេលនេះទៅ ពួកនាងចូរថ្វាយទានចំពោះព្រះទសពលបានតាមដែលនាងត្រូវការ ខាងក្រោយកត្ត នឹងទៅវិហារស្តាប់ធម្មកថាក៏បាន យើងនឹងឲ្យការរក្សាដល់នាង ។ ព្រះនាង ក្រាបទូលថា ទេវៈ បើដូច្នោះ តាំងពីថ្ងៃនេះទៅសូមទ្រង់មេត្តាសូមព្រះភិក្ខុត្រឹមតែមួយអង្គមកសម្តែងធម៌ដល់ពួកនាងខ្ញុំម្ចាស់ ។ ព្រះរាជាស្តេចទៅសំណាក់ព្រះសាស្តា កាលនឹងទ្រង់សូម ក៏ទ្រង់សូមព្រះអានន្ទ-

ត្ថេរៈ ។ ចាប់តាំងពីនោះ ស្ត្រីទាំងនោះ ឲ្យនិមន្តព្រះថេរៈមក ហើយធ្វើសក្ការៈ គោរពរាប់អាន រៀនសូត្រធម៌ក្នុងសំណាក់ព្រះថេរៈ ពេលដែលលោកឆាន់ស្រេចហើយ ។ ថ្ងៃមួយ ស្ត្រីទាំងនោះ ជ្រះថ្លាក្នុងអនុមោទនារបស់ព្រះថេរៈ បានថ្វាយឧត្តរាសង្គៈ សំពត់ដណ្តប់ ៥០០ ផ្ទាំង ចំពោះព្រះថេរៈ ។ បានឮថា ក្នុងជាតិមុន ព្រះថេរៈបានថ្វាយចម្រៀកសំពត់លើបាតព្រះហស្ត ព្រមទាំងម្ជុលមួយដល់ព្រះ-បច្ចេកពុទ្ធមួយអង្គក្នុងវេលាដេរសំពត់ ។ ដោយផលរបស់ម្ជុល ព្រះថេរៈនោះ បានជាអ្នកមានបញ្ញាច្រើនក្នុងអត្តភាពនេះ ទាំងបានសំពត់ ៥០០ ផ្ទាំង តាមទំនងនេះ ដោយផលនៃចម្រៀកសំពត់ ។

បន្ទាប់ពីនោះ ព្រះនាងមាគណ្ឌិយាមិនឃើញកិច្ចដែលនឹងគប្បីធ្វើយ៉ាងដទៃ ទើបក្រាបទូលថា មហារាជ ពួកយើងនឹងទៅព្រះឧទ្យានជាមួយគ្នា ព្រះអង្គ ព្រះរាជាទ្រង់អនុញ្ញាតថា ល្អហើយ ទេវី ដូច្នេះ ព្រះនាងទើបឲ្យហៅមក ត្រាស់ថា វេលាពួកខ្ញុំទៅសួន (ព្) ចូរទៅកាន់ទីនៅរបស់ព្រះនាងសាមាវតី ឃាំងព្រះនាងសាមាវតី ព្រមទាំងបរិវារទុកខាងក្នុង ប្រាប់ថា ជាព្រះរាជបន្ទូលរបស់ព្រះរាជា ហើយបិទទ្វារ ឲ្យយកចំបើងមកគរទុក ហើយចូរដុតភ្លើងឲ្យឆេះនិវេសន៍នោះ ។ នាយមាគណ្ឌិយាស្តាប់ពាក្យព្រះនាងហើយ ក៏ធ្វើតាមដែលព្រះនាងបង្គាប់គ្រប់ប្រការ ។ ថ្ងៃនោះ ស្ត្រីទាំងអស់នោះមិនអាចចូលសមាបត្តិបាន ព្រោះអានុភាពរបស់ឧបបី-

ឡូកកម្មដែលធ្វើក្នុងជាតិមុន ក៏ឆេះស្លាប់ ដូចជាកម្មេចផេះព្រមគ្នានោះឯង ។ ពួកទាហានរក្សាស្ត្រីទាំងនោះ ក៏ទៅគាល់ក្រាបទូលថា បពិត្រទេវៈ អ្នកទាំងឡាយបានធ្វើកម្មឈ្មោះនេះ ។ ព្រះរាជាទ្រង់សើុបសួរទៀតថា អ្នកណាធ្វើ ក៏ទ្រង់ជ្រាបថា ព្រះនាងមាគណ្ឌិយាប្រើឲ្យមនុស្សធ្វើ ទើបត្រាស់បង្គាប់ឲ្យហៅព្រះនាងមកត្រាស់ថា នាងធ្វើកម្មបានល្អហើយ នាងធ្វើកម្មដែលយើងកំពុងនឹងធ្វើ នាងដ៏ចម្រើន សេចក្ដីព្យាយាមដើម្បីនឹងសម្លាប់យើង ដែលបង្ករឡើងម្ដងហើយ ម្ដងទៀត ត្រូវទម្លាយហើយ យើងនឹងឲ្យសម្បត្តិដល់នាង ចូរហៅពួកញាតិរបស់នាងមក ។ ព្រះនាងស្ដាប់ព្រះរាជតម្រាស់ហើយ ក៏ឲ្យហៅមនុស្សដែលមិនជាញាតិធ្វើឲ្យជាញាតិមកហើយ ។ ព្រះរាជាទ្រង់ជ្រាបថា អ្នកទាំងអស់ប្រជុំគ្នាហើយ ក៏ឲ្យជីករណ្ដៅកប់អ្នកទាំងនោះត្រឹមកត្រង់ព្រះលាន ហើយឲ្យទម្លាយសិរសៈដែលនៅសល់ដោយនង្គ័លដែកខ្នាតធំ ឲ្យកាត់ព្រះនាងមាគណ្ឌិយាជាចម្រៀកតូចៗ ឲ្យបោះចូលក្នុងខ្ទះខ្លាញ់ ។

សួរថា កម្មដែលព្រះនាងសាមាវតី និងបរិវារត្រូវភ្លើងឆេះ គឺ កម្មអ្វី ។

ឆ្លើយថា បានឮមក ព្រះនាងសាមាវតីនោះ កាលព្រះពុទ្ធមិនទាន់ឧប្បត្តិ បានលេងទឹកក្នុងស្ទឹងគង្គាជាមួយស្ត្រី ៥០០ នាក់នោះឯង ឈរក្រៅកំពង់ទឹក ក៏កើតភាពត្រជាក់ ឃើញបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធក្នុងទីមិនឆ្ងាយ មិនបាន

ពិនិត្យមើលខាងក្នុង ក៏ដុតភ្លើងនាំគ្នាអាំង ខាងក្នុងបណ្ណសាលាព្រះបច្ចេកពុទ្ធគង់ចូលសមាបត្តិ ។ ស្ត្រីទាំងនោះ កាលអណ្តាតភ្លើងទ្រោមចុះទើបឃើញ ព្រះបច្ចេកពុទ្ធ គិតគ្នាថា ពួកយើងធ្វើកម្មអ្វីហ្ន៎ ព្រះបច្ចេកពុទ្ធអង្គនេះ ទ្រង់ជាអ្នកប្រចាំរាជត្រកូល ព្រះរាជាទ្រង់ឃើញហេតុនេះហើយ ទ្រង់នឹងក្រោធដល់ពួកយើង ឥឡូវនេះ គួរពួកយើងនឹងឈាបនកិច្ចព្រះអង្គឲ្យបានរៀបរយចុះ ទើបដាក់ឧសដទៃៗដុតភ្លើង កាលអណ្តាតភ្លើងទ្រោមចុះទៀត ព្រះបច្ចេកពុទ្ធចេញចាកសមាបត្តិ រលាស់ចីវរហើយ ក៏ហោះឡើងកាន់វេហាស៍ ទាំងដែលស្ត្រីទាំងនោះមើលឃើញនុ៎ះឯង ។ ស្ត្រីទាំងនោះឆេះក្នុងនរកដោយកម្មនោះ ហើយក៏ដល់សេចក្តីវិនាសលើកនេះ ដោយកម្មដ៏សេសដែលទុំជោរហើយ ។ តែក្នុងបរិស័ទ ៤ កើតការសន្ទនាគ្នាឡើងថា នាងខុជ្ជុត្តរាដែលជាពហុស្សូត តាំងនៅក្នុងអត្តភាពជាស្ត្រី ពោលធម៌ដល់ស្ត្រី ៥០០ នាក់ ឲ្យតាំងនៅក្នុងសោតាបត្តិផល ចំណែកព្រះនាងសាមាវតីផ្សាយមេត្តា ហាមកូនធ្នូដែលព្រះរាជាទ្រង់ក្រោធចំពោះខ្លួនបាន ។ មហាជនក៏ពោលគុណរបស់ព្រះនាង ។ រឿងដែលកើតឡើងយ៉ាងនេះ ។ តមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនវិហារ ទ្រង់ធ្វើហេតុនោះឯងឲ្យជាអត្ថុប្បត្តិ ហើយទ្រង់ស្ថាបនានាងខុជ្ជុត្តរាទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងឧបាសិកាអរិយសាវិកាដែលជាពហុស្សូត ទ្រង់ស្ថាបនាព្រះនាងសាមាវតីទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងឧបាសិកាអ្នកមាន

*ប្រក្រតីនៅដោយមេត្តា ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៣-៤

# អដ្ឋកថាសូត្រទី ៥

## ប្រវត្តិនាងឧត្តរានន្ទមាតា

*ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ៖*

[១៥២] *ដោយបទថា* **ឈាយីនំ** *លោកសម្តែងថា នាងឧត្តរានន្ទមាតា ប្រសើរបំផុតលើពួកឧបាសិកាអ្នកត្រេកអរក្នុងឈាន ។ ដូចបានស្តាប់មក នាងឧត្តរានោះ គ្រាព្រះពុទ្ធព្រះនាមថា* **បទុមុត្តរៈ** *កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី ស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរបំផុតជាងពួកឧបាសិកាសាវិកាអ្នកត្រេកអរក្នុងឈាន ធ្វើកុសលឲ្យក្រៃលែងឡើងទៅ ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតានិងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងគភ៌របស់កិរិយាបុណ្ណសេដ្ឋី[១] ដែលអាស្រ័យសុមនសេដ្ឋី នៅក្នុងក្រុងរាជគ្រឹះ ។ បិតាមាតាតាំងឈ្មោះនាងថា* **ឧត្តរា** *។ ក្នុងថ្ងៃធ្លងនក្ខត្តប្ញក្សមួយ រាជគហសេដ្ឋីហៅនាយបុណ្ណៈមកពោលថា បុណ្ណៈ នក្ខត្តឫក្ស ឬឧបោសថ នឹងធ្វើអ្វីដល់បុគ្គលក្រលំបាកបាន អ្នកចូរប្រាប់មកថា អ្នកនឹងទទួលបានតម្លៃចាយវាយក្នុងនក្សត្រឫក្ស ហើយលេង*

---

១ *កូមា : បុណ្ណសីហស្ស នាម របស់បុរសឈ្មោះបុណ្ណសីហៈ ។*

នក្ខត្តឫក្ស ឬនឹងនាំគោមានកម្លាំង និងនង្គ័លទៅភ្ជួរស្រែ នាយបុណ្ណៈពោលថា លោកម្ចាស់ ខ្ញុំនឹងប្រឹក្សាជាមួយភរិយាជាមុនទើបដឹង ហើយប្រាប់រឿងនោះដល់ភរិយា ។ ភរិយាគេពោលថា ធម្មតាសេដ្ឋីជា លោកជាឥស្សរជន ពាក្យនិយាយរបស់គេដែលពោលជាមួយលោក រមែងពិត ចំណែកលោកកុំលះបង់ការធ្វើស្រែរបស់ខ្លួនឡើយ ។ នាយបុណ្ណៈនោះស្តាប់ពាក្យភរិយាហើយ ក៏ទៅដើម្បីនាំសំភារៈសម្រាប់ភ្ជួរស្រែ ។ ក្នុងថ្ងៃនោះ ព្រះសារីបុត្តត្ថេរ ចេញពីនិរោធសមាបត្តិ នឹកថាថ្ងៃនេះ យើងគួរនឹងធ្វើការសង្គ្រោះនរណា ក៏ឃើញឧបនិស្ស័យរបស់នាយបុណ្ណៈក្នុងវេលាស្វែងរកអាហារ ទើបកាន់បាត្រចីវរទៅកាន់ទីដែលនាយបុណ្ណៈភ្ជួរស្រែគង់ឈរក្នុងទីមិនឆ្ងាយ ។ នាយបុណ្ណៈឃើញព្រះថេរៈក៏ឈប់ភ្ជួរស្រែ ដើរទៅរកព្រះថេរៈ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ ព្រះថេរៈក្រឡេកមើលគេហើយសួរដល់ទឹកដែលប្រើបាន ។ គេគិតថា ភិក្ខុអង្គនេះនឹងត្រូវការខ្ទាមាត់ ទើបប្រញាប់ទៅពីទីនោះ នាំឈើស្ទន់មក ធ្វើឲ្យជាកប្បិយៈហើយប្រគេនព្រះថេរៈ កាលព្រះថេរៈកំពុងជម្រះធ្មេញ ក៏នាំធម្មក្រក និងបាត្រចេញទៅដាក់ទឹកពេញ ហើយនាំមកព្រះថេរៈក៏ខ្ទាមាត់ ធ្វើដំណើរស្វែងរកអាហារ ។

នាយបុណ្ណៈគិតថា ព្រះថេរៈមិនធ្វើដំណើរផ្លូវនេះក្នុងថ្ងៃដទៃៗ តែថ្ងៃនេះនឹងធ្វើដំណើរដើម្បីសង្គ្រោះយើង ឱហ្ន៎ ! ភរិយារបស់យើងគប្បីបានដាក់អាហារ

ដែលនឹងនាំមកឲ្យយើងទៅក្នុងបាត្រព្រះថេរៈចុះ ។ គ្រានោះ កិរិយារបស់គេគិតថា ថ្ងៃនេះ ជាថ្ងៃនក្ខត្តឫក្ស ទើបចាត់ចែងរបស់ទំពារ របស់បរិភោគ ដោយទំនងដែលខ្លួនបានពីព្រឹកព្រលឹម មកកាន់ទីដែលស្វាមីភ្ជួរស្រែ ក្នុងចន្លោះផ្លូវ ជួបព្រះថេរៈទើបគិតថា យើងជួបព្រះថេរៈក្នុងថ្ងៃដទៃៗ ទេយ្យធម៌មិនមាន សូម្បីកាលមានទេយ្យធម៌ យើងក៏មិនជួបបដិគ្គាហកៈ តែថ្ងៃនេះ ទាំងពីរយ៉ាងមានព្រមចំពោះមុខហើយ ចាំយើងចាត់ចែងចំណែករបស់ស្វាមីនាំមកជាថ្មី នឹងថ្វាយអាហារចំណែកនេះចំពោះព្រះថេរៈជាមុន ធ្វើទានឲ្យប្រកបដោយចេតនាទាំង ៣ ហើយដាក់ភោជននោះក្នុងបាត្រព្រះសារីបុត្តត្ថេរ ហើយពោលថា សូមឲ្យខ្ញុំម្ចាស់បានរួចផុតពីជីវិតលំបាកក្រីក្រក្នុងលោកនេះ ដោយទាននេះចុះ លោកម្ចាស់ ។ សូម្បីព្រះថេរៈក៏ធ្វើអនុមោទនាដល់នាងថា សូមអធ្យាស្រ័យរបស់នាងចូរពេញចុះ ត្រឡប់ពីទីនោះហើយ ក៏ទៅវិហារ ។ សូម្បីនាងក៏ត្រឡប់ទៅកាន់ផ្ទះខ្លួនវិញ ហើយចាត់ចែងរកអាហារសម្រាប់ស្វាមី នាំទៅកាន់ទីដែលស្វាមីភ្ជួរស្រែ ខ្លាចស្វាមីក្រោធ ទើបពោលថា នាយ ថ្ងៃនេះសូមនាយចូរអត់ទ្រាំម្តងចុះ ។ គេសួរថា ព្រោះអ្វី ។ នាងឆ្លើយថា ថ្ងៃនេះខ្ញុំកំពុងនាំអាហារមកសម្រាប់នាយ ក្នុងរវាងផ្លូវជួបព្រះថេរៈ ទើបដាក់អាហារចំណែករបស់នាយក្នុងបាត្រព្រះថេរៈ ហើយបានត្រឡប់ទៅផ្ទះវិញ ដាំស្លអាហារជាថ្មី ទើបនាំមកក្នុងពេលឥឡូវនេះ ។ គេពោលថា ប្អូនអើយ នាងធ្វើត្រូវ

ចិត្តខ្ញុំហើយៗ សូម្បីខ្ញុំ ក៏ថ្វាយឈើជំរះធ្មេញ និងទឹកខ្ពុរមាត់ចំពោះព្រះថេរៈតាំង ពីព្រឹកព្រលឹម ថ្ងៃនេះ ជាជោគរបស់យើងពិតៗ សូម្បីរបស់ទាំងអស់ដែលយើង ប្រគេនព្រះថេរៈ ក៏កើតជាសម្បត្តិរបស់យើងនោះឯង ទាំងពីរនាក់ ក៏មានចិត្តដូច គ្នាតែមួយ ។

គ្រានោះ នាយបុណ្ណៈបរិភោគអាហារស្រេចហើយ ក៏យកសិរសះកើយ ភ្លៅភរិយា ដេកមួយស្របក់ ។ ខណៈនោះគេក៏លក់ទៅ ។ គេលក់បានបន្តិច ហើយ ក៏ភ្ញាក់ សម្លឹងមើលទីដែលភ្ជួរស្រែ សម្លឹងមើលហើយសម្លឹងមើលទៀត ក៏ឃើញ ដូចជាពេញទៅដោយផ្កានោនព្រៃខ្នាតធំ ។ គេទើបនិយាយនឹងភរិយាថា ប្អូនអើយ នោះជាអ្វី ថ្ងៃនេះទីដែលភ្ជួរនេះ ប្រាកដជាមាសបានឬ ។ ភរិយានិយាយថា នាយ ថ្ងៃនេះ ព្រោះនាយនឿយហត់អស់មួយថ្ងៃ ប្រហែលជាភ្នែកព្រិលទៅក៏បាន ។ គេ និយាយថា ប្អូនអើយ នាងមិនជឿ ក៏មើលខ្លួនឯងចុះ ។ វេលានោះ ភរិយាសម្លឹង មើលហើយក៏និយាយថា នាយនិយាយពិត នោះគង់នឹងជាដូច្នោះ ។ នាយបុណ្ណៈ ក្រោកឡើងចាប់កំណាត់ឈើវាយត្រង់ក្បាលដីអាចម៍បំណះ ។ ដីអាចម៍បំណះ ក៏ដូច ជាគ្រាប់មូលៗ កប់ចូលទៅក្នុងដីអាចម៍បំណះ ដូច្នោះ ។ គេហៅភរិយាមក ពោល ថា ប្អូនអើយ កាលអ្នកដទៃៗ សាបព្រោះគ្រាប់ពូជ ពូជក៏នឹងឲ្យផល ៣-៤ ខែ ចំណែកផលទានដែលឲ្យក្នុងថ្ងៃនេះ ក៏ដោយពូជ គឺ សទ្ធា ដែលយើងនឹងដាំចុះក្នុង

ព្រះសារីបុត្តត្រេរជាម្ចាស់របស់យើង ។ ក្នុងផ្ទៃដីប្រមាណមួយករីសៈនេះ ដីសូម្បី ប្រមាណប៉ុនផ្លែកន្ទួតព្រៃ ឈ្មោះថា មិនមែនមាស មិនមានឡើយ ។ ភរិយាពោល ថា នាយ ឥឡូវនេះយើងនឹងធ្វើយ៉ាងណាហ្ន៎ ។ នាយបុណ្ណៈនិយាយថា ប្អូនអើយ យើងមិនអាចនាំមាសប៉ុណ្ណេះទៅប្រើប្រាសបានទេ ហើយដាក់មាសពេញក្នុងថាស ដែលភរិយានាំមកទុកក្នុងទីនោះ ឲ្យភរិយានាំទៅក្រាបទូលព្រះរាជាថា មនុស្សម្នាក់ ឈរកាន់ថាសដាក់មាស ព្រះអង្គ ។ ព្រះរាជាត្រាស់បង្គាប់ ឲ្យហៅគេចូលទៅ ត្រាស់សួរថា បា អ្នកបានមកពីទីណា ។ គេក្រាបទូលថា បពិត្រទេវៈ ទីដែលខ្ញុំ ព្រះអង្គភ្ជួរស្រែមួយកន្លែង សូមទ្រង់មេត្តាប្រោសបញ្ជូនមនុស្សទៅ ឲ្យជីកមាស ដែលកើតហើយទាំងអស់មក ព្រះអង្គ ។ ត្រាស់សួរថា អ្នកឯងឈ្មោះអ្វី ។ ទូល តបថា ឈ្មោះថា បុណ្ណៈ ព្រះអង្គ ។ ត្រាស់បង្គាប់ថា នាយ ពួកអ្នកចូរទៅទឹមរទេះ ជីកមាសពីទីដែលនាយបុណ្ណៈភ្ជួរស្រែ ។ ពួករាជបុរសទៅជាមួយពួករទេះ ពោល ថា ជាបុណ្យរបស់ព្រះរាជា ក៏កាន់យកដុំមាសទៅ ។ ដុំមាសដែលកាន់យកនោះ ក៏ប្រែជាដុំដីអាចម៍បំណះវិញ ។ រាជបុរសទាំងនោះទៅក្រាបទូលព្រះរាជា ។ ព្រះ រាជាត្រាស់ថា នាយ បើដូច្នោះ ពួកអ្នកចូរទៅពោលថា ជាបុណ្យរបស់នាយបុណ្ណៈ ហើយកាន់យកមក ។ វត្ថុដែលគេកាន់យក ក៏ជាមាសទាំងអស់នោះ ។ រាជបុរស ទាំងនោះ ក៏នាំមាសទាំងអស់នោះមកគរទុកត្រង់ព្រះលាន ។ គំនរខ្ពស់ប្រមាណ

ស្មើដើមត្នោត ។ ព្រះរាជាទ្រង់ឲ្យហៅពួកឈ្មួញមក ត្រាស់សួរថា ក្នុងផ្ទះណាមាន មាសប៉ុណ្ណេះខ្លះ ។ ពួកឈ្មួញក្រាបទូលថា មហាបពិត្រ របស់នរណាៗ ក៏មិនមាន ព្រះអង្គ ។ ត្រាស់ប្រឹក្សាថា យើងគួរនឹងធ្វើអ្វីដល់ម្ចាស់របស់ទ្រព្យប៉ុណ្ណេះហ្ន៎ ក្រាប ទូលថា គួរតាំងគេជាធនសេដ្ឋីចុះ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ពួក អ្នកចូរតែងតាំងបុណ្ណៈ ឈ្មោះថា **ធនសេដ្ឋី** ក្នុងព្រះនគរនេះ ។ ហើយព្រះរាជ-ទានរបស់ទាំងអស់នោះដល់នាយបុណ្ណៈនោះ និងព្រះរាជទានតំណែងសេដ្ឋីដល់គេ ក្នុងថ្ងៃនោះឯង ។ សេដ្ឋីនោះ កាលធ្វើមង្គល ក៏បានថ្វាយទានចំពោះព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ។ ក្នុងថ្ងៃទី ៧ កាលព្រះទសពលទ្រង់ធ្វើអនុមោទនា ក្នុងភត្តទានរបស់បុណ្ណសេដ្ឋីក្តី ភរិយាក្តី ធីតាក្តី ទាំងអស់គ្នាក៏តាំងនៅក្នុងសោតា-បត្តិផល ។

ក្រោយមក រាជគហសេដ្ឋីជ្រាបថា បុណ្ណសេដ្ឋីមានធីតាចម្រើនវ័យហើយ ទើបបញ្ជូនដំណឹងទៅកាន់ផ្ទះរបស់បុណ្ណសេដ្ឋីនោះ សូមធីតាដើម្បីបុត្ររបស់ខ្លួន ។ បុណ្ណសេដ្ឋី ទទួលដំណឹងរាជគហសេដ្ឋីហើយ ក៏បញ្ជូនដំណឹងតបទៅថា យើងមិន ឲ្យធីតាទេ ។ ចំណែកសុមនសេដ្ឋី (រាជគហសេដ្ឋី) បញ្ជូនដំណឹងទៅទៀតថា លោក អាស្រ័យផ្ទះយើងហើយ ឥឡូវនេះ ក៏ជាឥស្សរជនក្នុងពេលភ្លាមៗ មិនឲ្យធីតាដល់ យើងឬ ។ ពេលនោះ បុណ្ណសេដ្ឋីក៏ឆ្លើយថា លោកនិយាយដល់សភាពសេដ្ឋីរបស់

លោកមុនប៉ុណ្ណោះ ឈ្មោះថា បុរស លោកមិនគួរកំណត់យកថា ត្រូវតែយ៉ាងនេះ រហូតអស់កាលនោះទេ សេចក្ដីពិត យើងអាចទទួលយកពួកបុរសដូច្នោះ ធ្វើជាទាសៈ ក៏បាន តែយើងមិនអាចឈោងដល់ជាតិ និងគោត្ររបស់លោកបានទេ ។ ម្យ៉ាងទៀត ធីតារបស់យើង ក៏ជាអរិយសាវិកាជាព្រះសោតាបន្ន ធ្វើការបូជាដោយផ្កាឈើមានតម្លៃច្រើនកហាបណៈរាល់ៗ ថ្ងៃ យើងនឹងមិនបញ្ជូនធីតាទៅផ្ទះមនុស្សមិច្ឆាទិដ្ឋិដូចលោក ។ រាជគហសេដ្ឋីដឹងថា បុណ្ណសេដ្ឋីបដិសេធយ៉ាងនោះ ក៏បញ្ជូនដំណឹងទៅទៀតថា មេត្តាកុំទម្លាយសេចក្ដីស្និទ្ធស្នាលចាស់ៗ ចេញឡើយ យើងនឹងឲ្យចាត់ចែងផ្កាឈើមានតម្លៃ ២ កហាបណៈរាល់ៗ ថ្ងៃ ដល់កូនប្រសាររបស់យើង ។ បុណ្ណសេដ្ឋី ក៏ឆ្លើយទទួល ហើយបញ្ជូនធីតាទៅផ្ទះរបស់រាជគហសេដ្ឋីនោះ ។

តមកថ្ងៃមួយ នាងឧត្តរាធីតារបស់បុណ្ណសេដ្ឋីនោះ ក៏ពោលនឹងស្វាមីរបស់ខ្លួនយ៉ាងនេះថា ខ្ញុំធ្វើឧបោសថកម្មជាប្រចាំមួយខែ ៨ ថ្ងៃ ក្នុងផ្ទះរបស់ខ្លួន សូម្បីឥឡូវនេះ បើលោកឲ្យការយល់ព្រមបាន ខ្ញុំនឹងអធិដ្ឋានអង្គនៃឧបោសថ ។ ស្វាមីនោះពោលថា ខ្ញុំយល់ព្រមមិនបាន ហើយក៏មិនទទួលពាក្យ ។ នាងមិនអាចញ៉ាំងស្វាមីនោះឲ្យយល់ព្រមបាន ក៏នៅស្ងៀម គិតថា យើងនឹងអធិដ្ឋានអង្គឧបោសថខាងក្នុងវស្សាទៀត សូម្បីពេលនោះ កាលនាងសូមឱកាស ក៏មិនបានឱកាសទៀតទុំះឯង ។ ខាងក្នុងវស្សាកន្លងទៅ ២ ខែ លុះនៅសល់កន្លះខែ នាងទើបបញ្ជូនដំណឹង

ទៅប្រាប់បិតាមាតាថា ខ្ញុំត្រូវលោកពុកអ្នកម៉ែបញ្ជូនទៅយាំងទុកក្នុងទី ឃុំឃាំងអស់កាលដ៏យូរហើយ សូម្បីអធិដ្ឋានអដ្ឋង្គឧបោសថអស់ថ្ងៃមួយក៏មិនបាន សូមមេត្តាបញ្ជូនកហាបណៈដល់ខ្ញុំ ១៥.០០០ កហាបណៈចុះ ។ បិតាមាតាស្តាប់ដំណឹងធីតាហើយក៏មិនសួរថា ព្រោះហេតុអ្វី បានឲ្យបញ្ជូនប្រាក់ទៅ ។ នាងឧត្តរាទទួលកហាបណៈទាំងនោះហើយ ។ មានស្រីសោភិណីឈ្មោះ **សិរិមា** នៅក្នុងនគរនោះ ទើបឲ្យហៅនាងមក ហើយពោលថា នាងសិរិមា ខ្ញុំនឹងអធិដ្ឋានអដ្ឋង្គឧបោសថអស់កន្លះខែនេះ សូមនាងចូរទទួលកហាបណៈ ១៥.០០០ ទាំងនេះចុះ ហើយបម្រើសេដ្ឋីបុត្រហូតអស់កន្លះខែនេះ ។ នាងសិរិមាក៏ទទួលថា ល្អហើយនាងម្ចាស់ ។ តាំងពីនោះមក សេដ្ឋីបុត្រគិតថា យើងនឹងសប្បាយជាមួយនាងសិរិមា ទើបអនុញ្ញាតឲ្យនាងឧត្តរាទទួលឧបោសថកម្មអស់កន្លះខែ ។ នាងឧត្តរាដឹងថា ស្វាមីយល់ព្រមហើយ មានពួកទាសីហែហម ចាត់ចែងរបស់ទំពាររបស់ឆាន់ដោយដៃខ្លួនឯង ពីព្រឹកព្រលឹមរាល់ៗ ថ្ងៃ កាលព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ស្តេចយាងទៅវិហារ ក៏អធិដ្ឋានអដ្ឋង្គឧបោសថ ឡើងប្រាសាទដ៏ប្រសើរ អង្គុយរឭកដល់សីលរបស់ខ្លួន ។ កន្លងវេលាទៅកន្លះខែដោយអាការយ៉ាងនេះ ក្នុងថ្ងៃមិនបានសមាទានឧបោសថ នាងទើបត្រាច់ទៅចាត់ចែងបាយយាគូ និងរបស់ទំពារជាដើម អំពីព្រឹក ។

វេលានោះ សេដ្ឋីបុត្រនៅលើប្រាសាទដ៏ប្រសើរជាមួយនាងសិរិមា បើក

បន្ទួចដែលមានចម្រឹង ឈរមើលវត្ថុទៅតាមលំដាប់ នាងឧត្តរាងើយមើលទៅត្រង់បន្ទួច ឯសេដ្ឋីបុត្រក៏សម្លឹងមើលនាងឧត្តរា គិតថា ស្រីនេះគង់នឹងមានកំណើតមកពីសត្វនរក ដែលលះបង់សម្បត្តិបែបនេះហើយ ជាអ្នកប្រឡាក់ប្រឡូសដោយធូលីផ្ទាំង ខ្វល់ខ្វាយជាមួយទាសីទាំងឡាយដែលមិនគួរដល់ហេតុ ហើយធ្វើការទាំងរីករាយ ។ នាងឧត្តរាជ្រាបសេចក្ដីដែលសេដ្ឋីបុត្រនោះប្រមាទ គិតថា សេដ្ឋីបុត្រនេះឈ្មោះថា ជាអ្នកល្ងង់ខ្លៅ ដែលសម្គាល់ថា សម្បត្តិរបស់ខ្លួននឹងស្ថិតស្ថេរគ្រប់វេលា ដូច្នេះ សូម្បីខ្លួនឯងក៏មានការរីករាយទៅកើត ។ តពីនោះ នាងសិរីមាក៏ក្រោធហើយជេរថា នាងទាសីម្នាក់នេះ កាលយើងឈរក៏ហ៊ានញញឹមជាមួយស្វាមីរបស់យើងយ៉ាងនេះ ទើបប្រញាប់ចុះពីប្រាសាទ ។ ដោយអាកប្បកិរិយាដែលមករបស់នាងសិរីមានោះឯង នាងឧត្តរាក៏ជ្រាបថា ស្រីល្ងង់នេះ នៅក្នុងផ្ទះនេះត្រឹមតែកន្លះខែ ក៏កើតសេចក្ដីសម្គាល់ថា ផ្ទះនេះជារបស់ខ្លួន ដូច្នេះ ក្លាមនោះឯងក៏ឈរចូលឈានមានមេត្តាជាអារម្មណ៍ ។ ចំណែកនាងសិរីមា ក៏មកក្នុងរវាងទាសីទាំងឡាយចាប់ចោយពេញដោយប្រេងដែលក្ដៅ ក្នុងខ្វះបង់នំ ស្រោចលើសរីសៈនាងឧត្តរា ។ ដោយការផ្សាយមេត្តាឈាន ប្រេងក្ដៅដែលនាងសិរីមាស្រោចលើសរីសៈនាងឧត្តរាក៏ត្រឡប់ទៅដូចជាទឹកដែលស្រោចលើស្លឹកឈូកដូច្នោះ ។

ខណៈនោះ ទាសីទាំងឡាយដែលឈរជិតនាងសិរីមា ឃើញហេតុការណ៍

នោះហើយ ក៏ដើរនាងសិរីមានោះចំពោះមុខថា អើ នាងដ៏ចម្រើន នាងទទួលតម្លៃ អំពីដៃនាងម្ចាស់របស់យើង មកនៅក្នុងផ្ទះនេះ ក៏ព្យាយាមមកជោយទំនៀមជាម្ចាស់របស់ពួកខ្ញុំឬ ។ ខណៈនោះ នាងសិរីមាដឹងថា តួជាអាគន្តុកៈមកនៅមួយរយៈ ក៏ទៅពីទីនោះហើយ ក្រាបចុះទៀបជើងនាងឧត្តរា ពោលថា នាងម្ចាស់ ខ្ញុំមិនបាន ពិចារណាក៏ធ្វើកម្មយ៉ាងនេះ មេត្តាលើកទោសឲ្យខ្ញុំផង ។ នាងឧត្តរា ពោលថា នាងសិរីមា ខ្ញុំលើកទោសឲ្យនាងក្នុងឋានៈនេះមិនបានទេ ខ្ញុំជាធីតា មានបិតា នឹង លើកទោសឲ្យ ក៏កាលព្រះទសពលទ្រង់លើកទោសឲ្យនាងប៉ុណ្ណោះ ។

សូម្បីព្រះសាស្តាមានភិក្ខុសង្ឃជាបរិវារ ក៏ស្តេចមកប្រថាប់លើអាសនៈ ដែលចាត់ចែងទុកក្នុងនិវេសន៍របស់នាងឧត្តរា ។ នាងសិរីមាទើបទៅក្រាបទៀប ព្រះយុគលបាទព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្វើ កំហុសមួយក្នុងចំពោះនាងឧត្តរា នាងពោលថា កាលបើព្រះអង្គទ្រង់លើកទោស យើងក៏នឹងលើកទោសឲ្យ បពិត្រព្រះមានព្រះភាគ សូមព្រះអង្គប្រោសប្រទានទោស ដល់ខ្ញុំព្រះអង្គ ដែលខមាទោសផងចុះ ។ ព្រះមានព្រះភាគត្រាស់ថា សិរីមា តថាគត លើកទោសឲ្យនាង ។ វេលានោះ នាងសិរីមានោះ ក៏ទៅសូមឲ្យនាងឧត្តរាលើក ទោសឲ្យ ។ ក្នុងថ្ងៃនោះ នាងសិរីមាស្តាប់អនុមោទនាកត្ថាទានរបស់ព្រះទសពលថា

អក្កោធេន ជិនេ កោធំ  អសាធុំ សាធុនា ជិនេ

*ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។*

*គប្បីឈ្នះបុគ្គលក្រោធដោយសេចក្តីមិនក្រោធ គប្បីឈ្នះ*

*បុគ្គលមិនល្អដោយសេចក្តីល្អ គប្បីឈ្នះបុគ្គលកំណាញ់*

*ដោយការឲ្យ គប្បីឈ្នះបុគ្គលនិយាយកុហកដោយពាក្យពិត ។*

*កាលចប់ព្រះគាថា នាងសិរិមាក៏តាំងនៅក្នុងសោតាបត្តិផល និមន្តព្រះទស-ពលថ្វាយមហាទានក្នុងថ្ងៃស្អែក រឿងនេះកើតឡើងយ៉ាងនេះ ។ ខាងក្រោយមកព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនានាង* ***ឧត្តរានន្ទមាតា*** *ទុកក្នុងតំណែងឯតទគ្គៈប្រសើរជាងពួកឧបាសិកាអ្នកចូលឈាន ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## "ប្រវត្តិព្រះនាងសុប្បវាសាកោលិយធីតា"

*ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៥២] *បទថា* ***អ្នកថ្វាយរបស់មានរសដ៏ប្រណីត (បណីតទាយិកានំ)*** *ទ្រង់សម្តែងថា ព្រះនាងសុប្បវាសា កោលិយធីតា ប្រសើរជាងពួកឧបាសិកាអ្នកថ្វាយរបស់មានរសប្រណីត ។*

*ដូចបានស្តាប់មក ព្រះនាងសុប្បវាសា កោលិយធីតានោះ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី កំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាមួយនាក់ ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកថ្វាយរបស់មានរសប្រណីត បានធ្វើកុសលឲ្យក្រៃលែង ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលក្សត្រ នានគរកោលិយៈ ។ ព្រះញាតិតាំងព្រះនាមព្រះនាងថា* ***សុប្បវាសា*** *ទ្រង់ចម្រើនវ័យហើយ អភិសេកជាមួយសក្យកុមារមួយព្រះអង្គ ត្រឹមតែការចូលគាល់គ្រាដំបូងប៉ុណ្ណោះ ស្តាប់ធម្មកថារបស់ព្រះសាស្តា ក៏តាំងនៅក្នុងសោតាបត្តិផល តមក ព្រះនាងប្រសូត*

ព្រះឱរស ព្រះនាមថា **សីវលី** ។ រឿងរបស់ព្រះសីវលីនោះ ពោលទុកពិស្តារហើយ ក្នុងខាងក្រោយ ។ ថ្ងៃមួយ ព្រះនាងថ្វាយភោជនដ៏ប្រណីតមានរសប្រសើរបំផុតផ្សេងៗ ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្ដាសោយស្រេចហើយ កាលទ្រង់អនុមោទនា ទ្រង់ត្រាស់សម្ដែងធម៌នេះដល់ព្រះនាងសុប្បវាសាថា ម្នាលសុប្បវាសា អរិយសាវិកាអ្នកថ្វាយភោជន ឈ្មោះថា ឲ្យឋានៈទាំង ៥ ដល់ពួកបដិគ្គាហកៈ គឺ ឲ្យអាយុ ឲ្យវណ្ណៈ ឲ្យសុខៈ ឲ្យពលៈ ឲ្យបដិភាណៈ ។ អ្នកឲ្យអាយុ រមែងជាអ្នកមានចំណែកនៃអាយុ ទាំងដែលជារបស់ទិព្វ ទាំងដែលជារបស់មនុស្ស ។ល។ អ្នកឲ្យបដិភាណៈ រមែងជាអ្នកមានចំណែកនៃបដិភាណៈ ទាំងដែលជារបស់ទិព្វ ទាំងដែលជារបស់មនុស្ស រឿងនេះកើតឡើងយ៉ាងនេះ ។ តមកខាងក្រោយ ព្រះសាស្ដាប្រថាប់ក្នុងព្រះជេតវនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះនាងសុប្បវាសាកោលិយធីតាទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាសាវិកា អ្នកថ្វាយរបស់មានរសប្រណីត ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## "ប្រវត្តិនាងសុប្បិយាឧបាសិកា"

*ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៥២] បទថា* ***គិលានុបដ្ឋាកានំ*** *ទ្រង់សម្តែងថា នាងសុប្បិយាឧបាសិកា ប្រសើរជាងពួកឧបាសិកាអ្នកឧបដ្ឋាកភិក្ខុឈឺ ។*

*ដូចបានស្តាប់មក នាងសុប្បិយាឧបាសិកានេះ សម័យព្រះពុទ្ធព្រះនាមថា* ***បទុមុត្តរៈ*** *កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី តមក កំពុងស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាមួយនាក់ ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកឧបដ្ឋាកភិក្ខុឈឺ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្បក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូល ក្នុងក្រុងពារាណសី ។ បិតាមាតាទើបតាំងឈ្មោះនាងថា* ***សុប្បិយា*** *។ តមកព្រះសាស្តា មានភិក្ខុសង្ឃជាបរិវារ ស្តេចយាងទៅក្រុងពារាណសី ។ ដោយការគាល់គ្រាដំបូងប៉ុណ្ណោះ នាងស្តាប់ធម៌ហើយតាំងនៅក្នុងសោតាបត្តិផល ។ ថ្ងៃមួយ នាងទៅព្រះវិហារដើម្បីស្តាប់ធម៌ ចារិកទៅក្នុងព្រះវិហារ ជួបភិក្ខុឈឺមួយរូប ថ្វាយបង្គំហើយ ធ្វើការក្រោកទទួល សួរថា លោក*

ម្ចាស់គួរនឹងបានអ្វី ភិក្ខុឈឺឆ្លើយថា ឧបាសិកា គួរបានអាហារមានរស (សាច់) ។ នាងពោលថា ណ្ហើយចុះ លោកម្ចាស់ ខ្ញុំនឹងបញ្ជូនទៅថ្វាយ ថ្វាយបង្គំព្រះថេរៈ ហើយ ចូលទៅក្នុងក្រុង ។ ថ្ងៃស្អែក ក៏បញ្ជូនទាសីទៅផ្សារ ដើម្បីត្រូវការបវត្ត-មំសៈ (សាច់ដែលលក់ក្នុងផ្សារ) ។ ទាសីនោះរកបវត្តមំសៈទូទាំងក្រុងក៏មិនបាន ក៏ប្រាប់នាងថា មិនបានទេ ។ ឧបាសិកាគិតថា យើងប្រាប់ដល់លោកម្ចាស់ថា នឹងបញ្ជូនសាច់ទៅប្រគេន បើយើងមិនបញ្ជូនទៅ លោកម្ចាស់ កាលមិនបានពីទីដទៃ ក៏នឹងលំបាក គួរយើងនឹងធ្វើសាច់យ៉ាងណាមួយបញ្ជូនទៅប្រគេន ហើយក៏ចូលបន្ទប់ អារសាច់ជើងឲ្យដល់ទាសី ប្រាប់ថា នាងចូរយកសាច់នេះផ្សំដោយគ្រឿងផ្សំ នាំទៅវិហារប្រគេនលោកម្ចាស់ បើលោកសួរដល់យើង ក៏ចូរប្រាប់ថាឈឺ ។ ទាសីនោះ ក៏បានធ្វើយ៉ាងនោះ ។

ព្រះសាស្តាទ្រង់ជ្រាបហេតុនោះ ស្អែកឡើង វេលាភិក្ខាចារ ក៏មានភិក្ខុសង្ឃជាបរិវារ ស្តេចទៅផ្ទះរបស់ឧបាសិកា ។ នាងជ្រាបថា ព្រះតថាគតស្តេចមក ទើបប្រឹក្សាជាមួយស្វាមីថា លោកប្តី ខ្ញុំមិនអាចទៅគាល់ព្រះសាស្តាបាន បងចូរទៅក្រាបទូល អារាធនាព្រះសាស្តាឲ្យស្តេចយាងចូលផ្ទះ ហើយឲ្យប្រថាប់គង់ចុះ ។ ស្វាមីនោះក៏បានធ្វើយ៉ាងនោះ ។ ព្រះសាស្តាត្រាស់សួរថា សុប្បិយាទៅណា ។ ស្វាមីក្រាបទូលថា នាងឈឺ ព្រះអង្គ ។ ទ្រង់ត្រាស់ថា ចូរហៅ នាងមក លំដាប់

នោះ មនុស្សទាំងឡាយទៅប្រាប់ថា ព្រះសាស្តាទ្រង់ឲ្យហៅ ។ នាងគិតថា ព្រះសាស្តាទ្រង់សង្គ្រោះដល់មនុស្សលោកទាំងពួង ទ្រង់ជ្រាបហេតុរបស់យើង ទើបឲ្យហៅ ក៏ក្រោកឡើងពីគ្រែយ៉ាងឆាប់រហ័ស ។ គ្រានោះ ដោយពុទ្ធានុភាព ដំបៅ (ដែលអារសាច់ភ្លៅ) របស់នាង ក៏ដុះឡើងរំពេចនោះ ស្បែកក៏រាបស្មើ ពណ៌សម្បុរថ្លាផូរផង់ដូចដើម ។ ខណៈនោះ ឧបាសិកាក៏ញញឹមញញែម ថ្វាយបង្គំព្រះទសពលដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងដ៏សមគួរមួយ ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ឧបាសិកានេះ មិនសប្បាយព្រោះហេតុអ្វី ទើបត្រាស់សួរ នាងបានទូលរឿងដែលខ្លួនធ្វើគ្រប់យ៉ាងថ្វាយ ។ ព្រះសាស្តាសោយស្រេចហើយ ស្តេចទៅព្រះវិហារ ទ្រង់ប្រជុំភិក្ខុសង្ឃ ហើយទ្រង់តិះដៀលភិក្ខុនោះយ៉ាងច្រើន ទើបទ្រង់បញ្ញត្តិសិក្ខាបទ ។ រឿងនេះកើតឡើងយ៉ាងនេះ ។ ខាងក្រោយមក ព្រះសាស្តាប្រថាប់ក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនានាងសុប្បិយាឧបាសិកាទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកឧបដ្ឋាកភិក្ខុឈឺ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## ប្រវត្តិនាងកាតិយានី

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥២] ក្នុងបទថា **អវេច្ចប្បសន្នានំ** ទ្រង់សម្ដែងថា នាងកាតិយានី ប្រសើរជាងពួកឧបាសិកាអ្នកប្រកបដោយសេចក្ដីជ្រះថ្លាដ៏មុតមាំ ដែលខ្លួនចូលដល់ហើយ ។

ដូចបានស្ដាប់មក នាងកាតិយានីនោះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល ក្នុងក្រុងហង្សវតី ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកជ្រះថ្លាដ៏មុតមាំ ទើបបានធ្វើកុសលឲ្យក្រៃលែង ប្រាថ្នាតំណែងនោះ នាងវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងកុររឃរនគរ ។ បិតាមាតាតាំងឈ្មោះនាងថា **កាតិយានី** ។

តមក នាងចម្រើនវ័យ ជាមិត្តជិតស្និទ្ធរបស់នាងកាឡីអ្នកកុររឃរនគរ ក៏កាលព្រះកោដិកណ្ណសោណត្ថេរ ត្រូវមាតាអង្វរថា លោកកូនចូរពោលធម៌ដល់ញោម ដោយទំនងដែលព្រះទសពលត្រាស់ទុកចុះ ក៏គង់លើអាសនៈដែលគាត់

តែងហើយខាងក្នុងនគរ ពេលកណ្ដាលយប់ផ្ដើមទេសនា ធ្វើមាតាឲ្យជាព្រះអរិ-យកាយសក្ខី ។ កាលនោះ នាងកាតិយានីឧបាសិកា ទៅជាមួយនាងកាឡី ឈរស្ដាប់ធម៌ខាងក្រោយបរិស័ទ ។ សម័យនោះ ចោរប្រមាណ ៩០០ នាក់ ជីកឧម្មង្គផ្ដើមជ្រុងមួយខាងក្នុងនគរ តាមកំណត់សម្គាល់ដែលធ្វើទុកក្នុងវេលាពេលថ្ងៃ ទម្លុះទៅដល់ផ្ទះនាងកាតិយានីឧបាសិកា ។ បណ្ដាចោរទាំងនោះ មេចោរមិនចូលទៅជាមួយចោរទាំងនោះទេ ទៅកាន់ទីពោលធម៌របស់ព្រះសោណត្ថេរ ដើម្បីស៊ើបថាបរិស័ទនេះប្រជុំគ្នាធ្វើអ្វីហ្ន៎ កាលឈរនៅចុងបរិស័ទ ក៏ឈរខាងក្រោយនាងកាតិ-យានីឧបាសិកានោះឯង ។ វេលានោះ នាងកាតិយានីហៅទាសីមកប្រាប់ថា នាងនាងចូរចូលទៅផ្ទះនាំប្រទីបប្រេងមក ខ្ញុំនឹងអុជប្រទីបឲ្យភ្លឺង ហើយស្ដាប់ធម៌ ។ ទាសីនោះទៅផ្ទះអុជប្រទីបជួបពួកចោរជីកឧម្មង្គ ក៏មិនបានកាន់យកប្រទីបប្រេងមក ទៅប្រាប់ម្ចាស់របស់ខ្លួនថា នាងម្ចាស់ ពួកចោរជីកឧម្មង្គក្នុងផ្ទះនាងម្ចាស់ ។ មេចោរស្ដាប់ពាក្យទាសីនោះហើយ គិតថា បើស្រីអ្នកនេះជឿពាក្យទាសីនេះ ហើយទៅផ្ទះសោត យើងក៏នឹងយកដាវកាប់នាងឲ្យដាច់ជាពីរកំណាត់ក្នុងទីនេះ នេះឯងបើស្ត្រីនេះស្ដាប់ធម៌ដោយនិមិត្តដែលនាងកាន់យកហើយនុ៎ះឯង យើងក៏នឹងឲ្យសងទ្រព្យដែលពួកចោរលួចនោះ ។ ចំណែកនាងកាតិយានី ស្ដាប់ពាក្យទាសីហើយ ក៏ពោលថា នាងកុំធ្វើសំឡេងខ្លាំងឡើយ ដែលឈ្មោះថា ពួកចោរ កាលនឹងលួច

ក៏លួចតែទ្រព្យដែលខ្លួនឃើញប៉ុណ្ណោះទេ ចំណែកខ្ញុំនឹងស្តាប់ធម៌ដែលរកបានដ៏លំបាកក្នុងថ្ងៃនេះ នាងកុំធ្វើអន្តរាយដល់ធម៌ឡើយ ។ មេចោរស្តាប់ពាក្យនាង ក៏គិតថា ពួកយើងដែលនាំគ្នាលួចទ្រព្យក្នុងផ្ទះរបស់ស្ត្រីដែលតាំងមាំដោយអធ្យាស្រ័យដូច្នេះ ក៏គប្បីត្រូវធរណីស្រូបដោយពិត ។ រំពេចនុ៎ះឯង មេចោរនោះក៏ទៅបង្គាប់ឲ្យសងទ្រព្យដែលលួចចេញមក ហើយពួកចោរក៏នាំគ្នាមកឈរស្តាប់ធម៌ខាងក្រោយបរិស័ទ ។ ចំណែកឧបាសិកាកាតិយានី ចប់ទេសនារបស់ព្រះថេរៈ ក៏តាំងនៅក្នុងសោតាបត្តិផល ។ ខណៈនោះ កាលអរុណរះ មេចោរក៏ទៅក្រាបទៀបជើងឧបាសិកា ពោលថា ម៉ែម្ចាស់ មេត្តាលើកទោសឲ្យដល់ពួកខ្ញុំទាំងអស់គ្នាផងចុះ ។ នាងសួរថា ក៏ពួកលោកធ្វើអ្វីដល់ខ្ញុំឬ ។ មេចោរនោះក៏ប្រាប់ទោសដែលខ្លួនធ្វើទាំងអស់ ។ នាងពោលថា បាអើយ ខ្ញុំលើកទោសឲ្យពួកលោក ។ មេចោរពោលថា ម៉ែម្ចាស់ ក៏ម៉ែម្ចាស់លើកទោសឲ្យដល់ពួកយើងហើយ តែសូមម៉ែម្ចាស់មេត្តាឲ្យពួកយើងគ្រប់គ្នា បានបួសក្នុងសំណាក់ព្រះថេរៈបុត្ររបស់ម៉ែម្ចាស់ផងចុះ ។ នាងក៏នាំចោរទាំងនោះទៅឲ្យបួសក្នុងសំណាក់ព្រះកោដិកណ្ណសោណត្ថេរ ។ អ្នកទាំងនោះ បួសក្នុងសំណាក់ព្រះថេរៈហើយ ក៏សម្រេចព្រះអរហន្តគ្រប់ៗ រូប ។ រឿងនេះកើតឡើងយ៉ាងនេះ ។ តខាងក្រោយមក ព្រះសាស្តាប្រថាប់នៅក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់

ស្ដាបនាឧបាសិកាកាតិយានីទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាជាអរិយសាវិកាអ្នកជ្រះថ្លាយ៉ាងមុតមាំ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

## “ប្រវត្តិនាងនកុលមាតាគហបតានី”

*ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៥២] ដោយបទថា **វិស្សាសិកានំ** ទ្រង់សម្តែងថា នកុលមាតាគហបតានី ប្រសើរជាងពួកឧបាសិកាអរិយសាវិកាអ្នកពោលពាក្យដ៏ស្និទ្ធស្នាល ។ ក៏ពាក្យដែលនឹងគប្បីពោលក្នុងរឿងនេះទាំងអស់ មានន័យដូចពោលទុកហើយក្នុងឧបាសកបាលិ ក្នុងខាងក្រោយនោះឯង ។*

*គប្បីជ្រាបរឿងនកុលមាតាដោយប្រៀប (ក្នុងឧបាសកបាលិ) នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៩

ដូចប្រវត្តិរបស់នកុលបិតា ។

# អដ្ឋកថាសូត្រទី ១០

## “ប្រវត្តិឧបាសិកាកាឡីអ្នកស្រុកកុររឃរនគរ”

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៥២] ដោយបទថា **អនុស្សវប្បសន្នានំ** ទ្រង់សម្ដែងថា ឧបាសិកាកាឡី អ្នកកុររឃរនគរ ប្រសើរជាងពួកឧបាសិកាអ្នកប្រកបដោយសេចក្ដីជ្រះថ្លា ដែលកើតឡើងដោយការស្ដាប់តាមៗ គ្នាមក ។

ដូចបានស្ដាប់មក ឧបាសិកាកាឡីនោះ គ្រាព្រះពុទ្ធព្រះនាមថា **បទុមុត្តរៈ** កើតក្នុងត្រកូល នាក្រុងហង្សវតី កំពុងស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសិកាមួយនាក់ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកជ្រះថ្លាដោយការស្ដាប់តាមៗ គ្នាមក ទើបធ្វើកុសលឲ្យក្រៃលែងទៅប្រាថ្នាតំណែងនោះ ។ នាងវិលវល់នៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងផ្ទះត្រកូលក្នុងក្រុងរាជគ្រឹះ ។ ពួកញាតិបានតាំងនាមនាងថា **កាឡី** ។ នាងចម្រើនវ័យហើយ មានស្វាមីក្នុងកុររឃរនគរ ។ គ្រានោះដោយការនៅរួមគ្នា នាងទើបតាំងគភ៌ ។ នាងមានគភ៌គ្រប់កំណត់ហើយ គិតថា ការប្រសូតបុត្រក្នុងផ្ទះរបស់អ្នកពួកដទៃមិនសមគួរ ទើបទៅកាន់កុររឃរនគរ ។ តពីវេលាកណ្ដាលយប់ ស្ដាប់ពាក្យរបស់ពួកសាតាគិរយក្ខ និងហេមវតយក្ខ ដែល

ឈរក្នុងអាកាសលើប្រាសាទរបស់ខ្លួន ពណ៌នាព្រះគុណព្រះរតនត្រ័យ កើតសេចក្ដីជ្រះថ្លា ព្រោះបានឮសំឡេងសរសើរគុណព្រះរតនត្រ័យ ក៏តាំងនៅក្នុងសោតាបត្តិផល ដោយមិនទាន់បានគាល់ព្រះសាស្ដាឡើយ តមក នាងក៏ប្រសូតបុត្រ ។ រឿងទាំងអស់ពោលទុកពិស្ដារហើយក្នុងខាងក្រោយ ។ តមក ព្រះសាស្ដាប្រថាប់ក្នុងកណ្ដាលភិក្ខុសង្ឃក្នុងព្រះជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាឧបាសិកានេះ ទុកក្នុងតំណែងឯតទគ្គៈ ប្រសើរជាងពួកឧបាសិកាអ្នកជ្រះថ្លាដោយស្ដាប់តាមៗ គ្នាមក ដូច្នេះឯង ។

ចប់អដ្ឋកថា ឧទាសិកាកាឡី

**ចប់អដ្ឋកថាវគ្គទី ៧**

## ចប់អដ្ឋកថាឧបាសិកាបាលិ ប្រដាប់ដោយ ១០ សូត្រ

## ចប់អដ្ឋកថាឯតទគ្គបាលិទាំងអស់

## នៃមនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

# អដ្ឋានបាលី

## អដ្ឋកថាវគ្គទី ១

### ពោលដោយឋានៈ និងអឋានៈ

ក្នុងអដ្ឋានបាលី គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៤៣] បទថា *អដ្ឋានំ (មិនមែនឋានៈ)* បានដល់ ការបដិសេធហេតុ ។ បទថា *អនវកាសោ (មិនមែនឱកាស)* បានដល់ ការបដិសេធបច្ច័យ ។ ព្រះមានព្រះភាគទ្រង់បដិសេធហេតុប៉ុណ្ណោះ សូម្បីដោយហេតុ និងបច្ច័យទាំងពីរ ។ ពិតណាស់ ហេតុ ត្រាស់ហៅថា ឋានៈ (ហេតុជាទីតាំង) និង ឱកាស (ចន្លោះ) ព្រោះផលរបស់ខ្លួន មានការប្រព្រឹត្តទៅជាប់ដោយផលនោះ ។ បទថា *យំ* ប្រែថា ព្រោះហេតុណា ។ បទថា *ទិដ្ឋិសម្បន្នោ (អ្នកដល់ព្រមដោយទិដ្ឋិ)* បានដល់ ព្រះអរិយសាវក គឺ ព្រះសោតាបន្នដែលដល់ព្រមដោយបញ្ញាក្នុងមគ្គ ។ ពិតហើយ ព្រះសោតាបន្ននោះ មានឈ្មោះច្រើន ដូចជាឈ្មោះថា **ទិដ្ឋិសម្បន្នោ** (អ្នកដល់ព្រមដោយទិដ្ឋិ) ក៏មាន , **ទស្សនសម្បន្នោ** (អ្នកដល់ព្រមដោយទស្សនៈ) ក៏មាន , **អាគតោ ឥមំ សទ្ធម្មំ** (អ្នកមកដល់ព្រះសទ្ធម្មនេះ) ក៏មាន , **បស្សតិ ឥមំ សទ្ធម្មំ** (អ្នកឃើញព្រះសទ្ធម្មហើយ) ក៏មាន , **សេក្ខេន ញាណេន សមន្នាគតោ**

(អ្នកប្រកបដោយញាណរបស់ព្រះសេក្ខៈ) ក៏មាន , **សេក្ខាយ វិជ្ជាយ សមន្នាគតោ** (អ្នកប្រកបដោយវិជ្ជារបស់ព្រះសេក្ខៈ) ក៏មាន , **ធម្មសោតសមាបន្នោ** (អ្នកដល់ព្រមដោយក្រសែធម៌) ក៏មាន , **អរិយោ និព្វេធិកប្បញ្ញោ** (អ្នកមានបញ្ញាជាគ្រឿងជម្រះកិលេសដ៏ប្រសើរ) ក៏មាន , **អមតទ្វារំ អាហច្ច តិដ្ឋតិ** (អ្នកតាំងនៅជិតទ្វារព្រះនិព្វាន) ក៏មាន ។

បទថា **កញ្ចិ សង្ខារំ (សង្ខារទីមួយ)** សេចក្ដីថា បណ្ដាសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ចំពោះសង្ខារណាៗ ត្រឹមតែសង្ខារមួយ ។ បទថា **និច្ចតោ ឧបគច្ឆេយ្យ** (គប្បីប្រកាន់ដោយសភាពជារបស់ទៀង) បានដល់ គប្បីប្រកាន់ថាទៀង ។ បទថា **នេតំ ឋានំ វិជ្ជតិ** (នោះមិនមែនឋានៈដែលនឹងមានបាន) បានដល់ ហេតុនេះមិនមាន គឺ រកមិនបាន ។

[១៩៤] បទថា **យំ បុថុជ្ជនោ** ប្រែថា ឈ្មោះថា បុថុជ្ជន ព្រោះហេតុណា ។ បទថា **ឋានមេតំ វិជ្ជតិ** (ជាឋានៈដែលនឹងមានបាន) បានដល់ ហេតុនោះមានហើយ អធិប្បាយថា ពិតហើយ ព្រោះបុថុជ្ជននោះមានសេចក្ដីឃើញថាទៀង គប្បីប្រកាន់បណ្ដាសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ចំពោះសង្ខារខ្លះ ថាជារបស់ទៀង ។

ក៏សង្ខារដែលប្រព្រឹត្តទៅក្នុងភូមិទី ៤ រមែងមិនជាអារម្មណ៍របស់ទិដ្ឋិ ឬ

អកុសលយ៉ាងដទៃ ព្រោះច្រើនដោយតេជៈ ដូចដុំដែកដែលក្តៅអស់ទាំងថ្ងៃ មិនជាអារម្មណ៍របស់ហ្វូងសត្វរុយ (ព្រោះជារបស់ក្តៅ) ដូច្នោះ ។ គប្បីជ្រាបសេចក្តីសូម្បីក្នុងបទថា **កិញ្ចិ សង្ខារំ សុខតោ** (សូម្បីសង្ខារនីមួយថាជាសុខ) ជាដើមដោយន័យនេះ ។ បទថា **សុខតោ ឧបគច្ឆេយ្យ** (គប្បីប្រកាន់ថាជាសុខ) នេះ ត្រាស់សំដៅដល់ការប្រកាន់ថាជាសុខ ដោយអំណាចអត្តទិដ្ឋិយ៉ាងនេះថា ខ្លួនមានសុខដោយចំណែកមួយ មិនមានរោគ ដរាបទីងស្លាប់ទៅ ។ ព្រោះថា ព្រះអរិយសាវកត្រូវសេចក្តីក្តៅក្រហាយគ្របសង្កត់ហើយ រមែងចូលទៅប្រកាន់សង្ខារខ្លះថាជាសុខ ដើម្បីរម្ងាប់សេចក្តីក្តៅក្រហាយ ដោយចិត្តប្រាសចាកទិដ្ឋិ ដូចសេក្ខព្រាហ្មណ៍[១] ដែលតក់ស្លុតខ្លាចដំរីចុះប្រេង ក៏ចាប់ឧច្ចារៈ ដូច្នោះ ។

[១៥៥] ក្នុងអត្តភាវៈ ព្រះដ៏មានព្រះភាគមិនត្រាស់ថា **សង្ខារំ** (សង្ខារ) តែត្រាស់ថា **កញ្ចិ ធម្មំ** (ធម៌នីមួយ) ដើម្បីទ្រង់រួមយកបញ្ញត្តិ មានកសិណជាដើម ។ សូម្បីក្នុងទីនេះ គប្បីជ្រាបការកំណត់សម្រាប់ព្រះអរិយសាវក ដោយអំណាចសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ។ ចំពោះបុថុជ្ជន ដោយអំណាចសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ម្យ៉ាងទៀត ក្នុងវារៈគ្រប់វារៈ កំណត់ចំពោះសូម្បីព្រះអរិយសាវក ដោយអំណាចសង្ខារដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ក៏គួរ ។

---

១ ចោក្ខព្រាហ្មណ៍ ។

ក៏បុថុជ្ជន រមែងប្រកាន់ធម៌ណាៗ ព្រះអរិយសាវក រមែងដោះសេចក្តីប្រកាន់ចាក ធម៌នោះៗ ។ គឺ បុថុជ្ជន កាលប្រកាន់ធម៌នោះៗ ថាទៀង ថាសុខ ថាខ្លួន ព្រះអរិយសាវក កាលប្រកាន់ធម៌នោះៗ ថាមិនទៀង ថាជាទុក្ខ ថាមិនមែនខ្លួន ឈ្មោះថា រមែងដោះសេចក្តីប្រកាន់នោះចេញ ។

ក្នុងព្រះសូត្រទាំង ៣ ព្រះសូត្រនេះ (ប្រការ ១៥៣-១៥៤-១៥៥) ព្រះអង្គ ត្រាស់ដល់ការដោះសេចក្តីប្រកាន់របស់បុថុជ្ជនទុកផង ។

[១៥៦-១៥៨] ក្នុងពាក្យថា **មាតរំ** (មាតា) ជាដើម លោកបំណងយក ស្ត្រីអ្នកឲ្យកំណើត ឈ្មោះថា មាតា , បុរសអ្នកឲ្យកំណើត ឈ្មោះថា បិតា និង ព្រះខីណាស្រពដែលជាមនុស្សប៉ុណ្ណោះ ឈ្មោះថា ព្រះអរហន្ត ។ សួរថា ព្រះ អរិយសាវក គប្បីផ្តាច់ជីវិតអ្នកដទៃបានឬ ។ ឆ្លើយថា ប្រការនោះមិនជាឋានៈ ។ ព្រោះថា បើព្រះអរិយសាវកដែលកើតក្នុងវាងកព មិនដឹងថា ខ្លួនជាអរិយសាវក សោត នរណាៗ ក៏នឹងគប្បីបង្គាប់យ៉ាងនេះថា លោកចូរផ្តាច់ជីវិតស្រមោចខ្មៅ ស្រមោចក្រហមនេះ ហើយបដិបត្តិមុខនាទីជាស្តេចចក្រពត្តិក្នុងចក្រវាឡទាំងអស់ ចុះ ។ ព្រះអរិយសាវកនោះ ក៏មិនផ្តាច់ជីវិតស្រមោចខ្មៅស្រមោចក្រហមនោះ ឡើយ ។ សូម្បីដូច្នោះ មនុស្សទាំងឡាយគប្បីបង្គាប់លោកយ៉ាងនេះថា បើលោក មិនសម្លាប់ស្រមោចខ្មៅស្រមោចក្រហមនោះសោត ពួកយើងនឹងកាត់សីរសៈលោក ។

មនុស្សទាំងឡាយនឹងបានកាត់សីរសៈរបស់លោក តែលោកមិនគប្បីសម្លាប់ស្រមោច ខ្មៅស្រមោចក្រហមនោះ ។ តែពាក្យនេះ ព្រះដ៏មានព្រះភាគត្រាស់ទុក ដើម្បីទ្រង់សម្តែងការមានទោសច្រើនរបស់បុថុជ្ជន ដើម្បីទ្រង់សម្តែងកម្លាំងរបស់ព្រះអរិយសាវក ។ ក៏ក្នុងប្រការនេះ មានអធិប្បាយដូច្នេះថា ភាពជាបុថុជ្ជន ឈ្មោះថាមានទោស ត្រង់បុថុជ្ជននឹងធ្វើអនន្តរិយកម្ម មាន **មាតុឃាត** ជាដើមបាន អរិយសាវក ឈ្មោះថា មានកម្លាំងច្រើន ត្រង់មិនធ្វើកម្មទាំងនោះ ។

[១៥៩] បទថា **បទុដ្ឋចិត្តោ**[១] (ជាអ្នកមានចិត្តប្រទូស្ត) បានដល់ ជាអ្នកមានចិត្តដែលវធកចិត្ត (ចិត្តគិតនឹងសម្លាប់) ប្រទូសរ៉ាយហើយ ។ បទថា **លោហិតំ ឧប្បាទេយ្យ** បានដល់ ធ្វើព្រះលោហិតសូម្បីប៉ុនរុយតូចផឹកបាន ឲ្យពុះឡើងក្នុងព្រះសរីរៈរបស់ព្រះតថាគតដែលទ្រង់ព្រះជន្មនៅ ។

[១៦០] បទថា **សង្ឃំ ភិន្ទេយ្យ** (គប្បីទម្លាយសង្ឃឲ្យបែកគ្នា) បានដល់ ធ្វើសង្ឃអ្នកមានសមានសំវាស (ធម៌ជាគ្រឿងនៅស្មើគ្នា) ដែលតាំងនៅក្នុងសីមាស្មើគ្នា ឲ្យបែកគ្នាដោយអាការ ៥ យ៉ាង ។ ពិតណាស់ ព្រះមានព្រះភាគត្រាស់ពាក្យនេះទុកថា ម្នាលឧបាលិ សង្ឃរមែងបែកគ្នាដោយអាការ ៥ គឺ ដោយកម្ម ដោយឧទ្ទេស ដោយការចង្អុលបង្ហាញ ដោយប្រកាស ដោយចាប់ស្លាក ។ បណ្តា

---

១ ក្នុងបិដក : ទុដ្ឋេន ចិត្តេន ។

បទទាំងនោះ បទថា **កម្មេន** (ដោយកម្ម) បានដល់ ដោយកម្មទាំង ៤ កម្មណាមួយ ។ បទថា **ឧទ្ទេសេន** (ដោយឧទ្ទេស) បានដល់ ដោយបាតិមោក្ខុទ្ទេស ៥ ឧទ្ទេសណាមួយ ។ បទថា **វោហារេន្ត** (ដោយការចង្អុលបង្ហាញ) បានដល់ ដោយការចង្អុលបង្ហាញ គឺ សម្តែងភេទករវត្ថុ (រឿងធ្វើឲ្យបែកគ្នា) ១៨ យ៉ាង មានការសម្តែងថា អធម៌ជាធម៌ជាដើម ដោយឧប្បត្តិ (ហេតុកើតរឿងនោះៗ) ។ បទថា **អនុស្សាវនេន** (ដោយប្រកាស) បានដល់ ធ្វើការពោលពាក្យប្រកាស ដោយន័យជាដើមថា ពួកលោកជ្រាបឬទេថា យើងបួសមកពីត្រកូលខ្ពស់ និងជាពហុស្សូត ពួកលោកមិនគួរកើតចិត្តគិតថា បុគ្គលដូចជាយើងនេះនឹងគប្បីកាន់យកសត្ថុសាសន៍ (ពាក្យទូន្មានរបស់ព្រះសាស្តា) ក្រៅធម៌ ក្រៅវិន័យ អវិចីសម្រាប់យើងជារបស់ត្រជាក់ដូចស្មួនឧប្បលឬ យើងមិនខ្លាចអបាយឬ ។ បទថា **សលាកគ្គាហេន** (ដោយចាប់ស្លាក) បានដល់ ដោយប្រកាសយ៉ាងនេះហើយ ធ្វើចិត្តរបស់ភិក្ខុទាំងនោះឲ្យរឹងមាំ ធ្វើឲ្យជាធម៌មិនត្រឡប់ត្រឡិនហើយ បានចាប់ស្លាកដោយពោលថា ពួកលោកចូរចាប់ស្លាកនេះ ។

ក៏បណ្តាអាការទាំង ៥ នោះ កម្ម ឬឧទ្ទេសប៉ុណ្ណោះ គួរយកជាប្រមាណ ។ ចំណែកការពោល ការប្រកាស និងការឲ្យចាប់ស្លាក ជាចំណែកខាងដើម ។ ព្រោះថា សូម្បីកាលសង្ឃពោលដោយអំណាចសម្តែងរឿង ១៨ ប្រការ ប្រកាសបបួល

ដើម្បីឲ្យកើតសេចក្ដីពេញចិត្តក្នុងរឿងនោះ នាំគ្នាចាប់ស្លាកហើយ ក៏មិនទាន់ឈ្មោះថា ធ្វើសង្ឃឲ្យបែកគ្នា ។ ចំពោះកាលណា ភិក្ខុ ៤ រូប ឬលើសពី ៤ រូប ចាប់ស្លាកហើយ ធ្វើកម្ម (សង្ឃកម្ម) ឬឧទ្ទេសផ្សេងគ្នា កាលនោះ ទើបឈ្មោះថា ធ្វើសង្ឃឲ្យបែកគ្នា ។ ប្រការថា បុគ្គលដែលដល់ព្រមដោយទិដ្ឋិយ៉ាងនេះ គប្បីធ្វើសង្ឃឲ្យបែកគ្នា នេះមិនមែនឋានៈ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ ក៏ជាការសម្ដែងអនន្តរិយកម្ម ៥ មាន **មាតុឃាត** (សម្លាប់មាតា) ជាដើម ។ បុថុជ្ជនធ្វើអនន្តរិយកម្មពួកណាបាន តែអនន្តរិយកម្មទាំងនោះព្រះអរិយសាវកមិនធ្វើ ។ ដើម្បីសេចក្ដីជាក់ច្បាស់នៃអនន្តរិយកម្ម ៥ នោះ គប្បីជ្រាបវិនិច្ឆ័យ ដោយកម្ម ដោយទ្វារ ដោយការតាំងនៅក្នុងអវិចីរហូតអស់កប្ប ដោយវិបាក ដោយសាធារណៈជាដើម ។

ក្នុងហេតុទាំងនោះ គប្បីជ្រាបវិនិច្ឆ័យដោយកម្មមុន ។ ពិតហើយ បុគ្គលដែលជាមនុស្សប៉ុណ្ណោះ ផ្ដាច់ជីវិតមាតា ឬបិតាជាមនុស្ស ដែលមិនទាន់ត្រឡប់ភេទពីមនុស្ស ទើបជាអនន្តរិយកម្ម ។ បុគ្គលធ្វើអនន្តរិយកម្ម គិតថា យើងនឹងហាមវិបាករបស់កម្មនោះ ដូច្នេះ ទើបសាងសថូបមាសប្រមាណប៉ុនព្រះមហាចេតិយឲ្យពេញទាំងចក្រវាឡក្ដី ថ្វាយមហាទានចំពោះព្រះភិក្ខុសង្ឃដែលគង់ពេញសាកលចក្រវាឡក្ដី មិនលះជាយសំពត់សង្ឃាដិរបស់ព្រះដ៏មានព្រះភាគត្រាច់ទៅក្ដី កាលកាយបែកធ្លាយស្លាប់ទៅ ក៏ចូលដល់នរកប៉ុណ្ណោះ ។ ចំណែកបុគ្គលណា ខ្លួនឯង

ជាមនុស្ស ផ្តាច់ជីវិតមាតា ឬបិតាជាសត្វតិរច្ឆានក្តី ខ្លួនឯងជាសត្វតិរច្ឆានដូចគ្នាក្តី កម្មរបស់អ្នកនោះ មិនជាអនន្តរិយកម្ម តែជាកម្មធ្ងន់ប្រហាក់ប្រហែលអនន្តរិយកម្មនោះឯង ។ តែបញ្ហានេះ លោកពោលសម្រាប់បុគ្គលដែលជាមនុស្ស ។ ក្នុងបញ្ហានោះ គួរពោលរឿងឯឡកចតុក្កៈ សង្គាមចតុក្កៈ និងចោរចតុក្កៈ ។ ក៏បុគ្គលសូម្បីតាំងចិត្តថា យើងនឹងសម្លាប់ពពែ ហើយសម្លាប់មាតា ឬបិតាជាមនុស្ស ដែលតាំងនៅក្នុងទីនៅរបស់ពពែ ឈ្មោះថា ត្រូវអនន្តរិយកម្ម ។ បុគ្គលដែលសម្លាប់ពពែដោយគិតថាជាពពែ ឬដោយគិតថាជាមាតា ឬបិតា ឈ្មោះថា មិនត្រូវអនន្តរិយកម្ម ។ បុគ្គលដែលសម្លាប់មាតា ឬបិតា ដោយគិតថាជាមាតា ឬបិតា ឈ្មោះថា ត្រូវអនន្តរិយកម្មដោយពិត ។ ក្នុង ២ ចតុក្កៈក្រៅពីនេះក៏ន័យនេះដូចគ្នា ។ គប្បីជ្រាបចតុក្កៈទាំងនេះ សូម្បីក្នុងព្រះអរហន្ត ក៏ដូចក្នុងមាតា ឬបិតា ។ បុគ្គលដែលសម្លាប់ព្រះអរហន្តជាមនុស្សប៉ុណ្ណោះ ឈ្មោះថា ត្រូវអនន្តរិយកម្ម ។ សម្លាប់ព្រះអរហន្តជាយក្ខ ឈ្មោះថា មិនត្រូវអនន្តរិយកម្ម ។ តែជាកម្មធ្ងន់ ដូចអនន្តរិយកម្មនោះឯង ។ កាលបុគ្គលប្រើសស្ត្រាប្រហារ ឬដាក់ថ្នាំពិសដល់ព្រះអរហន្តជាមនុស្ស វេលាដែលលោកនៅជាបុថុជ្ជន ប្រសិនបើលោកសម្រេចព្រះអរហត្តមរណៈព្រោះការប្រហារដោយសស្ត្រា ឬថ្នាំពិសនោះឯង បុគ្គលនោះ រមែងឈ្មោះថា សម្លាប់ព្រះអរហន្តដោយពិត ។ ទានណា គេថ្វាយវេលាដែលលោកជាបុថុជ្ជន

លោកសម្រេចព្រះអរហន្តហើយបរិភោគ ទាននោះ ក៏នៅឈ្មោះថា ឲ្យដល់បុថុជ្ជន នោះឯង ។ បុគ្គលដែលសម្លាប់ព្រះអរិយបុគ្គលដ៏សេស ( សោតាបន្ន សកទាគាមី អនាគាមី ) មិនជាអនន្តរិយកម្ម តែជាកម្មធ្ងន់ដូចអនន្តរិយកម្មនោះឯង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអនន្តរិយកម្ម ចំណែកលោហិតុប្បាទ ដូចតទៅនេះ ៖

ឈ្មោះថា បុគ្គលដែលជាសត្រូវនឹងកាត់ព្រះចម្មៈ (ស្បែក) ក្នុងព្រះវរកាយ ដែលនៅមិនបែករបស់ព្រះតថាគត ឲ្យព្រះលោហិតហូរចេញមិនបាន ។ វៀរតែព្រះលោហិតនឹងកកនៅក្នុងទីមួយខាងក្នុងព្រះវរកាយប៉ុណ្ណោះ ។ កំទេចថ្មដែលបែកចេញពីដុំថ្ម ដែលព្រះទេវទត្តទម្លាក់ ទៅប៉ះខ្ទប់ចុងព្រះបាទរបស់ព្រះតថាគត ព្រះបាទដូចត្រូវប៉ះដោយពូថៅ បានមានលោហិតកកនៅខាងក្នុងប៉ុណ្ណោះ ។ កម្មរបស់ព្រះទេវទត្តដែលធ្វើយ៉ាងនោះ ឈ្មោះថា ជាអនន្តរិយកម្ម ។ ចំណែកពេទ្យជីវកកាត់ព្រះចម្មៈដោយសស្ត្រាតាមការពេញព្រះទ័យរបស់ព្រះតថាគត នាំលោហិតចេញពីទីនោះ បានធ្វើឲ្យទ្រង់ជាសុខ ។ កម្មរបស់ពេទ្យជីវកធ្វើយ៉ាងនោះជាបុញ្ញកម្មដោយពិត ។

សួរថា កាលព្រះតថាគតបរិនិព្វានហើយ បុគ្គលពួកណាទម្លាយព្រះចេតិយ កាត់ដើមពោធិ ជាន់ឈ្លីព្រះធាតុ កម្មអ្វីនឹងមានដល់បុគ្គលទាំងនោះ ។

ឆ្លើយថា កម្មទាំងនោះជាកម្មធ្ងន់ដូចគ្នានឹងអនន្តរិយកម្ម ។ តែមែកពោធិ

ដែលបៀតបៀនសថូប ឬព្រះបដិមា ទីមានព្រះធាតុ (បញ្ចុះ) នឹងកាត់ចេញក៏គួរ ។ សូម្បីបើពួកសត្វទំត្រង់មែកពោធិនោះ បន្ទោបង់ឧច្ចារៈព្រះចេតិយ នឹងកាត់ចេញក៏គួរ ។ ព្រោះព្រះចេតិយបញ្ចុះព្រះសរីរធាតុ សំខាន់ជាងបរិភោគចេតិយ ដែលបញ្ចុះគ្រឿងបរិភោគ ។ នឹងកាត់ឫសពោធិដែលទៅទម្លាយចេតិយវត្ថុចេញ ក៏គួរ ។ តែមែកពោធិដែលបៀតបៀនផ្ទះពោធិ នឹងកាត់មែកពោធិ ដើម្បីរក្សាផ្ទះពោធិមិនបាន ។ ព្រោះផ្ទះពោធិមាន ដើម្បីប្រយោជន៍ដល់ដើមពោធិ (តែ) ដើមពោធិមិនមែនដើម្បីប្រយោជន៍ដល់ផ្ទះពោធិទេ ។ សូម្បីក្នុងផ្ទះរក្សាអាសនៈ (ព្រះវិហារ) ក៏ន័យនេះដូចគ្នា ។ នឹងកាត់មែកពោធិដើម្បីរក្សាផ្ទះអាសនៈ (ព្រះវិហារ) ដែលគេបញ្ចុះព្រះធាតុក៏គួរ ។ ដើម្បីរក្សាដើមពោធិ នឹងកាត់មែកដែលដណ្ដើមឱជៈ (គឺអាហារ) ឬមែកពុកចេញ ក៏គួរដូចគ្នា ។ សូម្បីបុណ្យក៏មានដូចការប្រតិបត្តិព្រះសរីរៈព្រះពុទ្ធ ដូច្នោះ ។

ក្នុងសង្ឃភេទ ការបំបែកសង្ឃ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

កាលសង្ឃអ្នកនៅក្នុងសីមាមិនបានប្រជុំគ្នា កាលភិក្ខុដែលសង្ឃធ្វើការចង្អុលដល់ការសូត្រប្រកាស និងការឲ្យចាប់ស្លាក ហើយនៅនាំបរិស័ទមួយចំណែកទៅធ្វើសង្ឃកម្ម ឬសូត្របាតិមោក្ខផ្សេងគ្នា ឈ្មោះថា ជាសង្ឃភេទដោយ ជាអនន្តរិយកម្មផង ។ តែកាលភិក្ខុធ្វើដោយសេចក្ដីសម្គាល់ថា នឹងសមគ្រស្មានគ្នា ( ឬ )

ដោយសេចក្តីសម្គាល់ថា ធ្វើត្រូវ ក៏ត្រឹមតែការបែកគ្នាប៉ុណ្ណោះ មិនទាន់ជាអនន្តរិយកម្ម ។ ធ្វើក្នុងបរិស័ទដែលតិចជាង ៩ រូបក៏ដូចគ្នា (គឺ ជាការបែកគ្នា តែមិនជាអនន្តរិយកម្ម) ។ ដោយកំណត់ ភិក្ខុចំនួន ៩ រូប យ៉ាងតិចបំផុត ក្នុងពួកភិក្ខុ ៩ រូប ភិក្ខុណាទម្លាយសង្ឃ អនន្តរិយកម្មរមែងមានដល់ភិក្ខុនោះ ។ កម្មរបស់ភិក្ខុពួកអធម្មវាទីដែលបដិបត្តិតាមភិក្ខុនោះ ជាកម្មមានទោសច្រើន ។ ចំពោះភិក្ខុដែលជាធម្មវាទីមិនមានទោស ។ ក្នុងការធ្វើសង្ឃភេទ ចំពោះភិក្ខុ ៩ រូបនោះ មានព្រះសូត្រអាងដូច្នេះថា ម្នាលឧបាលិ មួយចំណែកមាន ៤ រូប មួយចំណែកទៀតក៏មាន ៤ រូប , រូបទី ៩ សូត្រប្រកាសឲ្យចាប់ស្លាក ដោយពោលថា នេះធម៌ នេះវិន័យ នេះសត្ថុសាសន៍ ពួកលោកចូរកាន់យកស្លាកយ៉ាងនេះ ចូរពេញចិត្តស្លាកនេះឯង ។ ម្នាលឧបាលិ សង្ឃរាជី (ការប្រេះស្រាំនៃព្រះសង្ឃ) ផង សង្ឃភេទ (ការបែកនៃសង្ឃ) ផង រមែងមានដោយប្រការយ៉ាងនេះ ។ ដូច្នោះ គប្បីជ្រាបវិនិច្ឆ័យដោយកម្ម ដោយប្រការដូច្នេះ ។

បទថា ទ្វារតោ (ដោយទ្វារ) មានអធិប្បាយថា ក៏កម្មទាំងអស់នេះនុ៎ះឯងរមែងតាំងឡើងផ្លូវកាយទ្វារខ្លះ ផ្លូវវចីទ្វារខ្លះ ។ ក្នុងរឿងដែលពោលដោយទ្វារនេះ កម្ម ៤ ប្រការខាងដើម សូម្បីនឹងតាំងឡើងផ្លូវវចីទ្វារដោយអណត្តិកប្រយោគ (គឺប្រយោគបង្គាប់) ក៏ធ្វើកាយទ្វារឲ្យបរិបូរបានដូចគ្នា ។ សង្ឃភេទ សូម្បីនឹងតាំង

ឡើងផ្លូវកាយទ្វាររបស់ភិក្ខុដែលធ្វើការលើកដៃ ក៏ធ្វើឲ្យវចីទ្វារបរិបូរបានដូចគ្នា ។ ក្នុងរឿងនេះ គប្បីជ្រាបវិនិច្ឆ័យសុម្បីដោយទ្វារ ដោយប្រការដូច្នេះ ។

បទថា **កប្បដ្ឋិតិយតោ** (ដោយការនៅរហូតកប្ប) មានអធិប្បាយថា ក៏ក្នុងរឿងនេះ សង្ឃភេទ ជាបាបតាំងនៅរហូតកប្ប ។ ធ្វើសង្ឃភេទក្នុង (ពេលដែល) កប្បតាំងនៅ ឬក្នុងពេលវាងកណ្តាលកប្ប នឹងរួចចាកបាបក្នុងកាលកប្បវិនាសទុំះឯង ។ ក៏បើថាស្អែកនេះ កប្បនឹងវិនាសសោត ធ្វើសង្ឃភេទថ្ងៃនេះ ថ្ងៃស្អែកនេះក៏រួច នឹងឆេះនៅក្នុងនរកមួយថ្ងៃប៉ុណ្ណោះ ។ តែការធ្វើយ៉ាងនេះ មិនមាន ។ កម្ម ៤ ប្រការដ៏សេស ជាអនន្តរិយកម្មប៉ុណ្ណោះ មិនជាកម្មតាំងនៅរហូតអស់នៃកប្ប ។ គប្បីជ្រាបវិនិច្ឆ័យក្នុងកម្មតាំងនៅអស់នៃកប្បក្នុងរឿងនេះ ដោយប្រការដូច្នេះ ។

បទថា **បាកតោ** (ដោយវិបាក) មានអធិប្បាយថា ក៏បុគ្គលណាធ្វើកម្មសុម្បីទាំង ៥ ប្រការនេះ សង្ឃភេទប៉ុណ្ណោះ រមែងឲ្យផលដល់បុគ្គលនោះ ដោយអំណាចបដិសន្ធិ កម្មដ៏សេសរមែងរាប់ថា ជាកម្មដែលមានហើយ (អហោសិ-កម្ម) វិបាករបស់កម្មដ៏សេស មិនមានដូច្នេះ ជាដើម ។ កាលសង្ឃភេទមិនមាន លោហិតុប្បាទ (គឺ ការធ្វើព្រះលោហិតឲ្យពុរពង) រមែងឲ្យផល កាលលោហិតុ-ប្បាទនេះមិនមាន អរហន្តឃាត (គឺ ការសម្លាប់ព្រះអរហន្ត) រមែងឲ្យផល កាល

អរហន្តឃាតមិនមាន បើបិតាជាអ្នកមានសីល មាតាទ្រុស្តសីល ឬមិនមានសីល ដូចបិតានោះ បិតុឃាត (គឺការសម្លាប់បិតា) រមែងឲ្យផលដោយអំណាចបដិសន្ធិ ។ បើមាតាជាអ្នកមានសីល មាតុឃាតរមែងឲ្យផលដោយអំណាចបដិសន្ធិ ។ សូម្បីកាលបិតាមាតាទាំងពីរនាក់ ជាអ្នកស្មើគ្នាដោយសីល ឬដោយទ្រុស្តសីល មាតុឃាតប៉ុណ្ណោះ រមែងឲ្យផលដោយអំណាចបដិសន្ធិ ព្រោះមាតាជាអ្នកធ្វើវត្ថុដែលធ្វើបានលំបាក ទាំងជាអ្នកមានឧបការៈច្រើនដល់បុត្រទាំងឡាយ ។ ដូច្នោះគប្បីជ្រាបវិនិច្ឆ័យសូម្បីដោយវិបាក គឺ ផលក្នុងរឿងនេះ ដោយប្រការដូច្នេះ ។

បទថា **សាធារណាទីហិ** (ដោយសាធារណៈជាដើម) សេចក្តីថា កម្មបថ ៤ ប្រការខាងដើម ជាកម្មទូទៅដល់គ្រហស្ថ និងបព្វជិតទាំងពួង ចំណែកសង្ឃភេទរមែងមានចំពោះភិក្ខុដែលមានប្រការដូចត្រាស់ទុក រមែងមិនមានដល់បុគ្គលដទៃដោយព្រះបាលីថា ម្នាលឧបាលិ ភិក្ខុនីទម្លាយសង្ឃមិនបាន សិក្ខមានា សាមណេរ សាមណេរី ឧបាសក ឧបាសិកា ក៏បំបែកសង្ឃមិនបាន ម្នាលឧបាលិភិក្ខុដែលជាបកតត្ត មានធម៌ជាគ្រឿងនៅរួម ដែលស្មើគ្នា នៅក្នុងសីមាស្មើគ្នា រមែងធ្វើសង្ឃភេទបាន ព្រោះដូច្នោះ សង្ឃភេទ ទើបជាកម្មមិនទូទៅ ។ ដោយ **អាទិ** ស័ព្ទ (គឺស័ព្ទថា ជាដើម) ជនទាំងអស់នោះ ជាអ្នកសហគតៈដោយទុក្ខវេទនា និងសម្បយុត្តដោយទោសៈ មោហៈ ។ គប្បីជ្រាបវិនិច្ឆ័យដោយកម្មទូទៅជាដើម

ក្នុងរឿងនេះ ដោយប្រការដូច្នេះ ។

[១៦១] បទថា **អញ្ញំ សត្ថារំ** (សាស្តាដទៃ) សេចក្តីថា បុគ្គលដែលដល់ព្រមដោយទិដ្ឋិ គិតថា ព្រះសាស្តារបស់យើងនេះ មិនអាចធ្វើកិច្ចរបស់ព្រះសាស្តាបាន ទើបកាន់យកលទ្ធិដទៃសូម្បីក្នុងចន្លោះភពយ៉ាងនេះថា លោកនេះជាសាស្តារបស់យើង ដូច្នេះ ប្រការនេះមិនមែនជាឋានៈ ។

[១៦២] បទថា **ឯកិស្សាយ លោកធាតុយា** (ក្នុងលោកធាតុតែមួយ) គឺក្នុងម៉ឺនលោកធាតុ ។ ក៏ខេត្តមាន ៣ គឺ ជាតិខេត្ត ១ អាណាខេត្ត ១ វិស័យខេត្ត ១ ។ ក្នុងខេត្តទាំង ៣ នោះ **ម៉ឺនលោកធាតុ** ឈ្មោះថា ជាតិខេត្ត ។ ព្រោះថាម៉ឺនលោកធាតុនោះ កក្រើកញ័រក្នុងវេលាដែលព្រះតថាគតស្តេចចុះកាន់គភ៌ព្រះមាតាស្តេចចេញ (ព្រះផ្នួស) ត្រាស់ដឹង ប្រកាសព្រះធម្មចក្រ ដាក់ព្រះជន្មាយុសង្ខារនិងបរិនិព្វាន ។ **សែនកោដិចក្រវាឡ** ឈ្មោះថា អាណាខេត្ត ។ ព្រោះថាអាណាខេត្តរបស់អាដានាដិយបរិត្ត មោរបរិត្ត ធជគ្គបរិត្ត និងរតនបរិត្ត ជាដើមរមែងផ្សាយទៅក្នុងសែនកោដិចក្រវាឡនេះ ។ ឯចំណែក **វិស័យខេត្ត** មិនមានប្រមាណ (គឺរាប់មិនបាន) ។ ក៏ធម្មតា ព្រះពុទ្ធទាំងឡាយ ឈ្មោះថា ធម៌មិនមែនជាវិស័យមិនមាន ព្រោះព្រះបាលីថា ព្រះញាណ (សេចក្តីដឹង) មានប្រមាណត្រឹមណា ប្រការដែលនឹងគប្បីដឹង ក៏មានប្រមាណត្រឹមនោះ ប្រការដែលនឹងគប្បី

មានប្រមាណត្រឹមណា ព្រះញាណក៏មានប្រមាណត្រឹមនោះ ។ ប្រការដែលនឹងគប្បីដឹង មានព្រះញាណជាទីបំផុត ព្រះញាណក៏មានប្រការដែលនឹងគប្បីដឹងជាទីបំផុត ដូច្នេះ ។

ក៏ក្នុងខេត្តទាំង ៣ នេះ មិនមានព្រះសូត្រដែលថា វៀរចក្រវាឡនេះចេញព្រះពុទ្ធទាំងឡាយ រមែងស្តេចឧប្បត្តិក្នុងចក្រវាឡដទៃ តែមានព្រះសូត្រថា ស្តេចមិនឧប្បត្តិ ។ ក៏ព្រះបិដកមាន ៣ គឺ ព្រះវិន័យបិដក ព្រះសុត្តន្តបិដក ព្រះអភិធម្មបិដក ។ សង្គីតិ (គឺការសង្គាយនា) ក៏មាន ៣ ជង គឺ សង្គីតិរបស់ព្រះមហាកស្សបត្ថេរ ១ សង្គីតិរបស់ព្រះយសត្ថេរ ១ សង្គីតិរបស់ព្រះមោគ្គលិបុត្តត្ថេរ ១ ។ ក្នុងព្រះពុទ្ធវចនៈ គឺ ត្រៃបិដក ដែលលើកឡើងកាន់សង្គីតិទាំង ៣ ជងនេះ មិនមានព្រះសូត្រដែលថា ក្រៅពីចក្រវាឡនេះទៅ ព្រះពុទ្ធទាំងឡាយទ្រង់ឧប្បត្តិក្នុងចក្រវាឡដទៃ តែមានព្រះសូត្រថា ទ្រង់មិនឧប្បត្តិក្នុងចក្រវាឡដទៃ ។

បទថា **អបុព្វំ អចរិមំ** (ព្រមគ្នា) បានដល់ ក្នុងកាលមិនមុនមិនក្រោយគ្នា លោកអធិប្បាយថា ទ្រង់មិនឧប្បត្តិព្រមគ្នា គឺ ទ្រង់ឧប្បត្តិមុន ឬក្រោយគ្នា ។ ក្នុងពាក្យដែលថា មិនមុនមិនក្រោយគ្នានោះ គប្បីជ្រាបថា ក្នុងកាលមុន គឺ តាំងពីវេលាដែលប្រថាប់ត្រង់ពោធិបល្ល័ង្ក ដោយតាំងព្រះទ័យថា មិនសម្រេចព្រះពោធិញ្ញាណនឹងមិនក្រោកឡើង ដរាបដល់ទ្រង់បដិសន្ធិក្នុងព្រះគភ៌ព្រះមាតា ។

ក៏ក្នុងការបដិសន្ធិរបស់ព្រះពោធិសត្វ លោកកំណត់ខេត្ត ដោយម៉ឺនចក្រ-វាឡកក្រើកញាប់ញ័រប៉ុណ្ណោះ ក៏ជាការហាមការឧប្បត្តិនៃព្រះពុទ្ធព្រះអង្គដទៃ ក្នុងរវាងនោះ ។ គប្បីជ្រាបថា ក្នុងកាលខាងក្រោយ គឺ តាំងពីបរិនិព្វាន ដរាបដល់ព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃទ្រង់តាំងនៅ ព្រោះកាលព្រះធាតុតាំងនៅ ព្រះពុទ្ធទាំងឡាយឈ្មោះថា ទ្រង់តាំងនៅ ព្រោះដូច្នោះ ក្នុងរវាងកាលនេះ រមែងជាការហាមការឧប្បត្តិឡើងនៃព្រះពុទ្ធព្រះអង្គដទៃ ។ តែកាលព្រះធាតុបរិនិព្វានហើយ មិនហាមការឧប្បត្តិនៃព្រះពុទ្ធព្រះអង្គដទៃ ។

សួរថា ក៏ព្រោះអ្វី ព្រះពុទ្ធទាំងឡាយ ទើបទ្រង់មិនឧប្បត្តិមិនមុនមិនក្រោយគ្នា (គឺព្រមគ្នា) ។ ឆ្លើយថា ព្រោះឧប្បត្តិព្រមគ្នាមិនជាហេតុអស្ចារ្យ ។ ព្រោះថាព្រះពុទ្ធទាំងឡាយជាអច្ឆរិយៈមនុស្ស ។ សមដូចដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក ជាមនុស្សអស្ចារ្យ រមែងឧប្បត្តិឡើង បុគ្គលឯកដូចម្ដេច គឺ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ" ។ ក៏បើព្រះពុទ្ធមាន ២ ព្រះអង្គ មាន ៤ ព្រះអង្គ មាន ៨ ព្រះអង្គ ឬមាន ១៦ ព្រះអង្គ គប្បីឧប្បត្តិព្រមគ្នាសោត ក៏គប្បីជាបុគ្គលមិនគួរអស្ចារ្យ ។ សូម្បីមានចេតិយ ២ ក្នុងវិហារតែមួយជាមួយគ្នា លាភសក្ការៈរមែងមិនមហោឡារ ។ សូម្បីភិក្ខុទាំងឡាយ ក៏មិនគួរអស្ចារ្យ ព្រោះមានច្រើន សូម្បីព្រះពុទ្ធទាំងឡាយក៏ដូច្នោះ ព្រោះដូច្នោះ ទើបទ្រង់មិនឧប្បត្តិព្រម

គ្នា ។

កាលពោលដោយទេសនា ក៏មិនប្លែកគ្នាដូច្នេះ ៖ ព្រះពុទ្ធមួយព្រះអង្គ ទ្រង់សម្តែងធម៌ណា មានសតិប្បដ្ឋានជាដើម ព្រះពុទ្ធព្រះអង្គដទៃសូម្បីឧប្បត្តិឡើង ក៏ទ្រង់សម្តែងធម៌នោះឯង ព្រោះហេតុនោះ ទើបមិនគួរអស្ចារ្យ ។ តែកាលព្រះពុទ្ធតែមួយព្រះអង្គទ្រង់សម្តែងធម៌ សូម្បីការសម្តែងធម៌ ក៏ជារបស់គួរអស្ចារ្យ ។

កាលពោលដោយមិនមានការជំទាស់គ្នា កាលព្រះពុទ្ធច្រើនព្រះអង្គឧប្បត្តិឡើង ពួកពុទ្ធមាមកៈក៏នឹងគប្បីវិវាទគ្នាថា ព្រះពុទ្ធរបស់ពួកយើងគួរជ្រះថ្លា ព្រះពុទ្ធរបស់ពួកយើងមានព្រះសូរសេងពីរោះ មានលាភ មានបុណ្យ ដូច្នេះ ដូចពួកសិស្សរបស់ពួកអាចារ្យជាច្រើន ដូច្នោះ សូម្បីព្រោះហេតុនោះ ទើបមិនឧប្បត្តិឡើងយ៉ាងនោះ ។

ប្រការមួយទៀត ហេតុក្នុងប្រការនេះ ព្រះនាគសេនត្រូវព្រះបាទមិលិន្ទសួរ ក៏បានពោលទុកពិស្តារហើយ ។ ក្នុងមិលិន្ទបញ្ហានោះ លោកពោលទុកថា ព្រះបាទមិលិន្ទត្រាស់សួរថា លោកម្ចាស់នាគសេន ព្រះមានព្រះភាគបានភាសិតសេចក្តីនេះទុកថា ម្នាលភិក្ខុទាំងឡាយ ប្រការដែលព្រះអរហន្តសម្មាសម្ពុទ្ធនឹងឧប្បត្តិមិនមុនមិនក្រោយ (ព្រមគ្នា) ២ ព្រះអង្គ ក្នុងលោកធាតុតែមួយនោះ មិនមែនជាឋានៈ មិនមែនឱកាស នោះមិនមែនជាឋានៈដែលនឹងមានបាន ។ លោកម្ចាស់

ព្រះនាគសេន ក៏ព្រះតថាគតគ្រប់ព្រះអង្គ កាលទ្រង់នឹងសម្តែង ក៏ទ្រង់សម្តែងពោធិបក្ខិយធម៌ ៣៧ ប្រការ កាលនឹងត្រាស់ ក៏ត្រាស់អរិយសច្ច ៤ កាលនឹងទ្រង់ឲ្យសិក្សា ក៏ទ្រង់ឲ្យសិក្សាសិក្ខា ៣ និងកាលនឹងទ្រង់ទូន្មាន ក៏ទ្រង់ទូន្មានវត្តបដិបត្តិ គឺ សេចក្តីមិនប្រមាទ ។ លោកម្ចាស់នាគសេន ប្រសិនបើព្រះតថាគតគ្រប់ព្រះអង្គមានឧទ្ទេសតែមួយដូចគ្នា មានកថាតែមួយដូចគ្នា មានការទូន្មានតែម្យ៉ាងដូចគ្នាសោត ព្រោះហេតុអ្វី ព្រះតថាគត ២ ព្រះអង្គ ទើបមិនឧប្បត្តិក្នុងសម័យតែមួយ ។ ព្រោះការឧប្បត្តិឡើងរបស់ព្រះពុទ្ធសូម្បីតែមួយព្រះអង្គ លោកនេះក៏កើតការភ្លឺស្វាងយ៉ាងនេះហើយ បើនឹងគប្បីមានព្រះពុទ្ធសូម្បីអង្គទី ២ លោកនេះក៏នឹងកើតការភ្លឺស្វាងមានប្រមាណយ៉ាងក្រៃលែង ដោយព្រះរស្មីរបស់ព្រះពុទ្ធ ២ ព្រះអង្គ ។ មួយទៀត ព្រះពុទ្ធ ២ ព្រះអង្គ កាលនឹងទ្រង់ទូន្មាន ក៏ទ្រង់ទូន្មានដោយងាយ និងកាលនឹងទ្រង់ប្រៀនប្រដៅ ក៏ទ្រង់ប្រៀនប្រដៅដោយងាយ ។ ក្នុងរឿងដែលព្រះពុទ្ធ ២ ព្រះអង្គ មិនកើតឧប្បត្តិព្រមគ្នានោះ សូមលោកម្ចាស់មេត្តាសម្តែងហេតុឲ្យខ្ញុំអស់សេចក្តីសង្ស័យផងចុះ ។

ព្រះនាគសេនឆ្លើយថា មហាបពិត្រ មុឺនលោកធាតុនេះ ទ្រទ្រង់ព្រះពុទ្ធទុកបានត្រឹមតែមួយព្រះអង្គ ទ្រទ្រង់ព្រះគុណរបស់ព្រះតថាគតបានត្រឹមតែមួយព្រះអង្គ បើព្រះពុទ្ធស្តេចឧប្បត្តិជាអង្គទី ២ មុឺនលោកធាតុនេះ ក៏នឹងទ្រទ្រង់ទុក

មិនបាន គប្បីកក្រើកញាប់ញ័រ បាក់ស្រុតរាត់រាយខ្ចាត់ខ្ចាយ រហូតដល់ការតាំងនៅមិនបាន ។ មហាបពិត្រ ទូកដែលផ្ទុកមនុស្សបានមួយនាក់ កាលមនុស្សម្នាក់ឡើង ទូកនឹងព្រៀបស្មើទឹក កាលអ្នកទីពីរ ដែលមានអាយុ ពណ៌សម្បុរ វ័យខ្នាតប្រមាណ សភាពស្គម ធាត់ មានអវយវៈគ្រប់ចំណែកបរិបូរណ៍ មកដល់គេឡើងទូកនោះ មហាបពិត្រ ទូកនោះ នឹងទទួលអ្នកទាំងពីរបានឬទេ ។ មិនបានទេលោកម្ចាស់ ទូកនឹងឃ្លេងឃ្លោង ផ្អៀងលិចចុះទៅ តាំងនៅមិនបាន គប្បីលិចចុះទៅក្នុងទឹក យ៉ាងណា មហាបពិត្រ មុឺនលោកធាតុនេះក៏ដូច្នោះដែរ រមែងទ្រទ្រង់ព្រះគុណរបស់ព្រះតថាគតបានត្រឹមតែមួយព្រះអង្គប៉ុណ្ណោះ បើព្រះពុទ្ធអង្គទីពីរឧប្បត្តិឡើង មុឺនលោកធាតុនេះនឹងតាំងនៅមិនបាន នឹងគប្បីកក្រើកញាប់ញ័ររញ្ជួយបាក់ស្រុត ខ្ចាត់ខ្ចាយទៅ តាំងនៅមិនបាន ។ មហាបពិត្រ ឬប្រៀបដូចបុរសគប្បីបរិភោគអាហារតាមសេចក្តីត្រូវរហូតដល់ក គេពេញចិត្តក្នុងការបរិភោគមិនឈប់ធ្វើឲ្យខ្ជិលប្រអូស ឱនខ្លួនមិនចុះដូចកំណាត់ឈើ នៅតែបរិភោគអាហារដដែលនោះចូលទៀត មហាបពិត្រ បុគ្គលនោះនឹងគប្បីមានសេចក្តីសុខខ្លះឬទេ ។ មិនជាសុខឡើយលោកម្ចាស់ គេបរិភោគទៀតក៏នឹងស្លាប់ប៉ុណ្ណោះ ឧបមានោះយ៉ាងណា មហាបពិត្រ មុឺនលោកធាតុនេះ ក៏ដូច្នោះដែរ ទ្រទ្រង់ព្រះពុទ្ធបានត្រឹមតែមួយព្រះអង្គ រមែងទ្រទ្រង់គុណរបស់ព្រះតថាគតបានត្រឹមតែមួយព្រះអង្គ បើព្រះ

ពុទ្ធព្រះអង្គទី ២ នឹងឧប្បត្តិឡើង មុីនលោកធាតុនេះនឹងតាំងនៅមិនបាន នឹងកក្រើក ញាប់ញ័រ បាក់ស្រុត រត់រាយខ្ចាត់ខ្ចាយដល់ការតាំងនៅមិនបាន ។ លោកម្ចាស់នាគសេន ផែនដីកក្រើកញាប់ញ័រ ព្រោះសេចក្តីធ្ងន់របស់ធម៌ដ៏ក្រៃលែងឬណា ? ថ្វាយព្រះពរ មហាបពិត្រ ក្នុងទីនេះមានរទេះ ២ ពេញដោយរតនៈ គេយករតនៈពីរទេះមួយមកដាក់ថែមក្នុងរទេះមួយទៀត មហាបពិត្រ រទេះនោះនឹងទ្ររតនៈរបស់រទេះទាំងពីរបានឬហ្ន៎ ។ មិនបានឡើយលោកម្ចាស់ សូម្បីដុំរបស់រទេះនោះ ក៏នឹងបែក សូម្បីកាំក្តី កង់ក្តី ភ្លៅក្តី របស់រទេះនោះក៏នឹងបាក់ទៅ ។ មហាបពិត្ររទេះ ព្រោះសេចក្តីធ្ងន់របស់រតនៈច្រើនពេកមិនមែនឬ ? ។ ឧបមានេះយ៉ាងណា មហាបពិត្រ ផែនដីកក្រើកញាប់ញ័រ ក៏ព្រោះភាពធ្ងន់របស់ធម៌ដ៏ក្រៃលែង ដូច្នោះនោះឯង ។

មហាបពិត្រ ហេតុនេះ លោកប្រមូលមកក៏ដើម្បីសម្តែងព្រះពលៈរបស់ព្រះពុទ្ធទាំងឡាយ សូមទ្រង់ប្រោសស្តាប់ហេតុសូម្បីយ៉ាងដទៃទៀត ដែលជាហេតុធ្វើឲ្យព្រះពុទ្ធ ២ ព្រះអង្គ មិនឧប្បត្តិក្នុងគ្រាតែមួយ មហាបពិត្រ ប្រសិនបើព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គ គប្បីឧប្បត្តិក្នុងគ្រាតែមួយ ពាក្យដែលថា ព្រះពុទ្ធជាឯកអគ្គបុគ្គល ក៏នឹងខុស ពាក្យដែលថា ព្រះពុទ្ធទ្រង់ចម្រើនបំផុត ។ល។ ព្រះពុទ្ធទ្រង់ប្រសើរបំផុត ព្រះពុទ្ធទ្រង់ខ្ពង់ខ្ពស់បំផុត ព្រះពុទ្ធទ្រង់ជាកំពូល ព្រះពុទ្ធ

ទ្រង់មិនមានបុគ្គលស្មើ ព្រះពុទ្ធទ្រង់មិនមានបុគ្គលប្រៀប ព្រះពុទ្ធទ្រង់មិនមានបុគ្គលផ្ទៀប ព្រះពុទ្ធមិនមានបុគ្គលផ្ទឹម ដូច្នេះនោះ ក៏នឹងគប្បីខុស ។ មហាបពិត្រ សូមព្រះអង្គទ្រង់ជ្រាបហេតុ ដែលជាហេតុឲ្យព្រះសម្មាសម្ពុទ្ធ ២ ព្រះអង្គទ្រង់មិនឧប្បត្តិក្នុងគ្រាតែមួយនេះឯង ដោយសេចក្តីនេះចុះ ។

មហាបពិត្រ មួ៉ាងទៀត ប្រការដែលព្រះពុទ្ធមួយព្រះអង្គប៉ុណ្ណោះ ឧប្បត្តិឡើងក្នុងលោកនោះ ជាប្រក្រតីរបស់ព្រះពុទ្ធទាំងឡាយ ។ ព្រោះហេតុអ្វី ព្រោះគុណរបស់ព្រះសព្វញ្ញុពុទ្ធទាំងឡាយជាហេតុធំ ។ មហាបពិត្រ សូម្បីវត្ថុដទៃណាឈ្មោះថាជារបស់ធំ វត្ថុនោះក៏មានត្រឹមតែម្យ៉ាងប៉ុណ្ណោះ ។ មហាបពិត្រ ផែនដីជារបស់ធំ ផែនដីនោះក៏មានតែមួយផ្ទាំង , សាគរធំ ក៏មានតែមួយកន្លែង , រណ្តៅភ្នំសិនេរុធំ ក៏មានតែមួយ , អាកាសធំ ក៏មានអន្លង់តែមួយ , ព្រះព្រហ្មធំ ក៏មានតែមួយអង្គ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធជាដើមទាំងនោះ ឧប្បត្តិក្នុងទីណា ក្នុងទីនោះ បុគ្គលពួកដទៃរមែងមិនមានឱកាស ព្រោះដូច្នោះ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធតែមួយព្រះអង្គប៉ុណ្ណោះ ឧប្បត្តិឡើងក្នុងលោក ។ លោកម្ចាស់នាគសេន បញ្ហា ព្រមទាំងហេតុដែលឧបមា លោកម្ចាស់ពោលល្អហើយ ។

បទថា **ឯកិស្សា លោកធាតុយា** (ក្នុងលោកធាតុមួយ) គឺ ក្នុងចក្រវាឡតែមួយ ក្នុងផ្នែកខាងដើម លោកយកម៉ឺនចក្រវាឡដោយពាក្យ (ថាម៉ឺនលោក-

ធាតុ) នេះ ។ សូម្បីម៉ឺនចក្រវាឡនោះ ក៏គួរកំណត់យកត្រឹមតែចក្រវាឡមួយប៉ុណ្ណោះ ។ ព្រោះថា ព្រះពុទ្ធជាម្ចាស់ទាំងឡាយ កាលឧប្បត្តិ រមែងឧប្បត្តិក្នុងចក្រវាឡនេះប៉ុណ្ណោះ ក៏កាលហាមស្ថានទីដែលឧប្បត្តិទុក ព្រះពុទ្ធជាម្ចាស់ទាំងឡាយទើបមិនឧប្បត្តិក្នុងចក្រវាឡដទៃៗ រមែងជាការហាមដាច់ខាត (គឺនឹងឧប្បត្តិក្នុងទីដទៃមិនបាន) ។

ចប់អដ្ឋកថា វគ្គទី ១

# អដ្ឋកថាវគ្គទី ២

*"ពោលដោយឋានៈ និងអឋានៈ"*

[១៦៣] *ក្នុងបទថា **អបុព្វំ អចរិមំ** (ព្រមគ្នា) នេះ មុនកាលដែលចក្ករតនៈប្រាកដ ឈ្មោះថា **បុព្វំ** (មុន) ខាងក្រោយចក្ករតនៈនោះឯងអន្តរធាន ឈ្មោះថា **ចរិមំ** (ក្រោយ) ក្នុងពាក្យនោះ ចក្ករតនៈអន្តរធាន មាន ២ ប្រការ គឺស្តេចចក្រពត្តិសុគត ឬទ្រង់ព្រះផ្នួស ។ ក៏ប៉ុន្តែ ការអន្តរធាននោះ នឹងអន្តរធានក្នុងថ្ងៃទី ៧ ពីការសុគត ឬពីការទ្រង់ព្រះផ្នួស ។ បន្ទាប់ពីនោះទៅ មិនហាមការប្រាកដឡើងនៃស្តេចចក្រពត្តិ ។*

*សួរថា ក៏ព្រោះហេតុអ្វី ស្តេចចក្រពត្តិទើបទ្រង់មិនឧប្បត្តិព្រមគ្នា ២ អង្គក្នុងចក្រវាឡតែមួយ ឆ្លើយថា ព្រោះនឹងកើតការវិវាទ ព្រោះមិនគួរអស្ចារ្យ និងព្រោះចក្ករតនៈមានអានុភាពច្រើន ។ ដោយហេតុថា ស្តេចចក្រពត្តិ ២ ព្រះអង្គទ្រង់ឧប្បត្តិឡើង សេចក្តីវិវាទក៏នឹងគប្បីកើតឡើងថា ព្រះរាជារបស់ពួកយើងជាធំ ព្រះរាជារបស់យើង (ផ្សេងទៀត) ជាធំ និងមិនគួរអស្ចារ្យ ដោយសម្គាល់ថាជាចក្រពត្តិក្នុងទ្វីបមួយ មួយទៀត ការមានអានុភាពច្រើនរបស់ចក្ករតនៈ ដែលអាចប្រគល់ភាពជាធំឲ្យក្នុងទ្វីបទាំង ៤ មានទ្វីបតូច ២.០០០ ជាបរិវារនោះ ក៏នឹង*

សាបសូន្យទៅ ។ ស្ដេចចក្រពត្តិ ២ ព្រះអង្គ មិនឧប្បត្តិក្នុងចក្រវាឡតែមួយ ក៏ព្រោះនឹងកើតសេចក្ដីវិវាទ ១ ព្រោះមិនគួរអស្ចារ្យ ១ និងព្រោះចក្ករតនៈមានអានុភាពច្រើន ១ ដោយប្រការដូច្នេះ ។

[១៦៤] ក្នុងបទទាំងនេះថា **យំ ឥត្ថី អរហំ អស្ស សម្មាសម្ពុទ្ធោ** (ប្រការដែលស្ត្រីជាព្រះអរហន្តសម្មាសម្ពុទ្ធ) ដូច្នេះ អធិប្បាយថា ពុទ្ធភាព (ភាពជាព្រះពុទ្ធ) ដែលអាចឲ្យសព្វញ្ញុគុណកើតហើយ ដឹកនាំសត្វចេញចាកលោក ចូរទុកសិនចុះ ។ ស្ត្រីសូម្បីត្រឹមតែតាំងសេចក្ដីប្រាថ្នា ក៏រមែងមិនសម្រេចភាព (ជាព្រះពុទ្ធ) ។

ហេតុជាគ្រឿងតាំងសេចក្ដីប្រាថ្នាឲ្យសម្រេចទាំងនេះ គឺ ៖

**មនុស្សត្តំ លិង្គសម្បត្តិ ហេតុ សត្ថារទស្សនំបព្វជ្ជា**
**គុណសម្បត្តិ អធិការោ ច ឆន្ទតា អដ្ឋធម្មសមោធានា**
**អភិនីហារោ សមិជ្ឈតិ ។**

អភិនីហាររមែងសម្រេចព្រោះប្រជុំធម៌ ៨ ប្រការ គឺ ភាពជាមនុស្ស ១ ការដល់ព្រមដោយភេទ (បុរស) ១ ហេតុ (គឺឧបនិស្ស័យដែលជាហេតុសាងកុសលច្រើន) ១ ការបានជួបព្រះសាស្ដា ១ ការបានបព្វជ្ជា ១ ការដល់ព្រមដោយគុណ (មានឈានសមាបត្តិជាដើម) ១ អធិការ (គឺបុញ្ញាភិសម្ភារដ៏ក្រៃលែង

ដូចជាបំពេញបញ្ចមហាបរិច្ចាគ) ១ ជាអ្នកមានឆន្ទៈ (ក្នុងព្រះពោធិញ្ញាណ) ១ ។

ស្ត្រីមិនអាចធ្វើសូម្បីបណិធាន គឺ ការតាំងសេចក្តីប្រាថ្នាដូចពោលមកនេះឲ្យសម្រេចបាន ពុទ្ធភាពនឹងមានអំពីណាបាន ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ប្រការដែលស្ត្រីជាព្រះអរហន្តសម្មាសម្ពុទ្ធនោះមិនមែនជាឋានៈ មិនមែនជាឱកាស ។ ការសន្សំឲ្យបរិបូរណ៍ដោយអាការទាំងពួងប៉ុណ្ណោះ រមែងធ្វើអត្តភាពដែលសម្បូរណ៍ដោយអាការទាំងពួងឲ្យកើត ព្រោះហេតុនោះ បុរសទើបជាព្រះអរហន្តសម្មាសម្ពុទ្ធបាន ។

[១៦៥] សូម្បីក្នុងបទដែលថា ***យំ ឥត្ថី រាជា អស្ស ចក្កវត្តិ*** (ប្រការដែលស្ត្រីគប្បីជាស្តេចចក្រពត្តិ) ដូច្នេះជាដើម មានអធិប្បាយថា ព្រោះហេតុដែលលក្ខណៈទាំងឡាយរបស់ស្ត្រីមិនគ្រប់គ្រាន់ ព្រោះស្ត្រីមិនមានរបស់កំបាំង ដែលជាវត្ថុជាទីតាំងនៅក្នុងស្រោម រតនៈ ៧ ប្រការ ក៏មិនដល់ព្រម ព្រោះមិនមានឥត្ថីរតន៍ ទាំងអត្តភាពដែលក្រៃលែងជាងមនុស្សទាំងពួងក៏មិនមាន ដូច្នោះ ទើបត្រាស់ថា ប្រការដែលស្ត្រីគប្បីជាស្តេចចក្រពត្តិនោះ មិនមែនជាឋានៈ មិនមែនជាឱកាស ដូច្នេះ ។

មួយទៀត ព្រោះឋានៈទាំង ៣ មានស្តេចសក្កៈជាដើម ជាឋានៈខ្ពង់ខ្ពស់ ចំណែកស្ត្រីជាភេទទន់ទាប ដូច្នោះ ស្ត្រីនោះទើបជាស្តេចសក្កៈជាដើម មិនសម្រេច

បានជាច់ខាត ។ សួរថា សូម្បីភេទបុរស ក៏មិនមានក្នុងព្រហ្មលោក ដូចភេទស្ត្រី មិនមែនឬ ។ ព្រោះដូច្នោះ ទើបមិនគួរពោលថា បុរសគប្បីគ្រប់គ្រងភាពជាព្រហ្ម នោះ ជាឋានៈដែលនឹងមានបាន? ឆ្លើយថា មិនគួរពោលថា មិនមែន ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបុរសក្នុងលោកនេះ កើតក្នុងព្រហ្មលោកនោះ បាន ។

[១៦៦] ក៏ក្នុងបទថា **ព្រហ្មត្តំ** (ភាពជាព្រហ្ម) លោកសំដៅយកសេចក្តី ដែលជាស្តេចមហាព្រហ្ម ។ មួយទៀត ស្ត្រីបំពេញឈានក្នុងលោកនេះ ធ្វើកាលៈ (ស្លាប់) ទៅហើយ រមែងចូលដល់ភាពជាសម្លាញ់នៃពួកព្រហ្មបារិសជ្ជា (ព្រហ្ម ដែលជាបរិស័ទ) មិនចូលដល់ភាពជាស្តេចមហាព្រហ្ម ចំណែកបុរសមិនគួរពោល ថា មិនកើតក្នុងព្រហ្មលោកនោះ ។ មួយទៀត ក្នុងព្រហ្មលោកនោះ សូម្បីភេទ ទាំងពីរមិនមាន ព្រហ្មទាំងឡាយក៏មានសណ្ឋានទ្រង់ទ្រាយដូចបុរសនោះឯង មិន មានសណ្ឋានទ្រង់ទ្រាយដូចស្ត្រីឡើយ ព្រោះដូច្នោះ ព្រះតម្រាស់ដែលត្រាស់ទុក នោះ ជាការត្រាស់ទុកល្អហើយនុ៎ះឯង ។

[១៦៧] ក្នុងបទថា **កាយទុច្ចរិតស្ស** (កាយទុច្ចរិត) ជាដើម មានអធិ- ប្បាយថា ពូជស្តៅ និងនទោងព្រៃ រមែងមិនធ្វើផ្លែឲ្យមានរសផ្អែមកើតបាន តែធ្វើ ផ្លែដែលមានរសមិនគួរពេញចិត្ត មិនមានរសផ្អែមឲ្យកើតតែម្យ៉ាង យ៉ាងណា កាយ-

ទុច្ចរិតជាដើម រមែងមិនធ្វើផលដែលមានរសឆ្ងាញ់ឲ្យកើត រមែងធ្វើផលដែលមិនឆ្ងាញ់ប៉ុណ្ណោះឲ្យកើត ដូច្នោះ ។ ពូជអំពៅ និងពូជស្រូវសាលី រមែងឲ្យផលមានរសផ្អែមឆ្ងាញ់ទាំងនោះឲ្យកើត រមែងមិនធ្វើផលដែលមិនគួររីករាយ ផលក្តៅឲ្យកើត យ៉ាងណា កាយសុចរិតជាដើម រមែងធ្វើវិបាកផលដែលពេញចិត្តទាំងនោះឲ្យកើត មិនធ្វើផលដែលមិនឆ្ងាញ់ពិសាឲ្យកើត ដូច្នោះ ។

សមពិតដូចព្រះតម្រាស់ ដែលត្រាស់ទុកថា ៖

បុគ្គលសាបព្រោះពូជណា រមែងបានផលនោះ បុគ្គលធ្វើហេតុល្អ រមែងបានផលល្អ ចំណែកបុគ្គលធ្វើហេតុអាក្រក់ រមែងបានផលអាក្រក់ ។

ព្រោះដូច្នោះ ទើបត្រាស់ព្រះតម្រាស់មានជាដើមថា **អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ កាយទុច្ចរិតស្ស** (វិបាកគួរប្រាថ្នា គួររីករាយ គួរពេញចិត្ត នៃកាយទុច្ចរិតនឹងគប្បីកើតឡើងនោះ មិនមែនជាឋានៈ មិនមែនជាឱកាស ដែលមានបាន) ដូច្នេះ ។

ភាពជាអ្នកមានសេចក្តីព្រមព្រៀង ៥ យ៉ាង គឺ អ្នកមានសេចក្តីព្រមព្រៀងដោយការសន្សំ ១ , អ្នកមានសេចក្តីព្រមព្រៀងដោយចេតនា ១ , អ្នកមានសេចក្តីព្រមព្រៀងដោយកម្ម ១ , អ្នកមានសេចក្តីព្រមប្រៀងដោយវិបាក ១ , អ្នកមាន

សេចក្តីព្រមព្រៀងដោយសេចក្តីប្រាកដ ១ ឈ្មោះថា ជាអ្នកមានសេចក្តីព្រមព្រៀងក្នុងបទថា **កាយទុច្ចរិតសមង្គី** (ព្រមព្រៀងដោយកាយទុច្ចរិត) ដូច្នេះជាដើម ។

បណ្តាភាពជាអ្នកមានសេចក្តីព្រមព្រៀង ៥ យ៉ាងនោះ អ្នកមានសេចក្តីព្រមព្រៀងក្នុងខណៈសន្សំកុសលកម្ម និងអកុសលកម្ម លោកហៅថា ជាអ្នកព្រមព្រៀងដោយការសន្សំ ។ អ្នកមានសេចក្តីព្រមព្រៀងដោយចេតនា ក៏ដូចគ្នា ។ ក៏សត្វទាំងឡាយមិនទាន់សម្រេចព្រះអរហត្តត្រឹមណា សត្វសូម្បីទាំងពួងលោកក៏ហៅថា ជាអ្នកព្រមព្រៀងដោយចេតនា ព្រោះជាអ្នកព្រមព្រៀងដោយចេតនាដែលសន្សំយកទុកក្នុងកាលមុនត្រឹមនោះ នេះឈ្មោះថា ជាអ្នកមានសេចក្តីព្រមព្រៀងដោយចេតនា ។

សត្វសូម្បីទាំងពួង លោកហៅថា ជាអ្នកមានសេចក្តីព្រមព្រៀងដោយកម្ម ព្រោះសំដៅយកកម្មដែលគួរដល់វិបាក ដែលបានសន្សំទុកក្នុងកាលមុន ដរាបដែលមិនទាន់សម្រេចព្រះអរហត្ត នេះឈ្មោះថា ជាអ្នកព្រមព្រៀងដោយកម្ម ។

ភាពជាអ្នកព្រមព្រៀងដោយវិបាក គប្បីជ្រាបចំពោះក្នុងខណៈនៃវិបាកប៉ុណ្ណោះ ។ ក៏សម្រាប់ពួកសត្វដែលចុតិចាកភពនោះៗ ទៅកើតក្នុងនរក នរករមែងប្រាកដដោយអាការប្រាកដទាំងឡាយ មានអណ្តាតភ្លើង និងឆ្នាំងលោហៈជាដើម ។ សម្រាប់ពួកសត្វដែលជាគព្ភសេយ្យកសត្វ (សត្វកើតក្នុងគភ៌) គភ៌

របស់មាតា រមែងប្រាកដ ។ ចំពោះពួកសត្វដែលកើតក្នុងទេវលោក ទេវលោករមែងប្រាកដដោយអាការដែលប្រាកដដើមកល្បព្រឹក្ស និងវិមានជាដើម ឧប្បត្តិ-និមិត្ត រមែងប្រាកដយ៉ាងនេះ ដូចពោលមកដូច្នេះ ដរាបដែលសត្វទាំងនោះមិនទាន់សម្រេចព្រះអរហត្ត ដូច្នោះ ភាពនៃសត្វទាំងនោះមិនទាន់រួចផុតពីសេចក្តីប្រាកដនៃឧប្បត្តិនិមិត្តនេះ ទើបឈ្មោះថា ជាអ្នកព្រមព្រៀងដោយសេចក្តីប្រាកដ ភាពជាអ្នកព្រមព្រៀងដោយសេចក្តីប្រាកដនោះមិនពិតប្រាកដ ។ ចំណែកអ្នកមានសេចក្តីព្រមព្រៀងដ៏សេស (៤ ប្រការ) ពិតប្រាកដ ។ ពិតណាស់ សូម្បីកាលនរកប្រាកដឡើងហើយ ទេវលោកក៏ប្រាកដឡើងបាន , សូម្បីកាលទេវលោកប្រាកដឡើងហើយ នរកក៏ប្រាកដឡើងបាន , សូម្បីកាលមនុស្សលោកប្រាកដហើយ តិរច្ឆានកំណើតក៏ប្រាកដបាន និងសូម្បីកាលតិរច្ឆានកំណើតប្រាកដហើយ មនុស្ស-លោកក៏ប្រាកដឡើងបានដូចគ្នា ។

ក្នុងសេចក្តីនោះ មានរឿងដូចតទៅនេះ ៖

បានឮថា មានព្រះធម្មកថិកមួយរូប ឈ្មោះថា **សោណត្ថេរៈ** នៅក្នុងខេលវិហារ ជិតជើងភ្នំសោណគិរី ។ បិតារបស់លោកឈ្មោះថា **សុនខវាជិក** ។ ព្រះថេរៈសូម្បីហាមបិតា ក៏មិនអាចឲ្យនៅក្នុងសេចក្តីសង្រួមបាន គិតថា បុគ្គលក្រលំបាកចូរកុំវិនាសឡើយ ដូច្នេះ ទើបឲ្យបិតាបួសក្នុងពេលចាស់ ទាំងដែលមិន

ចន៍បួស ។ នរកប្រាកដដល់លោកដែលដេកនៅលើទីដេកសម្រាប់អ្នកជំងឺ ។ ពួកឆ្កែធំៗ មកពីជើងភ្នំសោណគិរី លោមព័ទ្ធធ្វើដូចនឹងខាំស៊ី ។ លោកភ័យខ្លាចចំពោះមរណភ័យ ទើបពោលថា ប៉ា! សោណៈ ដេញវា ប៉ា! សោណៈ ដេញវា ។ ព្រះសោណៈសួរថា ដេញអ្វី ព្រះមហាថេរៈ ។ ព្រះថេរៈដែលជាបិតានិយាយថា ប៉ា! មិនឃើញទេឬ ហើយប្រាប់រឿងរ៉ាវនោះ ។ ព្រះសោណត្ថេរៈគិតថា បិតារបស់បុគ្គលដូចយើង នឹងកើតក្នុងនរកបានយ៉ាងណា សូម្បីយើងក៏នឹងជាទីពឹងរបស់លោក ដូច្នេះ ហើយទើបបង្គាប់សាមណេរទាំងឡាយ ឲ្យនាំផ្កាឈើច្រើនប្រភេទមក ហើយធ្វើគ្រឿងបូជាដែលតាំងនឹងផែនដី និងគ្រឿងបូជាលើគ្រែ ត្រង់លានព្រះចេតិយ និងលានព្រះពោធិ ហើយឲ្យបិតាអង្គុយលើគ្រែនិយាយថា ព្រះមហាថេរៈ គ្រឿងបូជានេះ ខ្ញុំធ្វើដើម្បីប្រយោជន៍ដល់លោក លោកចូរពោលថា បពិត្រព្រះមានព្រះភាគ គ្រឿងបណ្ណាការរបស់អ្នកក្រខ្សត់នេះ ជារបស់ខ្ញុំព្រះអង្គ ដូច្នេះ ហើយថ្វាយបង្គំព្រះមានព្រះភាគ ធ្វើចិត្តឲ្យជ្រះថ្លាចុះ ។ ព្រះមហាថេរៈឃើញគ្រឿងបូជាហើយ ទើបធ្វើតាមនោះ ធ្វើចិត្តឲ្យជ្រះថ្លាហើយ ក្នុងខណៈនោះឯង ទេវលោកប្រាកដដល់លោក សួននន្ទវ័ន សួនចិត្តលតាវ័ន សួនមិស្សកវ័ន និងវិមានទាំងឡាយ ព្រមទាំងទេពអប្សរ ហាក់ដូចជាបានហែហមហើយ ។ ព្រះមហាថេរៈនិយាយថា គេចចេញ ប៉ា! សោណៈ ។ ព្រះសោណៈសួរថា មាន

រឿងអ្វី ព្រះមហាថេរៈនិយាយថា នោះមាតារបស់កូនកំពុងមក ។ ព្រះថេរៈគិតថា សួតិប្រាកដដល់ព្រះមហាថេរៈហើយ ។

គប្បីជ្រាបថា ភាពជាអ្នកព្រមព្រៀងដោយការប្រាកដ រមែងមិនពិតប្រាកដដោយប្រការយ៉ាងនេះ ។ ក្នុងភាពជាអ្នកព្រមព្រៀងទាំងនេះ ពាក្យថា ភាពជាអ្នកព្រមព្រៀងដោយកាយទុច្ចរិត ដូច្នេះជាដើម ត្រាស់ទុកក្នុងទីនេះ ក៏ដោយអំណាចសេចក្តីព្រមព្រៀងដោយការសន្សំ ចេតនា និងកម្ម និងដោយអំណាចជាអ្នកព្រមព្រៀងដោយកាយទុច្ចរិត ។ ក្នុងពាក្យថា ភាពជាអ្នកព្រមព្រៀងដោយកាយ-ទុច្ចរិតជាដើមនោះ លោកអាចារ្យពួកមួយពោលថា ក្នុងខណៈណាគេសន្សំកម្មទុកក្នុងខណៈនោះឯងមិនហាមសួតិសម្រាប់គេ ។ ចំណែកអាចារ្យពួកមួយទៀត ពោលថា ធម្មតាកម្មដែលជាគ្រឿងប្រមូលមក (សន្សំ) បានវារៈ គឺ គ្រាឲ្យវិបាកខ្លះមិនបានខ្លះ មានហើយ ក្នុងរឿងកម្មដែលជាគ្រឿងប្រមូលមកនោះ ក្នុងកាលណាកម្មបានវារៈឲ្យវិបាក ក្នុងកាលនោះប៉ុណ្ណោះ ទើបហាមសួតិសម្រាប់គេ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយទាំងនោះឯង ។

ចប់អដ្ឋកថា វគ្គទី ២

## ចប់អដ្ឋកថា អដ្ឋានបាលី

# អដ្ឋកថាវគ្គទី ៣

*(មិនមានអដ្ឋកថាជួយកែសេចក្ដីទេ)*

# ចប់អដ្ឋកថា អដ្ឋានបាលី

# អដ្ឋកថាឯកធម្មាទិបាលី

## អដ្ឋកថាវគ្គទី ១

*“ពោលដោយអនុស្សតិ ១០”*

*គប្បីជ្រាបវិនិច្ឆ័យក្នុងឯកធម្មបាលី ដូចតទៅ ៖*

[១៧៩] *ភាពជាធម៌មួយ ឈ្មោះថា* **ឯកធម្មោ** *(ធម៌មួយ) ។ បទថា* **ឯកន្តនិព្វិទាយ** *(ដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង) បានដល់ ដើម្បីប្រយោជន៍ដល់សេចក្ដីនឿយណាយ គឺ ដើម្បីប្រយោជន៍ដល់សេចក្ដីធុញទ្រាន់ក្នុងវដ្តៈតែម្យ៉ាង ។ បទថា* **វិរាគាយ** *(ដើម្បីប្រាសចាកតម្រេក) បានដល់ ដើម្បីប្រយោជន៍ដល់ការប្រាសចាកតម្រេកក្នុងវដ្តៈ ។ ម្យ៉ាងទៀត ដើម្បីប្រាសចាក គឺ ដើម្បីការទៅប្រាសទៅនៃកិលេសទាំងឡាយ មានរាគៈជាដើម ។ បទថា* **និរោធាយ** *(ដើម្បីរំលត់) ដើម្បីសេចក្ដីរំលត់កិលេសទាំងឡាយ មានរាគៈជាដើម គឺ ដើម្បីប្រយោជន៍ដល់ការធ្វើកិលេសមានរាគៈជាដើម មិនឲ្យប្រព្រឹត្តទៅ ។ ម្យ៉ាងទៀត ដើម្បីប្រយោជន៍ដល់ការរលត់វដ្តៈ ។ បទថា* **ឧបសមាយ** *(ដើម្បីស្ងប់រម្ងាប់) ដើម្បីប្រយោជន៍ដល់ការចូលទៅស្ងប់កិលេស ។ បទថា* **អភិញ្ញាយ** *(ដើម្បីការដឹងដ៏ក្រៃលែង) គឺ ដើម្បីប្រយោជន៍ដល់ការលើកឡើងកាន់ត្រៃលក្ខណ៍ មានការមិន*

ទៀងជាដើមហើយដឹងក្រៃលែង ។ បទថា **សម្ពោធាយ** (ដើម្បីសេចក្តីត្រាស់ដឹង) បានដល់ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងសច្ចៈទាំង ៤ ។ ម្យ៉ាងទៀត គឺ ដើម្បីប្រយោជន៍ដល់ការត្រាស់ដឹងញាណក្នុងមគ្គទាំង ៤ ដែលព្រះអង្គត្រាស់ទុក យ៉ាងនេះថា ញាណក្នុងមគ្គទាំង ៤ តថាគតហៅថា **ពោធិ** (ការត្រាស់ដឹង) ។ បទថា **និព្វានាយ** (ដើម្បីនិព្វាន) បានដល់ ដើម្បីប្រយោជន៍ដល់ការធ្វើឲ្យជាក់ច្បាស់ព្រះនិព្វានដែលមិនមានបច្ច័យតាក់តែង ។

ព្រះដ៏មានព្រះភាគត្រាស់ពណ៌នា ពុទ្ធានុស្សតិកម្មដ្ឋាន ដោយបទទាំង ៧ នេះ ដោយប្រការដូច្នេះ ។ ព្រោះហេតុអ្វី? ព្រោះព្រះអង្គជាបណ្ឌិត ទ្រង់ត្រាស់ពណ៌នាទុកដើម្បីឲ្យមហាជនកើតសេចក្តីឧស្សាហ៍ ដូចឈ្មួញឈ្មោះ វិសកណ្តកៈ (ឈ្មួញស្ករអំពៅ) ដូច្នោះ ។ គុឡវាណិជ (ឈ្មួញស្ករត្នោត) ឈ្មោះថា វិស-កណ្តកវាណិជ (ឈ្មួញស្ករអំពៅ) ។

បានឮថា ឈ្មួញនោះ បានផ្ទុកទំនិញមានស្ករដុំ និងស្ករក្រាមដោយរទេះ ហើយទៅកាន់ស្រុកជាយដែន ស្រែកឃោសនា (លក់) ថា ពួកលោកចូរមកទិញយកវិសកណ្តកៈ ដូច្នេះ ។ ចំណែកពួកអ្នកស្រុក គ្រាស្តាប់ពាក្យឃោសនាហើយ ទើបគិតគ្នាថា ឈ្មោះថា ថ្នាំពិសជាដុំ នឹងមានពិសដ៏ខ្លាំងក្លា អ្នកណាទំពាស៊ី ដុំថ្នាំពិសនោះ អ្នកនោះរមែងស្លាប់ , សូម្បីបន្លា (ដែលមានពិស) មុតហើយ ក៏

រមែងស្លាប់ ។ ទំនិញសូម្បីទាំងពីរនោះ ក៏ជាដុំរឹងៗ ។ បណ្ដាទំនិញដែលជាដុំរឹងៗ ទាំងនោះ នឹងមានអានិសង្សអ្វី ដូច្នេះហើយ ឲ្យបិទទ្វារផ្ទះ និងដេញឲ្យក្មេងៗ គេចចេញទៅ ។ ឈ្មួញឃើញហេតុនោះហើយ គិតថា ពួកអ្នកស្រុកទាំងនេះ មិនយល់ក្នុងពាក្យ ណ្ហើយចុះ យើងនឹងឲ្យពួកគេទិញទំនិញដោយឧបាយ ដូច្នេះ ហើយទើបស្រែកឃោសនាថា ពួកលោកចូរមកទិញទំនិញដ៏ឆ្ងាញ់ទៅ ពួកលោក ចូរមកទិញទំនិញដ៏ល្អទៅ ពួកលោកនឹងបានស្ករត្នោត ស្ករអំពៅ ស្ករក្រាមដែល មានតម្លៃ ពួកលោកគប្បីទិញដោយទ្រព្យ មានមាសកចាស់ ឬកហាបណៈចាស់ជា ដើមក៏បាន ។ ពួកអ្នកស្រុកលុះស្ដាប់ពាក្យឃោសនានោះហើយ ក៏នាំគ្នារីករាយ សរសើរ លើកគ្នាជាក្រុមជាពួក ទៅឲ្យទ្រព្យជាតម្លៃខ្ពស់ ទិញយកទំនិញមក ។

ក្នុងរឿងកម្មដ្ឋាននោះ ព្រះមានព្រះភាគត្រាស់បង្រៀនកម្មដ្ឋាន មានពុទ្ធានុស្សតិជាអារម្មណ៍ ប្រៀបផ្ទឹមដូចឈ្មួញឈ្មោះថា វិសកណ្ដកៈឃោសនាថា ពួកលោកចូរទិញយកវិសកណ្ដកៈទៅ ដូច្នេះ ។ កាលទ្រង់ធ្វើមហាជនឲ្យកើតសេចក្ដីឧស្សាហ៍ក្នុងកម្មដ្ឋាននោះ ដោយការត្រាស់សរសើរគុណរបស់ពុទ្ធានុស្សតិកម្មដ្ឋាន ដោយបទទាំង ៧ នេះ ប្រៀបផ្ទឹមដូចជាឈ្មួញពោលសរសើរគុណវិសកណ្ដកៈ ធ្វើឲ្យមហាជនកើតឧស្សាហ៍ ដើម្បីត្រូវការនឹងទិញយកវិសកណ្ដកៈនោះ ដូច្នោះ ។

បទថា **កតមោ ឯកធម្មោ** (ធម៌មួយគឺអ្វី) ដូច្នេះ ជាកថេតុកម្យតាបុច្ឆា ពាក្យសួរដែលព្រះអង្គត្រាស់សួរដើម្បីទ្រង់ឆ្លើយដោយព្រះតម្រាស់ថា ពុទ្ធានុស្សតិនេះ ជាឈ្មោះរបស់អនុស្សតិ ដែលកើតឡើងប្រារព្ធព្រះពុទ្ធជាអារម្មណ៍ ។ ក៏ពុទ្ធានុស្សតិកម្មដ្ឋាននោះមាន ២ យ៉ាង គឺ មានប្រយោជន៍ដល់ការធ្វើចិត្តឲ្យរីករាយ និងមានប្រយោជន៍ដល់វិបស្សនា ។

ពាក្យដែលពោលនោះ ដូចម្តេច? គឺ ក្នុងខណៈណា ភិក្ខុចម្រើនអសុភសញ្ញាក្នុងអសុភារម្មណ៍ ចិត្តុប្បាទត្រូវប៉ះខ្ទប់រួញរា ព្រោះមិនធ្លាប់ មិនទៅតាមវិថីវមែងស្ទុះផ្លូវខាងនេះខាងនោះ ដូចគោកោងដូច្នោះ ក្នុងខណៈនោះ ចិត្តុប្បាទនោះលះបង់កម្មដ្ឋានដើមចេញ ហើយរឭកដល់លោកិយគុណ និងលោកុត្តរគុណរបស់ព្រះតថាគត ដោយន័យថា **ឥតិបិ សោ ភគវា** ដូច្នេះជាដើម ។ កាលភិក្ខុនោះរឭកដល់ព្រះពុទ្ធហើយ ចិត្តុប្បាទរមែងផូរផង់ប្រាសចាកនីវរណៈ ។ ភិក្ខុនោះហ្វឹកហាត់ចិត្តនោះយ៉ាងនោះហើយ ទើបមនសិការកម្មដ្ឋានពីដើមនុ៎ះឯងទៀត ។

សួរថា មនសិការកម្មដ្ឋានអំពីដើមទៀត ដូចម្តេច? ឆ្លើយថា មនសិការកម្មដ្ឋានដើម ដូចបុរសមានកម្លាំងកាត់ដើមឈើធំ ដើម្បីត្រូវការយកទៅធ្វើជហ្វាផ្ទះកំពូល កាលមុខពូថៅរិលទៅ ព្រោះត្រឹមតែកាត់មែក និងស្លឹកឈើប៉ុណ្ណោះ សូម្បីកាលមិនអាចកាត់ដើមឈើធំបាន ក៏មិនដាក់ធុរៈ ទៅរោងជាងដែកឲ្យធ្វើពូថៅ

ឲ្យមុត ហើយគប្បីកាត់ដើមឈើធំនោះទៀត យ៉ាងណា គប្បីជ្រាបការឧបមេយ្យនេះ ដូច្នោះ ភិក្ខុហ្វឹកហាត់ចិត្តដោយអំណាចពុទ្ធានុស្សតិយ៉ាងនេះបានហើយ ទើបមនសិការដល់កម្មដ្ឋានដើមទៀត ធ្វើបឋមឈានមានអសុភជាអារម្មណ៍ឲ្យកើតឡើង ពិចារណាអង្គឈានទាំងឡាយ រមែងឈានចុះកាន់អរិយភូមិបាន ។ ពុទ្ធានុស្សតិកម្មដ្ឋាន រមែងជាប្រយោជន៍ដល់ការធ្វើចិត្តឲ្យរីករាយ ដោយប្រការយ៉ាងនេះ ។

ក៏ក្នុងកាលណា ភិក្ខុនោះរឭកដល់ពុទ្ធានុស្សតិហើយ តាមរឭកដល់ ដោយន័យជាដើមថា **កោ អយំ ឥតិបិ សោ ភគវា** (បុគ្គលនេះ គឺ នរណា សូម្បីព្រោះហេតុនេះ បុគ្គលនោះ គឺ ព្រះមានព្រះភាគ) ដូច្នេះជាដើម ។ កំណត់ហើយថា គេជាស្ត្រី ឬជាបុរស ជាទេវតា មនុស្ស មារ ព្រហ្ម បុគ្គលណាមួយ ឬក៏បានឃើញថា បុគ្គលនេះមិនមែនអ្នកដទៃណាទេ ចិត្តដែលប្រកបដោយសតិប៉ុណ្ណោះរឭកបាន ដូច្នេះ ហើយកំណត់អរូបថា ក៏ចិត្តនេះឯង ពោលដោយខន្ធ ជាវិញ្ញាណក្ខន្ធ វេទនាដែលសម្បយុត្តជាមួយចិត្តនោះ ជាវេទនាខន្ធ សញ្ញាដែលសម្បយុត្តជាមួយចិត្ត ជាសញ្ញាខន្ធ ធម៌មានផស្សៈជាដើម ដែលកើតព្រមគ្នា ជាសង្ខារក្ខន្ធ (រួមសេចក្តីថា) ខន្ធទាំង ៤ នេះ ជាអរូបក្ខន្ធ ហើយស្វែងរកទីអាស្រ័យរបស់អរូបនោះ ក៏បានជួបហទយៈវត្ថុ ទើបពិចារណាមហាភូតរូបទាំង ៤ ដែលជាទីអាស្រ័យរបស់អរូបនោះ និងឧបាទាយរូបដ៏សេសដែលអាស្រ័យមហាភូតរូបនោះ

ប្រព្រឹត្តទៅ ហើយកំណត់រូប និងអរូបដោយសង្ខេបថា នេះជារូប ដែលមុនជាអរូប និងកំណត់ទុក្ខសច្ចក្នុងខន្ធ ៥ ជាប្រភេទទៀតថា ដោយសង្ខេបខន្ធសូម្បីទាំង ៥ នេះ ជាទុក្ខសច្ចៈ ដូច្នេះ ក្នុងខាងដើមកំណត់សច្ចៈទាំង ៤ យ៉ាងនេះថា តណ្ហាជាទីកើតនៃទុក្ខនោះ ជាសមុទ័យសច្ចៈ ការរលត់នៃទុក្ខនោះ ជានិរោធសច្ចៈ បដិបទាជាគ្រឿងដឹងការរលត់ ជាមគ្គសច្ចៈ ហើយឈានចុះកាន់អរិយភូមិដោយលំដាប់ ។ ក្នុងកាលនោះ កម្មដ្ឋាននេះទាំងអស់ រមែងឈ្មោះថា ជាប្រយោជន៍ដល់វិបស្សនា ។ ក្នុងបទថា **អយំ ខោ** (ធម៌មួយនេះឯង) ជាដើម គប្បីជ្រាបវារៈនៃអប្បនា ដោយន័យដូចពោលហើយនោះឯង ។

[១៨០] សូម្បីក្នុងធម្មានុស្សតិជាដើម ក៏មានន័យនេះដូចគ្នា ។ ក៏ក្នុងសេចក្ដីដែលពោលដោយធម្មានុស្សតិនោះ មានអត្ថដូចតទៅនេះ ៖

អនុស្សតិដែលកើតឡើងព្រោះប្រារព្ធព្រះធម៌ ឈ្មោះថា **ធម្មានុស្សតិ** ។ ពាក្យថា ធម្មានុស្សតិនេះ ជាឈ្មោះរបស់សតិដែលមានព្រះធម្មគុណ ដែលព្រះអង្គត្រាស់ទុកល្អហើយជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងព្រោះប្រារព្ធព្រះសង្ឃ ឈ្មោះថា **សង្ឃានុស្សតិ** ។ ពាក្យថា សង្ឃានុស្សតិនេះ ជាឈ្មោះរបស់សតិដែលមានព្រះសង្ឃគុណ ព្រោះជាអ្នកបដិបត្តិល្អហើយជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងព្រោះប្រារព្ធសីល ឈ្មោះថា **សីលានុស្សតិ** ។ ពាក្យថា សីលានុស្សតិ នេះ ជាឈ្មោះរបស់សតិដែលមានគុណរបស់សីល មានសីលមិនដាច់ជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងព្រោះប្រារព្ធចាគៈ ការបរិច្ចាគ ឈ្មោះថា **ចាគានុស្សតិ** ។ ពាក្យថា ចាគានុស្សតិ នេះ ជាឈ្មោះរបស់សតិដែលមានគុណនៃចាគៈ ព្រោះជាអ្នកមានទានដែលខ្លួនបរិច្ចាគហើយជាដើមជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើងព្រោះប្រារព្ធទេវតា ឈ្មោះថា **ទេវតានុស្សតិ** ។ ពាក្យថា ទេវតានុស្សតិ នេះ ជាឈ្មោះរបស់សតិដែលមានសទ្ធារបស់ខ្លួនជាអារម្មណ៍ ដោយតាំងទេវតាទុកក្នុងឋានៈជាសាក្សី ។

សតិដែលកើតឡើង ព្រោះប្រារព្ធខ្យល់ដង្ហើមចូលចេញ ឈ្មោះថា **អានាបានស្សតិ** ។ ពាក្យថា អានាបានស្សតិ នេះ ជាឈ្មោះរបស់សតិដែលមានខ្យល់ដកដង្ហើមចូល និងខ្យល់ដកដង្ហើមចេញជានិមិត្តជាអារម្មណ៍ ។

សតិដែលកើតឡើង ព្រោះប្រារព្ធសេចក្តីស្លាប់ ឈ្មោះថា **មរណស្សតិ** ។ ពាក្យថា មរណស្សតិ នេះ ជាឈ្មោះរបស់សតិដែលមានការដាច់ជីវិតិន្ទ្រិយជាអារម្មណ៍ ។

កាលពោល គប្បីពោលថា សតិដែលប្រព្រឹត្តទៅកាន់រូបកាយ ដែលផ្សេង

ដោយសក់ជាដើម ឬដែលប្រព្រឹត្តទៅក្នុងកាយ ឈ្មោះថា **កាយគតា** , កាយគតាផង សតិនោះផង ឈ្មោះថា **កាយគតាសតិ** តែលោកមិនធ្វើរស្សៈឲ្យខ្លី ត្រឡប់ជាពោលថា កាយគតាសតិ ពាក្យថា កាយគតាសតិ នេះ ជាឈ្មោះសតិ ដែលមានចំណែករបស់កាយមានសក់ជាដើម ជានិមិត្តជាអារម្មណ៍ ។

អនុស្សតិដែលកើតឡើង ព្រោះប្រារព្ធការចូលទៅស្ងប់រម្ងាប់ ឈ្មោះថា **ឧបសមានុស្សតិ** ។ ពាក្យថា ឧបសមានុស្សតិ នេះ ជាឈ្មោះរបស់សតិដែលមានការចូលទៅស្ងប់ទុក្ខទាំងពួងជាអារម្មណ៍ ។ម្យ៉ាងទៀត ការចូលទៅស្ងប់មាន ២ យ៉ាង គឺ **អច្ចន្តុបសម** (ការចូលទៅស្ងប់ដ៏កំពូល) និង **ខយូបសម** (ការចូលទៅស្ងប់ដោយការអស់កិលេស) ។ ក្នុង ២ យ៉ាងនោះ ព្រះនិព្វាន ឈ្មោះថា ការស្ងប់ដ៏កំពូល , មគ្គឈ្មោះថា ការស្ងប់ដោយការអស់កិលេស ។ អត្ថក្នុងអធិការនេះ គឺ សតិដែលកើតឡើងដល់អ្នករឭកដល់សេចក្តីស្ងប់សូម្បីទាំងពីរនេះ ដោយប្រការយ៉ាងនេះ ឈ្មោះថា **ឧបសមានុស្សតិ** ។

ក្នុងកម្មដ្ឋានទាំង ១០ នេះ កម្មដ្ឋាន ៣ យ៉ាងនេះ គឺ អានាបានស្សតិ មរណស្សតិ កាយគតាសតិ រមែងជាប្រយោជន៍ដល់វិបស្សនាតែម្យ៉ាង កម្មដ្ឋានដ៏សេស ៧ យ៉ាង ជាប្រយោជន៍ដល់ការធ្វើចិត្តឲ្យរីករាយផង ជាប្រយោជន៍ដល់វិបស្សនាផង ដោយប្រការដូច្នេះ ។

ចប់អដ្ឋកថា វគ្គទី ៦

# អដ្ឋកថាវគ្គទី ២

## “ពោលដោយមិច្ឆាទិដ្ឋិ និងសម្មាទិដ្ឋិ”

*ក្នុងវគ្គទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៨១] *បទថា* ***មិច្ឆាទិដ្ឋិ*** *នេះ ជាឈ្មោះនៃទិដ្ឋិសូម្បីទាំង ៦២ ។ បទថា* ***មិច្ឆាទិដ្ឋិកស្ស*** *បានដល់ បុគ្គលដែលប្រកបដោយទិដ្ឋិនោះ ។*

[១៨២-១៨៤] *បទថា* ***សម្មាទិដ្ឋិ*** *នេះ ជាឈ្មោះរបស់សម្មាទិដ្ឋិសូម្បីទាំង ៥ ប្រការ ។ បទថា* ***សម្មាទិដ្ឋិកស្ស*** *បានដល់ បុគ្គលដែលប្រកបដោយសម្មាទិដ្ឋិនោះ ។ ( មានអធិប្បាយក្នុងទំព័រ ២៤៩ ) ។*

[១៨៥-១៨៦] *ការធ្វើមិនធ្វើទុកក្នុងចិត្តដោយឧបាយ ឈ្មោះថា (**អយោនិសោ មនសិការ**) ។ ការធ្វើក្នុងចិត្តដោយឧបាយ ឈ្មោះថា (**យោនិសោ មនសិការ**) ។ ការមិនធ្វើទុកក្នុងចិត្តដោយឧបាយ និងដោយឧបាយនោះ កាលមិនធ្វើទុកក្នុងចិត្តដោយឧបាយ មិច្ឆាទិដ្ឋិដែលនៅមិនទាន់កើត រមែងកើតឡើង ដែលកើតឡើងហើយ រមែងចម្រើន រហូតដល់ការបដិសន្ធិដោយពិត ។ កាលពិតហើយ មិច្ឆាទិដ្ឋិ ឈ្មោះថា ចម្រើនហើយ ។ កាលធ្វើទុកក្នុងចិត្តដោយឧបាយ សម្មាទិដ្ឋិដែលនៅមិនទាន់កើត រមែងកើតឡើង ដែលកើតឡើងហើយ រមែងចម្រើនច្រើនឡើង រហូតដល់*

ព្រះអរហត្តមគ្គ ។ កាលសម្រេចព្រះអរហត្តផលហើយ សម្មាទិដ្ឋិឈ្មោះថា ជា ការចម្រើនច្រើនហើយ ។

[១៨៧] ក្នុងបទថា **មិច្ឆាទិដ្ឋិយា ភិក្ខវេ សមន្នាគតា សត្តា** (ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយដែលប្រកបដោយមិច្ឆាទិដ្ឋិ) នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

**មិច្ឆាទិដ្ឋិខ្លះហាមសួគ៌ផង ហាមមគ្គផង ។ ខ្លះហាមមគ្គប៉ុណ្ណោះ មិនហាមសួគ៌ ។ ខ្លះមិនហាមទាំងសួគ៌ មិនហាមទាំងមគ្គ ។**

បណ្តាមិច្ឆាទិដ្ឋិទាំងនោះ មិច្ឆាទិដ្ឋិ ៣ យ៉ាងនេះ គឺ អហេតុទិដ្ឋិ អកិរិយទិដ្ឋិ នត្ថិទិដ្ឋិ ហាមសួគ៌ និងហាមមគ្គ ។

អន្តគាហិកមិច្ឆាទិដ្ឋិ មានវត្ថុ ១០ ហាមមគ្គ តែមិនហាមសួគ៌ ។

សក្កាយទិដ្ឋិ មានវត្ថុ ២០ មិនហាមសួគ៌ មិនហាមមគ្គ ។ តែលោកបដិសេធវិធីនេះ ហើយពោលថា “ធម្មតាទិដ្ឋ ដោយទីបំផុតកំណត់យកសក្កាយទិដ្ឋិដែលមានវត្ថុ ២០ ប្រការ ឈ្មោះថា អាចនាំទៅកាន់សួគ៌មិនមាន រមែងធ្វើឲ្យលិចចុះក្នុងនរកតែម្យ៉ាងប៉ុណ្ណោះ ដោយព្រះបាលីក្នុងព្រះសូត្រនេះថា **មិច្ឆាទិដ្ឋិយា ភិក្ខវេ សមន្នាគតា** (ម្នាលភិក្ខុទាំងឡាយ សត្វដែលប្រកបដោយមិច្ឆាទិដ្ឋិ) ដូច្នេះ” ជាដើម ដូចជា ដុំថ្មសូម្បីប៉ុនសណ្តែកបាយ និងសណ្តែកលឿងបោះចុះទៅក្នុងទឹក

ឈ្មោះថា ទីងអណ្តែតទៅខាងលើមិនមាន រមែងលិចចុះទៅខាងក្រោមតែម្យ៉ាង យ៉ាងណា ដោយទីបំផុតសូម្បីតែសក្កាយទិដ្ឋិ ឈ្មោះថា អាចនាំទៅកាន់សួគ៌រមែងមិនមាន រមែងឲ្យលិចចុះក្នុងអបាយទាំងឡាយតែម្យ៉ាងប៉ុណ្ណោះ ក៏ដូច្នោះ ។

[១៨៨] ក្នុងបទថា **សម្មាទិដ្ឋិយា ភិក្ខវេ សមន្នាគតា** (អ្នកប្រកបដោយសម្មាទិដ្ឋិ) នេះ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

សម្មាទិដ្ឋិមាន ៥ យ៉ាង គឺ កម្មស្សកតាសម្មាទិដ្ឋិ ឈានសម្មាទិដ្ឋិ វិបស្សនាសម្មាទិដ្ឋិ មគ្គសម្មាទិដ្ឋិ ផលសម្មាទិដ្ឋិ ។ ក្នុងសម្មាទិដ្ឋិ ៥ យ៉ាងនោះ កម្មស្សកតាសម្មាទិដ្ឋិ រមែងនាំមកនូវភពសម្បត្តិ ។ ឈានសម្មាទិដ្ឋិ រមែងឲ្យបដិសន្ធិក្នុងរូបភព ។ មគ្គសម្មាទិដ្ឋិ រមែងកម្ចាត់វដ្តៈ ។ ផលសម្មាទិដ្ឋិ រមែងហាមភព ។

សួរថា វិបស្សនាសម្មាទិដ្ឋិធ្វើអ្វី ?

ឆ្លើយថា សូម្បីវិបស្សនាសម្មាទិដ្ឋិនោះ ក៏មិននាំមកនូវបដិសន្ធិ ។

ចំណែកព្រះតិបិដកចូឡអភ័យត្ថេរៈ ពោលថា អ្នកដ៏មានអាយុ បើវិបស្សនាសម្មាទិដ្ឋិដែលអប់រំហើយ អាចឲ្យសម្រេចព្រះអរហត្តក្នុងបច្ចុប្បន្នបានសោតប្រការនោះក៏ជាការល្អ បើមិនឲ្យសម្រេចព្រះអរហត្តបាន ក៏នៅឲ្យបដិសន្ធិក្នុងភព ៧ ភពបាន ។ លោកពោលដល់សម្មាទិដ្ឋិដែលជាលោកិយៈ និងលោកុត្តរៈ នេះ

ទុកយ៉ាងនេះ ។ ក៏ក្នុងសេចក្ដីដូចពោលនេះ គប្បីជ្រាបសម្មាទិដ្ឋិដែលជាលោកិយៈ ដែលធ្វើឲ្យសម្រេចក្នុងភពប៉ុណ្ណោះ ។

[១៨៩] គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **យញ្ចេវ កាយកម្មំ យថាទិដ្ឋិសមត្តំ សមាទិន្នំ** ដូចតទៅនេះ ៖

បទថា **យថាទិដ្ឋិ** បានដល់ តាមសមគួរដល់ទិដ្ឋិនោះ ។ បទថា **សមត្តំ** (ឲ្យបរិបូរណ៍) បានដល់ ពេញលេញ ។ បទថា **សមាទិន្នំ** (សមាទាន) បានដល់ កាន់យកហើយ ។ កាយកម្មនោះមាន ៣ យ៉ាង គឺ កាយកម្មតាំងនៅតាមទិដ្ឋិ ១ កាយកម្មដែលកើតព្រមនឹងទិដ្ឋិ ១ កាយកម្មដែលអនុលោមទិដ្ឋិ ១ ។

បណ្ដាកាយកម្ម ៣ យ៉ាងនោះ កាយកម្ម គឺ បាណាតិបាត អទិន្នាទាន និងមិច្ឆាចារ របស់បុគ្គលដែលមានលទ្ធិយ៉ាងនេះថា កាលបុគ្គលសម្លាប់សត្វ លួចទ្រព្យដែលម្ចាស់របស់មិនឲ្យ ប្រព្រឹត្តមិច្ឆាចារ បាបដែលមានហេតុមកពីការធ្វើនោះមិនមាន ការឲ្យផលរបស់បាបក៏មិនមាន នេះឈ្មោះថា **កាយកម្មតាំងនៅតាមទិដ្ឋិ** ។

មួយទៀត កាយកម្មដែលកើតព្រមនឹងទស្សនៈនេះ នៃលទ្ធិនេះដែលថា កាលបុគ្គលសម្លាប់សត្វ លួចទ្រព្យដែលម្ចាស់របស់មិនឲ្យ ប្រព្រឹត្តមិច្ឆាចារ បាបដែលមានហេតុមកពីការធ្វើនោះមិនមាន ការឲ្យផលរបស់បាបក៏មិនមាន ដូច្នេះ

ឈ្មោះថា **កាយកម្មដែលកើតព្រមនឹងទិដ្ឋិ** ។

កាយកម្មនោះឯង ដែលបុគ្គលសមាទានឲ្យបរិបូរណ៍ ប្រកាន់ ស្ទាបអង្អែលឲ្យបរិបូរណ៍ ឈ្មោះថា **កាយកម្មអនុលោមទិដ្ឋិ** ។ សូម្បីក្នុងវចីកម្មជាដើម ក៏មានន័យនេះដូចគ្នា ។ ក៏ក្នុងកាយកម្មនេះ ប្រកបសេចក្តីថា កាលបុគ្គលសម្លាប់សត្វ លួចទ្រព្យដែលម្ចាស់របស់មិនបានឲ្យ ប្រព្រឹត្តមិច្ឆាចារ បាបដែលមានហេតុមកពីការធ្វើនោះមិនមាន ដូច្នេះ យ៉ាងណា ក្នុងវចីកម្ម និងមនោកម្មក៏ដូច្នោះ គប្បីប្រកបសេចក្តីថា កាលបុគ្គលនិយាយកុហក ពោលពាក្យស៊ិកសៀត ពោលពាក្យគ្រោតគ្រាត ពោលពាក្យរោយរាយ បាបដែលមានហេតុមកពីការនិយាយនោះមិនមាន កាលបុគ្គលមានអភិជ្ឈា (គឺការសម្លឹងរំពៃ) មានចិត្តព្យាបាទ មានការឃើញខុស បាបដែលមានហេតុពីវចីទុច្ចរិត និងមនោទុច្ចរិតមិនមាន ដូច្នេះ ។

ក៏ក្នុងបទថា **យា ច ចេតនា** (ចេតនា) ដូច្នេះជាដើម ចេតនាដែលកើតព្រមនឹងទិដ្ឋិ ឈ្មោះថា ចេតនា ។ សេចក្តីប្រាថ្នាដែលកើតព្រមនឹងទិដ្ឋិ ឈ្មោះថា **បត្ថនា** (សេចក្តីប្រាថ្នា) ។ ការតាំងចិត្តទុកតាមចេតនា និងសេចក្តីប្រាថ្នា ឈ្មោះថា **បណិធិ** (សេចក្តីតាំងចិត្ត) ។ ចំណែកធម៌មានផស្សៈជាដើម ដែលប្រកបព្រមនឹងចេតនាជាដើមនោះ ឈ្មោះថា សង្ខារ (ធម៌ដែលបច្ច័យតាក់តែង) ។

បទថា **ទិដ្ឋិ ហិ ភិក្ខវេ បាបិកា** (ម្នាលភិក្ខុទាំងឡាយ ព្រោះទិដ្ឋិអាក្រក់)

សេចក្តីថា ព្រោះថា ទិដ្ឋិរបស់បុគ្គលនោះអាក្រក់ថោកទាប ។ បទថា **និក្ខិត្តំ** បានដល់ ដាំទុក ។ បទថា **ឧបាទិយតិ** បានដល់ ស្រូបយក ។ បទនេះថា **កដុក-ត្តាយ** (ដើម្បីភាពល្វីងហាង) ជាវេវចនៈរបស់បទដំបូងនុ៎ះឯង ។

ក៏សូម្បីក្នុងទីនេះ គប្បីជ្រាបពាក្យថា **កដុកំ** ប្រែថា ល្វីង ដូចក្នុងអាគត-ស្ថាន (ព្រះបាលី) ថា "កាលមុន ស្វាយនេះជាឈើសម្បូរដោយពណ៌ ក្លិន និង រស បានទទួលការសរសើរហើយ ឥឡូវនេះ ស្វាយនេះក៏ក្លាយជាឈើមានផ្លែល្វីង ព្រោះហេតុអ្វី ។ បពិត្រព្រះបាទទធិវាហនៈ ស្វាយរបស់ព្រះអង្គ ត្រូវរួបរឹតដោយស្តៅ ឫសពាន់ព័ទ្ធដោយឫស មែកពាន់ព័ទ្ធដោយមែក ស្វាយនេះទើបក្លាយជាឈើមានផ្លែល្វីង ព្រោះនៅរួមនឹងដើមឈើមានរសល្វីង ។ បទថា **អសាត-ត្តាយ** (មិនគួរត្រេកអរ) សេចក្តីថា ព្រោះជារបស់មានរសមិនឆ្ងាញ់ ។

ក៏ក្នុង **វីជុបមសូត្រ** នេះ ព្រះថេរៈកាលមុនពោលថា និយតមិច្ឆាទិដ្ឋិ លោកកាន់យកដោយពាក្យថា ទិដ្ឋិ ។ តែពាក្យនោះ លោកបដិសេធហើយពោលថា រួមយកសូម្បីទិដ្ឋិទាំង ៦២ ។ ក្នុងព្រះសូត្រតទៅ គប្បីប្រកបកាយកម្មជាដើម ដែលតាំងនៅតាមទិដ្ឋិ ហើយជ្រាបដោយន័យមានជាដើមថា កាលបុគ្គលវៀរចាក បាណាតិបាត អទិន្នាទាន វៀរចាកមិច្ឆាចារ បុណ្យកើតពីការវៀរចាកនោះជាហេតុ រមែងមិនមាន ដូច្នេះ ។ ក៏ក្នុងទីនេះ គប្បីជ្រាបការតាំងចិត្ត ដែលកើតព្រមនឹង

*សម្មាទិដ្ឋិប៉ុណ្ណោះ ឈ្មោះថា* **បត្ថនា** *(សេចក្តីប្រាថ្នា) ។ ក៏ក្នុងអធិការនេះ លោកពោលសំដៅយកសម្មាទិដ្ឋិទាំងលោកិយៈ និងលោកុត្តរៈ ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា វគ្គទី ២

# អដ្ឋកថាវគ្គទី ៣

## *"ពោលដោយបុគ្គលតែម្នាក់ ដែលកើតឡើងហើយ ញុំាងការវិនាសដល់លោកជាដើម"*

## អដ្ឋកថាសូត្រទី ១

*គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[១៩១] បទថា **មិច្ឆាទិដ្ឋិកោ** (បុគ្គលជាមិច្ឆាទិដ្ឋិ) បានដល់ បុគ្គលដែលមិនឃើញតាមសេចក្ដីពិត ។ បទថា **វិបរីតទស្សនោ** (មានការឃើញវិបរិត) បានដល់ ជាអ្នកមានកាឃើញប្រែប្រួលទៅតាមការឃើញខុសនោះឯង ។ បទថា **សទ្ធម្មា វុដ្ឋាបេត្វា** (ឲ្យចេញពីព្រះសទ្ធម្មហើយ) សេចក្ដីថា ឲ្យចេញចាកធម៌ គឺ កុសលកម្មបថ ១០ ។ បទថា **អសទ្ធម្មេ បតិដ្ឋាបេតិ** សេចក្ដីថា ឲ្យតាំងនៅក្នុងអសទ្ធម្ម ពោលគឺ អកុសលកម្មបថ ១០ ។ ក៏ក្នុងបទថា **ឯកបុគ្គលោ** នេះ គប្បីជ្រាបថា បានដល់ ព្រះទេវទត្ត និងគ្រូទាំង ៦ និងបុគ្គលដទៃៗ ដែលមានសភាពដូច្នោះ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៩២] បទថា **សម្មាទិដ្ឋិកោ** (បុគ្គលជាសម្មាទិដ្ឋិ) បានដល់ អ្នកមានការឃើញតាមសេចក្តីពិត ។

បទថា **អវិបរីតទស្សនោ** (មានការឃើញមិនវិបរិត) បានដល់ អ្នកមានការឃើញដែលមិនប្រែប្រួលចាកពីការឃើញត្រូវនោះឯង ។ បទថា **អសទ្ធម្មា** សេចក្តីថា អកុសលកម្មបថ ១០ ។ បទថា **សទ្ធម្មេ** សេចក្តីថា ក្នុងសទ្ធម្ម ពោលគឺ កុសលកម្មបថ ១០ ។ ក៏ក្នុងបទថា **ឯកបុគ្គលោ** (បុគ្គលឯក) នេះ ក្នុងកាលព្រះពុទ្ធជាម្ចាស់ស្តេចមិនទាន់ឧប្បត្តិ រមែងបានដល់បុគ្គល មានជាដើមយ៉ាងនេះគឺ ស្តេចចក្រពត្តិ ព្រះសព្វញ្ញុពោធិសត្វ កាលព្រះពុទ្ធស្តេចឧប្បត្តិហើយ រមែងបានដល់ ព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធ ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៩៣] បទថា **មិច្ឆាទិដ្ឋិបរមានិ** (មានមិច្ឆាទិដ្ឋិដ៏ក្រៃលែង) នេះ មានវិគ្រោះថា មិច្ឆាទិដ្ឋិជាយ៉ាងក្រៃលែងនៃទោសទាំងនោះ ហេតុនោះ ទោសទាំងនោះ ឈ្មោះថា មានមិច្ឆាទិដ្ឋិជាយ៉ាងក្រៃលែង ។ អធិប្បាយថា អនន្តរិយកម្ម ៥ ឈ្មោះថា កម្មមានទោសច្រើន ។ មិច្ឆាទិដ្ឋិប៉ុណ្ណោះ ឈ្មោះថា មានទោសច្រើនជាងអនន្តរិយកម្ម ៥ សូម្បីទាំងនោះ ។

សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះអនន្តរិយកម្ម ៥ នោះ មានខេត្តកំណត់ ។ ព្រោះថា លោកពោលអនន្តរិយកម្ម ៤ យ៉ាងថា ឲ្យកើតក្នុងនរក ។ សូម្បីសង្ឃភេទ ក៏ជាកម្មតាំងនៅក្នុងនរកអស់នៃកប្បប៉ុណ្ណោះ ។ អនន្តរិយកម្មទាំងនោះមានខេត្តកំណត់ ទីបំផុតក៏ញុំាំងប្រាកដ ដោយប្រការយ៉ាងនេះ ។ ចំណែកនិយតមិច្ឆាទិដ្ឋិ (គឺការយើញខុសដែលទៀង) មិនមានខេត្តកំណត់ ព្រោះនិយតមិច្ឆាទិដ្ឋិនោះ ជាឫសគល់របស់វដ្ដៈ ។ ការចេញចាកភព រមែងមិនមានចំពោះបុគ្គលដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិនោះ ។ ជនពួកណា ជឿពាក្យរបស់បុគ្គលដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិនោះ ជនពួកនោះក៏រមែងបដិបត្តិខុស ។ មួយទៀត ទាំងសួគ៌ ទាំងមគ្គ រមែងមិនមានដល់បុគ្គលដែលប្រកបដោយនិយតមិច្ឆាទិដ្ឋិនោះ

ក្នុងគ្រាកប្បវិនាស កាលមហាជននាំគ្នាកើតក្នុងព្រហ្មលោក បុគ្គលដែលជានិយតមិច្ឆាទិដ្ឋិ មិនកើតក្នុងព្រហ្មលោកទេ (តែត្រឡប់) កើតត្រង់ខ្នងចក្រវាឡ ។ សួរថា ក៏ខ្នងចក្រវាឡភ្លើងមិនឆេះឬ ? ឆ្លើយថា ឆេះ ។ អាចារ្យពួកខ្លះពោលថា ក៏កាលខ្នងចក្រវាឡត្រូវភ្លើងឆេះហើយ បុគ្គលជានិយតមិច្ឆាទិដ្ឋិនេះ ក៏ត្រូវភ្លើងឆេះ នៅក្នុងឱកាសមួយក្នុងអាកាស ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[១៩៤] បទថា **មក្ខលិ** សេចក្ដីថា ម្ចាស់លទ្ធិដែលមានឈ្មោះយ៉ាងនេះ ព្រោះប្រកាន់ពាក្យថា **មា លិ** (កុំផ្ទាតដួល) ។ បទថា **នទីមុខេ** (មាត់ស្ទឹង) សេចក្ដីថា ក្នុងទីដែលស្ទឹង ២ ខ្សែមកជួបគ្នា ។ ពាក្យនេះត្រឹមតែ (លើកមក) ទេសនាប៉ុណ្ណោះ ។ ទឹកសូម្បីយ៉ាងដទៃបែបនោះ ដែលមកជួបគ្នានៃស្ទឹងខ្សែណាមួយ ក្នុងបណ្ដាទឹកទាំងនេះ គឺ ផ្លូវទឹក ២ ខ្សែ , ខ្សែទឹក ២ ខ្សែ , ទន្លេ , សមុទ្រ និងមេទឹកនៃសមុទ្រ (ក៏ដូចគ្នា) ។ បទថា **ខិបំ** ប្រែថា លប ។ បទថា **ឧឌ្ឌេយ្យ** (ទម្លាក់) បានដល់ ដាក់ ។ អធិប្បាយថា ពួកមនុស្សយកដើមបបុស ដើមអំពៅ ឬស្សី ឬសរសៃវល្លិ មកក្រងជាលបប៉ុនផ្ទាំង ១ ខ្ទះ ២ ខ្ទះ ៣ ខ្ទះ ចងប្រើសត្រង់មាត់លបដោយផ្ដៅ នាំទៅដាក់ យកមាត់លបពន្លិចទុកក្នុងទឹក បោះបង្គោលទុកទាំងពីរខាង ចងលបដោយផ្ដៅទុកនឹងគោលនោះ ។ ពាក្យថា **ដាក់លប** នេះ លោកពោលសំដៅយកការធ្វើដូចពោលហើយនោះឯង ។ សូម្បីត្រីតូចៗ ចូលទៅក្នុងលបនោះហើយ ក៏ចេញមិនបាន ។ បទថា **អនយាយ** (ដើម្បីសេចក្ដីសាបសូន្យ) សេចក្ដីថា ដើម្បីសេចក្ដីមិនចម្រើន ។ បទថា **ព្យសនាយ** សេចក្ដីថា ដើម្បីសេចក្ដីវិនាស ។ បទថា **មក្ខលិ មោឃបុរិសោ** បានដល់ បុរស

ទទេឈ្មោះ មក្ខលិគោសាលនេះ ។ បទថា **មនុស្សខិប្បំ មញ្ញេ លោកេ ឧប្បន្នោ** (ដូចលបសម្រាប់ដាក់មនុស្ស កើតឡើងហើយក្នុងលោក) សេចក្តីថា កើតឡើងហើយក្នុងលោក ដូចជាលបដាក់មនុស្ស ដើម្បីហាមមហាជនទៅក្នុងផ្លូវនោះ គឺផ្លូវទៅស្ថានសួគ៌ និងព្រះនិព្វាន ។

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥ ជាដើម

*ក្នុងសូត្រទី ៥ ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

[១៩៥] *បទថា* ***ទុរក្ខាតេ ភិក្ខវេ ធម្មវិនយេ*** *(ក្នុងធម្មវិន័យដែលពោលទុកខុស) មានអធិប្បាយថា ពាក្យទូន្មានរបស់ម្ចាស់លទ្ធិក្រៅព្រះសាសនា ឈ្មោះថា ធម្មវិន័យដែលពោលទុកខុស ។ ព្រោះថា ក្នុងពាក្យទូន្មាននោះ សូម្បីអ្នកទូន្មាន ក៏មិនមែនជាសព្វញ្ញូ សូម្បីធម៌ ក៏ជាធម៌ដែលពោលទុកខុស សូម្បីពួកគណៈ ក៏ជាអ្នកបដិបត្តិខុស ។ បទថា* ***យោ ច សមាទបេតិ*** *(អ្នកដឹកនាំ) បានដល់បុគ្គលដែលជាអាចារ្យណា រមែងដឹកនាំ ។ បទថា* ***យញ្ច សមាទបេតិ*** *(អ្នកត្រូវដឹកនាំ) សេចក្ដីថា ដឹកនាំអន្តេវាសិក (សិស្ស) ណា ។ បទថា* ***យោ ច សមាទបិតោ តថត្តាយ បដិបជ្ជតិ*** *(អ្នកដែលត្រូវដឹកនាំហើយ រមែងបដិបត្តិយ៉ាងនោះ) សេចក្ដីថា អន្តេវាសិកណា ត្រូវអាចារ្យបបួលហើយ ធ្វើតាមពាក្យរបស់អាចារ្យនោះ ឈ្មោះថា បដិបត្តិដើម្បីសេចក្ដីជាយ៉ាងនោះ ។ បទថា* ***ពហុំ អបុញ្ញំ បសវន្តិ*** *(រមែងប្រសព្វបាបកម្ម មិនមែនជាបុណ្យ) អធិប្បាយថា ក៏បុគ្គលដែលដឹកនាំ កាលដឹកនាំមនុស្ស ១០០ នាក់ ក្នុងកម្មមានបាណាតិបាតជាដើម រមែងបានអកុសលស្មើគ្នានឹងអកុសលរបស់បុគ្គលអ្នកត្រូវដឹកនាំ សូម្បីទាំងអស់នោះ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា មនុស្សទាំងអស់នោះ រមែងប្រសព្វ*

បាបកម្ម មិនមែនបុណ្យដ៏ច្រើន ។

[១៩៦] បទថា *ស្វាក្ខាតេ* (ដែលពោលទុកល្អហើយ) បានដល់ ក្នុងព្រះធម៌ និងព្រះវិន័យដែលត្រាស់ទុកល្អហើយ គឺ សម្ដែងទុកល្អហើយ ព្រោះក្នុងព្រះធម៌ និងព្រះវិន័យបែបនេះ ព្រះសាស្ដាក៏ទ្រង់ជាព្រះសព្វញ្ញូ ព្រះធម៌ ព្រះ-សាស្ដាក៏ត្រាស់ទុកល្អហើយ និងពួកគណៈក៏ជាអ្នកបដិបត្តិល្អហើយ ។ បទថា **សព្វេ តេ ពហុំ បុញ្ញំ បសវន្តិ** (បុគ្គលទាំងអស់នោះ រមែងប្រសព្វបុណ្យដ៏ច្រើន) មានអធិប្បាយថា បុគ្គលអ្នកដឹកនាំបានឃើញភិក្ខុទាំងឡាយចូលទៅបិណ្ឌបាត បានដឹកនាំអ្នកដទៃៗ ឲ្យប្រគេនបាយយាគូ និងភត្តជាដើម រមែងបានកុសលស្មើនឹងកុសលរបស់អ្នកថ្វាយទានសូម្បីទាំងអស់ ។ ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា បុគ្គលទាំងអស់នោះ រមែងប្រសព្វបុណ្យដ៏ច្រើន ។

[១៩៧] បទថា **ទាយកេន មត្តា ជានិតព្វា** (ទាយកគប្បីដឹងប្រមាណ) សេចក្ដីថា បុគ្គលដែលឲ្យគប្បីដឹងប្រមាណ គឺ គប្បីឲ្យល្មមប្រមាណ ឲ្យរហូតពេញ មិនគួរឲ្យរហូតហៀរ តែមិនពោលថា មិនគប្បីឲ្យ ដូច្នេះ ពោលថា គប្បីឲ្យតិចតួចល្មមប្រមាណ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះកាលពេញហើយ សូម្បីនឹងឲ្យបន្ថែមទៀត មនុស្សសម្បត្តិ ទិព្វសម្បត្តិ ឬនិព្វានសម្បត្តិ ដែលច្រើនហួសរមែងមិនមាន ។ បទថា **នោ បដិគ្គាហកេន** (បដិគ្គាហកៈមិនចាំបាច់ដឹងប្រមាណ)

សេចក្ដីថា ក៏ចំពោះបដិគ្គាហកៈ ឈ្មោះថា កិច្ចក្នុងការដឹងប្រមាណហើយទទួលយក រមែងមិនមាន ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះដែលឈ្មោះថាបដិបទាក្នុងភាពជាអ្នកប្រាថ្នាតិច ដែលមានមូលមកពីការដឹងប្រមាណពេញហើយទទួលល្មមប្រមាណ រមែងមិនមានដល់បដិគ្គាហកៈនោះ ។ ប៉ុន្តែថា បានប៉ុនណាគួរទទួលយកប៉ុណ្ណោះ ។ ព្រោះមូលក្នុងការទទួលដែលនៅសល់ហួរហៀរ នឹងជាការទទួលដើម្បីចិញ្ចឹមបុត្រ និងភរិយា សម្រាប់បដិគ្គាហកៈនោះឯង ។

[១៩៨] បទថា **បដិគ្គាហកេន មត្តា ជានិតព្វា** (បដិគ្គាហកៈគប្បីស្គាល់ប្រមាណ) សេចក្ដីថា បុគ្គលដែលជាបដិគ្គាហកៈគប្បីដឹងប្រមាណ ។ គប្បីដឹងយ៉ាងណា? គឺ កាលនឹងទទួល ត្រូវដឹងអំណាចរបស់អ្នកឲ្យ ត្រូវដឹងអំណាច (ច្រើនតិច) របស់ទេយ្យធម៌ ត្រូវដឹងកម្លាំងរបស់ខ្លួន ។ បើទេយ្យធម៌មានច្រើន អ្នកឲ្យត្រូវការឲ្យតិចសោត គួរទទួលយកតែតិចតាមកម្លាំងរបស់អ្នកឲ្យ ។ ទេយ្យធម៌មានតិច អ្នកឲ្យត្រូវការឲ្យច្រើន គួរទទួលយកតែតិចតាមកម្លាំងរបស់ទេយ្យធម៌ ។ សូម្បីទេយ្យធម៌ក៏ច្រើន សូម្បីអ្នកឲ្យក៏ត្រូវការនឹងឲ្យច្រើន បដិគ្គាហកៈគួរដឹងកម្លាំងរបស់ខ្លួន ហើយទទួលយកល្មមប្រមាណ ក៏កាលដឹងប្រមាណយ៉ាងនេះហើយទទួលយក រមែងធ្វើបដិបទា គឺ សេចក្ដីប្រាថ្នាតិចឲ្យពេញបរិបូណ៌ ។ លាភរមែងកើតឡើងដល់បុគ្គលដែលមិនធ្លាប់មានលាភកើតឡើងហើយ លាភដែលកើតឡើង

ហើយ រមែងតាំងនៅ ។ បុគ្គលដែលនៅមិនទាន់ជ្រះថ្លា ក៏ជ្រះថ្លា បុគ្គលដែលជ្រះថ្លាហើយ ក៏ជ្រះថ្លាក្រៃលែងឡើង ដូចជាបុគ្គលដែលជាទីគាប់ចិត្តរបស់មហាជនធ្វើព្រះសាសនាឲ្យតាំងនៅរហូតអស់កាលយូរ ។ ក្នុងសេចក្តីនោះ មានរឿងតទៅនេះជាឧទាហរណ៍ ៖

បានឮថា ក្នុង **រោហនជនបទ** មានភិក្ខុកំលោះមួយរូបនៅក្នុងកុឡុមរិយ-វិហារ ក្នុងសម័យដែលរកភិក្ខាហារលំបាក (លោក) ទទួលភត្តាហារតែមួយវែកដើម្បីឆាន់ ក្នុងផ្ទះរបស់នាយលម្ពកណ្ណ (កម្មករ) ម្នាក់ក្នុងស្រុកនោះ ហើយទទួលភត្តាហារវែកមួយទៀតប៉ុណ្ណោះ ដើម្បីប្រយោជន៍នឹងនាំទៅ ។ ថ្ងៃមួយ លោកបានឃើញភិក្ខុអាគន្តុកៈមួយរូបក្នុងផ្ទះនោះ ទើបទទួលយកភត្តាហារតែមួយវែកប៉ុណ្ណោះ ។ ព្រោះហេតុនោះ តមកខាងក្រោយ កុលបុត្រនោះជ្រះថ្លានឹងលោក ទើបប្រាប់ដល់ពួកមិត្តអាមាត្យត្រង់ទ្វារព្រះរាជវាំងថា ភិក្ខុប្រចាំត្រកូលរបស់យើង ជាអ្នកប្រាថ្នាតិចបែបនេះ ។ មិត្តអាមាត្យសូម្បីទាំងអស់នោះ ក៏ជ្រះថ្លាក្នុងគុណ គឺ សេចក្តីប្រាថ្នាតិចរបស់លោក នាំគ្នាតាំងភត្តាហារជាប្រចាំ ៦០ សម្រាប់ ក្នុងមួយថ្ងៃៗ ។ ភិក្ខុដែលប្រាថ្នាតិចជាធម្មតាយ៉ាងនេះឯង រមែងញុំាងលាភដែលមិនទាន់កើត ឲ្យកើតឡើង ។

សូម្បីព្រះរាជាសទ្ធាតិស្សមហារាជ ទ្រង់ឲ្យតិស្សអាមាត្រ ដែលជាអ្នកឧប-

ផ្លាកជិតទៅសាកសួរ ទ្រង់ឲ្យគេអាំងសត្វទទាមួយមកឲ្យ ។ កាលតិស្សអាមាត្រធ្វើយ៉ាងនោះហើយ លុះវេលាទឹងសោយទើបត្រាស់ថា យើងឲ្យចំណែកដ៏ប្រសើរហើយទើបបរិភោគ ទើបឲ្យប្រទានសាច់សត្វទទាដល់សាមណេរអ្នកកាន់វត្តរបស់ព្រះមហាថេរៈជិតបរិវេណកស្សត្ថសាលា កាលលោកទទួលយកតែបន្តិច ក៏ជ្រះថ្លាក្នុងគុណ គឺ សេចក្តីប្រាថ្នាតិចរបស់លោក ទើបត្រាស់ថា ម្នាលបា ញោមជ្រះថ្លាសូមថ្វាយកត្តាហារជាប្រចាំ ៨ សម្រាប់ដល់លោក ។ សាមណេរទូលថា មហាបពិត្រ កត្តាហារប្រចាំទាំងនោះ អាត្មាថ្វាយឧបជ្ឈាយ៍ ។

ព្រះរាជាត្រាស់ថា ញោមថ្វាយ ៨ សម្រាប់ទៀត ។ សាមណេរទូលថា កត្តាហារ ៨ សម្រាប់នោះ អាត្មាសូមថ្វាយអាចារ្យរបស់អាត្មា ។

ព្រះរាជាត្រាស់ថា ញោមថ្វាយ ៨ សម្រាប់ទៀត ។ សាមណេរទូលថា អាត្មាថ្វាយកត្តាហារ ៨ សម្រាប់នោះ ដល់លោកដែលស្មើដោយឧបជ្ឈាយ៍ ។

ព្រះរាជាត្រាស់ថា ញោមថ្វាយ ៨ សម្រាប់ទៀត សាមណេរទូលថា អាត្មាថ្វាយកត្តាហារ ៨ សម្រាប់នោះ ដល់ភិក្ខុសង្ឃ ។

ព្រះរាជាត្រាស់ថា ញោមថ្វាយកត្តាហារសូម្បី ៨ សម្រាប់ទៀត ។ សាមណេរនោះទើបទទួលយក ។ លាភដែលកើតឡើងដល់សាមណេរនោះ រមែងជាលាភដែលសម្បូរ ដោយប្រការយ៉ាងនេះ ។

សូម្បីក្នុងបទថា **អប្បសន្នា បសីទន្តិ** (អ្នកដែលមិនទាន់ជ្រះថ្លា ក៏ជ្រះថ្លាឡើង) នេះ ក៏មានឧបមាដូចតទៅនេះ ៖

ទីយព្រាហ្មណ៍ និមន្តព្រាហ្មណ៍ទាំងឡាយមកឆាន់ បានថ្វាយកត្តាហារម្តង ៥ ផ្តិល ក៏មិនអាចឲ្យឆ្អែតគ្រប់គ្រាន់ ។ នៅថ្ងៃមួយ បានស្តាប់ពាក្យថា បានឮថា ពួកព្រះសមណៈជាអ្នកប្រាថ្នាតិច ដើម្បីនឹងសាកល្បង ទើបឲ្យមនុស្សកាន់កត្តាហារទៅកាន់វិហារក្នុងវេលាដែលព្រះភិក្ខុសង្ឃធ្វើភត្តកិច្ច ឃើញភិក្ខុប្រមាណ ៣០ រូប ឆាន់នៅលើរោងឆាន់ ទើបកាន់យកកត្តាហារមួយផ្តិលទៅកាន់ទីជិតព្រះសង្ឃត្ថេរ ។ ព្រះថេរៈបានប្រើម្រាមដៃចាប់យកបន្តិច ។ ដោយទំនងនេះនុ៎ះឯង កត្តាហារតែមួយផ្តិល ក៏បានទូទៅដល់ភិក្ខុគ្រប់រូប ។ អំពីនោះមក ព្រាហ្មណ៍ក៏ជ្រះថ្លាក្នុងសេចក្តីប្រាថ្នាតិចថា បានឮថា ព្រះសមណៈទាំងនេះ មានគុណគ្រប់យ៉ាង ទើបលះបង់ទ្រព្យមួយពាន់ សាងព្រះចេតិយទុកក្នុងវិហារនោះឯង ។ អ្នកដែលមិនទាន់ជ្រះថ្លា រមែងជ្រះថ្លា ដោយប្រការយ៉ាងនេះ ។

ក្នុងបទថា **បសន្នា ភិយ្យោ បសីទន្តិ** (អ្នកដែលជ្រះថ្លាហើយ ក៏កាន់ជ្រះថ្លាឡើង) នេះ កិច្ចជាប់ដោយរឿងរ៉ាវ (ដែលនឹងនាំមកសាធកៈ) មិនមាន ។ ក៏ព្រោះឃើញសេចក្តីប្រាថ្នាតិច សេចក្តីជ្រះថ្លា រមែងចម្រើនក្រៃលែងឡើងដល់អ្នកដែលជ្រះថ្លាហើយ ។

ក៏មហាជនបានឃើញបុគ្គលអ្នកប្រាថ្នាតិច ដូចព្រះមជ្ឈន្តិកតិស្សត្ថេរៈជាដើម រមែងសម្គាល់ថា ជាអ្នកប្រាថ្នាតិចខ្លះ ព្រោះហេតុនោះ អ្នកប្រាថ្នាតិច ទើបឈ្មោះថា ជាបុគ្គលសំខាន់របស់មហាជន ។ មួយទៀត អ្នកប្រាថ្នាតិច ឈ្មោះថា រមែងធ្វើព្រះសាសនាឲ្យតាំងនៅបានយូរ ព្រោះព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រាថ្នាតិច រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីតាំងមាំ ដើម្បីសេចក្ដីមិនជាប់ជំពាក់ ដើម្បីសេចក្ដីមិនអន្តរធាននៃព្រះសទ្ធម្ម ដូច្នេះ ។

បទថា **នោ ទាយកេន** (ទាយកមិនបាច់ដឹងប្រមាណទេ) សេចក្ដីថា ក៏ក្នុងព្រះធម្មវិន័យដែលត្រាស់ទុកល្អហើយ ឈ្មោះថា កិច្ចដែលត្រូវដឹងប្រមាណហើយទើបឲ្យ រមែងមិនមានដល់ទាយក ។ ទេយ្យធម៌ប្រមាណប៉ុនណាមានហើយ គួរឲ្យមិនលើសប្រមាណប៉ុណ្ណោះ ។ ក៏ទាយកអ្នកឲ្យនេះ រមែងបាននូវវត្ថុដែលប្រណីតក្រៃលែងៗ ឡើង មិនលើសមនុស្សសម្បត្តិ និងទិព្វសម្បត្តិ ព្រោះហេតុដែលឲ្យហួសលើសប្រមាណ ។

[១៩៩] បទថា **យោ អារទ្ធវីរិយោ សោ ទុក្ខំ វិហរតិ** (បុគ្គលប្រារព្ធសេចក្ដីព្យាយាម... រមែងនៅជាទុក្ខ) សេចក្ដីថា បុគ្គលប្រកបរឿយៗ នូវវត្ត មានការធ្វើឲ្យក្ដៅ ដោយសេចក្ដីក្ដៅ ៥ យ៉ាង ការធ្វើសេចក្ដីព្យាយាមដោយការកប់ក្នុងរណ្ដៅខ្សាច់ ការត្រឡប់ទៅមកក្រោមកំដៅព្រះអាទិត្យ ( គឺដេកកណ្ដាលថ្ងៃ )

សេចក្តីព្យាយាមក្នុងការអត្តឃចប្រហោងជាដើម រមែងនៅជាទុក្ខក្នុងបច្ចុប្បន្ន ។ កាលបុគ្គលនោះឯងសមាទាន (វត្ត) ក្នុងលទ្ធិខាងក្រៅព្រះសាសនា (គេ) កើតក្នុងនរកដោយវិបាកនៃការប្រព្រឹត្តតបៈនោះ ឈ្មោះថា រមែងនៅជាទុក្ខក្នុងសម្បរាយភព ។

[២០០] បទថា *យោ កុសីតោ សោ ទុក្ខំ វិហរតិ* (បុគ្គលខ្ជិលច្រអូស... រមែងនៅជាទុក្ខ) សេចក្តីថា សូម្បីបុគ្គលខ្ជិលច្រអូសនេះ ក៏នៅជាទុក្ខ ទាំងក្នុងបច្ចុប្បន្ន និងក្នុងសម្បរាយភព ។

សួរថា នៅជាទុក្ខយ៉ាងណា? ឆ្លើយថា បុគ្គលណា ចាប់ផ្តើមតាំងពីបួសមក មិនមានការធ្វើទុកក្នុងចិត្តដោយឧបាយ មិនរៀនព្រះពុទ្ធវចនៈ មិនធ្វើអាចរិយវត្ត និងឧបជ្ឈាយវត្ត មិនធ្វើវត្ត (គឺការបោសសំអាត) លានព្រះចេតិយ និងលានព្រះពោធិ៍ ។ បរិភោគសទ្ធាទេយ្យ (របស់ដែលគេឲ្យដោយសទ្ធា) របស់មហាជន ដោយការមិនពិចារណា ប្រកបរឿយៗ នូវសេចក្តីសប្បាយក្នុងការដេករហូតអស់ថ្ងៃ ក្នុងវេលាភ្ញាក់ឡើង ក៏ត្រិះរិះដោយវិតក្កៈ ៣ ប្រការ (គឺកាមវិតក្កៈ ព្យាបាទវិតក្កៈ វិហិង្សាវិតក្កៈ) បុគ្គលនោះ រមែងឃ្លាតចាកភិក្ខុភាវៈ (ភាពជាភិក្ខុ) ដោយពីរបីថ្ងៃប៉ុណ្ណោះ ។ ឈ្មោះថា នៅជាទុក្ខក្នុងបច្ចុប្បន្ន ដោយប្រការយ៉ាងនេះ និងក៏ព្រោះបួសហើយ មិនធ្វើសមណធម៌ដោយប្រពៃ គេរមែងបដិសន្ធិក្នុង

ក្នុងអបាយតែម្យ៉ាង ព្រោះមានបាលីថា ៖

កុសោ យថា ទុគ្គហិតោ ហត្ថមេវានុកន្តតិ
សាមញ្ញំ ទុប្បរាមដ្ឋំ និរយាយុបកឌ្ឍតីតិ ។

គុណជាគ្រឿងលំអសមណៈ (ព្រហ្មចរិយៈ) ដែលបុគ្គលចាប់មិនល្អ រមែងនាំទៅនរក ដូចស្បូវក្លាំងដែលបុគ្គលចាប់មិនណែន (ហើយទាញមក) រមែងមុតដៃនុ៎ះឯង ដូច្នោះ ។

ឈ្មោះថា រមែងនៅជាទុក្ខក្នុងសម្បរាយភព ដោយប្រការយ៉ាងនេះ ។

[២០១] បទថា *យោ កុសីតោ សោ សុខំ វិហរតិ* (បុគ្គលខ្ជិលច្រអូស... រមែងនៅជាសុខ) សេចក្ដីថា បុគ្គលធ្វើការប្រព្រឹត្តតបៈអ្វីៗ ក្នុងការប្រព្រឹត្តតបៈដែលមានប្រការដូចពោលហើយតាមវេលា ស្លៀកសំពត់ស ទ្រទ្រង់ផ្កាឈើ និងលាបរបស់ក្រអូប បរិភោគភោជនដែលឆ្ងាញ់ ដេកលើទីដេកដែលទន់តាមវេលា រមែងនៅជាសុខក្នុងបច្ចុប្បន្ន និងសម្បរាយភព ។ ក៏ព្រោះគេមិនប្រកាន់មាំការប្រព្រឹត្តតបៈនោះ ទើបមិនសោយទុក្ខក្នុងនរក ព្រោះដូច្នោះ ទើបឈ្មោះថា នៅជាសុខក្នុងសម្បរាយភព ។

[២០២] បទថា *យោ អារទ្ធវីរិយោ សោ សុខំ វិហរតិ* (បុគ្គលប្រារព្ធសេចក្ដីព្យាយាម...រមែងនៅជាសុខ) សេចក្ដីថា បុគ្គលប្រារព្ធសេចក្ដីព្យាយាម ផ្ដើម

តាំងពីកាលដែលបានបួសមក រមែងធ្វើឲ្យបរិបូណ៌ក្នុងវត្តទាំងឡាយ រៀនយកព្រះពុទ្ធវចនៈ ធ្វើកម្មក្នុងយោនិសោមនសិការ កាលគេនឹកដល់ការបំពេញវត្ត ការរៀនសូត្រព្រះពុទ្ធវចនៈ និងការធ្វើសមណធម៌ ចិត្តរមែងជ្រះថ្លា ព្រោះហេតុនោះ ទើបឈ្មោះថា នៅជាសុខក្នុងបច្ចុប្បន្ន ដោយប្រការដូច្នេះ ។ តែកាលមិនអាចសម្រេចព្រះអរហន្តក្នុងបច្ចុប្បន្ន រមែងនឹងជាអ្នកត្រាស់ដឹងរហ័សក្នុងភពដែលកើត ព្រោះហេតុនោះ ទើបឈ្មោះថា នៅជាសុខសូម្បីក្នុងសម្បរាយភព ។

[២០៣] ព្រះសូត្រនេះ មានពាក្យជាដើមថា "ម្នាលភិក្ខុទាំងឡាយ លាមកសូម្បីមានចំនួនតិចក៏មានក្លិនស្អុយ យ៉ាងណា" ដូច្នេះ ត្រាស់ទុកព្រោះអត្ថុប្បត្តិ (ហេតុកើតរឿង) ។

សួរថា ហេតុកើតរឿងដូចម្តេច? ឆ្លើយថា ហេតុកើតរឿងនៃសត្តុប្បាទសូត្រ ក្នុងនវកនិបាត ។ ពិតណាស់ ព្រះតថាគត កាលនឹងត្រាស់រឿងនោះ បានត្រាស់ថា "បុគ្គល ៩ ជំពូក ផុតពីនរក ផុតពីកំណើតសត្វតិរច្ឆាន ផុតពីប្រេតវិស័យ" ដូច្នេះជាដើម ។ គ្រានោះ ព្រះតថាគតមានព្រះតម្រិះថា ក៏បើបុត្ររបស់យើងស្តាប់ធម្មទេសនានេះហើយសម្គាល់ថា ពួកយើងជាអ្នកអស់នរក អស់កំណើតសត្វតិរច្ឆាន អស់ប្រេតវិស័យ អស់អបាយ ទុគ្គតិ វិនិបាតហើយ ក៏នឹងមិនគប្បីសម្គាល់ដល់សេចក្តីព្យាយាមដើម្បីមគ្គផលខ្ពស់ៗ ឡើងទៅ តថាគតនឹងធ្វើសេចក្តីសង្វេគ

ឲ្យកើតដល់បុត្ររបស់យើងទាំងនោះ ដូច្នេះហើយ ទើបទ្រង់ផ្ដើមព្រះសូត្រនេះថា *សេយ្យថាបិ ភិក្ខវេ* (ម្នាលភិក្ខុទាំងឡាយ ប្រៀបដូច...សូម្បីយ៉ាងណា) ដូច្នេះជាដើម ដើម្បីនឹងឲ្យកើតសង្វេគ ។

បណ្ដាបទទាំងនោះ បទថា **អប្បមត្តកោ** (ត្រឹមតែតិចតួច) បានដល់ មានប្រមាណបន្តិច គឺ មានប្រមាណតិច ។ លាមកនោះ ដោយទីបំផុតសូម្បីតែចុងស្លឹកស្មៅក្ដាំង ក៏ជុំក្លិនស្អុយនុ៎ះឯង ។

[២០៤] បទថា **អប្បមត្តកំបិ ភវំ ន វណ្ណេមិ** (ភពសូម្បីតិចតួច តថាគតមិនសរសើរ) សេចក្ដីថា តថាគតមិនសរសើរការបដិសន្ធិក្នុងភពសូម្បីដោយកាលតិចតួច ។ ឥឡូវនេះ កាលនឹងទ្រង់សម្ដែងការប្រៀបធៀបកាលវេលានោះ ទើបត្រាស់ថា **អន្តមសោ អច្ឆរាសង្ឃាតមត្តំបិ** (ដោយទីបំផុត សូម្បីត្រឹមតែវេលាផ្ទាត់ម្រាមដៃ) ដូច្នេះ ។ ក្នុងពាក្យនេះ លោកអធិប្បាយថា ក្នុងកាលសូម្បីត្រឹមតែយកម្រាមដៃ ២ មករួមគ្នាហើយ ផ្ទាត់ចេញជាកំណត់យ៉ាងទាបបំផុត ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្ដីងាយទាំងនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៩ ជាដើម

## ចប់អដ្ឋកថាវគ្គទី ៣

# អដ្ឋកថាវគ្គទី ៤

*"ពោលដោយសត្វកើតក្នុងមជ្ឈិមជនបទមានតិច"*

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖*

*[២០៥] បទថា **ជម្ពុទីបេ** (ក្នុងជម្ពូទ្វីប) សេចក្តីថា ឈ្មោះថា ជម្ពូទ្វីប ព្រោះជាទ្វីបដែលគេដឹងទូទៅ គឺ ប្រាកដដោយដើមព្រីងជាសម្គាល់ ។ គេថា ទ្វីបនេះ មានដើមព្រីងធំកម្ពស់ ១០០ យោជន៍ មែកប្រវែង ៥០ យោជន៍ ទំហំដើមមូល ១៥ យោជន៍ កើតនៅត្រង់ក្នុំហិមពាន្តតាំងនៅអស់នៃកប្ប ។ ទ្វីបនេះ ហៅថា **ជម្ពូទ្វីប** ព្រោះមានដើមព្រីងធំនោះ ។ម្យ៉ាងទៀត ក្នុងទ្វីបនេះ ដើមព្រីងតាំងនៅអស់នៃកប្ប យ៉ាងណា សូម្បីដើមឈើទាំងនេះ គឺ ដើមកូម្ពក្នុងអមរគោយានទ្វីប ដើមកល្បព្រឹក្សក្នុងឧត្តរកុរុទ្វីប ដើមជ្រៃក្នុងបុព្វវិទេហទ្វីប ដើមប្រទៀងរបស់ពួកអសុរ ដើមរការបស់ពួកគ្រុឌ ដើមបារិច្ឆត្តរបស់ពួកទេវតា ក៏តាំងនៅអស់នៃកប្បដូចគ្នា ដូច្នោះ ។ លោកប្រព័ន្ធជាគាថាទុកថា ៖*

*បាតលី សិម្ពលី ជម្ពូ ទេវានំ បារិឆត្តកោ*
*កទម្ពោ កប្បរុក្ខោ ច សិរីសេន ភវតិ សត្តមោ*

ដើមប្រទៀង ដើមរកា ដើមព្រីង ដើមបារិច្ឆត្តរបស់ទេវតា ដើមកុម្ព ដើមកល្បព្រឹក្ស និងដើមជ្រេសជាតម្រប់ ៧ ដើម ។

បទថា **អារាមរាមណេយ្យកំ** (សួនដែលគួររីករាយ) សេចក្តីថា បណ្តាសួនផ្កាឈើ និងសួនផ្លែឈើ ដែលគួររីករាយ ដូចសួនព្រះវេឡុវ័ន ជីវកម្ពវ័ន ជេតវ័ន និងបុព្វារាម ។ សួនដែលគួររីករាយនោះ ក្នុងជម្ពូទ្វីបនេះមានតិច គឺតិចតួច អធិប្បាយថា មានមិនច្រើន ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។ បទថា **វនរាមណេយ្យកំ** (ព្រៃដែលគួររីករាយ) ក្នុងសូត្រនេះ គប្បីជ្រាបថា ព្រៃឈើ គឺ ដងព្រៃ ក្នុងប្រទេសនៃភ្នំវង្ក និងភ្នំហេមវន្តជាដើម ក៏ដូចគ្នានឹងព្រៃនាគវ័ន ព្រៃសាលវ័ន និងព្រៃចម្បកវ័នជាដើម ។ បទថា **ភូមិរាមណេយ្យកំ** (ភូមិប្រទេសដែលគួររីករាយ) បានដល់ ផ្ទៃដីដែលស្មើ (គឺរៀបរយ) ដូចព្រះជេតវ័នវិហារ និងស្រែក្នុងដែនមគធៈជាដើម ។ បទថា **បោក្ខរណីរាមណេយ្យកំ** (ស្រះបោក្ខរណីដែលគួររីករាយ) បានដល់ ទីតាំងស្រះបោក្ខរណីដែលមានសណ្ឋានមូលបួនជ្រុង វែង និងកោងជាដើម ដូចស្រះបោក្ខរណីរបស់ស្តេចជេត និងស្រះបោក្ខរណីរបស់ស្តេចមល្លៈ ។ បទថា **ឧក្កូលវិកូលំ** បានដល់ ទីទួល និងទីទំនាប ។ ក្នុងព្រះបាលីថា **ឧក្កូលវិកូលំ** នោះ ទីទួល ឈ្មោះថា **ឧក្កូល** ទីទំនាប ឈ្មោះថា **វិកូល** ។ បទថា **នទីវិទុគ្គំ** (លំហទឹក) បានដល់ ស្ទឹង ដែល

ហៅ **នទីវិទុគ្គំ** ព្រោះជាស្ទឹងដែលហូរទៅលំបាក ។ បទថា **ខាណុកណ្ដកដ្ឋានំ** (ទីតាំងនៃដង្គត់ និងបន្លា) បានដល់ ទីសម្បូរដោយដង្គត់ និងបន្លា ដែលកើតក្នុងទីនោះឯង និងដែលបុគ្គលដទៃនាំមកបោល ។ បទថា **បព្វតវិសមំ** (ភ្នំរដិបរដុប) បានដល់ ទីរដិបរដុបនៃភ្នំទុំះឯង ។

បទថា **យេ ឱទកា** (សត្វដែលកើតក្នុងទឹក) សេចក្ដីថា សត្វដែលកើតក្នុងទឹកប៉ុណ្ណោះ ច្រើនជាង ។ បានឮថា ចាកជម្ពូទ្វីបនេះទៅ ប្រមាណ ៧០០ យោជន៍ មានប្រទេសឈ្មោះថា សុវណ្ណភូមិ ។ សំពៅត្រាច់ទៅដោយខ្យល់បក់ទៅផ្លូវតែមួយ នឹងធ្វើដំណើររហូតអស់វេលា ៧ ថ្ងៃ ៧ យប់ ។ សម័យមួយ ទូកត្រាច់ទៅយ៉ាងនោះ ធ្វើដំណើរទៅត្រឹមតែ ៧ ថ្ងៃ (ដោយត្រាច់ទៅ) តាមក្រោយត្រីនន្ទិយាវដ្ដ[1] គប្បីជ្រាបថា សត្វក្នុងទឹកមានច្រើនយ៉ាងនេះ ។ ប្រការមួយទៀត ព្រោះលើដីមានតិច និងព្រោះក្នុងទឹកមានច្រើន គប្បីជ្រាបអត្ថក្នុងរឿងនេះ ដូចតទៅនេះ ៖

ដូចជា ក្នុងបឹងធំមានឈូកមួយគុម្ព មានស្លឹក ៤ សន្លឹក ចំពោះត្រង់កណ្ដាល (គុម្ព) មានផ្កាឈូកក្រពុំមួយផ្កា យ៉ាងណា ទ្វីបទាំង ៤ ដូចស្លឹកឈូក ៤ សន្លឹក ភ្នំសិនេរុ ដូចផ្កាឈូកក្រពុំត្រង់ណ្ដាល (គុម្ព) ដូច្នោះដែរ ។ ឱកាសទំនេរដែល

---

១-គេថា ត្រីទំហំធំៗ ច្រើន អាចជាត្រីប្រភេទត្រីវាឡក៏មាន ។

ទឹកលោមព័ន្ធទ្វីប ក៏ដូចទឹកដ៏សេស ។ ទឹកជារបស់ច្រើននោះ រមែងប្រាកដដល់លោកអ្នកមានឫទ្ធិ ។ ព្រោះកាលលោកអ្នកមានឫទ្ធិទៅផ្លូវអាកាស ទ្វីបទាំង ៤ រមែងប្រាកដដូចស្ទឹកឈូក ៤ សន្ទឹក ភ្នំសិនេរុ ប្រាកដដូចផ្កាឈូកក្រពុំនៅត្រង់កណ្តាល គប្បីជ្រាបថា ព្រោះសត្វកើតក្នុងទឹកមានច្រើន សត្វក្នុងទឹកប៉ុណ្ណោះទើបច្រើនជាង ដោយប្រការយ៉ាងនេះ ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២ ជាដើម

ក្នុងសូត្រទី ២ ជាដើម គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ៖

[២០៦] បទថា *អញ្ញត្រ មនុស្សេហិ* (ក្នុងកំណើតដ៏ទៃពីមនុស្ស) សេចក្តីថា ក្នុងទីនេះលោកប្រាថ្នាយកអបាយទាំង ៤ វៀរមនុស្សទាំងឡាយ ។

បទថា *មជ្ឈិមេសុ ជនបទេសុ* (ក្នុងមជ្ឈិមជនបទ) អធិប្បាយថា ក្នុងទិសខាងកើត មាននិគមឈ្មោះ កជង្គលៈ , តពីនិគមនោះទៅ ជាមហាសាលនគរ , បន្ទាប់ពីមហាសាលនគរនោះទៅ ជាបច្ចន្តជនបទ រួមចូលមក ជាមជ្ឈិម-ប្រទេស ។

ក្នុងទិសខាងកើតឆៀងខាងត្បូង មានទន្លេឈ្មោះថា សាលវតី បន្ទាប់ពីទន្លេនោះទៅជាបច្ចន្តជនបទ រួមមក ជាមជ្ឈិមប្រទេស , ក្នុងទិសត្បូង មាននិគមឈ្មោះថា សេតកណ្ណិកៈ បន្ទាប់ពីនិគមនោះទៅ ជាបច្ចន្តជនបទ រួមមកជាមជ្ឈិមប្រទេស , ក្នុងទិសខាងលិច មានស្រុកព្រាហ្មណ៍ឈ្មោះ ថូនៈ បន្ទាប់ពីស្រុកព្រាហ្មណ៍នោះទៅ ជាបច្ចន្តជនបទ រួមមក ជាមជ្ឈិមប្រទេស , ក្នុងទិសឧត្តរមានភ្នំឈ្មោះ ឧសីរធជៈ បន្ទាប់ពីភ្នំនោះ ជាបច្ចន្តជនបទ រួមមក ជាមជ្ឈិមប្រទេស , ក្នុងជនបទដែលលោកកំណត់ទុកដូចពោលមកដូច្នេះ ។ ជនបទនេះ មានសណ្ឋាន

ដូចស្គរសំភោរ (វាស់) ដោយត្រង់ កន្លែងខ្លះ ៨០ យោជន៍ កន្លែងខ្លះ ១០០ យោជន៍ កន្លែងខ្លះ ២០០ យោជន៍ តែត្រង់កណ្តាល ៣០០ យោជន៍ (វាស់) ដោយជុំវិញ ៩០០ យោជន៍ ។ សត្វទាំងនេះ គឺ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវក ព្រះពុទ្ធបដ្ឋាក និងព្រះពុទ្ធសាវក ព្រះពុទ្ធមាតា ព្រះពុទ្ធបិតា ស្តេចចក្រពត្តិ រមែងកើតក្នុងទីមានប្រមាណប៉ុណ្ណោះ ។ ប្រការមួយទៀត មជ្ឈិមប្រទេស សូម្បីប្រៀបធៀបយករមែងបាន ។ គប្បីជ្រាបន័យយ៉ាងនេះថា ក៏ជម្ពូទ្វីបសូម្បីទាំងអស់ឈ្មោះថា ជាមជ្ឈិមប្រទេស ទ្វីបដ៏សេសជាបច្ចន្តជនបទ ។ ក្រុងអនុរាធបុរៈ ក្នុងតម្ពបណ្ណិទ្វីប (កោះលង្កា) ឈ្មោះថា ជាមជ្ឈិមប្រទេស ប្រទេសដ៏សេសជាបច្ចន្តជនបទ ។

ក្នុងបទថា **បញ្ញវន្តោ អជឡា អនេឡមូគា** (មានបញ្ញា មិនល្ងង់ខ្លៅ មិនល្ងង់ល្ងើ) នេះ បុគ្គលប្រកបដោយបញ្ញាទាំងនេះ គឺ កម្មស្សកតាបញ្ញា ១ ឈានបញ្ញា ១ វិបស្សនាបញ្ញា ១ មគ្គបញ្ញា ១ ផលបញ្ញា ១ ឈ្មោះថា បុគ្គលមានបញ្ញា ។ បុគ្គលមិនល្ងង់ខ្លៅ ឈ្មោះថា បុគ្គលមិនវង្វេង ។ ទឹកមាត់របស់ជនពួកណាមិនហូរចេញពីមាត់ ជនទាំងនោះ ឈ្មោះថា អ្នកមិនមានទឹកមាត់ហូរ ។ អធិប្បាយថា មាត់មិនមានទឹកមាត់ (មិនហូរ) មាត់មិនមានទោស ។

បទថា **បដិពលា** (អាច) បានដល់ អ្នកអាច គឺ ជាអ្នកប្រកបដោយកម្លាំង

កាយ និងកម្លាំងញាណ ។ បទថា **អត្ថមញ្ញាតុំ** (ទើងដឹងអត្ថ) សេចក្តីថា ដើម្បីដឹងប្រយោជន៍ និងមិនមែនប្រយោជន៍ ហេតុ និងមិនមែនហេតុ ។ បទថា **ទុប្បញ្ញា** បានដល់ អ្នកមិនមានបញ្ញា ។ បទថា **ជឡា** បានដល់ អ្នកល្ងង់ល្ងើ ។

បទថា **អរិយេន បញ្ញាចក្ខុនា** (ដោយបញ្ញាចក្ខុដ៏ប្រសើរ) សេចក្តីថា ព្រមដោយវិបស្សនា និងមគ្គ ។ បទថា **អវិជ្ជាគតា** (ធ្លាក់ទៅក្នុងអវិជ្ជា) សេចក្តីថា បុគ្គលប្រកបដោយសេចក្តីងងឹត គឺ អវិជ្ជា ។

បទថា **យេ លភន្តិ តថាគតំ ទស្សនាយ** (សត្វដែលបានឃើញព្រះតថាគត) សេចក្តីថា សត្វពួកណាដឹងគុណរបស់ព្រះតថាគត រមែងបានឃើញព្រះតថាគតដោយចក្ខុវិញ្ញាណ ។

បទថា **តថាគតប្បវេទិតំ** (ដែលព្រះតថាគតប្រកាសទុក) សេចក្តីថា ដែលព្រះតថាគតប្រកាសហើយ គឺ ត្រាស់ប្រកាសទុកហើយ ។ បទថា **សវនាយ** (ដើម្បីស្តាប់) បានដល់ ដើម្បីស្តាប់ដោយសោតវិញ្ញាណ ។

បទថា **ធារេន្តិ** (ទ្រទ្រង់ចាំទុក) បានដល់ មិនវង្វេងភ្លេចក្នុងព្រះធម្មវិន័យនោះ ។ បទថា **ធតានំ ធម្មានំ អត្ថំ ឧបបរិក្ខន្តិ** (សត្វដែលពិចារណាអត្ថនៃធម៌ដែលខ្លួនចាំទុកបាន) សេចក្តីថា សាកសួរអត្ថ និងមិនមែនអត្ថនៃព្រះបាលីដោយរបៀបរបប ។ បទថា **អត្ថមញ្ញាយ ធម្មមញ្ញាយ** (ដឹងទូទៅដល់អត្ថ ដឹងទូទៅដល់

ធម៌ហើយ) បានដល់ ដឹងអដ្ឋកថា និងបាលី ។ **ធម្មានុធម្មំ បដិបជ្ជន្តិ** (បដិបត្តិធម៌សមគួរដល់ធម៌) បានដល់ បំពេញបដិបទាដែលសមគួរ ។

បទថា **សំវេជនីយេសុ ឋានេសុ** (ក្នុងឋានៈជាទីតាំងនៃសេចក្ដីស្លុតចិត្ត) បានដល់ ក្នុងហេតុដែលគួរសង្វេគ ។ បទថា **សំវិជ្ជន្តិ** (ស្លុតចិត្ត) សេចក្ដីថា រមែងដល់សេចក្ដីសង្វេគ ។ បទថា **យោនិសោ បទហន្តិ** (ផ្ដើមតាំងសេចក្ដីព្យាយាមដោយល្អ) សេចក្ដីថា ធ្វើបធានៈ គឺ សេចក្ដីព្យាយាមដែលតាំងទុកដោយឧបាយ ។

បទថា **វវស្សគ្គារម្មណំ** (ធ្វើនិព្វានឲ្យជាអារម្មណ៍) សេចក្ដីថា ព្រះនិព្វានហៅថា វវស្សគ្គៈ (សេចក្ដីស្លុតចិត្តជាទីលះបង់សង្ខារ) ។ ធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍ ។ បទថា **លភន្តិ សមាធឹ** (បានសមាធិ) សេចក្ដីថា រមែងបានមគ្គសមាធិ និងផលសមាធិ ។

បទថា **អន្នគ្គរសគ្គានំ** បានដល់ បាយដ៏ប្រសើរ និងរសដ៏ប្រសើរ ។ បទថា **ឧញ្ឆេន កបាលភត្តេន យាបេន្តិ** (ញុំាងអត្តភាពឲ្យប្រព្រឹត្តដោយការស្វែងរក ដោយភត្តដែលនាំមកដោយអំបែង) សេចក្ដីថា រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយមើមឈើ និងផ្លែឈើតូចធំក្នុងព្រៃ ឬដោយភត្តាហារដែលខ្ទួននាំមកហើយដោយអំបែង ព្រោះការស្វែងរក ។ ក៏ក្នុងរឿងនេះ បុគ្គលណា កាលចិត្ត

កើតត្រូវការរបស់ទំពាររបស់ស៊ីអ៊ីៗ មិនបានរបស់នោះភ្លាមៗ បុគ្គលនេះឈ្មោះ ថា មិនបានបាយដ៏ប្រសើរ និងរសដ៏ប្រសើរ ។ សូម្បីកាលបុគ្គលណា បានក្នុង ពេលភ្លាមៗ ហើយសម្លឹងមើល (ឃើញ) ពណ៌ ក្លិន និងរស មិនពេញចិត្ត សូម្បីបុគ្គលនេះ ក៏ឈ្មោះថា មិនបានបាយដ៏ប្រសើរ និងរសដ៏ប្រសើរ ។ ចំណែក បុគ្គលណា បានរបស់ដែលមាន ពណ៌ ក្លិន និងរសពេញចិត្ត បុគ្គលនេះ ឈ្មោះ ថា បានបាយដ៏ប្រសើរ និងរសដ៏ប្រសើរ ។ បុគ្គលអ្នកនោះ គប្បីជ្រាបដោយខ្លួន ខ្ពង់ខ្ពស់ ដូចស្តេចចក្រពត្តិ ដោយខ្លួនយ៉ាងទាប ដូចព្រះបាទធម្មាសោករាជ ។ ក៏ដោយសង្ខេប កត្តាហារមួយថាសមានតម្លៃមួយសែន ឈ្មោះថា បាយដ៏ប្រសើរ និងរសដ៏ប្រសើរ ។

សួរថា ក៏កាលពួកមនុស្សបានឃើញភិក្ខុសង្ឃត្រាច់បិណ្ឌបាត ហើយថ្វាយ កត្តាហារដ៏ឧត្តម និងប្រណីត នេះហៅថាអ្វី? ឆ្លើយថា នេះក៏ហៅថា បាយដ៏ ប្រសើរ និងរសដ៏ប្រសើរ ព្រោះប្រៀបធៀបបុគ្គលដែលញ៉ាំងអត្តភាពឲ្យប្រព្រឹត្ត ទៅដោយកត្តាហារដែលខ្លួននាំមកដោយអំបែង ដោយការស្វែងរក ។

ក្នុងបទថា **អត្ថរសស្ស** (អត្ថរស) ជាដើម មានអធិប្បាយថា សាមញ្ញ- ផល ៤ ឈ្មោះថា អត្ថរស ។ មគ្គ ៤ ឈ្មោះថា ធម្មរស ។ ព្រះអមតនិព្វាន ឈ្មោះថា វិមុត្តិរស ។ ពាក្យដ៏សេសក្នុងទីគ្រប់កន្លែង មានសេចក្តីងាយទាំងអស់

នោះឯង ។

ចប់អដ្ឋកថា សូត្រទី ២ជាដើម

## ចប់អដ្ឋកថា វគ្គទី ៤

## ចប់វគ្គទីបេយ្យាល

# អដ្ឋកថាបសានករធម្មាធិបាលី

## “ពោលដោយគុណសម្បត្តិដែលជាចំណែកមួយរបស់លោក”

## អដ្ឋកថាបសានករធម្មវគ្គ

[២០៧] *ពាក្យថា* ***អគ្គំ*** *(ចំណែកមួយ) ក្នុងបទជាដើមថា* ***អគ្គមិទំ*** *នេះ ជាឈ្មោះនៃចំណែកមួយ លោកអធិប្បាយថា នេះជាលោកពិត គឺ ជាចំណែកមួយរបស់លោក ។ បទថា* ***យទិទំ អារញ្ញកត្តំ*** *(ភាពជាអ្នកនៅព្រៃជាវត្ត) គឺ ភាពជាអ្នកនៅព្រៃដោយចំណែកមួយណា ។ អធិប្បាយថា ឈ្មោះថា ជាអ្នកនៅព្រៃជាចំណែកមួយរបស់លោក គឺ ភិក្ខុដែលព្រៃអាចបានលោក ព្រោះជាអ្នកបំពេញបានយ៉ាងពិត ។ ក៏ភិក្ខុដែលនៅព្រៃជាវត្ត គិតថា យើងនឹងធ្វើវត្តដែលសមគួរដល់ការនៅព្រៃរបស់ខ្លួន ទើបមិនធ្វើកម្មដែលឈ្មោះថា លាមក ។ បើដូច្នោះ មហាជនក៏នឹងកើតសេចក្តីគោរពចំពោះលោកថា ភិក្ខុនេះសមាទានការនៅព្រៃជាវត្ត រមែងធ្វើការបូជាដោយបច្ច័យទាំង ៤ ។ ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភាពជាអ្នកនៅព្រៃជាវត្តនេះ ជាលោកពិតដូច្នេះ ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះឯង ។*

*ក៏ភាពជាអ្នកបានស្តាប់ច្រើន ឈ្មោះថា* ***ពាហុសច្ចៈ*** *ក្នុងសូត្រនេះ ។ បទ*

ថា **ជាវរេយ្យំ** (ភាពជាអ្នកមាំមួន) បានដល់ ភាពជាអ្នកដល់នូវសេចក្តីមាំមួន ព្រោះជាអ្នកបួសយូរ ។ បទថា **អាកប្បសម្បទា** (ការបរិបូរដោយអាកប្បកិរិយា) បានដល់ ការដល់ព្រមដោយមារយាទ មានការគ្រងចីវរជាដើម ។ ភាពជាអ្នកមានបរិវារស្អាត ឈ្មោះថា **បរិវារសម្បទា** (ការដល់ព្រមដោយបរិវារ) ។ ភាពជាកុលបុត្រ ឈ្មោះថា **កុលបុត្តិ** (បុត្រអ្នកមានត្រកូល) ។ ភាពជាអ្នកមានរូប-សម្បត្តិ ឈ្មោះថា **វណ្ណបោក្ខរតា** (ជាអ្នកមានពណ៌សម្បុរស្អាត) ។ ការពោលពាក្យពីរោះ ឈ្មោះថា **កល្យាណវាក្ករណតា** (ភាពជាអ្នកចចារពីរោះ) ។ ការដល់ព្រមដោយការមិនមានរោគ ឈ្មោះថា **អប្បាពាធតា** (ភាពជាអ្នកមានអាពាធតិច) ។ ក៏ភិក្ខុដែលមិនមានរោគ រមែងបំពេញវាសធុរៈ (ធុរៈក្នុងការអប់រំចិត្ត) និងគន្ថធុរៈឲ្យបរិបូរណ៍បាន ព្រោះខ្លួនជាអ្នកមានរាងកាយសប្បាយ ។ ព្រោះហេតុនោះ លោកទាំងឡាយទើបកើតឡើងដល់ភិក្ខុនោះឯង ។

ចប់អដ្ឋកថា បសាទករធម្មវគ្គ

# អដ្ឋកថា អបរអច្ឆរាសង្ឃាតវគ្គ

[២០៨] ព្រះសូត្រសូម្បីនេះថា **អច្ឆរាសង្ឃាតមត្តំ** (វេលាមួយផ្ទាត់ម្រាមដៃ) ដូច្នេះ ត្រាស់ទុកក្នុងហេតុកើតឡើងនៃអគ្គិក្ខន្ធោបមសូត្រ ។ ក៏កថាដែលពោលដល់ផលរបស់មេត្តា ដែលមិនដល់អប្បនាមិនមាន ។ ព្រះធម្មទេសនានេះ គប្បីជ្រាបថា ទ្រង់ប្រារព្ធក្នុងកាលកើតឡើងនោះឯង ។

ក្នុងបទទាំងនោះ បទថា **បឋមំ** មានវិមសារដូចពោលទុកក្នុងវិគគ្គថាជាទី ១ តាមលំដាប់នៃការរាប់ ។ ឈ្មោះថា ទី ១ ព្រោះចូលឈានទី ១ នេះ ។ បទថា **ឈានំ** សេចក្ដីថា ឈ្មោះថា ឈានមាន ២ យ៉ាង គឺ អារម្មណូបនិជ្ឈាន និងលក្ខណូបនិជ្ឈាន ។ ក្នុងឈាន ២ យ៉ាង គឺ សមាបត្តិ ៨ ឈ្មោះថា អារម្មណូបនិជ្ឈាន ។ ក៏សមាបត្តិ ៨ នោះ ហៅថា អារម្មណូបនិជ្ឈាន ព្រោះចូលទៅសម្ងឹងអារម្មណ៍ មានបឋវីកសិណជាដើម ។ វិបស្សនា មគ្គ និងផល ឈ្មោះថា លក្ខណូបនិជ្ឈាន ។ ក៏វិបស្សនា ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះចូលទៅសម្ងឹងលក្ខណៈរបស់សង្ខារដោយអំណាចត្រៃលក្ខណ៍ មានការមិនទៀងជាដើម ។ មគ្គ លោកហៅថា លក្ខណូបនិជ្ឈាន ព្រោះកិច្ចក្នុងការចូលទៅសម្ងឹងលក្ខណៈនៃវិបស្សនា រមែងសម្រេចដោយមគ្គ ។ ផល លោកហៅថា លក្ខណូប-

និជ្ឈាន ព្រោះចូលទៅសម្ងឹងព្រះនិព្វាន ដែលមានលក្ខណៈជាសុញ្ញតៈ (សូន្យទទេ) អនិមិត្តៈ (មិនមាននិមិត្ត) និងអប្បណិហិតៈ (មិនមានទីតាំង) ។ ក៏បណ្ដាឈាន ២ យ៉ាងនោះ ក្នុងអត្ថនេះបំណងយកអារម្មណូបនិជ្ឈាន ។

បទថា **កោ បន វាទោ យេ នំ ពហុលីករោន្តិ** (ចាំបាច់ពោលថ្វីដល់អ្នកធ្វើឲ្យច្រើននូវបឋមឈាននោះ) សេចក្ដីថា មិនមានពាក្យដែលនឹងគប្បីពោលក្នុងបុគ្គលដែលធ្វើបឋមឈាននោះឲ្យច្រើន ពាក្យដ៏សេសក្នុងសូត្រនេះ គប្បីយល់ដោយន័យដូចពោលទុកហើយក្នុងខាងក្រោយនោះឯង ។

[២០៩] សូម្បីក្នុងបទថា **ទុតិយំ** ដូច្នេះជាដើមទៅ ក៏គប្បីជ្រាបអត្ថដោយន័យមានជាដើមថា ជាទី ២ តាមលំដាប់នៃការរាប់ ដូច្នេះ ។

បទថា **មេត្តំ** បានដល់ ផ្សាយប្រយោជន៍ទៅក្នុងសព្វសត្វទាំងឡាយ ។ បទថា **ចេតោវិមុត្តិ** បានដល់ ការរួចផុតដោយចិត្ត ។ មេត្តាដែលដល់អប្បនាប៉ុណ្ណោះ លោកបំណងយកក្នុងទីនេះ ។ សូម្បីក្នុងករុណាជាដើម ក៏មានន័យនេះនុ៎ះឯង ។ ក៏ព្រហ្មវិហារទាំង ៤ នេះ ជាវដ្ដៈ ជាបាទនៃវដ្ដៈ ជាបាទនៃវិបស្សនាធម៌ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្ន ជាបាទនៃអភិញ្ញា ឬជាបាទនៃនិរោធ ។ តែមិនមែនជាលោកុត្តរៈ ។ សួរថា ព្រោះហេតុអ្វី?

ឆ្លើយថា ព្រោះនៅមានសត្វជាអារម្មណ៍ ។

បទថា **កាយេ កាយានុបស្សី** (ពិចារណាកាយក្នុងកាយ) សេចក្តីថា បុគ្គលពិចារណាឃើញដោយបញ្ញានូវកាយនោះឯង ក្នុងកាយ ១៨ ប្រការនេះ គឺ អានាបានបព្វៈ ១ ឥរិយាបថបព្វៈ ១ ចតុសម្បជញ្ញបព្វៈ ១ បដិកូលមនសិការ-បព្វៈ ១ ធាតុមនសិការបព្វៈ ១ នវសីវថិកាបព្វៈ ៩ កសិណ មាននីលកសិណជាដើម ៤ ជាប់ដោយបរិកម្មខាងក្នុង ។ បទថា **វិហរតិ** (នៅ) បានដល់ រស់នៅ គឺ ប្រព្រឹត្តទៅហើយ ។ ដោយបទថា **វិហរតិ** (នៅ) នេះ ជាការពោលដល់ ឥរិយាបថរបស់ភិក្ខុដែលចម្រើនកាយានុបស្សនាសតិប្បដ្ឋានដោយកាយ ១៨ យ៉ាង នេះឯង ។ បទថា **អាតាបី** (គប្បីជាអ្នកមានសេចក្តីព្យាយាម) បានដល់ មានសេចក្តីព្យាយាម ដោយសេចក្តីព្យាយាមជាគ្រឿងចម្រើនសតិប្បដ្ឋាន មានប្រការដូចពោលហើយនោះឯង ។ បទថា **សម្បជានោ** (មានសម្បជញ្ញៈ) បានដល់ ដឹងដោយប្រពៃដោយបញ្ញាជាគ្រឿងពិចារណាកាយានុបស្សនាសតិប្បដ្ឋាន ដោយកាយ ១៨ យ៉ាង ។ បទថា **សតិមា** (មានសតិ) បានដល់ ជាអ្នកប្រកបដោយសតិដែលឃុំគ្រងការពិចារណាឃើញដោយកាយ ១៨ យ៉ាង ។ បទថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** (កម្ចាត់អភិជ្ឈា និងទោមនស្សក្នុងលោក) មានអធិប្បាយថា ភិក្ខុនាំចេញ គឺ គ្របសង្កត់តណ្ហាដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ និងទោមនស្សដែលប្រកបដោយបដិឃៈក្នុងលោក ពោលគឺ កាយនោះឯង ជាអ្នក

ពិចារណាឃើញកាយក្នុងកាយ ។ ដោយប្រការត្រឹមប៉ុណ្ណេះ គប្បីជ្រាបថា លោកពោលការពិចារណារូបសុទ្ធៗ ដោយកាយានុបស្សនាសតិប្បដ្ឋាន ។

បទថា *វេទនាសុ វេទនានុបស្សី* (ពិចារណាវេទនាក្នុងវេទនាទាំងឡាយ) សេចក្ដីថា ក៏ក្នុងពាក្យជាដើមថា បណ្ដាវេទនាទាំងឡាយមានសុខវេទនាជាដើម ភិក្ខុជាអ្នកពិចារណាឃើញវេទនា ៩ យ៉ាង ដូចដែលត្រាស់ទុកយ៉ាងនេះថា កាលសោយសុខវេទនា រមែងដឹងច្បាស់ថា យើងកំពុងសោយសុខវេទនា កាលសោយទុក្ខវេទនា រមែងដឹងច្បាស់ថា យើងកំពុងសោយទុក្ខវេទនា កាលសោយអទុក្ខមសុខវេទនា (វេទនាដែលមិនសុខមិនទុក្ខ) រមែងដឹងច្បាស់ថា យើងសោយអទុក្ខមសុខវេទនា កាលសោយសុខវេទនាអាស្រ័យអាមិស... ឬកាលសោយសុខវេទនាប្រាសចាកអាមិស... កាលសោយទុក្ខវេទនាអាស្រ័យអាមិស... ឬសោយទុក្ខវេទនាប្រាសចាកអាមិស អទុក្ខមសុខវេទនាអាស្រ័យអាមិស ឬអទុក្ខមសុខវេទនាប្រាសចាកអាមិស រមែងដឹងច្បាស់ថា យើងសោយអទុក្ខមសុខវេទនាប្រាសចាកអាមិស ដូច្នេះ គប្បីជ្រាបអត្ថក្នុងរឿងនេះ ដោយអំណាចនៃវីរិយៈ បញ្ញា និងសតិ ដែលជាតួគ្រប់គ្រងការចម្រើនវេទនានុបស្សនាសតិប្បដ្ឋានដោយប្រការ ៩ យ៉ាង ។ ក៏ក្នុងបទថា *លោកេ* (ក្នុងលោក) នេះ គប្បីជ្រាបថា បានដល់វេទនា ។

សូម្បីក្នុងចិត្ត និងធម៌ជាដើម ក៏មានន័យនេះឯង ។ តែបទថា **ចិត្តេ ចិត្តានុបស្សី** (ពិចារណាចិត្តក្នុងចិត្ត) ក្នុងសូត្រនេះ មានន័យថា ពិចារណាឃើញដោយអនុបស្សនាដែលពិចារណាយ៉ាងនេះ ក្នុងចិត្ត ១៦ ប្រភេទ ដែលលោកអធិប្បាយទុកថា "ឬរមែងដឹងច្បាស់នូវចិត្តមានរាគៈថា ជាចិត្តមានរាគៈ" ដូច្នេះ ។

បទថា **ធម្មេសុ ធម្មានុបស្សី** (ពិចារណាធម៌ក្នុងធម៌ទាំងឡាយ) សេចក្តីថា ពិចារណាឃើញធម៌ទាំងនោះដោយអនុបស្សនា ដែលជាគួរពិចារណាក្នុងធម៌ដែលពោលទុក ៥ ប្រការ ដោយកោដ្ឋាសៈ (គឺចំណែក) យ៉ាងនេះ គឺ នីវរណៈ ៥ ឧបាទានក្ខន្ធ ៥ អាយតនៈខាងក្នុង និងអាយតនៈខាងក្រៅមួយយ៉ាង ៦ ពោជ្ឈង្គៈ ៧ អរិយសច្ចៈ ៤ ។

ក៏ក្នុងការពិចារណាឃើញធម៌នេះ លោកពោលការពិចារណានាមសុទ្ធៗក្នុងវេទនានុបស្សនាសតិប្បដ្ឋាន និងចិត្តានុបស្សនាសតិប្បដ្ឋាន ។ ពោលដល់ការពិចារណាទាំងរូប និងនាមក្នុងធម្មានុបស្សនាសតិប្បដ្ឋាន ។ គប្បីជ្រាបថា សតិ-ប្បដ្ឋានសូម្បីទាំង ៤ នេះ លោកពោលទាំងលោកិយៈ និងលោកុត្តរៈលាយគ្នា ។

បទថា **អនុប្បន្នានំ** (ដែលនៅមិនទាន់កើត) បានដល់ ដែលនៅមិនទាន់កើត ។ បទថា **បាបកានំ** (លាមក) បានដល់ ថោកទាប ។ បទថា **អកុសលានំ ធម្មានំ** បានដល់ ធម៌មានលោភៈជាដើម ដែលកើតចាកពីសេចក្តីមិនឆ្លាត ។ បទថា

**អនុប្បាទាយ** (ដើម្បីមិនឲ្យកើតឡើង) គឺ ដើម្បីប្រយោជន៍ដល់ការមិនកើត ។ បទថា **ឆន្ទំ ជនេតិ** (ញ៉ាំងឆន្ទៈឲ្យកើត) សេចក្តីថា រមែងឲ្យកើតកុសលឆន្ទៈ ក្នុងភាពជាអ្នកប្រាថ្នានឹងធ្វើ ។ បទថា **វាយមតិ** (ព្យាយាម) បានដល់ ធ្វើសេចក្តីព្យាយាមជាគ្រឿងប្រកប គឺ ការតស៊ូពុះពារ ។ បទថា **វីរិយំ អារភតិ** (ប្រារព្ធសេចក្តីព្យាយាម) បានដល់ ធ្វើសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ចិត្តំ បគ្គណ្ហាតិ** (ផ្គងចិត្តទុក) បានដល់ លើកចិត្តឡើងដោយសេចក្តីព្យាយាមដែលកើតរួមគ្នានោះឯង ។ បទថា **បទហតិ** (តាំងទុក) បានដល់ ធ្វើសេចក្តីព្យាយាមដែលជាបធានៈ ។

បទថា **ឧប្បន្នានំ** (ដែលកើតឡើងហើយ) បានដល់ កើតហើយ គឺ បង្កើតហើយ ។ បទថា **កុសលានំ ធម្មានំ** (កុសលធម៌) បានដល់ ធម៌មានអលោភៈជាដើម ដែលកើតពីសេចក្តីខ្វាត ។ បទថា **ឋិតិយា** (ដើម្បីការតាំងមាំ) បានដល់ ដើម្បីសេចក្តីតាំងនៅ ។ បទថា **អសម្មោសាយ** បានដល់ ដើម្បីការមិនវិនាស ។ បទថា **ភិយ្យោភាវាយ** បានដល់ ឲ្យរឹងរឹតតែចម្រើន ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីបរិបូណ៌ទូលំទូលាយឡើង ។ បទថា **ភាវនាយ** បានដល់ ដើម្បីសេចក្តីចម្រើន ។ បទថា **បារិបូរិយា** បានដល់ ដើម្បីសេចក្តីពេញលេញ ។

ការអធិប្បាយចំពោះបទមួយសម្រាប់សម្មប្បធាន ៤ ត្រឹមតែប៉ុណ្ណេះ ។

ក៏ឈ្មោះថា កថាពោលអំពីសម្មប្បធាននេះមាន ២ យ៉ាង គឺ ជាលោកិយៈ ១ ជាលោកុត្តរៈ ១ ។ ក្នុងកថា ២ យ៉ាងនោះ សម្មប្បធានកថាដែលជាលោកិយៈ មានក្នុងខាងដើមនៃកថាទាំងពួង ។ កថាពោលដោយសម្មប្បធានដែលជាលោ-កិយៈនោះ គប្បីជ្រាបបានក្នុងខណៈមគ្គជាលោកិយៈ ដោយបរិយាយនៃកស្សប-សំយុត្ត ។

សមដូចព្រះមហាកស្សបពោលទុកក្នុងកស្សបសំយុត្តនោះថា ៖

អ្នកមានអាយុ សម្មប្បធាន (សេចក្ដីព្យាយាមប្រពៃ) ៤ ទាំងនេះ សម្មប្បធាន ៤ យ៉ាងដូចម្ដេច ។ អ្នកមានអាយុ ភិក្ខុក្នុងព្រះធម្ម-វិន័យនេះ រមែងធ្វើសេចក្ដីព្យាយាមដោយគិតថា អកុសលធម៌ដ៏លាមកដែលនៅមិនកើតឡើងដល់យើង កាលកើតឡើង គប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស , រមែងប្រារព្ធសេចក្ដីព្យាយាមដោយគិតថា អកុសលធម៌ដ៏លាមកដែលកើតឡើងហើយដល់យើង កាលលះមិនទាន់បាន គប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស , រមែងប្រារព្ធសេចក្ដីព្យាយាមថា កុសលធម៌ដែលមិនកើតឡើងដល់យើង កាលមិនទាន់កើតឡើង គប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស , រមែងប្រារព្ធសេចក្ដីព្យាយាមដោយគិត

ថា កុសលធម៌ដែលកើតឡើងហើយដល់យើង កាលរលត់ទៅ គប្បីប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស ដូច្នេះ ។

ក៏ក្នុងអធិការនេះ អកុសលធម៌ទាំងឡាយ មានលោភៈជាដើម គប្បីជ្រាបថា ជាអកុសលធម៌ដ៏លាមក ។ បទថា **អនុប្បន្នា មេ កុសលា ធម្មា** (កុសលធម៌មិនទាន់កើតឡើងដល់យើង) បានដល់ សមថវិបស្សនា និងមគ្គ ។ សមថវិបស្សនា និងមគ្គ ឈ្មោះថា កុសលដែលកើតឡើងហើយ ។ តែមគ្គនោះ កើតឡើងតែមួយដងហើយរលត់ទៅ ឈ្មោះថា រមែងប្រព្រឹត្តទៅដើម្បីសេចក្តីវិនាស មិនមាន ។ ព្រោះមគ្គនោះ ឲ្យបច្ច័យដល់ផល (មុន) ហើយក៏រលត់ទៅ ។ ម្យ៉ាងទៀត សូម្បីក្នុងផ្នែកខាងដើមក៏ពោលទុកថា គប្បីកាន់យកចំពោះសមថវិបស្សនាប៉ុណ្ណោះ ឈ្មោះថា កុសលដែលកើតឡើងហើយ តែពាក្យដែលពោលនោះមិនគួរ ។ កថាពោលដោយសម្មប្បធានដែលជាលោកិយៈ គប្បីជ្រាបដោយបរិយាយនៃកស្សបសំយុត្តក្នុងខាងដើមៗ នៃសូត្រទាំងពួង ។ ក៏ក្នុងខណៈលោកុត្តរមគ្គ សេចក្តីព្យាយាមតែម្យ៉ាងនេះប៉ុណ្ណោះ បានឈ្មោះ ៤ ដាប់ដោយធ្វើកិច្ច ៤ យ៉ាងឲ្យសម្រេច ។

ក្នុងបទថា **អនុប្បន្នានំ បាបកានំ** (ដ៏លាមកដែលមិនទាន់កើតឡើង) នេះ ក្នុងបាលីនៃកស្សបសំយុត្តនោះ គប្បីជ្រាបសេចក្តីតាមន័យដែលពោលក្នុងបទថា

*អនុប្បន្នោ ចេវ កាមច្ឆន្ទោ* (កាមច្ឆន្ទៈមិនទាន់កើតឡើង) ដូច្នេះជាដើម ។

ក្នុងបទថា **ឧប្បន្នានំ បាបកានំ** (ដ៏លាមកដែលកើតឡើង) នេះ ឧប្បន្នៈមាន ៤ យ៉ាង គឺ វត្តមានុប្បន្នៈ ភុត្វាវិគតុប្បន្នៈ ឱកាសកតុប្បន្នៈ ភូមិលទ្ធុប្បន្នៈ ។

ក្នុងឧប្បន្នៈ ៤ យ៉ាងនោះ ប្រការដែលកិលេសមាន (និង) ព្រមព្រៀងដោយការប្រកាន់មាំ នេះឈ្មោះថា វត្តមានុប្បន្នៈ ។

ក៏កាលកម្មប្រព្រឹត្តទៅហើយ វិបាកសោយរសអារម្មណ៍ហើយ រលត់ទៅ ឈ្មោះថា ភុត្វាវិគតុប្បន្នៈ ។ កម្មដែលកើតឡើងហើយរលត់ទៅ ក៏ឈ្មោះថា ភុត្វាវិគតុប្បន្នៈ ។ សូម្បីទាំងពីរន័យនោះក៏រាប់ថា ភុត្វាវិគតុប្បន្នៈ ។

កុសលកម្មហាមវិបាករបស់កម្មដទៃ ឲ្យឱកាសដល់វិបាករបស់ខ្លួន ។ វិបាកដែលកើតឡើងក្នុងឱកាសដែលបានយ៉ាងនេះ ហៅថា ឧប្បន្នៈ ផ្តើមតាំងពីបានឱកាស នេះឈ្មោះថា ឱកាសកតុប្បន្នៈ ។

ក៏បញ្ចក្ខន្ធ ឈ្មោះថា ភូមិរបស់វិបស្សនា ។ បញ្ចក្ខន្ធទាំងនោះ ផ្សេងដោយអតីតខន្ធជាដើម ។ ចំណែកកិលេសដែលដេកត្រាំនៅក្នុងបញ្ចក្ខន្ធទាំងនោះ មិនគួរពោលថា ជាអតីត ឬអនាគត ។ ព្រោះកិលេស សូម្បីដេកត្រាំនៅក្នុងអតីតខន្ធ ក៏នៅលះមិនបាន សូម្បីដែលដេកត្រាំក្នុងអនាគតខន្ធ ក៏នៅលះមិនបាន សូម្បីដែល

ដេកត្រាំនៅក្នុងបច្ចុប្បន្នខន្ធ ក៏នៅលះមិនបាន ព្រោះហេតុនោះ ប្រការដែលលះកិលេសដែលដេកត្រាំក្នុងខន្ធផ្សេងៗ មិនបាន នេះឈ្មោះថា ភូមិលទ្ធុប្បន្នៈ ។ ព្រោះហេតុនោះ បុរាណាចារ្យទាំងឡាយទើបពោលថា កិលេសទាំងឡាយដែលដកមិនបានក្នុងភូមិនោះៗ រមែងរាប់ថា ឈ្មោះថា ភូមិលទ្ធុប្បន្នៈ ។

ឧប្បន្នៈ ៤ ប្រការ យ៉ាងទៀត គឺ សមុទាចារុប្បន្នៈ អារម្មណាធិគហិតុប្បន្នៈ អវិក្ខម្ភិតុប្បន្នៈ អសមុគ្ឃាដិតុប្បន្នៈ ។

ក្នុងឧប្បន្នៈ ៤ យ៉ាងនោះ ឧប្បន្នៈដែលប្រព្រឹត្តទៅក្នុងពេលភ្លាមៗ នោះឈ្មោះថា សមុទាចារុប្បន្នៈ ។

មិនគួរពោលថា កិលេសមិនទាន់កើតឡើង ក្នុងខណៈដែលបើកភ្នែកឡើងម្តង ហើយរឭកដល់អារម្មណ៍ដែលប្រកាន់ជានិមិត្ត ។ ព្រោះហេតុអ្វី? ព្រោះកិលេសកាន់យកអារម្មណ៍ ។ សួរថា ដូចអ្វី? ឆ្លើយថា ដូចបុគ្គលយកពូថៅកាប់ដើមឈើដែលមានជ័រ និយាយមិនបានថា ក្នុងទីដែលត្រូវពូថៅកាប់ហើយ ជ័រនឹងមិនហូរ ។ នេះឈ្មោះថា អារម្មណាធិគហិតុប្បន្នៈ ។

ក៏កិលេសដែលមិនបានគ្របសង្កត់ដោយសមាបត្តិ មិនគួរពោលថា នឹងមិនកើតក្នុងទីឈ្មោះនេះ ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះមិនបានគ្របសង្កត់ ។ សួរថា ដូចអ្វី? ឆ្លើយថា ដូចអ្នកយកពូថៅកាត់ដើមឈើដែលមានជ័រ

មិនគួរពោលថា ជ័រទើងមិនហូរក្នុងទីឈ្មោះនេះ ។ នេះឈ្មោះថា អវិក្ខម្ភិតុប្បន្នៈ ។

ក៏កិលេសដែលមិនបានដកចេញដោយមគ្គ រមែងកើតសូម្បីដល់បុគ្គល ដែលកើតក្នុងភវគ្គព្រហ្ម ព្រោះហេតុនោះ គប្បីអធិប្បាយឲ្យពិស្ដារដោយន័យមុន នុ៎ះឯង ។ នេះឈ្មោះថា អសមុគ្ឃាដិតុប្បន្នៈ ។

ក្នុងឧប្បន្នៈទាំងនោះ ឧប្បន្នៈ ៤ យ៉ាង គឺ វត្តមានុប្បន្នៈ ភុត្វាវិគតុប្បន្នៈ ឱកាសកតុប្បន្នៈ សមុទាចារុប្បន្នៈ មិនមែនជាឧប្បន្នៈដែលមគ្គទើងគប្បីសម្លាប់ ។ ឧប្បន្នៈដែលមគ្គគប្បីសម្លាប់ មាន ៤ យ៉ាង គឺ ភូមិលទ្ធុប្បន្នៈ អារម្មណាធិគហិតុប្បន្នៈ អវិក្ខម្ភិតុប្បន្នៈ អសមុគ្ឃាដិតុប្បន្នៈ ។ ព្រោះមគ្គកើតឡើង រមែងលះកិលេសទាំងនេះ ។ មគ្គនោះ លះកិលេសពួកណា កិលេសពួកនោះ មិនគួរទើងពោលថា ជាអតីត អនាគត ឬបច្ចុប្បន្ន ។

សមដូចដែលត្រាស់ទុកថា ៖

បើលះកិលេសដែលជាអតីតបានសោត បើយ៉ាងនោះ
បុគ្គលនោះរមែងញុំាងកិលេសដែលអស់ទៅហើយ ឲ្យ
អស់ទៅបាន ញុំាងកិលេសដែលរលត់ហើយ ឲ្យរលត់
បាន ញុំាងកិលេសដែលប្រាសទៅហើយ ឲ្យប្រាសទៅ
ញុំាងកិលេសដែលដល់តាំងនៅមិនបាន ឲ្យដល់ការតាំង

នៅមិនបាន លះកិលេសដែលកន្លងទៅហើយ ដែលមិនមានបាន ។ បុគ្គលលះកិលេសដែលជាអនាគតបានឬ បើយ៉ាងនោះ ក៏រមែងលះកិលេសដែលនៅមិនទាន់កើត រមែងលះកិលេសដែលមិនទាន់បង្កើត មិនទាន់កើតឡើងហើយ មិនទាន់ប្រាកដបាន រមែងលះកិលេសដែលមិនទាន់មកដល់ ដែលមិនមានបាន ។ បុគ្គលលះកិលេសដែលជាបច្ចុប្បន្នបានឬ បើដូច្នោះ បុគ្គលអ្នកពេញចិត្ត រមែងលះរាគៈបាន បុគ្គលអ្នកប្រទូស រមែងលះទោសៈបាន បុគ្គលអ្នកវង្វេង រមែងលះមោហៈបាន បុគ្គលអ្នកអួតអាង រមែងលះមានះបាន បុគ្គលអ្នកប្រកាន់មាំក្នុងការឃើញខុស រមែងលះទិដ្ឋិបាន បុគ្គលអ្នកសម្រេចចិត្តមិនបាន រមែងលះវិចិកិច្ឆាបាន បុគ្គលអ្នកមានកម្លាំង រមែងលះអនុស័យបាន ធម៌ខ្មៅ និងធម៌ស ក៏រមែងជាធម៌គូនឹងគ្នាប្រព្រឹត្តទៅ ។ ការបំពេញមគ្គ ប្រកបដោយអាប់ឱនព្រោះកិលេសនោះ ក៏មាន ។ល។ បើដូច្នោះ ការបំពេញមគ្គ រមែងមិនមាន , ការធ្វើផលឲ្យជាក់ច្បាស់

រមែងមិនមាន , ការលះកិលេសរមែងមិនមាន , ការត្រាស់ដឹងធម៌រមែងមិនមាន ។ ការបំពេញមគ្គមាន ។បេ។ ការត្រាស់ដឹងធម៌មាន ។ សួរថា ប្រៀបដូចអ្វី? ឆ្លើយថា ប្រៀបដូចដើមឈើធំទង់ៗ ។បេ។ ជាឈើដែលនៅមិនទាន់មានផ្លែ (បុរសគប្បីកាត់ដើមឈើនោះត្រង់ឫស) ផ្លែដែលមិនទាន់កើត ក៏មិនកើតឡើយ ។

ដើមឈើដែលមិនទាន់ចេញផ្លែ (មានមក) ក្នុងព្រះបាលី តែគួរសម្តែងដើមដែលមានផ្លែផង ។ ប្រៀបផ្ទឹមដូចដើមស្វាយធំទង់ដែលមានផ្លែ ពួកមនុស្សទើងបរិភោគផ្លែរបស់វា ទើប (អង្រួន) ឲ្យផ្លែដែលនៅសល់ជ្រុះចុះ ហើយយកដាក់ក្នុងកន្ត្រកឲ្យពេញ , ក្រោយមក បុរសម្នាក់ទៀត យកពូថៅកាត់ដើមស្វាយនោះ ។ ផ្លែដែលជាអតីតរបស់ស្វាយដើមនោះ រមែងជាផ្លែដែលបុរសអ្នកនោះធ្វើឲ្យវិនាសមិនបាន ផ្លែដែលជាបច្ចុប្បន្ន និងអនាគតក៏ធ្វើឲ្យវិនាសមិនបាន ។ ព្រោះផ្លែដែលជាអតីត ពួកមនុស្សក៏បរិភោគទៅហើយ ផ្លែដែលជាអនាគតក៏មិនទាន់កើត ទើបមិនអាចធ្វើឲ្យវិនាស ។ ក៏ក្នុងសម័យដែលដើមស្វាយនោះត្រូវគេកាត់ ផ្លែស្វាយមិនទាន់មាន ព្រោះហេតុនោះ ផ្លែដែលជាបច្ចុប្បន្ន ទើបមិនត្រូវធ្វើឲ្យវិនាស ។ ក៏បើដើមស្វាយមិនទាន់ត្រូវកាត់ ផ្លែរបស់វា អាស្រ័យរសដី និងរសទឹកកើតឡើង

ក្នុងខាងក្រោយនោះ រមែងត្រូវធ្វើឲ្យវិនាស ។ ព្រោះផ្លែទាំងនោះនៅមិនទាន់កើត ក៏កើតមិនបាន ដែលមិនបង្កើត ក៏មិនបង្កើត និងដែលមិនទាន់ប្រាកដ ក៏ប្រាកដមិនបាន យ៉ាងណា មគ្គក៏ដូច្នោះដូចគ្នា រមែងលះកិលេសដែលផ្សេងដោយកិលេសជាអតីតជាដើមក៏មិនមែន នឹងមិនលះក៏មិនមែន ។ ការកើតឡើងនៃកិលេសពួកណា នឹងគប្បីមានក្នុងកាលមគ្គមិនទាន់កំណត់ដឹងខន្ធទាំងឡាយ (តែ) ព្រោះមគ្គកើតឡើងកំណត់ដឹងខន្ធទាំងឡាយបានហើយ កិលេសទាំងនោះ ដែលមិនទាន់កើតក៏មិនកើត ដែលមិនទាន់បង្កើតក៏មិនបង្កើត ដែលមិនទាន់ប្រាកដក៏មិនប្រាកដ ។ គប្បីអធិប្បាយសេចក្តីនេះឲ្យជាក់ច្បាស់ ដោយថ្នាំសម្រាប់ឲ្យស្ត្រី ម្តាយកូនតូចមិនទាន់ប្រសូតបុត្រ តទៅទៀត ឬសូម្បីសម្រាប់រម្ងាប់រោគរបស់អ្នកជម្ងឺ ។ មិនគួរពោលថា កិលេសទាំងឡាយដែលមគ្គលះបាននោះ ជាអតីត អនាគត ឬបច្ចុប្បន្ន ដោយប្រការយ៉ាងនេះ ។ មួយទៀត មគ្គនឹងមិនលះកិលេសទាំងឡាយក៏ទេ ។ តែទ្រង់សំដៅយកកិលេសដែលមគ្គលះបង់បាននោះឯង ទើបត្រាស់ថា **ឧប្បន្នានំ បាបកានំ** ដូច្នេះជាដើម ។

ក៏មគ្គនឹងលះតែកិលេសប៉ុណ្ណោះក៏មិនមែន សូម្បីឧបាទិន្នក្ខន្ធដែលកើតឡើងក៏លះបាន ព្រោះលះកិលេសទាំងឡាយបានដាច់ខាតហើយ ។ សមដូចដែលត្រាស់ទុកថា "(ខន្ធទាំងឡាយពួកណា គឺ) នាម និងរូបគប្បីកើតឡើងក្នុងសង្សារ

ដែលកំណត់ទីបំផុតខាងដើម និងខាងចុងមិនបាន វៀរ ៧ ភព ដោយរលត់អភិ-សង្ខារវិញ្ញាណដោយសោតាបត្តិមគ្គញ្ញាណ ខន្ធទាំងឡាយនោះ រមែងរលត់" ដូច្នេះ សេចក្ដីពិស្ដារហើយ ។ មគ្គ រមែងចេញចាកឧបាទិន្នកក្ខន្ធ និងអនុបាទិន្នកក្ខន្ធ ដោយប្រការដូច្នេះ ។

ក៏ពោលអំពីភពទាំងពួង សោតាបត្តិមគ្គ រមែងចេញចាកអបាយភព ។ សកទាគាមិមគ្គ រមែងចេញចាកចំណែកមួយរបស់សុគតិភព ។ អនាគាមិមគ្គ រមែងចេញចាកសុគតិកាមភព ។ អរហន្តមគ្គ រមែងចេញចាករូបភព និងអរូបភព ។ អាចារ្យខ្លះពោលថា "ព្រះអរហត្តមគ្គ រមែងចេញចាកភពទាំងពួង" ដូច្នេះក៏មាន ។

សួរថា បើដូច្នោះ ក្នុងខណៈនៃមគ្គនឹងមានការអប់រំដើម្បីញ៉ាំងធម៌ដែលមិនទាន់កើតឲ្យកើតឡើងបានយ៉ាងណា ឬនឹងមានការអប់រំដើម្បីឲ្យធម៌ដែលកើតឡើងហើយតាំងនៅបានយ៉ាងណា? ឆ្លើយថា ព្រោះមគ្គប្រព្រឹត្តទៅមិនដាច់ខ្សែនុ៎ះឯង , ក៏មគ្គដែលកំពុងប្រព្រឹត្តទៅ ហៅឈ្មោះថា **អនុប្បន្នៈ** ព្រោះមិនធ្លាប់កើតឡើងក្នុងកាលមុន ។ ដូចជា បុគ្គលដែលទៅកាន់ទីដែលមិនធ្លាប់ទៅ និងបានសោយអារម្មណ៍ដែលមិនធ្លាប់បានសោយ រមែងពោលថា ពួកយើងបានទៅកាន់ទីដែលមិនធ្លាប់បានទៅហើយក៏មិនមែន សោយអារម្មណ៍ដែលមិនធ្លាប់បានសោយហើយក៏មិនមែន ដូច្នេះយ៉ាងណា ។ ការប្រព្រឹត្តទៅរបស់មគ្គនុ៎ះឯង ឈ្មោះថា

តាំងនៅ ព្រោះហេតុនោះនឹងពោលថា ក្នុងការៈនៃការតាំងនៅ ដូច្នេះក៏គួរ ។ សេចក្តីព្យាយាមក្នុងខណៈលោកុត្តរមគ្គនេះរបស់ភិក្ខុនោះ រមែងបានឈ្មោះ ៤ យ៉ាង មានជាដើមថា **អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ** ដូច្នេះ ដូច្នោះដូចគ្នា ។ កថាពោលអំពីសេចក្តីព្យាយាមត្រូវក្នុងខណៈលោកុត្តរមគ្គ ត្រឹមតែប៉ុណ្ណោះ ។ ក៏ក្នុងព្រះសូត្រនេះ លោកពោលសេចក្តីព្យាយាមត្រូវ ដែលជាលោកិយៈ និងលោកុត្តរៈលាយគ្នា ។

បណ្តាឥទ្ធិបាទទាំងឡាយ សមាធិដែលអាស្រ័យឆន្ទៈប្រព្រឹត្តទៅ ឈ្មោះថា ឆន្ទសមាធិ ។ បទថា **បធានសង្ខារសមន្នាគតំ** (ដែលប្រកបដោយឆន្ទសមាធិ-បធានសង្ខារ) សេចក្តីថា បាទនៃសេចក្តីសម្រេច ដែលសម្តែងទុកហើយដោយធម៌ទាំងនោះ ឬបាទដែលជាសេចក្តីសម្រេច ឈ្មោះថា **ឥទ្ធិបាទ** ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះនុ៎ះឯង ។ ក្នុងទីនេះមានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះ ។ ចំណែកសេចក្តីពិស្តារ មានមកហើយក្នុងឥទ្ធិបាទវិភង្គនុ៎ះឯង ។ ក៏ន័យ (នៃឥទ្ធិបាទនោះ) សម្តែងទុកហើយក្នុងវិសុទ្ធិមគ្គ ។ ក្នុងវិសុទ្ធិមគ្គនោះ សម្តែងទុកថា ក្នុងកាលណាភិក្ខុនេះអាស្រ័យធុរៈណាមួយក្នុងឥទ្ធិបាទ មានឆន្ទៈជាដើម ចម្រើនវិបស្សនា ហើយសម្រេចព្រះអរហត្ត សូម្បីសមថៈក៏ដូចគ្នា ឥទ្ធិបាទ ដែលភិក្ខុនោះអាស្រ័យចម្រើនវិបស្សនា ក្នុងកាលនោះ ជាលោកិយៈក្នុងខាងដើម ជាលោកុត្តរៈ

ក្នុងខាងចុង សូម្បីឥទ្ធិបាទដ៏សេស ក៏យ៉ាងនោះ ។ ក្នុងព្រះសូត្រនេះ ក៏ត្រាស់ឥទ្ធិបាទដែលជាលោកិយៈ និងលោកុត្តរៈ ។

ក៏សទ្ធាក្នុងបទថា **សទ្ធិន្ទ្រិយំ ភាវេតិ** (ចម្រើនសទ្ធិន្ទ្រិយ) ដូច្នេះជាដើម ឈ្មោះថា សទ្ធិន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងសទ្ធាធុរៈរបស់ខ្លួន ។ សូម្បីក្នុងវីរិយិន្ទ្រិយជាដើម ក៏ន័យនេះឯង ។ ក៏ក្នុងបទថា **ភាវេតិ** (ចម្រើន) នេះ ព្រះយោគាវចរអ្នកផ្តើមបំពេញព្យាយាម ជម្រះសទ្ធិន្ទ្រិយឲ្យបរិសុទ្ធដោយហេតុ ៣ ប្រការ ឈ្មោះថា ចម្រើនសទ្ធិន្ទ្រិយ ។ សូម្បីក្នុងវីរិយិន្ទ្រិយជាដើម ក៏មានន័យនេះដូចគ្នា ។

សមដូចព្រះសារីបុត្រពោលទុកថា ៖

> សទ្ធិន្ទ្រិយ រមែងបរិសុទ្ធិដោយហេតុ ៣ ប្រការទាំងនេះ ដល់បុគ្គលដែលវៀរបុគ្គលដែលមិនមានសទ្ធា អ្នកសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលមានសទ្ធា អ្នកពិចារណាព្រះសូត្រដែលគួរជ្រះថ្លា ។
>
> វីរិយិន្ទ្រិយ រមែងបរិសុទ្ធិដោយហេតុ ៣ ប្រការទាំងនេះ ដល់បុគ្គលដែលវៀរចាកបុគ្គលដែលខ្ជិលច្រអូស អ្នកសេព សេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលប្រារព្ធសេចក្តីព្យាយាម អ្នកពិចារណាសម្មប្បធាន (ការព្យាយាម

ត្រូវ) ។

សតិន្ទ្រិយ រមែងបរិសុទ្ធិដោយហេតុ ៣ ប្រការនេះ ដល់បុគ្គលដែលវៀរចាកបុគ្គលដែលមិនមានសតិ អ្នកសេពសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលមានសតិប្រាកដ អ្នកពិចារណាសតិប្បដ្ឋាន ។

សមាធិន្ទ្រិយ រមែងបរិសុទ្ធិដោយហេតុ ៣ ប្រការនេះ ដល់បុគ្គលវៀរបុគ្គលដែលមានចិត្តមិនតាំងមាំ សេពសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តតាំងមាំ អ្នកពិចារណាឈាន និងវិមោក្ខ ។

បញ្ញិន្ទ្រិយ រមែងបរិសុទ្ធិដោយហេតុ ៣ ប្រការនេះ ដល់បុគ្គលដែលវៀរបុគ្គលដែលមិនមានបញ្ញា អ្នកសេពសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលមានបញ្ញា អ្នកពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ ។

ក៏បទថា គម្ភីរញាណចរិយំ បច្ចវេក្ខតោ (អ្នកពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ) ក្នុងព្រះបាលីនោះ មានសេចក្តីថា អ្នកពិចារណាលំដាប់ខន្ធ[១]

១-ដីកាថា : ខន្ធទាំងឡាយមានផ្សេងៗ ដោយលក្ខណៈ ជាតិ និងភូមិជាដើម ។

លំដាប់ឥន្ទ្រិយ ពលៈ និងពោជ្ឈង្គៈ លំដាប់មគ្គ និងលំដាប់នៃផលដ៏ល្អិតល្អន់សុខុម ។ ក៏ព្រះយោគាវចរអ្នកផ្តើមបំពេញកម្មដ្ឋាន មិនធ្វើការប្រកាន់មាំដោយអំណាចនៃហេតុ មួយៗ ៣ ទាំងនេះ ផ្តើមតាំងពីការប្រកាន់មាំក្នុងសទ្ធាធុរៈជាដើម អប់រំឲ្យចម្រើនឡើង ក្នុងទីបំផុតក៏លះបង់បាន រមែងកាន់យកព្រះអរហត្ត ។ ព្រះយោគាវចរនោះ ឈ្មោះថា ចម្រើនឥន្ទ្រិយទាំងនេះ ដរាបដល់ព្រះអរហត្តមគ្គ ។ កាលសម្រេចព្រះអរហត្តផលហើយ រមែងឈ្មោះថា ជាអ្នកចម្រើនឥន្ទ្រិយ ។ លោកពោលឥន្ទ្រិយសូម្បីទាំង ៥ នេះ ទាំងជាលោកិយៈ និងលោកុត្តរៈ ដោយប្រការដូច្នេះ ។

ក្នុងសទ្ធាពលៈជាដើម សទ្ធានុ៎ះឯងជាពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ព្រោះហេតុនោះ ទើបឈ្មោះថា **សទ្ធាពលៈ** ។ សូម្បីក្នុងវិរិយពលៈជាដើម ក៏មានន័យដូចសទ្ធាពលៈនុ៎ះឯង ។ ក៏សទ្ធាក្នុងអធិការពោលអំពីពលៈនេះ រមែងមិនញាប់ញ័រដោយសេចក្តីមិនជឿ , សេចក្តីព្យាយាម រមែងមិនញាប់ញ័រដោយសេចក្តីខ្ជិលច្រអូស , សតិរមែងមិនញាប់ញ័រដោយសេចក្តីវង្វេងភ្លេចសតិ , សមាធិរមែងមិនញាប់ញ័រដោយសេចក្តីរវើរវាយ , បញ្ញារមែងមិនញាប់ញ័រដោយអវិជ្ជា ព្រោះហេតុនោះ ពលៈសូម្បីទាំងអស់ហៅថា ពលៈ ព្រោះអត្ថថា មិនញាប់ញ័រ ។ ក៏ការប្រកបសេចក្តីព្យាយាមក្នុងការចម្រើនការទៅក្នុងពលៈនេះ គប្បីជ្រាបដោយ

ន័យដូចពោលហើយក្នុងការចម្រើនឥន្រ្ទិយនុ៎ះឯង ។ លោកពោលពលៈ ៥ នេះ ទាំងជាលោកិយៈ និងលោកុត្តរៈ ។

ក្នុងបទថា **សតិសម្ពោជ្ឈង្គំ ភាវេតិ** (ចម្រើនសតិសម្ពោជ្ឈង្គៈ) នេះ មានការនាន័យ នៃការពណ៌នាសេចក្តីព្រមជាមួយកុលបុត្រអ្នកផ្តើមបំពេញកម្មដ្ឋាន ត្រឹមតែប៉ុណ្ណេះ ។ បទដើម ៧ បទ ដែលពោលទុកដោយន័យជាដើមថា **សតិ-សម្ពោជ្ឈង្គំ** ដូច្នេះ ក្នុងព្រះបាលីនោះ មានការពណ៌នាសេចក្តីដូចតទៅនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងសតិសម្ពោជ្ឈង្គមុន ។ ឈ្មោះថា សតិ ព្រោះអត្ថថា រឭកបាន ។ ក៏សតិនោះ មានសេចក្តីប្រាកដឡើងជាលក្ខណៈ ឬមានការឲ្យនឹកបាន ជាលក្ខណៈ ។

សមដូចដែលព្រះនាគសេនពោលទុកថា "មហាបពិត្រ នាយឃ្លាំងរបស់ព្រះរាជា ក្រាបទូលឲ្យព្រះរាជាឲ្យទ្រង់រឭកដល់ព្រះរាជទ្រព្យថា បពិត្រមហារាជ ប្រាក់មានប៉ុណ្ណេះ មាសមានប៉ុណ្ណេះ ទ្រព្យសម្បត្តិមានប៉ុណ្ណេះ ដូច្នេះ យ៉ាងណា មហាបពិត្រ សតិក៏ដូច្នោះដែរ កាលកើតឡើង រមែងឲ្យនឹកបាន រមែងឲ្យរឭកបាន នូវធម៌ទាំងឡាយ ដែលជាកុសល និងអកុសល មានទោស និងមិនមានទោស ថោកទាប និងប្រណីត មានចំណែកប្រៀបដោយធម៌ខ្មៅ និងធម៌ស" ។ គឺ សតិប្បដ្ឋានទាំង ៤ នេះឯង សេចក្តីពិស្តារហើយ ។ (សតិ) មានការឲ្យនឹកបាន

ជារស (គឺកិច្ច) ។ ក៏ព្រះថេរៈពោលលក្ខណៈនោះ របស់សតិនោះថា ជាកិច្ចនុ៎ះឯង ។ មួយាងទៀត (សតិ) មានការមិនវង្វេងភ្លេចជារស មានការឈមមុខចំពោះអារម្មណ៍ជាបច្ចុប្បដ្ឋាន (អាការប្រាកដ) ។ សតិនុ៎ះឯង ជាសម្ពោជ្ឈង្គៈ ព្រោះដូច្នោះ ទើបឈ្មោះថា សតិសម្ពោជ្ឈង្គៈ ដោយប្រការយ៉ាងនេះ ។

ក្នុងបទថា **សតិសម្ពោជ្ឈង្គោ** នោះ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះជាអង្គនៃបញ្ញាគ្រឿងត្រាស់ដឹង ឬនៃព្រះពោធិញ្ញាណ ។ សួរថា លោកអធិប្បាយទុកដូចម្តេច? ឆ្លើយថា អធិប្បាយទុកថា ធម្មសាមគ្គីនេះ ហៅថា **ពោធិ** ព្រោះធ្វើអធិប្បាយថា ព្រះអរិយសាវករមែងត្រាស់ដឹងដោយធម្មសាមគ្គី គឺ សតិ ធម្មវិចយៈ វិរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលកើតឡើងក្នុងខណៈនៃមគ្គ ដែលជាលោកិយៈ និងលោកុត្តរៈ ដែលជាបដិបក្ខចំពោះអន្តរាយមិនមែនតិច មានការតាំងនៅ និងការប្រមូលទុកនូវសេចក្តីរួញរា សេចក្តីរវើរវាយ និងសេចក្តីប្រកាន់មាំក្នុងការប្រកបកាមសុខ ការធ្វើខ្លួនឲ្យលំបាក និងក្នុងឧច្ឆេទទិដ្ឋិ និងសស្សតទិដ្ឋិ ។ បទថា **ពុជ្ឈតិ** (រមែងត្រាស់ដឹង) សេចក្តីថា បេញចាកសេចក្តីលក់ គឺកិលេសសន្តាន ។ អធិប្បាយថា ត្រាស់ដឹងអរិយសច្ចៈ ៤ ឬធ្វើឲ្យជាក់ច្បាស់ចំពោះព្រះនិព្វាន ។ សមដូចដែលត្រាស់ទុកហើយថា "ចម្រើនពោជ្ឈង្គៈ ៧ ហើយត្រាស់ដឹងព្រមនូវព្រះសម្មាសម្ពោធិញ្ញាណដ៏ប្រសើរ" ដូច្នេះ ។ ឈ្មោះថា ពោជ្ឈង្គៈ

ព្រោះជាអង្គនៃពោធិ គឺ ធម្មសាមគ្គីនោះ៉ៈ ដូចជា ឈានង្គៈ (អង្គឈាន) មគ្គង្គៈ (អង្គមគ្គ) ដូច្នោះ ។ ព្រះអរិយសាវក ហៅថា **ពោធិ** ព្រោះអធិប្បាយថា ព្រះអរិយសាវកត្រាស់ដឹងដោយធម្មសាមគ្គីនោះ ដែលមានប្រការដូចពោលហើយ អង្គនៃព្រះអរិយសាវក (ដែលហៅថាពោធិ) នោះ សូម្បីព្រោះហេតុនោះ ទើបឈ្មោះថា ពោជ្ឈង្គៈ (អង្គនៃព្រះអរិយសាវកអ្នកត្រាស់ដឹង) ដូចអង្គប្រកបនៃកងទ័ព និងអង្គប្រកបនៃរថជាដើមដូច្នោះ ។ ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទាំងឡាយ ទើបពោលថា ឈ្មោះថា **ពោជ្ឈង្គៈ** ព្រោះជាអង្គនៃបុគ្គលដែលត្រាស់ដឹង ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពោជ្ឈង្គៈ សូម្បីដោយគម្ពីរបដិសម្ភិទាមគ្គជាដើម ដូច្នេះ បទថា **ពោជ្ឈង្គា** សេចក្តីថា ឈ្មោះថា ពោជ្ឈង្គៈ ព្រោះអត្ថដូចម្តេច? ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះប្រព្រឹត្តទៅដើម្បីត្រាស់ដឹង ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹង ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹងតាមលំដាប់ ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹងចំពោះ ។ ឈ្មោះថា ពោជ្ឈង្គៈ ព្រោះត្រាស់ដឹងព្រម ។ អង្គនៃការត្រាស់ដឹងដ៏ប្រសើរផង ល្អស្អាតផង ឈ្មោះថា សម្ពោជ្ឈង្គៈ ។ សម្ពោជ្ឈង្គៈ គឺ សតិ ឈ្មោះថា **សតិសម្ពោជ្ឈង្គ** (អង្គនៃការត្រាស់ដឹងព្រម គឺ សតិ) ទើបជាអង្គនៃការត្រាស់ដឹង ។ (រមែងចម្រើន) សតិសម្ពោជ្ឈង្គៈនោះ ។

សូម្បីក្នុងបទថា **ធម្មវិចយសម្ពោជ្ឈង្គំ** ដូច្នេះជាដើម មានវិនិច្ឆ័យដូចតទៅ

នេះ ៖

ឈ្មោះថា **ធម្មវិចយៈ** ព្រោះស្វែងរកសច្ចធម៌ទាំង ៤ ។ ក៏ធម្មវិចយៈនោះ មានការជ្រើសរើសជាលក្ខណៈ មានការចាក់ធ្លុះជារស មានការមិនវង្វេងជាបច្ចុប្បដ្ឋាន (អាការប្រាកដ) ។ ឈ្មោះថា **វីរិយៈ** ព្រោះភាវៈក្លាហាន និងព្រោះដំណើរទៅតាមវិធី ។ ក៏វីរិយៈនោះ មានការផ្គងទុកជាលក្ខណៈ មានការឧបត្ថម្ភជារស មានការមិនធូរថយជាបច្ចុប្បដ្ឋាន ។ ឈ្មោះថា **បីតិ** ព្រោះឆ្អែតស្កប់ស្កល់ ។ បីតិនោះ មានការផ្សាយជ្រួតជ្រាបជាលក្ខណៈ ឬមានសេចក្តីត្រេកអរជាលក្ខណៈ មានការធ្វើកាយ និងចិត្តឲ្យឆ្អែតស្កប់ស្កល់ជារស មានការធ្វើកាយ និងចិត្តនោះឯងឲ្យព្រឺព្រួចឡើងជាបច្ចុប្បដ្ឋាន ។ ឈ្មោះថា **បស្សទ្ធិ** ព្រោះរម្ងាប់សេចក្តីខ្វល់ខ្វាយនៃកាយ និងចិត្ត ។ បស្សទ្ធិនោះ មានសេចក្តីស្ងប់ជាលក្ខណៈ មានការញាំញីសេចក្តីខ្វល់ខ្វាយនៃកាយ និងចិត្តជារស មានសេចក្តីត្រជាក់ដែលកើតពីសេចក្តីមិនក្តៅក្រហាយជាបច្ចុប្បដ្ឋាន ។ ឈ្មោះថា **សមាធិ** ព្រោះការតាំងមាំ ។ ក៏សមាធិនោះ មានការមិនរើរវាយជាលក្ខណៈ ឬមានការមិនផ្សាយចេញជាលក្ខណៈ មានការប្រមូលចិត្ត និងចេតសិកទុកជារស មានការតាំងនៅនៃចិត្តជាបច្ចុប្បដ្ឋាន ។ ឈ្មោះថា **ឧបេក្ខា** ព្រោះព្រងើយកន្តើយ ។ ឧបេក្ខានោះ មានការពិចារណាជាលក្ខណៈ មានការហាមការធូរពេក និងតឹងពេកទៅជារស ឬមានការកាត់ផ្តាច់ក្នុង

ការចូលជាបច្ឆិមភាគជារស មានភាពជាកណ្តាលជាបច្ចុប្បដ្ឋាន ។ បទដ៏សេសមានន័យដូចពោលទុកហើយនុ៎ះឯង ។ បទថា **ភាវេតិ** (ចម្រើន) សេចក្តីថា កពូន គឺឲ្យបន្ថែមឡើង អធិប្បាយថា ឲ្យច្រើនឡើង ។

ក្នុងសម្ពោជ្ឈង្គៈនោះ ធម៌ ៤ ប្រការ គឺ សតិសម្បជញ្ញៈ ១ ការវៀរបុគ្គលដែលមិនមានសតិ ១ ការសេពគប់បុគ្គលដែលមានសតិតាំងមាំ ១ ភាពជាអ្នកបង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គៈនោះ ១ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃសតិសម្ពោជ្ឈង្គៈ ។ ក៏ក្នុងឋានៈទាំង ៧ សូម្បីមានការឈានទៅជាដើម សតិសម្ពោជ្ឈង្គៈរមែងកើតឡើង ដោយសតិសម្បជញ្ញៈ ព្រោះការវៀរចាកបុគ្គលដែលមិនមានសតិ ដូចក្អែកលាក់ចំណី ដោយការសេពបុគ្គលដែលមានសតិតាំងមាំ ដូចព្រះតិស្សទត្តត្ថេរៈ និងព្រះអភ័យត្ថេរៈ និងដោយភាពជាអ្នកមានចិត្តបង្អោនទៅដើម្បីឲ្យសតិតាំងឡើង ក្នុងការឈរ និងការអង្គុយជាដើម ។ ព្រោះដូច្នោះ កុលបុត្រអ្នកផ្តើមបំពេញកម្មដ្ឋាន ញ៉ាំងសតិសម្ពោជ្ឈង្គៈឲ្យតាំងឡើងដោយហេតុ ៤ ប្រការទាំងនេះ ហើយធ្វើសតិសម្ពោជ្ឈង្គៈនោះតែម្យ៉ាងឲ្យជាធុរៈ រមែងកាន់យកព្រះអរហត្តបានដោយលំដាប់ ។ កុលបុត្រនោះឯង ឈ្មោះថា ចម្រើនសតិសម្ពោជ្ឈង្គៈក្នុងព្រះអរហត្តមគ្គ ។ កាលកុលបុត្រនោះ សម្រេចព្រះអរហត្តផលហើយ រមែងជាអ្នកឈ្មោះថា ចម្រើនសតិសម្ពោជ្ឈង្គៈហើយ ។

ធម៌ ៧ ប្រការ គឺ ការសោកសួរ ១ ការធ្វើវត្ថុឲ្យល្អស្អាត ១ ការធ្វើឥន្ទ្រិយឲ្យប្រព្រឹត្តទៅស្មើ ១ វៀរចាកបុគ្គលដែលមិនមានបញ្ញា ១ សេពគប់បុគ្គលដែលមានបញ្ញា ១ ពិចារណាញាណចរិយាដ៏ជ្រាលជ្រៅ ១ បង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គៈនោះ ១ ។ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយ-សម្ពោជ្ឈង្គៈ ។

បណ្ដាធម៌ ៧ ប្រការនោះ ភាពជាអ្នកច្រើនដោយការសោកសួរ ដែលអាស្រ័យអត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ អង្គមគ្គ ឈានសមថៈ និងវិបស្សនា ឈ្មោះថា ការសោកសួរ ។ ការធ្វើឲ្យស្អាតរៀបរយដល់វត្ថុទាំងខាងក្នុង និងខាងក្រៅ ឈ្មោះថា ការធ្វើវត្ថុឲ្យស្អាតរៀបរយ ។ ក៏ក្នុងកាលណា សក់ ក្រចក និងរោមរបស់កុលបុត្រនោះវែង ឬសរីរៈមានទោស ប្រឡាក់ប្រឡូស និងប្រកបដោយមន្ទិលញើសក្អែល ក្នុងកាលនោះ វត្ថុខាងក្នុងមិនស្អាតមិនបរិសុទ្ធ ។ មួយទៀត ក្នុងកាលណា ចីវរចាស់ ស្មោកគ្រោក មានក្លិនមិនល្អ ឬសេនាសនៈស៊ុបទ្រុប ក្នុងកាលនោះ វត្ថុខាងមិនរៀបរយ មិនស្អាត ។ ព្រោះដូច្នោះ គួរធ្វើវត្ថុខាងក្នុងឲ្យស្អាតរៀបរយ ដោយការកោរសក់ជាដើម ដោយការធ្វើរាងកាយឲ្យស្រាល ដោយការសម្អាតទាំងខាងលើ និងខាងក្រោមជាដើម និងដោយការអប់ និងងូត ។ គប្បីធ្វើវត្ថុខាងក្រៅឲ្យស្អាត ដោយការដេរ ការបោក

គក់ ការជ្រលក់ និងការប្រោះព្រំជាដើម ។ ក៏ញាណក្នុងចិត្ត និងចេតសិក ដែលកើតឡើងក្នុងវត្ថុខាងក្នុង និងខាងក្រៅដែលមិនស្អាតនុ៎ះឯង ក៏ជាហេតុធ្វើញាណមិនឲ្យបរិសុទ្ធិផងដែរ ប្រៀបផ្ទឹមដូចពន្លឺរបស់ប្រទីបដែលអាស្រ័យចង្កៀងប្រទីប ប្រឆេះ និងប្រេងជាដើម ដែលមិនស្អាតកើតឡើងដូច្នោះ ។ ក៏ញាណអាស្រ័យចិត្ត និងចេតសិកដែលកើតក្នុងវត្ថុទាំងខាងក្នុង និងខាងក្រៅដែលស្អាត ក៏ជាញាណជាក់ច្បាស់ ដូចពន្លឺរបស់ប្រទីបដែលអាស្រ័យចង្កៀងប្រទីប ប្រឆេះ និងប្រេងជាដើមដែលស្អាត កើតឡើងដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា ធ្វើវត្ថុឲ្យស្អាត រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គៈ ដូច្នេះ ។

ការធ្វើឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមឲ្យស្មើ ឈ្មោះថា ការធ្វើឥន្ទ្រិយឲ្យស្មើ ។ ក៏បើសទ្ធិន្ទ្រិយរបស់កុលបុត្រនោះមានកម្លាំង ឥន្ទ្រិយក្រៅពីនេះទន់ខ្សោយ ។ តពីនោះ វីរិយិន្ទ្រិយមិនអាចធ្វើនាទីផ្គងទុក សតិន្ទ្រិយមិនអាចធ្វើនាទីដែលប្រាកដ សមាធិន្ទ្រិយមិនអាចធ្វើនាទីមិនរវើរវាយ បញ្ញិន្ទ្រិយមិនអាចធ្វើនាទីឃើញ ។ ព្រោះដូច្នោះ សទ្ធិន្ទ្រិយនោះគួរឲ្យថយចុះ ដោយការពិចារណាសភាវធម៌ ឬដោយការមិនបានដាក់ចិត្ត ដោយប្រការដែលកាលដាក់ចិត្ត (សទ្ធិន្ទ្រិយ) ត្រឡប់មានកម្លាំងឡើង ។ ក៏ក្នុងសេចក្តីនេះ មានរឿងព្រះវក្កលិត្ថេរៈជាឧទាហរណ៍ ។ បើវីរិយិន្ទ្រិយមានកម្លាំង កាលនោះ សទ្ធិន្ទ្រិយ រមែងមិនអាច

ធ្វើកិច្ចក្នុងការបង្អោនចិត្តជឿ ឥន្ទ្រិយក្រៅពីនេះ ក៏មិនអាចធ្វើកិច្ចក្រៅនេះតែមួយប្រភេទបាន ។ ព្រោះដូច្នោះ វីរិយិន្ទ្រិយគួរធ្វើឲ្យថយចុះ ដោយការធ្វើសទ្ធាជាដើមឲ្យចម្រើនឡើង ។ សូម្បីក្នុងសេចក្ដីនោះ ក៏គួរសម្ដែងរឿងរបស់ព្រះសោណត្ថេរៈ ។ សូម្បីក្នុងឥន្ទ្រិយដ៏សេស ក៏យ៉ាងនោះ ។ គប្បីជ្រាបថា កាលឥន្ទ្រិយណាមួយមានកម្លាំងខ្លាំង ឥន្ទ្រិយក្រៅពីនេះ នឹងមិនអាចក្នុងនាទីរបស់ខ្លួនៗ ។

ក៏ដោយចំពោះ ក្នុងអធិការពោលអំពីឥន្ទ្រិយនេះ លោកសរសើរការស្មើគ្នារបស់សទ្ធា និងបញ្ញា , សមាធិ និងវីរិយៈ ។ ព្រោះបុគ្គលដែលមានសទ្ធាចាស់ក្លា តែបញ្ញាទន់ខ្សោយ ជាអ្នកជ្រះថ្លាងាយ រមែងជ្រះថ្លាក្នុងវត្ថុដែលមិនគួរ ។ បុគ្គលដែលមានបញ្ញាច្រើន មានសទ្ធាតិច រមែងប្រសព្វក្នុងចំណែកតាមអំពើចិត្ត នឹងជួយបានលំបាក ដូចរោគមានសមុដ្ឋានមកពីថ្នាំ រមែងជារោគដែលជួយបានលំបាក ។ បុគ្គលដែល (មានការគិត) ច្រើនពេកថា កុសលមានដោយត្រឹមតែធ្វើឲ្យកើតឡើងក្នុងចិត្តប៉ុណ្ណោះ ហើយមិនធ្វើកុសល មានការឲ្យទានជាដើម រមែងកើតក្នុងនរក ។ ព្រោះសទ្ធា និងបញ្ញាទាំងពីរស្មើគ្នា បុគ្គលទើបជ្រះថ្លាក្នុងរឿងដែលគួរ ។ ក៏សេចក្ដីខ្ជិលច្រអូស រមែងគ្របសង្កត់បុគ្គលដែលមានសមាធិខ្លាំងក្លា តែមានសេចក្ដីព្យាយាមទន់ខ្សោយ ព្រោះសមាធិជាចំណែកជិតនឹងសេចក្ដីខ្ជិលច្រអូស ។ សេចក្ដីរវើរវាយ រមែងគ្របសង្កត់បុគ្គលដែលមានសេចក្ដីព្យាយាម

ខ្លាំងក្លា សមាធិទន់ខ្សោយ ព្រោះសេចក្តីព្យាយាមជាចំណែកជិតនឹងសេចក្តីរវើ-រវាយ ។ ក៏សមាធិដែលស្មើគ្នានឹងសេចក្តីព្យាយាម រមែងមិនធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ។ សេចក្តីព្យាយាមដែលស្មើនឹងសមាធិ រមែងមិនធ្លាក់ទៅក្នុងសេចក្តីរវើរវាយ ។ ព្រោះដូច្នោះ ត្រូវធ្វើទាំងពីរយ៉ាងនោះឲ្យស្មើគ្នា ក៏ព្រោះទាំងពីរយ៉ាងស្មើគ្នា អប្បនារមែងកើត ។

ម្យ៉ាងទៀត ចំពោះអ្នកចម្រើនសមាធិ សទ្ធាមានកម្លាំងទើបគួរ ។ ព្រោះបុគ្គលជឿ កាលដាក់ចិត្តជឿ ទើបសម្រេចដល់អប្បនា ។ ក៏បណ្តាសមាធិ និងបញ្ញា ការមានចិត្តតម្កល់មាំមានកម្លាំង រមែងគួរចំពោះអ្នកចម្រើនសមាធិ ។ ព្រោះអ្នកចម្រើនសមាធិនោះ រមែងសម្រេចដល់អប្បនា ។ បញ្ញាមានកម្លាំង រមែងគួរចំពោះលោកអ្នកបំពេញវិបស្សនា ។ ព្រោះអ្នកចម្រើនវិបស្សនានោះ រមែងសម្រេចការត្រាស់ដឹងត្រៃលក្ខណ៍ ។ ក៏សមាធិ និងបញ្ញាទាំងពីរស្មើគ្នា រមែងជាអប្បនាដោយពិត ។ ក៏សតិមានកម្លាំង រមែងគួរគ្រប់យ៉ាង ។ ក៏សតិ រមែងរក្សាចិត្តទុកមិនឲ្យធ្លាក់ទៅក្នុងសេចក្តីរាយមាយ ដោយអំណាចរបស់សទ្ធា សេចក្តីព្យាយាម និងបញ្ញា ដែលជាចំណែកជិតនៃសេចក្តីរាយមាយ និងមិនឲ្យធ្លាក់ទៅក្នុងសេចក្តីខ្ជិលច្រអូស ព្រោះសមាធិដែលជាចំណែកជិតនៃសេចក្តីខ្ជិលច្រអូស ។ ព្រោះដូច្នោះ សតិនោះត្រូវប្រាថ្នាក្នុងទីទាំងពួង ដូចអំបិល និងគ្រឿងទេស ត្រូវប្រើផ្សំជាមួយ

បាយគ្រប់ប្រភេទ និងដូចជាអាមាត្រអ្នកជំនាញក្នុងសព្វកិច្ច ចាំបាច់ត្រូវប្រើក្នុងរាជការទាំងពួង ដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលថា "សតិ ព្រះ-មានព្រះភាគត្រាស់ថា មានប្រយោជន៍គ្រប់យ៉ាង" ។ សួរថា ព្រោះហេតុអ្វី? ឆ្លើយថា ព្រោះចិត្តមានសតិជាទីពឹងអាស្រ័យ និងសតិមានការរក្សាជាអាការប្រាកដ វៀរសតិចេញហើយ ការផ្គង និងការគ្របសង្កត់ចិត្ត នឹងមានមិនបាន ដូច្នេះ ។

ការវៀរចាកឲ្យឆ្ងាយពីបុគ្គលដែលមានបញ្ញាថោកទាប បុគ្គលមិនមានបញ្ញាមិនពិចារណាក្នុងប្រភេទនៃខន្ធជាដើម ឈ្មោះថា ជាបុគ្គលដែលមានបញ្ញាថោកទាប ។ ការសេពបុគ្គលដែលប្រកបដោយឧទយព្វយប្បញ្ញា (ឃើញការកើត-រលត់) ដែលកំណត់ពិចារណាលក្ខណៈ ៥០ គត់ ឈ្មោះថា សេពគប់បុគ្គលដែលមានបញ្ញា ។ ការពិចារណាប្រភេទនៃញាណដែលជ្រាលជ្រៅ ដែលប្រព្រឹត្តទៅក្នុងខន្ធជាដើមដ៏ជ្រាលជ្រៅ ឈ្មោះថា ពិចារណាការប្រព្រឹត្តទៅនៃញាណដ៏ជ្រាលជ្រៅ ។ ការមានចិត្តបង្អោនទៅ ទោរទៅដើម្បីឲ្យធម្មវិចយសម្ពោជ្ឈង្គៈតាំងឡើងក្នុងការឈរ និងការអង្គុយជាដើម ឈ្មោះថា ការបង្អោនចិត្តទៅក្នុងធម្មវិចយ-សម្ពោជ្ឈង្គៈនោះ ។ ព្រោះដូច្នោះ កុលបុត្រអ្នកផ្តើមបំពេញសេចក្តីព្យាយាម ធ្វើធម្មវិចយសម្ពោជ្ឈង្គៈឲ្យតាំងឡើងដោយហេតុ ៧ ប្រការទាំងនេះ ធ្វើធម្មវិចយ-សម្ពោជ្ឈង្គៈនោះៗ ឯង ឲ្យជាធុរៈ រមែងកាន់យកព្រះអរហត្តបានដោយលំដាប់ ។

កុលបុត្រនោះ ឈ្មោះថា ចម្រើនធម្មវិចយសម្ពោជ្ឈង្គៈដរាបដល់អរហត្តមគ្គ ។ កាលសម្រេចផល រមែងឈ្មោះថា ជាបុគ្គលចម្រើនធម្មវិចយសម្ពោជ្ឈង្គៈហើយ ។

ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃវីរិយសម្ពោ-ជ្ឈង្គៈ គឺ ការពិចារណាភ័យក្នុងអបាយ ១ ការឃើញអានិសង្ស ១ ការពិចា-រណាផ្លូវសម្រាប់ទៅ ១ សេចក្តីកោតក្រែងចំពោះបិណ្ឌបាត ១ ការពិចារណាមត៌កក្នុងភាពជាទាយាទធំ ១ ការពិចារណាភាពជាធំនៃព្រះសាស្តា ១ ការពិចា-រណាភាពជាធំដោយជាតិ ១ ការពិចារណាក្នុងភាពជាបុគ្គលប្រព្រឹត្តព្រហ្មចរិយជាធំ ១ ការវៀរបុគ្គលខ្ជិលច្រអូស ១ សេពគប់បុគ្គលដែលផ្តើមសេចក្តីព្យាយាម ១ ភាពជាបុគ្គលមានចិត្តបង្អោនទៅក្នុងវីរិយសម្ពោជ្ឈង្គៈនោះ ១ ។

បណ្តាធម៌ ១១ ប្រការនោះ វីរិយសម្ពោជ្ឈង្គៈ រមែងកើតឡើងសូម្បីដល់អ្នកពិចារណាអបាយយ៉ាងនេះថា នរណាៗ មិនអាចញុំាងវីរិយសម្ពោជ្ឈង្គៈឲ្យកើតឡើងសូម្បីក្នុងវេលាសោយទុក្ខធំ ផ្តើមតាំងពីត្រូវទោស ដោយចំណង ៥ យ៉ាងក្នុងនរក សូម្បីក្នុងវេលាត្រូវគេចាប់ដោយសំណាញ់ អួន និងទ្រូដាដើម ក្នុងកំណើតសត្វតិរច្ឆាន , មួយទៀត សូម្បីក្នុងវេលាអូសរទេះជាដើម របស់សត្វដែលត្រូវចាក់ដោយគ្រឿងប្រហារមានជន្លួញ និងសរជាដើម សូម្បីក្នុងវេលារសាប់រសល់ដោយសេចក្តីស្រេកឃ្លានរហូតអស់ពាន់ៗ ឆ្នាំខ្លះ មួយពុទ្ធន្តរខ្លះ ក្នុងប្រេតវិស័យ

សូម្បីក្នុងវេលាសោយទុក្ខដែលកើតអំពីខ្យល់ និងកំដៅថ្ងៃជាដើម ទាំងអត្តភាព មានត្រឹមតែស្បែកដណ្តប់ឆ្អឹង កម្ពស់ប្រមាណ ៦០ ហត្ថ ក្នុងពួកប្រេតកាលកញ្ជិ- កាសុរ , ម្នាលភិក្ខុទាំងឡាយ កាលនេះឯង ជាកាលរបស់អ្នកហើយ ដូច្នេះ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើតសូម្បីដល់អ្នកឃើញអានិសង្សយ៉ាងនេះថា បុគ្គលខ្ជិលច្រអូសមិនបានលោកុត្តរធម៌ ៩ , បុគ្គលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ទើបបាន ។ នេះជាអានិសង្សរបស់វីរិយសម្ពោជ្ឈង្គៈ ។ រមែងកើតសូម្បីដល់អ្នក ពិចារណាផ្លូវទៅយ៉ាងនេះថា ផ្លូវដែលព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះមហាសាវក ទាំងពួងទៅហើយ យើងគួរទៅ ក៏ផ្លូវនោះបុគ្គលខ្ជិលច្រអូសមិនអាចទៅ ដូច្នេះ ។

រមែងកើត សូម្បីដល់អ្នកពិចារណាដល់សេចក្តីកោតក្រែងក្នុងបិណ្ឌបាត យ៉ាងនេះថា មនុស្សពួកណាទំនុកបម្រុងលោកដោយបិណ្ឌបាតជាដើម មនុស្សទាំង នេះ មិនមែនញាតិ មិនមែនទាសៈកម្មករ ឲ្យបិណ្ឌបាតដ៏ប្រណីតជាដើមដល់លោក ដោយសង្ឃឹមថា ពួកយើងនឹងអាស្រ័យលោកនោះរស់នៅ ក៏មិនមែន ដោយពិត គេសង្ឃឹមថា ការធ្វើឧបការៈរបស់ខ្លួនជាមានផលច្រើន ទើបឲ្យ ។ សូម្បីព្រះសាស្តា ទ្រង់ឃើញយ៉ាងនេះថា ភិក្ខុនេះ បរិភោគបច្ច័យទាំងនេះហើយ នឹងជាអ្នកមានរាង កាយនៅជាសុខ ដូច្នេះ ទើបទ្រង់អនុញ្ញាតបច្ច័យទាំងឡាយដល់លោក ក៏មិនមែន ដោយពិត ទ្រង់អនុញ្ញាតបច្ច័យទាំងឡាយដល់លោក ក៏ដោយព្រះបំណងថា ភិក្ខុ

នេះ បរិភោគបច្ច័យទាំងនេះធ្វើសមណធម៌ហើយនឹងរួចចាកវដ្តទុក្ខ ។ ឥឡូវនេះ លោកខ្ជិលច្រអូស មិនកោតក្រែងក្នុងបិណ្ឌបាតនោះក៏ទេ ព្រោះធម្មតាថា សេចក្តីកោតក្រែងក្នុងបិណ្ឌបាត រមែងមានដល់អ្នកដែលប្រារព្ធសេចក្តីព្យាយាមប៉ុណ្ណោះ ដូចព្រះមហាមិត្តត្ថេរ និងព្រះបិណ្ឌបាតិយតិស្សត្ថេរ ជាអ្នកពិចារណាដល់សេចក្តីកោតក្រែងក្នុងបិណ្ឌបាត ដូច្នោះ ។

បានឮមកថា ព្រះមហាមិត្តត្ថេរអាស្រ័យនៅក្នុងល្អាងឈ្មោះ **កស្សកៈ** ។ ក៏មហាឧបាសិកាម្នាក់ក្នុងគោចរគ្រាមរបស់លោក បដិបត្តិព្រះថេរៈដូចជាបុត្រ ។ ថ្ងៃមួយ នាងទៅព្រៃទើបបង្គាប់កូនស្រីថា កូន អង្ករស្រូវចាស់នៅឯណោះ ទឹកដោះស្រស់នៅឯណោះ ទឹកដោះថ្លានៅឯណោះ ទឹកអំពៅឯណោះ វេលាម្ចាស់បងមិត្តរបស់ឯងមក ឯងចូរដាំបាយថ្វាយព្រមទាំងទឹកដោះស្រស់ ទឹកដោះថ្លា និងទឹកអំពៅ ហើយឯងក៏គួរបរិភោគផងចុះ ចំណែកម៉ែនឹងបរិភោគបាយកកដែលដាំទុកកាលថ្ងៃម្សិលមិញ និងទឹកជ្រក់ ។ កូនស្រីសួរថា ចុះពេលថ្ងៃ ម៉ែនឹងបរិភោគអ្វីទេ ។ ម្តាយតបថា កូនចូរដាក់បន្លែជ្រក់ យកកញ្ចុំអង្ករដាំបបរ ហើយទុកឲ្យម៉ែចុះ ។ ព្រះថេរៈដណ្តប់ចីវរហើយកំពុងនាំបាត្រចេញមក បានឮសំឡេងនោះទើបពោលទូន្មានខ្លួនថា ន័យថា មហាឧបាសិកានឹងបរិភោគបាយកកជាមួយទឹកជ្រក់ សូម្បីពេលថ្ងៃក៏បរិភោគបបរជូរផ្សំដោយចុងអង្ករជាមួយទឹកជ្រក់ ក៏នាងប្រាប់

ឲ្យដាំបាយអង្ករស្រូវចាស់ជាដើម ដើម្បីប្រយោជន៍ដល់លោក និងនាងអាស្រ័យលោកហើយនឹងប្រាថ្នាបានស្រែ បានចម្ការក៏មិនមែន តែនាងប្រាថ្នាសម្បត្តិទាំង ៣ ទើបឲ្យ លោកនឹងអាចឲ្យសម្បត្តិទាំងនោះដល់នាងទេ ក៏បិណ្ឌបាតនេះឯង អ្នកនៅមានរាគៈ ទោសៈ មោហៈ មិនអាចទទួល ដូច្នេះហើយទើបយកបាត្រដាក់ក្នុងស្ពាក ដោះកូនក្តុំត្រឡប់ទៅកាន់ល្អាងកស្សកៈ រក្សាបាត្រទុកក្រោមគ្រែ ពាក់ចីវរទុកត្រង់ខ្សែស្នួរ អង្គុយអធិដ្ឋានសេចក្តីព្យាយាមថា បើយើងមិនទាន់សម្រេចព្រះអរហត្ត នឹងមិនចេញទៅ ។ ភិក្ខុដែលមិនប្រមាទនៅប្រចាំមកយូរ ចម្រើនវិបស្សនាក៏សម្រេចអរហត្តក្នុងវេលាមុនភត្តាហារ ជាព្រះខីណាស្រព ធ្វើការញញឹមចេញទៅដូចផ្កាឈូករីក ដូច្នោះ ។ ទេវតាដែលស្ថិតនៅត្រង់ទ្វារល្អាងថ្លែងឧទានថា ៖

នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម

យស្ស តេ អាសវា ខីណា ទក្ខិណេយ្យោសិ មារិស

បុរសអាជានេយ្យ ខ្ញុំសូមនមស្ការលោក បុរសដ៏ឧត្តម ខ្ញុំសូមនមស្ការលោក លោកអ្នកនិរទុក្ខ លោកមានអាសវៈអស់ហើយ ជាព្រះទក្ខិណេយ្យបុគ្គល ។

ដូច្នេះ ហើយពោលថា លោកដ៏ចម្រើន ស្ត្រីចាស់ថ្វាយភិក្ខាហារដល់ព្រះអរហន្តដូចលោកដែលចូលទៅបិណ្ឌបាតនឹងរួចផុតទុក្ខ ។ ព្រះថេរៈក្រោកឡើងបើកទ្វារ

សម្លឹងមើលវេលា ដឹងថានៅព្រឹក ទើបកាន់បាត្រ និងចីវរចូលទៅកាន់ស្រុក ។ ស្ងួម្បីក្មេងស្រីក៏ត្រៀមកត្តាហារទុករួចរាល់ហើយ អង្គុយសម្លឹងមើលទ្វារដោយសង្ឃឹមថា បន្តិចទៀតម្ចាស់បងរបស់យើងនឹងមកដល់ ។ កាលព្រះថេរៈដល់ទ្វារផ្ទះ ក្មេងស្រីនោះក៏ទទួលបាត្រ ដាក់កត្តាហារព្រមដោយទឹកដោះថ្លា និងទឹកអំពៅដរាបពេញ ហើយដាក់ទុកត្រង់ដៃ ។ ព្រះថេរៈធ្វើអនុមោទនាថា ចូរមានសេចក្តីសុខចុះ ហើយចៀសចេញទៅ ។ ក៏ក្មេងស្រីនោះបានឈរសម្លឹងមើលលោកហើយ ។ ក៏ក្នុងសេចក្តីនោះ ព្រះថេរៈមានឆវីវណ្ណបរិសុទ្ធិក្រៃលែងណាស់ ឥន្ទ្រិយថ្លាផូរផង់ ទឹកមុខស្រស់បស់ដូចផ្លែត្នោតទុំជ្រុះចាកទងដូច្នោះ ។ មហាឧបាសិកាត្រឡប់មកពីព្រៃសួរកូនស្រីថា លោកបងមកហើយឬកូន ។ កូនស្រីទើបប្រាប់ការប្រព្រឹត្តទៅនោះទាំងអស់ ។ ឧបាសិកាដឹងថា កិច្ចនៃបព្វជិតរបស់បុត្រយើងដល់ទីបំផុតហើយក្នុងថ្ងៃនេះ ទើបពោលថា កូន! បងប្រុសរបស់ឯងត្រេកអរ មិនធុញទ្រាន់ក្នុងព្រះពុទ្ធសាសនាឡើយ ។

ក៏រឿងព្រះបិណ្ឌបាតិយត្ថេរគប្បីជ្រាបយ៉ាងនេះ ។ បានឮថា បុរសក្រខ្វត់ម្នាក់ក្នុងស្រុកមហាគ្រាម ចិញ្ចឹមជីវិតដោយការលក់ឧស ។ បុរសនេះបានឈ្មោះតាមហេតុនោះឯង ទើបមានឈ្មោះថា ទារុកណ្ឌកមហាតិស្សៈ ។ ថ្ងៃមួយ គេនិយាយចំពោះកិរិយារបស់គេថា ឈ្មោះថា ការរស់នៅរបស់ពួកយើងដូចម្តេច ព្រះសាស្តា

ត្រាស់ថា **ទលិទ្ទទាន** (ទានរបស់អ្នកក្រ) មានផលច្រើន តែយើងមិនអាចឲ្យជា ប្រចាំបាន យើងថ្វាយបក្ខិកភត្តហើយ សូម្បីសលាកភត្តដែលកើតឡើងចំពោះមុខ យើងក៏នឹងថ្វាយ ។ ភរិយាទទួលពាក្យថា ល្អហើយនាយ ហើយបានថ្វាយបក្ខិក-ភត្តតាមមានតាមបានក្នុងថ្ងៃស្អែក ។ ក៏វេលានោះ ជាវេលាដែលព្រះភិក្ខុសង្ឃមិន ហាមដោយរឿងបច្ច័យទាំងឡាយ ។ ភិក្ខុកម្លោះ និងសាមណេរទាំងឡាយ ឆាន់ ភោជនសុទ្ធតែប្រណីត ដឹងថា នេះជាអាហារមិនល្អ ក៏ធ្វើបក្ខិកភត្តរបស់អ្នកទាំង ពីរនោះឲ្យត្រឹមតែជាថាទទួលប៉ុណ្ណោះ កាលអ្នកទាំងពីរនោះឃើញហើយ ក៏លះ ចោល ហើយក៏ទៅ ។ ចំណែកស្ត្រីនោះឃើញការធ្វើនោះ ទើបប្រាប់ដល់ស្វាមី ។ តែមិនមានសេចក្តីក្តៅក្រហាយចិត្តថា ភិក្ខុលះបង់ចោលរបស់ដែលយើងថ្វាយ ។ ស្វាមីរបស់នាងពោលថា ក៏ពួកយើងមិនអាចឲ្យលោកម្ចាស់ឆាន់បានដោយងាយ ព្រោះជាអ្នកក្រ យើងនឹងធ្វើយ៉ាងណាហ្ន៎ ទើបនឹងអាចយកចិត្តលោកម្ចាស់បាន ។ ពេលនោះ ភរិយារបស់គេពោលថា នាយ លោកនិយាយអ្វី ធម្មតាអ្នកក្រខ្សត់ ទាំងឡាយក៏មានបុត្រដែរមិនមែនឬ នេះធីតារបស់លោក ។ លោកចូរយកធីតា ម្នាក់នេះ ដាក់ជាធានាទុកក្នុងត្រកូលមួយ យកទ្រព្យត្រឹមតែ ១២ កហាបណៈមក ( ១ កហាបណៈ = ៤ បាទ របស់អ្នកស្រុកមគធៈ ) ហើយទិញមេគោយកទឹក ដោះមួយក្បាលមក យើងនឹងថ្វាយសលាកភត្តផ្សំជាមួយទឹកដោះស្រស់ដល់លោក

ម្ចាស់ យើងអាចយកចិត្តរបស់លោកម្ចាស់ទាំងនេះបាន ដោយអាការយ៉ាងនេះ ។ ស្វាមីក៏ព្រមព្រៀងថា បាន ហើយទើបធ្វើយ៉ាងនោះ ។ ដោយបុណ្យរបស់អ្នកទាំងពីរនោះ មេគោនោះ ឲ្យទឹកដោះ ៣ មាណិកៈ ក្នុងពេលល្ងាច (មាណិកៈជាមាត្រារបស់អ្នកស្រុកមគធៈ) ក្នុងពេលព្រឹកឲ្យទឹកដោះ ៣ មាណិកៈ ។ អ្នកទាំងពីរធ្វើទឹកដោះស្រស់ដែលបានក្នុងពេលល្ងាចឲ្យជាទឹកដោះជូរ ក្នុងថ្ងៃស្អែក ទើបធ្វើឲ្យជាទឹកដោះថ្លាអំពីទឹកដោះខាប់ដែលកាន់យកចាកពីទឹកដោះជូរនោះ ហើយថ្វាយសលាកកត្តផ្សំដោយទឹកដោះស្រស់ព្រមទាំងទឹកដោះថ្លាទុំឯង ចាប់តាំងអំពីនោះភិក្ខុដែលមានបុណ្យ ទើបនឹងបានសលាកកត្តក្នុងផ្ទះរបស់គេ ។

ថ្ងៃមួយ ស្វាមីពោលនឹងភរិយាថា ពួកយើងផុតពីរឿងដែលគួរអៀនខ្មាសក៏ព្រោះមានកូនស្រី ទាំងកត្តាហារក្នុងផ្ទះរបស់យើងតែមួយ ជារបស់គួរបរិភោគនៃភិក្ខុទាំងឡាយ នាងកុំប្រមាទក្នុងវត្តដ៏ល្អនេះដរាបដល់បងមកវិញ បងនឹងធ្វើការងារណាមួយដើម្បីលោះកូនស្រី គេទៅកាន់ប្រទេសមួយធ្វើការងារគាបអំពៅអស់វេលា ៦ ខែ បានប្រាក់ ១២ កហាបណៈ គិតថា ប្រាក់ប៉ុណ្ណេះអាចនឹងលោះកូនស្រីរបស់យើងបាន ទើបយកជាយសំពត់ខ្ចប់កហាបណៈទាំងនោះទុក ហើយធ្វើដំណើរដោយតាំងចិត្តថានឹងទៅស្រុក ។

ក្នុងសម័យនោះ ព្រះបិណ្ឌបាតិយតិស្សត្ថេរនៅក្នុងអម្ពរិយមហាវិហារ គិត

ថា នឹងទៅមហាវិហារថ្វាយបង្គំព្រះចេតិយ ទើបចេញអំពីទីនៅរបស់ខ្លួន ទៅកាន់ស្រុកមហាគ្រាមនិមន្តទៅផ្លូវនោះដូចគ្នា ឧបាសកនោះឃើញព្រះថេរៈពីចម្ងាយ គិតថា យើងមកតែម្នាក់ឯង នឹងទៅស្តាប់ធម្មកថាកណ្ឌមួយព្រមជាមួយលោកម្ចាស់រូបនេះ ព្រោះអ្នកមានសីលរកបានដោយលំបាកសូម្បីគ្រប់វេលា ទើបប្រញាប់ទៅឲ្យទាន់ព្រះថេរៈ ថ្វាយបង្គំហើយដើរទៅជាមួយគ្នា កាលវេលាធាន់កត្តាហារជិតចូលមកដល់ ទើបគិតថា កត្តាហារមិនមាននៅក្នុងដៃយើង ហើយក៏ដល់វេលាធាន់កិច្ចាហាររបស់លោកម្ចាស់ ទាំងតម្លៃប្រើប្រាស់នេះក៏មាននៅក្នុងដៃយើង ក្នុងវេលាដល់ស្រុកណាមួយ យើងនឹងថ្វាយបិណ្ឌបាតដល់លោកម្ចាស់ ។

កាលការគិតរបស់គេកើតឡើងយ៉ាងនេះប៉ុណ្ណោះ ក៏មានមនុស្សម្នាក់កាន់កត្តាហារមកដល់ទីនោះល្មម ឧបាសកឃើញបុរសនោះហើយ ពោលនិមន្តថា លោកម្ចាស់ដ៏ចម្រើនមេត្តារង់ចាំបន្តិចសិន ហើយចូលទៅរកបុរសនោះ ពោលថា បុរសដ៏ចម្រើន ខ្ញុំនឹងឲ្យកហាបណៈដល់លោក លោកចូរឲ្យកត្តាហារដល់ខ្ញុំ បុរសនោះគិតថា កត្តាហារនេះនឹងមានតម្លៃត្រឹមតែមួយមាសកៈក៏មិនបានផង តែឧបាសកនេះឲ្យយើងមួយកហាបណៈជាលើកដំបូងតែម្តង ហេតុក្នុងរឿងនេះនឹងមាន លុះគិតហើយទើបពោលថា មួយកហាបណៈយើងមិនឲ្យទេ ឧបាសកពោលថា បើដូច្នោះលោកចូរកាន់យក ២ កហាបណៈ ចូរកាន់យក ៣ កហាបណៈ ដោយទំនងនេះ

បំណងនឹងឲ្យកហាបណៈនោះសូម្បីទាំងអស់ បុរសនោះសម្គាល់ថា កហាបណៈសូម្បីដទៃរបស់ឧបាសកនោះនៅមាន ទើបពោលថា យើងមិនឲ្យ គ្រានោះ ឧបាសកនោះពោលនឹងបុរសនោះថា លោកដ៏ចម្រើន ប្រសិនបើកហាបណៈដទៃរបស់យើងគប្បីនៅមានសោត យើងនឹងឲ្យកហាបណៈទាំងនោះ តែយើងនឹងកាន់យកដើម្បីប្រយោជន៍ខ្លួនឯងក៏មិនមែន យើងនិមន្តលោកម្ចាស់មួយរូបឲ្យគង់ចាំនៅត្រង់គល់ឈើមួយដើម កុសលនឹងមានដល់លោកផង លោកចូរឲ្យកត្តាហារនោះដល់យើងចុះ ៗ បុរសនោះនិយាយថា លោកដ៏ចម្រើន បើដូច្នោះលោកចូរយកទៅ ចូរនាំកហាបណៈទាំងនោះមក បានកាន់យកកហាបណៈហើយ ឲ្យកត្តាហារទៅ ឧបាសកកាន់កត្តាហារចូលទៅរកព្រះថេរៈហើយពោលថា ករុណាលោកម្ចាស់ មេត្តានាំបាត្រចេញមកចុះ ព្រះថេរៈនាំបាត្រចេញមក កាលឧបាសកថ្វាយកត្តាហារចូលទៅបានពាក់កណ្តាលក៏បិទបាត្រវិញ ឧបាសកពោលថា មានតែចំណែកមួយប៉ុណ្ណោះ ខ្ញុំករុណាមិនអាចបរិភោគអំពីមួយចំណែកនេះបានទេ កត្តាហារនេះខ្ញុំស្វែងរកបានមកក៏ដើម្បីប្រយោជន៍ដល់លោកម្ចាស់ប៉ុណ្ណោះ សូមលោកម្ចាស់ចូរទទួលកត្តាហារនោះចុះ ដើម្បីអនុគ្រោះខ្ញុំ ព្រះថេរៈគិតថា មានហេតុ (សមគួរ) ទើបទទួលមកឆាន់ទាំងអស់ ឧបាសកបានគ្រងទឹកផឹកដោយគ្រឿងតម្រងទឹក ហើយថ្វាយ តពីនោះ កាលព្រះថេរៈធ្វើភត្តកិច្ចស្រេចហើយ សូម្បីទាំងពីរនាក់ក៏ធ្វើដំណើរទៅ (ជា

មួយគ្នា ) ។

ព្រះថេរៈសួរឧបាសកថា ព្រោះហេតុអ្វី លោកទើបមិនបរិភោគ ឧបាសកនោះប្រាប់រឿងរ៉ាវក្នុងការទៅរបស់ខ្លួនទាំងអស់ ព្រះថេរៈស្តាប់ការប្រព្រឹត្តទៅនោះហើយតក់ស្លុត គិតថា ឧបាសកធ្វើវត្តដែលធ្វើបានលំបាក ក៏យើងបរិភោគបិណ្ឌបាតជាបែបនេះ គួរជាអ្នកកតញ្ញូចំពោះឧបាសកនេះ យើងបានសេនាសនៈដែលជាទីសប្បាយហើយ កាលស្បែក សាច់ និងឈាម សូម្បីនឹងស្ងួតទៅក្នុងសេនាសនៈនោះ (ក៏ដោយ) បើមិនទាន់សម្រេចព្រះអរហត្តដោយការអង្គុយទុំះឯង នឹងមិនក្រោកឡើងឡើយ ព្រះថេរៈនោះទៅកាន់តិស្សមហាវិហារ ធ្វើអាគន្តុកវត្ត (គឺវត្តបដិបត្តិសម្រាប់អ្នកចរមក) ហើយចូលទៅកាន់សេនាសនៈសម្រាប់ខ្លួន ក្រាលកម្រាលហើយអង្គុយលើកម្រាលនោះ កំណត់មូលកម្មដ្ឋានរបស់ខ្លួននោះឯង ព្រះថេរៈនោះមិនអាចនឹងធ្វើសូម្បីត្រឹមតែឱកាសឲ្យកើតឡើងក្នុងរាត្រីនោះ ។ ចាប់ផ្តើមតាំងពីថ្ងៃស្អែក ទើបកាត់សេចក្តីកង្វល់ក្នុងការស្វែងរកកិច្ចាចេញ ក៏ឃើញច្បាស់កម្មដ្ឋាននោះឯង ទាំងអនុលោម និងបដិលោម ព្រះថេរៈឃើញច្បាស់ហើយឧបាយនេះ បានសម្រេចព្រះអរហន្តព្រមដោយបដិសម្ភិទាក្នុងអរុណទី ៧ ហើយគិតថា សរីរៈនេះនឿយលំបាកពេកណាស់ ជីវិតរបស់យើងនឹងប្រព្រឹត្តទៅបានយូរទេហ្ន៎ គ្រានោះ ព្រះថេរៈកំណត់បានពិតប្រាកដថា សរីរៈនោះនឹងមិនអាចប្រព្រឹត្តទៅបាន

ទើបកាន់បាត្រ និងចីវរទៅកណ្តាលវិហារ វាយស្គរឲ្យភិក្ខុសង្ឃប្រជុំគ្នា ។

ព្រះសង្ឃត្ថេរសួរថា នរណាឲ្យភិក្ខុសង្ឃប្រជុំ ។ ព្រះថេរៈឆ្លើយថា ខ្ញុំករុណា ។ ព្រះសង្ឃត្ថេរសួរថា ដើម្បីអ្វី អាវុសោ ។ ព្រះថេរៈឆ្លើយថា កម្មដទៃមិនមានទេ លោកម្ចាស់ ប៉ុន្តែថា លោកម្ចាស់អង្គណាមានសេចក្តីសង្ស័យក្នុងមគ្គ ឬផល លោកម្ចាស់អង្គនោះចូរសួរខ្ញុំចុះ ។ ព្រះសង្ឃត្ថេរៈសួរថា អាវុសោ ភិក្ខុទាំងឡាយដូចលោក រមែងមិនពោលគុណដែលមិនមានទេ សេចក្តីសង្ស័យក្នុងមគ្គ ឬផលនេះមិនមានដល់ពួកយើង ក៏អ្វីជាហេតុឲ្យកើតសេចក្តីសង្វេគដល់លោក ។ លោកធ្វើអ្វីឲ្យជាបច្ច័យ ព្រះអរហត្តនេះទើបកើតឡើង ។ ព្រះថេរៈឆ្លើយថា លោកម្ចាស់ក្នុងវល្លិយវិថីនាស្រុកមហាគ្រាមនេះ មានឧបាសកឈ្មោះទារុភណ្ឌកមហាតិស្សៈចងកូនស្រីរបស់ខ្លួនទុកខាងក្រៅ ហើយយកទ្រព្យមក ១២ កហាបណៈ ទិញមេគោយកទឹកដោះមួយក្បាល ផ្តើមតាំងសលាកភត្តទឹកដោះស្រស់ដល់ព្រះសង្ឃ ។ គេគិតថា យើងនឹងលោះធីតា ទើបធ្វើការស៊ីឈ្នួលនៅក្នុងរោងគាបអំពៅអស់ ៦ ខែ បានទ្រព្យ ១២ កហាបណៈ ហើយទើបដើរទៅស្រុករបស់ខ្លួនដោយបំណងថានឹងលោះធីតា ឃើញខ្ញុំព្រះករុណាក្នុងរវាងផ្លូវ ក្នុងវេលាភិក្ខាចារ បានឲ្យកហាបណៈទាំងអស់នោះ ហើយកាន់យកភត្តាហារមកប្រគេនខ្ញុំករុណាទាំងអស់ ។ ខ្ញុំឆាន់បិណ្ឌបាតនោះហើយមកទីនេះ បានសេនាសនៈដែលសប្បាយហើយគិតថា យើង

នឹងធ្វើសេចក្ដីកោតក្រែងចំពោះបិណ្ឌបាត ដូច្នេះ ទើបបានធ្វើគុណវិសេសឲ្យកើតឡើង លោកម្ចាស់ ។ បរិស័ទទាំង ៤ ប្រជុំគ្នានៅទីនោះ បានឲ្យសាធុការដល់ព្រះថេរៈ ។ ឈ្មោះថា អ្នកអាចដើម្បីតាំងនៅតាមការៈរបស់ខ្លួនមិនមានឡើយ ។ ព្រះថេរៈអង្គុយនិយាយនៅត្រង់កណ្ដាលសង្ឃ កំពុងនិយាយទុំឯង អធិដ្ឋានថា កូដាគារ (គឺផ្ទះកំពូល) របស់យើងចូរឃ្លាតទៅ ក្នុងវេលាដែលទារុកណ្ឌកមហាតិស្សៈ យកដៃពាល់ត្រូវប៉ុណ្ណោះ ដូច្នេះហើយ បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។

ព្រះបាទកាកវណ្ណតិស្សមហារាជទ្រង់ស្ដាប់ថា ព្រះថេរៈមួយរូបបរិនិព្វានទើបស្ដេចទៅកាន់វិហារ ទ្រង់ធ្វើសក្ការៈហើយ ត្រាស់បង្គាប់ឲ្យត្រៀមកូដាគារ ហើយលើកព្រះថេរៈដាក់ក្នុងកូដាគារនោះ ទ្រង់ត្រិះរិះថា យើងនឹងទៅត្រង់ជើងក្ដារឥឡូវនេះ ទើបទ្រង់លើកកូដាគារ ក៏មិនអាចធ្វើឲ្យឃ្លាតទីបាន ។ ព្រះរាជាត្រាស់សួរភិក្ខុសង្ឃថា លោកម្ចាស់ដ៏ចម្រើន ពាក្យអ្វីដែលព្រះថេរៈពោលទុក មានឬទេ ។ ភិក្ខុទាំងឡាយទើបទូលរឿងរ៉ាវដែលព្រះថេរៈពោលទុក ។ ព្រះរាជាត្រាស់បង្គាប់ឲ្យហៅឧបាសកនោះមក ហើយត្រាស់សួរថា ក្នុងទីបំផុត ៧ ថ្ងៃ បន្ទាប់ពីនេះទៅ អ្នកថ្វាយភត្តាហារដល់ភិក្ខុណាខ្លះ ដែលធ្វើដំណើរឬ ។ ឧបាសកទូលថា ថ្វាយភិក្ខុអង្គនេះ ព្រះសម្មតិទេព ។ ព្រះរាជាត្រាស់សួរថា អ្នកថ្វាយទំនងណា ។ ឧបាសក

នោះ ទើបក្រាបទូលហេតុការណ៍ទាំងអស់ ។ លំដាប់នោះ ព្រះរាជាទើបទ្រង់បញ្ជូនឧបាសកនោះទៅត្រង់ទីតាំងកូដាគាររបស់ព្រះថេរៈ ដោយព្រះតម្រាស់ថា អ្នកចូរទៅ ចូរដឹងព្រះថេរៈនោះថា ជាអគ្គនោះ ឬអគ្គដទៃ ។ ឧបាសកនោះទៅហើយលើកវាំងននឡើងឃើញមុខព្រះថេរៈក៏ចាំបាន យកដៃទាំងពីរគក់ទ្រូង ហើយទៅកាន់សំណាក់ព្រះរាជា ក្រាបទូលថា បពិត្រសម្មតិទេព ជាលោកម្ចាស់របស់ខ្ញុំព្រះអង្គ ។ លំដាប់នោះ ព្រះរាជាត្រាស់បង្គាប់ឲ្យព្រះរាជទានគ្រឿងប្រដាប់ដ៏ធំដល់ឧបាសកនោះ ត្រាស់ចំពោះឧបាសកអ្នកប្រដាប់ស្រេចហើយថា មហាតិស្សៈបងប្រុស លោកចូរទៅថ្វាយបង្គំលោកម្ចាស់របស់យើងហើយ ទើបលើកកូដាគារឡើង ។ ឧបាសកទទួលព្រះតម្រាស់ថា ព្រះករុណា ព្រះអង្គ ហើយទៅថ្វាយបង្គំបាទាព្រះថេរៈ យកដៃទាំងពីរលើកឡើងទូលលើក្បាលរបស់ខ្លួន ។ ខណៈនោះឯង កូដាគារក៏អណ្តែតទៅតាមផ្លូវអាកាស ប្រតិស្ឋានទៅខាងលើជើងថ្ករ ។ ក្នុងកាលនោះ អណ្តាតភ្លើងក៏ឆេះឡើងឯងអំពីជ្រុងទាំង ៤ នៃជើងថ្ករ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើត សូម្បីដល់អ្នកពិចារណាដល់មត៌ក ជាទាយាទធំយ៉ាងនេះថា ក៏ទ្រព្យមត៌ក គឺ អរិយទ្រព្យ ៧ របស់ព្រះសាសនានោះជារបស់ធំក្រៃលែង ទ្រព្យមត៌កនោះ ដែលបុគ្គលខ្ជិលច្រអូសមិនអាចទទួលបាន ដូចជាមាតាបិតា រមែងកាត់កាល់បុត្រដែលប្រព្រឹត្តខុសទុកខាងក្រៅថា អ្នកនេះមិនមែន

ជាបុត្ររបស់យើង កាលមាតាបិតាស្លាប់ទៅ គេរមែងមិនបានទ្រព្យមត៌ក យ៉ាងណា សូម្បីបុគ្គលខ្ជិលច្រអូសក៏ដូច្នោះ រមែងមិនបានមត៌ក គឺ អរិយទ្រព្យនេះ បុគ្គលប្រារព្ធសេចក្ដីព្យាយាមប៉ុណ្ណោះ ទើបបាន ដូច្នេះ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើត សូម្បីដល់អ្នកពិចារណាដល់ព្រះសាស្ដាជាធំយ៉ាងនេះថា ក៏ព្រះសាស្ដារបស់លោកជាធំដ៏ក្រៃលែង ព្រោះក្នុងវេលាដែលព្រះសាស្ដារបស់លោកបដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតាក្ដី ស្ដេចចេញដើម្បីគុណដ៏ធំក្រៃលែងក្ដី ក្នុងការត្រាស់ដឹងសម្ពោធិញ្ញាណដ៏ក្រៃលែងក្ដី ក្នុងការប្រកាសព្រះធម្មចក្ក ទ្រង់សម្ដែងយមកបាដិហារ្យ ស្ដេចចុះចាកពីទេវលោក និងទ្រង់ដាក់អាយុសង្ខារក្ដី ក្នុងកាលរលត់ខន្ធបរិនិព្វានក្ដី មុឺនលោកធាតុញាប់ញ័រហើយ ការដែលលោកបួសក្នុងសាសនារបស់ព្រះសាស្ដាបែបនោះ ហើយជាបុគ្គលខ្ជិលច្រអូសមិនសមគួរឡើយ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើត សូម្បីដល់អ្នកពិចារណាដល់ជាតិជាធំយ៉ាងនេះថា សូម្បីពោលដោយជាតិ ឥឡូវនេះ លោកក៏ជាអ្នកមានជាតិមិនទទន់ខ្សោយ លោកជាអ្នកកើតក្នុងវង្សរបស់ព្រះបាទឧក្កាករាជ ដែលជាខ្សែស្រឡាយបន្តមកពីវង្សព្រះបាទមហាសម្មតរាជ ដែលមិនលាយឡំ (នឹងវង្សដទៃ) ជាញាតិរបស់ព្រះបាទសុទ្ធោទនមហារាជ និងព្រះនាងមាយាទេវី ជាប្អូនប្រុសរបស់ព្រះរាហុលភទ្ទៈ

ឈ្មោះថា លោកជាបុត្ររបស់ព្រះជិនស្រីបែបនេះ ជាបុគ្គលខ្ជិលច្រអូស មិនគួរឡើយ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើត សូម្បីដល់អ្នកពិចារណាសព្រហ្មចារីជាធំយ៉ាងនេះថា ព្រះសារីបុត្រ និងព្រះមោគ្គល្លាន និងព្រះអសីតិមហាសាវក រមែងត្រាស់ដឹងលោកុត្តរធម៌ ៩ ដោយសេចក្ដីព្យាយាម លោកចូរប្រព្រឹត្តតាមផ្លូវរបស់សព្រហ្មចរិយទាំងនោះ ដូច្នេះ ។

វីរិយសម្ពោជ្ឈង្គៈ រមែងកើត សូម្បីដល់បុគ្គលដែលវៀរបុគ្គលខ្ជិលច្រអូស បុគ្គលលះបង់សេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ដូចជាពោះថ្លាន់ស៊ីពេញពោះហើយក៏ឈប់ (មិនវារទៅណា) សូម្បីដល់អ្នកសេពគប់បុគ្គលដែលមានចិត្តរឹងមាំប្រារព្ធសេចក្ដីព្យាយាម សូម្បីដល់បុគ្គលដែលមានចិត្តបង្អោនទៅ ដើម្បីញុំាងសេចក្ដីព្យាយាមឲ្យកើតឡើងក្នុងការឈរ និងការអង្គុយជាដើម ។ ព្រោះដូច្នោះ កុលបុត្រអ្នកផ្ដើមបំពេញកម្មដ្ឋាន ធ្វើវីរិយសម្ពោជ្ឈង្គៈឲ្យតាំងឡើង ដោយហេតុ ១១ ប្រការ ទាំងនេះហើយ ធ្វើវីរិយសម្ពោជ្ឈង្គៈនោះឯងឲ្យជាធុរៈ តម្កល់ទុកឲ្យមាំ រមែងកាន់យកព្រះអរហត្តបានដោយលំដាប់ ។ កុលបុត្រនោះ ឈ្មោះថា បានចម្រើនវីរិយសម្ពោជ្ឈង្គៈដរាបដល់អរហត្តមគ្គ ។ កាលសម្រេចផលហើយ ឈ្មោះថា ជាអ្នកចម្រើនវីរិយសម្ពោជ្ឈង្គៈហើយនោះឯង ។

ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គៈ គឺ ពុទ្ធានុស្សតិ (រឭកដល់គុណរបស់ព្រះពុទ្ធ) ១ ធម្មានុស្សតិ (រឭកដល់គុណរបស់ព្រះធម៌) ១ សង្ឃានុស្សតិ (រឭកដល់គុណរបស់ព្រះសង្ឃ) ១ សីលានុស្សតិ (រឭកដល់គុណរបស់សីល) ១ ចាគានុស្សតិ (រឭកដល់ការបរិច្ចាគ) ១ ទេវ-តានុស្សតិ (រឭកដល់គុណដែលធ្វើបុគ្គលឲ្យជាទេវតា) ១ ឧបសមានុស្សតិ (រឭកដល់ការចូលទៅស្ងប់ គឺ ព្រះនិព្វាន) ១ វៀរបុគ្គលសៅហ្មង ១ សេពគប់បុគ្គលរៀបរយ ១ ពិចារណាព្រះសូត្រដែលគួរជ្រះថ្លា ១ ជាបុគ្គលមានចិត្តបង្អោនទៅក្នុងបីតិសម្ពោជ្ឈង្គៈនោះ ១ ។

ក៏សូម្បីកាលបុគ្គលរឭកដល់គុណរបស់ព្រះពុទ្ធ បីតិសម្ពោជ្ឈង្គៈ រមែងកើតឡើងផ្សាយជ្រួតជ្រាបសព្វាង្គកាយ ដរាបដល់ឧបចារសមាធិ ។ បីតិសម្ពោ-ជ្ឈង្គៈ រមែងកើត សូម្បីដល់បុគ្គលដែលរឭកដល់គុណរបស់ព្រះធម៌ និងព្រះសង្ឃ សូម្បីដល់បព្វជិតដែលពិចារណាចតុប្បារិសុទ្ធិសីល រក្សាមិនឲ្យដាច់មករហូតអស់កាលយូរ សូម្បីដល់គ្រហស្ថដែលពិចារណាសីល ១០ សីល ៥ សូម្បីដល់បុគ្គលដែលប្រគេនភោជនដ៏ប្រណីតដល់សព្រហ្មចារីក្នុងយាមមានភ័យ ដែលកើតពីការស្វែងរកភិក្ខាហារបានលំបាកជាដើម ហើយពិចារណាដល់ការបរិច្ចាគថា យើងបានឲ្យទានឈ្មោះយ៉ាងនេះហើយជាដើម សូម្បីដល់គ្រហស្ថ ដែលពិចារណាដល់ទាន

ដែលឲ្យហើយដល់លោកអ្នកមានសីលទាំងឡាយបែបនេះ សូម្បីដល់អ្នកពិចារ-
ណាដល់គុណទាំងឡាយ ដែលជាហេតុឲ្យអ្នកប្រកបសម្រេចភាពជាទេវតាបែបនោះ
ថាមាននៅក្នុងខ្លួន សូម្បីដល់បុគ្គលពិចារណាដល់កិលេសទាំងឡាយដែលគ្របសង្កត់
ដោយការចូលសមាបត្តិថា មិនរវើរវាយមកអស់ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ សូម្បីដល់
អ្នកដែលវៀរចាកបុគ្គលសៅហ្មងដូចជាធូលីលើខ្នងលា ព្រោះមិនមានការស្រឡាញ់
ដោយអំណាចសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាដើម ព្រោះជាអ្នកសៅហ្មង ដែលដល់
កិរិយាដែលមិនគោរពក្នុងការឃើញព្រះចេតិយ ឃើញដើមពោធិ៍ និងឃើញព្រះថេរៈ
សូម្បីដល់អ្នកសេពគប់បុគ្គលដែលរៀបរយ មានចិត្តទន់ភ្លន់ ច្រើនដោយសេចក្តី
ជ្រះថ្លាក្នុងព្រះពុទ្ធជាដើម សូម្បីដល់អ្នកពិចារណាព្រះសូត្រដែលគួរជ្រះថ្លា សម្តែង
គុណរបស់ព្រះរតនត្រ័យ សូម្បីដល់អ្នកមានចិត្តបង្អោនទៅដើម្បីញ៉ាំងបីតិឲ្យកើត
ឡើងក្នុងការឈរ និងការអង្គុយជាដើម ។ ព្រោះហេតុនោះ កុលបុត្រអ្នកផ្តើម
បំពេញកម្មដ្ឋាន ញ៉ាំងបីតិសម្ពោជ្ឈង្គៈឲ្យតាំងឡើងដោយហេតុ ១១ ប្រការនេះ
ហើយ ធ្វើបីតិសម្ពោជ្ឈង្គៈនោះឯងឲ្យជាធុរៈ តម្កល់ទុក រមែងកាន់យកព្រះអរហត្ត
បានដោយលំដាប់ ។ កុលបុត្រនោះ ឈ្មោះថា ចម្រើនបីតិសម្ពោជ្ឈង្គៈដរាបដល់
អរហត្តមគ្គ ។ កាលសម្រេចផលហើយ ឈ្មោះថា ជាអ្នកចម្រើនបីតិសម្ពោជ្ឈង្គៈ
ហើយ ។

ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតនៃបស្សទ្ធិសម្ពោជ្ឈង្គៈ គឺ សេពភោជនដែលប្រណីត ១ សេពរដូវដែលសប្បាយ ១ សេពឥរិយាបថដែលសប្បាយ ១ ប្រកបខ្លួនជាកណ្តាល ១ វៀរបុគ្គលដែលមានកាយមិនស្ងប់ ១ សេពបុគ្គលដែលមានកាយស្ងប់ ១ បង្អោនចិត្តទៅក្នុងបស្សទ្ធិសម្ពោជ្ឈង្គៈនោះ ១ ។

ក៏សេចក្តីស្ងប់ រមែងកើតដល់បុគ្គលបរិភោគភោជនដែលសប្បាយ ប្រណីត ស្អាតល្អ សូម្បីដល់បុគ្គលសេពរដូវដែលត្រជាក់ និងក្តៅ និងឥរិយាបថមានឈរជាដើមដែលសប្បាយ ។ ក៏បុគ្គលណាមានជាតិជាមហាបុរស ជាអ្នកអត់ធន់បានក្នុងរដូវ (ត្រជាក់ ក្តៅ) និងឥរិយាបថទាំងពួង ពាក្យនេះ លោកពោលអំពីសំដៅយកបុគ្គលនេះក៏មិនមែន ។ សេចក្តីស្ងប់ រមែងកើតដល់បុគ្គលដែលសេពរដូវនិងឥរិយាបថដែលជាសភាគគ្នា ។ ការពិចារណាភាពជាអ្នកមានកម្មជារបស់ខ្លួនទាំងរបស់ខ្លួន និងរបស់អ្នកដទៃ ហៅថា ការប្រកបខ្លួនជាកណ្តាល សេចក្តីស្ងប់រមែងកើតដោយការប្រកបខ្លួនជាកណ្តាលដូចពោលមកនេះ ។ សេចក្តីស្ងប់ រមែងកើតសូម្បីដល់អ្នកវៀរបុគ្គលដែលមានកាយមិនស្ងប់ អ្នកត្រាច់បៀតបៀនសត្វដទៃដោយដុំដី និងកំណាត់ឈើជាដើម សូម្បីដល់អ្នកសេពបុគ្គលដែលមានកាយស្ងប់សង្រួមដៃ និងជើង សូម្បីដល់អ្នកមានចិត្តបង្អោនទៅដើម្បីត្រូវការធ្វើសេចក្តីស្ងប់ឲ្យកើតឡើងក្នុងការឈរ និងការអង្គុយជាដើម ។ ព្រោះដូច្នោះ កុលបុត្រអ្នកផ្តើម

បំពេញកម្មដ្ឋាន ញ៉ាំងធម្មវិចយសម្ពោជ្ឈង្គៈឲ្យតាំងឡើងដោយហេតុ ៧ ប្រការនេះ ធ្វើធម្មវិចយសម្ពោជ្ឈង្គៈនោះឲ្យជាធុរៈ តម្កល់ទុកឲ្យល្អ រមែងកាន់យកព្រះអរហត្ត បានដោយលំដាប់ ។ កុលបុត្រនោះ ឈ្មោះថា រមែងចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ រហូតដល់ព្រះអរហត្តមគ្គ កាលសម្រេចផលហើយ រមែងឈ្មោះថា ចម្រើនធម្មវិចយ-សម្ពោជ្ឈង្គៈបានហើយ ។

ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតនៃសមាធិសម្ពោជ្ឈង្គៈ គឺ ធ្វើវត្ថុឲ្យស្អាតរៀបរយ ១ ធ្វើឥន្ទ្រិយឲ្យប្រព្រឹត្តទៅស្មើ ១ សេចក្តីឆ្លាតក្នុងនិមិត្ត ១ ផ្គងចិត្តក្នុងសម័យ (គួរផ្គង) ១ គ្របសង្កត់ចិត្តក្នុងសម័យ (គួរគ្របសង្កត់) ១ ការធ្វើ (ចិត្ត) ឲ្យរីករាយក្នុងសម័យ (គួរឲ្យរីករាយ) ១ ការសម្លឹងមើលចិត្ត ក្នុងសម័យ (គួរសម្លឹងមើល) ១ វៀរបុគ្គលដែលមានចិត្តមិនតាំងមាំ ១ សេព បុគ្គលដែលមានចិត្តតាំងមាំ ១ ពិចារណាឈាន និងវិមោក្ខ ១ ភាពជាអ្នកមាន ចិត្តបង្អោនទៅក្នុងសមាធិសម្ពោជ្ឈង្គៈ ១ ។

បណ្តាធម៌ទាំងនោះ ការធ្វើវត្ថុឲ្យស្អាតរៀបរយ និងការធ្វើឥន្ទ្រិយឲ្យប្រព្រឹត្ត ទៅស្មើ គប្បីជ្រាបដោយន័យដូចពោលហើយ ។ សេចក្តីឆ្លាតក្នុងការរៀនកសិណ និមិត្ត ឈ្មោះថា ឆ្លាតក្នុងនិមិត្ត ។ បទថា **សមយេ ចិត្តស្ស បគ្គណ្ហនតា** (ផ្គង ចិត្តក្នុងសម័យ) សេចក្តីថា ក្នុងសម័យណា ចិត្តរួញរាដោយធូរថយសេចក្តីព្យាម

ជាដើម ក្នុងសម័យនោះ ផ្គងចិត្តទុកដោយការធ្វើធម្មវិចយសម្ពោជ្ឈង្គៈ វីរិយ-សម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈឲ្យកើតឡើង ។ បទថា **សមយេ ចិត្តស្ស និគ្គ-ណ្ហនតា** (គ្របសង្កត់ចិត្តក្នុងសម័យ) សេចក្តីថា ក្នុងសម័យណា ចិត្តរាយមាយដោយប្រារព្ធសេចក្តីព្យាយាមខ្លាំងពេក ក្នុងសម័យនោះ ត្រូវគ្របសង្កត់ចិត្តដោយបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈឲ្យកើតឡើង ។ បទថា **សមយេ សម្បហំសនតា** (ការធ្វើចិត្តឲ្យរីករាយក្នុងសម័យ) សេចក្តីថា ក្នុងសម័យណា ចិត្តមិនរីករាយ ព្រោះប្រកបដោយបញ្ញាតិចតួច ឬព្រោះមិនបានសុខដែលស្ងប់ ក្នុងសម័យនោះឯង គប្បីញ៉ាំងចិត្តឲ្យសង្វេគដោយការពិចារណាសំវេគវត្ថុ ៨ ប្រការ ។ ឈ្មោះថា សំវេគវត្ថុ ៨ ប្រការ គឺ ជាតិ ជរា ព្យាធិ មរណៈ រួមជា ៤ ទុក្ខក្នុងអបាយជាទី ៥ ទុក្ខមានវដ្តៈជាមូលក្នុងអតីតជាទី ៦ ទុក្ខមានការស្វែងរកអាហារក្នុងបច្ចុប្បន្នជាទី ៧ ទុក្ខមានវដ្តៈជាមូលក្នុងអនាគតជាទី ៨ ។ ការញ៉ាំងសេចក្តីជ្រះថ្លាឲ្យកើតឡើង ដោយការរឭកដល់គុណរបស់ព្រះរតនត្រ័យ នេះហៅថា ការធ្វើចិត្តឲ្យរីករាយក្នុងសម័យ ។ ឈ្មោះថា ការសម្លឹងមើលចិត្តក្នុងសម័យ បានដល់ ក្នុងគ្រាដែលចិត្តអាស្រ័យការបដិបត្តិប្រពៃជាចិត្តមិនរួញរា មិនរាយមាយ មានសេចក្តីរីករាយ ប្រព្រឹត្តទៅតាមសមថវិថីដែលប្រព្រឹត្តទៅយ៉ាងស្មើក្នុងអារម្មណ៍នោះ កុលបុត្រមិនត្រូវខ្វល់ខ្វាយក្នុងការផ្គង គ្រប

សង្កត់ និងធ្វើឲ្យរីករាយ ដូចសារថី មិនត្រូវខ្វល់ខ្វាយក្នុងកាលសេះរត់ទៅស្មើ នេះហៅថា ការសម្លឹងមើលចិត្តក្នុងសម័យ ។ ឈ្មោះថា ការវៀរបុគ្គលដែលមានចិត្តមិនតាំងមាំ បានដល់ វៀរឲ្យឆ្ងាយពីបុគ្គលដែលមានចិត្តរាយមាយ បុគ្គលមិនទាន់សម្រេចឧបចារសមាធិ ឬអប្បនាសមាធិ ។ ឈ្មោះថា សេពបុគ្គលដែលមានចិត្តតាំងមាំ បានដល់ សេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលមានចិត្តតាំងមាំដោយឧបចារសមាធិ និងអប្បនាសមាធិ ។ ឈ្មោះថា ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងសមាធិសម្ពោជ្ឈង្គៈនោះ បានដល់ ជាអ្នកមានចិត្តបង្អោនទៅ ឈមទៅដើម្បីឲ្យសមាធិកើតឡើងក្នុងការឈរ និងការអង្គុយជាដើម ។ ក៏កាលបដិបត្តិយ៉ាងនោះឯង សមាធិសម្ពោជ្ឈង្គៈរមែងកើតឡើង ។ ព្រោះដូច្នោះ កុលបុត្តអ្នកផ្តើមបំពេញកម្មដ្ឋាន ញ៉ាំងសមាធិសម្ពោជ្ឈង្គៈឲ្យកើតឡើងដោយហេតុ ១១ ប្រការនេះ ការធ្វើសមាធិសម្ពោជ្ឈង្គៈប៉ុណ្ណោះឲ្យជាធុរៈ តម្កល់មាំហើយ រមែងកាន់យកព្រះអរហត្តបានដោយលំដាប់ ។ កុលបុត្រនោះ ឈ្មោះថា បំពេញសមាធិសម្ពោជ្ឈង្គៈដរាបដល់អរហត្តមគ្គ កាលសម្រេចផលហើយ រមែងឈ្មោះថា ជាអ្នកបានចម្រើនសមាធិសម្ពោជ្ឈង្គៈហើយ ។

ធម៌ ៥ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គៈ គឺ ភាពជាកណ្តាលក្នុងសត្វ ១ ភាពជាកណ្តាលក្នុងសង្ខារ ១ ការវៀរបុគ្គលដែល

ជាប់ជំពាក់ក្នុងសត្វ និងសង្ខារ ១ សេពគប់បុគ្គលដែលដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ ១ ភាពជាអ្នកមានចិត្តបង្អោនទៅក្នុងឧបេក្ខាសម្ពោជ្ឈង្គៈ ១ ។

ក្នុងធម៌ ៥ ប្រការនោះ បុគ្គលរមែងញ៉ាំងភាពជាកណ្តាលក្នុងសត្វឲ្យកើតឡើងដោយអាការ ២ យ៉ាង គឺ ដោយការពិចារណាដល់សត្វមានកម្មជារបស់ខ្លួន យ៉ាងនេះថា យើងមកដោយកម្មរបស់ខ្លួន នឹងទៅដោយកម្មរបស់ខ្លួន សូម្បីសត្វនេះនឹងទៅដោយកម្មរបស់ខ្លួនដូចគ្នា យើងនឹងប្រកាន់នរណាថាជារបស់ខ្លួន ដូច្នេះ និងដោយការពិចារណាដល់ការមិនមាននៃសត្វយ៉ាងនេះថា ដោយបរមត្ថ សត្វមិនមាន យើងនឹងប្រកាន់នរណាថាជារបស់ខ្លួន ដូច្នេះ ។ បុគ្គលរមែងញ៉ាំងភាពជាកណ្តាលក្នុងសង្ខារឲ្យកើតឡើងដោយអាការ ២ យ៉ាង គឺ ដោយការពិចារណាដល់របស់ដែលមិនមានម្ចាស់ យ៉ាងនេះថា ចីវរនេះចូលដល់ភាពពិការ (ប្រែប្រួល) នៃពណ៌ និងការចាស់ទៅដោយលំដាប់ ជាកំណាត់សំពត់សម្រាប់ជូតជើង នឹងត្រូវយកចុងឈើច្រត់កៀសចោល ក៏បើចីវរនោះគប្បីមានម្ចាស់ គេនឹងត្រូវមិនឲ្យវាវិនាសទៅយ៉ាងនេះ និងដោយការពិចារណាជារបស់មួយខណៈ មួយគ្រា យ៉ាងនេះថា ចីវរនេះជារបស់មួយខណៈ មួយគ្រា មិនមាំទាំ ដូច្នេះ ។ សូម្បីក្នុងបាត្រជាដើម ក៏គប្បីប្រកបសេចក្តីដូចក្នុងចីវរនុ៎ះឯង ។

ក្នុងបទថា *សត្តសង្ខារកេលាយនបុគ្គលបរិវជ្ជនតា* (ការវៀរបុគ្គលដែល

ជាប់ជំពាក់ក្នុងសត្វ និងសង្ខារ) នេះ គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ។ បុគ្គលណាជាគ្រហស្ថ ប្រកាន់បុត្ត និងធីតាជាដើមរបស់ខ្លួនថា ជារបស់យើង ឬជាបព្វជិតប្រកាន់អន្តេវាសិកអ្នករួមឧបជ្ឈាយ៍គ្នាជាដើមថា ជារបស់យើង ធ្វើការកោរសក់កោរពុកមាត់ ដេរចីវរ ជ្រលក់ចីវរ និងដុតបាត្រជាដើម ដល់អន្តេវាសិកជាដើមទាំងនោះដោយដៃរបស់ខ្លួនឯង កាលមិនឃើញសូម្បីត្រឹមតែមួយរយៈ ក៏រកមើលទៅដោយជុំវិញថា សាមណេរឯណោះទៅណា ភិក្ខុកម្លោះឯណោះទៅណា ដូច្នេះដូចម្រឹគផ្អើល សម្លឹងមើលផ្លូវនេះផ្លូវនោះដូច្នោះ សូម្បីអ្នកដទៃនឹងសូមទៅដើម្បីប្រយោជន៍ដល់ការកោរសក់ជាដើមថា សូមលោកម្ចាស់ឲ្យភិក្ខុរូបឯណោះទៅត្រឹមតែមួយភ្លែតចុះ ក៏មិនឲ្យ ដោយនិយាយបង្វៀងថា សូម្បីពួកយើងក៏មិនទាន់ឲ្យភិក្ខុរូបនោះធ្វើការងាររបស់ខ្លួន ពួកលោកនាំភិក្ខុនេះទៅនឹងមានសេចក្តីលំបាក នេះឈ្មោះថា **ជាប់ជំពាក់ក្នុងសត្វជារបស់ខ្លួន** ។ ចំណែកបុគ្គលណាប្រកាន់ចីវរ បាត្រ ភាជនៈ និងឈើច្រត់ជាដើមថា ជារបស់យើង សូម្បីអ្នកដទៃនឹងយកដៃស្ទាបអង្អែល ក៏មិនព្រមឲ្យ គេខ្ចីមួយរយៈក៏និយាយថា សូម្បីយើងជាម្ចាស់របស់វត្ថុនេះ ក៏មិនទាន់បានប្រើ យើងនឹងឲ្យពួកលោកបានដូចម្តេច នេះឈ្មោះថា **ជាប់ជំពាក់ក្នុងសង្ខារជាជារបស់ខ្លួន** ។

ចំណែកបុគ្គលណាដាក់ខ្លួនជាកណ្តាល ជាអ្នកព្រងើយក្នុងវត្ថុសូម្បីទាំងពីរ

ពួកនោះ បុគ្គលនេះឈ្មោះថា **ដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ** ។ ឧបេក្ខាសម្ពោជ្ឈង្គៈនេះ រមែងកើតឡើង សូម្បីដល់អ្នកវៀរចាកបុគ្គលដែលប្រកាន់សត្វ និងសង្ខារយ៉ាងនេះ ។ សូម្បីដល់អ្នកសេពគប់បុគ្គលដែលដាក់ខ្លួនជាកណ្តាលក្នុងសត្វ និងសង្ខារ សូម្បីដល់បុគ្គលមានចិត្តបង្អោនទៅដើម្បីឲ្យឧបេក្ខាសម្ពោជ្ឈង្គៈនោះកើតឡើងក្នុងការឈរ និងការអង្គុយជាដើម ដោយប្រការដូច្នេះ ។ ព្រោះដូច្នោះ កុលបុត្រអ្នកផ្តើមបំពេញកម្មដ្ឋាន ធ្វើឧបេក្ខាសម្ពោជ្ឈង្គៈឲ្យកើតឡើងដោយហេតុ ៥ ប្រការទាំងនេះ ធ្វើឧបេក្ខាសម្ពោជ្ឈង្គៈនោះឯងឲ្យជាធុរៈ តម្កល់ទុកឲ្យមាំទាំ រមែងកាន់យកព្រះអរហត្តបានដោយលំដាប់ ។ កុលបុត្រនោះ ឈ្មោះថា ចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈដរាបដល់អរហត្តមគ្គ កាលសម្រេចផលហើយ រមែងឈ្មោះថា បានចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈហើយ ។ សម្ពោជ្ឈង្គៈទាំង ៧ នេះទ្រង់ត្រាស់លាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ដោយប្រការដូច្នេះ ។

បទថា **សម្មាទិដ្ឋឹ ភាវេតិ** (ចម្រើនសម្មាទិដ្ឋិ) សេចក្តីថា រមែងកពូន គឺចម្រើនឡើងនូវសម្មាទិដ្ឋិដែលជាខាងដើមនៃមគ្គមានអង្គ ៨ ។ ក្នុងបទដ៏សេសក៏មានន័យនេះនុ៎ះឯង ។ ក៏ក្នុងប្រការពោលដោយមគ្គមានអង្គ ៨ នេះ **សម្មាទិដ្ឋិ** មានសេចក្តីឃើញត្រូវជាលក្ខណៈ ។ **សម្មាសង្កប្បៈ** មានការលើកឡើងនូវចិត្តដោយប្រពៃជាលក្ខណៈ ។ **សម្មាវាចា** មានការកាន់យកត្រូវជាលក្ខណៈ ។ **សម្មា-**

**កម្មន្តៈ** មានការតាំងឡើងនូវការងារត្រូវជាលក្ខណៈ ។ **សម្មាអាជីវៈ** មានការធ្វើអាជីវៈឲ្យបរិសុទ្ធិដោយប្រពៃជាលក្ខណៈ ។ **សម្មាវាយាមៈ** មានការផ្គងទុកត្រូវជាលក្ខណៈ ។ **សម្មាសតិ** មានការប្រាកដឡើងត្រូវជាលក្ខណៈ ។ **សម្មាសមាធិ** មានការតាំងចិត្តត្រូវជាលក្ខណៈ ។

ក្នុងមគ្គមានអង្គ ៨ នោះ មគ្គមួយៗ មានកិច្ច ៣ យ៉ាង គឺ សម្មាទិដ្ឋិលះមិច្ឆាទិដ្ឋិព្រមទាំងកិលេសដែលជាសត្រូវរបស់ខ្លួនសូម្បីយ៉ាងដទៃៗ ធ្វើនិរោធឲ្យជាអារម្មណ៍ ឃើញសម្បយុត្តធម៌ព្រោះមិនវង្វេង ដោយអំណាចការកម្ចាត់មោហៈដែលបិទបាំងសម្មាទិដ្ឋិនោះ ។ សូម្បីសម្មាសង្កប្បៈជាដើមក៏ដូចគ្នា លះបង់មិច្ឆាសង្កប្បៈជាដើម និងធ្វើនិរោធឲ្យជាអារម្មណ៍ ។

ដោយចំពោះដ៏យ៉ាងក្រៃលែង ក្នុងមគ្គនេះ សម្មាសង្កប្បៈត្រិះរិះដល់សហជាតធម៌ សម្មាវាចាកំណត់កាន់យកត្រូវ សម្មាកម្មន្តៈតាំងឡើងនូវការងារត្រូវ សម្មាអាជីវៈធ្វើអាជីវៈឲ្យបរិសុទ្ធិដោយប្រពៃ សម្មាវាយាមៈផ្គងទុកប្រពៃ សម្មាសតិប្រាកដឡើងប្រពៃ សម្មាសមាធិតាំងចិត្តប្រពៃ ។

ប្រការមួយទៀត ធម្មតាថា សម្មាទិដ្ឋិនេះ ក្នុងខាងដើមមានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា (តែ) ក្នុងខណៈមគ្គ មានខណៈតែមួយ មានអារម្មណ៍តែមួយ ។ តែកាលពោលអំពីកិច្ច បានឈ្មោះ ៤ យ៉ាង មាន **ទុក្ខេ ញាណំ** (ដឹង

ក្នុងទុក្ខ) ដូច្នេះជាដើម ។ សូម្បីសម្មាសង្កប្បៈជាដើម ក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នាក្នុងខាងដើម តែក្នុងខណៈមគ្គ មានខណៈតែមួយ និងមានអារម្មណ៍តែមួយ ។ ក្នុងមគ្គទាំងនោះ សម្មាសង្កប្បៈ កាលពោលដោយកិច្ច បាន ឈ្មោះ ៣ យ៉ាង ឈ្មោះថា នេក្ខម្មសង្កប្បៈជាដើម ។ អង្គមគ្គ ៣ មានសម្មាវាចាជាដើម ក្នុងខាងដើមមានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា គឺ ជាវិរតិខ្លះ ជាចេតនាខ្លះ តែក្នុងខណៈមគ្គ ជាវិរតិប៉ុណ្ណោះ ។ សូម្បីអង្គមគ្គទាំងពីរនេះ គឺ សម្មាវាយាមៈ សម្មាសតិ កាលពោលដោយកិច្ច បានឈ្មោះ ៤ យ៉ាង ដោយអំណាចសម្មប្បធាន ៤ និងសតិប្បដ្ឋាន ៤ ។ ចំណែកសម្មាសមាធិ ក៏ជាសម្មាសមាធិតែម្យ៉ាង ទាំងក្នុងខាងដើមទាំងក្នុងខណៈមគ្គ ។

ក្នុងធម៌ ៨ ប្រការនេះ ដូចពណ៌នាមកនេះ ព្រះដ៏មានព្រះភាគទ្រង់សំដែងសម្មាទិដ្ឋិមុន ព្រោះជាឧបការៈដល់ព្រះយោគីអ្នកបដិបត្តិដើម្បីសម្រេចព្រះនិព្វាន ។ ក៏សម្មាទិដ្ឋិនេះ ប្រព្រឹត្តទៅដោយឈ្មោះថា **បញ្ញាបជ្ជោតោ បញ្ញាសត្ថំ** (ពន្លឺ គឺ បញ្ញា សស្ត្រា គឺ បញ្ញា) ដូច្នេះ ។ ព្រោះហេតុនោះ ព្រះយោគាវចរកម្ចាត់ងងឹត គឺ អវិជ្ជា ដោយសម្មាទិដ្ឋិ គឺ វិបស្សនាញាណនេះក្នុងខាងដើម សម្លាប់ចោរ គឺ កិលេសចេញ រមែងសម្រេចព្រះនិព្វានដោយសេចក្ដីក្សេម ។ ព្រោះហេតុនោះ លោកទើបពោលថា ៖

និព្វានាធិគមាយ បដិបន្នស្ស យោគិនោ

ពហុការត្តា បឋមំ សម្មាទិដ្ឋិ ទេសិតា ។

ព្រះមានព្រះភាគទ្រង់សម្តែងសម្មាទិដ្ឋិមុន ព្រោះជាធម៌

មានឧបការៈច្រើនដល់ព្រះយោគីដែលបដិបត្តិដើម្បី

សម្រេចព្រះនិព្វាន ។

ក៏សម្មាសង្កប្បៈ មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ ព្រោះដូច្នោះទើបត្រាស់ទុកក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ ។ ដូចជា ហិរញ្ញិកប្រើដៃត្រឡប់ទៅត្រឡប់មកមើល ហិរញ្ញិករមែងដឹងថា នេះជារបស់ថ្លុម នេះជារបស់ពិត យ៉ាងណា សូម្បីព្រះយោគាវចរក៏ដូច្នោះ ក្នុងខាងដើម ញ៉ាំងវិតក្កឲ្យត្រិះរិះទៅមក និងញ៉ាំងវិបស្សនាបញ្ញាពិចារណា រមែងដឹងថា ធម៌ទាំងនេះជាកាមាវចរៈ ធម៌ទាំងនេះជារូបាវចរៈជាដើម និងដូចជាជាងចាំង យកពូថៅចាំងឈើធំដែលបុរសចាប់ចុងត្រឡប់ទៅមកឲ្យ រមែងនាំទៅប្រើការងារបាន យ៉ាងណា ព្រះយោគាវចរពិចារណាធម៌ដែលវិតក្កៈត្រិះរិះឲ្យដោយបញ្ញា ដោយន័យមានជាដើមថា ធម៌ពួកនេះជាកាមាវចរៈ ធម៌ទាំងនេះជារូបាវចរៈ រមែងសម្រេចកិច្ចការងារបាន ដូច្នោះ ព្រោះហេតុនោះ លោកទើបពោលថា ក៏សម្មាសង្កប្បៈ មានឧបការៈមកដល់សម្មាទិដ្ឋិនោះ ព្រោះដូច្នោះ ទើបត្រាស់ទុកក្នុងលំដាប់នៃសម្មាទិដ្ឋិនោះ ដូច្នេះ ។

សម្មាសង្កប្បៈនេះ មានឧបការៈដល់សម្មាវាចា ក៏ដូចជាមានឧបការៈដល់សម្មាទិដ្ឋិដូច្នោះ សមដូចដែលត្រាស់ទុកថា "ម្នាលគហបតី បុគ្គលត្រិះរិះហើយពិចារណាហើយក្នុងខាងដើមមុនឯង ទើបថ្លែងវាចា" ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់សម្មាវាចាទុកក្នុងលំដាប់នៃសម្មាសង្កប្បៈនោះ ។

ក៏ព្រោះហេតុដែលបុគ្គលទឹងត្រូវចាត់ចែងដោយវាចាមុនថា យើងទឹងធ្វើវត្ថុនេះ និងវត្ថុនេះ ដូច្នេះហើយ ទើបប្រកបការងារក្នុងលោក ព្រោះដូច្នោះ ទើបត្រាស់សម្មាកម្មន្តៈទុកក្នុងលំដាប់សម្មាវាចា ព្រោះវាចាមានឧបការៈដល់ការងារ ។

ក៏ព្រោះហេតុដែលសីល មានអាជីវៈជាទី ៨ រមែងបរិបូណ៌ដល់បុគ្គលលះវចីទុច្ចរិត ៤ និងកាយទុច្ចរិត ៣ ហើយធ្វើវចីសុចរិត និងកាយសុចរិតទាំងពីរយ៉ាងឲ្យបរិបូណ៌ មិនបរិបូណ៌សម្រាប់បុគ្គលក្រៅពីនេះ ព្រោះដូច្នោះ ទើបត្រាស់សម្មាអាជីវៈទុកក្នុងលំដាប់នៃសម្មាវាចា និងសម្មាកម្មន្តៈទាំងពីរនោះ ។

ដើម្បីសម្តែងថា បើបុគ្គលដែលមានអាជីវៈបរិសុទ្ធិយ៉ាងនេះ ធ្វើសេចក្តីត្រេកអររីករាយ ដោយហេតុត្រឹមតែប៉ុណ្ណេះថា អាជីវៈរបស់យើងបរិសុទ្ធិ ហើយជាអ្នកប្រមាទដូចជាអ្នកដេកលក់ មិនគួរ ដោយពិត គប្បីប្រារព្ធសេចក្តីព្យាយាមគ្រប់ៗ ឥរិយាបថ ទើបត្រាស់សម្មាវាយាមៈទុកក្នុងលំដាប់នៃសម្មាអាជីវៈនោះ ។ តពីនោះ ដើម្បីទឹងសម្តែងថា សូម្បីប្រារព្ធសេចក្តីព្យាយាមហើយ ក៏គួរធ្វើសតិឲ្យ

តាំងមាំក្នុងវត្ថុទាំង ៤ មានកាយជាដើម ទើបទ្រង់សម្តែងសម្មាសតិទុកក្នុងលំដាប់នៃសម្មាវាយាមៈ ។

ក៏ព្រោះហេតុដែលសតិតាំងមាំយ៉ាងនេះហើយ ធ្វើទុកក្នុងចិត្តដោយល្អដល់គតិធម៌ទាំងឡាយដែលមានការឧបការៈ និងមិនមានឧបការៈដល់សមាធិ រមែងអាចធ្វើចិត្តឲ្យតម្កល់មាំក្នុងឯកគ្គតារម្មណ៍ ព្រោះដូច្នោះ គប្បីជ្រាបថា ទ្រង់សម្តែងសម្មាសមាធិទុកក្នុងលំដាប់នៃសម្មាសតិនោះឯង ។ ដូច្នោះ ទើបត្រាស់មគ្គដែលប្រកបដោយអង្គ ៨ នេះ លាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

[២១០] ក្នុងបទថា **អជ្ឈត្តំ រូបសញ្ញី** (បុគ្គលមានសេចក្តីសម្គាល់ គឺបរិកម្មនូវរូបខាងក្នុង) ដូច្នេះជាដើម ភិក្ខុឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ គឺដឹងរូបខាងក្នុង រមែង (បរិកម្ម គឺ ពិចារណារឿយៗ) ត្រង់សក់ ត្រង់ប្រមាត់ ឬត្រង់គ្រាប់ភ្នែក ។ ក៏កាលបរិកម្មរូបពណ៌លឿង រមែងបរិកម្មត្រង់ខ្លាញ់ខាប់ ត្រង់សម្បុរស្បែក ត្រង់បាតដៃបាតជើង ឬត្រង់គ្រាប់ភ្នែកដែលមានពណ៌លឿង ។ កាលបរិកម្មរូបពណ៌ក្រហម រមែងបរិកម្មត្រង់សាច់ ត្រង់ឈាម ត្រង់អណ្តាត ឬត្រង់គ្រាប់ភ្នែកដែលមានពណ៌ក្រហម ។ កាលបរិកម្មរូបពណ៌ស រមែងបរិកម្មត្រង់ឆ្អឹង ត្រង់ធ្មេញ ត្រង់ក្រចក ឬត្រង់គ្រាប់ភ្នែកដែលមានពណ៌ស ។ ក៏រូបពណ៌ខៀវជាដើមនោះ មិនជាពណ៌ខៀវពិត មិនលឿងពិត មិនក្រហមពិត មិនសពិត

ជាពណ៌មិនបរិសុទ្ធិឡើយ ។

បទថា **ពហិទ្ធា រូបានិ បស្សតិ** (ឃើញរូបខាងក្រៅ) សេចក្តីថា បរិកម្មយ៉ាងនេះរបស់ភិក្ខុណាកើតឡើងខាងក្នុង និមិត្តកើតឡើងខាងក្រៅ ភិក្ខុនោះ ហៅថា មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញរូបខាងក្រៅ ដោយអំណាចបរិ-កម្មរូបខាងក្នុង និងឲ្យរូបខាងក្រៅដល់អប្បនា ។ បទថា **បរិត្តានិ** (តូច) បានដល់ នៅមិនទាន់ចម្រើន ។ បទថា **សុវណ្ណទុព្វណ្ណានិ** (មានសម្បុរល្អ ឬសម្បុរអាក្រក់) សេចក្តីថា ទោះបីជារូបមានសម្បុរល្អ ឬសម្បុរអាក្រក់ក៏ដោយចុះ គប្បីជ្រាបថា លោកពោលអភិកាយនៈនេះ ដោយអំណាចរូបដែលជាបរិត្តារម្មណ៍ប៉ុណ្ណោះ ។

បទថា **តានិ អភិភុយ្យ** (គ្របសង្កត់រូបទាំងនោះបានហើយ) សេចក្តីថា បុរសដែលមានភ្លើងធាតុល្អ បានភត្តាហារប្រមាណមួយវែក គិតថា មានអ្វីដែលយើងនឹងគប្បីបរិភោគបានក្នុងភត្តាហារនេះ ទើបរួមធ្វើឲ្យជាដុំពំនូតតែមួយ យ៉ាងណា បុគ្គលដែលមានញាណដ៏ក្រៃលែង មានញាណចាស់ក្លាក៏ដូច្នោះ ពិចារណាថា មានអ្វីដែលយើងនឹងគប្បីចូលឈានក្នុងបរិត្តារម្មណ៍នេះ យ៉ាងនេះ មិនជារឿងធ្ងន់សម្រាប់យើង ទើបគ្របសង្កត់រូបទាំងនោះ ចូលឈាន អធិប្បាយថា ឲ្យដល់អប្បនាក្នុងរូបនោះព្រមទាំងធ្វើនិមិត្តឲ្យកើតឡើងនោះឯង ។ ក៏ដោយបទថា **ជានាមិ បស្សាមិ** (យើងដឹង យើងឃើញ) នេះ ទ្រង់ត្រាស់ដល់សេចក្តីពឹងរបស់ភិក្ខុនោះ ។

ក៏សេចក្ដីរពឹងដល់នោះឯង រមែងមានដល់ភិក្ខុដែលចេញចាកសមាបត្តិ មិនមែនមានក្នុងខាងក្នុងសមាបត្តិ ។

បទថា **ឯវំ សញ្ញី ហោតិ** (មានសេចក្ដីសម្គាល់ដូច្នេះ) សេចក្ដីថា រមែងមានសេចក្ដីសម្គាល់យ៉ាងនេះ ដោយសេចក្ដីសម្គាល់ក្នុងការរំពឹងដល់ខ្លះ ដោយសេចក្ដីសម្គាល់ក្នុងឈានខ្លះ ។ ក៏សេចក្ដីសម្គាល់ក្នុងការគ្របសង្កត់ (រូប) រមែងមានដល់ភិក្ខុនោះ សូម្បីក្នុងខាងក្នុងសមាបត្តិ តែសេចក្ដីសម្គាល់ក្នុងការរពឹងដល់រមែងមានដល់ភិក្ខុដែលចេញចាកសមាបត្តិហើយប៉ុណ្ណោះ ។

[២១១-២១២] បទថា **អប្បមាណានិ** (មិនមានប្រមាណ) សេចក្ដីថា ពង្រីកឡើង គឺ ធំឡើង ។ ក៏ក្នុងបទថា **អភិភុយ្យ** (គ្របសង្កត់) នេះ មានសេចក្ដីថា ដូចបុរសដែលបរិភោគ បានបរិភោគភត្តាហារបន្ថែមទៀត ហើយក៏គិតថា សូម្បីភត្តាហារដទៃក៏ដោយចុះ ភត្តាហារនោះនឹងធ្វើអ្វីយើង រមែងមិនឃើញភត្តាហារដែលបានបន្ថែមនោះថា ជារបស់ច្រើន យ៉ាងណា បុគ្គលដែលមានញាណដ៏ក្រៃលែងមាន ញាណចាស់ក្លា ក៏ដូច្នោះ ឃើញថា យើងនឹងគប្បីចូលឈានអ្វីក្នុងរូបនេះ រូបនេះ មានប្រមាណច្រើនក៏មិនមែន យើងមិនជូនចិត្តក្នុងការធ្វើចិត្តឲ្យតម្កល់មាំ (ជាមួយ រូបនេះ) ដូច្នេះ គ្របសង្កត់រូបទាំងនោះចេញហើយ ចូលសមាបត្តិ គឺធ្វើឲ្យដល់ អប្បនា ព្រមទាំងធ្វើនិមិត្តឲ្យកើតឡើងនោះឯង ។

[២១៣] បទថា **អជ្ឈត្តំ អរូបសញ្ញី** (បុគ្គលមិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុង) សេចក្តីថា បុគ្គលពួកមួយវៀរចាកបរិកម្មសញ្ញាក្នុងរូបជាខាងក្នុងចេញព្រោះមិនបាន ឬព្រោះមិនត្រូវការ ។ បទថា **ពហិទ្ធា រូបានិ បស្សតិ** (ឃើញរូបខាងក្រៅ) សេចក្តីថា បរិកម្មក្តី និមិត្តក្តី របស់ភិក្ខុណាកើតឡើងក្នុងចំណែកខាងក្រៅ ភិក្ខុនោះ លោកហៅថា បុគ្គលពួកមួយ មានសេចក្តីសម្គាល់រូបក្នុងខាងក្នុងឃើញរូបក្នុងខាងក្រៅ ។ ពាក្យដ៏សេសក្នុងសូត្រនេះ មានន័យដូចពោលទុកក្នុងអភិភាយតនៈទី ៤ នោះឯង ។ ក៏បណ្តារូបទាំង ៤ នេះ រូបដែលជាបរិត្តារម្មណ៍ មកដោយអំណាចវិតក្កចរិត ។ រូបច្រើនមិនមានប្រមាណ មកដោយអំណាចមោហចរិត ។ រូបមានវណ្ណល្អ មកដោយអំណាចទោសចរិត ។ រូបមានវណ្ណៈអាក្រក់ មកដោយអំណាចរាគចរិត ។ ព្រោះរូបទាំងនេះ ជាសប្បាយរបស់ចរិតទាំងនេះ ។ ក៏រូបទាំងនោះជាសប្បាយ បានពោលទុកពិស្តារហើយក្នុងចរិយនិទ្ទេសក្នុងវិសុទ្ធិមគ្គនោះ ។

ក្នុងអភិភាយតនៈទី ៥ ជាដើម គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ៖

[២១៤-២១៦] បទថា **នីលានិ** (ខៀវ) ពោលជាប់ដោយការកាន់យកទាំងអស់ ។ បទថា **នីលវណ្ណានិ** (មានពណ៌ខៀវ) ពោលទាក់ទងដោយពណ៌ ។ បទថា **នីលនិទស្សនានិ** (ប្រៀបជាមួយរបស់ពណ៌ខៀវ) ពោលទាក់ទងដោយឃើញពណ៌ខៀវ អធិប្បាយថា ពណ៌មិនលាយឡំគ្នា ពណ៌ប្រាកដច្បាស់ ។ ឃើញជាពណ៌ខៀវតែ

មួយពណ៌ប៉ុណ្ណោះ ។ ក៏បទថា **នីលនិភាសានិ** (មានពន្លឺខៀវ) ពោលជាប់ដោយពន្លឺ អធិប្បាយថា ប្រកបដោយពន្លឺពណ៌ខៀវ ។ ទ្រង់ត្រាស់ថា អភិភាយតនៈទាំងនោះបរិសុទ្ធិ ដោយបទថា **នីលនិភាសានិ** នេះ ។ ក៏ទ្រង់ត្រាស់អភិភាយតនៈទាំងនេះ ដោយពណ៌បរិសុទ្ធិប៉ុណ្ណោះ ។ ក៏ក្នុងអធិការដែលពោលដោយអភិភាយតនៈនេះ ការធ្វើកសិណ ការបរិកម្ម និងវិធីដល់អប្បនា មានជាអាទិថា កាលកាន់យកនីលកសិណ រមែងកាន់យកនិមិត្តក្នុងផ្កាឈើ សំពត់ ឬវណ្ណធាតុដែលមានពណ៌ខៀវ ដូច្នេះ ទាំងអស់បានពោលទុកហើយដោយពិស្តារក្នុងវិសុទ្ធិមគ្គ ។ ក៏អភិភាយតនឈានទាំង ៨ ប្រការនេះ ជាវដ្តៈខ្លះ ជាបាទរបស់វដ្តៈខ្លះ ជាបាទរបស់វិបស្សនាខ្លះ ធម៌ជាគ្រឿងនៅជាសុខក្នុងទិដ្ឋធម៌ខ្លះ ជាបាទរបស់អភិញ្ញាខ្លះ ជាបាទនៃនិរោធខ្លះ តែគប្បីជ្រាបថា ជាលោកិយៈប៉ុណ្ណោះ មិនមែនជាលោកុត្តរៈ ។

[២១៧] ក្នុងបទថា **រូបី រូបានិ បស្សតិ** (បុគ្គលមានរូបរមែងឃើញរូបទាំងឡាយ) នេះ រូបឈាន ដែលកើតដោយអំណាចនីលកសិណជាដើម ត្រង់សក់ជាដើមក្នុងខាងក្នុង ឈ្មោះថា រូប ។ ឈ្មោះថា **រូបី** ព្រោះអត្ថថា គេមានរូបឈាននោះ ។ បទថា **ពហិទ្ធា រូបានិ បស្សតិ** (ឃើញរូបខាងក្រៅ) សេចក្តីថា រមែងឃើញរូប មាននីលកសិណជាដើមខាងក្រៅ ដោយឈានចក្ខុ ។ ដោយបទនេះ ទ្រង់សម្តែងរូបាវចរឈានសួម្បីទាំង ៤ របស់បុគ្គលដែលញ៉ាំងឈានឲ្យកើតក្នុង

កសិណដែលជាវត្ថុខាងក្នុង និងខាងក្រៅ ។

[២១៨] បទថា *អជ្ឈត្តំ អរូបសញ្ញី* (បុគ្គលមិនមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុង) សេចក្តីថា មិនមានសេចក្តីសម្គាល់រូបខាងក្នុង គឺ រូបាវចរឈានដែលមិនកើតក្នុងសក់ជាដើមរបស់ខ្លួន ។ ដោយបទនេះ ទ្រង់សម្តែងរូបាវចរឈានរបស់បុគ្គលដែលបរិកម្ម (កសិណ) ក្នុងខាងក្រៅ ហើយធ្វើឈានឲ្យកើត (ត្រង់កសិណ) ក្នុងខាងក្រៅនុ៎ះឯង ។

ដោយបទថា *សុភន្តេវ អធិមុត្តោ ហោតិ* (ជាអ្នកបង្អោនចិត្តទៅថាស្អាតប៉ុណ្ណោះ) នេះ ទ្រង់សម្តែងឈានក្នុងវណ្ណកសិណ មាននីលកសិណជាដើមដែលបរិសុទ្ធិ ។ ក្នុងឈានទាំងនោះ សេចក្តីរំពឹងថា ស្អាត រមែងមិនមានក្នុងខាងក្នុងអប្បនាក៏ពិត តែ ភិក្ខុណាធ្វើសេចក្តីស្អាត ដែលបរិសុទ្ធិល្អឲ្យជាអារម្មណ៍របស់កសិណហើយ ព្រោះហេតុដែលភិក្ខុនោះពាល់ត្រូវ ហៅថា ជាអ្នកបង្អោនចិត្តទៅថា ស្អាត ព្រោះដូច្នោះ ទើបត្រាស់ទេសនាយ៉ាងនោះ ។ ក៏ក្នុងបដិសម្ភិទាមគ្គព្រះសារីបុត្រពោលទុកថា ឈ្មោះថា វិមោក្ខ ព្រោះជាអ្នកបង្អោនចិត្តទៅថា ស្អាតដូចម្តេច ។ ភិក្ខុក្នុងព្រះសាសនានេះ មានចិត្តសហគតដោយមេត្តា ផ្សាយទៅរហូតទិសមួយ ។ល។ ព្រោះជាអ្នកចម្រើនមេត្តា សត្វទាំងឡាយទើបជាអ្នកមិនគួរស្អប់ខ្ពើម ។ មានចិត្តសហគតដោយករុណា មុទិតា ឧបេក្ខាផ្សាយទៅរហូតទិស

មួយ ។ល។ ព្រោះជាអ្នកចម្រើនដោយករុណា មុទិតា ឧបេក្ខា សត្វទាំងឡាយ ទើបជាអ្នកមិនគួរវង្វៀស ឈ្មោះថា វិមោក្ខ ព្រោះអត្ថថា ជាអ្នកបង្អោនចិត្តថា ស្អាត យ៉ាងនេះ ដោយប្រការដូចពោលមកនេះ ។

[២១៩] ពាក្យណាដែលនឹងគប្បីពោល ក្នុងបទថា **សព្វសោ រូបសញ្ញានំ** (កន្លងរូបសញ្ញាដោយប្រការទាំងពួង) ជាដើម ពាក្យទាំងអស់នោះ បានពោលទុកហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

ក៏ក្នុងបទថា **បឋវីកសិណំ ភាវេតិ** (ចម្រើនបឋវីកសិណ) នេះ ដែលឈ្មោះថា កសិណ ព្រោះអត្ថថា ទាំងអស់ ។ បទថា **បឋវីកសិណំ ភាវេតិ** នេះ ជាឈ្មោះរបស់កសិណ មានបឋវីជាអារម្មណ៍ក៏មាន របស់បរិកម្មថា បឋវីក៏មាន របស់ឧគ្គហនិមិត្តក៏មាន របស់បដិភាគនិមិត្តក៏មាន របស់ឈានដែលធ្វើនិមិត្តនោះឲ្យជាអារម្មណ៍កើតឡើងក៏មាន ។ តែក្នុងទីនេះ លោកបំណងយកឈានដែលមានបឋវីកសិណជាអារម្មណ៍ ។ ភិក្ខុនោះ ចម្រើនបឋវីកសិណនោះ ។

សូម្បីក្នុងអាបោកសិណជាដើម ក៏មានន័យនេះដូចគ្នា ។ ក៏ភិក្ខុកាលនឹងចម្រើនកសិណទាំងនេះ ជម្រះសីលហើយ តាំងនៅក្នុងសីលដែលបរិសុទ្ធិ កាត់បណ្តាបលិពោធ (សេចក្តីកង្វល់) ១០ ប្រការ ដែលមានហើយចេញ ហើយចូលទៅរកកល្យាណមិត្តអ្នកឲ្យកម្មដ្ឋាន រៀនយកកម្មដ្ឋានដែលសប្បាយ ដែលចម្រើន

ដល់ចរិតរបស់ខ្លួន ហើយលះទីនៅដែលមិនសមគួរដល់ការបំពេញកសិណ នៅក្នុងទីនៅដែលសមគួរ កាត់សេចក្តីកង្វល់តូចៗ កុំធ្វើការនៅវិធីគ្រប់យ៉ាងឲ្យវិនាស គប្បីចម្រើនចុះ ។ នេះជាសេចក្តីសង្ខេបក្នុងសូត្រនេះ ចំណែកសេចក្តីពិស្តារបានពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

[២២០-២២៣] ក៏វិញ្ញាណកសិណ មកក្នុងវិសុទ្ធិមគ្គនោះទាំងអស់ វិញ្ញាណ-កសិណនោះ ដោយអត្ថ ក៏គឺ វិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសកសិណ ។ ក៏វិញ្ញាណនោះឯង លោកពោលដោយជាអារម្មណ៍ មិនមែនពោលដោយជាសមា-បត្តិ ។ ក៏ភិក្ខុនេះ ធ្វើវិញ្ញាណកសិណនោះឲ្យជាវិញ្ញាណមិនមានទីបំផុត ហើយចម្រើនវិញ្ញាណញ្ចាយតនៈសមាបត្តិ ហៅថា ចម្រើនវិញ្ញាណកសិណ ។ កសិណ ១០ សូម្បីនេះ ជាវដ្តៈខ្លះ ជាបាទរបស់វដ្តៈខ្លះ ជាបាទរបស់វិបស្សនាខ្លះ ជាប្រយោជន៍ដល់ការនៅជាសុខក្នុងបច្ចុប្បន្នខ្លះ ជាបាទរបស់អភិញ្ញាខ្លះ ជាបាទរបស់និរោធខ្លះ តែជាលោកិយៈប៉ុណ្ណោះ មិនមែនជាលោកុត្តរៈ ។

[២២៤] បទថា *អសុភសញ្ញំ ភាវេតិ* (ចម្រើនអសុភសញ្ញា) សេចក្តីថា សញ្ញាដែលសហគតដោយបឋមឈានដែលកើតក្នុងអារម្មណ៍ ១០ មានសាកសពដែលហើមប៉ោងជាដើម ហៅថា អសុភសញ្ញា ។ អប់រំ គឺ កពូន ចម្រើនអសុភ-សញ្ញានោះ អធិប្បាយថា ធ្វើអសុភសញ្ញាដែលនៅមិនទាន់កើតឡើង តាមវក្យាអសុ-

កសញ្ញា ដែលកើតឡើងហើយទុក ។ ក៏ផ្លូវនៃការចម្រើនអសុភ ១០ ទាំងអស់ បានពោលទុកពិស្តារហើយក្នុងវិសុទ្ធិមគ្គ ។

បទថា **មរណសញ្ញំ ភាវេតិ** (ចម្រើនមរណសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលធ្វើមរណៈទាំង ៣ គឺ សម្មុតិមរណៈ ខណិកមរណៈ សមុច្ឆេទមរណៈ ឲ្យជាអារម្មណ៍កើតឡើង អធិប្បាយថា ធ្វើសញ្ញាដែលនៅមិនទាន់កើត ឲ្យកើតឡើង តាមរក្សាសញ្ញាដែលកើតឡើងហើយទុក ។ មរណស្សតិ ដែលមានលក្ខណៈដូចពោលទុកក្នុងខាងក្រោយនុ៎ះឯង ហៅថា មរណសញ្ញាក្នុងទីនេះ ។ អធិប្បាយថា ចម្រើនមរណសញ្ញានោះ ធ្វើឲ្យកើតឡើង ឲ្យចម្រើនឡើង ។ ក៏ន័យនៃការចម្រើនមរណសញ្ញានោះ ពោលទុកពិស្តារហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

បទថា **អាហារេ បដិកូលសញ្ញំ ភាវេតិ** (ចម្រើនអាហារេបដិកូលសញ្ញា) សេចក្តីថា រមែងចម្រើនសញ្ញាដែលកើតឡើងដល់ភិក្ខុដែលពិចារណាភាពបដិកូល ៩ យ៉ាង មានបដិកូលដោយការទៅជាដើម ក្នុងកវឡិង្ការាហារដែលបរិភោគ និងផឹកជាដើម អធិប្បាយថា ធ្វើឲ្យកើតឡើង ចម្រើនឡើង ។ ន័យនៃការចម្រើនអាហារេបដិកូលសញ្ញានោះ ពោលទុកពិស្តារហើយក្នុងវិសុទ្ធិមគ្គនុ៎ះឯង ។

បទថា **សព្វលោកេ អនភិរតសញ្ញំ ភាវេតិ** (ចម្រើនសព្វលោកេអនភិរតសញ្ញា) សេចក្តីថា ចម្រើនអនភិរតសញ្ញា (សេចក្តីសម្គាល់ថាមិនគួរត្រេកអរ)

គឺ **ឧក្កណ្ឋិតសញ្ញា** (សេចក្តីសម្គាល់ថាមិនគួរពេញចិត្ត) ក្នុងត្រៃលោកធាតុទាំងអស់ ។ បទថា **អនិច្ចសញ្ញំ ភាវេតិ** (ចម្រើនអនិច្ចសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលកើតឡើងក្នុងខន្ធ ៥ ថាមិនទៀង កំណត់ពិចារណាការកើតឡើង ការវិនាសទៅ និងសេចក្តីប្រែប្រួលនៃឧបាទានក្ខន្ធ ៥ ។ បទថា **អនិច្ចេ ទុក្ខសញ្ញំ ភាវេតិ** (ចម្រើនអនិច្ចេទុក្ខសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលកើតឡើងថាជាទុក្ខ កំណត់ពិចារណាទុក្ខលក្ខណៈ ពោលគឺ សេចក្តីបៀតបៀនក្នុងខន្ធបញ្ចកៈដែលមិនទៀង ។

បទថា **ទុក្ខេ អនត្តសញ្ញំ ភាវេតិ** (ចម្រើនទុក្ខេអនត្តសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលកើតឡើងថា ជាអនត្តា ដែលកំណត់ពិចារណាអនត្តលក្ខណៈ ពោលគឺ អាការដែលមិននៅក្នុងអំណាច ក្នុងខន្ធបញ្ចកៈដែលជាទុក្ខ ព្រោះអត្ថថាបៀតបៀន ។ បទថា **បហានសញ្ញំ ភាវេតិ** (ចម្រើនបហានសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលបហានៈ ៥ យ៉ាង ឲ្យជាអារម្មណ៍កើតឡើង ។ បទថា **វិរាគសញ្ញំ ភាវេតិ** (ចម្រើនវិរាគសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលធ្វើវិរាគៈ ៥ យ៉ាងនោះឯង ឲ្យជាអារម្មណ៍កើតឡើង ។

បទថា **និរោធសញ្ញំ ភាវេតិ** (ចម្រើននិរោធសញ្ញា) សេចក្តីថា ចម្រើនសញ្ញាដែលធ្វើសង្ខារនិរោធឲ្យជាអារម្មណ៍កើតឡើង ។ អាចារ្យខ្លះពោលថា សញ្ញា

ដែលធ្វើព្រះនិព្វានឲ្យជាអារម្មណ៍កើតឡើង ដូច្នេះក៏មាន ។ ក៏ក្នុងបទថា **និរោធ-សញ្ញំ ភាវេតិ** នេះ លោកពោលដល់វិបស្សនាដែលចាស់ក្លា ដោយសញ្ញាទាំង ៣ នេះ គឺ សព្វលោកេអនភិរតសញ្ញា ១ អនិច្ចសញ្ញា ១ អនិច្ចេទុក្ខសញ្ញា ១ ។ លោកពោលដដែលព្រោះការប្រារព្ធវិបស្សនា ដោយសញ្ញា ១០ ប្រការ មានពាក្យថា **អនិច្ចសញ្ញំ ភាវេតិ** ដូច្នេះជាដើម ។ បទថា **ពុទ្ធានុស្សតិ** ជាដើម បានពោលអធិប្បាយសេចក្តីទុកហើយ ។

បទថា **បឋមជ្ឈានសហគតំ** (សហគតដោយបឋមជ្ឈាន) សេចក្តីថា ទៅ គឺ ប្រព្រឹត្តទៅព្រមជាមួយបឋមជ្ឈាន អធិប្បាយថា សម្បយុត្តដោយបឋមជ្ឈាន ។ បទថា **សទ្ធិន្ទ្រិយំ ភាវេតិ** (ចម្រើនសទ្ធិន្ទ្រិយ) សេចក្តីថា ចម្រើនសទ្ធិន្ទ្រិយឲ្យសហគតដោយបឋមជ្ឈាន គឺ អប់រំ កពូនឲ្យច្រើន ។ ក្នុងគ្រប់បទមានន័យដូចពោលមកនេះ ។

ចប់អដ្ឋកថា អបរអច្ឆរាសង្ឃាតវគ្គ

# អដ្ឋកថា

## កាយគតាសតិវគ្គ

[២២៥] ក្នុងបទថា *ចេតសា ផុដោ* (ផ្សាយទៅដោយចិត្ត) នេះ ការផ្សាយមាន ២ យ៉ាង គឺ ផ្សាយទៅដោយអាលោកកសិណ ១ ផ្សាយទៅដោយទិព្វចក្ខុ ១ ។ ក្នុង ២ យ៉ាងនោះ ការចូលអាបោកសិណហើយ ផ្សាយទៅដោយអាបោ ឈ្មោះថា ផ្សាយដោយអាបោកសិណ ។ កាលមហាសមុទ្រសូម្បីត្រូវផ្សាយទៅ ដោយការផ្សាយទៅយ៉ាងនេះ ស្ទឹងតូចៗ គ្រប់ខ្សែដែលហូរទៅរកមហាសមុទ្រ រមែងជាការរួមចូលផង ។ ក៏ការចម្រើនអាលោកកសិណហើយ ឃើញសមុទ្រទាំងអស់ដោយចក្ខុ ឈ្មោះថា ផ្សាយដោយទិព្វចក្ខុ ។ កាលមហាសមុទ្រត្រូវផ្សាយទៅ ដោយការផ្សាយទៅយ៉ាងនេះ ស្ទឹងតូចៗ ដែលហូរទៅរកមហាសមុទ្រ រមែងជាការរួមចូលផង ។ បទថា **អន្តោគធា តស្ស** (ឈានចុះក្នុងខាងក្នុងភិក្ខុនោះ) សេចក្ដីថា កុសលធម៌ទាំងឡាយ រមែងឈានចុះក្នុងខាងក្នុងនៃការចម្រើនរបស់ភិក្ខុនោះ ។ ក្នុងបទថា **វិជ្ជាភាគិយា** (ដែលប្រព្រឹត្តទៅក្នុងចំណែកវិជ្ជា) នេះ មានវិគ្រោះដូចតទៅនេះ ឈ្មោះថា វិជ្ជាភាគៈ ព្រោះប្រសព្វក្នុងវិជ្ជា គឺ ដោយការប្រកបចូលគ្នាបាន ។ ឈ្មោះថា វិជ្ជាភាគិយៈ ព្រោះប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា គឺ ក្នុងភាគ

នៃវិជ្ជា ។ ក្នុងបទថា វិជ្ជាភាគិយៈ នោះ វិជ្ជាមាន ៨ គឺ វិបស្សនា ១ មនោ-មយិទ្ធិ ១ អភិញ្ញា ៦ ។ ដោយអត្ថដំបូង ធម៌ដែលសម្បយុត្តដោយវិជ្ជាទាំងនោះ ជាវិជ្ជាភាគិយៈ ។ ដោយអត្ថក្រោយ វិជ្ជាប្រការណាមួយ ត្រឹមតែមួយក្នុងបណ្តាវិជ្ជា ៨ នោះ ជាវិជ្ជា ។ ធម៌ដ៏សេស ជាវិជ្ជាភាគិយៈ (គឺជាចំណែកនៃវិជ្ជា) ។ រួមសេចក្តីថា វិជ្ជាក្តី ធម៌ដែលសម្បយុត្តដោយវិជ្ជាក្តី គប្បីជ្រាបថា ជាវិជ្ជាភាគិយៈទាំងអស់ ។

[២២៦] បទថា **មហតោ សំវេគាយ** (ដើម្បីសេចក្តីសង្វេគធំ) ប្រែថា ដើម្បីប្រយោជន៍ដល់សេចក្តីសង្វេគធំ ។ សូម្បីក្នុងពីរបទខាងមុខ ក៏មានន័យនោះដូចគ្នា ។ ក៏ក្នុងអធិការនេះ វិបស្សនា ឈ្មោះថា សេចក្តីសង្វេគធំ មគ្គ ៤ ឈ្មោះថា ប្រយោជន៍ធំ សាមញ្ញផល ៤ ឈ្មោះថា សេចក្តីក្សេមចាកយោគៈធំ ។ម្យ៉ាងទៀត មគ្គ និងវិបស្សនា ឈ្មោះថា សេចក្តីសង្វេគធំ សាមញ្ញផល ៤ ឈ្មោះថា ប្រយោជន៍ធំ ព្រះនិព្វាន ឈ្មោះថា សេចក្តីក្សេមចាកយោគៈធំ ។ បទថា **សតិ-សម្បជញ្ញាយ** (ដើម្បីសតិ និងសម្បជញ្ញៈ) បានដល់ ដើម្បីប្រយោជន៍ដល់សតិ និងញាណ ។ បទថា **ញាណទស្សនប្បដិលាភាយ** (ដើម្បីបានញាណទស្សនៈ) គឺ ដើម្បីទិព្វចក្ខុញាណ ។ បទថា **ទិដ្ឋធម្មសុខវិហារាយ** (ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន) បានដល់ ដើម្បីត្រូវការនៅជាសុខក្នុងអត្តភាពដែលប្រាកដហើយនេះឯង ។

បទថា ***វិជ្ជាវិមុត្តិផលសច្ឆិកិរិយាយ*** (ដើម្បីធ្វើឲ្យច្បាស់នូវផល គឺ វិជ្ជា និងវិមុត្តិ) បានដល់ ដើម្បីត្រូវការធ្វើឲ្យឃើញច្បាស់នូវផលរបស់វិជ្ជា និងវិមុត្តិ ។ ក៏ក្នុងបទថា ***ដើម្បីធ្វើឲ្យជាក់ច្បាស់នូវផល គឺ វិជ្ជា និងវិមុត្តិ*** នេះ បញ្ញាក្នុងមគ្គ ឈ្មោះថា វិជ្ជា ។ ធម៌ដ៏សេសដែលសម្បយុត្តដោយវិជ្ជានោះ ឈ្មោះថា វិមុត្តិ ។ អរហត្តផល ឈ្មោះថា ផលរបស់ធម៌ទាំងនោះ អធិប្បាយថា ដើម្បីធ្វើឲ្យជាក់ច្បាស់អរហត្តផលនោះ ។

[២២៧-២២៩] បទថា ***កាយោបិ បស្សម្ភតិ*** (សូម្បីកាយក៏ស្ងប់) សេចក្តីថា ទាំងនាមកាយ ទាំងករជកាយ រមែងស្ងប់ គឺ ជាកាយដែលស្ងប់ហើយ ។ បទថា ***វិតក្កវិចារាបិ*** (សូម្បីវិតក្កវិចារៈ) សេចក្តីថា ធម៌ទាំងនេះ ឈ្មោះថា រមែងចូលទៅស្ងប់ដោយទុតិយជ្ឈាន ។ តែក្នុងទីនេះ លោកពោលសំដៅយកការចូលទៅស្ងប់ធម៌គ្រោតគ្រាត ។ បទថា ***កេវលា*** (ទាំងអស់) បានដល់ ដោយសព្វគ្រប់ អធិប្បាយថា ទាំងអស់មិនមានសល់ឡើយ ។ បទថា ***វិជ្ជាភាគិយា*** (ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា) គឺ ប្រព្រឹត្តទៅក្នុងចំណែកនៃការដឹងច្បាស់ ។ ធម៌ទាំងនោះបានសម្តែងចែកទុកក្នុងខាងដើមហើយ ។

[២៣០] បទថា ***អវិជ្ជា បហីយតិ*** (រមែងលះអវិជ្ជាចេញបាន) សេចក្តីថា សេចក្តីងងឹតឈឹង គឺ ការមិនដឹងដែលធ្វើសេចក្តីងងឹតឈឹងយ៉ាងមហន្ត ជាឫស

គល់នៃវដ្តៈក្នុងឋានៈ ៨ ប្រការដែលភិក្ខុរមែងលះបាន ។ បទថា **វិជ្ជា ឧប្បជ្ជតិ** (វិជ្ជារមែងកើតឡើង) បានដល់ វិជ្ជាក្នុងអរហត្តមគ្គរមែងកើតឡើង ។ បទថា **អស្មិមានោ បហីយតិ** (រមែងលះអស្មិមានះចេញបាន) សេចក្តីថា មានះ ៩ ថា ជាយើងជាដើម ដែលភិក្ខុរមែងលះបាន ។ បទថា **អនុសយា** (អនុស័យ) បានដល់ អនុស័យ ៧ ។ បទថា **សំយោជនានិ** (សំយោជនៈ) បានដល់ សញ្ញោជនៈ ១០ ។

[២៣១] បទថា **បញ្ញាបភេទាយ** (ដើម្បីសេចក្តីបែកធ្លាយនៃបញ្ញា) បានដល់ ដើម្បីដល់សេចក្តីបែកធ្លាយនៃបញ្ញា ។ បទថា **អនុបាទាបរិនិព្វានាយ** (ដើម្បីអនុ-បាទាបរិនិព្វាន) ប្រែថា ដើម្បីត្រូវការធ្វើឲ្យជាក់ច្បាស់បរិនិព្វាន ដែលរកបច្ច័យមិនបាន ។

[២៣២-២៣៣] បទថា **អនេកធាតុបដិវេធោ ហោតិ** (រមែងមានការត្រាស់ដឹងធាតុច្រើនប្រការ) សេចក្តីថា រមែងមានការត្រាស់ដឹងចាក់ធ្លុះលក្ខណៈរបស់ធាតុ ១៨ ប្រការ ។ បទថា **នានាធាតុបដិវេធោ ហោតិ** (រមែងមានការចាក់ធ្លុះធាតុច្រើនប្រការ) សេចក្តីថា រមែងមានការចាក់ធ្លុះលក្ខណៈដោយភាវៈផ្សេងៗ នៃធាតុទាំង ១៨ នោះឯង ។ ដោយបទថា **អនេកធាតុបដិសម្ភិទា ហោតិ** (រមែងបែកធ្លាយក្នុងធាតុច្រើនប្រការ) នេះ លោកពោលដល់ការដឹងប្រភេទរបស់ធាតុ ។ បញ្ញាជាគ្រឿងដឹងថា ធាតុនេះឈ្មោះថាមានច្រើនប្រការ ឈ្មោះថា **ធាតុបភេទញ្ញាណ**

(សេចក្តីដឹងប្រភេទរបស់ធាតុ) ។ ក៏សេចក្តីដឹងប្រភេទរបស់ធាតុនេះ មិនមែនមានដល់បុគ្គលទូទៅ មានដោយចំពោះដល់ពុទ្ធទាំងឡាយប៉ុណ្ណោះ ។ សេចក្តីដឹងប្រភេទរបស់ធាតុនោះ ព្រះសម្មាសម្ពុទ្ធទ្រង់មិនបានត្រាស់ទុកដោយប្រការទាំងពួង (ដោយចំពោះ) ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះកាលត្រាស់ទុក ក៏មិនមានប្រយោជន៍ ។

[២៣៤] បទ ១៦ មានជាដើមថា **បញ្ញាបដិលាភាយ** (ដើម្បីបានបញ្ញា) ដូច្នេះទៅ ៖ ទ្រង់តាំងមាតិកាហើយ អធិប្បាយសេចក្តីពិស្តារទុកក្នុងបដិសម្ភិទាមគ្គយ៉ាងនេះថា **សប្បុរិសូបសំសេវៈ** (សេពគប់សប្បុរស) ១ **សទ្ធម្មស្សវនៈ** (ស្តាប់ធម៌របស់សប្បុរស) ១ **យោនិសោមនសិការៈ** (ធ្វើទុកក្នុងចិត្តដោយឧបាយ) ១ **ធម្មានុធម្មប្បដិបត្តិ** (បដិបត្តិធម៌សមគួរដល់ធម៌) ១ (និងមាតិកាយ៉ាងនេះថា) ម្នាលភិក្ខុទាំងឡាយ ធម៌ ៤ ប្រការនេះឯង ដែលបុគ្គលអប់រំហើយ ធ្វើឲ្យច្រើនហើយ រមែងប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា ។ល។ រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាជម្រះកិលេស ។

សមដូចព្រះសារីបុត្រពោលទុក ក្នុងបទថា **បញ្ញាបដិលាភាយ សំវត្តន្តិ**[១] (រមែងប្រព្រឹត្តទៅដើម្បីបាននូវបញ្ញា) ការបានចំពោះនូវបញ្ញា ដូចម្តេច ។ ការបាន

---

១-ក្នុងបាលីបិដក : ជា សំវត្តតិ ។

ការបានចំពោះ ការដល់ ការដល់ព្រម ការពាល់ត្រូវ ការធ្វើឲ្យច្បាស់ ការចូលដល់ មគ្គញាណ ៤ ផលញាណ ៤ បដិសម្ភិទាញាណ ៤ អភិញ្ញាញាណ ៦ ញាណ ៧៣ ញាណ ៧៧ ។ នេះឈ្មោះថា ការបានចំពោះនូវបញ្ញា ក្នុងបទថា ***រមែងប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា*** ។

ក្នុងបទថា ***បញ្ញាវុឌ្ឍិយា សំវត្តតិ*** (រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើននៃបញ្ញា) នេះ សេចក្តីចម្រើនបញ្ញាដូចម្តេច ។ បញ្ញារបស់ព្រះសេក្ខៈ ៧ ពួក និងរបស់កល្យាណបុថុជ្ជន រមែងចម្រើន តែបញ្ញារបស់ព្រះអរហន្តជាវឌ្ឍនាបញ្ញា (គឺបញ្ញាដែលចម្រើនពេញលេញហើយ) នេះឈ្មោះថា សេចក្តីចម្រើនបញ្ញា ក្នុងបទថា ***រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើនបញ្ញា*** ។

ក្នុងបទថា ***បញ្ញាវេបុល្លាយ សំវត្តតិ*** (រមែងប្រព្រឹត្តទៅដើម្បីធំទូលាយនៃបញ្ញា) ភាពធំទូលាយនៃបញ្ញា ដូចម្តេច ។ បញ្ញារបស់ព្រះសេក្ខបុគ្គល ៧ ពួក និងរបស់កល្យាណបុថុជ្ជន រមែងដល់ភាពធំទូលាយ បញ្ញារបស់ព្រះអរហន្ត ដល់ភាពធំទូលាយហើយ នេះឈ្មោះថា ភាពធំទូលាយនៃបញ្ញា ក្នុងបទថា ***រមែងប្រព្រឹត្តទៅដើម្បីភាពធំទូលាយនៃបញ្ញា*** ។

ក្នុងបទថា ***មហាបញ្ញតាយ សំវត្តតិ*** (រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាធំ) បញ្ញាធំ ដូចម្តេច ។ ឈ្មោះថា បញ្ញាធំ ព្រោះកំណត់កាន់យកប្រយោជន៍

ធំ ឈ្មោះថា បញ្ញាធំ ព្រោះកំណត់កាន់យកធម៌ធំ ។បេ។ និរុត្តិធំ បដិភាណធំ គំនរសីលធំ គំនរសមាធិ បញ្ញា វិមុត្តិ និងវិមុត្តិញាណទស្សនៈធំ ឋានៈ និងអឋានៈធំ វិហារសមាបត្តិធំ អរិយសច្ចធំ សតិប្បដ្ឋាន សម្មប្បធាន និងឥទ្ធិបាទធំ ឥន្ទ្រិយពលៈធំ ពោជ្ឈង្គៈធំ អរិយមគ្គធំ សាមញ្ញផលធំ មហាអភិញ្ញាធំ ព្រះនិព្វានដែលជាប្រយោជន៍ដ៏ធំក្រៃលែង ។ នេះឈ្មោះថា បញ្ញាធំ ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាធំ** ។

ក្នុងបទថា ***បុថុប្បញ្ញតាយ សំវត្តន្តិ*** (រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលមានបញ្ញាក្រាស់) បញ្ញាក្រាស់ ដូចម្តេច ។ ឈ្មោះថា បញ្ញាក្រាស់ ព្រោះញាណរមែងប្រព្រឹត្តទៅក្នុងខន្ធផ្សេងៗ ក្រាស់ ។ ឈ្មោះថា បញ្ញាក្រាស់ ព្រោះញាណរមែងប្រព្រឹត្តទៅក្នុងធាតុផ្សេងៗ ក្រាស់ ក្នុងអាយតនៈផ្សេងៗ ក្រាស់ ក្នុងបដិច្ចសមុប្បាទផ្សេងៗ ក្រាស់ ក្នុងការបានសុញ្ញតៈផ្សេងៗ ក្រាស់ ក្នុងអត្ថ ធម៌ និរុត្តិ បដិភាណក្រាស់ ក្នុងសីលក្ខន្ធ សមាធិខន្ធ បញ្ញាខន្ធ វិមុត្តិខន្ធ និងវិមុត្តិញាណទស្សនខន្ធផ្សេងៗ ក្រាស់ ក្នុងឋានៈនិង អឋានៈផ្សេងៗ ក្រាស់ ក្នុងវិហារសមាបត្តិផ្សេងៗ ក្រាស់ ក្នុងអរិយសច្ចផ្សេងៗ ក្រាស់ ក្នុងសតិប្បដ្ឋាន សម្មប្បធាន ឥទ្ធិបាទ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈផ្សេងៗ ក្រាស់ ។ ឈ្មោះថា បញ្ញាក្រាស់ ព្រោះញាណប្រព្រឹត្តទៅក្នុងព្រះនិព្វានដែលជាប្រយោជន៍យ៉ាងក្រៃលែង កន្លងធម៌ដែលទូទៅ

ដល់ជនផ្សេងៗ ក្រាស់ ។ នេះឈ្មោះថា បញ្ញាក្រាស់ ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលមានបញ្ញាក្រាស់** ។

ក្នុងបទថា **វិបុលបញ្ញាយ សំវត្តតិ** (រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលមានបញ្ញាទូលាយ) បញ្ញាទូលាយ ដូចម្តេច ។ ឈ្មោះថា បញ្ញាទូលាយ ព្រោះកំណត់កាន់យកប្រយោជន៍ដ៏ទូលាយ ។ល។ ឈ្មោះថា បញ្ញាទូលាយ ព្រោះកំណត់កាន់យកព្រះនិព្វានដែលមានប្រយោជន៍ក្រៃលែងទូលាយ ។ នេះឈ្មោះថា បញ្ញាទូលាយ ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលមានបញ្ញាទូលាយ** ។

ក្នុងបទថា **គម្ភីបញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលមានបញ្ញាជ្រាលជ្រៅ) បញ្ញាជ្រាលជ្រៅ ដូចម្តេច ។ ឈ្មោះថា បញ្ញាជ្រាលជ្រៅ ព្រោះញាណប្រព្រឹត្តទៅក្នុងខន្ធទាំងឡាយដ៏ជ្រាលជ្រៅ ។ សេចក្តីពិស្តារដូចគ្នានឹងប្រការដែលពោលដោយបញ្ញាក្រាស់ ។ ឈ្មោះថា បញ្ញាជ្រាលជ្រៅ ព្រោះញាណរមែងប្រព្រឹត្តទៅក្នុងព្រះនិព្វាន ដែលមានប្រយោជន៍យ៉ាងក្រៃលែងជ្រាលជ្រៅ ។ នេះឈ្មោះថា បញ្ញាជ្រាលជ្រៅ ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីភាពជាបុគ្គលមានបញ្ញាជ្រាលជ្រៅ** ។

ក្នុងបទថា **អសមត្ថបញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាឥតអ្នកណាស្មើ) បញ្ញាឥតអ្នកណាស្មើ ដូចម្តេច ។ បុគ្គលណាចាក់ធ្លុះ

ធ្វើឲ្យច្បាស់ ពាល់ត្រូវដោយបញ្ញា នូវធម៌ និរុត្តិ បដិភាណ ដោយកំណត់ដឹង ធម៌ និរុត្តិ និងបដិភាណ នរណាៗ ដទៃរមែងមិនអាចគ្របសង្កត់ អត្ថ ធម៌ និរុត្តិ និងបដិភាណរបស់បុគ្គលនោះ និងបុគ្គលនោះ ដែលអ្នកដទៃទាំងឡាយមិនគប្បីគ្របសង្កត់បាន ព្រោះដូច្នោះ បុគ្គលនោះ ទើបឈ្មោះថា **បុគ្គលមានបញ្ញាឥតមានអ្នកស្មើបាន** ។

បញ្ញារបស់កល្យាណបុថុជ្ជន ថ្លាយ ឃ្លាតថ្លាយ ថ្លាយសែនថ្លាយ មិនជិត មិនស្មើនឹងបញ្ញារបស់អដ្ឋមកបុគ្គល[១] បុគ្គលទី ៨ កាលប្រៀបនឹងកល្យាណបុថុជ្ជន អដ្ឋមកបុគ្គល ឈ្មោះថា ជាអ្នកមានបញ្ញាមិនស្មើគ្នាបាន ។ បញ្ញារបស់អដ្ឋមកបុគ្គលថ្លាយ ។បេ។ មិនស្មើនឹងបញ្ញារបស់ព្រះសោតាបន្ន កាលបើប្រៀបនឹងអដ្ឋមកបុគ្គល ព្រះសោតាបន្ន ឈ្មោះថា ជាអ្នកមានបញ្ញាមិនជិត ។ បញ្ញារបស់ព្រះសោតាបន្នថ្លាយ ។បេ។ បញ្ញារបស់ព្រះសកទាគាមីថ្លាយ ។បេ។ បញ្ញារបស់ព្រះអនាគាមី ។បេ។ បញ្ញារបស់ព្រះអរហន្តថ្លាយ ឃ្លាតថ្លាយ ថ្លាយសែនថ្លាយ មិនជិត មិនជិតបើប្រៀបនឹងបញ្ញារបស់ព្រះបច្ចេកពុទ្ធ កាលប្រៀបនឹងព្រះអរហន្ត ព្រះបច្ចេកពុទ្ធ ឈ្មោះថា ជាអ្នកមានបញ្ញាមិនជិត ។ បើប្រៀបនឹងបញ្ញាព្រះបច្ចេក-

---

១-អដ្ឋមកបុគ្គល (បុគ្គលទី ៨) ក្នុងទីនេះសំដៅដល់លោកដែលតាំងនៅក្នុងសោតាបត្តិមគ្គ ព្រោះរាប់តាំងពីលោកដែលតាំងនៅក្នុងអរហត្តផលមក ។

ពុទ្ធ ជាមួយមនុស្សលោកព្រមទាំងទេវតា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់មានព្រះបញ្ញាឥតមានអ្នកណាប្រៀបបាន គឺ ប្រសើរបំផុត ។

ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ទ្រង់ឆ្លាតក្នុងប្រភេទរបស់បញ្ញា ទ្រង់មានព្រះញាណបែកធ្លាយ ។ល។ បណ្ឌិតទាំងនោះតែងបញ្ញាហើយ ចូលទៅគាល់ព្រះតថាគត ទូលសួរទាំងបញ្ហាសម្ងាត់ និងបិទបាំង បញ្ហាទាំងនោះដែលព្រះដ៏មាន-ព្រះភាគត្រាស់ប្រាប់ និងទ្រង់តបហើយ ទ្រង់រមែងបង្ហាញហេតុឲ្យឃើញច្បាស់និងបញ្ហាដែលគេលើកឡើងមកនោះ ព្រះមានព្រះភាគក៏ទ្រង់តបបានយ៉ាងសម្បូរ ។ ដោយពិត ក្នុងបញ្ហានោះ ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់ដោយព្រះបញ្ញា ព្រោះហេតុនោះ ទើបឈ្មោះថា មានព្រះបញ្ញាឥតមានអ្នកប្រៀបបាន ជាបញ្ញាប្រសើរបំផុត នេះឈ្មោះថា បញ្ញាឥនមានអ្នកប្រៀបបាន ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាឥតមានអ្នកប្រៀបបាន** ។

ក្នុងបទថា **ភូរិប្បញ្ញតាយ សំវត្តតិ** (ប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាក្រាស់ដូចផែនដី) នេះ ភូរិប្បញ្ញា ដូចម្តេច ។ ឈ្មោះថា ភូរិប្បញ្ញា ព្រោះគ្របសង្កត់រាគៈហើយ ។ ឈ្មោះថា ភូរិប្បញ្ញា ព្រោះគ្របសង្កត់រាគៈបានហើយ ។ ឈ្មោះថា ភូរិបញ្ញា ព្រោះរមែងគ្របសង្កត់ ទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាឋេយ្យៈ ថម្ភៈ សារម្ភៈ មានៈ

អតិមានះ មទះ បមាទះ កិលេសទាំងពួង ទុច្ចរិតទាំងពួង អភិសង្ខារទាំងពួង ។ល។ កម្មដែលជាហេតុនាំទៅកាន់ភពទាំងពួង ។ ឈ្មោះថា ភូរិប្បញ្ញា ព្រោះគ្រប សង្កត់កម្មដែលជាហេតុនាំទៅកាន់ភពទាំងពួងបានហើយ ។ រាគះ ឈ្មោះថា អរិ ។ បញ្ញាដែលញាំញីអរិនោះ ហេតុនោះ ឈ្មោះថា ភូរិប្បញ្ញា ។ ឈ្មោះថា ភូរិប្បញ្ញា ព្រោះគ្របសង្កត់អរិបានហើយ ។ ទោសះ មោហះ ។ល។ កម្មជាហេតុនាំទៅកាន់ភពទាំងពួង ឈ្មោះថា អរិ បញ្ញាដែលញាំញីអរិនោះ ហេតុនោះ ឈ្មោះថា ភូរិ-ប្បញ្ញា ។ ផែនដីហៅថា ភូរិ បុគ្គលប្រកបដោយបញ្ញាដែលផ្សាយទៅធំទូលាយ ស្មើផែនដីនោះ ហេតុនោះ ទើបឈ្មោះថា ភូរិប្បញ្ញា (អ្នកមានបញ្ញាស្មើផែនដី) ។ ម្យ៉ាងទៀត ពាក្យនេះ គឺ ភូរិ មេធា បរិណាយិកា ជាឈ្មោះរបស់បញ្ញា ។ នេះ ឈ្មោះថា ភូរិប្បញ្ញា ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាក្រាស់ ដូចផែនដី** ។

ក្នុងបទថា **បញ្ញាពាហុល្លាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញាច្រើន) នេះ ភាពជាបុគ្គលមានបញ្ញាច្រើន ដូចម្តេច ។ បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកធ្ងន់ក្នុងបញ្ញា ជាអ្នកមានបញ្ញាជាចរិត មានបញ្ញាជាទីអាស្រ័យ បង្អោនចិត្តទៅក្នុងបញ្ញា មានបញ្ញាជាទង់ជ័យ មានបញ្ញាជាកំពូលទង់ មានបញ្ញាជាអធិបតី ច្រើនដោយការវិច័យ ច្រើនដោយការស្រាវជ្រាវ ច្រើនដោយការពិ-

បារណា ច្រើនដោយការសម្លឹងពិនិត្យ មានការសម្លឹងពិនិត្យជាធម្មតា នៅដោយបញ្ញាដែលជាក់ច្បាស់ និងប្រព្រឹត្តក្នុងបញ្ញានោះ ធ្ងន់ក្នុងបញ្ញានោះ ច្រើនដោយបញ្ញានោះ ឈមទៅក្នុងបញ្ញានោះ បង្អោនទៅក្នុងបញ្ញានោះ ទោរទៅក្នុងបញ្ញានោះ បង្អោនចិត្តទៅក្នុងបញ្ញានោះ មានបញ្ញាជាអធិបតី ឧបមាដូចភិក្ខុដែលធ្ងន់ក្នុងពួកគណៈ ក៏ហៅថា អ្នកច្រើនដោយពួកគណៈ អ្នកធ្ងន់ក្នុងចីវរ អ្នកធ្ងន់ក្នុងបាត្រ អ្នកធ្ងន់ក្នុងសេនាសនៈ ក៏ហៅថា អ្នកច្រើនដោយសេនាសនៈ យ៉ាងណា បុគ្គលខ្លះក្នុងលោកនេះក៏ដូច្នោះដូចគ្នា ជាអ្នកធ្ងន់ក្នុងបញ្ញា មានបញ្ញាជាចរិត ។ល។ មានបញ្ញាជាអធិបតី ។ នេះឈ្មោះថា ភាពជាអ្នកច្រើនដោយបញ្ញា ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញារួសរាន់** ។

ក្នុងបទថា **សីឃប្បញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញារហ័ស) នេះ បញ្ញារហ័ស ដូចម្ដេច ។ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើសីលឲ្យបរិបូណ៌រហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើឥន្ទ្រិយសំវរៈ ភោជនេមត្តញ្ញុតា ជាគរិយានុយោគ សីលក្ខន្ធ សមាធិខន្ធ វិមុត្តិខន្ធ វិមុត្តិញ្ញាណទស្សនក្ខន្ធឲ្យបរិបូណ៌រហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះត្រាស់ដឹងឋានៈ និងអឋានៈបានរហ័ស ព្រោះធ្វើវិហារសមាបត្តិឲ្យបរិបូណ៌បានរហ័ស ព្រោះត្រាស់ដឹងអរិយសច្ចៈបានរហ័ស ព្រោះចម្រើនសតិប្បដ្ឋានបានរហ័ស ព្រោះចម្រើនសម្ម-

ប្បធាន ឥទ្ធិបាទ ឥន្ទ្រិយពលៈ ពោជ្ឈង្គៈ អរិយមគ្គបានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើឲ្យច្បាស់សាមញ្ញផលបានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះត្រាស់ដឹងអភិញ្ញាបានរហ័ស ។ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់ព្រះនិព្វានដែលជាប្រយោជន៍យ៉ាងក្រៃលែងបានរហ័ស ។ នេះឈ្មោះថា បញ្ញារហ័ស ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាបុគ្គលមានបញ្ញារហ័ស** ។

ក្នុងបទថា **លហុបញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីភាពជាអ្នកមានបញ្ញារហ័ស) នេះ បញ្ញារហ័ស ដូចម្តេច ។ ឈ្មោះថា បញ្ញារហ័ស ព្រោះបំពេញសីលឲ្យបរិបូណ៌រហ័ស ។ល។ ឈ្មោះថា បញ្ញារហ័ស ព្រោះធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដែលជាប្រយោជន៍យ៉ាងក្រៃលែងបានរហ័ស ។ នេះឈ្មោះថា បញ្ញារហ័ស ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញារហ័ស** ។

ក្នុងបទថា **ហាសបញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញារីករាយ) នេះ បញ្ញារីករាយ ដូចម្តេច ។ ឈ្មោះថា បញ្ញារីករាយ ព្រោះបុគ្គលពួកខ្លះក្នុងលោកនេះ មានសេចក្តីរីករាយច្រើន មានសេចក្តីពេញចិត្តច្រើន មានសេចក្តីត្រេកអរច្រើន មានបាមោជ្ជៈច្រើន បំពេញសីលទាំងឡាយឲ្យបរិបូណ៌ ។ល។ ឈ្មោះថា បញ្ញារីករាយ ព្រោះធ្វើឲ្យច្បាស់នូវព្រះនិព្វានដែលជាប្រយោជន៍យ៉ាងក្រៃលែង ។ នេះឈ្មោះថា បញ្ញារីករាយ ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បី**

ជាអ្នកមានបញ្ញារឹករាយ ។

ក្នុងបទថា *ជវនបញ្ញតាយ សំវត្តន្តិ* (រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាជាគ្រឿងស្ទុះទៅ) នេះ បញ្ញាជាគ្រឿងស្ទុះទៅ ដូចម្ដេច ។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះរូបណាមួយដែលជាអតីត អនាគត និងបច្ចុប្បន្ន... វេទនា សញ្ញា សង្ខារ វិញ្ញាណណាមួយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ជាខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិតល្អន់ ថោកទាប ឬប្រណីត នៅឆ្ងាយ ឬជិត បញ្ញាជាគ្រឿងស្ទុះទៅកាន់វិញ្ញាណទាំងពួង ដោយភាពជារបស់មិនទៀង ។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅ ដោយភាពជាទុក្ខ ដោយភាពជាអនត្តា ។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅកាន់ចក្ខុ ។ល។ ជរា និងមរណៈ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ថាជារបស់មិនទៀង ថាជាទុក្ខ ថាជាអនត្តា ។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះប្រៀបធៀប ពិចារណា ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់នូវរូបដែលជាអតីត អនាគត និងបច្ចុប្បន្ន ថាមិនទៀង ព្រោះអត្ថថាអស់ទៅ ថាជាទុក្ខ ព្រោះអត្ថថា គួរខ្លាច ថាជាអនត្តា ព្រោះអត្ថថា មិនមានសារៈ ហើយស្ទុះទៅកាន់ព្រះនិព្វានដែលជាទីរលត់រូប ។ល។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះស្ទុះទៅកាន់ព្រះនិព្វានដែលជាទីរលត់ជរា និងមរណៈ ។ ឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ព្រោះប្រៀបធៀប ពិចារណា ដឹងច្បាស់ ធ្វើឲ្យជាក់ច្បាស់

នូវរូប ។បេ។ ជរា និងមរណៈ ទាំងអតីត អនាគត បច្ចុប្បន្ន ដែលមិនទៀង ត្រូវបច្ច័យតាក់តែង អាស្រ័យគ្នាកើតឡើង មានការវិនាសជាធម្មតា មានការអស់ទៅជាធម្មតា មានការបែកធ្លាយទៅជាធម្មតា មានការរលត់ទៅជាធម្មតា ហើយស្ទុះទៅកាន់ព្រះនិព្វានដែលជាទីរលត់ជរា និងមរណៈ នេះឈ្មោះថា បញ្ញាជាគ្រឿងស្ទុះទៅ ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាជាគ្រឿងស្ទុះទៅ** ។

ក្នុងបទថា **តិក្ខបញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាដ៏មុត) នេះ បញ្ញាដ៏មុត ដូចម្ដេច ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះកាត់កិលេសបាន ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួល លះបង់ បន្ទោបង់ ធ្វើឲ្យដល់ទីបំផុត ឲ្យដល់សេចក្ដីមិនមានតទៅ នូវកាមវិតក្កៈ ព្យាបាទវិតក្កៈ វិហិង្សាវិតក្កៈ អកុសលបាបធម៌ដែលកើតឡើងហើយ ឈ្មោះថា បញ្ញាដ៏មុត ព្រោះមិនទទួលទុក លះបង់ បន្ទោបង់បាន ធ្វើឲ្យដល់ទីបំផុត ឲ្យដល់ការមិនមានតទៅនូវរាគៈ ទោសៈ មោហៈដែលកើតឡើងហើយមិនឲ្យកើតឡើង ។បេ។ នូវកម្មជាហេតុទៅកាន់ភពទាំងពួង ។ ឈ្មោះថា បញ្ញាដ៏មុត ព្រោះសម្រេច ធ្វើឲ្យជាក់ច្បាស់ ពាល់ត្រូវដោយបញ្ញានូវអរិយមគ្គ ៤ សាមញ្ញផល ៤ បដិសម្ភិទា ៤ អភិញ្ញា ៦ លើអាសនៈតែមួយ ។ នេះឈ្មោះថា បញ្ញាដ៏មុត ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាដ៏មុត** ។

ក្នុងបទថា **និព្វេធិកបញ្ញតាយ សំវត្តន្តិ** (រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាជាគ្រឿងទម្លាយកិលេស) នេះ បញ្ញាជាគ្រឿងទម្លាយកិលេស ដូចម្តេច ។ ឈ្មោះថា បញ្ញាជាគ្រឿងទម្លាយកិលេស ព្រោះបុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកភ័យព្រួយច្រើន ជាអ្នកតក់ស្លុតច្រើន ជាអ្នកអផ្សុកច្រើន ជាអ្នកច្រើនដោយសេចក្តីមិនត្រេកអរ ច្រើនទៅដោយសេចក្តីមិនត្រេកអរក្រៃលែងក្នុងសង្ខារទាំងពួង ជាអ្នកបែរមុខចេញ មិនត្រេកអរក្នុងសង្ខារទាំងពួង ជម្រះ ទម្លាយកងលោភៈដែលមិនទាន់ធ្លាប់ជម្រះ មិនធ្លាប់ទម្លាយ ។ ឈ្មោះថា បញ្ញាជាគ្រឿងទម្លាយកិលេស ព្រោះជម្រះ ទម្លាយកងទោសៈ កងមោហៈ កោធៈ ឧបនាហៈ ។ល។ កម្មដែលជាគ្រឿងនាំទៅកាន់ភពទាំងពួងដែលមិនធ្លាប់ជម្រះ ដែលមិនធ្លាប់ទម្លាយ ។ នេះឈ្មោះថា បញ្ញាជាគ្រឿងទម្លាយកិលេស ក្នុងបទថា **រមែងប្រព្រឹត្តទៅដើម្បីជាអ្នកមានបញ្ញាជាគ្រឿងទម្លាយកិលេស** ។

គប្បីជ្រាបខ្លឹមសារក្នុងអធិការដែលពោលដោយបញ្ញានេះ ដោយន័យដូចពោលទុកក្នុងបដិសម្ភិទាមគ្គដោយប្រការយ៉ាងនេះ ។ ក៏ក្នុងបដិសម្ភិទាមគ្គនោះជាពហុវចនៈតែម្យ៉ាង ក្នុងសូត្រនេះជាឯកវចនៈ ដូច្នោះ សេចក្តីផ្សេងគ្នាក្នុងរឿងបញ្ញានេះ មានត្រឹមតែប៉ុណ្ណោះ ។ ពាក្យដ៏សេសដូចគ្នាទាំងអស់នោះឯង ។ ក៏ឯមហាបញ្ញា១៦ ប្រការនេះ លោកពោលលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

ចប់អដ្ឋកថា កាយគតាសតិវគ្គ

# អ ដ្ឋ ក ថា

## អមតវគ្គ

[២៣៥] បទថា *អមតន្តេ ភិក្ខវេ បរិភុញ្ជន្តិ* (ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនោះរមែងឈ្មោះថា បរិភោគអមតៈ) សេចក្ដីថា ពួកភិក្ខុនោះឈ្មោះថា រមែងបរិភោគព្រះនិព្វានដែលប្រាសចាកមរណៈ ។ សួរថា ក៏ព្រះនិព្វានជាលោកុត្តរៈ កាយគតាសតិជាលោកិយៈ មិនមែនឬ បុគ្គលបរិភោគកាយគតាសតិនោះ ឈ្មោះថា បរិភោគអមតៈបានដូចម្ដេច ។ ឆ្លើយថា ព្រោះត្រូវចម្រើនកាយគតាសតិ ទើបនឹងសម្រេច (អមតនិព្វាន) ។ ពិតណាស់ បុគ្គលចម្រើនកាយគតាសតិ រមែងសម្រេចអមតៈ មិនចម្រើនក៏មិនសម្រេច ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនោះ ។ គប្បីជ្រាបសេចក្ដីក្នុងបទទាំងពួង ដោយឧបាយដូចពោលមកនេះ ។

[២៣៨]ម្យ៉ាងទៀត បទថា *វិរទ្ធំ* (ពួកភិក្ខុណាបោះបង់ហើយ) ក្នុងសូត្រនេះ បានដល់ ធ្វេសប្រហែសហើយ គឺ មិនសម្រេច ។ បទថា *អារទ្ធំ* (ដែលពួកភិក្ខុនោះប្រារព្ធហើយ) បានដល់ បរិបូណ៌ហើយ ។

[២៣៩] បទថា *បមាទឹសុ* (ប្រមាទ) បានដល់ វង្វេង ។

[២៤០] បទថា *បមុដ្ឋំ* ប្រែថា ភ្លេចភ្លាំង ផ្សាយទៅ ឬវិនាសទៅ ។

[២៤១] បទថា *អាសេវិតំ* (ពួកភិក្ខុនោះគប់ប្រសព្វហើយ) បានដល់ គប់ប្រសព្វមកអំពីដើម ។

[២៤២] បទថា *ភាវិតំ* (ពួកភិក្ខុនោះចម្រើនហើយ) បានដល់ កពូនហើយ ។

[២៤៣] បទថា *ពហុលីកតំ* (ដែលពួកភិក្ខុនោះធ្វើឲ្យច្រើនហើយ) បានដល់ ធ្វើរឿយៗ ។

[២៤៤] បទថា *អនភិញ្ញាតំ* (ដែលពួកភិក្ខុនោះមិនដឹងច្បាស់) បានដល់ មិនដឹងដោយញាតអភិញ្ញា (ដឹងក្រៃលែងដោយញាណ) ។

[២៤៥] បទថា *អបរិញ្ញាតំ* (ដែលពួកភិក្ខុនោះមិនកំណត់ដឹង) បានដល់ មិនកំណត់ដឹងដោយញាតបរិញ្ញា (ដឹងច្បាស់ដោយញាណ) នោះឯង ។

[២៤៦] បទថា *អសច្ឆិកតំ* (ដែលពួកភិក្ខុនោះមិនធ្វើឲ្យជាក់ច្បាស់) បានដល់ មិនធ្វើឲ្យប្រចក្ស ។ បទថា *សច្ឆិកតំ* (ដែលពួកភិក្ខុនោះធ្វើឲ្យជាក់ច្បាស់ហើយ) បានដល់ ធ្វើឲ្យប្រចក្ស ។ ពាក្យដ៏សេសគ្រប់កន្លែងមានសេចក្ដីងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា អមតវគ្គ

**ចប់អដ្ឋកថាឯកនិបាតប្រមាណ ១.០០០ សូត្រ ឈ្មោះមនោរថបូរណី**

**អដ្ឋកថាអង្គុត្តរនិកាយ**

# ទុកនិបាត

# អដ្ឋកថា បឋមបណ្ណាសកៈ

## អដ្ឋកថា កម្មករណវគ្គទី ១

### អដ្ឋកថាសូត្រទី ១

*“ពោលដោយទោសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងភពមុខ”*

*ទុកនិបាត សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៤៧] *បទថា **វជ្ជានិ** (ទោស) បានដល់ ទោស គឺ កំហុស ។ បទថា **ទិដ្ឋធម្មិកំ** (ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន) បានដល់ មានផលកើតឡើងក្នុងបច្ចុប្បន្ន គឺ ក្នុងអត្តភាពនេះឯង ។ បទថា **សម្បរាយិកំ** (ដែលប្រព្រឹត្តទៅក្នុងភពមុខ) បានដល់ មានផលកើតឡើងក្នុងខាងមុខ គឺ ក្នុងអត្តភាពដែលមិនទាន់មកដល់ ។*

*បទថា **អាគុចារី** (អ្នកប្រព្រឹត្តអំពើអាក្រក់) បានដល់ អ្នកធ្វើអាក្រក់ គឺ ធ្វើខុស ។ បទថា **រាជានោ គហេត្វា វិវិធា កម្មករណា ករោន្តេ** (ព្រះរាជាចាប់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ច្រើនប្រភេទ) សេចក្តីថា រាជបុរសទាំងឡាយចាប់ចោរមក ដាក់កម្មករណ៍ទាំងឡាយផ្សេងៗ ។ ក៏បានឈ្មោះថា ព្រះរាជា*

ទ្រង់ឲ្យរាជបុរសដាក់កម្មករណ៍ទាំងនោះ ។ បុគ្គលនេះ ឃើញចោរនោះត្រូវដាក់កម្មករណ៍យ៉ាងនេះ ។ ព្រោះហេតុនោះ លោកទើបពោលថា **បស្សតិ ចោរំ អាគុចារឹ រាជានោ គហេត្វា វិវិធា កម្មករណា ករោន្តេ** ដូច្នេះ ។ បទថា **អឌ្ឍទណ្ឌកេហិ** (ដោយដំបងខ្លី) សេចក្ដីថា ដោយឈើដំបង ឬដោយកំណាត់ឈើ ដែលយកកំណាត់ឈើប្រវែង ៤ ហត្ថមកកាត់ជា ២ កំណាត់ ដាក់ដងសម្រាប់កាន់ទុកដើម្បីប្រហារ ។ បទថា **ពិលង្គថាលិកំ** (ឆ្នាំងដាក់ទឹកជ្រក់) បានដល់ ដាក់កម្មករណ៍វិធី ធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ ។ កាលនឹងដាក់កម្មករណ៍នោះ បើកលលាដ៍ក្បាល និងយកដង្កៀបថ្ពៀបដុំដែកក្រហមដាក់ចូលក្នុងលលាដ៍ក្បាលនោះ ដោយហេតុនោះ ខួរក្នុងក្បាលក៏ពុះចេញមក ។

បទថា **សង្ខមុណ្ឌិកំ** (ខាត់សម្បកស័ង្ខ) បានដល់ ដាក់កម្មករណ៍ដូចខាត់សម្បកស័ង្ខ ។ កាលនឹងដាក់កម្មករណ៍នោះ គេពន្លះស្បែកក្បាលពីគុម្ពត្រចៀកទាំងពីរខាងចុះមកជើងសក់ ហើយក្រេបួចសរសៃសក់ទាំងអស់ចង ប្រើឈើស៊កលើកឡើង ឲ្យស្បែកក្បាលរបូតឡើងមកព្រមទាំងសក់ តពីនោះ ក៏ប្រើខ្សាច់គ្រើមខាត់លលាដ៍ក្បាលឲ្យរលីងដូចសម្បកស័ង្ខ ។ បទថា **រាហុមុខំ** (មាត់រាហូ) បានដល់ ដាក់កម្មករណ៍វិធីមាត់រាហូ ។ កាលនឹងដាក់កម្មករណ៍នោះ គេយកទំពក់ដែកថ្កក់មាត់ឲ្យហារឡើង ហើយដុតភ្លើងក្នុងមាត់នោះ វិធីមួយទៀត គេប្រើពន្លាក

ជាប់វង្វះមាត់ឲ្យដល់គុម្ពត្រចៀកទាំងពីរខាង ឈាមហូរចេញមកពេញមាត់ ។ បទថា **ជោតិមាលិកំ** (ផ្កាឈើភ្លើង) សេចក្តីថា គេប្រើសំពត់ចាស់ជ្រលក់ប្រេងរុំខ្លួនទាំងមូល ហើយដុតភ្លើង ។ បទថា **ហត្ថប្បជ្ជោតិកំ** (រុំដៃ) សេចក្តីថា គេប្រើសំពត់ចាស់ជ្រលក់ប្រេងរុំដៃទាំងពីរ ហើយដុតភ្លើងឲ្យដូចជាគប់ភ្លើង ។ បទថា **ឯរកវដ្តិកំ** (ពន្ទាត់ស្បែក) បានដល់ ដាក់កម្មករណ៍វិធីពន្ទាត់ស្បែក ។ កាលនឹងធ្វើកម្មករណ៍នោះ រមែងពន្ទាត់ស្បែកចេញជាចំរៀកៗ តាំងពីក្រោម.កចុះទៅដល់ក.ជើង ហើយប្រើខ្សែចងចោរទាញទៅ កាលចោរដើរទៅ ស្បែកក៏ជាប់ជាចំរៀកៗចុះមក ។ បទថា **ចីរកវាសិកំ** (សំពត់សំបកឈើ) បានដល់ វិធីកម្មករណ៍ដូចសំពត់សំបកឈើ ។ កាលនឹងធ្វើកម្មករណ៍នោះ គេចៀរស្បែកឲ្យជាចំរៀកៗដូចធ្វើដំបូងនុ៎ះឯង តែធ្វើជា ២ ផ្នែក គឺ ពីក្រោម.កចុះមកដល់ចង្កេះ ១ ផ្នែក ពីចង្កេះដល់ក.ជើង ១ ផ្នែក ចំរៀកស្បែកខាងលើគ្របចុះមកបិទកាយខាងក្រោម ដូចជាស្លៀកសំពត់សំបកឈើ ។ បទថា **ឯណេយ្យកំ** (ឈរដូចសត្វទ្រាយ) បានដល់ វិធីធ្វើកម្មករណ៍ឈរដូចសត្វទ្រាយ ។ វិធីនោះ គេប្រើកងដែកដាក់កដៃទាំងពីរ និងដាក់ជើងទាំងពីរឲ្យឈរ ស៊កជាប់នឹងបង្គោលដែកដែលបោះទុក ឲ្យគេឈរលើដីត្រង់បង្គោលដែក ៤ កន្លែងដែលបោះទុក ហើយដុតភ្លើងជុំវិញ គេរមែងដូចជាសត្វទ្រាយត្រូវភ្លើងឆេះស្លាប់ សូម្បីក្នុងអនាគតស្ថាន លោកក៏ពោលដូច្នេះ

ដូចគ្នា ។ កាលដល់វេលាសមគួរ ក៏ដកបង្គោលចេញ ឲ្យគេឈរ (ដូចជាសត្វជើង ៤) ដោយចុងឆ្អឹងទាំង ៤ នុ៎ះឯង ។ ឈ្មោះថា ហេតុការណ៍បែបនេះ រមែងមិនមាន ។ បទថា **ពឡិសមំសិកំ** (ថ្ពក់ដោយសន្ទូច) សេចក្ដីថា ប្រើសន្ទូចមានទៀង ២ ខាង ថ្ពក់ស្បែក សាច់ សរសៃទាញចេញមក ។ បទថា **កហាបណកំ** (អំពើដែលគេធ្វើឲ្យខូចសរីរៈប៉ុនកហាបណៈមួយ) សេចក្ដីថា គេប្រើកាំបិតដ៏មុតអារសរីរៈគ្រប់កន្លែង តាំងពីចង្កេះចេញទៅជាចំរៀកៗ ទំហំប៉ុនកហាបណៈ ។ បទថា **ខារាបដិច្ឆកំ** (អំពើដែលគេយកទឹកផ្សាស្រោច) សេចក្ដីថា សាប់ចិញ្ច្រាំទូទាំងកាយ ហើយប្រើទឹកផ្សាស្រោច ធ្វើឲ្យស្បែក សរសៃ ជ្រុះចេញមកនៅសល់តែឆ្អឹង ។ បទថា **បលិឃបរិវត្តកំ** (អំពើដែលគេធ្វើដូចជាបង្វិលជើងគុល ឬសសរគោល) សេចក្ដីថា គេចាប់ឲ្យដេកផ្អៀង ប្រើលំពែងដែកដោតត្រង់ប្រហោងត្រចៀកធ្លុះចុះទៅឲ្យជាប់ក្នុងដី ហើយចាប់ជើងទាំងពីរលើកដើរបង្វិលទៅ ។ បទថា **បលាលបីឋកំ** (អំពើដែលគេធ្វើឲ្យដូចជាកណ្ដាប់ចំបើង) សេចក្ដីថា ប្រធានដែលឆ្លាត ប្រើដុំថ្មប្រមៀលកិនកំទេចលើខ្លួនឲ្យឆ្អឹងបែក តែមិនឲ្យដាច់ស្បែក ហើយចាប់សក់លើកអង្រួនៗ ឲ្យសាច់រួមចូលជាដុំ ប្រើសក់នោះឯងចងទុកដូចជាដុំចំបើង ។ បទថា **សុនខេហិបិ ខាទាបេន្តិ** (ឲ្យឆ្កែខាំខ្លះ) សេចក្ដីថា មិនឲ្យអាហារឆ្កែ ២-៣ ថ្ងៃ ហើយឲ្យហ្វូងឆ្កែដែលឃ្លានខាំស៊ី ត្រឹមតែមួយភ្លែតក៏នៅសល់តែឆ្អឹង ។ បទថា

*សូលេ ឧត្តាសេន្តិ* (ឲ្យដេកផ្ងារលើឈើអណ្ដោតទាំងរស់ខ្លះ) បានដល់ លើកឡើង ឲ្យដេកលើឈើអណ្ដោត ។

បទថា ***ន បរេសំ បាភតំ បលុម្បន្តោ វិចរតិ*** (មិនដែលដណ្ដើមគ្រឿងបណ្ណាការរបស់បុគ្គលដទៃ) សេចក្ដីថា ឃើញទ្រព្យសម្បត្តិរបស់អ្នកដទៃនៅចំពោះមុខ ដោយហោចសូម្បីជារបស់ដែលមានតម្លៃ ១.០០០ ជ្រុះនៅតាមថ្នល់ ក៏មិនបានដណ្ដើមយក ដោយគិតថា នឹងមានជីវិតព្រោះវត្ថុនេះឬ ឬថា ប្រយោជន៍អ្វីដោយវត្ថុនេះ ហើយប្រើខ្នងជើងកៀសចេញទៅ ។ បទថា ***បាបកោ*** (ដែលថោកទាប) បានដល់ អាក្រក់ ។ បទថា ***ទុក្ខោ*** (ជាទុក្ខ) គឺ មិនគួរប្រាថ្នា ។ បទថា ***កិញ្ចិ តំ*** (ទុច្ចរិតពួកខ្លះ) សេចក្ដីថា គប្បីមានហេតុនេះបានដូចម្ដេច ។ បទថា ***យេនាហំ*** កាត់បទថា ***យេន អហំ*** ។

បទថា ***កាយទុច្ចរិតំ*** បានដល់ កាយកម្មដែលជាអកុសល ៣ យ៉ាង មានបាណាតិបាតជាដើម ។ បទថា ***កាយសុចរិតំ*** បានដល់ កុសលកម្ម ៣ យ៉ាង ដែលជាបដិបក្ខចំពោះកាយទុច្ចរិត ។ បទថា ***វចីសុចរិតំ*** បានដល់ កុសលកម្ម ៤ យ៉ាង ដែលជាបដិបក្ខចំពោះវចីទុច្ចរិត ។ បទថា ***មនោទុច្ចរិតំ*** បានដល់ មនោកម្មដែលជាអកុសល ៣ យ៉ាង មានអភិជ្ឈាជាដើម ។ បទថា ***មនោសុចរិតំ*** បានដល់ កុសលកម្ម ៣ យ៉ាង ដែលជាបដិបក្ខចំពោះមនោទុច្ចរិត ។

ក្នុងពាក្យថា **សុទ្ធំ អត្តានំ បរិហរតិ** នេះ សុទ្ធិមាន ២ យ៉ាង គឺ បរិយាយសុទ្ធិ ១ (សុទ្ធិដោយអម) និប្បរិយាយសុទ្ធិ ១ (សុទ្ធិដោយត្រង់) ។ ពិតណាស់ បុគ្គលឈ្មោះថា រក្សាខ្លួនឲ្យបរិសុទ្ធដោយបរិយាយ ដោយសរណគមន៍ ឈ្មោះថា រក្សាខ្លួនឲ្យបរិសុទ្ធដោយបរិយាយដោយសីល ៥ ដោយសីល ១០ ដោយចតុប្បារិសុទ្ធិសីល ដោយបឋមជ្ឈាន ។បេ។ ដោយនេវសញ្ញានាសញ្ញាយតនឈាន ដោយសោតាបត្តិមគ្គ ។បេ។ ដោយអរហត្តមគ្គ ក៏ដូចគ្នា ។ ចំណែកបុគ្គលតាំងនៅក្នុងអរហត្តផល ជាព្រះខីណាស្រព ញុំាងខន្ធ ៥ ដែលមានឫសគល់ដាច់ហើយឲ្យប្រព្រឹត្តទៅខ្លះ ឲ្យទំពារស៊ីខ្លះ ឲ្យបរិភោគខ្លះ ឲ្យអង្គុយខ្លះ ឲ្យដេកខ្លះ គប្បីជ្រាបថា រក្សា គឺ ផ្គត់ផ្គង់ខ្លួនឲ្យបរិសុទ្ធ គឺ អស់មន្ទិលដោយនិប្បរិយាយនោះឯង ។ បទថា **តស្មា** (ព្រោះដូច្នោះ) សេចក្តីថា ព្រោះទាំងពីរយ៉ាងនេះ ជាទោសតែម្យ៉ាង មិនមែនមិនជាទោសឡើយ ។ បទថា **វជ្ជភីរុនោ** (ជាបុគ្គលខ្លាចដល់ទោស) បានដល់ ជាអ្នកភ័យខ្លាចដល់ទោស ។ បទថា **វជ្ជភយទស្សាវិនោ** (មានប្រក្រតីឃើញទោសព្រោះជារបស់គួរខ្លាច) បានដល់ ឃើញទោសជាភ័យរឿយៗ ។ បទថា... **ឯតំ បាដិកង្ខំ** (គប្បីសង្ឃឹមបាន) សេចក្តីថា សេចក្តីនេះនឹងគប្បីប្រាថ្នាបាន អធិប្បាយថា សេចក្តីនេះនឹងមានពិត ។ បទថា **យំ** ត្រឹមតែជានិបាត ម្យ៉ាងទៀត ជាពាក្យពោលដល់ហេតុ សេចក្តីថា ហេតុជាគ្រឿងរួចផុតចាកទោសទាំងពួង ។

សួរថា ទីងរួចផុតដោយហេតុអ្វី ។ ឆ្លើយថា រួចផុតដោយមគ្គទី ៤ ផង ដោយផលទី ៤ ផង ។ ពិតហើយ បុគ្គលរួចផុតដោយមគ្គ ឈ្មោះថា រមែងរួចផុតក្នុងកាលសម្រេចផលហើយ ឈ្មោះថា រមែងរួចផុតយ៉ាងបរិសុទ្ធ ។ ក៏អកុសល មិនឲ្យផលដល់ព្រះខីណាស្រពឬ ។ ឲ្យផល ។ ដោយអកុសលនោះ លោកធ្វើទុកមុនពេលមិនទាន់សម្រេចជាព្រះខីណាស្រព និងឲ្យផលតែក្នុងអត្តភាពនេះប៉ុណ្ណោះ ក្នុងសម្បរាយភព ផលកម្មមិនមានដល់លោក ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## *"សេចក្តីព្យាយាមកើតបានលំបាក ២ យ៉ាង"*

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៤៨] បទថា **បធានានិ** (សេចក្តីព្យាយាម) បានដល់ វិរិយៈ ។ ពិតណាស់ សេចក្តីព្យាយាម លោកហៅថា **បធានៈ** ព្រោះគួរតាំងទុក ឬព្រោះធ្វើសេចក្តីព្យាយាម ។ បទថា **ទុរភិសម្ភវានិ** (កើតឡើងបានលំបាក) សេចក្តីថា លំបាកនឹងបង្កាប់ គឺ លំបាកនឹងឲ្យប្រព្រឹត្តទៅ អធិប្បាយថា ធ្វើបានលំបាក ។ បទថា **អគារំ អជ្ឈាវសតំ** (អ្នកនៅគ្រប់គ្រងផ្ទះ) បានដល់ អ្នកនៅផ្ទះ ។ ដោយបទថា **ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានុប្បាទនត្ថំ បធានំ** (ចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជបរិក្ខារ) ទ្រង់សម្តែងថា ឈ្មោះថា សេចក្តីព្យាយាមដើម្បីឲ្យបច្ច័យ ៤ មានចីវរជាដើមទាំងនេះកើតឡើង កើតឡើងលំបាក ។ សេចក្តីពិត ការដែលនិយាយថា លោកទាំងឡាយចូរឲ្យសំពត់ត្រឹមតែ ៤ ហត្ថ ឬកត្តាហារអន្តរប្រមាណមួយទុកដៃ ឬបណ្ណសាលាប្រមាណ ៤ ហត្ថ ឬភេសជ្ជៈមានទឹកដោះថ្លា ទឹកដោះខាប់ជាដើមត្រឹមតែបន្តិច ដូច្នេះក្តី ការនាំចេញឲ្យក្តី ធ្វើបានលំបាក ដូចកងទ័ព ២ ចំណែក ចូលធ្វើសង្គ្រាមជាមួយគ្នា ។*

ព្រោះហេតុនោះ ព្រះដ៏មានព្រះភាគទើបត្រាស់ថា

*ទានំ ច យុទ្ធំ ច សមានមាហុ អប្បាបិ សន្តា ពហុកំ ជិនន្តិ*

*អប្បំបិ ចេ សទ្ធហានោ ទទាតិ តេនេវ សោ ហោតិ សុខី បរត្ថ ។*

ទាន និងចំបាំងលោកពោលថាស្មើគ្នា សប្បុរសសូម្បីតិចក៏ឈ្នះ

មនុស្សច្រើនបាន បើមានសទ្ធា សូម្បីនឹងឲ្យតិច គេរមែងមាន

សេចក្តីសុខក្នុងលោកដទៃ ព្រោះហេតុនោះឯង ដូច្នេះ ។

បទថា **អគារស្មា អនគារិយំ បព្វជិតានំ** (អ្នកដែលចេញចាកផ្ទះបួសជាបព្វជិត) សេចក្តីថា ចេញចាកផ្ទះចូលបព្វជ្ជាជាអ្នកមិនមានផ្ទះ វៀរកសិកម្ម និងគោរក្ខកម្មជាដើម ដែលនាំប្រយោជន៍មកដល់ផ្ទះ គឺ ដល់អ្នកគ្រប់គ្រងផ្ទះ ។ បទថា **សព្វុបធិប្បដិនិស្សគ្គត្ថំ បធានំ** (សេចក្តីព្យាយាមដើម្បីលះបង់នូវឧបធិទាំងពួងដ៏ប្រសើរ សេចក្តីថា សេចក្តីព្យាយាមដែលកើតរួមជាមួយវិបស្សនា និងមគ្គ ដើម្បីប្រយោជន៍ព្រះនិព្វាន ពោលគឺ រលាស់ចេញចាកឧបធិ គឺ ខន្ធ កិលេស និងអភិសង្ខារ ។ បទថា **តស្មា** (ព្រោះដូច្នោះ) សេចក្តីថា ព្រោះសេចក្តីព្យាយាម ២ យ៉ាងនេះ កើតបានលំបាក ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## "ធម៌ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ២ យ៉ាង"

*ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៤៩] បទថា* ***តបនីយា*** *(ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ) សេចក្ដីថា ឈ្មោះថា ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ព្រោះពួកសត្វរមែងក្ដៅទាំងក្នុងលោកនេះ និងលោកដទៃ ។ បទថា* ***តប្បតិ*** *(ក្ដៅក្រហាយហើយ) សេចក្ដីថា រមែងក្ដៅក្រហាយ ដោយសេចក្ដីក្ដៅក្រហាយ គឺ រមែងសោកសៅ ដូចនន្ទយក្ខ ដូចនន្ទមាណព ដូចនន្ទគោឃាត ដូចទេវទត្ត និងដូចពីរនាក់បងប្អូន ធ្វើកាយទុច្ចរិត (ក្ដៅក្រហាយហើយ) ។*

*ដំណាលមកថា បងប្អូនពីរនាក់នោះ សម្លាប់គោហើយបែងចែកសាច់ជាពីរចំណែក ។ តពីនោះ ប្អូនប្រុសនិយាយនឹងបងប្រុសថា ខ្ញុំមានក្មេងច្រើននាក់ បងឲ្យពោះគោទាំងនេះមកខ្ញុំចុះ ។ បងនិយាយនឹងប្អូនថា សាច់ទាំងអស់យើងបែងចែកជាពីរចំណែកហើយ ឯងប្រាថ្នាអ្វីទៀត ហើយក៏វាយប្អូនស្លាប់ទៅ តែកាលក្រឡេកមើលឃើញប្អូនស្លាប់ ទើបគិតបានថា យើងធ្វើកម្មធ្ងន់ណាស់ ។ គេក៏សោកសៅ ។ ក្នុងទីឈរក្ដី ទីអង្គុយក្ដី គេនឹកដល់កម្មនោះប៉ុណ្ណោះ មិនបាននូវ*

សេចក្តីសប្បាយចិត្តឡើយ ។ សូម្បីឱជារសដែលគេលេប ផឹក និងទំពារចូលទៅ ក៏មិនជ្រួតជ្រាបក្នុងរាងកាយរបស់គេ ។ រាងកាយរបស់គេក៏មានត្រឹមតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ ។ គ្រានេះ ព្រះថេរៈមួយរូបឃើញគេ ទើបសួរថា ឧបាសក លោកក៏មានបាយទឹកសមល្មម តែដូចម្តេចទើបនៅសល់ត្រឹមតែស្បែកដណ្តប់ឆ្អឹងប៉ុណ្ណោះ លោកមានកម្មអ្វី ដែលធ្វើឲ្យក្តៅចិត្តឬ ។ គេឆ្លើយថា មានលោកម្ចាស់ ហើយប្រាប់រឿងទាំងអស់នោះ ។ ព្រះថេរៈនិយាយចំពោះគេថា ឧបាសក លោកធ្វើកម្មធ្ងន់ លោកខុសក្នុងហេតុដែលមិនគួរខុស ។ គេស្លាប់ទៅ ក៏ទៅកើតក្នុងនរកដោយកម្មនោះឯង ។ បុគ្គលដែលក្តៅក្រហាយព្រោះវចីទុច្ចរិត ដូចជាសុប្បពុទ្ធសក្យៈ ព្រះកោកាលិកៈ និងនាងចិញ្ចាមាណវិកាជាដើម ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*“ធម៌មិនជាទីតាំងនៃសេចក្តីក្តៅក្រហាយ ២ យ៉ាង”*

[២៥០] *ពាក្យដែលនៅសល់ក្នុងសូត្រទី ៤ នេះ មានអត្ថងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

*"គុណរបស់ធម៌ ២ យ៉ាង"*

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៥១] *បទថា* ***ទ្វិនាហំ*** *កាត់បទជា* ***ទ្វិន្នំ អហំ*** *ៗ បទថា* ***ឧបញ្ញាសិ*** *(ដឹងទូទៅ) សេចក្តីថា បានចូលទៅដឹង គឺ ជ្រាបគុណ អធិប្បាយថា ត្រាស់ដឹង ។ ឥឡូវនេះ កាលទឹងទ្រង់សម្តែងធម៌ទាំងនោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា* ***យា ច អសន្តុដ្ឋិតា*** *(ភាពជាអ្នកមិនសន្តោស) ជាដើម ។ ព្រោះព្រះដ៏មានព្រះភាគទ្រង់អាស្រ័យធម៌ ២ នេះ សម្រេចព្រះសព្វញ្ញុតញ្ញាណ ដូច្នោះ កាលទឹងទ្រង់សម្តែងអានុភាពធម៌ ២ យ៉ាងនោះ ទើបត្រាស់យ៉ាងនេះ ។ បណ្តាបទទាំងនោះ បទថា* ***អសន្តុដ្ឋិតា កុសលេសុ ធម្មេសុ*** *(ភាពជាអ្នកមិនសន្តោសក្នុងកុសលធម៌) នេះ ព្រះមានព្រះភាគទ្រង់សម្តែងសេចក្តីដូច្នេះថា តថាគតមិនសន្តោសដោយត្រឹមតែឈាននិមិត្ត ឬដោយត្រឹមតែឱភាសនិមិត្ត ញុំាងអរហត្តមគ្គឲ្យកើតឡើងបានតែម្យ៉ាង គឺ តថាគតមិនសន្តោសក្នុងវេលាដែលអរហត្តមគ្គមិនទាន់កើតឡើង ។ និងតថាគតមិនរួញរាក្នុងសេចក្តីព្យាយាមឡើយ បានធ្វើសេចក្តីព្យាយាម កាលទឹងទ្រង់សម្តែងអត្ថដូចពោលនេះ ទើបត្រាស់ព្រះពុទ្ធវចនៈថា* ***យា ច អប្បដិវាណិតា*** *(ភាពជាអ្នក*

មិនរួញរា) ជាដើម ។

បណ្តាបទទាំងនោះ បទថា **អប្បដិវាណិតា** (ភាពជាអ្នកមិនរួញរា) បាន ដល់ ការមិនបញ្ឈប់ គឺ មិនរួញរា ។ បទថា **សុទំ** ក្នុងបទថា **អប្បដិវាណំ សុទាហំ ភិក្ខវេ បទហាសឹ** (បានឮថា ព្រះតថាគតផ្តើមតាំងសេចក្តីព្យាយាមដែលមិនធូរថយ) ត្រឹមតែជានិបាត ក្នុងសេចក្តីនេះមានន័យដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតតាំងនៅក្នុងសេចក្តីមិនរួញរា ប្រាថ្នាជាព្រះសព្វញ្ញូ បានធ្វើសេចក្តីព្យាយាម កាលនៅជាពោធិសត្វ ។ ឥឡូវនេះ កាលទ្រង់សម្តែងវិធីធ្វើសេចក្តីព្យាយាម ទើបត្រាស់ព្រះពុទ្ធវចនៈថា **កាមំ តចោ ច** (ស្បែក...ក៏ដោយចុះ) ជាដើម ។ បណ្តាបទទាំងនោះ បទថា **យន្តំ** (ផលនោះ) នេះ ទ្រង់សម្តែងគុណជាតដែលនឹងគប្បីសម្រេច ។ ក្នុងបទថា **បុរិសត្ថាមេន** (ដោយកម្លាំងរបស់បុរស) ជាដើម ត្រាស់ដល់កម្លាំងដែលឲ្យកើតញាណ សេចក្តីព្យាយាមដែលឲ្យកើតញាណ សេចក្តីប្រឹងប្រែងដែលឲ្យកើតញាណរបស់បុរស ។ បទថា **សណ្ឋានំ** (ឈប់) បានដល់ នៅ គឺ មិនប្រព្រឹត្តទៅ រួញរា អធិប្បាយថា រម្ងាប់ ។ ដោយព្រះពុទ្ធវចនៈត្រឹមប៉ុណ្ណេះ ឈ្មោះថា ព្រះអង្គត្រាស់សេចក្តីតាំងចិត្តមាំក្នុងការបំពេញព្យាយាមដែលប្រកបដោយអង្គ ៤ ។ ក្នុងទីនេះបទថា **កាមំ តចោ** (ស្បែក) ជាអង្គមួយ ។ បទថា **នហារុ ច** (សរសៃ) ជាអង្គមួយ ។ បទថា **អដ្ឋិ ច** (ឆ្អឹង) ជាអង្គមួយ ។

បទថា **មំសលោហិតំ** (សាច់ និងឈាម) ជាអង្គមួយ ។ អង្គ ៤ នេះឯង ។ បទថា **បុរិសត្ថាមេន** ជាដើម ជាឈ្មោះនៃសេចក្តីព្យាយាមយ៉ាងក្រៃលែង ។ សេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ ខាងដើមដោយប្រការដូច្នេះ តាំងមាំហើយយ៉ាងនេះ គប្បីជ្រាបថា ឈ្មោះថា ការតាំងសេចក្តីព្យាយាមដែលប្រកបដោយអង្គ ៤ ។ ដោយព្រះពុទ្ធវចនៈត្រឹមប៉ុណ្ណេះ គឺ ព្រះអង្គត្រាស់បដិបទាជាហេតុត្រាស់ដឹងធម៌របស់ព្រះអង្គត្រង់ពោធិបល្ល័ង្ក ។

ឥឡូវនេះ ដើម្បីនឹងត្រាស់គុណដែលព្រះអង្គបានមកដោយបដិបទានោះ ទើបត្រាស់ព្រះពុទ្ធវចនៈថា **តស្ស មយ្ហំ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ ដែលតថាគតនោះ) ជាដើម ។ បណ្តាបទទាំងនេះ បទថា **អប្បមាទាធិគតា** (ដែលតថាគតត្រាស់ដឹងហើយដោយសេចក្តីមិនប្រមាទ) សេចក្តីថា បានហើយដោយសេចក្តីមិនប្រមាទ ពោលគឺ ការនៅមិនប្រាសចាកសតិ ។ បទថា **ពោធិ** (ពោធិញ្ញាណ) បានដល់ ចតុមគ្គញ្ញាណ និងសព្វញ្ញុតញ្ញាណ ។ ព្រោះថា បុគ្គលដែលស្រវឹងប្រមាទ មិនអាចសម្រេចចតុមគ្គញ្ញាណ និងសព្វញ្ញុញ្ញាណនោះបាន ព្រោះហេតុដូច្នោះ ព្រះអង្គទើបត្រាស់ថា **អប្បមាទាធិគតា ពោធិ** ដូច្នេះ ។ បទថា **អនុត្តរោ យោគក្ខេមោ** (ធម៌ដែលជាដែនក្សេមចាកយោគៈដ៏ប្រសើរ) សេចក្តីថា មិនមែនបញ្ញាជាគ្រឿងត្រាស់ដឹងតែម្យ៉ាងប៉ុណ្ណោះ សូម្បីធម៌ដែលរួចផុតចាកគ្រឿង

អ្នកដែលកំពូល ពោលគឺ អរហត្តផល និព្វាន តថាគតក៏បានសម្រេចព្រោះសេចក្តីមិនប្រមាទនោះឯង ។

ឥឡូវនេះ កាលនឹងទ្រង់ឲ្យភិក្ខុសង្ឃកាន់យកក្នុងគុណដែលព្រះអង្គបានមក ទើបត្រាស់ព្រះពុទ្ធវចនៈថា **តុម្ហេ ចេបិ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយ សូម្បីអ្នកទាំងឡាយ) ជាដើម ។ បណ្តាបទទាំងនេះ បទថា **យស្សត្ថាយ** (ដើម្បីសេចក្តីត្រូវការ) សេចក្តីថា ដើម្បីប្រយោជន៍ដល់ផលដែលជាទីបំផុតនៃព្រហ្មចរិយៈ យ៉ាងណា អធិប្បាយថា ជាអ្នកប្រាថ្នាដើម្បីនឹងចូលដល់ផលដែលជាទីបំផុតនៃព្រហ្មចរិយៈណា ។ បទថា **ព្រហ្មចរិយបរិយោសានំ** (ទីបំផុតនៃព្រហ្មចរិយៈ) បានដល់អរិយផលដែលជាទីបំផុតនៃមគ្គព្រហ្មចរិយៈ ។ បទថា **អភិញ្ញា សច្ឆិកត្វា** (ធ្វើឲ្យជាក់ច្បាស់ដោយញាណដ៏ក្រៃលែង) សេចក្តីថា ធ្វើឲ្យប្រចក្សដោយបញ្ញាដ៏ក្រៃលែង គឺ ដោយបញ្ញាដែលខ្ពស់បំផុត ។ បទថា **ឧបសម្បជ្ជ វិហរិស្សថ** (នឹងចូលដល់ហើយ) សេចក្តីថា នឹងបានចំពោះ គឺ ត្រាស់ដឹងហើយ ។ បទថា **តស្មា** (ព្រោះហេតុនោះ) សេចក្តីថា ព្រោះធម្មតា សេចក្តីព្យាយាមដែលមិនរួញរានេះមានឧបការៈច្រើន ឲ្យសម្រេចប្រយោជន៍ហើយ ។

ចប់អដ្ឋកថា សូត្រទី៥

# អដ្ឋកថាសូត្រទី ៦

## *សេចក្តីពេញចិត្ត និងសេចក្តីនឿយណាយក្នុងធម៌ ដែលជាបច្ច័យនៃសំយោជនៈ*

*ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៥២] បទថា **សញ្ញោជនិយេសុ ធម្មេសុ** (ក្នុងធម៌ដែលជាបច្ច័យនៃសំយោជនៈ) សេចក្តីថា ក្នុងធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាបច្ច័យនៃសញ្ញោជនៈ ១០ ។ បទថា **អស្សាទានុបស្សិតា** (ការពិចារណាឃើញដោយសេចក្តីពេញចិត្ត) សេចក្តីថា ការឃើញ គឺ ភាវៈដែលឃើញ ដោយអស្សាទៈ (គួរត្រេកអរ) ។ បទថា **និព្វិទានុបស្សិតា** (ការពិចារណាឃើញដោយអំណាចសេចក្តីនឿយណាយ) សេចក្តីថា ការឃើញដោយអំណាចសេចក្តីនឿយណាយ គឺ ដោយអំណាចសេចក្តីធុញទ្រាន់ ។ បទថា **ជាតិយា** (ចាកជាតិ) បានដល់ ចាកការកើតនៃខន្ធ ។ បទថា **ជរាយ** (ចាកជរា) បានដល់ ចាកសេចក្តីចាស់នៃខន្ធ ។ បទថា **មរណេន** (ចាកមរណៈ) បានដល់ ចាកការបែកធ្លាយនៃខន្ធ ។ បទថា **សោកេហិ** (ចាកសោកៈ) បានដល់ ចាកពីសេចក្តីសោកដែលមានលក្ខណៈក្រៀមក្រំខាងក្នុង ។ បទថា **បរិទេវេហិ** (ចាកបរិទេវៈ) បានដល់ ចាកសេចក្តី*

ទួញយំដែលមានលក្ខណៈរៀបរាប់អាស្រ័យសេចក្ដីសោកនោះ ។ បទថា **ទុក្ខេហិ** (ចាកទុក្ខ) បានដល់ ចាកទុក្ខដែលបៀតបៀនកាយ ។ បទថា **ទោមនស្សេហិ** (ចាកទោមនស្ស) បានដល់ ចាកទោមនស្សដែលបៀតបៀនចិត្ត ។ បទថា **ឧបា-យាសេហិ** (ចាកឧបាយាសៈ) បានដល់ ចាកសេចក្ដីចង្អៀតចង្អល់ដែលមានលក្ខណៈចង្អៀតចិត្តយ៉ាងក្រៃលែង ។ បទថា **ទុក្ខស្មា** (ចាកទុក្ខ) បានដល់ ចាកទុក្ខក្នុងវដ្ដៈទាំងអស់ ។ បទថា **បជហាតិ** (រមែងលះបង់បាន) បានដល់ រមែងលះបង់បានដោយមគ្គ ។ ក្នុងបទថា **បហាយ** (លះបានហើយ) នេះ ត្រាស់ខណៈនៃផល ។ ក្នុងសូត្រនេះ ត្រាស់ទាំងវដ្ដៈ និងវិវដ្ដៈ ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## "ធម៌ចំណែកខ្មៅ ២ យ៉ាង"

ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៥៣] បទថា **កណ្ហា** (ចំណែកខ្មៅ) សេចក្តីថា មិនមែនជាធម៌ចំណែកខ្មៅ ព្រោះមានពណ៌ខ្មៅ តែបង្អោនដើម្បីជាធម៌ខ្មៅ ព្រោះដូច្នោះ ទើបឈ្មោះថាជាធម៌ចំណែកខ្មៅ ព្រោះជាធម៌ចំណែកខ្មៅដោយផលសម្រេច ម្យ៉ាងទៀត កាលពោលដោយកិច្ច (គឺនាទី) របស់ខ្លួន អកុសលធម៌ទាំងអស់ ជាធម៌ចំណែកខ្មៅទាំងនោះឯង ព្រោះថា ចិត្តរមែងផូរផង់មិនបាន ព្រោះអកុសលធម៌ទាំងនោះកើតឡើង ។ បទថា **អហិរិកំ** ប្រែថាមិនមានការខ្មាស ។ បទថា **អនោត្តប្បំ** ប្រែថាមិនមានការខ្លាចក្រែង ។

ចប់អដ្ឋកថា សូត្រទី៧

# អដ្ឋកថាសូត្រទី ៨

## *"ធម៌ចំណែកស ២ យ៉ាង"*

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៥៤] *បទថា* ***សុក្កា*** *(ចំណែកស) សេចក្ដីថា មិនមែនជាធម៌ចំណែកស ព្រោះមានពណ៌ស តែបង្អោនទៅដើម្បីជាធម៌ចំណែកស ព្រោះដូច្នោះ ទើបឈ្មោះថា ធម៌ចំណែកស ព្រោះជាធម៌ចំណែកសដោយផលសម្រេច ម្យ៉ាងទៀត កាលពោលអំពីកិច្ច (គឺនាទី) របស់ខ្លួន កុសលធម៌ទាំងអស់ជាធម៌ចំណែកសទាំងនោះឯង សេចក្ដីថា ចិត្ត រមែងថ្លាផូរផង់ ព្រោះកុសលធម៌ទាំងនោះកើតឡើង ។ ក្នុងពាក្យថា* ***ហិរិ ច ឱត្តប្បញ្ច*** *(ហិរិ ១ ឱតប្បៈ ១) នេះ ហិរិមានលក្ខណៈខ្មាសបាប ឱត្តប្បៈមានលក្ខណៈខ្លាចបាប ។ មួយទៀត ពាក្យដែលគប្បីពោលឲ្យពិស្ដារក្នុងទីនេះ បានពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។*

ចប់អដ្ឋកថា សូត្រទី៨

# អដ្ឋកថាសូត្រទី ៩

## *"លោកបញ្ញត្តិថាមាតាជាដើម ព្រោះអាស្រ័យធម៌ស ២ យ៉ាង"*

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៥៥] បទថា* ***លោកំ បាលេន្តិ*** *(រមែងរក្សាលោក) សេចក្តីថា រមែងតាំងលោកទុក គឺ ឲ្យស្ថិតនៅ បានដល់ រក្សាទុក ។ បទថា* ***នយិធ បញ្ញាយេថ មាតា*** *(នរណាៗ ក្នុងលោកនេះមិនគប្បីបញ្ញត្តិថាមាតា) សេចក្តីថា មាតាអ្នកឲ្យកំណើតក្នុងលោកនេះ នឹងមិនគប្បីប្រាកដជាទីគោរពរាប់អានថា ស្ត្រីនេះជាមាតារបស់យើង សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ បទថា* ***សម្ភេទំ*** *(ប្រឡូកប្រឡំ) បានដល់ ការលាយឡំគ្នា ឬការមិនមានដែនកំណត់ ។ ក្នុងបទថា* ***យថា អជេឡកា*** *(ដូចពួកសត្វពពែ ពួកសត្វចៀម) ជាដើមមានវិនិច្ឆ័យថា ព្រោះថាសត្វទាំងនោះរមែងមិនមានស្មារតីក្នុងការគោរពរាប់អានថា ស្ត្រីនេះជាមាតារបស់យើង ឬថា ជាមា-មីងរបស់យើង រមែងបដិបត្តិខុសក្នុងវត្ថុដែលខ្លួនបានអាស្រ័យកើតឡើងនុ៎ះឯង ដូច្នោះ កាលទ្រង់ប្រៀបធៀប ទើបត្រាស់ព្រះពុទ្ធវចនៈថា* ***យថា អជេឡកា*** *ជាដើម ។*

ចប់អដ្ឋកថា សូត្រទី៩

# អដ្ឋកថាសូត្រទី ១០

## *"ពោលដោយវស្សូបនាយិកា ២ យ៉ាង"*

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៥៦] *សូត្រនេះ ព្រះមានព្រះភាគត្រាស់ ព្រោះមានហេតុឲ្យកើតរឿង អ្វីជាហេតុឲ្យកើតរឿង ការពោលទោសរបស់ពួកមនុស្សជាហេតុឲ្យកើតរឿង ។ មានរឿងថា ២០ វស្សា ក្នុងបឋមពោធិកាល ព្រះមានព្រះភាគទ្រង់មិនបានបញ្ញត្តិថ្ងៃចូលវស្សា ភិក្ខុទាំងឡាយ មិនមានការជំពាក់ក្នុងរឿងវស្សា បានចារិកទៅតាមសប្បាយទាំងក្នុងរដូវក្ដៅ ទាំងក្នុងរដូវរងារ ទាំងក្នុងរដូវភ្លៀង ។ ពួកមនុស្សឃើញដូច្នោះ នាំគ្នាពោលទោសមានពាក្យជាដើមថា ហេតុដូចម្ដេចព្រះសមណៈ-សក្យបុត្រ នាំគ្នាចារិកទាំងរដូវត្រជាក់ ទាំងរដូវក្ដៅ ទាំងរដូវភ្លៀង ជាន់ស្មៅទើបនឹងលាស់ បៀតបៀនវត្ថុមានជីវិត ធ្វើសត្វតូចៗ ដ៏ច្រើនឲ្យលំបាក សូម្បីពួកអន្យ-តិរ្ថិយដែលពោលធម៌មិនល្អ មិនប្រពៃទាំងនោះ ក៏ឈប់សម្រាកពេលភ្លៀង សត្វទាំងឡាយនៅធ្វើសំបុកត្រង់ចុងឈើ ឈប់សម្រាកពេលភ្លៀង ដូច្នេះ ។ ភិក្ខុទាំងឡាយក្រាបទូលរឿងនោះចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់លើករឿងនោះឲ្យជាហេតុ ទ្រង់សម្ដែងសូត្រនេះ ត្រាស់ព្រះពុទ្ធតម្រាស់ជាដំបូងត្រឹម*

ប៉ុណ្ណេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចូលចាំវស្សា ដូច្នេះ ។ តមក ទ្រង់ជ្រាបថា ពួកភិក្ខុកើតវិតក្កៈថា គួរចូលចាំវស្សាពេលណា ទើបត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យចូលចាំវស្សាក្នុងរដូវភ្លៀង ។ តមក ភិក្ខុទាំង ឡាយសង្ស័យថា ថ្ងៃចូលវស្សាមានប៉ុន្មានថ្ងៃ នាំគ្នាក្រាបទូលសេចក្តីនោះចំពោះ ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់ជ្រាបដូច្នោះ កាលទ្រង់សម្តែងសូត្រ នេះទាំងអស់ ទើបត្រាស់ព្រះពុទ្ធតម្រាស់ជាដើមថា **ទ្វេមា ភិក្ខវេ** (ម្នាលភិក្ខុទាំង ឡាយ វស្សូបនាយិកា ២ យ៉ាងនេះ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **វស្សូ-បនាយិកា** បានដល់ ថ្ងៃចូលវស្សា ។ បទថា **បុរិមិកា** (ដើម) សេចក្តីថា កាល ដល់ថ្ងៃ ១ រោច ខែ ៨ គប្បីចូលវស្សា ៣ ខែដំបូង មានថ្ងៃពេញបូណ៌មី ខែ ១១ ជាទីបំផុត ។ បទថា **បច្ឆិមិកា** (ក្រោយ) សេចក្តីថា កាលខែ ៨ កន្លងទៅ គប្បី ចូលវស្សា ៣ ខែក្រោយ មានថ្ងៃពេញបូណ៌មី ខែ ១២ ជាទីបំផុត ។

ចប់អដ្ឋកថា សូត្រទី ១០

## ចប់កម្មករណវគ្គទី ១

## ក្នុងវគ្គនេះ មាន ១០ សូត្រ

# អធិករណវគ្គទី ២

## អដ្ឋកថាសូត្រទី ១

### *"ពោលអំពីពលៈ ២ យ៉ាង"*

*អធិករណវគ្គទី ២ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៥៧] បទថា **ពលានិ** (ពលៈ) សេចក្តីថា ឈ្មោះថា ពលៈ ដោយអត្ថដូចម្តេច ឈ្មោះថា ពលៈ ដោយអត្ថថា មិនជាទីតាំងនៃសេចក្តីញាប់ញ័រ គឺដោយអត្ថថា គ្របសង្កត់បានលំបាក និងញាំញីមិនបាន ។ បទថា **បដិសង្ខានពលំ** បានដល់ កម្លាំង គឺ ការពិចារណា ។ បទថា **ភាវនាពលំ** បានដល់ កម្លាំង គឺ ការចម្រើន គឺ កម្លាំង គឺ ការវឌ្ឍនា ។ បទថា **សុទ្ធំ អត្តានំ** (រក្សាខ្លួនឲ្យបរិសុទ្ធិ) នេះ គប្បីជ្រាបតាមន័យដែលពោលហើយក្នុងខាងក្រោយនោះឯង ។ បទថា **តត្រ** (ក្នុង...នោះ) បានដល់ ក្នុងពលៈ ២ យ៉ាងនោះ ។ បទថា **យទិទំ** កាត់បទជា **យំ ឥទំ** (នេះណា) ។ បទថា **សេក្ខមេតំ ពលំ** (ពលៈរបស់ព្រះសេក្ខៈ) សេចក្តីថា ភាវនាពលៈនោះ បានដល់ កម្លាំងញាណរបស់ព្រះសេក្ខៈ ៧ ពួក ។ បទថា **សេក្ខំ ហិ សោ ភិក្ខវេ ពលំ អាគម្ម** (ក៏បុគ្គលនោះអាស្រ័យពលៈជារបស់ព្រះសេក្ខៈ) សេចក្តីថា ប្រារព្ធ សំដៅ គឺ អាស្រ័យកម្លាំងញាណ*

របស់ព្រះសេក្ខៈ ៧ ពួក ។ បទថា **បជហតិ** (រមែងលះបានដោយសមុច្ឆេទ) សេចក្តីថា លះបានដោយមគ្គ ។ ដោយបទថា **បហាយ** (លុះលះបានជាសមុច្ឆេទហើយ) នេះ ត្រាស់ដល់ផល ។ បទថា **យំ បាបំ** (កម្មដែលជាបាប) សេចក្តីថា វត្ថុណាជាបាប គឺ លាមក ។ ក៏ព្រោះបុគ្គលចម្រើនពលៈទាំង ២ យ៉ាង ទាំងនេះហើយ ទើបសម្រេចព្រះអរហត្តបាន ដូច្នោះ គប្បីជ្រាបថា ពលៈដ៏កំពូល ទ្រង់មិនបានចាត់ទុកក្នុងទីនេះ ។

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*"ពលៈ ២ យ៉ាង (មួយ៉ាងទៀត)"*

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៥៨] ក្នុងបទថា **សតិសម្ពោជ្ឈង្គំ ភាវេតិ** (រមែងចម្រើនសតិសម្ពោ-ជ្ឈង្គៈ) ជាដើម មានពណ៌នាសេចក្តីនៃបទដែលមិនទាន់មានមកក្នុងខាងក្រោយដូច្នេះ ។ បទថា **វិវេកនិស្សិតំ** (ដែលអាស្រ័យវិវេក) បានដល់ អាស្រ័យភាពស្ងប់ស្ងាត់ ។ ភាពស្ងប់ស្ងាត់ ឈ្មោះថា វិវេក ។ វិវេកដូចពោលនេះ មាន ៥ យ៉ាង គឺ តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និងនិស្សរណវិវេក ។ ក្នុងវិវេក ៥ យ៉ាងនោះ ក្នុងបទថា **វិវេកនិស្សិតំ** (អាស្រ័យវិវេក) គប្បីជ្រាបសេចក្តីថា ភិក្ខុចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យតទង្គវិវេក អាស្រ័យសមុច្ឆេទវិវេក និងអាស្រ័យនិស្សរណវិវេក ។ ពិតហើយ ព្រះយោគីអ្នកបំពេញសតិសម្ពោជ្ឈង្គភាវនា ក្នុងខណៈវិបស្សនា រមែងចម្រើនសតិសម្ពោជ្ឈង្គអាស្រ័យតទង្គវិវេកដោយកិច្ច អាស្រ័យនិស្សរណវិវេកដោយអជ្ឈាស្រ័យ តែក្នុងខណៈមគ្គ អាស្រ័យសមុច្ឆេទវិវេកដោយកិច្ច អាស្រ័យនិស្សរណវិវេកដោយអារម្មណ៍ ។ អាចារ្យពួកខ្លះពោលថា អាស្រ័យវិវេកទាំង ៥ យ៉ាងក៏មាន ។ ពិតហើយ អាចារ្យ*

ទាំងនោះ មិនមែនលើកពោជ្ឈង្គៈទាំងឡាយឡើងក្នុងខណៈនៃពលវិបស្សនា មគ្គ និងផលចិត្តតែម្យ៉ាងប៉ុណ្ណោះ សូម្បីក្នុងកសិណឈាន អានាបានស្សតិ អសុភកម្មដ្ឋាន និងព្រហ្មវិហារឈាន ដែលជាបាទនៃវិបស្សនា ក៏លើកឡើងផង តែព្រះអដ្ឋកថាចារ្យទាំងឡាយក៏មិនបដិសេធ ដូច្នោះ តាមមតិរបស់អាចារ្យទាំងនោះ ក្នុងខណៈដែលកំពុងប្រព្រឹត្តទៅនៃឈានទាំងនោះ អាស្រ័យវិក្ខម្ភនវិវេកដោយកិច្ចប៉ុណ្ណោះ ដូចដែលពោលថា ក្នុងខណៈវិបស្សនា អាស្រ័យនិស្សរណវិវេកដោយអជ្ឈាស្រ័យ យ៉ាងណា ក៏គួរនឹងពោលថា ចម្រើនសតិសម្ពោជ្ឈង្គដែលអាស្រ័យបដិបស្សទ្ធិវិវេកក៏បាន ដូច្នោះ ។ សូម្បីក្នុងសតិសម្ពោជ្ឈង្គដែលអាស្រ័យវិរាគៈជាដើម ក៏ន័យនេះដូចគ្នា ។ ធម៌មានវិរាគៈជាដើម មានអត្ថថា ស្ងាត់ដូចគ្នា ។ ក៏ការលះក្នុងបទថា **វោស្សគ្គបរិណាមី** (បង្អោនទៅក្នុងការលះ) នេះ មាន ២ យ៉ាងប៉ុណ្ណោះ គឺ ការលះដោយបរិច្ចាគ ១ ការលះដោយស្ទុះទៅ ១ ។ ក្នុង ២ យ៉ាងនោះ បទថា **បរិច្ចាគវោស្សគ្គោ** (ការលះដោយបរិច្ចាគ) បានដល់ ការលះកិលេសដោយខណៈ ក្នុងខណៈវិបស្សនា និងជាសមុច្ឆេទក្នុងខណៈមគ្គ ។ បទថា **បក្ខន្ទនវោស្សគ្គោ** (ការលះដោយស្ទុះទៅ) បានដល់ ការស្ទុះទៅកាន់ព្រះនិព្វាន ដោយបង្អោនទៅក្នុងព្រះនិព្វាននោះ ក្នុងខណៈវិបស្សនា , តែធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ក្នុងខណៈមគ្គ ដោយធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ។ ការលះទាំង ២ យ៉ាង

នោះ រមែងមានក្នុងសតិសម្ពោជ្ឈង្គៈ ដែលលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ នេះ តាមន័យដែលមកក្នុងអដ្ឋកថា ។ ពិតហើយ សតិសម្ពោជ្ឈង្គៈនេះ រមែងលះកិលេស ស៊ុះទៅកាន់ព្រះនិព្វាន ដោយប្រការដូចពោលហើយ ។ មួយទៀត ដោយពាក្យទាំងអស់ថា **វោស្សគ្គបរិណាមី** (បង្អោនទៅក្នុងការលះ) នេះ លោកអធិប្បាយដូច្នេះថា តាំងនៅក្នុងការលះ គឺ ដែលកំពុងបង្អោនទៅក៏បង្អោនទៅ និងដែលកំពុងចាស់ក្លាក៏នឹងចាស់ក្លាទៅ ។ ភិក្ខុដែលបំពេញពោជ្ឈង្គការនានេះ រមែងចម្រើនសតិសម្ពោជ្ឈង្គៈ ដោយប្រការដែលសតិសម្ពោជ្ឈង្គៈចាស់ក្លា និងនឹងចាស់ក្លាហើយ ដើម្បីការលះ គឺ ការលះបង់កិលេស ដើម្បីការលះ គឺ ស៊ុះទៅកាន់ព្រះនិព្វាន ។ សូម្បីក្នុងពោជ្ឈង្គៈដ៏សេសក៏ន័យនេះដូចគ្នា ។ ក៏ព្រះនិព្វាននេះឯង លោកពោលថា **វិវេក** ព្រោះស្ងាត់ចាកសង្ខតធម៌គ្រប់យ៉ាង ពោលថា **វិរាគៈ** ព្រោះប្រាសចាកសង្ខតធម៌គ្រប់យ៉ាង ពោលថា **និរោធ** ព្រោះជាធម៌ដែលរលត់សង្ខតធម៌ ។ ក៏មគ្គនោះឯង ឈ្មោះថា បង្អោនទៅក្នុងការលះ ព្រោះដូច្នោះ ភិក្ខុចម្រើនសតិសម្ពោជ្ឈង្គៈដែលអាស្រ័យវិវេក ដោយធ្វើវិវេកឲ្យជាអារម្មណ៍ប្រព្រឹត្តទៅ អាស្រ័យវិរាគៈ អាស្រ័យនិរោធ ក៏ដូចគ្នា ។ សតិសម្ពោជ្ឈង្គៈនោះឯង បង្អោនទៅហើយ ចាស់ក្លាហើយ ដោយលះកិលេស ព្រោះកម្ចាត់កិលេសបាន ដោយសមុច្ឆេទ ក្នុងខណៈអរិយមគ្គកើតឡើង ដោយស៊ុះទៅកាន់ព្រះនិព្វាននោះឯង

គប្បីឃើញអត្ថនេះ ដូចពោលមកដូច្នេះឯង ។ សូម្បីក្នុងពោជ្ឈង្គៈដ៏សេស ក៏ន័យនេះដូចគ្នា ។ ពោជ្ឈង្គៈទាំង ៧ នេះ ព្រះមានព្រះភាគត្រាស់លាយគ្នា ទាំងជាលោកិយៈ និងលោកុត្តរៈ ដោយប្រការដូច្នេះ ភាវៈដ៏ប្រសើរក្នុងពលៈទាំង ២ នេះ គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។

ចប់អដ្ឋកថា សូត្រទី២

# អដ្ឋកថាសូត្រទី ៣

## *"ពលៈ ២ យ៉ាង (ន័យមួយទៀត)"*

*ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៥៩] *សេចក្ដីព្រះបាលីរបស់ឈាន ៤ ថា* ***វិវិច្ចេវ កាមេហិ*** *(ស្ងាត់ចាកកាម) ជាដើម និងន័យនៃភាវនា បានពោលទុកពិស្ដារក្នុងគម្ពីរវិសុទ្ធិមគ្គដោយប្រការទាំងពួងនោះឯង ។ ក៏ឈានទាំង ៤ នេះ ភិក្ខុមួយរូបចម្រើនដើម្បីត្រូវការឲ្យចិត្តតម្កល់មាំ មួយរូបចម្រើនដើម្បីត្រូវការជាបាទនៃវិបស្សនា មួយរូបចម្រើនដើម្បីត្រូវការជាបាទនៃអភិញ្ញា មួយរូបចម្រើនដើម្បីត្រូវការជាបាទនៃនិរោធ មួយរូបចម្រើនដើម្បីសេចក្ដីវិសេសនៃភព ។ តែក្នុងសូត្រនេះ ឈានទាំង ៤ ពួកនោះទ្រង់បំណងជាបាទនៃវិបស្សនា ។ ពិតណាស់ ភិក្ខុនេះចូលដល់ឈានទាំងនេះហើយ ចេញចាកសមាបត្តិ ពិចារណាសង្ខារ កំណត់ហេតុបច្ច័យ និងកំណត់នាមរូប ព្រមទាំងបច្ច័យ ប្រមូលឥន្ទ្រិយ ពលៈ និងពោជ្ឈង្គៈ សម្រេចព្រះអរហត្ត ។ ឈានទាំងនេះ ព្រះមានព្រះភាគត្រាស់លាយគ្នាទាំងជាលោកិយៈ និងជាលោកុត្តរៈ ។ មួយទៀត ភាវៈដ៏ប្រសើរក្នុងពលៈ ២ សូម្បីនេះ គប្បីជ្រាបតាមន័យដែលពោលហើយនុ៎ះឯង ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## "ធម្មទេសនារបស់ព្រះតថាគត ២ យ៉ាង"

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៦០] ដោយបទថា **សង្ខិត្តេន ច វិត្ថារេន ច** (ដោយសង្ខេប ១ ដោយពិស្តារ ១) ព្រះមានព្រះភាគទ្រង់សម្តែងថា ធម្មទេសនាមាន ២ ប៉ុណ្ណោះ គឺធម្មទេសនាដោយសង្ខេប ធម្មទេសនាដោយពិស្តារ ។ ក្នុង ២ យ៉ាងនោះ ទេសនាដែលត្រាស់សម្តែងចំពោះមាតិកា ឈ្មោះថា ទេសនាដោយសង្ខេប ។ ទេសនាដែលត្រាស់ចែកមាតិកានោះៗ ដោយល្អិតល្អន់ ឈ្មោះថា ទេសនាដោយពិស្តារ ។ ម្យ៉ាងទៀត ទេសនាដែលទ្រង់តាំងមាតិកាក្តី ទ្រង់មិនតាំងក្តី ត្រាស់ចែកដោយពិស្តារ ឈ្មោះថា ទេសនាដោយពិស្តារ ។ ក្នុងទេសនា ២ យ៉ាងនោះ ទេសនាដោយសង្ខេបត្រាស់ដល់បុគ្គលដែលមានបញ្ញាច្រើន ទេសនាដោយពិស្តារត្រាស់ដល់បុគ្គលដែលមានបញ្ញាតិច ។ ព្រោះទេសនាដោយពិស្តារ រមែងយឺតយូរដល់អ្នកមានបញ្ញាច្រើន ។ ទេសនាដោយសង្ខេប រមែងដូចជាទន្សាយលោត ដល់អ្នកមានបញ្ញាតិច មិនអាចចាប់ខាងដើមខាងចុងបាន ។ មួយទៀត ទេសនាដោយសង្ខេប ត្រាស់ដល់បុគ្គលប្រភេទឧគ្ឃដិតញ្ញូ ទេសនាដោយពិស្តារត្រាស់ដល់បុគ្គល

៣ ប្រភេទក្រៅនេះ (វិបចិត្តញ្ញូ នេយ្យៈ បទបរមៈ) ។ ព្រះត្រៃបិដកទាំងអស់ រមែង

រាប់ចូលក្នុងប្រការនេះថា ទេសនាដោយសង្ខេប ទេសនាដោយពិស្ដារទុំះឯង ។

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

*"ហេតុឲ្យអធិករណ៍ប្រព្រឹត្តទៅយូរ និងមិនប្រព្រឹត្តទៅយូរ"*

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៦១] *បទថា* ***យស្មឹ ភិក្ខវេ អធិករណេ*** *(ម្នាលភិក្ខុទាំងឡាយ ក្នុងអធិករណ៍) សេចក្តីថា ក្នុងអធិករណ៍ណា ក្នុងបណ្តាអធិករណ៍ ៤ ទាំងនេះ គឺ វិវាទាធិករណ៍ អនុវាទាធិករណ៍ អាបត្តាធិករណ៍ និងកិច្ចាធិករណ៍ ។ បទថា* ***អាបន្នោ ច ភិក្ខុ*** *ប្រែថា ភិក្ខុអ្នកត្រូវអាបត្តិ ។ បទថា* ***សស្មេតំ*** *កាត់បទជា* ***តស្មឹ ឯតំ*** *ប្រែថា ក្នុងអធិករណ៍នោះ ប្រការដែលគប្បីសង្ឃឹមនោះ ។ បទថា* ***ទីឃត្តាយ*** *(ដើម្បីតាំងនៅយូរ) បានដល់ ដើម្បីតាំងនៅអស់កាលយូរ ។ បទថា* ***ខរត្តាយ*** *(ដើម្បីសេចក្តីរឹងរូស) បានដល់ ដើម្បីពោលវាចាគ្រោតគ្រាតយ៉ាងនេះថា លោកជាទាសៈ ជាមនុស្សក្បាលត្រងិល ជាមនុស្សចណ្ឌាល ជាជាងតម្បាញ ។ បទថា* ***វាឡត្តាយ*** *(ដើម្បីសេចក្តីកោងកាច) បានដល់ ដើម្បីប្រទូស្ត គឺ ប្រហារដោយដុំថ្ម ដុំដី និងកំណាត់ឈើជាដើម ។ បទថា* ***ភិក្ខុ ច ន ផាសុំ វិហរិស្សន្តិ*** *(និងភិក្ខុទាំងឡាយ នឹងនៅមិនជាសុខ) សេចក្តីថា កាលភិក្ខុសង្ឃវិវាទគ្នា ភិក្ខុដែលបំណងនឹងរៀនឧទ្ទេស ឬបរិបុច្ឆា ឬបំណងនឹងបំពេញព្យាយាមទាំងនោះ នឹងនៅ*

មិនជាសុខ ។ កាលភិក្ខុសង្ឃធ្វើឧបោសថ ឬបវារណា ភិក្ខុដែលមានសេចក្ដីត្រូវការឧទ្ទេសជាដើម រមែងមិនអាចរៀនឧទ្ទេសជាដើមបាន ពួកភិក្ខុអ្នកចម្រើនវិបស្សនា រមែងមិនមានចិត្តមានអារម្មណ៍តែមួយ តពីនោះ ក៏មិនអាចឲ្យគុណវិសេសកើតបាន ភិក្ខុទាំងឡាយនឹងនៅមិនជាសុខដោយអាការយ៉ាងនេះឯង ។ ក្នុងបទថា **ន ទីឃត្តាយ** ជាដើម គប្បីជ្រាបសេចក្ដីដោយន័យដូចនឹងដែលពោលហើយ ។ បទថា **ឥធ** (ក្នុងធម្មវិន័យនេះ) បានដល់ ក្នុងសាសនានេះ ។ បទថា **ឥតិ បដិសញ្ចិក្ខតិ** បានដល់ ពិចារណាហើយយ៉ាងនេះ ។ បទថា **អកុសលំ** ក្នុងបទថា **អកុសលំ អាបន្នោ** (ត្រូវអាបត្តិដែលជាអកុសល) នេះ ទ្រង់សំដៅដល់អាបត្តិ សេចក្ដីថា ត្រូវអាបត្តិ ។ បទថា **កិញ្ចិទេវ ឯសំ** (ណានីមួយ) សេចក្ដីថា មិនមែនអាបត្តិទាំងអស់ តែជាអាបត្តិចំណែកខ្លះប៉ុណ្ណោះ អធិប្បាយថា អាបត្តិខ្លះៗ ។ បទថា **កាយេន** (ត្រូវដោយកាយ) បានដល់ ករជកាយ ។ បទថា **អនត្តមនោ** (ជាអ្នកមិនពេញចិត្ត) បានដល់ មានចិត្តមិនត្រេកអរ ។ បទថា **អនត្តមនវាចំ** (អ្នកមានវាចាមិនជាទីពេញចិត្ត) បានដល់ វាចាមិនគួរត្រេកអរ ។ បទថា **មមេវ** (ចំពោះយើងប៉ុណ្ណោះ) បានដល់ ដល់យើងតែម្នាក់ ។ បទថា **តត្ថ** (ក្នុង...នោះ) បានដល់ ក្នុងហេតុនោះ ។ បទថា **អច្ចយោ អច្ចគមា** (ទោសទើបគ្របសង្កត់) សេចក្ដីថា កំហុសបានកន្លងល្មើសញាំញី (ខ្ញុំ) ខ្ញុំតែម្នាក់មានកំហុសក្នុងរឿងនេះ ។

បទថា *សុំកទាយិកំវ ភណ្ឌស្មឹ* (ដូចជាទោសត្រូវអ្នកថ្វាយសួយ ព្រោះនាំរបស់គេចពន្ធ ដូច្នោះ) សេចក្ដីថា កាលនាំទំនិញគេចពន្ធ កំហុសរមែងធ្លាក់ដល់អ្នកនាំទំនិញគេចពន្ធ គេជាអ្នកខុសក្នុងរឿងនោះ មិនមែនព្រះរាជា មិនមែនរាជបុរស ។ លោកអធិប្បាយថា បុគ្គលណានាំទំនិញគេចពន្ធ ដែលព្រះរាជាទ្រង់តាំងទុក ពួករាជបុរសយករទេះនាំបុគ្គលនោះព្រមទាំងទំនិញមកសម្ដែងដល់ព្រះរាជា ទោសមិនមានដល់ទំនិញ មិនមានដល់ព្រះរាជា មិនមានដល់ពួករាជបុរស តែទោសមានដល់បុគ្គលដែលគេចពន្ធប៉ុណ្ណោះ ភិក្ខុនោះក៏ដូច្នោះនុ៎ះឯង ត្រូវអាបត្តិណាហើយក្នុងរឿងនោះ អាបត្តិនោះមិនមានទោស ភិក្ខុដែលចោទក៏មិនមានទោស តែភិក្ខុអ្នកត្រូវអាបត្តិប៉ុណ្ណោះ មានទោសដោយហេតុ ៣ ប្រការ គឺ គេមានទោស ព្រោះជាអ្នកត្រូវអាបត្តិខ្លះ មានទោសព្រោះភិក្ខុអ្នកចោទក៏មិនពេញចិត្តខ្លះ មានទោសព្រោះមានអ្នកមិនពេញចិត្តប្រាប់អាបត្តិដល់អ្នកដទៃខ្លះ ។ តែចំពោះភិក្ខុអ្នកចោទក៏លោកបានឃើញភិក្ខុនោះត្រូវអាបត្តិ ក្នុងប្រការនោះមិនមានទោស តែមានទោសព្រោះចោទក៏ដោយសេចក្ដីមិនពេញចិត្ត ភិក្ខុនេះ សូម្បីមិនដាក់ចិត្តដល់ប្រការនោះក៏ពិចារណាឃើញទោសរបស់ខ្លួន ឈ្មោះថា រមែងពិចារណាយ៉ាងនេះ ដូច្នេះថា ទោសក្នុងហេតុនោះ រមែងនឹងធ្លាក់ដល់ខ្ញុំតែម្នាក់ ដូចទោសព្រោះទំនិញគេចពន្ធ ដូច្នោះ ។ ក្នុងទុតិយវារៈ ទោស ២ យ៉ាង គឺ ភិក្ខុដែលចោទក៏មិនពេញចិត្ត ១

*ចម្លើយត្រូវចោទក៏ដោយសេចក្តីមិនពេញចិត្ត ១ គប្បីប្រកបអត្ថក្នុងបទនេះថា* ***អច្ចយោ អច្ចគ្គមា*** *(ទោសទើបគ្របសង្កត់) ដោយអំណាចទោស ២ យ៉ាងនោះ ។ ពាក្យដ៏សេសក្នុងទីនេះ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## *"ហេតុបច្ច័យឲ្យសត្វស្លាប់ហើយចូលដល់ទុគ្គតិ និងសុគតិ"*

*ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៦២] *បទថា* ***អញ្ញតរោ*** *(បុគ្គលម្នាក់) បានដល់ ព្រាហ្មណ៍ម្នាក់មិនប្រាកដឈ្មោះ ។ បទថា* ***យេន*** *(ត្រង់ទីប្រថាប់) ក្នុងបទថា* ***យេន ភគវា តេនុបសង្កមិ*** *(ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់) នេះ ជាតតិយាវិភត្តិចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ ព្រោះដូច្នោះ គប្បីជ្រាបអត្ថក្នុងទីនេះយ៉ាងនេះថា ព្រះមានព្រះភាគទ្រង់គង់នៅក្នុងទីណា ព្រាហ្មណ៍ចូលទៅគាល់ក្នុងទីនោះ ។ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងទីនេះយ៉ាងនេះថា ពួកទេវតា និងមនុស្សចូលទៅគាល់ព្រះមានព្រះភាគដោយហេតុណា ព្រាហ្មណ៍ចូលទៅគាល់ដោយហេតុនោះ ។ ក៏ព្រាហ្មណ៍នោះ ចូលទៅគាល់ព្រះមានព្រះភាគដោយហេតុអ្វី ។ ព្រោះបំណងលុះគុណវិសេសនានប្បការ ដូចហ្វូងបក្សីចូលរកដើមឈើធំដែលមានផ្លែជានិច្ច ព្រោះត្រូវការស៊ីផ្លែឈើឆ្ងាញ់ៗ ។ មួយទៀត បទថា* ***ឧបសង្កមិ*** *(ចូលទៅគាល់) លោកអធិប្បាយថា ទៅហើយ ។ បទថា* ***ឧបសង្កមិត្វា*** *(លុះចូលទៅគាល់ហើយ) ជាពាក្យសម្ដែងដល់ទីបំផុតនៃការចូលទៅគាល់ ។ ម្យ៉ាងទៀត លោកអធិប្បាយ*

ថា បុគ្គលដែលទៅយ៉ាងនេះ ទៅកាន់ទីជិតជាងនោះ ពោលគឺ ក្បែរជិតព្រះមានព្រះភាគ ។ បទថា **ភគវតា សទ្ធឹ សម្មោទិ** (បានប្រាស្រ័យជាមួយព្រះមានព្រះភាគ) សេចក្តីថា ព្រាហ្មណ៍នោះបានសេចក្តីរីករាយជាមួយព្រះមានព្រះភាគ ដូចដែលព្រះដ៏មានព្រះភាគ ត្រាស់សួរព្រាហ្មណ៍ដល់រឿងល្មមអត់ទ្រាំបានជាដើម បានដល់ សេចក្តីរីករាយតែម្យ៉ាង ដូចទឹកក្តៅ និងទឹកត្រជាក់ ។ ក៏កថាឈ្មោះសម្មោទនីយៈ ព្រោះឲ្យកើតសេចក្តីរីករាយ ពោលគឺ បីតិ និងបាមោជ្ជៈ និងព្រោះភាវៈដែលគួររីករាយ ដែលរីករាយដោយពាក្យជាដើមថា ល្មមអត់ទ្រាំបានឬ ព្រះគោតមល្មមប្រព្រឹត្តទៅបានឬ ព្រះគោតម និងសាវករបស់ព្រះគោតមមានអាពាធតិច មានរោគតិច រហ័សរហួន មានកម្លាំងនៅជាសប្បាយឬ ឈ្មោះថា សារណីយៈ ព្រោះសមគួរឲ្យរឭកដល់គ្នារហូតអស់កាលយូរ រឭករឿយៗ និងព្រោះភាវៈដែលគួររឭក ព្រោះមានសេចក្តីពីរោះទាំងអត្ថៈ និងព្យញ្ជនៈ ម្យ៉ាងទៀត ឈ្មោះថា **សម្មោទនីយៈ** ព្រោះជាសុខក្នុងកាលស្តាប់ ឈ្មោះថា **សារណីយៈ** ព្រោះជាសុខក្នុងកាលរឭកដល់ ។ មួយទៀត ឈ្មោះថា **សម្មោទនីយៈ** ព្រោះព្យញ្ជនៈបរិសុទ្ធិ ឈ្មោះថា **សារណីយៈ** ព្រោះអត្ថៈបរិសុទ្ធិ ព្រាហ្មណ៍សម្រេចការពោលសម្មោទនីយកថា សារណីយកថា គឺ ឲ្យចប់ដោយអនេកបរិយាយយ៉ាងនេះ ដោយប្រការដូច្នេះហើយ បំណាន់នឹងទូលសួររឿងដែលខ្លួនមក ទើបអង្គុយ

ចុះក្នុងកន្លែងដ៏សមគួរ ។ ស័ព្ទថា **ឯកមន្តំ** (ក្នុងទីដែលសមគួរមួយ) សម្តែងការ-នបុំសកៈ ដូចក្នុងប្រយោគជាដើមថា **វិសមំ ចន្ទិមសុរិយា បរិវត្តន្តិ** ព្រះច័ន្ទ និង ព្រះអាទិត្យជាដើមគោចរមិនស្មើគ្នា ដូច្នោះ គប្បីជ្រាបអត្ថក្នុងទីនេះយ៉ាងនេះថា អង្គុយដូចបុគ្គលអង្គុយក្នុងទីដែលសមគួរ ។ ម្យ៉ាងទៀត បទនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា **និសីទិ** (អង្គុយ) បានដល់ ចូលទៅជិត ។ ធម្មតាបុគ្គលឆ្លាត ចូលទៅរកអ្នកដែលមានឋានៈជាគ្រូ រមែងអង្គុយក្នុងទីដ៏សមគួរ ដោយភាពជាអ្នកឆ្លាតក្នុងរឿងអង្គុយ ។ ឯព្រាហ្មណ៍នេះ ក៏ជាព្រាហ្មណ៍ម្នាក់ក្នុង បណ្តាអ្នកឆ្លាតទាំងនោះ ដូច្នោះ ទើបអង្គុយក្នុងកន្លែងដ៏សមគួរ ។

សួរថា អង្គុយដូចម្តេច ទើបឈ្មោះថា អង្គុយក្នុងកន្លែងដែលសមគួរ ។ ឆ្លើយថា អង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង ។ ទោសនៃការអង្គុយ ៦ យ៉ាង អ្វីខ្លះ ។ ទោសនៃការអង្គុយ ៦ យ៉ាង គឺ អង្គុយឆ្ងាយពេក អង្គុយជិតពេក អង្គុយ លើខ្យល់ អង្គុយទីខ្ពស់ អង្គុយចំមុខពេក អង្គុយខាងក្រោយពេក ។ អ្នកអង្គុយ ឆ្ងាយពេក បើត្រូវការនឹងនិយាយក៏ត្រូវនិយាយសំឡេងខ្លាំង ។ អង្គុយជិតពេក រមែងនឹងត្បិតត្បៀត ។ អង្គុយលើខ្យល់ រមែងនឹងបៀតបៀនដោយក្លិនខ្លួន ។ អង្គុយទីខ្ពស់ រមែងប្រកាសថាមិនគោរព ។ អង្គុយចំមុខពេក បើត្រូវការនឹង មើល ក៏នឹងមើលភ្នែកគ្នា ។ អង្គុយខាងក្រោយពេក បើត្រូវការនឹងមើល ក៏នឹង

ត្រូវអើតកមើល ។ ព្រោះដូច្នោះ ព្រាហ្មណ៍នេះទើបអង្គុយវៀរទោសនៃការអង្គុយទាំង ៦ យ៉ាងនេះ ហេតុនោះ លោកទើបពោលថា អង្គុយចុះក្នុងទីដ៏សមគួរ ។

បទថា **ឯតទវោច** (បានទូលសួរ) សេចក្ដីថា ពាក្យសួរមាន ២ យ៉ាង គឺ ពាក្យសួររបស់គ្រហស្ថ ១ ពាក្យសួររបស់បព្វជិត ១ ក្នុង ២ យ៉ាងនោះ ពាក្យសួររបស់គ្រហស្ថ មកដោយន័យជាដើមថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល ។ ពាក្យសួររបស់បព្វជិត មកដោយន័យនេះថា បពិត្រលោកដ៏ចម្រើន ឧបាទានក្ខន្ធ ៥ ទាំងនេះឬហ្ន៎ ។ ក៏ព្រាហ្មណ៍នេះ កាលនឹងសួរ ទើបសួរពាក្យរបស់គ្រហស្ថដែលសមគួរដល់ខ្លួន ទើបបានក្រាបទូលពាក្យនេះ គឺ ពាក្យជាដើមថា បពិត្រព្រះគោតម អ្វីជាហេតុ អ្វីជាបច្ច័យ ។ បណ្ដាបទទាំងនោះ បទទាំងពីរថា **ហេតុ បច្ចយោ** នេះ ជាពាក្យសម្ដែងខែដល់ហេតុទុំះឯង ។ បទថា **អធម្មចរិយ វិសមចរិយាហេតុ** (ព្រោះហេតុនៃការប្រព្រឹត្តមិនស្មើ គឺ ប្រព្រឹត្តអធម៌) សេចក្ដីថា ព្រោះហេតុនៃការប្រព្រឹត្តមិនរៀបរយ ពោលគឺ ការប្រព្រឹត្តខុសធម៌ អធិប្បាយថា ព្រោះការប្រព្រឹត្តនោះជាហេតុ ព្រោះការប្រព្រឹត្តនោះជាបច្ច័យ ។ ក្នុងបទនោះ មានអត្ថរបស់បទ ដូច្នេះ ការប្រព្រឹត្តវត្ថុដែលមិនមែនធម៌ ឈ្មោះថា ការប្រព្រឹត្តខុសធម៌ អធិប្បាយថា ការធ្វើដែលមិនមែនធម៌ ។ ការប្រព្រឹត្តដែលមិនរៀបរយ ឬសេចក្ដីប្រព្រឹត្តនូវកម្មដែលមិនរៀបរយ ហេតុនោះ

ទើបឈ្មោះថា ប្រព្រឹត្តមិនរៀបរយ ។ ការប្រព្រឹត្តមិនរៀបរយនោះផង ការប្រព្រឹត្តខុសធម៌ផង ហេតុនោះ ទើបឈ្មោះថា ការប្រព្រឹត្តមិនរៀបរយ គឺ ការប្រព្រឹត្តខុសធម៌ ។ សូម្បីក្នុងធម៌ចំណែកស ក៏គប្បីជ្រាបអត្ថដោយឧបាយនេះ តែដោយអត្ថក្នុងទីនេះ គប្បីជ្រាបថា អកុសលកម្មបថ ១០ ឈ្មោះថា ការប្រព្រឹត្តមិនរៀបរយ គឺ ការប្រព្រឹត្តខុសធម៌ កុសលកម្មបថ ១០ ឈ្មោះថា ការប្រព្រឹត្តរៀបរយ ពោលគឺ ការប្រព្រឹត្តត្រូវធម៌ ។

**អភិក្កន្ត** ស័ព្ទ ក្នុងបទថា **អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម** (បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើនភាសិតរបស់ព្រះអង្គពីរោះណាស់) នេះ ប្រែថា អស់ទៅ ល្អ ស្អាត និងគួរអនុមោទនាក្រៃលែង ។ ប្រែថា **អស់ទៅ** បានក្នុងប្រយោគជាដើមថា **អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ** បពិត្រព្រះអង្គដ៏ចម្រើន រាត្រីអស់ទៅហើយ បឋមយាមកន្លងទៅហើយ ភិក្ខុសង្ឃគង់យូរហើយ ។ ប្រែថា **ល្អ** បានក្នុងប្រយោគជាដើមថា បុគ្គលទាំង ៤ នាក់នេះ បុគ្គលនេះល្អជាង និងប្រណីតជាង ។ ប្រែថា **ស្អាត** បានក្នុងគាថាជាដើមថា

នរណាមានវណ្ណៈស្អាតក្រៃលែង រុងរឿងដោយឫទ្ធិ
រុងរឿងដោយយស ញុំាងទិសទាំងពួងឲ្យភ្លឺស្វាង

ថ្វាយបង្គំជើងរបស់តថាគត ។

ប្រែថា **គួរអនុមោទនាក្រៃលែង** បានក្នុងពាក្យជាដើមថា គួរអនុមោទនាក្រៃលែង ព្រះអង្គ ។ សូម្បីក្នុងទីនេះ **អភិក្កន្ត** សព្ទ ក៏ប្រែថា គួរអនុមោទនាដ៏ក្រៃលែងនោះឯង និងព្រោះប្រែថា គួរអនុមោទនាក្រៃលែង ដូច្នោះ គប្បីជ្រាបថា លោកអធិប្បាយទុកថា ល្អក្រៃលែង ព្រះគោតមដ៏ចម្រើន ដូច្នេះ ។

*បណ្ឌិតគប្បីធ្វើពាក្យនិយាយដដែល ព្រោះសេចក្តីភ័យខ្លាច ក្រោធ សរសើរ រួសរាន់ ភ្ញាក់ផ្អើល រីករាយ សោក និងជ្រះថ្លា ។*

ក៏ **អភិក្កន្ត** សព្ទនេះ គប្បីជ្រាបថា លោកពោល ២ ដងក្នុងទីនេះ ដោយអំណាចសេចក្តីជ្រះថ្លា និងដោយអំណាចសេចក្តីសរសើរ តាមលក្ខណៈដូចពោលមកនេះ ។ម្យ៉ាងទៀត បទថា **អភិក្កន្តំ** ប្រែថា គួរប្រាថ្នាក្រៃលែង គឺ គួរពេញចិត្តក្រៃលែង អធិប្បាយថា ល្អក្រៃលែង ។ ក្នុងពីរសព្ទនោះ ដោយ **អភិក្កន្ត** សព្ទមួយ ព្រាហ្មណ៍សរសើរទេសនា សព្ទមួយទៀត សរសើរសេចក្តីជ្រះថ្លារបស់ខ្លួន ។ ឯក្នុងទីនេះ មានអធិប្បាយដូច្នេះថា ព្រាហ្មណ៍សរសើរព្រះតម្រាស់របស់ព្រះមានព្រះភាគ សំដៅយកអត្ថ ២ ថា ព្រះតម្រាស់របស់ព្រះគោតមដ៏ចម្រើន ល្អក្រៃលែង ព្រោះកម្ចាត់ទោស ល្អក្រៃលែង ព្រោះសម្រេចគុណ ។ គប្បីប្រកបដូចគ្នាដោយបទមានជាដើមថា ព្រោះឲ្យកើតសទ្ធា ព្រោះឲ្យកើតបញ្ញា ព្រោះមាន

អត្ថ ព្រោះមានព្យញ្ជនៈ ព្រោះបទរាក់ ព្រោះអត្ថជ្រៅ ព្រោះសប្បាយត្រចៀក ព្រោះចូលដល់ចិត្ត ព្រោះមិនលើកខ្លួន ព្រោះមិនគ្របសង្កត់លោក ព្រោះត្រជាក់ដោយករុណា ព្រោះត្រាស់ដោយបញ្ញា ព្រោះជាផ្លូវដែលគួររីករាយ ព្រោះគ្របសង្កត់សត្រូវបាន ព្រោះសប្បាយដល់អ្នកស្តាប់ ព្រោះគួរពិចារណា និងព្រោះចម្រើន ។ សូម្បីតពីនោះ ក៏នៅសរសើរទេសនាដោយឧបមាដល់ ៤ ប្រការនោះឯង ។ បណ្តាបទទាំងនោះ បទថា **និក្កុជ្ជិតំ** (របស់ដែលផ្កាប់) បានដល់ ផ្កាប់មុខ ឬយកមុខចុះក្រោម ។ បទថា **ឧក្កុជ្ជេយ្យ** (ផ្ងារ) ប្រែថា ផ្ងារឡើង ។ បទថា **បដិច្ឆន្នំ** (របស់ដែលបិទ) បានដល់ បិទបាំងដោយស្មៅជាដើម ។ បទថា **វិវរេយ្យ** (បើក) បានដល់ ផ្ងារឡើង ។ បទថា **មូឡ្ហស្ស** (ដល់អ្នកវង្វេង) បានដល់ មនុស្សវង្វេងទិស ។ បទថា **មគ្គំ អាចិក្ខេយ្យ** (ប្រាប់ផ្លូវ) សេចក្តីថា ទាញដៃទៅប្រាប់ថា ផ្លូវនេះ ។ បទថា **អន្ធការេ** (ក្នុងទីងងឹត) បានដល់ ងងឹត ៤ យ៉ាង គឺ ថ្ងៃ ១៤ រោច កណ្តាលយប់ ព្រៃក្រាស់ ពពកក្រាស់ ។ អត្ថនៃបទដែលលំបាកប៉ុណ្ណេះ ។ ចំណែកសេចក្តីអធិប្បាយមានដូចតទៅនេះ គឺ ព្រះគោតមដ៏ចម្រើនឲ្យខ្ញុំព្រះអង្គជាអ្នកបែរខ្នងដល់ព្រះសទ្ធម្មធ្លាក់នៅក្នុងអសទ្ធម្ម ចេញចាកអសទ្ធម្មបាន ដូចបុគ្គលផ្ងាររបស់ដែលផ្កាប់ ទ្រង់បង្ហាញពាក្យទូន្មានដែលត្រូវមិច្ឆាទដ្ឋិបិទបាំង ផ្តើមតាំងពីសាសនាព្រះមានព្រះភាគកស្សបៈអន្តរធានដូចបើករបស់ដែលបិទ ទ្រង់ធ្វើឲ្យនូវ

ផ្លូវសួគ៌ និងនិព្វានដល់ខ្ញុំព្រះអង្គអ្នកប្រព្រឹត្តផ្លូវអាក្រក់ផ្លូវខុស ដូចប្រាប់ផ្លូវដល់អ្នកវង្វេង ទ្រង់ប្រកាសធម៌ដល់ខ្ញុំព្រះអង្គដោយអនេកបរិយាយ ព្រោះទ្រង់ប្រកាសដោយបរិយាទាំងនេះ ដោយទ្រង់ទ្រោលប្រទីប គឺ ទេសនា កម្ចាត់សេចក្តីងងឹត គឺ មោហៈ ដែលបិទបាំងព្រះរតនត្រ័យនោះដល់ព្រះអង្គអ្នកលិចចុះក្នុងទីងងឹត គឺ មោហៈ មិនឃើញរូបនៃព្រះពុទ្ធរតនៈជាដើម ដូចអ្នកបំភ្លឺប្រទីបប្រេងក្នុងទីងងឹត ។ ព្រោះសរសើរទេសនាយ៉ាងនេះហើយ មានចិត្តជ្រះថ្លាក្នុងព្រះរតនត្រៃព្រោះទេសនានេះ កាលធ្វើអាការរបស់អ្នកជ្រះថ្លា ទើបពោលពាក្យជាដើមថា **ឯសាហំ** ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ឯសាហំ** កាត់បទជា **ឯសោ អហំ** ប្រែថា ខ្ញុំព្រះអង្គនេះ ។ បទថា **ភវន្តំ គោតមំ សរណំ គច្ឆាមិ** (សូមដល់ព្រះគោតមជាសរណៈ) សេចក្តីថា ខ្ញុំព្រះអង្គរបស់ដល់ គឺ សេពគប់ សេព អង្គុយជិតព្រះគោតមដ៏ចម្រើនដោយសេចក្តីបំណងនេះថា ព្រះគោមដ៏ចម្រើន ជាទីពឹង ជាទីទៅក្នុងខាងមុខ ជាអ្នកកម្ចាត់សេចក្តីអាក្រក់ និងជាអ្នកប្រទានប្រយោជន៍ដ៏ធំដល់ខ្ញុំព្រះអង្គ អធិប្បាយថា ជ្រាប គឺ ដឹងយ៉ាងនេះ ។ ក៏ធាតុពួកណាមានសេចក្តីថា ទៅ ធាតុពួកនោះមានសេចក្តីថា ដឹង ក៏មាន ដូច្នោះ អត្ថនៃបទថា **គច្ឆាមិ** នេះ លោកទើបពោលថា **ជានាមិ ពុជ្ឈាមិ** ខ្ញុំព្រះអង្គជ្រាប គឺ ដឹង ដូច្នេះ ។ ក្នុងបទថា **ធម្មញ្ច ភិក្ខុសង្ឃញ្ច** (ទាំងព្រះធម៌ និងព្រះសង្ឃ) នេះ ឈ្មោះថា ធម៌ ព្រោះទ្រទ្រង់ពួកសត្វអ្នកសម្រេច

មគ្គ និងធ្វើនិរោធឲ្យជាក់ច្បាស់ បដិបត្តិតាមពាក្យប្រៀនប្រដៅ មិនឲ្យធ្លាក់ទៅក្នុងអបាយ ៤ ។ ដោយអត្ថ បានដល់ អរិយមគ្គ និងព្រះនិព្វាន ។ សមដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បណ្តាសង្ខតធម៌ទាំងឡាយ អរិយមគ្គប្រកបដោយអង្គ ៨ តថាគតពោលថា ប្រសើរជាងសង្ខតធម៌ទាំងនោះ ។ ពោលដោយពិស្តារ មិនមែនតែអរិយមគ្គ និងព្រះនិព្វានប៉ុណ្ណោះ ដែលឈ្មោះថា ធម៌ ដែលពិត សូម្បីបរិយត្តិធម៌ និងអរិយផល ក៏ឈ្មោះថា ធម៌ ។ សមដូចដែលត្រាស់ទុកក្នុងឆត្តមាណវកវិមានវត្ថុថា

រាគវិរាគមនេជមសោកំ ធម្មមសង្ខតមប្បដិកូលំ
មធុរមិមំ បគុណំ សុវិភត្តំ ធម្មមិមំ សរណត្ថមុបេហិ ។

អ្នកចូរចូលដល់ធម៌ជាគ្រឿងប្រាសចាករាគៈ មិនញាប់ញ័រ
មិនសោកសៅ ជាអសង្ខតធម៌ មិនបដិកូល ស្អាត វាងវៃ
ចែកទុកល្អហើយនេះ ថាជាសរណៈចុះ ។

បទថា **រាគវិរាគោ** (ប្រាសចាករាគៈ) ក្នុងទីនេះ ត្រាស់សំដៅដល់មគ្គ ។ បទថា **អនេជមសោកំ** (មិនញាប់ញ័រ មិនសោកសៅ) បានដល់ ផល ។ បទថា **ធម្មមសង្ខតំ** (ជាអសង្ខតធម៌) បានដល់ និព្វាន ។ បទថា **អប្បដិកូលំ មធុរមិមំ បគុណំ សុវិភត្តំ** (មិនបដិកូល ស្អាត វាងវៃ ចែកទុកល្អហើយ) បានដល់ ធម្មក្ខន្ធ

ទាំងអស់ដែលចែកជា ៣ បិដក ។ ឈ្មោះថា សង្ឃ ព្រោះសម្ព័ន្ធគ្នាដោយទិដ្ឋិ និងសីល ។ សង្ឃនោះ ដោយអត្ថ បានដល់ ក្រុមព្រះអរិយបុគ្គល ៨ ។ សម ដូចដែលត្រាស់ទុកក្នុងវិមានវត្ថុនោះថា

យត្ថ ច ទិន្នមហប្ផមាហុ ចតូសុ សុចីសុ បុរិសយុគេសុ

អដ្ឋ ច បុគ្គលធម្មទសា តេ សង្ឃមិមំ សរណត្ថមុបេហិ ។

អ្នកចូរចូលដល់សង្ឃ គឺ ជាបុគ្គលស្អាត ៤ គូ ជាបុគ្គល ៨ ពួក

ដែលជាអ្នកឃើញធម៌ដែលបណ្ឌិតពោលថា ទានដែលថ្វាយលោក

ហើយមានផលច្រើននេះ ថាជាសរណៈចុះ ។

ពួកនៃភិក្ខុទាំងឡាយ ឈ្មោះភិក្ខុសង្ឃ ។ ព្រាហ្មណ៍ប្រកាសការដល់សរណៈ ៣ ប្រការ ដោយពាក្យត្រឹមប៉ុណ្ណេះ ។ ដើម្បីភាពជាអ្នកឆ្លាតក្នុងសរណគមន៍ទាំងនោះ សូម្បីក្នុងទីនេះក៏គួរជ្រាបវិធីនេះថា សរណៈ ការដល់សរណៈ អ្នកដល់សរណៈ ប្រភេទនៃការដល់សរណៈ ផលនៃការដល់សរណៈ សេចក្ដីសៅហ្មង និងការដាច់សរណៈ គឺ ដូចម្ដេច ។ គប្បីជ្រាបដោយអត្ថនៃបទមុន ឈ្មោះថា សរណៈ ព្រោះអត្ថថា កម្ចាត់ អធិប្បាយថា សម្លាប់គ្រឿងសៅហ្មងដោយជុំវិញ គឺ សេចក្ដីភ័យ សេចក្ដីតក់ស្លុត សេចក្ដីទុក្ខ និងទុគ្គតិ ធ្វើឲ្យវិនាស ដោយការដល់សរណៈនុ៎ះឯង របស់អ្នកដែលដល់សរណៈ ។ បទថា ការដល់សរណៈនេះ ជាឈ្មោះរបស់ព្រះ

រតនត្រ័យ ។ មយ៉ាងទៀត ឈ្មោះថា ពុទ្ធ ព្រោះកម្ចាត់ភ័យរបស់ពួកសត្វ ព្រោះឲ្យវត្ថុដែលជាប្រយោជន៍ប្រព្រឹត្តទៅ ឲ្យចេញចាកវត្ថុដែលមិនជាប្រយោជន៍ ។ ឈ្មោះថា ធម៌ ព្រោះលើកសត្វឲ្យឆ្លងចាកកន្តារ គឺ ភព និងព្រោះធ្វើសេចក្តីធូរស្រាលចិត្តដល់សត្វលោក ។ ឈ្មោះថា សង្ឃ ព្រោះធ្វើសក្ការៈសូម្បីមានប្រមាណតិច ឲ្យបានផលដ៏ធំ ។ ដូច្នោះ ព្រះរតនត្រ័យទើបជាសរណៈ ដោយបរិយាយសូម្បីនេះ ។ ចិត្តុប្បាទដែលកម្ចាត់កិលេសបានដោយសេចក្តីជ្រះថ្លា និងសេចក្តីគោរពព្រះរតនត្រ័យនោះ ដែលប្រព្រឹត្តទៅដោយអាការ គឺ ភាពជាអ្នកមានព្រះរតនត្រ័យនោះជាខាងមុខ ឈ្មោះថា សរណៈ សត្វដែលមានសេចក្តីព្រមព្រៀងដោយការដល់សរណៈនោះ ដល់សរណៈ គឺ ដល់រតនៈទាំង ៣ នេះ ថាជាសរណៈដោយចិត្តុប្បាទមានប្រការដូចពោលហើយ អធិប្បាយថា ចូលដល់រតនៈទាំង ៣ នេះថា ជាទីទៅខាងមុខយ៉ាងនេះ ដោយប្រការដូច្នេះ ។ សរណៈ ការដល់សរណៈ និងអ្នកដល់សរណៈ ទាំងបីយ៉ាងនេះ គប្បីជ្រាបប៉ុណ្ណេះ ។ ក៏ក្នុងប្រភេទនៃការដល់សរណៈ ការដល់សរណៈមាន ២ ប្រភេទ គឺ ជាលោកុត្តរៈ ១ ប្រភេទ ជាលោកិយៈ ១ ប្រភេទ ។ ក្នុង ២ ប្រភេទនោះ ការដល់សរណៈជាលោកុត្តរៈ សម្រាប់អ្នកដែលឃើញអរិយសច្ចហើយ ដោយអារម្មណ៍មានព្រះនិព្វានជាអារម្មណ៍ ដោយកិច្ច រមែងសម្រេចក្នុងព្រះរតនត្រ័យទាំងអស់ ដោយការកាត់ផ្តាច់ឧបក្កិលេសដោយ

សរណគមន៍ក្នុងមគ្គខណៈ ។ ការដល់សរណៈដែលជាលោកិយៈ សម្រាប់ពួកបុថុជ្ជន ដោយអារម្មណ៍ មានពុទ្ធគុណជាដើមជាអារម្មណ៍ រមែងសម្រេចដោយការគ្របសង្កត់ឧបក្កិលេសដោយសរណៈនោះឯង ។ ការដល់សរណៈនោះ ដោយអត្ថ បានដល់ ការមានសទ្ធាក្នុងវត្ថុ ៣ មានព្រះពុទ្ធជាដើម និងសម្មាទិដ្ឋិដែលមានសទ្ធាជាមូល ។ ក្នុងបុញ្ញកិរិយាវត្ថុ ១០ លោកហៅថា ទិដ្ឋុជុកម្ម ។

ការដល់សរណៈនេះ ប្រព្រឹត្តទៅដោយអាការ ៤ គឺ ដោយការថ្វាយខ្លួន ១ ដោយភាពជាអ្នកមានព្រះរតនត្រ័យទៅខាងមុខ ១ ដោយចូលដល់ភាពជាសិស្ស ១ ដោយការបន្ទោរខ្លួន ១ ។ ក្នុង ៤ យ៉ាងនោះ ដែលឈ្មោះថា **ការថ្វាយខ្លួន** បានដល់ ការលះបង់ខ្លួនថ្វាយចំពោះព្រះពុទ្ធជាដើម យ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំសូមប្រគល់ខ្លួនចំពោះព្រះពុទ្ធ ចំពោះព្រះធម៌ ចំពោះព្រះសង្ឃ ។ ដែលឈ្មោះថា **ជាអ្នកមានព្រះរតនត្រ័យទៅខាងមុខ** បានដល់ ភាពជាអ្នកមានព្រះរតនត្រ័យនៅខាងមុខ យ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាខាងមុខ សូមលោកទាំងឡាយចូរចាំខ្ញុំទុក ដូច្នេះ ។ ដែលឈ្មោះថា **ចូលដល់ភាពជាសិស្ស** បានដល់ ការចូលដល់ភាពជាសិស្សយ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំជាអន្តេវាសិក (សិស្ស) របស់ព្រះពុទ្ធ របស់ព្រះធម៌ របស់ព្រះសង្ឃ សូមលោកទាំងឡាយចូរចាំខ្ញុំទុក ដូច្នេះ ។ ដែលឈ្មោះថា

ធ្វើការបង្អោនខ្លួន បានដល់ ការធ្វើសេចក្ដីគោរពយ៉ាងក្រៃលែងក្នុងព្រះពុទ្ធជាដើម យ៉ាងនេះថា តាំងពីថ្ងៃនេះជាដើមទៅ ខ្ញុំសូមធ្វើអភិវាទ ការក្រោកទទួល អញ្ជលីកម្ម សាមីចិកម្ម ចំពោះវត្ថុ ៣ មានព្រះពុទ្ធជាដើមប៉ុណ្ណោះ សូមលោកទាំងឡាយចូរចាំខ្ញុំទុក ដូច្នេះ ។ កាលធ្វើអាការ ៤ យ៉ាងនេះ សូម្បីណាមួយ រមែងជាការដល់សរណៈហើយនោះឯង ។

ម្យ៉ាងទៀត គប្បីជ្រាបការថ្វាយខ្លួន សូម្បីយ៉ាងនេះថា ខ្ញុំសូមលះបង់ខ្លួនចំពោះព្រះមានព្រះភាគ សូមលះបង់ខ្លួនចំពោះព្រះធម៌ ចំពោះព្រះសង្ឃ ខ្ញុំសូមលះបង់ជីវិត ដែលខ្ញុំលះបង់ខ្លួនហើយនោះឯង ជាការដែលខ្ញុំលះបង់ជីវិតហើយនោះឯង ខ្ញុំសូមដល់ព្រះពុទ្ធជាសរណៈ ព្រះពុទ្ធជាសរណៈជាទីពួនសម្ងំ ជាទីពឹងរបស់ខ្ញុំ ដរាបអស់ជីវិត ។ ការចូលដល់ភាពជាសិស្ស គប្បីឃើញការដល់សរណៈរបស់ព្រះមហាកស្សបៈ សូម្បីយ៉ាងនេះថា បើខ្ញុំនឹងគប្បីឃើញព្រះសាស្ដា ក៏សូមឃើញព្រះមានព្រះភាគប៉ុណ្ណោះ បើខ្ញុំនឹងគប្បីឃើញព្រះសុគត ក៏សូមឃើញព្រះមានព្រះភាគប៉ុណ្ណោះ បើខ្ញុំនឹងគប្បីឃើញព្រះសម្មាសម្ពុទ្ធ ក៏សូមឃើញព្រះមានព្រះភាគប៉ុណ្ណោះ ។ ភាពជាអ្នកមានព្រះរតនត្រ័យជាខាងមុខ គប្បីជ្រាបការដល់សរណៈរបស់អឡវកយក្ខជាដើម សូម្បីយ៉ាងនេះថា

សោ អហំ វិចរិស្សាមិ គាមា គាមំ បុរា បុរំ

នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។

ខ្ញុំ នឹងត្រាច់ទៅពីស្រុកកាន់ស្រុក ពីក្រុងកាន់ក្រុង សូមនមស្ការព្រះពុទ្ធ និងព្រះធម៌របស់ព្រះអង្គដែលជាធម៌ដ៏ប្រសើរ ដូច្នេះឯង ។

ការធ្វើសេចក្តីបង្អោន គប្បីឃើញយ៉ាងនេះថា គ្រានោះឯង ព្រាហ្មណ៍ព្រហ្មាយុក្រោកចាកអាសនៈ ដណ្តប់សំពត់ឆៀងស្មាម្ខាង ក្រាបសិរសៈចុះទៀបព្រះយុគលបាទរបស់ព្រះមានព្រះភាគ ជញ្ជក់ព្រះយុគលបាទ ប្របាច់ដោយបាតដៃ និងប្រកាសឈ្មោះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រាហ្មណ៍ព្រហ្មាយុ បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រាហ្មណ៍ព្រហ្មាយុ ។

ឯការបង្អោនខ្លួននេះ មាន ៤ យ៉ាង ដោយអំណាចញាតិ ភ័យ អាចារ្យ និងទក្ខិណេយ្យបុគ្គល ។ ក្នុង ៤ យ៉ាងនោះ ការដល់សរណៈ រមែងមានដោយការបង្អោនខ្លួនដល់ទក្ខិណេយ្យបុគ្គល មិនមែនមានដោយ ៣ យ៉ាងក្រៅពីនេះ ។ ព្រោះថា សរណៈដែលបុគ្គលកាន់យកដោយអំណាចបុគ្គលប្រសើរនុ៎ះឯង ដាច់ក៏ដោយអំណាចបុគ្គលប្រសើរដូចគ្នា ដូច្នោះ បុគ្គលណាជាសក្យៈក៏ដោយ ជាលោកិយៈក៏ដោយ ថ្វាយបង្គំដោយគិតថា ព្រះពុទ្ធជាព្រះញាតិរបស់យើង ដូច្នេះ សរណៈ មិនឈ្មោះថា បុគ្គលនោះទទួលឡើយ ។ មយ៉ាងទៀត បុគ្គលណាថ្វាយបង្គំដោយសេចក្តីខ្លាចថា ព្រះសមណគោតមទ្រង់ជាបុគ្គលដែលព្រះរាជាបូជា មាន

អានុភាពច្រើន កាលយើងមិនថ្វាយបង្គំ នឹងធ្វើសេចក្តីវិនាសឲ្យ ដូច្នេះ សរណៈ ឈ្មោះថា បុគ្គលនោះមិនទទួលដូចគ្នា ។ បុគ្គលណារព្ញកដល់អ្វីៗ ដែលខ្លួនរៀន ក្នុងសំណាក់របស់ព្រះមានព្រះភាគ គ្រាជាព្រះពោធិសត្វ និងរៀនអនុសាសនី គ្រាជាព្រះពុទ្ធ បែបនេះថា

ឯកេន ភោគេ ភុញ្ជេយ្យ ទ្វីហិ កម្មំ បយោជយេ

ចតុត្ថញ្ច និធាបេយ្យ អាបទាសុ ភវិស្សតិ ។

បុគ្គលគប្បីប្រើប្រាស់ទ្រព្យមួយចំណែកចិញ្ចឹមជីវិត ប្រើទ្រព្យ ២ ចំណែក ប្រកបការងារ ចំណែកទី ៤ គប្បីរក្សាទុកក្នុងគ្រាអន្តរាយ ដូច្នេះ ។

ហើយថ្វាយបង្គំដោយគិតថា ជាអាចារ្យរបស់យើង ដូច្នេះ សរណៈ ក៏រមែងមិនឈ្មោះថា បុគ្គលនោះទទួលដូចគ្នា ។ តែបុគ្គលណាថ្វាយបង្គំ ដោយគិតថា បុគ្គលនេះជាអគ្គទក្ខិណេយ្យបុគ្គលក្នុងលោក សរណៈ រមែងឈ្មោះថា បុគ្គលនោះទទួលហើយនោះឯង ។ អ្នកដែលទទួលសរណៈយ៉ាងនេះហើយ ជាឧបាសកក៏ដោយ ជាឧបាសិកាក៏ដោយ ថ្វាយបង្គំញាតិសូម្បីបួសក្នុងពួកអន្យតិរ្ថិយ៍ ដោយគិតថា អ្នកនេះជាញាតិរបស់យើង ដូច្នេះ សរណៈក៏មិនដាច់ នឹងចាំបាច់ពោលថ្វីដល់អ្នកដែលមិនបានបួស ថ្វាយបង្គំព្រះរាជាដោយអំណាចសេចក្តីខ្លាចថា ធម្មតាព្រះរាជានោះ គេបូជាទូទាំងប្រទេស កាលយើងមិនថ្វាយបង្គំ នឹងគប្បីធ្វើសេចក្តី

វិនាសឲ្យ ដូច្នេះ ក៏ដូចគ្នា សូម្បីសំពះតិរ្ថិយអ្នកបង្រៀនសិល្បៈយ៉ាងណាមួយ ដោយគិតថា អ្នកនេះជាអាចារ្យរបស់យើង ការដល់សរណៈក៏មិនដាច់ គប្បីជ្រាបប្រភេទនៃការដល់សរណៈ ដោយប្រការដូច្នេះ ។ ក្នុងទីនេះ ការដល់សរណៈដែលជាលោកុត្តរៈ មានសាមញ្ញផល ៤ ជាវិបាកផល មានការអស់ទុក្ខទាំងអស់ជាអានិសង្សផល ។ សមដូចដែលត្រាស់ទុកថា

យោ ច ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ គតោ

ចត្តារិ អរិយសច្ចានិ សម្មប្បញ្ញាយ បស្សតិ

ទុក្ខំ ទុក្ខសមុប្បាទំ ទុក្ខស្ស ច អតិក្កមំ

អរិយញ្ចដ្ឋង្គិកំ មគ្គំ ទុក្ខូបសមគាមិនំ

ឯតំ ខោ សរណំ ខេមំ ឯតំ សរណមុត្តមំ

ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចតិ ។

បុគ្គលណាដល់ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃជាសរណៈ បុគ្គលនោះរមែងឃើញអរិយសច្ច ៤ ដោយបញ្ញាដ៏ប្រពៃ គឺ ឃើញទុក្ខ ទុក្ខសមុទ័យ ទុក្ខនិរោធ និងអរិយមគ្គប្រកបដោយអង្គ ៨ ដែលឲ្យដល់សេចក្ដីស្ងប់ទុក្ខ នោះឯងសរណៈដ៏ក្សេម នោះជាសរណៈដ៏ឧត្ដម បុគ្គលអាស្រ័យសរណៈនេះ

រមែងផុតពីទុក្ខទាំងពួង ដូច្នេះ ។

ម្យ៉ាងទៀត គប្បីជ្រាបអានិសង្សផលនៃការដល់សរណៈនោះ សូម្បីដោយអំណាចនៃការមិនចូលទៅប្រកាន់ ថាជារបស់ទៀងជាដើម ។ សមដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ មិនមែនឋានៈ មិនមែនឱកាសដែលបុគ្គលអ្នកបរិបូរដោយទិដ្ឋិនឹងគប្បីប្រកាន់សង្ខារអ្វីៗ ថាទៀង ថាជាសុខ ប្រកាន់ធម៌អ្វីៗ ថាជាខ្លួន សម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត គិតប្រទូស្តធ្វើព្រះតថាគតឲ្យពុរពងព្រះលោហិត បំបែកសង្ឃ ឧទ្ទិសចំពោះសាស្តាដទៃ នោះមិនមែនជាឋានៈឡើយ ម្យ៉ាងទៀត ទាំងភាវសម្បត្តិ ទាំងភោគសម្បត្តិ ក៏ជាផលនៃការដល់សរណៈដែលជាលោកិយៈនុ៎ះឯង ។ សមដូចដែលត្រាស់ទុកថា

យេកេចិ ពុទ្ធំ សរណំ គតាសេ
ន តេ គមិស្សន្តិ អបាយភូមឹ
បហាយ មានុសំ ទេហំ
ទេវកាយំ បរិបូរេស្សន្តិ ។

ជនពួកណាមួយដល់ព្រះពុទ្ធជាសរណៈ ជនពួកនោះនឹងមិនទៅកាន់អបាយភូមិ គេលះកាយជាមនុស្សហើយ នឹងធ្វើកាយជាទិព្វឲ្យបរិបូណ៌ ដូច្នេះ ។

លោកពោលទុកម្យ៉ាងទៀតថា គ្រានោះឯង ស្តេចសក្កៈចមទេព ព្រមទាំងទេវតា ៨០.០០០ ចូលទៅរកព្រះមហាមោគ្គល្លានដល់ទីនៅ ។ល។ ព្រះមហាមោគ្គល្លានបានពោលពាក្យនេះចំពោះស្តេចសក្កចមទេព ដែលឈរក្នុងកន្លែងដ៏សមគួរថា ទេវៈ ការដល់ព្រះពុទ្ធជាសរណៈ មានប្រយោជន៍ពិត ម្នាលទេវៈ ព្រោះហេតុដែលដល់ព្រះពុទ្ធជាសរណៈនុ៎ះឯង សត្វពួកខ្លះក្នុងលោកនេះ កាលបែកកាយស្លាប់ទៅ រមែងចូលដល់សុគតិលោកសួគ៌ គេទាំងឡាយ រមែងប្រសើរលើសទេវតាដទៃៗ ដោយឋានៈ ១០ ប្រការ គឺ អាយុទិព្វ វណ្ណៈទិព្វ សុខ យស អធិបតីជាទិព្វ រូប សំឡេង ក្លិន រស និងផោដ្ឋព្វៈដែលជាទិព្វ ។ ក្នុងព្រះធម៌ និងព្រះសង្ឃ ក៏ន័យនេះ ។ ម្យ៉ាងទៀត គប្បីជ្រាបផលវិសេសនៃការដល់សរណៈ សូម្បីដោយអំណាចវេលាមសូត្រជាដើម ។ ផលនៃការដល់សរណៈ គប្បីជ្រាបយ៉ាងនេះ ។ ឯក្នុងការដល់សរណៈ ២ យ៉ាងនោះ ការដល់សរណៈជាលោកិយៈ រមែងសៅហ្មង ដោយការមិនដឹង សង្ស័យ និងមិច្ឆាទិដ្ឋិជាដើម ក្នុងព្រះរតនត្រ័យ រមែងមិនមានផលរុងរោចន៍ មិនមានផលដ៏វិសាល ។ ការដល់សរណៈជាលោកុត្តរៈ មិនមានសៅហ្មង ។ មួយទៀត ការដល់សរណៈដែលជាលោកិយៈ មាន ២ ប្រភេទ គឺ ប្រភេទមានទោស ១ ប្រភេទមិនមានទោស ១ ។ ក្នុង ២ ប្រភេទនោះ ប្រភេទមានទោស រមែងមានព្រោះការប្រគល់ខ្លួនក្នុងសាស្តាដទៃជា

ដើម ប្រភេទនោះមានផលមិនគួរប្រាថ្នា ។ ប្រភេទមិនមានទោស រមែងមានព្រោះកាលកិរិយា (ស្លាប់) ប្រភេទនោះ មិនមានផលព្រោះមិនមានវិបាក ។ ចំណែកការដល់សរណៈដែលជាលោកុត្តរ មិនមានដាច់ឡើយ ។ ព្រោះថា សូម្បីក្នុងរវាងភពព្រះអរិយសាវក ក៏មិនឧទ្ទិសចំពោះសាស្ដាដទៃ គប្បីជ្រាបសេចក្ដីសៅហ្មង និងការដាច់នៃការដល់សរណៈយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **ឧបាសកំ មំ ភវំ គោតមោ ធារេតុ** (សូមព្រះគោតម ចូរចាំខ្ញុំព្រះអង្គថាជាឧបាសក) សេចក្ដីថា សូមលោកព្រះគោតមដ៏ចម្រើន ចូរចាំ គឺ ចូរទ្រង់ជ្រាបខ្ញុំព្រះអង្គយ៉ាងនេះថា ខ្ញុំព្រះអង្គនេះជាឧបាសក ដូច្នេះ ។ ដើម្បីភាពជាអ្នកឆ្លាតក្នុងរឿងរបស់ឧបាសក គប្បីជ្រាបសេចក្ដីក្នុងទីនេះដូច្នេះថា ឧបាសក គឺ នរណា ។ ហេតុអ្វី ទើបហៅឧបាសក ។ ឧបាសកមានសីលដូចម្ដេច ។ មានអាជីវៈដូចម្ដេច ។ មានវិបត្តិដូចម្ដេច ។ មានសម្បត្តិដូចម្ដេច ។ បណ្ដាបទទាំងនោះ បទថា **កោ ឧបាសកោ** (ឧបាសក គឺ នរណា) បានដល់ គ្រហស្ថពួកខ្លះដែលដល់សរណៈបី ។ សមដូចដែលត្រាស់ទុកថា ម្នាលមហានាម បុគ្គលជាឧបាសកដោយហេតុណាដែរ បុគ្គលជាអ្នកដល់ព្រះពុទ្ធជាសរណៈ ដល់ព្រះធម៌ជាសរណៈ ដល់ព្រះសង្ឃជាសរណៈ ម្នាលមហានាម បុគ្គលរមែងជាឧបាសកដោយហេតុយ៉ាងនេះឯង ។

សួរថា ហេតុអ្វីទើបហៅថា ឧបាសក ។ ឆ្លើយថា ហៅថា ឧបាសក ព្រោះអង្គុយជិតព្រះរតនត្រ័យ គឺ ហៅគេថា ឧបាសក ព្រោះអង្គុយជិតព្រះពុទ្ធ ហៅថាឧបាសក ព្រោះអង្គុយជិតព្រះធម៌ ព្រះសង្ឃ ។

សួរថា ឧបាសកមានសីលដូចម្តេច ។ ឆ្លើយថា មានចេតនាជាគ្រឿងវៀរបាប ៥ ប្រការ ។ ដូចដែលត្រាស់ថា ម្នាលមហានាម ដោយហេតុណា ឧបាសកជាអ្នកវៀរចាកបាណាតិបាត ជាអ្នកវៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការផឹកទឹកស្រវឹង គឺ សុរា និងមេរ័យដែលជាទីតាំងនៃសេចក្តីប្រមាទ ម្នាលមហានាម ឧបាសក រមែងមានសីលដោយហេតុត្រឹមនេះឯង ។

សួរថា មានអាជីវៈដូចម្តេច ។ ឆ្លើយថា វៀរចាកជំនួញដែលខុស ៥ យ៉ាង ចិញ្ចឹមជីវិតសមគួរដោយធម៌ ។ សមពិតដូចដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាង ឧបាសកមិនគប្បីធ្វើ ៥ យ៉ាងអ្វីខ្លះ គឺ លក់សស្ត្រា លក់សត្វមានជីវិត លក់សាច់ លក់ទឹកស្រវឹង លក់ថ្នាំពិស ម្នាលភិក្ខុទាំងឡាយ ជំនួញ ៥ យ៉ាងនេះឯង ឧបាសកមិនគប្បីធ្វើ ។

សួរថា មានវិបត្តិដូចម្តេច ។ ឆ្លើយថា សីលវិបត្តិ និងអាជីវវិបត្តិនោះឯង ជាវិបត្តិរបស់ឧបាសក ។ មា៉្យងទៀត កិរិយាដែលជាហេតុឲ្យឧបាសកជាអ្នកថោក

ទាប សៅហ្មង អាក្រក់នោះ គប្បីជ្រាបថា ជាវិបត្តិរបស់ឧបាសកនោះ ។ កិរិយាដែលពោលនោះ ដោយអត្ថ ក៏គឺ ធម៌ ៥ ប្រការ ព្រោះជាអ្នកមិនមានសទ្ធាជាដើម ។ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ ប្រការ រមែងជាឧបាសកថោកទាប ជាឧបាសកសៅហ្មង ជាឧបាសកអាក្រក់ ធម៌ ៥ ប្រការអ្វីខ្លះ គឺ ជាអ្នកមិនមានសទ្ធា ១ ទ្រុស្តសីល ១ មានមង្គលភ្ញាក់ផ្អើល គឺ ជឿមង្គល មិនជឿកម្ម ១ ស្វែងរកស្រែបុណ្យក្រៅពុទ្ធសាសនា ១ មិនបំពេញបុណ្យក្នុងពុទ្ធសាសនា ១ ដូច្នេះ ។

សួរថា មានសម្បត្តិដូចម្តេច ។ ឆ្លើយថា សីលសម្បត្តិ និងអាជីវៈសម្បត្តិនោះឯង ជាសម្បត្តិរបស់ឧបាសក ។ ធម៌ ៥ ប្រការ មានសទ្ធាជាដើម ធ្វើឲ្យឧបាសកនោះ ជាឧបាសកកែវជាដើម ។ ដូចដែលត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយធម៌ ៥ ប្រការ រមែងជាឧបាសកកែវ ឧបាសកបទុម និងឧបាសកបុណ្ឌរិក ធម៌ ៥ ប្រការអ្វីខ្លះ គឺ ជាអ្នកមានសទ្ធា ១ មានសីលបរិសុទ្ធិ ១ មិនមានមង្គលភ្ញាក់ផ្អើល គឺ ជឿកម្មមិនជឿមង្គល ១ មិនស្វែងរកស្រែបុណ្យក្រៅព្រះពុទ្ធសាសនា ១ បំពេញបុណ្យតែក្នុងព្រះពុទ្ធសាសនា ១ ដូច្នេះ ។

**អគ្គ** (ជាដើម) សព្ទ ក្នុងបទថា **អជ្ជតគ្គេ** (តាំងពីថ្ងៃនេះជាដើមទៅ) នេះ រមែងប្រាកដក្នុងសេចក្តីថា (ប្រែថា) ជាដើម ចុង ចំណែក និង ប្រសើរ

**បំផុត** ។ ប្រាកដក្នុងអត្ថថា **ជាដើម** ក្នុងប្រយោគជាដើមថា នៃទ្វារបាលសម្លាញ់ តាំងពីថ្ងៃនេះជាដើមទៅ លោកចូរបិទទ្វារចំពោះពួកនិគ្រន្ថប្រុសស្រី ដូច្នេះ ។ ក្នុងអត្ថថា **ចុង** ក្នុងប្រយោគជាដើមថា គប្បីយកចុងម្រាមទ្រនិ៎ះឯង ទល់ចុងម្រាម ចុងអំពៅ ចុងឫស្សី ដូច្នេះ ។ ក្នុងអត្ថថា **ចំណែក** ក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យបែងចែករបស់មានរសជូរ ឬចំណែកទឹកឃ្មុំ តាមចំណែករបស់វិហារ ឬតាមចំណែករបស់បរិវេណ ដូច្នេះ ។ ក្នុងអត្ថថា **ប្រសើរបំផុត** ក្នុងប្រយោគជាដើមថា ម្នាលភិក្ខុទាំងឡាយ សត្វពួកណាមិនមានជើងក៏ដោយ ។បេ។ បណ្តាសត្វពួកនោះ បណ្ឌិតពោល ព្រះតថាគតថាប្រសើរបំផុត ដូច្នេះ ។ ក៏ក្នុងទីនេះ **អគ្គ** ស័ព្ទនេះ គប្បីឃើញក្នុងសេចក្តីថា **ជាដើម** ។ ដូច្នោះក្នុងបទថា **អជ្ជតគ្គេ** នេះ គប្បីជ្រាបអត្ថយ៉ាងនេះថា ធ្វើថ្ងៃនេះឲ្យជាដើម (តាំងពីថ្ងៃនេះជាដើមទៅ) បទថា **អជ្ជតំ** ប្រែថា ថ្ងៃនេះ ។ បាឋៈថា **អជ្ជទគ្គេ** ដូច្នេះក៏មាន ។ ទ អក្សរធ្វើនាទីភ្ជាប់បទ ។ សេចក្តីថា ធ្វើថ្ងៃនេះឲ្យជាដើម ។

បទថា **បាណុបេតំ** (រហូតអស់ជីវិត) សេចក្តីថា ចូលដល់ដោយខ្យល់ដង្ហើមទាំងឡាយ គឺ ចូលដល់ខណៈដែលជីវិតរបស់ខ្ញុំព្រះអង្គនៅប្រព្រឹត្តទៅ ។ សូមព្រះគោតមដ៏ចម្រើន ចូរចាំ គឺ ទ្រង់ជ្រាបខ្ញុំព្រះអង្គថា មិនមានសាស្តាដទៃ ជាឧបាសកដែលដល់សរណៈដោយត្រៃសរណគមន៍ ជាកប្បិយការកៈ បើសូម្បី

នឹងមាននរណាយកដាវដ៏មុត មកកាត់សិរសៈរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គក៏នឹងមិនព្រមពោលព្រះពុទ្ធថា មិនមែនព្រះពុទ្ធ ព្រះធម៌ថា មិនមែនព្រះធម៌ ឬព្រះសង្ឃថា មិនមែនព្រះសង្ឃ ។ ព្រាហ្មណ៍ (មិនប្រាកដឈ្មោះ) ដល់សរណៈដោយការថ្វាយខ្លួនយ៉ាងនេះ ដោយប្រការដូច្នេះ បវារណាដោយបច្ច័យ ៤ ហើយ ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ ៣ ជុំវិញ ហើយចៀសចេញទៅ ។

ចប់អដ្ឋកថា សូត្រទី៦

# អដ្ឋកថាសូត្រទី ៧

## *“ហេតុបច្ច័យដែលឲ្យសត្វស្លាប់ចូលដល់ទុគ្គតិ និងសុគតិ”*

*ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៦៣] *បទថា* ***ជាណុស្សោណិ*** *ក្នុងបទថា* ***ជាណុស្សោណិ*** *នេះ ជាតំណែង តំណែងអ្វី ។ ត្រកូលណាបានតំណែង ត្រកូលនោះ លោកហៅថា ត្រកូលជាណុស្សោណិ (ត្រកូលដែលជាហេតុឲ្យបានតំណែងនោះ លោកហៅថា ត្រកូលជាណុស្សោណិ) ព្រោះថា ព្រាហ្មណ៍នេះ ដែលគេហៅថា ជាណុស្សោណិ ព្រោះកើតក្នុងត្រកូលនោះ និងព្រោះបានសក្ការៈ គឺ តំណែងជាណុស្សោណិពីព្រះរាជា ។ បទថា* ***តេនុបសង្កមិ*** *(ចូលទៅគាល់) សេចក្តីថា ព្រាហ្មណ៍ប្រាប់មកថា ព្រះសមណគោតមជាបណ្ឌិត ជាអ្នកប្រាជ្ញ ជាពហុស្សូត គិតថា បើព្រះសមណគោតមនោះនឹងដឹងប្រភេទនៃលិង្គ វិភត្តិ និងការកៈ ជាដើមសោត ព្រះអង្គក៏ដឹងវត្ថុដែលពួកយើងដឹងប៉ុណ្ណោះ ឬថា វត្ថុដែលពួកយើងមិនដឹងព្រះអង្គក៏ដឹង គេកាន់ទង់ គឺ មានះឡើងក្លាម ហែហមទៅដោយបរិវារជាច្រើន ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។*

*បទថា* ***កតត្តា ច ព្រាហ្មណ អកតត្តា ច*** *សេចក្តីថា ព្រះសាស្តាទ្រង់*

ស្តាប់ពាក្យរបស់ព្រាហ្មណ៍នោះហើយ មានព្រះតម្រិះថា ព្រាហ្មណ៍នេះមកក្នុងទីនេះ មិនមែនបំណងនឹងដឹង តែមកដើម្បីស្វែងរកសេចក្តី ទើបបានកាន់ទង់ គឺមានះឡើងក្នុងពេលដែលមក នឹងមានអ្វីហ្ន៎ បើតថាគតប្រាប់ដោយវិធីដែលព្រាហ្មណ៍នេះ គប្បីដឹងទូទៅដល់អត្ថរបស់បញ្ហា ទើបមានសេចក្តីចម្រើន ឬថា ប្រាប់ដោយវិធីដែលព្រាហ្មណ៍មិនដឹង ទើបមានសេចក្តីចម្រើន ទើបត្រាស់ថា **កតត្តា ច ព្រាហ្មណ អកតត្តា ច** ដូច្នេះ ។

ព្រាហ្មណ៍បានស្តាប់ដូច្នេះហើយ គិតថា ព្រះសមណគោតមត្រាស់ដល់ការកើតក្នុងនរក ព្រោះធ្វើក៏មាន ព្រោះមិនធ្វើក៏មាន សេចក្តីនេះដឹងបានលំបាកនឹងតឹងឈឹង ព្រោះត្រាស់ដល់ការកើតក្នុងទីមួយកន្លែង ដោយហេតុដល់ពីរយ៉ាង យើងមិនមានទីពឹងក្នុងរឿងនេះ តែបើយើងនៅស្ងៀម វេលានិយាយក្នុងកណ្តាលពួកព្រាហ្មណ៍ ព្រាហ្មណ៍ទាំងឡាយនឹងគប្បីពោលនឹងយើងយ៉ាងនេះថា លោកលើកទង់ គឺ មានះឡើងក្នុងកាលមកកាន់សំណាក់របស់ព្រះសមណគោតម ត្រូវគេពោលពាក្យមួយម៉ាត់ប៉ុណ្ណោះក៏នៅស្ងៀម និយាយអ្វីមិនចេញ លោកនឹងនិយាយក្នុងទីនេះធ្វើអ្វី ដូច្នោះ ក៏ធ្វើដូចជាដឹង ទើបសួរបញ្ហាក្នុងការទៅសួគ៌ទៀត ទើបផ្តើមបញ្ហាទីពីរថា **កោ បន ភោ គោតម** (ព្រះគោតមដ៏ចម្រើន អ្វី...) ដូច្នេះ ។ មួយទៀត ព្រាហ្មណ៍នោះមានការគិតយ៉ាងនេះថា នឹងដឹងបញ្ហាខាងក្រោម ដោយ

បញ្ហាខាងលើ នឹងដឹងបញ្ហាខាងលើដោយបញ្ហាខាងក្រោម ដូច្នោះ ព្រាហ្មណ៍ទើបសួរបញ្ហានេះ ។ ព្រះសាស្តាមានព្រះតម្រិះដោយន័យមុននោះឯង កាលនឹងត្រាស់ដោយវិធីដែលព្រាហ្មណ៍មិនដឹង ទើបត្រាស់ថា **កតត្តា ច ព្រាហ្មណ អកតត្តា ច** ដូច្នេះទៀត ។ កាលព្រាហ្មណមិនអាចដឹងនៅក្នុងរឿងនោះបាន ទើបដាក់ចិត្តចុះថា រឿងនោះចូរលើកទុកចុះ អ្នកដែលមកសំណាក់របស់បុគ្គលប្រភេទនេះ គួរបានដឹងរឿងហើយសឹមទៅ យើងនឹងលះបង់វាទៈរបស់ខ្លួន អនុវត្តតាមព្រះសមណគោតម ស្វែងរកប្រយោជន៍ នឹងជម្រះផ្លូវទៅកាន់បរលោក កាលនឹងអារាធនាព្រះសាស្តា ទើបពោលពាក្យជាដើមថា **ន ខោ អហំ** (ខ្ញុំព្រះអង្គមិនយល់) ដូច្នេះ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ប្រាបថា ព្រាហ្មណ៍ដាក់មានះចុះហើយ កាលទ្រង់អធិប្បាយទេសនាឲ្យប្រាកដឡើង ទើបត្រាស់ថា **តេនហិ ព្រាហ្មណ** (ព្រាហ្មណ៍បើដូច្នោះ) ជាដើម ។ បណ្តាបទទាំងនោះ បទថា **តេនហិ** (បើដូច្នោះ) សម្តែងដល់ហេតុ អធិប្បាយថា ព្រោះព្រាហ្មណ៍នោះ កាលមិនដឹងអត្ថនៃព្រះតម្រាស់ដែលត្រាស់ដោយសង្ខេប ទើបអារាធនាឲ្យសម្តែងដោយពិស្តារ ។ ពាក្យដ៏សេសក្នុងទីនេះ ងាយទាំងអស់នោះឯង ។

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

## “ទោសរបស់ទុច្ចរិត និងអានិសង្សរបស់សុចរិត”

ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៦៤] បទថា **អាយស្មា** (លោក) ជាពាក្យសម្ដែងសេចក្ដីស្រឡាញ់ ។ បទថា **អានន្ទោ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា **ឯកំសេន** (ដោយចំណែកមួយ) បានដល់ ដោយទីបំផុតតែម្យ៉ាង ។ បទថា **អនុវិច្ច** (ជំនាញហើយ) បានដល់ ពិចារណាហើយ ។ បទថា **វិញ្ញូ** (អ្នកដឹង) បានដល់ បណ្ឌិត ។

បទថា **គរហន្តិ** (រមែងតិះដៀល) បានដល់ តិះដៀល គឺ ពោលទោស ។ ពាក្យដ៏សេសក្នុងទីនេះ ងាយទាំងអស់ ។

ចប់អដ្ឋកថា សូត្រទី៨

# អដ្ឋកថាសូត្រទី ៩

*"ចូរលះអកុសល ធ្វើកុសលឲ្យកើត"*

[២៦៥] *ពាក្យទាំងអស់ក្នុងសូត្រទី ៩ ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា សូត្រទី៩

# អដ្ឋកថាសូត្រទី ១០

## *“ធម៌ជាហេតុឲ្យព្រះសទ្ធម្មវិនាស និងតាំងនៅ”*

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៦៦] បទថា **ទុន្និក្ខិត្តញ្ច បទព្យញ្ជនំ** (បទព្យញ្ជនៈដែលតាំងទុកមិនល្អ) បានដល់ បាលីដែលដំកល់ទុកខុសលំដាប់ ក៏បទនោះឯង ហៅថា ព្យញ្ជនៈ ព្រោះជាទីប្រាកដច្បាស់នៃអត្ថ ។ បទ និងព្យញ្ជនៈទាំងពីរនោះ ជាឈ្មោះរបស់បាលីនុ៎ះឯង ។ បទថា **អត្ថោ ច ទុន្នីតោ** (អត្ថដែលនាំមកមិនល្អ) សេចក្តីថា អដ្ឋកថានៃបាលីដែលប្រែចាប់សេចក្តីខុសលំដាប់ ។ បទថា **ទុន្និក្ខិតស្ស ភិក្ខវេ បទព្យញ្ជនស្ស អត្ថោបិ ទុន្នយោ ហោតិ** (សូម្បីអត្ថនៃបទព្យញ្ជនៈដែលតាំងទុកមិនល្អ រមែងជាការនាំមកមិនល្អ) សេចក្តីថា អដ្ឋកថាបាលីដែលប្រែចាប់សេចក្តីខុសលំដាប់ រមែងឈ្មោះថា ដើម្បីសេចក្តីសាបសូន្យនៃព្រះសទ្ធម្ម ។*

ចប់អដ្ឋកថា សូត្រទី ១០

## អដ្ឋកថាសូត្រទី ១១

*ក្នុងសូត្រទី ១១ គប្បីជ្រាបសេចក្តីដោយន័យផ្ទុយគ្នាដែលពោលហើយ ។*

ចប់អដ្ឋកថា សូត្រទី ១១

## ចប់អធិករណវគ្គទី ២

## រួមក្នុងវគ្គនេះមាន ១១ សូត្រ

## ព្រះអដ្ឋកថាកែសេចក្តី ៩ សូត្រ

# ពាលវគ្គទី ៣

## អដ្ឋកថាសូត្រទី ១

### *"បុគ្គលពាល ២ ពួក"*

*ពាលវគ្គទី ៣ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៦៧] បទថា **អច្ចយំ អច្ចយតោ ន បស្សតិ** (បុគ្គលមិនឃើញទោសថាជាទោស) សេចក្ដីថា ធ្វើខុសហើយ មិនឃើញកំហុសរបស់ខ្លួនថា យើងធ្វើខុសបានដល់ មិនពោលថា ខ្ញុំធ្វើខុសហើយ នាំទណ្ឌកម្មមកសូមខមាទោស ។*

*បទថា **អច្ចយំ ទេសេន្តស្ស** (បុគ្គលកាលបើអ្នកដទៃប្រាប់ទោស) សេចក្ដីថា កាលគេពោលយ៉ាងនេះហើយ នាំទណ្ឌកម្មមកសូមខមាទោស ។*

*បទថា **យថាធម្មំ ន បដិគ្គណ្ហាតិ** (បុគ្គលដែលមិនព្រមទទួលទោសតាមធម៌) សេចក្ដីថា កាលគេពោលថា ខ្ញុំនឹងមិនធ្វើយ៉ាងនេះទៀត សូមលោកមេត្តាអត់ទោសដល់ខ្ញុំ ដូច្នេះ ក៏មិនព្រមទទួលការសូមទោសនេះតាមធម៌ គឺ តាមការពិត គឺមិនពោលថា ចាប់តាំងពីពេលនេះ លោកកុំធ្វើយ៉ាងនេះទៀត យើងអត់ទោសដល់លោក ដូច្នេះ ។ ធម៌ចំណែកស គប្បីជ្រាបដោយន័យផ្ទុយគ្នាដូចពោលហើយ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## *"បុគ្គល ២ ពួក ពោលបង្កាច់ព្រះតថាគត"*

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៦៨] បទថា **អព្ភាចិក្ខន្តិ** (ពោលបង្កាច់) បានដល់ ពោលអាងខុស គឺពោលដោយរឿងមិនពិត ។ បទថា **ទោសន្តរោ** (មានទោសនៅខាងក្នុង) ប្រែថា មានទោសៈតាំងនៅក្នុងខាងក្នុង ។ ពិតណាស់ បុគ្គលបែបនេះ រមែងពោលបង្កាច់ព្រះតថាគត ដូចសុនក្ខត្តលិច្ឆវី ពោលថា ឧត្តរិមនុស្សធម្មរបស់ព្រះសមណគោតម មិនមានទេ ។ បទថា **សទ្ធោ វា ទុគ្គហិតេន** (បុគ្គលជឿដោយការប្រកាន់ខុស) សេចក្តីថា បុគ្គលដែលមានសទ្ធា ចាស់ក្លាដោយសទ្ធាដែលវៀរចាកញាណ មានសេចក្តីជ្រះថ្លាតិច ប្រកាន់ខុស ពោលបង្កាច់ព្រះតថាគតដោយន័យជាដើមថា ដែលឈ្មោះថា ព្រះពុទ្ធនោះ ជាលោកុត្តរៈទាំងអស់ សូម្បីព្រះអាការ ៣២ មានព្រះកេសាជាដើម របស់ព្រះអង្គសុទ្ធតែជាលោកុត្តរៈ ដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*“បុគ្គល ២ ពួក ពោលបង្កាច់ និងមិនពោលបង្កាច់ព្រះតថាគត”*

[២៦៩] *ក្នុងសូត្រទី ៣ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## *"បុគ្គល ២ ពួក ពោលបង្កាច់ និងមិនពោលបង្កាច់ព្រះតថាគត"*

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៧០] *បទថា* ***នេយ្យត្ថំ សុត្តន្តំ*** *(ព្រះសុត្តន្តៈដែលមានអត្ថគួរណែនាំ) សេចក្តីថា សុត្តន្តៈណាមានអត្ថគប្បីណែនាំ ដែលសុត្តន្តៈមានអត្ថគប្បីណែនាំនោះ ។ បទថា* ***នីតត្ថោ សុត្តន្តោតិ ទីបេតិ*** *(បុគ្គលដែលសម្តែង... ថាព្រះសុត្តន្តៈមានអត្ថណែនាំហើយ) សេចក្តីថា រមែងពោលថា សុត្តន្តៈនេះមានអត្ថពោលទុកហើយ ។ ក្នុងបាលីចំណែកនោះ សុត្តន្តៈដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ បុគ្គលពួក ២ បុគ្គលពួក ៣ បុគ្គលពួក ៤ ដូច្នេះ ឈ្មោះថា មានអត្ថគប្បីណែនាំ ។ ក៏ក្នុងទីនេះ សូម្បីព្រះសម្មាសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ ដូច្នេះ ជាដើមក៏ពិត តែកាលពោលដោយបរមត្ថ បុគ្គលមិនមានទេ គប្បីណែនាំអត្ថដល់គេយ៉ាងនេះដោយប្រការដូច្នេះឯង តែបុគ្គលល្ងង់ខ្លៅ ទើបសម្តែងថា សុត្តន្តៈនេះ មានអត្ថណែនាំហើយ ព្រោះថា កាលបុគ្គលមិនមានដោយបរមត្ថហើយ ព្រះតថាគតក៏មិនគប្បីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពួក ១ ដូច្នេះជាដើម ។ តែព្រោះព្រះអង្គត្រាស់យ៉ាងនោះ ដូច្នោះ ទើបកាន់យកថា បុគ្គលមាន*

ហើយដោយបរមត្ថ ឈ្មោះថា រមែងសម្តែងសុត្តន្តៈមានអត្ថគួរណែនាំថា ជាសុត្តន្តៈមានអត្ថណែនាំហើយ ។ បទថា **នីតត្ថំ** (មានអត្ថណែនាំទៅហើយ) បានដល់មានអត្ថដែលត្រាស់ទុកយ៉ាងនេះថា **អនិច្ចំ ទុក្ខំ អនត្តា** ដែលក្នុងទីនេះក៏មានអត្ថជាក់ច្បាស់ហើយថា មិនទៀង ជាទុក្ខ មិនមែនតួខ្លួន ។ តែព្រោះបុគ្គលនេះល្ងង់ខ្លៅ ទើបគិតថា នៅមានសុត្តន្តៈដែលមានអត្ថគប្បីណែនាំ យើងនឹងនាំអត្ថនៃសុត្តន្តៈនោះមក កាលកាន់យកថា ទៀង ជាសុខ ជាតួខ្លួន ក៏មាននៅ ដូច្នេះឈ្មោះថា រមែងសម្តែងសុត្តន្តៈមានអត្ថណែនាំហើយ ថាជា សុត្តន្តៈមានអត្ថគួរណែនាំ ។

ចប់អដ្ឋកថា សូត្រទី ៤

## អដ្ឋកថាសូត្រទី ៥

*ក្នុងសូត្រទី ៥ មានសេចក្តីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី៥

# អដ្ឋកថាសូត្រទី ៦

## “គតិ ២ យ៉ាង របស់បុគ្គលមានកម្មលាមក និងមិនលាមក”

ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៧១] បទថា **បដិច្ឆន្នកម្មន្តស្ស** (បុគ្គលមានការងារបិទបាំង) បានដល់បុគ្គលអ្នកធ្វើបាប ។ ព្រោះអ្នកទាំងឡាយ រមែងធ្វើបាបដោយអាការបិទបាំង សូម្បីបើធ្វើដោយអាការមិនបិទបាំង បាបកម្មក៏បានឈ្មោះថា កម្មដែលបិទបាំងហើយនោះឯង ។ បទថា **និរយោ** (នរក) បានដល់ ខន្ធព្រមទាំងឱកាស និងខន្ធក្នុងកំណើតតិរច្ឆាន ។

ចប់អដ្ឋកថា សូត្រទី៦

# អដ្ឋកថាសូត្រទី ៧-៨

[២៧២] *ក្នុងសូត្រទី ៧ និងសូត្រទី ៨ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី៧-៨

# អដ្ឋកថាសូត្រទី ៩

*"ឋានៈ ២ ដែលបុគ្គលទ្រុស្តសីល និងបុគ្គលមានសីលត្រូវទទួល"*

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៧៣] *បទថា **បដិគ្គហា** (ឋានៈដែលត្រូវទទួល) បានដល់ ឋានៈដែលទទួល សេចក្តីថា ស្ថានទី ២ កន្លែង រមែងទទួលបុគ្គលទ្រុស្តសីល ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## *"ប្រយោជន៍ ២ ប្រការក្នុងការសេពសេនាសនៈស្ងាត់"*

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៧៤] *បទថា* ***អត្ថវសេ*** *(អំណាចប្រយោជន៍) បានដល់ ហេតុ ។ បទថា* ***អរញ្ញវនបត្ថានិ*** *(ព្រៃនិងតាំងនៅក្នុងព្រៃ) បានដល់ ព្រៃ និងព្រៃស្ងាត់ ។ ក្នុង ២ យ៉ាងនោះ ក្នុងអភិធម្ម លោកហៅទីទាំងអស់ដែលនៅក្រៅសសរឥន្ទខីល (សសរគោលក្រុង) ចេញទៅថា ព្រៃ ដោយត្រង់ក៏ពិត តែគប្បីជ្រាបថា លោកបំណងយកសេនាសនៈព្រៃ ដែលភិក្ខុសមាទានអរញ្ញិកធុតង្គល្មមស្នាក់អាស្រ័យបានដែលលោកពោលថា យ៉ាងជិតបំផុត ៥០០ ធ្នូនោះឯង ។*

*បទថា* ***វនបត្ថំ*** *(តាំងនៅក្នុងព្រៃ) បានដល់ ព្រៃដែលកន្លងគាមខេត្តចេញទៅ មិនមានអាវាសរបស់មនុស្ស មិនមានទីភ្ជួររាស់ ទីសាបព្រោះ ។ បទថា* ***បន្តានិ*** *(ដែលស្ងាត់) បានដល់ ជ្រៅ គឺ ឆ្ងាយ ។ បទថា* ***ទិដ្ឋធម្មសុខវិហារំ*** *(ការនៅជាសប្បាយក្នុងបច្ចុប្បន្ន) បានដល់ ការនៅជាសុខទាំងដែលជាលោកិយៈ និងលោកុត្តរៈ ។ បទថា* ***បច្ឆិមញ្ច ជនតំ អនុកម្បមានោ*** *(អនុគ្រោះពពួកជនជំនាន់ក្រោយ) សេចក្ដីថា អនុគ្រោះសាវកជំនាន់របស់តថាគត ។*

ចប់អដ្ឋកថា សូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

## *“ធម៌ ២ យ៉ាងប្រព្រឹត្តទៅក្នុងចំណែកវិជ្ជា”*

*ក្នុងសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៧៥] បទថា **វិជ្ជាភាគិយា** (ប្រព្រឹត្តទៅក្នុងចំណែកនៃវិជ្ជា) ប្រែថា ប្រព្រឹត្តទៅក្នុងចំណែកនៃការដឹងច្បាស់ ។ បទថា **សមថោ** (សមថៈ) បានដល់ការដែលចិត្តមានអារម្មណ៍តែមួយ (តម្កល់មាំ) ។ បទថា **វិបស្សនា** បានដល់ញាណកំណត់សង្ខារជាអារម្មណ៍ ។ បទថា **កិមត្ថមនុភោតិ** (រមែងសម្រេចប្រយោជន៍អ្វី) សេចក្តីថា ឲ្យសម្រេចប្រយោជន៍អ្វី គឺ ឲ្យដល់ព្រម ឲ្យបរិបូណ៌ ។ បទថា **ចិត្តំ ភាវិយតិ** (រមែងអប់រំចិត្ត) សេចក្តីថា ចម្រើនឡើង ញុំាងមគ្គចិត្តឲ្យកើតឡើង ។ បទថា **យោ រាគោ សោ បហីយតិ** (រមែងលះរាគៈបាន) សេចក្តីថា លះកិលេសដែលឈ្មោះថា រាគៈ ដោយអំណាចដកចេញបាន ។ ព្រោះរាគៈជាសត្រូវរបស់មគ្គចិត្ត មគ្គចិត្តជាសត្រូវរបស់រាគៈ ។ ខណៈមានរាគៈ មិនមានមគ្គចិត្ត ខណៈមានមគ្គចិត្ត មិនមានរាគៈ ។ រាគៈកើតឡើងកាលណា រមែងហាមមិនឲ្យមគ្គចិត្តកើតឡើងកាលនោះ គឺ កាត់ផ្លូវ ។ មគ្គចិត្តកើតឡើងកាលណា កាលនោះ មគ្គចិត្តក៏ដករាគៈព្រមទាំងឫសនោះឯង ព្រោះហេតុនោះ ទើបត្រាស់ថា*

*រាគោ បហីយតិ (រមែងលះរាគៈបាន)* ។

*បទថា **វិបស្សនា ភិក្ខវេ ភាវិតា** (វិបស្សនាដែលអប់រំហើយ) សេចក្ដីថា វិបស្សនាញាណដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ ។ បទថា **បញ្ញា ភាវិយតិ** (រមែងអប់រំបញ្ញា) សេចក្ដីថា មគ្គបញ្ញាដែលវិបស្សនាឲ្យចម្រើន គឺឲ្យបរិបូណ៌ ឲ្យវឌ្ឍនៈ ។ បទថា **យា អវិជ្ជា សា បហីយតិ** សេចក្ដីថា (រមែងលះអវិជ្ជាបាន) សេចក្ដីថា លះអវិជ្ជាធំដែលជាមូលនៃវដ្ដៈបានក្នុងឋានៈទាំង ៨ ។ អវិជ្ជាជាសត្រូវរបស់មគ្គប្បញ្ញា មគ្គប្បញ្ញាក៏ជាសត្រូវរបស់អវិជ្ជា ។ ក្នុងខណៈមានអវិជ្ជា មិនមានមគ្គប្បញ្ញា ក្នុងខណៈមានមគ្គប្បញ្ញា មិនមានអវិជ្ជា ។ អវិជ្ជាកើតឡើងកាលណា កាលនោះរមែងហាមមិនឲ្យមគ្គប្បញ្ញាកើតឡើង គឺ កាត់ផ្លូវ ។ មគ្គប្បញ្ញាកើតឡើងកាលណា កាលនោះ មគ្គប្បញ្ញាក៏ដកអវិជ្ជាព្រមទាំងឫសនោះឯង ។ ព្រោះហេតុនោះទើបត្រាស់ថា **អវិជ្ជា បហីយតិ** (រមែងលះអវិជ្ជាបាន) ។ សហជាតធម៌ទាំងពីរ គឺ មគ្គចិត្ត និងមគ្គប្បញ្ញា ព្រះមានព្រះភាគត្រាស់ហើយដោយប្រការដូច្នេះ ។*

[២៧៦] *ដោយព្រះតម្រាស់ថា **រាគុបក្កិលិដ្ឋំ វា ភិក្ខវេ ចិត្តំ ន វិមុច្ចតិ** (ចិត្តដែលសៅហ្មងដោយរាគៈ រមែងមិនរួចផុត) ដូច្នេះ ព្រះមានព្រះភាគទ្រង់សម្ដែងថា មគ្គចិត្តរមែងមិនរួចផុត ព្រោះចិត្តនៅសៅហ្មងដោយរាគៈ ។ ដោយព្រះ-*

ត្រាស់ថា ***អវិជ្ជុបក្កិលិដ្ឋា វា បញ្ញា ន ភាវិយតិ*** *(បញ្ញាដោយអវិជ្ជា រមែងមិនចម្រើន) ដូច្នេះ ព្រះមានព្រះភាគទ្រង់សម្តែងថា ភិក្ខុរមែងចម្រើនមគ្គប្បញ្ញាមិនបាន ព្រោះបញ្ញានៅសៅហ្មងដោយអវិជ្ជា ។ បទថា* ***ឥតិ ខោ ភិក្ខវេ*** *ប្រែថា ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ។ បទថា* ***រាគវិរាគា ចេតោវិមុត្តិ*** *(ព្រោះប្រាសចាករាគៈ ទើបឈ្មោះថា ចេតោវិមុត្តិ) សេចក្តីថា ធម្មតាចេតោវិមុត្តិរមែងមាន ព្រោះប្រាសចាករាគៈ គឺ រាគៈអស់ទៅ ។ បទនេះជាឈ្មោះនៃផលសមាធិ ។ បទថា* ***អវិជ្ជាវិរាគា បញ្ញាវិមុត្តិ*** *(ព្រោះប្រាសចាកអវិជ្ជា ទើបឈ្មោះថា បញ្ញាវិមុត្តិ) សេចក្តីថា ធម្មតាបញ្ញាវិមុត្តិរមែងមាន ព្រោះប្រាសចាកអវិជ្ជា គឺ អវិជ្ជាអស់ទៅ ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់សមាធិ និងវិបស្សនាដែលប្រព្រឹត្តទៅក្នុងខណៈផ្សេងៗ ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ១១

## ចប់ពាលវគ្គទី ៣

## រួមក្នុងវគ្គនេះមាន ១១ សូត្រ

## ព្រះអដ្ឋកថាកែសេចក្តី ៧ សូត្រ

# សមចិត្តវគ្គទី ៤

## អដ្ឋកថាសូត្រទី ១

### *"ភូមិរបស់អសប្បុរស និងសប្បុរស"*

*សមចិត្តវគ្គ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៧៧] *បទថា* ***អសប្បុរិសភូមិ*** *(ភូមិអសប្បុរស) បានដល់ ឋានៈដែលតាំងនៅរបស់ពួកអសប្បុរស ។ សូម្បីក្នុងភូមិរបស់សប្បុរស ក៏ន័យនេះឯង ។ បទថា* ***អកតញ្ញូ*** *បានដល់ មិនដឹងបុណ្យគុណដែលអ្នកដទៃធ្វើដល់ខ្លួន ។ បទថា* ***កតវេទី*** *បានដល់ មិនដឹងបុណ្យគុណដែលអ្នកដទៃធ្វើដល់ខ្លួន ដោយធ្វើឲ្យប្រាកដ ។ បទថា* ***ឧបញ្ញាតំ*** *(អសប្បុរសសរសើរ) ប្រែថា លើកតម្កើង ពេញចិត្ត សរសើរ ។ បទថា* ***យទិទំ*** *ប្រែថា នេះណា (មានន័យថា គឺ) ។ បទថា* ***អកតញ្ញុតា អកតវេទិតា*** *(ជាបុគ្គលអកត្តញ្ញូកតវេទី) បានដល់ ការមិនដឹងឧបការៈដែលអ្នកដទៃធ្វើ និងការមិនដឹងឧបការៈដែលអ្នកដទៃធ្វើ ដោយធ្វើឲ្យប្រាកដ (មិនតបគុណគេ) ។ បទថា* ***កេវលា*** *(ទាំងអស់) បានដល់ តែម្យ៉ាង ។ សូម្បីក្នុងធម៌ចំណែកស ក៏គប្បីជ្រាបសេចក្តីតាមន័យដែលពោលហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## “បុគ្គល ២ ពួក មិនងាយធ្វើតបបាន”

ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៧៨] បទថា **មាតុ ច បិតុ ច** (មាតា ១ បិតា ១) បានដល់ មាតាបង្កើត ១ បិតាបង្កើត ១ ។ បទថា **ឯកេន ភិក្ខវេ អំសេន មាតរំ បរិហរេយ្យ** (ម្នាលភិក្ខុទាំងឡាយ បុគ្គគប្បីបញ្ជិះមាតាដោយស្មាម្ខាង) សេចក្តីថា បុគ្គគប្បីប្រណិប័តន៍មាតាទុកលើស្មាម្ខាង ។ បទថា **ឯកេន អំសេន បិតរំ បរិហរេយ្យ** (គប្បីបញ្ជិះបិតាដោយស្មាម្ខាង) សេចក្តី បុគ្គគប្បីប្រណិប័តន៍បិតាទុកលើស្មាម្ខាងទៀត ។ បទថា **វស្សសតាយុកោ វស្សសតជីវី** (មានជីវិតរស់នៅអស់ ១០០ ឆ្នាំ) សេចក្តីថា កើតក្នុងវេលាមនុស្សមានអាយុ ១០០ ឆ្នាំ ហើយរស់នៅដល់ ១០០ ឆ្នាំ ។ មានពាក្យអធិប្បាយថា ប្រសិនបើបុគ្គគិតថា នឹងតបគុណមាតាបិតា បញ្ជិះមាតានៅលើស្មាខាងស្តាំ ឲ្យបិតាអង្គុយលើស្មាខាងឆ្វេង អស់ ១០០ ឆ្នាំ ហើយរស់នៅ ១០០ ឆ្នាំ ។ បទថា **សោ ច នេសំ ឧច្ឆាទនបរិមទ្ទនន្ហាបនសម្ពាហនេន** (គេគប្បីបដិបត្តិលោកទាំងពីរនោះ ដោយការអប់ក្លិន គក់ច្របាច់ ផ្ងូតទឹក និងដុសជម្រះ) សេចក្តីថា បុគ្គនោះឯង គប្បីទំនុកបម្រុងមាតាបិតាដែលអង្គុយនៅលើ

ស្មានោះឯង ដោយការអប់ក្លិនខ្ទួនឲ្យក្រអូបដើម្បីបំបាត់ក្លិនស្អុយ ដោយការច្របាច់ដៃជើង ដើម្បីកម្ចាត់បង់ភាពចុកស្រពន់ កាលវេលាត្រជាក់ផ្ងូតដោយទឹកកំដៅ វេលាក្ដៅផ្ងូតដោយទឹកត្រជាក់ ដោយការរួតរឹត គឺ រឹតដៃ និងជើងជាដើម ។ បទថា **តេបិ តត្ថេវ** (លោកទាំងពីរនោះ... នៅលើស្មាទាំងសងខាងនោះឯង) សេចក្ដីថា មាតាបិតាទាំងពីរ ក៏អង្គុយបន្ទោបង់ឧច្ចារៈបស្សាវៈនៅលើនោះឯង គឺ លើស្មាទាំងពីររបស់បុត្តនោះ ។ បទថា **ន ត្វេវ ភិក្ខវេ** (ម្នាលភិក្ខុទាំងឡាយការធ្វើយ៉ាងនោះ នៅមិនទាន់) សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ សូម្បីការប្រណិ-ប័តន៍យ៉ាងនេះ បុត្រនោះបានធ្វើគុណ ឬបានតបគុណដល់មាតាបិតាហើយ ក៏មិនមែន ។

បទថា **ឥស្សរាធិបច្ចេ រជ្ជេ** (ក្នុងរាជសម្បត្តិដែលជាឥស្សរាធិបតី) ព្រះមានព្រះភាគត្រាស់សំដៅដល់ស្ដេចចក្រពត្តិនោះឯង ។ បទថា **បោសកា** (ចិញ្ចឹម) បានដល់ ជាអ្នកចិញ្ចឹមបីបាច់ ដោយឲ្យដៃ និងជើងធំធាត់ ឲ្យផឹកលោហិតក្នុងហទយៈ ។ ព្រោះមាតាបិតាចិញ្ចឹមបុត្តដោយល្អ ផ្គត់ផ្គង់ដោយបាយ និងទឹកជាដើម ។ បទថា **ឥមស្ស លោកស្ស ទស្សេតារោ** (សម្ដែងលោកនេះ) សេចក្ដីថា ប្រសិនបើក្នុងថ្ងៃដែលបុត្តកើត មាតាបិតាចាប់ជើងបុត្តគ្រវែងទៅក្នុងព្រៃ ឬក្នុងជ្រោះ បុត្តក៏នឹងមិនបានឃើញឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងលោកនេះ តែព្រោះ

លោកមិនធ្វើយ៉ាងនេះ ថ្នាក់ថ្នមចិញ្ចឹមបីបាច់ បុត្តទើបឃើញឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ក្នុងលោកនេះ ព្រោះអាស្រ័យមាតាបិតា ដូច្នោះ មាតាបិតាទើបឈ្មោះថា ជាអ្នកសម្តែងលោកនេះដល់បុត្រ ។ បទថា ***សមាទបេតិ*** *(ឲ្យសមាទាន)* បានដល់ ឲ្យទទួលយក ។ ក្នុងព្រះសូត្រនេះ ព្រះមានព្រះភាគត្រាស់ សទ្ធា សីល ចាគៈ បញ្ញា លាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ កិក្ខុដូចជាព្រះធម្មសេនាបតីសារីបុត្តត្ថេរៈ គប្បីជ្រាបថា ឈ្មោះថា ញ៉ាំងមាតាបិតាឲ្យតាំងមាំនៅក្នុងគុណធម៌ទាំងនោះ ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## *"មិនគួរធ្វើទុច្ចរិត ៣ គួរធ្វើសុចរិត ៣"*

*ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៧៩] *បទថា **តេនុបសង្កមិ** (ចូលទៅគាល់) សេចក្តីថា ព្រាហ្មណ៍នោះជ្រាបមកថា ព្រះសមណគោតមត្រាស់ឆ្លើយពាក្យដែលអ្នកសួរ ព្រះអង្គទ្រង់មិននឿយណាយក្នុងពាក្យសួរ យើងនឹងតែងបញ្ហាដើម្បីគ្របសង្កត់ ទើបបរិភោគភោជនៈដែលប្រណីតហើយបិទទ្វារបន្ទប់អង្គុយគិត (តែងបញ្ហា) ។ លំដាប់នោះព្រាហ្មណ៍មានសេចក្តីគិតយ៉ាងនេះថា ក្នុងទីនេះមានសំឡេងគឹកកង ចិត្តមិនស្ងប់ យើងនឹងឲ្យធ្វើផ្ទះជាប់ផ្ទៃដី ឲ្យធ្វើផ្ទះជាប់ផ្ទៃដីហើយក៏ចូលទៅក្នុងផ្ទះនោះ គិតថា យើងត្រូវសួរយ៉ាងនេះហើយ នឹងឆ្លើយយ៉ាងនេះ គេចងបញ្ហាប្រការមួយ កាលនឹងវិសជ្ជនាបញ្ហាប្រការមួយ មិនអាចនឹងឃើញពាក្យឆ្លើយណាៗ អស់មួយថ្ងៃ ។ គេគិតហើយដោយទំនងនេះ កន្លងទៅ ៤ ខែ ។ កាលកន្លងទៅ ៤ ខែ គេទើបបានជួបបញ្ហា ២ បានឮមកថា ព្រាហ្មណ៍នោះមានសេចក្តីគិតយ៉ាងនេះថា យើងនឹងចូលទៅគាល់ព្រះសមណគោតមទូលសួរថា ព្រះគោតមដ៏ចម្រើនជាវាទីអ្វី ។ បើព្រះសមណគោតមពោលថា យើងជាកិរិយវាទី (មានវាទៈថាគួរធ្វើ) យើងនឹង*

គ្របសង្កត់ព្រះសមណគោតមថា ព្រះអង្គទូន្មានឲ្យគេធ្វើអាក្រក់គ្រប់យ៉ាង បើព្រះសមណគោតមពោលថា យើងជាអកិរិយវាទី (មានវាទៈថាមិនគួរធ្វើ) យើងនឹងគ្របសង្កត់ព្រះសមណគោតមថា ព្រះអង្គទូន្មានមិនឲ្យគេធ្វើល្អ ព្រះសមណគោ-តម ត្រូវសួរបញ្ហាទាំង ២ ហើយ នឹងលេបមិនចូលខ្ជាក់មិនចេញ យើងនឹងឈ្នះព្រះសមណគោតមក៏នឹងបរាជ័យ ដោយអាការយ៉ាងនេះ គេក្រោកឡើងទះដៃ ចេញអំពីផ្ទះជាប់ផ្ទៃដី គិតថា អ្នកសួរបញ្ហាប្រភេទនេះ មិនគួរទៅតែម្នាក់ឯង ទើបឲ្យឃោសនាទូទាំងក្រុងហែហមទៅព្រមដោយអ្នកក្រុងទាំងអស់ ចូលទៅគាល់ព្រះ-មានព្រះភាគដល់ទីប្រថាប់ ។ បទថា **កឹវាទី** (មានវាទៈយ៉ាងណា) បានដល់ មានលទ្ធិដូចម្តេច ។ ដោយបទថា **កិមក្ខាយីតិ** (ពោលថាយ៉ាងណា) ព្រាហ្មណ៍ទូលសួរថា ព្រះអង្គទូន្មានបដិបទាដល់សាវកយ៉ាងណា ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍តែងបញ្ហាអស់ ៤ ខែ ដោយសេចក្តីប្រកាន់ថា យើងឃើញបញ្ហាដែលធ្វើឲ្យព្រះសមណគោតមបរាជ័យហើយ កាលនឹងទ្រង់ទម្លាយបញ្ហានោះ ដោយបទតែមួយប៉ុណ្ណោះ ទើបត្រាស់ថា **កិរិយវាទី ចាហំ ព្រាហ្មណ អកិរិយវាទី ច** (ម្នាលព្រាហ្មណ៍ តថាគតមានវាទៈគួរធ្វើផង និងមានវាទៈថាមិនគួរធ្វើផង) ដូច្នេះ ។ លំដាប់នោះ ព្រាហ្មណ៍ដកមានះរបស់ខ្លួនហើយ កាលអារាធនាព្រះមានព្រះភាគ ទើបពោលពាក្យជាដើមថា

*យថាកថំ បន ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីនេះ ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## "ទក្ខិណេយ្យបុគ្គល ២ ពួក"

ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៨០] បទថា **ទក្ខិណេយ្យា** សេចក្តីថា ទានលោកហៅថា ទក្ខិណា ។ អនាថបិណ្ឌិកគហបតីសួរថា បុគ្គលប៉ុន្មានពួកដែលគួរទទួលទាននោះ ។ ដោយបទថា **សេក្ខា** (ព្រះសេក្ខៈ) នេះ ទ្រង់សម្តែងព្រះសេក្ខបុគ្គល ៧ ពួក ។ ឯក្នុងបទនេះ ទ្រង់សង្គ្រោះសូម្បីបុថុជ្ជនអ្នកមានសីល ដោយព្រះសោតាបន្នទុំឯង ។ បទថា **អាហុណេយ្យា យជមានានំ ហោន្តិ** (ជាអ្នកគួរដល់ទក្ខិណានៃទាយកអ្នកបូជា) សេចក្តីថា ជាអ្នកគួរដល់របស់ដែលនាំមកបូជារបស់អ្នកថ្វាយទាន ឈ្មោះថាជាអ្នកទទួលទាន ។ បទថា **ខេត្តំ** (បុញ្ញខេត្ត) បានដល់ ស្រែបុណ្យ គឺ ទីតាំង អធិប្បាយថា ជាទីដុះលូតលាស់នៃបុណ្យ ។

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

## *"បុគ្គលមានសំយោជនៈខាងក្នុង និងខាងក្រៅ"*

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៨១] *បទថា **បុព្វារាមេ** (ក្នុងបុព្វារាម) បានដល់ ទីអារាមនៅទិសខាងកើតក្រុងសាវត្ថី ។ បទថា **មិគារមាតុបាសាទេ** (ប្រាសាទរបស់នាងវិសាខា-មាតា) បានដល់ ជាប្រាសាទរបស់ឧបាសិកា ឈ្មោះវិសាខា ។ ក៏ឧបាសិកាវិសាខានោះហៅថា មិគារមាតា ព្រោះមិគារសេដ្ឋី (ឪពុកក្មេក) តាំងទុកក្នុងឋានៈជាមាតាផង ព្រោះបុត្តម្នាក់មានឈ្មោះដូចឈ្មោះរបស់សេដ្ឋីអ្នកជាជីតាផង ។ ប្រាសាទដែលនាងវិសាខាសាងមានបន្ទប់ ១.០០០ ឈ្មោះថា ប្រាសាទមិគារមាតា ។ ព្រះថេរៈស្នាក់នៅក្នុងប្រាសាទនោះ ។ បទថា **តត្រ ខោ អាយស្មា សារីបុត្តោ** (ទីនោះឯងព្រះសារីបុត្ត) សេចក្តីថា ព្រះធម្មសេនាបតីសារីបុត្តត្ថេរៈស្នាក់នៅក្នុងប្រាសាទនោះ ។*

*បទថា **ភិក្ខូ អាមន្តេសិ** (ហៅភិក្ខុទាំងឡាយមក) សេចក្តីថា ព្រះថេរៈហៅវេលាណា ។ ព្រោះសូត្រខ្លះ ពោលថា មុនភត្តក៏មាន សូត្រខ្លះថា ក្រោយភត្តសូត្រខ្លះថា យាមដំបូង សូត្រខ្លះថា យាមកណ្តាល សូត្រខ្លះថា យាមចុង ។ ក៏*

បដិបទាសូត្រក្នុងសមចិត្តវគ្គ ពោលថា ក្រោយកត្ត ព្រះថេរៈទើបហៅភិក្ខុទាំងឡាយ វេលាល្ងាច ។ សេចក្តីពិតសូត្រនេះ ព្រះថេរៈមិនបានពោលតែមួយអន្លើឯងប៉ុណ្ណោះទេ សូម្បីព្រះតថាគតក៏ត្រាស់ ។ សួរថា ព្រះថេរៈពោលទីណា ។ ឆ្លើយថា ពោលក្នុងរតនប្រាសាទរបស់នាងវិសាខា ។ ពិតហើយ ២០ វស្សា នាបឋមពោធិកាល ព្រះតថាគតមិនបានប្រថាប់នៅប្រចាំក្នុងទីណាៗ កាលមានសេចក្តីជាសុខ ក៏ស្តេចទៅប្រថាប់នៅក្នុងទីនោះៗ នោះឯង ។

វស្សាដំបូង ទ្រង់ប្រកាសធម្មចក្រក្នុងព្រៃឥសិបតនៈ ឲ្យមហាព្រហ្ម ១៨ កោដិផឹកទឹកអម្រឹត ទ្រង់អាស្រ័យក្រុងពារាណសី ប្រថាប់នៅក្នុងព្រៃឥសិបតនៈ ។

វស្សាទី ២ ទ្រង់អាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងវេឡុវ័នវិហារ ។

វស្សាទី ៣ និងទី ៤ ក៏ប្រថាប់នៅក្នុងវេឡុវ័នវិហារនោះឯង ។

វស្សាទី ៥ ទ្រង់អាស្រ័យក្រុងវេសាលី ប្រថាប់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ។

វស្សាទី ៦ ប្រថាប់នៅក្នុងមកុលបព៌ត ។

វស្សាទី ៧ ប្រថាប់នៅ (លើបណ្ឌុកម្ពលសិលាអាសនៈ) នាឋានតាវត្តិង្ស ។

វស្សាទី ៨ ទ្រង់អាស្រ័យសុង្សុមារគិរនគរ ជែនកត្តៈ ប្រថាប់នៅភេស-

កន្សាវែន ។

វស្សាទី ៩ ប្រថាប់នៅក្នុងក្រុងកោសម្ពី ។

វស្សាទី ១០ ប្រថាប់នៅក្នុងព្រៃស្រោងបាលិលេយ្យកៈ ។

វស្សាទី ១១ ប្រថាប់នៅក្នុងព្រាហ្មណគ្រាម ក្រុងនាលា ។

វស្សាទី ១២ ប្រថាប់នៅក្នុងក្រុងវេរញ្ជា ។

វស្សាទី ១៣ ប្រថាប់នៅក្នុងចាលិយបព៌ត ។

វស្សាទី ១៤ ប្រថាប់នៅក្នុងជេតវនវិហារ ។

វស្សាទី ១៥ ប្រថាប់នៅក្នុងក្រុងកបិលពស្ដុ ។

វស្សាទី ១៦ ទ្រង់ប្រោសអាឡវកយក្ខ ឲ្យសត្វប្រាំបីម៉ឺនបួនពាន់ផឹកទឹកអម្រឹត ប្រថាប់នៅក្នុងក្រុងអាឡវី ។

វស្សាទី ១៧ ប្រថាប់នៅក្នុងក្រុងរាជគ្រឹះទៀត ។

វស្សាទី ១៨ ប្រថាប់នៅក្នុងចាលិយបព៌តទៀត ។

វស្សាទី ១៩ ប្រថាប់នៅក្នុងចាលិយបព៌តដូចគ្នា ។

វស្សាទី ២០ អាស្រ័យក្រុងរាជគ្រឹះនុ៎ះឯង ប្រថាប់នៅ ។

២០ វស្សាដំបូង ព្រះតថាគតមិនបានប្រថាប់នៅប្រចាំ ដូចពោលមកនេះ ទីណាៗ មានសេចក្ដីសុខ ក៏ប្រថាប់នៅក្នុងទីនោះៗ នុ៎ះឯង ។ តពីនោះ ទ្រង់ប្រើ

សេនាសនៈ ២ កន្លែងជាប្រចាំ ។ ២ កន្លែង គឺ ទីណាខ្លះ ។ គឺ ជេតពន ១ បុព្វារាម ១ ។ ព្រោះហេតុអ្វី ។ ព្រោះត្រកូល ២ នេះ មានគុណច្រើន ។ ព្រះសាស្តាទ្រង់ប្រើប្រាស់សេនាសនៈ ២ កន្លែងនោះជាប្រចាំ ព្រោះទ្រង់អាស្រ័យគុណ ដែលសំដៅដល់គុណរបស់អនាថបិណ្ឌិកៈ និងនាងវិសាខា ។ សូម្បីស្តេចចារិកទៅក្នុងរដូវភ្លៀង ។ កាលថ្ងៃចូលវស្សា ក៏ប្រថាប់នៅក្នុងសេនាសនៈ ២ កន្លែងនោះឯង ។ ព្រះអង្គប្រថាប់នៅយ៉ាងនេះ ពេលយប់ទ្រង់ប្រថាប់នៅក្នុងព្រះជេតពន ភ្លឺឡើង ហែហមទៅដោយភិក្ខុសង្ឃ ស្តេចចូលទៅបិណ្ឌបាតក្រុងសាវត្ថី ផ្លូវទិសត្បូង ហើយស្តេចចេញផ្លូវទិសខាងកើត ទ្រង់សម្រាកពេលថ្ងៃនៅបុព្វារាម ។ ពេលយប់ប្រថាប់នៅក្នុងបុព្វារាម ភ្លឺឡើង ស្តេចចូលទៅបិណ្ឌបាតក្រុងសាវត្ថី ផ្លូវទិសខាងកើត ហើយស្តេចចេញផ្លូវទិសត្បូង ទ្រង់សម្រាកពេលថ្ងៃក្នុងព្រះជេតពន ។

ក៏ក្នុងថ្ងៃនោះ ព្រះសម្មាសម្ពុទ្ធប្រថាប់នៅក្នុងព្រះជេតពននោះឯង ។ កាលព្រះអង្គប្រថាប់នៅក្នុងទីណាមួយ ទ្រង់រមែងមិនវៀរពុទ្ធកិច្ច ៥ ប្រការឡើយ ។ ពុទ្ធកិច្ច ៥ ប្រការនោះ ពោលទុកពិស្តារហើយក្នុងខាងក្រោយ ។

បណ្តាកិច្ចទាំងនោះ កិច្ចក្នុងបច្ឆិមយាម ព្រះមានព្រះភាគទ្រង់ត្រួតមើលសត្វលោក ទ្រង់ឃើញថា អ្នកក្រុងសាវត្ថី និងពួកសត្វរកប្រមាណមិនបានជុំវិញ

ក្រុងសាវត្ថី ក្នុងផ្ទៃដីមួយគាវុត និងកន្លះយោជន៍ បានត្រាស់ដឹង តពីនោះ ទ្រង់ត្រួតមើលថា វេលាណាហ្ន៎ នឹងមានការត្រាស់ដឹង ទ្រង់ឃើញថា វេលាល្ងាច ទ្រង់ត្រួតមើលថា កាលតថាគតពោលនឹងមានការត្រាស់ដឹង ឬថា កាលសាវកពោលនឹងមានការត្រាស់ដឹង ទ្រង់ឃើញថា កាលព្រះសារីបុត្តត្ថេរៈពោល នឹងមានការត្រាស់ដឹង ទ្រង់ពិចារណាថា អង្គុយពោលទីណានឹងមានការត្រាស់ដឹង ទ្រង់ជ្រាបថា អង្គុយត្រង់រតនប្រាសាទរបស់នាងវិសាខា ទ្រង់បានជ្រាបថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមានការប្រជុំសាវក ៣ ដង ព្រះអគ្គសាវកទាំងឡាយ មានការប្រជុំតែមួយដង បណ្តាការប្រជុំទាំងនោះ ថ្ងៃនេះ នឹងមានការប្រជុំសាវកនៃព្រះធម្មសេនាបតីសារីបុត្តត្ថេរៈ លុះទ្រង់ជ្រាបហើយ ទ្រង់បដិបត្តិព្រះសរីរៈពីព្រឹក ទ្រង់ស្លៀកស្បង់ ជណ្តប់សុគតចីវរ ទ្រង់ប្រដាប់បាត្រសេលម័យ (បាត្រថ្ម) ហែហមទៅដោយភិក្ខុសង្ឃ ស្តេចចូលក្រុងផ្លូវទិសត្បូង ស្តេចបិណ្ឌបាតហើយ ទ្រង់ធ្វើឲ្យភិក្ខុសង្ឃរកបិណ្ឌបាតបានងាយ ស្តេចវិលត្រឡប់ចេញផ្លូវទិសត្បូង ដូចទូកដែលត្រូវខ្យល់ ប្រថាប់ឈរនៅក្រៅទ្វារ ។ លំដាប់នោះ ព្រះអសីតិមហាសាវក ភិក្ខុនីបរិស័ទ ឧបាសកបរិស័ទ ឧបាសិកាបរិស័ទ រួមជាបរិស័ទ ៤ ហែហមព្រះសាស្តា ។ ព្រះសាស្តាត្រាស់ហៅព្រះសារីបុត្តមក ត្រាស់បង្គាប់ថា សារីបុត្រ អ្នកគួរនឹងទៅបុព្វារាម ចូរនាំបរិស័ទរបស់អ្នកទៅ ។ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ថា ព្រះ

ករុណាព្រះអង្គ ហែហមដោយភិក្ខុបរិវាររបស់ខ្លួនប្រមាណ ៥០០ រូប បានទៅកាន់បុព្វារាម ។ ព្រះសាស្តាទ្រង់បញ្ជូនព្រះអសីតិមហាសាវកទៅកាន់បុព្វារាមដូចគ្នា ដោយទំនងនេះឯង ព្រះអង្គឯងស្តេចទៅព្រះជេតពនជាមួយព្រះអានន្ទតែមួយអង្គប៉ុណ្ណោះ ។ សូម្បីព្រះអានន្ទ ក៏ធ្វើវត្តចំពោះព្រះសាស្តា ហើយថ្វាយបង្គំ ក្រាបទូលថា ខ្ញុំព្រះអង្គនឹងទៅបុព្វារាម ព្រះអង្គ ។ ត្រាស់ថា ទៅចុះអានន្ទ ។ ព្រះអានន្ទថ្វាយបង្គំព្រះសាស្តាហើយ ទៅកាន់បុព្វារាមនោះឯង ។ ព្រះសាស្តាទ្រង់អាស្រ័យនៅព្រះជេតពនតែមួយព្រះអង្គប៉ុណ្ណោះ ។

ក៏ថ្ងៃនោះ បរិស័ទ ៤ ប្រាថ្នានឹងស្តាប់ធម្មកថារបស់ព្រះថេរៈប៉ុណ្ណោះ ។ សូម្បីព្រះបាទកោសលមហារាជ ក៏ហែហមទៅដោយពលនិកាយ ស្តេចទៅកាន់បុព្វារាមដូចគ្នា ។ អនាថបិណ្ឌិកគហបតីមានឧបាសក ៥០០ នាក់ជាបរិវារ ក៏បានទៅដូចគ្នា ។ ចំណែកមហាឧបាសិកាវិសាខា ហែហមទៅដោយស្រី ១.០០០ នាក់បានទៅហើយ ។ ក្នុងក្រុងសាវត្ថី ជាទីនៅនៃត្រកូលដែលអង់អាច ៥.៧០០.០០០ ត្រកូល ជនទាំងឡាយក្រៅអំពីក្មេងចាំផ្ទះ បាននាំគ្នាកាន់លម្អិតក្រអូប និងផ្កាឈើជាដើម ទៅកាន់បុព្វារាមទាំងអស់គ្នា ។ មនុស្សគ្រប់ពួកក្នុងទីមួយគាវុត មួយយោជន៍ និងកន្លះយោជន៍ ក្នុងស្រុកត្រង់ទ្វារក្រុងទាំង ៤ បានកាន់លម្អិតក្រអូប និងផ្កាឈើជាដើមទៅកាន់បុព្វារាម ។ ទូទាំងវិហារ ប្រៀបដូចជាក្រាលទៅដោយ

ផ្កាឈើទាំងឡាយ ។ សូម្បីព្រះធម្មសេនាបតីសារីបុត្ត ក៏បានទៅកាន់វិហារ ឈរក្នុងទីទួលក្នុងបរិវេណវិហារ ។ ភិក្ខុទាំងឡាយនាំគ្នាក្រាលអាសនៈប្រគេនព្រះថេរៈ ។ ព្រះថេរៈអង្គុយលើអាសនៈនោះ កាលព្រះថេរៈអ្នកឧបដ្ឋាកធ្វើវត្តហើយ លោកក៏ឲ្យឱវាទដល់ភិក្ខុសង្ឃ ចូលទៅកាន់គន្ធកុដិ អង្គុយចូលសមាបត្តិ បានវេលាតាមកំណត់ លោកចេញចាកសមាបត្តិ ទៅកាន់ស្ទឹងអចិរវតី ជម្រះញើសក្អែល រម្ងាប់សេចក្តីខ្វល់ខ្វាយ ហើយឡើងពីទឹកត្រង់កំពង់ដែលចុះនុ៎ះឯង គ្រងស្បង់ចីវរហើយឈរដណ្តប់សង្ឃាដិ ។ សូម្បីភិក្ខុសង្ឃក៏ចុះស្រង់ទឹកព្រមគ្នា ជម្រះញើសក្អែលហើយត្រឡប់ឡើងមកហែហមព្រះថេរៈ ។ សូម្បីខាងក្នុងវិហារក៏បានចាត់ចែងក្រាលធម្មាសនៈទុកសម្រាប់ព្រះថេរៈ ។ បរិស័ទទាំង ៤ ដឹងឱកាសរៀងៗ ខ្លួន ទើបអង្គុយរៀវខ្ទុំទុក ។ ព្រះសារីបុត្តត្ថេរៈ ហែហមដោយភិក្ខុប្រមាណ ៥០០ រូប មកកាន់ធម្មសភា អង្គុយបែរមុខទៅទិសខាងកើត ចាប់ផ្ចិតវីជនីដ៏វិចិត្រ លើរតនបល្ល័ង្កដែលលើកស្វេតច្ឆត្រឡើង ដែលប្រតិស្ឋានទៅលើក្បាលសិង្ហ ។ លុះអង្គុយហើយ ក្រឡេកមើលបរិស័ទ គិតថា បរិស័ទនេះច្រើនហួសប្រមាណ ការសម្តែងធម៌បន្ទាប់បន្សំ និងប្រមាណតិច មិនសមគួរដល់បរិស័ទនេះ សម្តែងធម៌ប្រការណាទើបនឹងសមគួរហ្ន៎ កាលនឹកដល់ព្រះត្រៃបិដក ទើបបានឃើញធម្មទេសនាពោលដោយសញ្ញោជនៈនេះ លុះកំណត់ធម្មទេសនាយ៉ាងនេះហើយ បំណងនឹង

សម្ដែងធម៌នោះ ទើបហៅភិក្ខុទាំងឡាយថា **អាវុសោ ភិក្ខវេ** (អ្នកមានអាយុទាំងឡាយ) ដូច្នេះ ។

បទថា **ភិក្ខវេ** មិនពោលថា **អាវុសោ** ព្រោះព្រះពុទ្ធទ្រង់ប្រើហៅភិក្ខុទាំងឡាយ ។ ក៏ព្រះសារីបុត្រនេះគិតថា យើងនឹងមិនហៅដូចព្រះទសពល កាលនឹងហៅសាវក ទើបពោលថា **អាវុសោ ភិក្ខវេ** ដូច្នេះ ដោយសេចក្ដីគោរពក្នុងព្រះសាស្ដា ។ បទថា **ឯតទវោច** (បានពោល) សេចក្ដីថា ព្រះសារីបុត្របានពោលពាក្យនេះ គឺ បទធម្មទេសនាថា លោកដ៏មានអាយុទាំងឡាយ ខ្ញុំនឹងសម្ដែងបុគ្គលមានសញ្ញោជនៈខាងក្នុង និងដែលមានសញ្ញោជនៈខាងក្រៅ ដូច្នេះ ។ ក៏ត្រង់រតនប្រាសាទនោះ មានទេវបុត្រជាព្រះសោតាបន្នស្ថិតនៅមួយអង្គ ពេលព្រះពុទ្ធ ឬព្រះសាវកទាំងឡាយផ្ដើមទេសនា ទេវបុត្រអង្គនោះក៏ជ្រាបថា ទេសនានេះរាក់ ទេសនានេះជ្រៅ ទេសនានេះទាក់ទងឈាន ទេសនានេះទាក់ទងវិបស្សនា ទេសនានេះទាក់ទងមគ្គ ទេសនានេះទាក់ទងផល ទេសនានេះទំនាក់ទំនងដល់ព្រះនិព្វាន ។ សូម្បីក្នុងថ្ងៃនោះ ពេលព្រះថេរៈផ្ដើមទេសនាប៉ុណ្ណោះ ទេវបុត្រអង្គនោះក៏ជ្រាបបានថា ព្រះធម្មសេនាបតីសារីបុត្តជាម្ចាស់របស់យើង ផ្ដើមទេសនាដោយទំនងណាៗ ក៏ដោយ ទេសនានេះនឹងឈានចុះដល់វិបស្សនា ព្រះថេរៈនឹងពោលវិបស្សនាដោយមុខទាំង ៦ វេលាចប់ទេសនា ទេវតាពាន់កោដិនឹងបានសម្រេចព្រះ

ព្រះអរហត្ត ចំណែកទេវតា និងមនុស្សដែលជាសោតាបន្នជាដើម កំណត់រាប់មិន បាន យើងនឹងថ្វាយសាធុការចំពោះលោកម្ចាស់របស់យើង ឲ្យសមគួរដល់ទេសនា ទើបប្រើទេវានុភាពថ្ងៃសំឡេងខ្លាំង ពោលថា **សាធុ សាធុ** លោកម្ចាស់ ដូច្នេះ ។

កាលទេវរាជឲ្យសាធុការ ពួកទេវតាអ្នកស្ថិតនៅត្រង់ប្រសាទ ១.០០០ អង្គ ជាបរិវារ ក៏នាំគ្នាឲ្យសាធុការព្រមគ្នាតែម្តង ។ ដោយសំឡេងសាធុការរបស់ទេវតា ទាំងនោះ ពួកទេវតាដែលនៅក្នុងបុព្វារាមបានឲ្យសាធុការ ។ ដោយសំឡេងរបស់ ទេវតាដែលនៅក្នុងបុព្វារាមទាំងនោះ ពួកទេវតាដែលនៅលើផែនដី ប្រមាណមួយ គាវុតបានឲ្យសាធុការ តពីនោះ ពួកទេវតាដែលនៅលើផែនដីកន្លះប្រយោជន៍ ពួក ទេវតាដែលនៅលើផែនដីមួយយោជន៍បានឲ្យសាធុការ ព្រោះដូច្នោះ ដោយឧបាយ នេះ ពួកទេវតាក្នុងចក្រវាឡមួយ ចក្រវាឡពីរ ចក្រវាឡបី ។ល។ រួមជាពួកទេវតា ក្នុងម៉ឺនចក្រវាឡ បានឲ្យសាធុការ ។ ដោយសំឡេងសាធុការរបស់ទេវតាទាំងនោះ ពួកនាគនៅក្នុងផែនដី និងពួកទេវតានៅក្នុងអាកាស បានឲ្យសាធុការ តពីនោះ ទេវតាពពកអ័ព្ទ ទេវតាពពកក្តៅ ទេវតាពពកត្រជាក់ ទេវតាពពកភ្លៀង មហា-រាជទាំង ៤ ជាន់ចាតុម្មហារាជិកា ទេវតាជាន់តាវត្តិង្ស ស្តេចសក្កទេវរាជ ទេវតា ជាន់យាមា សុយាមទេវរាជ ទេវតាជាន់តុសិត សន្តុសិតទេវរាជ ទេវតាជាន់និម្មា-នរតី និម្មានរតីទេវរាជ ទេវតាជាន់វសវត្តី វសវត្តីទេវរាជ ព្រហ្មបារិសជ្ជា ព្រហ្ម

បុរោហិតា មហាព្រហ្ម ទេវតាពួកបរិត្តាភា ពួកអប្បមាណាភា ពួកអាភស្សរា ពួកបរិត្តសុភា ពួកអប្បមាណសុភា ពួកសុភកិណ្ហា ពួកវេហប្ផលា ពួកអវិហា ពួកអតប្បា ពួកសុទស្សា ពួកសុទស្សី និងទេវតាពួកអកនិដ្ឋា រួមទេវតាទាំងពួង ក្នុងទីដែលល្មមនឹងស្តាប់សំឡេងបាន ក្រៅចាកពីពួកអសញ្ញី និងពួកអរូបាវចរៈ បានឲ្យសាធុការ ។ តពីនោះ ពួកមហាព្រហ្មដែលជាព្រះខីណាស្រព រំពឹងថា សំឡេងសាធុការនេះដូចនៅបន្តើយហ្ន៎ មកពីផ្ទៃផែនដីរហូតដល់ជាន់អកនិដ្ឋានេះ មានរឿងអ្វីហ្ន៎ គិតថា ព្រះធម្មសេនាបតីសារីបុត្ត គង់នៅរតនប្រាសាទរបស់នាងវិសាខា ក្នុងបុព្វារាម ផ្តើមសម្តែងធម៌ ពោលអំពីសញ្ញោជនៈ សូម្បីពួកយើងក៏គួរជាកាយសក្ខី (សាក្សី) ក្នុងទីនោះ ទើបបាននាំគ្នាទៅក្នុងទីនោះ ។ បុព្វារាមទើបពេញទៅដោយទេវតាទាំងឡាយ ។ ទីជុំវិញបុព្វារាមមួយគាវុត កន្លះយោជន៍ មួយយោជន៍ រហូតផ្សាយទៅទូទាំងចក្រវាឡ ផ្នែកខាងទទឹងផែនដី ទៅទល់កណ្តាប់ចក្រវាឡ ណែនណាន់ទៅដោយពួកទេវតាម៉ឺនចក្រវាឡមកប្រជុំគ្នា ។ ទេវតា ៦០ កោដិ ខាងលើបានឈរនិម្មិតអត្តភាពឲ្យតូចល្អិត ក្នុងទីប៉ុនចុងដែកស្រួចចាក់ចុះ ។

គ្រានោះ ព្រះសារីបុត្តរំពឹងថា កោលាហលនេះធំហ្ន៎ ។ តើមានរឿងអ្វី បានឃើញទេវតាដែលនៅក្នុងម៉ឺនចក្រវាឡមករួមគ្នានៅក្នុងចក្រវាឡតែមួយ មួយទៀត ព្រោះព្រះពុទ្ធទាំងឡាយមិនមានការចាំបាច់ក្នុងរឿងអធិដ្ឋាន ទ្រង់ឃើញ និង

ឲ្យបានឮសំឡេងដោយប្រមាណបរិស័ទប៉ុណ្ណោះ តែពួកសាវកគួរអធិដ្ឋាន ដូច្នោះ ព្រះថេរៈទើបចូលសមាបត្តិ ចេញចាកសមាបត្តិហើយ ទើបអធិដ្ឋានដោយមហគ្គតចិត្តថា សូមបរិស័ទទូទៅរហូតកណ្តាប់ចក្រវាឡទាំងអស់ ចូរឃើញយើង និង កាលយើងសម្តែងធម៌ ចូរបានឮសំឡេង ។ ផ្តើមពីវេលាដែលព្រះថេរៈអធិដ្ឋាន អ្នកដែលអង្គុយនៅខាងស្តាំព្រះថេរៈក៏ដោយ ត្រង់កណ្តាប់ចក្រវាឡក៏ដោយ មិនមានរឿងដែលត្រូវនិយាយថា ព្រះធម្មសេនាបតីសារីបុត្តជាយ៉ាងណា ខ្ពស់ ទាប ខ្មៅ ស យ៉ាងណា ។ ព្រះថេរៈបានប្រាកដចំពោះមុខរបស់បរិស័ទទាំងអស់ ដែលអង្គុយនៅគ្រប់ទិស ដូចព្រះចន្ទអណ្តែតនៅកណ្តាលនភាកាស ។ សូម្បីកាលព្រះថេរៈកំពុងសម្តែងធម៌ ទេវតា និងមនុស្សទាំងអស់ ដែលអង្គុយនៅខាងស្តាំព្រះថេរៈក៏ដោយ ត្រង់កណ្តាប់ចក្រវាឡក៏ដោយ ទាំងអស់បានឮសំឡេងព្រមៗ គ្នានោះឯង ។

គ្រាអធិដ្ឋានហើយ ព្រះថេរៈទើបផ្តើមសម្តែងបុគ្គលដែលមានសញ្ញាជនៈខាងក្នុង ។ បណ្តាបទទាំងនោះ បទថា **អជ្ឈត្តំ** (ខាងក្នុង) បានដល់ កាមភព ។ បទថា **ពហិទ្ធា** (ខាងក្រៅ) បានដល់ រូបភព និងអរូបភព ។ ពិតហើយ សត្វទាំងឡាយមានវេលានៅក្នុងកាមភពតិច ជាចំណែកទី ៤ នៃកប្បប៉ុណ្ណោះ វេលា ៣ ចំណែកក្រៅពីនេះ កាមភពសូន្យទទេ ។ សត្វដែលច្រើន មានវេលានៅក្នុងរូប-

ភពច្រើនក៏ពិត សូម្បីដូច្នោះ ព្រោះសត្វទាំងនោះមានចុតិ និងបដិសន្ធិក្នុងកាមភពច្រើន ក្នុងរូបភព និងអរូបភពតិច និងភពណាមានចុតិ និងបដិសន្ធិច្រើន ភពនោះរមែងមានអាល័យខ្លះ ប្រាថ្នាខ្លះ ការរៀបរាប់ច្រើនខ្លះ ភពណាមានចុតិ និងបដិសន្ធិតិច ភពនោះក៏មានអាល័យ ប្រាថ្នា ឬការរៀបរាប់តិច ដូច្នោះ កាមភពទើបឈ្មោះថា ខាងក្នុង រូបភព និងអរូបភព ទើបឈ្មោះថា ខាងក្រៅ ដូច្នេះឯង ។ ឆន្ទរាគៈក្នុងកាមភព ពោលគឺ ខាងក្នុង ឈ្មោះថា សញ្ញោជនៈខាងក្នុង ។ ឆន្ទរាគៈក្នុងរូបភព និងអរូបភព ពោលគឺ ខាងក្រៅ ឈ្មោះថា សញ្ញោជនៈខាងក្រៅ ។ម្យ៉ាងទៀត សញ្ញោជនៈ ៥ ដែលប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ឈ្មោះថា សញ្ញោជនៈខាងក្នុង ។ សញ្ញោជនៈ ៥ ដែលប្រព្រឹត្តទៅក្នុងចំណែកខាងលើ ឈ្មោះថា សញ្ញោជនៈខាងក្រៅ ។ ក្នុងប្រការនោះ មានអត្ថរបស់ពាក្យដូចតទៅនេះ ៖

កាមធាតុ លោកហៅថា **ខាងក្រោម** សញ្ញោជនៈទាំងឡាយទាក់ទងក្នុងវត្ថុទាបៗ នោះ ព្រោះឲ្យសម្រេចការកើតក្នុងកាមធាតុនោះ ដូច្នោះ ទើបឈ្មោះថា ប្រព្រឹត្តទៅក្នុងចំណែកខាងក្រោម ។ រូបធាតុ និងអរូបធាតុ លោកហៅថា **ខាងលើ** សញ្ញោជនៈទាំងឡាយទាក់ទងក្នុងចំណែកខាងលើ ព្រោះធ្វើសត្វឲ្យសម្រេចការកើតក្នុងរូបធាតុ និងអរូបធាតុនោះ ដូច្នោះទើបឈ្មោះថា ប្រព្រឹត្តទៅក្នុងចំណែក

ខាងលើ ។ បុគ្គលដែលប្រកបដោយសញ្ញោជនៈខាងក្នុង មានប្រភេទដូចពោល ហើយ ឈ្មោះថា អ្នកមានសញ្ញោជនៈខាងក្នុង បុគ្គលដែលប្រកបដោយសញ្ញោ-ជនៈខាងក្រៅ ឈ្មោះថា អ្នកមានសញ្ញោជនៈខាងក្រៅ ដោយប្រការដូច្នេះ ។ ទាំងពីរនេះ ជាឈ្មោះរបស់លោកិយជនដោយចំណែកច្រើន ដែលអាស្រ័យវដ្ដៈហើយក៏មិនមែន ។ តែទាំងពីរនេះ នឹងជាឈ្មោះរបស់ព្រះអរិយសាវកថ្នាក់សោតាបន្នសកទាគាមី និងអនាគាមីដែលកំណត់ជា ២ ពួក ។ ដូចជា ព្រៃគគី និងព្រៃសាលជាដើម រមែងមិនបានឈ្មោះថា សសរ ថាធ្នឹម ថាកុណ្ឌី រមែងបានឈ្មោះថា ព្រៃគគី ព្រៃសាលៈប៉ុណ្ណោះ តែកាលអ្នកណាប្រើពូថៅមុតកាត់ដើមឈើពីព្រៃនោះ ហើយចាំងឲ្យទៅជាសសរជាដើម រមែងបានឈ្មោះថា សសរ ថាធ្នឹម ថាកុណ្ឌី ក្នុងកាលនោះ យ៉ាងណា បុថុជ្ជនអ្នកមានកិលេសក្រាស់ នៅកំណត់លះបង់កពមិនបាន ក៏ដូច្នោះ មិនទាន់បានឈ្មោះនោះ ព្រះសោតាបន្នជាដើមប៉ុណ្ណោះ ដែលកំណត់លះបង់កពបាន ធ្វើកិលេសឲ្យស្រោលស្តើង ទើបតាំងនៅបាន ។

មួយទៀត ដើម្បីឲ្យសេចក្ដីនេះជាក់ច្បាស់ គប្បីជ្រាបឧបមាដូចក្រោលគោ ដូចតទៅនេះ ៖

មានរឿងថា អ្នកស្រុកធ្វើក្រោលគោ បានបោះស្នឹងខាងក្នុងច្រើន ប្រើខ្សែចងគោ ហើយដឹកទៅចងទុកត្រង់ស្នឹងទាំងនោះ កាលខ្សែមិនគ្រប់គ្រាន់ ទើបចាប់

ដឹកត្រង់ត្រចៀកទាំងពីររបស់គោទាំងឡាយបញ្ចូលក្រោល ហើយធ្វើ (ចង) យ៉ាង នោះដូចគ្នា ក្នុងក្រោលនោះ គោដែលចងទុកខាងក្នុងខ្លះដេកខាងក្រៅ គោដែល ចងទុកខាងក្រៅខ្លះដេកខាងក្នុង គោដែលចងខាងក្នុងខ្លះដេកខាង ក្នុងគោដែលចង ទុកខាងក្រៅខ្លះក៏ដេកខាងក្រៅនុ៎ះឯង គោខ្លះមិនបានចង ក៏ដើរនៅខាងក្នុងនុ៎ះឯង គោខ្លះមិនបានចង ដើរចេញមកខាងក្រៅក៏មាន ។ បណ្ដាគោទាំងនោះ គោដែល ចងខាងក្នុងដេកខាងក្រៅ ព្រោះខ្សែដែលចងវែង គោនោះត្រូវសេចក្ដីក្ដៅជាដើម បៀតបៀន ទើបចេញទៅដេករួមជាមួយគោទាំងឡាយខាងក្រៅ ។ សូម្បីគោដែល ចងទុកខាងក្រៅ ចូលទៅដេកខាងក្នុង ក៏ន័យនេះដូចគ្នា ។ ចំណែកគោណាចងទុក ខាងក្នុងដេកខាងក្នុង ព្រោះខ្សែចងនោះខ្លី ។ សូម្បីគោដែលចងខាងក្រៅ ដេក ខាងក្រៅ ក៏ន័យនេះឯង ។ គោទាំងពីរពួកនោះ រមែងដើរវិលទៅមកត្រង់ស្ទឹង ក្នុងក្រោលនោះឯងរហូតអស់ថ្ងៃ ។ តែគោណាមិនបានចងទុកខាងក្នុង រមែងដើរនៅ ក្នុងក្រុមគោទាំងឡាយ ក្នុងក្រោលនោះឯង ។ គោដែលដេក កាលត្រូវតឹងត្រចៀក ក៏បណ្ដោយតាមចូលទៅក្នុងក្រុមគោទាំងឡាយ មិនទៅកាន់ទីដទៃ ហើយដើរនៅ ក្នុងក្រុមនោះឯងរហូតអស់ថ្ងៃ ។ គោដែលមិនបានចងទុកខាងក្រៅក៏ដោយ ដែល ដើរនៅក្នុងក្រុមគោខាងក្រៅនោះក៏ដោយ ក៏មានន័យនេះដូចគ្នា ។

ក្នុងឧបមានោះ គប្បីជ្រាបថា ភព ៣ ដូចក្រោលគោ ។ អវិជ្ជាដូចស្ទឹង

ក្នុងក្រោលគោ ។ សញ្ញោជនៈ ១០ ដូចខ្សែចងគោត្រង់ស្នឹង ។ ពួកសត្វដែល កើតក្នុងភព ៣ ដូចជាគោ ។ ព្រះសោតាបន្ន និងព្រះសកទាគាមីក្នុងរូបភព និង អរូបភព ដូចគោដែលចងទុកខាងក្នុង ដេកខាងក្រៅ ។ ព្រះអរិយបុគ្គលទាំងនោះ នៅក្នុងរូបភព និងអរូបភពនោះក៏ពិត តែសញ្ញោជនៈក៏នៅប្រែកបលោកទាំងនោះ ទុកក្នុងកាមាវចរភព ។ សូម្បីបុថុជ្ជនក្នុងរូបភព និងអរូបភព ក៏សង្គ្រោះចូលក្នុង កាមាវចរភពនោះដូចគ្នា ព្រោះអត្ថថា នៅលះសញ្ញោជនៈមិនបាន ។ ពិតណាស់ សូម្បីបុថុជ្ជននោះ នៅក្នុងរូបភព និងអរូបភពក៏ដោយ សញ្ញោជនៈក៏នៅប្រែកប គេទុកក្នុងកាមាវចរភពដូចគ្នា ។ ព្រះអនាគាមីក្នុងកាមាវចរភព ដូចគោដែលចង ទុកខាងក្រៅ ដេកខាងក្នុង ព្រោះថា ព្រះអនាគាមីនោះ នៅក្នុងកាមាវចរភពក៏ពិត ប៉ុន្តែសញ្ញោជនៈក៏នៅប្រែកបលោកទុកក្នុងរូបភព និងអរូបភពដូចគ្នា ។ ព្រះសោ-តាបន្ន និងព្រះសកទាគាមីក្នុងកាមាវចរភព ដូចគោដែលចងទុកខាងក្នុង ដេកខាង ក្នុង ព្រោះថា លោកទាំងនោះនៅក្នុងកាមាវចរភពខ្លះ សញ្ញោជនៈចូលទៅប្រែកប លោកទុកក្នុងកាមាវចរភពខ្លះ ។ ព្រះអនាគាមីក្នុងរូបភព និងអរូបភព ដូចគោ ដែលចងទុកខាងក្រៅ ដេកខាងក្រៅ ព្រោះថា លោកនៅក្នុងរូបភព និងអរូបភព នោះខ្លះ សញ្ញោជនៈចូលទៅប្រែកបលោកទុកក្នុងរូបភព និងអរូបភពខ្លះ ។ ព្រះ ខីណាស្រពក្នុងកាមាវចរភព ដូចគោដែលមិនបានចងទុកខាងក្នុង ហើយដើរនៅ

ខាងក្នុង ។ ព្រោះវីណាស្រេពក្នុងរូបភព និងអរូបភព ដូចគោដែលមិនបានចងទុកខាងក្រៅ ដើរដេកនៅខាងក្រៅ ។ ក៏បណ្ដាសញ្ញោជនៈទាំងឡាយ សញ្ញោជនៈ ៣ នេះ គឺ សក្កាយទិដ្ឋិ វិចិកិច្ឆា សីលព្វតបរាមាស មិនហាមបុគ្គលដែលកំពុងទៅ បុគ្គលទៅហើយក៏នាំត្រឡប់មកមិនបាន ។ តែសញ្ញោជនៈ ២ ទាំងនេះ គឺ កាមច្ឆន្ទៈ ព្យាបាទៈ ដែលបុគ្គលមិនគ្របសង្កត់ដោយសមាបត្តិ ឬមិនដកចេញដោយមគ្គ រមែងមិនអាចឲ្យកើតក្នុងរូបភព និងអរូបភពបាន ។

បុរសដាក់ថង់រតនៈ ២ ទុកជិតខ្លួន បែងចែករតនៈ ៧ ប្រការ ឲ្យដល់បរិស័ទដែលមករកម្នាក់មួយកំបង់ លុះឲ្យរតនៈថង់ជំបូងយ៉ាងនេះហើយ សូម្បីថង់ទី ២ ក៏ឲ្យយ៉ាងនោះដូចគ្នា យ៉ាងណា ព្រះសារីបុត្តក៏ដូច្នោះ តាំងបទ ២ បទ ទាំងនេះថា **អជ្ឈត្តសំយោជនំ ច អាវុសោ បុគ្គលំ ទេសេស្សាមិ ពហិទ្ធាសំយោជនញ្ច** (ម្នាលអ្នកមានអាយុទាំងឡាយ ខ្ញុំនឹងសម្ដែងបុគ្គលដែលមានសញ្ញោជនៈខាងក្នុង និងបុគ្គលដែលមានសញ្ញោជនៈខាងក្រៅ) ដូច្នេះ ជាមាតិកាទុកមុន ឥឡូវនេះ ដើម្បីនឹងសម្ដែងល្អិតល្អន់ដល់បរិស័ទ ៨ ពួក ទើបផ្ដើមកថាយ៉ាងពិស្ដារនេះថា **កតមោ ចាវុសោ** (ម្នាលអ្នកមានអាយុទាំងឡាយ ក៏បុគ្គលដែលមានសញ្ញោជនៈខាងក្នុង ដូចម្ដេច) ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ឥធ** (ក្នុងព្រះធម្មវិន័យនេះ) បានដល់ ក្នុងព្រះ

សាសនានេះ ។ បទថា **សីលវា ហោតិ** (ជាអ្នកមានសីល) សេចក្តីថា ជាអ្នកបរិបូរដោយចតុប្បារិសុទ្ធិសីល ។ ព្រះសុធម្មត្ថេរ: អ្នកនៅទីបវិហារពោលថា ព្រះថេរ:លើកចតុប្បារិសុទ្ធិសីលឡើងសម្តែងដោយពាក្យត្រឹមតែប៉ុណ្ណេះ ហើយបានសម្តែងជេដ្ឋកសីលក្នុងចតុប្បារិសុទ្ធិសីលនោះយ៉ាងពិស្តារ ដោយបទថា **បាតិមោក្ខសំវរសំវុតោ** (សង្រួមដោយបាតិមោក្ខសំវរ:) ដោយប្រការដូច្នេះ ។ ចំណែកចូឡនាគត្ថេរ:អ្នកទ្រទ្រង់ព្រះត្រៃបិដក អន្តេវាសិករបស់ព្រះសុធម្មត្ថេរ: ពោលថា ព្រះសារីបុត្តត្ថេរ:ពោលដល់បាតិមោក្ខសំវរ:សូម្បីដោយបទទាំងពីរ ព្រោះបាតិមោក្ខសំវរ:នុ៎ះឯងជាសីល ចំណែក ៣ យ៉ាងក្រៅពីនេះ រមែងមានឋាន:ដែលហៅបានថា សីល ដូច្នេះ ។ កាលមិនស្របតាម លោកក៏ពោលក្រៃលែងឡើងទៅថា ត្រឹមតែរក្សាទ្វារ ៦ ប៉ុណ្ណោះ ក៏ឈ្មោះថា ឥន្ទ្រិយសំវរ: ត្រឹមតែឲ្យបច្ច័យកើតឡើងដោយធម៌ដ៏ស្មើ ក៏ឈ្មោះថា អាជីវបារិសុទ្ធិសីល ត្រឹមតែពិចារណាបច្ច័យដែលបានមកថា នេះមានប្រយោជន៍ ដូច្នេះ ហើយបរិភោគ ក៏ឈ្មោះថា បច្ចយសន្និស្សិតសីល តែបាតិមោក្ខសំវរ:ជាសីលដោយត្រង់ ភិក្ខុដែលមានបាតិមោក្ខសំវរ:បែកធ្លាយ មិនគួរនឹងពោលថា នឹងរក្សាប្រការដ៏សេសទុកបាន ដូចអ្នកដាច់ក្បាល ក៏មិនគួរពោលថា នឹងរក្សាដៃជើងទុកបាន ដូច្នោះ ចំណែកភិក្ខុអ្នកមានបាតិមោក្ខសំវរ:មិនមានភាពសៅហ្មង រមែងរក្សាប្រការដ៏សេសឲ្យជាប្រក្រតីបាន ដូច

អ្នកសីរសៈមិនដាច់ រមែងរក្សាជីវិតទុកបាន ដូច្នោះ ព្រះសារីបុត្តត្ថេរៈទើបសម្តែង បាតិមោក្ខសំវរៈដោយបទថា **សីលវា** (ជាអ្នកមានសីល) កាលទីឲ្យបាតិមោក្ខ-សំវរៈនោះពិស្តារ ទើបពោលថា **បាដិមោក្ខសំវរសំវុតោ** ជាដើម ។

បណ្តាបទទាំងនោះ បទថា **បាដិមោក្ខសំវរសំវុតោ** (សង្រួមហើយក្នុង បាតិមោក្ខសំវរៈ) សេចក្តីថា អ្នកប្រកបដោយសេចក្តីសង្រួមក្នុងព្រះបាតិមោក្ខ ។ បទថា **អាចារគោចរសម្បន្នោ** (ដល់ព្រមដោយអាចារៈ និងគោចរៈ) សេចក្តីថា ដល់ព្រមដោយអាចារៈ និងគោចរៈ (មារយាទ និងការទៅកាន់ទីដែលសមគួរ) ។ បទថា **អណុមត្តេសុ** (ត្រឹមតែតិចតួច) បានដល់ មានប្រមាណតិច ។ បទថា **វជ្ជេសុ** (ក្នុងទោស) បានដល់ ក្នុងអកុសលធម៌ទាំងឡាយ ។ បទថា **ភយទស្សាវី** (មានប្រក្រតីឃើញភ័យ) បានដល់ ឃើញជាភ័យ ។ បទថា **សមាទាយ** (សមា-ទាន) ប្រែថា កាន់យកដោយប្រពៃ ។ បទថា **សិក្ខតិ សិក្ខាបទេសុ** (រក្សាហើយ ក្នុងសិក្ខាបទទាំងឡាយ) សេចក្តីថា សមាទានសិក្សាសិក្ខាបទនោះៗ ។ម៉្យាងទៀត បទថា **សមាទាយ សិក្ខតិ សិក្ខាបទេសុ** (សមាទានសិក្សាហើយក្នុងសិក្ខាទាំង ឡាយ) សេចក្តីថា បណ្តាសិក្ខាបទទាំងឡាយ គឺ បណ្តាចំណែកនៃសិក្ខាបទទាំង ឡាយ សិក្ខាបទណាទីមួយ ដែលប្រព្រឹត្តទៅផ្លូវកាយក៏ដោយ ផ្លូវវាចាក៏ដោយ ដែលគួរសិក្សា កាន់យកសិក្ខាបទនោះៗ ទាំងអស់ដោយល្អ សិក្សាក្នុងរឿងនេះ

មានសេចក្តីសង្ខេប ដូច្នេះ ។ ក៏បទទាំងឡាយ មានបាតិមោក្ខសំវរៈជាដើម ទាំង អស់នេះ ពោលទុកយ៉ាងពិស្តារហើយក្នុងគម្ពីរវិសុទ្ធិមគ្គ និងចតុប្បារិសុទ្ធិសីល ក៏សម្តែងចែកទុកហើយ ដោយអាការទាំងពួង ។ បទថា **អញ្ញតរំ ទេវនិកាយំ** (ពួកទេពណាមួយ) សេចក្តីថា ពួកទេពជំពូកណាមួយ ក្នុងបណ្តាពួកទេពជាន់ កាមាវចរ ៦ ។ បទថា **អាគាមី ហោតិ** (ជាអាគាមី) សេចក្តីថា ជាអ្នកមកកើត ក្នុងខាងក្រោម ។ បទថា **អាគន្តា ឥត្ថត្តំ** (ត្រឡប់មកកាន់ភាវៈដូច្នេះ) សេចក្តីថា ជាអ្នកមកកាន់សភាពជាយ៉ាងនេះ គឺ មានបញ្ចក្ខន្ធជារបស់មនុស្សនេះឯង ។ ព្រះ ថេរៈសម្តែងថា ជាអ្នកកើតក្នុងភពនោះ ឬកើតក្នុងភពខ្ពស់ឡើងទៅមិនបាន រមែង ជាអ្នកមកកើតក្នុងភពខាងក្រោមទៀតទុ៎ះឯង ។ ដោយអង្គនេះ លោកពោលដល់ មគ្គខាងក្រោមទាំង ២ និងផលទាំង ២ របស់ភិក្ខុដែលចម្រើនធាតុកម្មដ្ឋាន ដែល ជាសុក្ខវិបស្សកៈ ។

បទថា **អញ្ញតរំ សន្តំ ចេតោវិមុត្តឹ** (ចេតោវិមុត្តិដ៏ស្ងប់ណាមួយ) សេចក្តី ថា ចតុត្ថជ្ឈានសមាបត្តិណាមួយ ក្នុងសមាបត្តិ ៨ ព្រោះថា ចតុត្ថជ្ឈានសមាបត្តិ នោះ ហៅថា ស្ងប់ ព្រោះកិលេសដែលជាសត្រូវស្ងប់ និងហៅថា ចេតោវិមុត្តិ ព្រោះចិត្តផុតចាកកិលេសទាំងនោះឯង ។ បទថា **អញ្ញតរំ ទេវនិកាយំ** (ពួកទេព ណាមួយ) បានដល់ ទេពណាមួយក្នុងទេពជាន់សុទ្ធាវាស ៥ ។ បទថា **អនាគន្តា**

**ឥត្ថត្តំ** (មិនត្រឡប់មកកាន់ភាពដូច្នេះទៀត) សេចក្តីថា មិនមកកាន់សេចក្តីជាអ្នកមានបញ្ចក្ខន្ធនេះទៀត ។ ព្រះថេរៈសម្តែងថា មិនកើតក្នុងភពខាងក្រោម នឹងកើតក្នុងភពខ្ពស់ឡើងទៅប៉ុណ្ណោះ ឬបរិនិព្វានក្នុងភពនោះឯង ។ ដោយអង្គនេះ លោកពោលដល់មគ្គ ៣ និងផល ៣ របស់ភិក្ខុដែលប្រកបការបំពេញសមាធិ ។

បទថា **កាមានំយេវ និព្វិទាយ** (ដើម្បីសេចក្តីនឿយណាយក្នុងកាមទាំងឡាយ) បានដល់ ដើម្បីត្រូវការនឿយណាយ គឺ ធុញទ្រាន់ក្នុងកាមទាំងពីរ ។ បទថា **វិរាគាយ** (ដើម្បីប្រាសចាក) បានដល់ ដើម្បីត្រូវការប្រាសចាកតម្រេក ។ បទថា **និរោធាយ** (ដើម្បីរលត់) បានដល់ ដើម្បីត្រូវការធ្វើឲ្យប្រព្រឹត្តទៅមិនបាន ។ បទថា **បដិបន្នោ ហោតិ** (រមែងបដិបត្តិ) បានដល់ ជាអ្នកបំពេញវត្តបដិបត្តិ ។ ដោយពាក្យត្រឹមប៉ុណ្ណោះ ក៏ព្រះថេរៈពោលអនាគាមិមគ្គវិបស្សនា ដើម្បីញ៉ាំងសេចក្តីប្រាថ្នាដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ របស់ព្រះសោតាបន្ន និងរបស់ព្រះសកទាគាមីឲ្យអស់ទៅ ។ បទថា **ភវានំយេវ** (ភពទាំងឡាយ) បានដល់ ភព ៣ ។ ដោយបទនេះ ព្រះថេរៈរមែងពោលដល់អរហត្តមគ្គវិបស្សនា ដើម្បីបំណងដល់ការប្រាសចាកតម្រេកក្នុងភពរបស់ព្រះអនាគាមី ។ ដោយបទថា **សោ តណ្ហក្ខយាយ បដិបន្នោ ហោតិ** (ភិក្ខុទាំងនោះរមែងបដិបត្តិដើម្បីអស់តណ្ហា) នេះ ព្រះថេរៈពាលដល់អនាគាមិមគ្គវិបស្សនា ដើម្បីកម្ចាត់តណ្ហាដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ របស់ព្រះ

សោតាបន្ន និងព្រះសកទាគាមីនោះឯង ។ បទថា **សោ លោកក្ខយាយ** (ភិក្ខុនោះ... ដើម្បីអស់លោកៈ) នេះ ព្រះថេរៈពោលដល់អរហត្តមគ្គវិបស្សនា ដើម្បីត្រូវការឲ្យលោកៈក្នុងភពរបស់ព្រះអនាគាមីអស់ទៅ ។ បទថា **អញ្ញតរំ ទេវនិកាយំ** (ពួកទេពណាមួយ) បានដល់ ពួកទេពណាមួយ ក្នុងជាន់សុទ្ធាវាសទាំងឡាយនុ៎ះឯង ។ បទថា **អនាគន្តា ឥត្ថត្តំ** (មិនត្រឡប់មកកាន់សភាពដូច្នេះ) សេចក្ដីថា មិនមកកាន់ភាពជាអ្នកមានបញ្ចក្ខន្ធនេះ ជាអ្នកមិនកើតក្នុងភពខាងក្រោម ជាអ្នកកើតក្នុងភពដែលខ្ពស់តទៅប៉ុណ្ណោះ ឬបរិនិព្វានក្នុងភពនោះឯង ។

ព្រះថេរៈពោលមគ្គ និងផល ២ ខាងក្រោម របស់ភិក្ខុអ្នកចម្រើនធាតុកម្ម-ដ្ឋានដែលជាសុក្ខវិបស្សកៈ ដោយអង្គដំបូង , ពោលមគ្គ និងផល ៣ របស់ភិក្ខុអ្នកប្រកបការបំពេញសមាធិ ដោយអង្គទី ២ ដោយប្រការដូច្នេះ ។

បទថា **សោ កាមានំ** (ភិក្ខុនោះ...នូវកាមទាំងឡាយ) នេះ ព្រះថេរៈពោលដល់អនាគាមិមគ្គវិបស្សនា ដើម្បីប្រាសចាកតម្រេកដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ របស់ព្រះសោតាបន្ន និងព្រះសកទាគាមីទាំងឡាយ ។ បទថា **សោ ភវានំយេវ** (ភិក្ខុនោះ...នូវភពទាំងឡាយ) នេះ ព្រះថេរៈពោលដល់អរហត្តមគ្គវិបស្សនា ដើម្បីការប្រាសចាកតម្រេកក្នុងភពរបស់ព្រះអនាគាមី ។ បទថា **សោ តណ្ហក្ខយាយ** (ភិក្ខុនោះ...ដើម្បីការអស់តណ្ហា) នេះ ព្រះថេរៈពោលដល់អនាគាមិមគ្គវិបស្សនា

ដើម្បីឲ្យតណ្ហាដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ របស់ព្រះសោតាបន្ន និងព្រះសក-ទាគាមីទាំងឡាយអស់ទៅ ។ បទថា **សោ លោកក្ខយាយ** (ភិក្ខុនោះ...ដើម្បីការអស់លោកៈ) នេះ ព្រះថេរៈពោលដល់អរហត្តមគ្គវិបស្សនា ដើម្បីឲ្យលោកៈរបស់ព្រះអនាគាមីអស់ទៅ ។ ព្រះថេរៈពោលវិបស្សនា ដោយមាតិកាទាំង ៦ ប្រការ ទេសនាទៅតាមលំដាប់អនុសន្ធិយ៉ាងនេះ ដោយប្រការដូច្នេះ ។ វេលាចប់ទេសនា ទេវតាមួយពាន់កោដិ សម្រេចព្រះអរហន្ត និងជាព្រះសោតាបន្នជាដើម រាប់មិនបាន ។ កាលត្រាស់មហាសមយសូត្រក្តី មង្គលសូត្រក្តី ចូឡរាហុលោវាទសូត្រ ទេវតាមួយពាន់កោដិសម្រេចព្រះអរហន្ត ដូចក្នុងសមាគមនេះ ។ ទេវតា និងមនុស្ស ជាព្រះសោតាបន្នជាដើម រាប់មិនបាន ។

បទថា **សមចិត្តា ទេវតា** (ទេវតាដែលមានចិត្តស្មើគ្នា) សេចក្តីថា ទេវតាទាំងឡាយ ឈ្មោះថា **សមចិត្តា** ព្រោះមានចិត្តល្អិតស្មើគ្នា ព្រោះថា ទេវតាទាំងអស់នោះ និម្មិតអត្តភាពរបស់ខ្លួនឲ្យល្អិតស្រដៀងចិត្ត ហេតុនោះ ទើបឈ្មោះថា **សមចិត្តា** ។ ឈ្មោះថា **សមចិត្តា** ដោយហេតុដទៃៗ ក៏មាន ។ ទេវតាទាំងពួងមានការគិតដូចគ្នាថា ព្រះថេរៈពោលសមាបត្តិមុន តែមិនបានពោលដោយកម្លាំងរបស់សមាបត្តិ ពួកយើងនឹងអារាធនាព្រះទសពលឲ្យត្រាស់កម្លាំងរបស់សមាបត្តិ ហេតុនោះទើបឈ្មោះថា **សមចិត្តា** ។ ហេតុម្យ៉ាងទៀត ពួកទេវតាគិតថា ព្រះថេរៈ

ពោលទាំងសមាបត្តិ ទាំងកម្លាំងរបស់សមាបត្តិ ដោយបរិយាយ ។ នរណាខ្លះហ្ន៎ មកសមាគមនេះ នរណាមិនមក កាលពិចារណាជ្រាបថា ព្រះតថាគតស្តេចមិនមក ទាំងអស់គ្នាមានការគិតតែម្យ៉ាងថា ពួកយើងនឹងអារាធនាព្រះតថាគត ធ្វើបរិស័ទឲ្យបរិបូណ៌ ហេតុនេះខ្លះ ទើបឈ្មោះថា **សមចិត្តា** ។ ហេតុម្យ៉ាងទៀត ទេវតាទាំងឡាយនោះឯង មានការគិតដូចគ្នាថា នរណាៗ ក្នុងកាលអនាគតមិនថា ជាភិក្ខុ ភិក្ខុនីក្តី ទេវតា មនុស្សក្តី នឹងមិនគោរព ព្រោះគិតថា ទេសនានេះ ជាសាវកភាសិត (មិនមែនពុទ្ធភាសិត) ពួកយើងនឹងអារាធនាព្រះសម្មាសម្ពុទ្ធ ធ្វើទេសនានេះ ឲ្យជាសព្វញ្ញុភាសិត ទេសនានេះនឹងជាទីតាំងនៃសេចក្តីគោរពក្នុងអនាគតដោយអាការយ៉ាងនេះ ហេតុនេះខ្លះ ទើបឈ្មោះថា **សមចិត្តា** ។ ហេតុម្យ៉ាងទៀត ទេវតាទាំងអស់នោះជាអ្នកបានសមាបត្តិដូចគ្នាខ្លះ បានអារម្មណ៍ដូចគ្នាខ្លះ ហេតុនោះទើបឈ្មោះថា **សមចិត្តា** យ៉ាងនេះក៏មាន ។

បទថា **ហដ្ឋា** (រីករាយ) បានដល់ ត្រេកអរ រីករាយ សប្បាយចិត្ត ។ បទថា **សាធុ** (សូមប្រទានឱកាស) ជានិបាត ក្នុងអត្ថថា អង្វរ ។ បទថា **អនុកម្បំ ឧបាទាយ** (ទ្រង់ព្រះករុណា) សេចក្តីថា អាស្រ័យសេចក្តីអនុគ្រោះ ករុណា ទតមើលព្រះថេរៈ ។ សេចក្តីពិតក្នុងឋានៈនេះ មានកិច្ចដែលត្រូវអនុគ្រោះព្រះថេរៈ ។ ក្នុងថ្ងៃដែលព្រះសាស្តាកំពុងត្រាស់ វេទនាកម្មដ្ឋាន ដល់ទីឃនខបរិព្វាជកជាក្មួយ

ឯឈ្មោះសូករខាតៈ ព្រះថេរៈឈរកាន់ផ្ចិតបក់ថ្វាយព្រះសាស្តា បានសម្រេចសាវក បារមីញាណ ដោយមិនចាំបាច់ណែនាំ ដូចអ្នកបរិភោគភោជនដែលគេទុកដើម្បីអ្នក ដទៃ បន្ទោបង់សេចក្តីស្រេកឃ្លាន និងដូចបុគ្គលយកគ្រឿងប្រដាប់ដែលគេចាត់ចែង ទុកដើម្បីអ្នកដទៃ មកប្រដាប់សិរសៈខ្លួនក្នុងថ្ងៃនោះឯង ឈ្មោះថា ព្រះមានព្រះភាគ ទ្រង់អនុគ្រោះហើយ ។ ទេវតាទាំងឡាយទូលអង្វរព្រះមានព្រះភាគថា សូមព្រះ មានព្រះភាគមេត្តាស្តេចយាងទៅអនុគ្រោះពួកទេវតា និងមនុស្សដ៏សេស នៅក្នុង ទីនោះ ។

បទថា **ពលវា បុរិសោ** (បុរសមានកម្លាំង) សេចក្តីថា មនុស្សកម្លាំងតិច មិនអាចនឹងបត់ដៃចូល ឬលាដៃចេញបានឆាប់រហ័ស មនុស្សមានកម្លាំងប៉ុណ្ណោះ អាច ហេតុនោះ លោកទើបពោលដូច្នេះ ។ បទថា **សម្មុខេ បាតុរហោសិ** (ទៅ ប្រាកដចំពោះមុខ) សេចក្តីថា បានប្រាកដក្នុងទីចំពោះមុខ គឺ ចំពោះមុខនោះឯង ។ បទថា **ភគវា ឯតទវោច** (ព្រះមានព្រះភាគបានត្រាស់) សេចក្តីថា ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះ គឺ ហេតុដែលព្រះអង្គស្តេចមក ដោយន័យថា **ឥធ សារីបុត្ត** ជាដើម ។ បានឮមកថា ព្រះមានព្រះភាគមានព្រះតម្រិះយ៉ាងនេះថា ប្រសិនបើ ជនពាល អកតញ្ញូបុគ្គលខ្លះ មិនថាជាភិក្ខុ ភិក្ខុនីក្តី ជាឧបាសក ឧបាសិកាក្តី នឹង គិតយ៉ាងនេះថា ព្រះសារីបុត្តបានបរិស័ទច្រើនហួសប្រមាណ ព្រះសម្មាសម្ពុទ្ធទ្រង់

មិនអាចនឹងអត់ទ្រាំក្នុងរឿងនេះបាន ទើបស្តេចមក ទ្រង់តាំងបរិស័ទដោយសេចក្តីឥស្សា បុគ្គលនោះគិតប្រទូសរ៉ាយនឹងតថាគត ដូច្នេះ នឹងគប្បីកើតក្នុងអបាយ ។ ព្រះមានព្រះភាគកាលត្រាស់ដល់ហេតុដែលព្រះអង្គស្តេចមក បានត្រាស់ព្រះពុទ្ធតម្រាស់ថា **ឥធ សារីបុត្ត** ជាដើម ។

លុះត្រាស់ដល់ហេតុដែលព្រះអង្គស្តេចមកយ៉ាងនេះហើយ ឥឡូវនេះដើម្បីនឹងត្រាស់កម្លាំងនៃសមាបត្តិ ទើបត្រាស់ព្រះពុទ្ធតម្រាស់ថា **តា ខោ បន សារីបុត្ត ទេវតា ទសបិ ហុត្វា** (សារីបុត្ត ក៏ទេវតាទាំងនោះ ១០ អង្គខ្លះ) ជាដើម ។ ក្នុងចំណែកនោះ គួរនឹងនាំអត្ថមក ដោយអំណាចយសខ្លះ ដោយអំណាចសមាបត្តិខ្លះ ។ នឹងពោលអំពីអំណាចយសមុន ទេវតាដែលមានយសធំ បានឈរក្នុងទីកន្លែងមួយ ១០ អង្គ ។ ទេវតាមានយសបន្ទាប់ពីនោះ បានឈរក្នុងទីកន្លែងមួយ ២០ អង្គ ។ ទេវតាមានយសបន្ទាប់ពីនោះ ។បេ។ បានឈរក្នុងទីកន្លែងមួយ ៦០ អង្គ ។ ចំណែកដោយអំណាចសមាបត្តិ គប្បីជ្រាបដូច្នេះ ទេវតាពួកណាចម្រើនសមាបត្តិថ្នាក់ប្រណីត ទេវតាទាំងនោះ បានឈរក្នុងទីកន្លែងមួយ ៦០ អង្គ ។ ទេវតាពួកណាចម្រើនសមាបត្តិទាបជាងនោះ ទេវតាទាំងនោះ បានឈរនៅក្នុងទីកន្លែងមួយ ៥០ អង្គ ។ ទេវតាពួកណាចម្រើនសមាបត្តិទាបជាងនោះ ។បេ។ ទេវតាទាំងនោះ បានឈរក្នុងទីកន្លែងមួយ ១០ អង្គ ។ម្យ៉ាងទៀត ទេវតាពួកណាចម្រើន

*សមាបត្តិថ្នាក់ទាប ទេវតាទាំងនោះ បានឈរក្នុងទីកន្លែងមួយ ១០ អង្គ ទេវតាពួកណាចម្រើនសមាបត្តិប្រណីតជាងនោះ ទេវតាទាំងនោះបានឈរក្នុងទីកន្លែងមួយ ២០ អង្គ ទេវតាពួកណាចម្រើនសមាបត្តិប្រណីតជាងនោះ ។បេ។ ទេវតាទាំងនោះបានឈរក្នុងទីកន្លែងមួយ ៦០ អង្គ ។*

*បទថា* **អារគ្គេ កោដិនិតុទនមត្តេ** *(ចុងដែកស្រួចដែលចាក់ចុះ) បានដល់ ក្នុងទីល្មមចាក់ចុងម្ជុលចុះបាន ។ បទថា* **ន ច អញ្ញមញ្ញំ ព្យាពាធេន្តិ** *(មិនប្រៀតបៀតគ្នានិងគ្នា) សេចក្តីថា សូម្បីឈរក្នុងទីចង្អៀតយ៉ាងនេះ ក៏មិនប្រៀតបៀតគ្នា មិនប៉ះគ្នា មិនសង្កត់គ្នា មិនរុញច្រានគ្នាឡើយ មិនមានហេតុអ្វីដែលនឹងត្រូវនិយាយថា ដៃលោកប៉ះយើង ជើងលោកប៉ះយើង លោកឈរជាន់យើង ដូច្នេះ ។ បទថា* **តត្ថ នូន** *(ក្នុងភពនោះពិតមែន) បានដល់ ក្នុងភពនោះដោយពិត ។ បទថា* **តថា ចិត្តំ ភាវិតំ** *(ចិត្តនោះ...អប់រំហើយ) សេចក្តីថា ចិត្តដែលទេវតាទាំងនោះអប់រំដោយអាការនោះ ។ បទថា* **យេន តា ទេវតា** *(នូវហេតុដែលទេវតាទាំងនោះ) សេចក្តីថា ចិត្តដែលទេវតាអប់រំដោយអាការនោះ ទើបជាហេតុឲ្យទេវតាទាំងនោះសូម្បីមានចំនួន ១០ ។បេ។ ក៏ឈរបាន និងមិនប្រៀតបៀតគ្នា ។ បទថា* **ឥធេវ ខោ** *(ក្នុងសាសនានេះឯង) បានដល់ ក្នុងសាសនា ឬក្នុងមនុស្សលោក ។ ជាសត្តមីវិភត្តិ ។ សេចក្តីថា ក្នុងសាសនានេះឯង ក្នុងមនុស្សលោកនេះឯង ។ ពិតហើយ ចិត្តដែល*

ទេវតាទាំងនោះអប់រំហើយ ក្នុងមនុស្សលោកនេះឯង និងក្នុងសាសនានេះឯង ដែលជាហេតុឲ្យទេវតាទាំងនោះកើតក្នុងរូបភពក៏មាន ឯទេវតាទាំងនោះ ដែលមកពីរូបភពនោះ និម្មិតអត្តភាពតូចល្អិតឈរយ៉ាងនេះ ។ បណ្ដាទេវតាទាំងនោះ សូម្បីទេវតាដែលធ្វើមគ្គ និងផល ៣ ឲ្យកើតក្នុងសាសនារបស់ព្រះកស្សបទសពល នឹងមានក៏ពិត តែព្រះមានព្រះភាគទ្រង់ត្រាស់ថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយមានអនុសាសនីដូចគ្នា ពាក្យទូន្មានដូចគ្នា កាលទ្រង់ធ្វើពាក្យទូន្មានរបស់ព្រះពុទ្ធអង្គដទៃៗ ជាពាក្យទូន្មានរបស់ព្រះអង្គនេះឯង ទើបត្រាស់ថា **ឥធេវ ខោ សារីបុត្ត** ដូច្នេះ ព្រះតថាគតត្រាស់កម្លាំងនៃសមាបត្តិ ដោយព្រះពុទ្ធតម្រាស់ត្រឹមប៉ុណ្ណេះឯង ។

ឥឡូវនេះ កាលនឹងត្រាស់អនុសាសនីតាមនិយាម ប្រារព្ធព្រះសារីបុត្តត្ថេរ ទើបត្រាស់ថា **តស្មាតិហ សារីបុត្ត** (ព្រោះដូច្នោះឯង សារីបុត្ត) ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **តស្មា** (ព្រោះដូច្នោះ) សេចក្ដីថា ព្រោះហេតុដែលទេវតាទាំងនោះ ធ្វើសមាបត្តិដែលមានក្នុងភពនេះឯងឲ្យកើតហើយ ទើបបានកើតក្នុងភពដែលមានហើយ ។ បទថា **សន្តិន្ទ្រិយា** (មានឥន្ទ្រិយស្ងប់) សេចក្ដីថា មានឥន្ទ្រិយស្ងប់ ព្រោះឥន្ទ្រិយទាំង ៥ ស្ងប់ ត្រជាក់ ប្រណីត ។ បទថា **សន្តមានសា** (មានចិត្តរម្ងាប់ហើយ) បានដល់ មានចិត្តស្ងប់ ព្រោះចិត្តស្ងប់ ត្រជាក់ ប្រណីត ។ បទថា **សន្តំយេវុបហារំ ឧបហរិស្សាម** (ទើបនាំកាយ និងចិត្តដែលស្ងប់រម្ងាប់ហើយ

ប៉ុណ្ណោះចូលទៅ) សេចក្តីថា ពួកយើងទើបស្នើសូម (ការរាប់អានបូជាដោយ) កាយ និងចិត្ត ដែលស្ងប់ ត្រជាក់ ប្រណីត នោះឯងចូលទៅ ។ បទថា **សព្រហ្ម-ចារីសុ** (ក្នុងសព្រហ្មចារីទាំងឡាយ) បានដល់ ក្នុងសហធម្មិកទាំងឡាយអ្នកប្រព្រឹត្តធម៌ជាន់ខ្ពស់ដែលស្មើគ្នា ជាអ្នកមានឧទ្ទេសដូចគ្នាជាដើម ។ ដោយព្រះពុទ្ធតម្រាស់នេះថា **ឯវញ្ហិ តេ សារីបុត្ត សិក្ខិតព្វំ** (សារីបុត្ត អ្នកគប្បីសិក្សាយ៉ាងនេះឯង) ដូច្នេះ ព្រះមានព្រះភាគ ទ្រង់បានធ្វើទេសនាឲ្យជាភាសិតនៃព្រះសព្វញ្ញុពុទ្ធ ដោយឋានៈត្រឹមប៉ុណ្ណោះ ។ បទថា **អនស្សុំ** (បាននាំគ្នាវិនាសហើយ) បានដល់ វិនាសហើយ ។ បទថា **យេ ឥមំ ធម្មបរិយាយំ នាស្សោសុំ** (ពួកអន្តិរិយបរិព្វាជក មិនបានស្តាប់ធម្មប្បរិយាយនេះ) សេចក្តីថា ព្រះមានព្រះភាគទ្រង់បញ្ចប់ទេសនាដោយអនុសន្ធិថា ពួកអ្នកបួសដែលរាប់អានលទ្ធិដទៃ អាស្រ័យទិដ្ឋិរបស់ខ្លួនដ៏លាមក សូន្យចាកសារៈ មិនបានប្រយោជន៍ មិនបានស្តាប់ធម្មទេសនាបែបនេះ ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## *"ពោលដោយហេតុបច្ច័យនៃការវិវាទគ្នា"*

*ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៨២] *បទថា **វរណាយំ វិហរតិ** (នៅជិតនគរវរណា) សេចក្ដីថា ក្រុងមានឈ្មោះថា **វរណា** ព្រះមហាកច្ចានៈចូលទៅអាស្រ័យក្រុងនោះ ។ បទថា **កាមរាគវិនិវេសវិនិពន្ធបលិគេធបរិយុដ្ឋានជ្ឈោសានហេតុ** (ព្រោះតែកាមរាគៈ ជាចំណងចងរឹត ធ្វើឲ្យជាប់ជំពាក់ គ្របសង្កត់រួបរឹត) សេចក្ដីថា ព្រោះកាមរាគៈជាចំណងជាហេតុ ធ្លាក់នៅក្នុងអំណាចកាមរាគៈជាហេតុ មានសេចក្ដីត្រេកអរក្នុងកាមរាគៈជាហេតុ ព្រោះការរួបរឹតនៃកាមរាគៈជាហេតុ និងព្រោះការគ្របសង្កត់របស់កាមរាគៈជាហេតុ ។ មានពាក្យអធិប្បាយដូច្នេះ ព្រោះកាមរាគៈដែលកើតឡើង អាស្រ័យកាមគុណ ៥ នោះ ចាប់ទុកជាដើមជាហេតុ ព្រោះត្រូវកាមរាគៈរួបរឹត ចងទុក ព្រោះល្មោភ គឺ ព្រោះវិលទៅរកកាមរាគៈនោះឯង ដូចជាល្បប់ធំ ព្រោះរួបរឹតដោយកាមរាគៈនោះឯង គឺ ត្រូវកាមរាគៈចាប់ទុក និងព្រោះជាប់ជំពាក់ដោយកាមរាគៈ គឺ ត្រូវកាមរាគៈលេបទុក ។ សូម្បីក្នុងបទថា **ទិដ្ឋិរាគោ** ជាដើម ក៏ន័យឯង ។ តែក្នុងបទថា **ទិដ្ឋិរាគោ** នេះ បណ្ឌិតគប្បីជ្រាបថា បានដល់ រាគៈដែលកើតឡើង ព្រោះ*

អាស្រ័យទិដ្ឋិ ៦២ ។ បទថា **បុរត្ថិមេសុ ជនបទេសុ** (ក្នុងជនបទទិសកើត) សេចក្តីថា អំពីទីដែលព្រះថេរៈទៅទិសខាងកើត មានសាវត្ថីជនបទ ។ ព្រះថេរៈកាលអង្គុយ ក៏អង្គុយបែរមុខទៅផ្លូវទិសនោះ ដូច្នោះ លោកទើបពោលយ៉ាងនេះ ។ បទថា **ឧទានំ ឧទានេសិ** (បន្លឺឧទាន) ប្រែថា ឧទានឡើង ។ ដូចជាប្រេង មិនអាចរក្សាទុកក្នុងគ្រឿងវាល់ ក៏បានហៀរចេញ គេហៅប្រេងនោះថា ប្រេងដែលសល់ និងទឹកដែលមិនអាចទប់បាន បានហូរហៀរទៅ គេហៅទឹកនោះថា ទឹកជន់ យ៉ាងណា ពាក្យដែលកើតអំពីបីតិក៏ដូច្នោះ ទប់ហទយៈមិនបាន គឺ មិនរក្សាទុកខាងក្នុង ក៏ធ្លាយចេញមកខាងក្រៅ លោកហៅថា **ឧទាន** អធិប្បាយថា ព្រាហ្មណ៍អាភមទណ្ឌៈ បន្លឺពាក្យដែលកើតពីបីតិ យ៉ាងនេះ ។

ចប់អដ្ឋកថា សូត្រទី ៦

---

# អដ្ឋកថាសូត្រទី ៧

## *"បណ្ឌិត និងព្រះថេរៈមិនមែនព្រោះតែមនុស្សចាស់"*

*ក្នុងសូត្រទី ៧ មាននិច្ឆ័យដូចតទៅនេះ ៖*

[២៨៣] *បទថា* **គុន្ទាវនេ** *(ព្រៃគុន្ទាវ័ន) បានដល់ ព្រៃដែលមានឈ្មោះយ៉ាង នេះ ។ បទថា* **ឧបសង្កមិ** *(ចូលទៅរក) សេចក្តីថា កណ្ឌរាយនព្រាហ្មណ៍បានជ្រាប ដំណឹងថា បានឮមកថា ព្រះមហាកច្ចានត្ថេរ ឃើញមនុស្សចាស់ប្រហែលឪពុក ខ្ញុំនក៏ដោយ ជីតាក៏ដោយ ជីទួតក៏ដោយ មិនសំពះ មិនក្រោកទទួល មិនអញ្ជើញ ឲ្យអង្គុយ ដូច្នេះ គិតថា មិនមាននរណាអាចដោះស្រាយរឿងប៉ុណ្ណេះឲ្យសម្រេច បាន ឃើងនឹងចូលទៅគ្របសង្កត់លោក ដូច្នេះ បរិភោគអាហារព្រឹកហើយ ចូល ទៅរកព្រះមហាកច្ចានៈដល់ទីនៅ ។ បទថា* **ជិណ្ណេ** *(ជរា) បានដល់ មនុស្សគ្រាំគ្រា ព្រោះជរា ។ បទថា* **វុឌ្ឍេ** *(ចាស់) បានដល់ អ្នកចម្រើនដោយវ័យ ។ បទថា* **មហល្លកេ** *(ចាស់) បានដល់ បុគ្គលចាស់ដោយជាតិ (កើតមកយូរ) ។ បទថា* **អទ្ធគតេ** *(កន្លងកាល) បានដល់ អ្នកកន្លងវេលាយូរហើយ ។ បទថា* **វយោអនុប្បត្តេ** *(វ័យជ្រុល) បានដល់ អ្នកចូលដល់បច្ឆិមវ័យ ។ បទថា* **តយិទំ ភោ កច្ចាន តថេវ** *(ដំណឹងដែលបានឮមកនោះ ពិតឬ) សេចក្តីថា ព្រះកច្ចានៈដ៏ចម្រើន ប្រការ*

ណាដែលពួកខ្ញុំស្តាប់មកយ៉ាងច្បាស់ ប្រការនោះក៏សមនឹងរឿងដែលខ្ញុំបានឃើញនេះ ដូច្នោះ រឿងក៏ពិតនោះ មិនជាដទៃ ។ បទថា **ន ហិ ភវំ កច្ចានោ ព្រាហ្មណេ** (ព្រោះព្រះកច្ចានៈមិនអភិវាទ ... ព្រាហ្មណ៍ ...) នេះ គណ្ឋរាយនព្រាហ្មណ៍ពោលសំដៅដល់ខ្លួនឯង ។ ន័យថា សេចក្តីនោះមានអធិប្បាយដូច្នេះថា ព្រះកច្ចានៈដ៏ចម្រើន ឃើញពួកយើងជាមនុស្សចាស់ដូច្នេះ ក៏មិនមានសូម្បីត្រឹមតែការសំពះសូម្បីត្រឹមតែការក្រោកទទួល សូម្បីត្រឹមតែការអញ្ជើញឲ្យទីអង្គុយ ។ បទថា **ន សម្បន្នមេវ** (មិនសមគួរពិត) សេចក្តីថា មិនសមគួរឡើយ គឺ មិនសមគួរនោះឯង ។

ព្រះថេរៈស្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ គិតថា ព្រាហ្មណ៍នេះមិនស្គាល់មនុស្សចាស់ មិនស្គាល់ក្មេង ចាំយើងប្រាប់មនុស្សចាស់ និងក្មេងដល់គេ ដូច្នេះកាលនឹងអធិប្បាយទេសនា ទើបពោលពាក្យថា **អត្ថិ ព្រាហ្មណ** (ព្រាហ្មណ៍...មានហើយ) ជាដើម ។ បណ្តាបទទាំងនោះ បទថា **ជានតា** (ទ្រង់ជ្រាប) បានដល់ទ្រង់ជ្រាបន័យទាំងពួង ។ បទថា **បស្សតា** (ទ្រង់ឃើញ) បានដល់ ទ្រង់ឃើញន័យនោះៗ ឯង ដូចឃើញផ្លែកន្ទួតព្រៃដាក់ទុកក្នុងដៃ ។ បទថា **វុឌ្ឍភូមិ** (ភូមិមនុស្សចាស់) បានដល់ ហេតុដែលធ្វើឲ្យជាមនុស្សចាស់ ។ បទថា **ទហរភូមិ** (ភូមិក្មេង) បានដល់ ហេតុដែលធ្វើឲ្យក្មេង ។ បទថា **អសីតិកោ** (មានអាយុ ៨០ ឆ្នាំ) បានដល់

មានវ័យ ៨០ ឆ្នាំ ។ បទថា **កាមេ បរិភុញ្ជតិ** (នៅបរិភោគកាម) សេចក្តីថា នៅត្រូវការបរិភោគកាមទាំង ២ គឺ វត្ថុកាម និងកិលេសកាម ។ បទថា **កាមមជ្ឈាវសតិ** (នៅក្នុងកណ្តាលកាម) សេចក្តីថា នៅ គឺ គ្រប់គ្រងកាមទាំង ២ យ៉ាង ដូចជាម្ចាស់ផ្ទះនៅគ្រប់គ្រងផ្ទះ ។ បទថា **កាមបរិយេសនាយ ឧស្សុកោ** (ខ្វល់ខ្វាយក្នុងការស្វែងរកកាម) សេចក្តីថា នៅខ្វល់ខ្វាយដើម្បីស្វែងរកកាមទាំង ២ យ៉ាង ។ បទថា **សោ ពាលោ ន ថេរោត្វេវ សង្ខំ គច្ឆតិ** (គេរមែងដល់ការរាប់ថា ក្មេងមិនមែនមនុស្សធំដោយពិត) សេចក្តីថា បុគ្គលនោះមិនរាប់ថា ជាមនុស្សធំ រាប់ថាជាក្មេង គឺ អ្នកមានបញ្ញាទន់ខ្សោយដោយពិត សមដូចដែលត្រាស់ទុកថា ៖

**ន តេន ច ថេរោ ហោតិ យេនស្ស បលិតំ សិរោ**

**បរិបក្កោ វយោ តស្ស មោឃជិណ្ណោតិ វុច្ចតិ ។**

បុគ្គលនឹងជាថេរៈ ព្រោះហេតុដែលមានសក់ស្កូវលើសិរសៈក៏មិនមែន បុគ្គលនោះមានវ័យគ្រាំគ្រាហើយ ហៅថា មនុស្សចាស់ទទេ ។

បទថា **ទហរោ** (ក្មេង) បានដល់ ក្មេងជំទង់ ។ បទថា **យុវា** (កំលោះ) បានដល់ ប្រកបដោយភាពជាកម្លោះ ។ បទថា **សុសុកាឡកេសោ** (មានសក់ខ្មៅ) សេចក្តីថា មានសក់ខ្មៅល្អ ។ បទថា **ភទ្រេន យោព្វនេន សមន្នាគតោ** (ប្រកបដោយភាពជាកំលោះដែលចម្រើន) សេចក្តីថា បុគ្គលឈ្មោះថា ជាកំលោះ ព្រោះប្រកប

ដោយភាពជាកម្លោះណា លោកសម្តែងសេចក្តីជាកម្លោះនោះថា **កំពុងចម្រើន** ។ បទថា **បឋមេន វយសា** (ត្រូវនៅក្នុងបឋមវ័យ) សេចក្តីថា អាយុ ៣៣ ឆ្នាំ ឈ្មោះជាបឋមវ័យ ប្រកបដោយបឋមវ័យនោះ ។ បទថា **បណ្ឌិតោ ថេរោត្វេវ សង្ខំ គច្ឆតិ** (គេរមែងដល់ការរាប់ថា បណ្ឌិត ជាមនុស្សធំដោយពិត) សេចក្តីថា បុគ្គលនោះ គឺបែបនេះ រាប់ថាជាបណ្ឌិតផង ជាថេរៈផងនោះឯង ។ សមដូចដែលត្រាស់ទុកថា ៖

យម្ហិ សច្ចញ្ច ធម្មោ ច អហឹសា សំយមោ ទមោ
ស វេ វន្តមលោ ធីរោ សោ ថេរោតិ បវុច្ចតិ ។

បុគ្គលណាមានសច្ចៈ ធម៌ទៀង មិនបៀតបៀន សង្រួម
ហ្វឹកហាត់ បុគ្គលនោះឯងជាអ្នកខ្ជាក់នូវកិលេសដូចធូលី
ហើយ ជាអ្នកប្រាជ្ញ តថាគតហៅថា ថេរៈ (មនុស្សធំ) ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៨

## *“ហេតុប្រព្រឹត្តទៅ និងមិនប្រព្រឹត្តទៅដើម្បីប្រយោជន៍”*

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៨៤] *បទថា* ***ចោរា ពលវន្តោ ហោន្តិ*** *(ពួកចោរមានកម្លាំង) សេចក្តីថា ពួកចោរព្រមព្រៀងដោយបក្ខពួក ព្រមព្រៀងដោយបរិវារ ព្រមព្រៀងដោយទីនៅ ព្រមព្រៀងដោយពាហនៈ ។ បទថា* ***រាជានោ តស្មឹ សមយេ ទុព្វលា ហោន្តិ*** *(សម័យនោះ ស្តេចផែនដីថយកម្លាំង) សេចក្តីថា ក្នុងសម័យនោះ ចំណែកស្តេចទាំងឡាយខ្សោយកម្លាំង ព្រោះមិនមានសម្បត្តិទាំងនោះ ។ បទថា* ***អតិយាតុំ*** *(នឹងស្តេចត្រឡប់ចូល) សេចក្តីថា ដើម្បីត្រួតមើលរាជបទខាងក្រៅ ហើយបំណាន់នឹងចូលព្រះនគរក្នុងខណៈដែលត្រូវការ ។ បទថា* ***និយ្យាតុំ*** *(ស្តេចចេញទៅ) សេចក្តីថា មិនមានសេចក្តីជាសុខដែលស្តេចនឹងចេញទៅ មិនថា ក្នុងបឋមយាម មជ្ឈិមយាម ឬបច្ឆិម-យាម ដោយមានព្រះតម្រាស់ថា ពួកចោរប្លន់ជនបទ ចាំការពារពួកវា ។ បទថា* ***បច្ចន្តិមេ វា ជនបទេ អនុសញ្ញាតុំ*** *(ឬនឹងចេញពាក្យបញ្ជាទៅកាន់ជនបទជាយដែន) សេចក្តីថា សូម្បីនឹងគ្រប់គ្រងជនបទ ជាយដែន ដើម្បីសាងទីនៅ សាងស្ពាន ជីកស្រះបោក្ខរណី និងសាងសាលាជាដើម ក៏មិនបានសុខ ។ បទថា* ***ព្រាហ្មណគហ-***

**បតិកានំ** បានដល់ ពួកព្រាហ្មណ៍ និងគហបតីទាំងឡាយដែលនៅខាងក្នុងព្រះនគរ ។ បទថា **ពាហិរានិ វា កម្មន្តានិ** (ការងារខាងក្រៅ) បានដល់ ការងារស្រែចំការក្រៅស្រុក ។ បទថា **បាបភិក្ខូ ពលវន្តោ ហោន្តិ** (ពួកភិក្ខុអាក្រក់មានកម្លាំង) សេចក្តីថា ពួកភិក្ខុអាក្រក់ជាចំណែកមានកម្លាំង ព្រមព្រៀងដោយឧបដ្ឋាកប្រុសស្រីជាច្រើន និងបានព្រះរាជា និងរាជមហាមាត្រជាទីពឹង ។ បទថា **បេសលា ភិក្ខូ តស្មឹ សមយេ ទុព្ពលា ហោន្តិ** (សម័យនោះភិក្ខុអ្នកមានសីលជាទីស្រឡាញ់ រមែងថយកម្លាំង) សេចក្តីថា ក្នុងសម័យនោះ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់ ជាអ្នកខ្សោយកម្លាំង ព្រោះមិនមានសម្បត្តិទាំងនោះ ។ បទថា **តុណ្ហីភូតា តុណ្ហីភូតា វ សង្ឃមជ្ឈេ សង្កសាយន្តិ** (ជាអ្នកនៅស្ងៀមអង្គុយក្នុងកណ្តាលសង្ឃ) សេចក្តីថា ជាអ្នកអង្គុយស្ងៀមក្នុងកណ្តាលសង្ឃ មិនអាចងើបមុខហាមាត់ពោលអ្វីៗ សូម្បីពាក្យតែមួយ អង្គុយដូចជាសោកសៅ ។ បទថា **តយិទំ** (សេចក្តីនេះ) បានដល់ ហេតុនោះៗ ។ ក្នុងចំណែកស ក៏គប្បីជ្រាបផ្ទុយគ្នានឹងដែលពោលហើយ ។

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*"ការបដិបត្តិខុស និងការបដិបត្តិត្រូវ"*

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៨៥] *បទថា* **មិច្ឆាបដិបត្តាធិករណហេតុ** *(ព្រោះការបដិបត្តិខុសជាហេតុ) សេចក្តីថា ព្រោះធ្វើ គឺ បដិបត្តិខុសជាហេតុ ។ បទថា* **ញាយំ ធម្មំ កុសលំ** *(ញាយកុសលធម៌) បានដល់ កុសលធម៌ព្រមទាំងវិបស្សនា និងមគ្គ ។ ព្រោះថា បុគ្គលបែបនេះ រមែងមិនអាចញ៉ាំងកុសលធម៌ព្រមទាំងវិបស្សនា និងឲ្យសម្រេច គឺ ឲ្យដល់ព្រមបាន ។ ក្នុងចំណែកល្អ ក៏គប្បីជ្រាបផ្ទុយគ្នានឹងដែលពោលហើយ ។ ក្នុងសូត្រនេះ ត្រាស់មគ្គព្រមទាំងវិបស្សនា ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*"ហេតុឲ្យព្រះសទ្ធម្មអន្តធាន និងតាំងនៅ"*

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៨៦] បទថា **ទុគ្គហិតេហិ** (ដែលខ្ជួនរៀនមិនល្អ) បានដល់ ដែលកាន់យកមកខុសរបៀប ។ បទថា **ព្យញ្ជនបដិរូបកេហិ** (ដោយព្យញ្ជនៈបដិរូប) បានដល់ ដែលមានព្យញ្ជនៈល្អ គឺ ដែលបានមកដោយមានអក្ខរវិចិត្រ ។ បទថា **អត្ថញ្ច ធម្មញ្ច បដិពាហន្តិ** (ជំទាស់ក្នុងអត្ថ និងធម៌) សេចក្តីថា រមែងជំទាស់ទាំងអដ្ឋកថា ទាំងបាលីនៃសុត្តន្តៈដែលខ្ជួនកាន់មកខុស ក្រៃលែងបំផុត ។ ចំណែកល្អ ក៏គប្បីជ្រាបផ្ទុយគ្នានឹងដែលពោលហើយ ។ ក្នុងសូត្រនេះ ត្រាស់ទាំងសេចក្តីចម្រើន និងសេចក្តីវិនាសនៃព្រះសាសនា ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០

**ចប់សមចិត្តវគ្គទី ៤**

**រួមក្នុងវគ្គនេះមាន ១០ សូត្រ**

**ព្រះអដ្ឋកថាកែសេចក្តី ១០ សូត្រ**

# បរិសវគ្គទី ៥

## អដ្ឋកថាសូត្រទី ១

### *"បរិស័ទ ២ ជំពូក គឺ រាក់ និងជ្រៅ"*

*វគ្គទី ៥ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៨៧] បទថា* ***ឧត្តានា*** *(រាក់) បានដល់ បើកផ្ចារ មិនបិទបាំង ។ បទថា* ***គម្ភីរា*** *(ជ្រៅ) បានដល់ កំបាំង បិទបាំង ។ បទថា* ***ឧទ្ធតា*** *(រាយមាយ) បានដល់ ប្រកបដោយសេចក្ដីប្របូកប្របល់ ។ បទថា* ***ឧន្នឡា*** *(មានមានះ) បានដល់ ប្រកាន់ខ្លួន អធិប្បាយថា មានមានះដុះឡើង ។ បទថា* ***ចបលា*** *(មានចិត្តឃ្លេងឃ្លោង) សេចក្ដីថា ប្រកបដោយសេចក្ដីលាក់លៀម មានការតាក់តែងចីវរជាដើម ។ បទថា* ***មុខរា*** *(មាត់រឹង) បានដល់ ឆ្មាស់ វាចាគ្រោតគ្រាត ។ បទថា* ***វិកិណ្ណវាចា*** *(សំដីរាយរាយ) បានដល់ និយាយមិនសង្រួម និយាយពាក្យដែលគ្មានប្រយោជន៍បានទាំងថ្ងៃ ។ បទថា* ***មុដ្ឋស្សតី*** *(មានសតិកាន់ច្រឡំ) បានដល់ គ្មានសតិ ។ បទថា* ***អសម្បជានា*** *(មិនមានសម្បជញ្ញៈ) បានដល់ គ្មានបញ្ញា ។ បទថា* ***អសមាហិតា*** *(មានចិត្តមិនខ្ជាប់ខ្ជួន) បានដល់ មិនបានសូម្បីត្រឹមតែចិត្តមានអារម្មណ៍តែមួយ ។ បទថា* ***បាកតិន្ទ្រិយា*** *(មិនសង្រួមឥន្ទ្រិយ) សេចក្ដីថា ប្រកបដោយឥន្ទ្រិយដែលតាំងនៅតាមប្រក្រតី ត្រូវបើក មិនរក្សា (មិនសង្រួម) ។ ចំណែកខាងល្អ គប្បីជ្រាប*

*ដោយន័យផ្ទុយគ្នាដែលពោលហើយនោះឯង ៗ*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## “បរិស័ទដែលបែកជាពួក និងសាមគ្គីគ្នា”

ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៨៨] បទថា **ភណ្ឌនជាតា** (ប្រេះឆាគ្នា) សេចក្តីថា ខាងដើមនៃការឈ្លោះ លោកហៅថា ប្រេះឆា ។ ការប្រេះឆានោះកើតហើយដល់ភិក្ខុទាំងនោះ ដូច្នោះ ទើបឈ្មោះថា កើតសេចក្តីប្រេះឆា ។ មួយទៀត បានដល់ ការឈ្លោះដែលកើតឡើង ដោយពោលពាក្យជាដើមថា ពួកយើងនឹងដាក់អាជ្ញា នឹងឲ្យចាប់ចងពួកលោក ន័យចំណែកគ្រហស្ថ គប្បីជ្រាបប៉ុណ្ណេះ ។ ចំណែកពួកបព្វជិត ដែលពោលវាចាដល់ការកន្លងអាបត្តិ ឈ្មោះថា កើតជម្លោះគ្នា ។ បទថា **វិវាទាបន្នា** (វិវាទគ្នា) បានដល់ សូម្បីវាទៈដែលជំទាស់គ្នា ។ បទថា **មុខសត្តីហិ វិតុទន្តា** (យកលំពែង គឺ មាត់ចាក់ដោតគ្នា) សេចក្តីថា វាចាជាទុព្ភាសិត លោកហៅថា លំពែង គឺ មាត់ ព្រោះអត្ថថា កាត់នូវគុណសេចក្តីល្អទាំងឡាយ សេចក្តីល្អ គឺ ចាក់គ្នាដោយវាចានោះឯង ។ បទថា **សមគ្គា** (សាមគ្គីគ្នា) សេចក្តីថា ប្រកបដោយភាពជាអ្នកព្រមព្រៀងគ្នា ដោយការធ្វើវត្ថុទាំងនេះ គឺ ការងារតែមួយ ឧទ្ទេសតែមួយ មានការសិក្សាស្មើគ្នា ។ បទថា **បិយចក្ខូហិ** (ដោយភ្នែកជាទីស្រឡាញ់) បានដល់ ដោយចក្ខុដែល

ប្រកបដោយមេត្តា បំណាច់ល្អដល់គ្នា ។

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## *"បរិស័ទដែលមិនមានអគ្គបុគ្គល និងមានអគ្គបុគ្គល"*

*ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៨៩] បទថា* ***អគ្គវតី*** *(មានអគ្គបុគ្គល) បានដល់ មានបុគ្គលខ្ពស់បំផុត ឬប្រកបដោយការបដិបត្តិដ៏ប្រសើរបំផុត គឺ ខ្ពស់បំផុត ។ បរិស័ទផ្ទុយពីបរិស័ទដែលមានបុគ្គលដ៏ប្រសើរនោះ ឈ្មោះថា បរិស័ទមិនមានអគ្គបុគ្គល ។ បទថា* ***ពាហុល្លិកា*** *(ជាបុគ្គលប្រាថ្នាច្រើន) បានដល់ បុគ្គលបដិបត្តិដោយសេចក្ដីប្រាថ្នាច្រើនដោយបច្ច័យ ៤ មានចីវរជាដើម ។ បរិស័ទឈ្មោះថា* ***សថិលិកា*** *ព្រោះអត្ថថា កាន់សាសនាធូរថយ ។ នីវរណៈ ៥ ហៅថា* ***ឱក្កមន*** *(ឈានចុះកាន់ផ្លូវថោកទាប) ។ ក្នុងបទថា* ***ឱក្កមនេ បុព្វង្គមា*** *(ជាប្រធានក្នុងការឈានចុះកាន់ផ្លូវថោកទាប) នេះ ដោយអត្ថថា ដំណើរចុះក្រោម អធិប្បាយថា ភិក្ខុជាថេរៈទាំងនោះ បំណងដោយធ្វើនីវរណៈ ៥ ឲ្យពេញ ។ បទថា* ***បវិវេកេ និក្ខិត្តធុរា*** *(លះបង់ធុរៈក្នុងបវិវេក) សេចក្ដីថា មិនអ្នកលះបង់ធុរៈក្នុងវិវេក ៣ យ៉ាង ។ បទថា* ***ន វិរិយំ អារពន្តិ*** *(មិនប្រារព្ធសេចក្ដីព្យាយាម) សេចក្ដីថា មិនធ្វើសេចក្ដីព្យាយាម ២ យ៉ាង ។ បទថា* ***អប្បត្តស្ស បត្តិយា*** *(ដើម្បីដល់ធម៌ដែលមិនទាន់បានដល់) សេចក្ដីថា ដើម្បីត្រូវការ*

សម្រេចគុណវិសេស គឺ ឈាន វិបស្សនា មគ្គ និងផលដែលខ្លួនមិនទាន់បានសម្រេច មកអំពីមុន ។ ពីរបទក្រៅអំពីនេះ **អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិ-កិរិយា** (ដើម្បីសម្រេចធម៌ដែលមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ដែលមិនទាន់បានធ្វើឲ្យជាក់ច្បាស់) នេះ ជាវេវចនៈរបស់បទ **អប្បត្តស្ស បត្តិយា** នោះឯង ។ បទថា **បច្ឆិមា ជនតា** (ប្រជុំជនជំនាន់ក្រោយ) បានដល់ ជនដែលជាសទ្ធិវិហារិក និងអន្តេវាសិក ។ បទថា **ទិដ្ឋានុគតឹ អាបជ្ជតិ** (កាន់យកតម្រាប់តាម) សេចក្តីថា កាលធ្វើតាមដែលឧបជ្ឈាយាចារ្យធ្វើហើយ ឈ្មោះថា ប្រព្រឹត្តតាមអាចារៈរបស់លោកទាំងនោះដែលខ្លួនឃើញហើយ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យផ្ទុយគ្នាតាមដែលពោលហើយ ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## *"បរិស័ទដែលមិនមែនអរិយៈ និងជាអរិយៈ"*

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៩០] បទថា **អរិយា** (ដែលជាអរិយៈ) បានដល់ អរិយសាវកបរិស័ទ ។ បទថា **អនរិយា** (មិនមែនអរិយៈ) បានដល់ បុថុជ្ជនបរិស័ទ ។ បទថា **ឥទំ ទុក្ខន្តិ យថាភូតំ នប្បជានន្តិ** (មិនដឹងច្បាស់តាមពិតថា នេះជាទុក្ខ) សេចក្ដីថា មិនដឹងតាមសេចក្ដីពិតថា បញ្ចក្ខន្ធដែលប្រព្រឹត្តទៅក្នុងភូមិ ៣ វៀរតណ្ហា ឈ្មោះថា ទុក្ខ ទុក្ខមានត្រឹមតែប៉ុណ្ណេះ ទុក្ខក្រៅអំពីនេះ មិនមាន ។ ក្នុងបទទាំងពួងក៏ន័យនេះ ក៏ក្នុងបទដ៏សេសមានអធិប្បាយថា តណ្ហាមានក្នុងកាលមុន ដែលធ្វើទុក្ខនោះឲ្យតាំងឡើង ឈ្មោះថា **ទុក្ខសមុទ័យ** ការអស់ទៅយ៉ាងដាច់ខាត គឺ មិនកើតឡើងទៀតនៃតណ្ហានោះឯង ឬនៃសច្ចៈទាំងពីរនោះ ឈ្មោះថា **ទុក្ខនិរោធ** ។ អរិយមគ្គប្រកបដោយអង្គ ៨ ឈ្មោះថា **ទុក្ខនិរោធគាមិនីបដិបទា** ។ ក្នុងសូត្រនេះ ត្រាស់មគ្គ ៤ និងផល ៤ ដោយសច្ចៈ ៤ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

## "បរិស័ទស្រេកកស្រេកាក និងបរិស័ទផូរផង់"

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៩១] បទថា **បរិសកសាដោ** បានដល់ បរិស័ទស្រេកកស្រេកាក បរិស័ទសម្រាម អធិប្បាយថា បរិស័ទមិនមានប្រយោជន៍ ។ បទថា **បរិសមណ្ឌោ** បានដល់ បរិស័ទផូរផង់ អធិប្បាយថា បរិស័ទដែលមានប្រយោជន៍ ។ បទថា **ឆន្ទាគតឹ គច្ឆន្តិ** (ដល់ឆន្ទាគតិ) សេចក្តីថា លុះក្នុងអគតិព្រោះសេចក្តីពេញចិត្ត អធិប្បាយថា ធ្វើវត្ថុដែលមិនគួរធ្វើ ។ សូម្បីក្នុងបទដ៏សេសក៏ន័យនេះឯង ។

ក៏ការលុះក្នុងអគតិទាំង ៤ នេះ នឹងមានក្នុងការបែងចែកវត្ថុ ក្នុងស្ថានទីដែលវិនិច្ឆ័យអធិករណ៍ ។ ក្នុង ២ យ៉ាងនោះ នឹងពោលក្នុងការបែងចែកវត្ថុមុន កាលវត្ថុមិនជាទីពេញចិត្តសូម្បីដល់ពួកភិក្ខុដែលជាការៈរបស់ខ្លួន ក្នុងឋានៈដែលខ្លួនត្រូវបិញ្ចឹមរក្សា ផ្លាស់ប្តូរវត្ថុនោះ ហើយឲ្យវត្ថុដែលពេញចិត្ត ឈ្មោះថា លុះក្នុងឆន្ទាគតិ ។ តែកាលវត្ថុជាទីពេញចិត្ត សូម្បីមានដល់ភិក្ខុដែលមិនបានជាការៈរបស់ខ្លួន ក៏ផ្លាស់វត្ថុរបស់នោះ ឲ្យវត្ថុមិនជាទីពេញចិត្តទៅ ឈ្មោះថា លុះក្នុងទោសាគតិ ។ កាលមិនដឹងវត្ថុ គឺ វត្ថុដែលគួរនឹងបែងចែក និងក្រិតក្រម ឈ្មោះថា លុះក្នុង

មោហាគតិ ។ កាលផ្លាស់ប្តូរឲ្យវត្ថុដែលពេញចិត្ត ដល់បុគ្គលមាត់រឹង ឬបុគ្គលអាស្រ័យព្រះរាជាជាដើម ព្រោះខ្លាចថា កាលយើងឲ្យវត្ថុមិនជាទីពេញចិត្ត អ្នកទាំងនេះ នឹងគប្បីធ្វើសេចក្តីវិនាសឲ្យ ឈ្មោះថា លុះក្នុងភយាគតិ ។ តែភិក្ខុណាមិនប្រព្រឹត្តយ៉ាងនេះ ជាជញ្ជីងនៃភិក្ខុទាំងពួង ដាក់ខ្លួនជាកណ្តាល មានសេចក្តីល្អ វត្ថុណាគួរដល់ភិក្ខុណា ក៏ឲ្យវត្ថុនោះឯងដល់ភិក្ខុនោះ ភិក្ខុនេះឈ្មោះថា មិនលុះក្នុងអគតិ ៤ យ៉ាង ។ ចំណែកក្នុងស្ថានទីវិនិច្ឆ័យអធិករណ៍ គប្បីជ្រាបដូច្នេះ ពោលគរុកាបត្តិរបស់ភិក្ខុដែលជាការៈរបស់ខ្លួន ថាជាលហុកាបត្តិ ឈ្មោះថា លុះក្នុងឆន្ទាគតិ ។ ពោលលហុកាបត្តិរបស់ភិក្ខុពួកដទៃ ថាជាគរុកាបត្តិ ឈ្មោះថា លុះក្នុងទោសាគតិ ។ មិនដឹងការចេញចាកអាបត្តិ និងកងអាបត្តិ ឈ្មោះថា លុះក្នុងមោហាគតិ ។ ពោលអាបត្តិធ្ងន់ពិតៗ របស់ភិក្ខុមាត់រឹង ឬភិក្ខុដែលព្រះរាជាទាំងឡាយបូជា ថាជាអាបត្តិស្រាល ព្រោះខ្លាចថា កាលយើងពោលអាបត្តិ ថាជាអាបត្តិធ្ងន់ ភិក្ខុនេះនឹងគប្បីធ្វើសេចក្តីវិនាសឲ្យ ឈ្មោះថា លុះក្នុងភយាគតិ ។ តែភិក្ខុណាពោលតាមសេចក្តីពិតគ្រប់យ៉ាងរបស់ភិក្ខុទាំងពួង ឈ្មោះថា មិនលុះក្នុងអគតិទាំង ៤ យ៉ាងនោះឯង ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

## “បរិស័ទសិក្សាខុសទំនង និងត្រូវទំនង”

ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖

[២៩២] បទថា **ឱក្កាចិត្តវិនីតា** (សិក្សាខុសទំនង) បានដល់ ទូន្មានលំបាក ។ បទថា **នោ បដិបុច្ឆាវិនីតា** (មិនសិក្សាដោយការសាកសួរ) បានដល់ ជាអ្នកមិនសិក្សាដោយសាកសួរ ។ បទថា **គម្ភីរា** (ជ្រាលជ្រៅ) បានដល់ ជ្រៅដោយបាលី ដូចចូឡវេទល្លសូត្រ ។ បទថា **គម្ភីរត្ថា** (មានអត្ថដ៏ជ្រៅ) បានដល់ ជ្រៅដោយអត្ថ ដូចមហាវេទល្លសូត្រ ។ បទថា **លោកុត្តរា** (ជាលោកុត្តរៈ) បានដល់ សម្តែងអត្ថជាលោកុត្តរៈ ។ បទថា **សុញ្ញតបដិសំយុត្តា** (ប្រកបដោយសុញ្ញតធម៌) បានដល់ ប្រកាសត្រឹមតែជាសុញ្ញតធម៌ ៧ ប៉ុណ្ណោះ ដូចអសង្ខតសំយុត្ត ។ បទថា **ន អញ្ញាចិត្តំ ឧបដ្ឋបេន្តិ** (មិនចូលទៅតាំងចិត្តទុកដើម្បីដឹងទូទៅដល់) បានដល់ មិនតាំងចិត្តដើម្បីទឹងដឹង គឺ ដេកលក់ខ្វះ បញ្ជូនចិត្តទៅទីដទៃខ្វះ ។ បទថា **ឧគ្គហេតព្វំ បរិយាបុណិតព្វំ** (ខ្វនគួរសិក្សា គួរទន្ទេញ) បានដល់ ដែលគប្បីកាន់យកផង ដែលគប្បីរៀនសូត្រផង ។ បទថា **កវិកតា** (ដែលកវីបានចងក្រងទុក) បានដល់ ដែលកវីតែងឡើង ។ បទថា **កាវេយ្យា** (ជាពាក្យកវី) ក្រៅពីនេះជាវេវចនៈរបស់បទថា

**កវិកតា** នោះឯង ។ បទថា **ចិត្តក្ខរា** បានដល់ មានអក្សរវិចិត្រ ។ បទថា **ចិត្ត-ព្យញ្ជនា** (មានព្យញ្ជនៈវិចិត្រ) ក្រៅពីនេះ ជាវេវចនៈរបស់បទថា **ចិត្តក្ខរា** នោះដូចគ្នា ។ បទថា **ពាហិរកា** (មានក្នុងខាងក្រៅ) បានដល់ ជាសុត្តន្តៈក្រៅព្រះសាសនា ។ បទថា **សាវកភាសិតា** (ដែលសាវកបានភាសិតទុក) បានដល់ ដែលពួកសាវករបស់ពាហិរកសាស្តាទាំងនោះពោលទុក ។ បទថា **សុស្សូសន្តិ** (រមែងតាំងចិត្តស្តាប់ដោយល្អ) សេចក្តីថា មានចិត្តរីករាយតាំងចិត្តស្តាប់ដោយល្អ ព្រោះមានអក្សរវិចិត្រ និងសម្បូរណ៍ដោយបទ ។ បទថា **ន ចវអញ្ញមញ្ញំ បដិបុច្ឆន្តិ** (មិនសាកសួរដល់គ្នានិងគ្នា) សេចក្តីថា មិនបានសួរអត្ថ អនុសន្ធិ ឬខាងដើមខាងចុងដល់គ្នានិងគ្នា ។ បទថា **ន បដិវិវរន្តិ** (មិនស្វែងរកការសាកសួរ) សេចក្តីថា មិនបានដើរទៅសាកសួរ ។ បទថា **ឥទំ កថំ** (ព្យញ្ជនៈនេះដូចម្តេច) សេចក្តីថា ព្យញ្ជនៈនេះ គប្បីយល់យ៉ាងណា គឺ គប្បីយល់ថាដូចម្តេច ។ បទថា **ឥមស្ស កវត្ថោ** (អត្ថនៃភាសិតនេះដូចម្តេច) សេចក្តីថា ភាសិតនេះមានខ្លឹមសារយ៉ាងណា មានអនុសន្ធិយ៉ាងណា មានខាងដើម និងខាងចុងយ៉ាងណា ។ បទថា **អវិវដំ** (អត្ថដែលកំបាំង) បានដល់ ដែលនៅបិទបាំង ។ បទថា **ន វិវរន្តិ** (មិនបើកបង្ហាញ) បានដល់ មិនលាតត្រដាង ។ បទថា **អនុត្តានីកតំ** (អត្ថដ៏ជ្រៅ) បានដល់ ដែលមិនប្រាកដ ។ បទថា **ន ឧត្តានីករោន្តិ** (មិនធ្វើឲ្យរាក់) សេចក្តីថា មិនបានធ្វើឲ្យ

ប្រាកដ ។ បទថា **កង្ខាឋានីយេសុ** (ជាទីតាំងនៃសេចក្តីសង្ស័យ) បានដល់ ដែលជាហេតុនៃសេចក្តីសង្ស័យ ។ ចំណែកល្អ ក៏គប្បីជ្រាបតាមន័យដូយគ្នានឹងដែលបានពោលហើយ ។

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

## *“បរិស័ទជួន់ក្នុងអាមិស និងជួន់ក្នុងព្រះសទ្ធម្ម”*

*ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៩៣] បទថា **អាមិសគរុ** (ជួន់ក្នុងអាមិស) បានដល់ ជួន់ក្នុងបច្ច័យ ៤ គឺ ជាបរិស័ទដែលកាន់យកលោកុត្តរៈជារបស់ថោកទាប ហើយតាំងនៅ ។ បទថា **សទ្ធម្ម** (ជួន់ក្នុងព្រះសទ្ធម្ម) បានដល់ ជាបរិស័ទដែលលើកព្រះលោកុត្តរធម៌ ៩ ជាទីគោរព ជួន់ក្នុងបច្ច័យ ៤ ជារបស់ថោកទាប ។ បទថា **ឧភតោភាគវិមុត្តោ** សេចក្តីថា ជាអ្នករួចផុតដោយចំណែកទាំងពីរ ។ បទថា **បញ្ញាវិមុត្តោ** បានដល់ ជាអ្នករួចផុតដោយបញ្ញា គឺ ជាព្រះខីណាស្រពប្រភេទសុក្ខវិបស្សកៈ ។ បទថា **កាយសក្ខី** បានដល់ ជាបុគ្គលពាល់ត្រូវឈានដោយនាមកាយ ក្រោយមកធ្វើនិរោធ គឺ និព្វានឲ្យជាក់ច្បាស់ ។ បទថា **ទិដ្ឋិប្បត្តោ** បានដល់ ជាបុគ្គលដល់ទីបំផុតនៃការឃើញ ។ ទាំង ២ ពួកនេះ រមែងបានក្នុងឋានៈ ៤ ។ បទថា **សទ្ធាវិមុត្តោ** ឈ្មោះថា សទ្ធាវិមុត្តិ ព្រោះជឿដោយជាប់ដល់រួចផុត ។ សូម្បីពួកនេះ ក៏រមែងបានក្នុងឋានៈ ៦ ។ ឈ្មោះថា **ធម្មានុសារី** ព្រោះតាមរឭកដល់ធម៌ ។ ឈ្មោះថា **សទ្ធានុសារី** ព្រោះតាមរឭកដល់សទ្ធា ។ សូម្បី ២ ពួកនេះ ក៏ជាបុគ្គលព្រមព្រៀង*

ដោយបឋមមគ្គ ។ បទថា **កល្យាណធម្មោ** ប្រែថា ជាអ្នកមានធម៌ល្អ ។ បទថា **ទុស្សីលោ បាបធម្មោ** (ទ្រុស្តសីល មានធម៌ថោកទាប) បានដល់ មានប្រក្រតីអាក្រក់ មានធម៌លាមក ។ ព្រោះហេតុអ្វីទើបកាន់យកយ៉ាងនេះ ។ ព្រោះពួកគេសម្គាល់ថា បើមនុស្សទាំងអស់ដូចៗ គ្នា សេចក្តីគោរពដ៏មានកម្លាំងក្នុងអ្នកមានសីល ក៏នឹងមិនមាន តែបើមានបុគ្គលខ្លះជាអ្នកទ្រុស្តសីល សេចក្តីគោរពមានកម្លាំង ទើបមានដល់បុគ្គលដែលមានសីល ដូច្នេះ ទើបប្រកាន់យ៉ាងនេះ ។ បទថា **តេ តេន លាភំ លភន្តិ** (អ្នកផ្សេងបានលាភដោយហេតុនោះ) សេចក្តីថា ភិក្ខុទាំងនោះពោលសរសើរភិក្ខុពួកខ្លះ តិះដៀលភិក្ខុពួកខ្លះ រមែងបានបច្ច័យ ៤ ។ បទថា **គធិតា** (ជ្រប់) បានដល់ ជាអ្នកជ្រប់ព្រោះតណ្ហា ។ បទថា **មុច្ឆិតា** (ស្រវឹង) បានដល់ ជាអ្នកស្រវឹងព្រោះតណ្ហា ។ បទថា **អជ្ឈោសន្នា** (លង់ចុះ) បានដល់ ជាអ្នកលង់លិចព្រោះលោភៈ ។ បទថា **អនាទីនវទស្សាវិនោ** (មិនឃើញទោស) បានដល់ មិនឃើញទោសក្នុងការបរិភោគដោយមិនពិចារណា ។ បទថា **អនិស្សរណបញ្ញា** (មិនមានបញ្ញាជាហេតុចេញចាកភព) បានដល់ វៀរចាកបញ្ញាជាគ្រឿងរលាស់ចេញ ជាប់ដោយឆន្ទរាគៈក្នុងបច្ច័យ ៤ គឺ មិនដឹងថា សេចក្តីនេះជាយ៉ាងនេះ ។ បទថា **បរិភុញ្ជន្តិ** (បរិភោគហើយ) បានដល់ ជាអ្នកបរិភោគដោយឆន្ទរាគៈ ។

ក្នុងបទថា **ឧភតោភាគវិមុត្តោ** ជាដើម ក្នុងធម៌ចំណែកល្អ មានវិនិច្ឆ័យដូច

តទៅនេះ ។ ព្រះអរិយបុគ្គល ៧ ពួក មានអធិប្បាយសង្ខេបដូច្នេះ ។ ភិក្ខុមួយរូប បដិបត្តិក្នុងបញ្ញាធុរៈ ធ្វើសមាបត្តិ ៨ ឲ្យកើត សម្រេចសោតាបត្តិមគ្គ លោកឈ្មោះថា **ធម្មានុសារី** និងឈ្មោះថា **កាយសក្ខី** ក្នុងឋានៈ ៦ មានសោតាបត្តិផលជាដើម ឈ្មោះថា **ឧភតោភាគវិមុត្តិ** ក្នុងខណៈសម្រេចអរហត្តផល អធិប្បាយថា ជាអ្នករួចផុត ២ ដង ឬរួចផុតទាំង ២ ចំណែក គឺ ដោយវិក្ខម្ភនវិមុត្តិព្រោះសមាបត្តិទាំងឡាយ និងដោយសមុច្ឆេទវិមុត្តិព្រោះមគ្គ ។ មួយរូបទៀត បដិបត្តិក្នុងបញ្ញាធុរៈ មិនអាចនឹងធ្វើសមាបត្តិឲ្យកើតបាន ជាសុក្ខវិបស្សកៈប៉ុណ្ណោះ សម្រេចនូវសោតាបត្តិមគ្គ លោកឈ្មោះថា **ធម្មានុសារី** ក្នុងខណៈនោះ និងឈ្មោះថា **ទិដ្ឋិប្បត្ត** ដល់ទីបំផុតនៃការឃើញ ក្នុងឋានៈ ៦ មានសោតាបត្តិផលជាដើម ឈ្មោះថា **បញ្ញាវិមុត្តិ** ក្នុងខណៈសម្រេចអរហត្តផល ។ មួយរូបទៀត បដិបត្តិធ្ងន់ក្នុងសទ្ធាធុរៈ ធ្វើសមាបត្តិ ៨ ឲ្យកើត ហើយសម្រេចសោតាបត្តិមគ្គ លោកឈ្មោះថា **សទ្ធានុសារី** ក្នុងខណៈនោះ និងឈ្មោះថា **កាយសក្ខី** ក្នុងឋានៈ ៦ មានសោតាបត្តិផលជាដើម ឈ្មោះថា **ឧភតោភាគវិមុត្តិ** ក្នុងខណៈសម្រេចអរហត្តផល ។ មួយរូបទៀត បដិបត្តិដោយសទ្ធាធុរៈ មិនអាចនឹងធ្វើសមាបត្តិឲ្យកើតបាន ជាសុក្ខវិបស្សកៈប៉ុណ្ណោះ កាលសម្រេចសោតាបត្តិមគ្គ លោកឈ្មោះថា **សទ្ធានុសារី** ក្នុងខណៈនោះ និងឈ្មោះថា **សទ្ធាវិមុត្តិ** ក្នុងឋានៈ ៦ មានសោតាបត្តិផលជាដើម និងបានឈ្មោះថា

*បញ្ញាវិមុត្តិ ក្នុងខណៈសម្រេចអរហត្តផល ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*"បរិស័ទរាបស្មា និងមិនរាបស្មា"*

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៩៤] *បទថា* ***វិសមា*** *(មិនរាបស្មា) បានដល់ ឈ្មោះថា មិនរៀបរយ ព្រោះអត្ថថា ក្ងាំងក្ងាត់ ។ បទថា* ***សមា*** *(រាបស្មា) បានដល់ ឈ្មោះថា រៀបរយ ព្រោះអត្ថថា មិនក្ងាំងក្ងាត់ ។ បទថា* ***អធម្មកម្មានិ*** *(កម្មដែលជាអធម៌) បានដល់ អំពើខុសធម៌ ។ បទថា* ***អវិនយកម្មានិ*** *(កម្មដែលមិនមែនវិន័យ) បានដល់ អំពើខុសវិន័យ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*“បរិស័ទគ្មានធម៌ និងប្រកបដោយធម៌”*

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៩៥] *បទថា* ***អធម្មិកា*** *(គ្មានធម៌) បានដល់ ប្រាសចាកធម៌ ។ បទថា* ***ធម្មិកា*** *(តាំងនៅក្នុងធម៌) បានដល់ ប្រកបដោយធម៌ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

## *"បរិស័ទជាអធម្មវាទី និងធម្មវាទី"*

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៩៦] *បទថា* ***អធិករណំ*** *(អធិករណ៍) បានដល់ អធិករណ៍ ៤ យ៉ាង មានវិវាទាធិករណ៍ជាដើម ។ បទថា* ***អាទិយន្តិ*** *(ទទួលយក) បានដល់ កាន់យក ។ បទថា* ***សញ្ញាបេន្តិ*** *(ឲ្យព្រមព្រៀង) បានដល់ ឲ្យដឹងគ្នា ។ បទថា* ***ន ច សញ្ញត្តិំ ឧបគច្ឆន្តិ*** *(មិនចូលដល់ការព្រមព្រៀងគ្នា) សេចក្តីថា មិនប្រជុំដើម្បីប្រកាសឲ្យដឹងគ្នា ។ បទថា* ***ន ច និជ្ឈាបេន្តិ*** *បានដល់ មិនឲ្យសម្លឹងទោសគ្នា ។ បទថា* ***ន ច និជ្ឈត្តិំ ឧបគច្ឆន្តិ*** *(មិនចូលដល់ការសម្លឹងទោសរបស់ខ្លួន) សេចក្តីថា មិនប្រជុំដើម្បីឲ្យសម្លឹងទោសគ្នានិងគ្នា ។ បទថា* ***អសញ្ញត្តិពលា*** *(មានការមិនព្រមព្រៀងគ្នាជាកម្លាំង) សេចក្តីថា ភិក្ខុទាំងនោះ ឈ្មោះថា* ***អសញ្ញត្តិពលា*** *ព្រោះមានការមិនព្រមព្រៀងគ្នាជាកម្លាំង ។ បទថា* ***អប្បដិនិស្សគ្គមន្តិនោ*** *(គិតមិនលះបង់) សេចក្តីថា ភិក្ខុពួកណាមានសេចក្តីគិតយ៉ាងនេះថា បើអធិករណ៍ដែលពួកយើងកាន់យកនឹងជាធម៌សោត ពួកយើងនឹងកាន់យក បើមិនមែនជាធម៌ទេ ពួកយើងនឹងដាក់ចុះដូច្នេះ ភិក្ខុទាំងនោះឈ្មោះថា មានការមិនគិតលះបង់ ។ តែភិក្ខុទាំងនេះមិនគិតដូច្នោះ*

*ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានការគិតលះបង់ ។ បទថា* ***ថាមសា បរា-មាសា អភិនិវិស្ស*** *(ប្រកាន់...ដោយកម្លាំង ដោយការស្ទាបអង្អែល) សេចក្តីថា ប្រកាន់មាំដោយកម្លាំងទិដ្ឋិ និងដោយការស្ទាបអង្អែលដោយទិដ្ឋិ ។ បទថា* ***ឥទមេវ សច្ចំ*** *(ពាក្យនេះប៉ុណ្ណោះពិត) សេចក្តីថា ពាក្យរបស់ពួកយើងនេះប៉ុណ្ណោះពិត ។ បទថា* ***មោឃមញ្ញំ*** *(ពាក្យដទៃទទេ) សេចក្តីថា ពាក្យរបស់បុគ្គលដ៏សេសជាមោឃៈ គឺ ទទេ ។ ចំណែកខាងល្អ មានសេចក្តីងាយទាំងនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់បរិសវគ្គទី ៥

## រួមក្នុងវគ្គនេះមាន ១០ សូត្រ
## ព្រះអដ្ឋកថាកែសេចក្តី ១០ សូត្រ

# ចប់បឋមបណ្ណាសកៈ

# ទុតិយបណ្ណាសកៈ

## បុគ្គលវគ្គទី ១

## អដ្ឋកថាសូត្រទី ១

*“បុគ្គល ២ ពួក កើតឡើងក្នុងលោក”*

*ទុតិយបណ្ណាសកៈ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៩៧] *ព្រោះកាន់យកព្រមទាំងស្តេចចក្រពត្តិ ទើបមិនបានត្រាស់បទថា លោកានុកម្បាយ ទុកផង ។ ក្នុងសូត្រនេះ ព្រោះការកើតឡើងនៃស្តេចចក្រពត្តិ សត្វលោក រមែងបានសម្បត្តិ ២ (គឺមនុស្សសម្បត្តិ និងសួគ៌សម្បត្តិ) ចំណែកការកើតឡើងនៃព្រះពុទ្ធទាំងឡាយ រមែងបានសម្បត្តិទាំង ៣ (គឺបានបន្ថែមនិព្វានសម្បត្តិផង ) ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

## *“អច្ឆរិយបុគ្គល ២ ពួក”*

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[២៩៨] បទថា* ***អច្ឆរិយមនុស្សា*** *សេចក្តីថា ពួកមនុស្សដែលមិនទូទៅ គឺមិនប្រាកដទូទៅ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

## *“កាលកិរិយារបស់បុគ្គល ២ ពួក”*

*ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[២៩៩] *បទថា **ពហុនោ ជនស្ស អនុតប្បា ហោតិ** (កើតសេចក្តីស្តាយក្រោយដល់ជនច្រើន) សេចក្តីថា រមែងធ្វើសេចក្តីទាស់ចិត្តដល់មហាជន ។ បណ្តាបុគ្គលទាំង ២ នោះ កាលកិរិយារបស់ស្តេចចក្រពត្តិ រមែងធ្វើសេចក្តីស្តាយក្រោយដល់ទេវតា និងមនុស្សក្នុងចក្រវាឡតែមួយ កាលកិរិយារបស់ព្រះតថាគតរមែងធ្វើសេចក្តីស្តាយក្រោយដល់ទេវតា និងមនុស្សក្នុងម៉ឺនចក្រវាឡ ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

## *"ថូបារហបុគ្គល ២ ពួក"*

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣០០] បទថា **ថូបារហា** (ថូបារហបុគ្គល) សេចក្តី បុគ្គលសមគួរ គឺសមគួរដល់សថូប ។ ព្រោះអ្នកប្រណិប័តន៍ព្រះចេតិយរបស់ស្តេចចក្រពត្តិ រមែងបានសម្បត្តិ ២ អ្នកប្រណិប័តន៍ព្រះចេតិយរបស់ព្រះពុទ្ធទាំងឡាយ រមែងបានសម្បត្តិសម្បីទាំង ៣ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

*"ព្រះពុទ្ធ ២ ពួក"*

*ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣០១] *បទថា ពុទ្ធា (ព្រះពុទ្ធជាម្ចាស់) បានដល់ បុគ្គលដែលត្រាស់ដឹងអរិយសច្ច ៤ ដោយអានុភាពរបស់ខ្លួន (ត្រាស់ដឹងឯង) ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

*“បុគ្គល ២ ពួក មិនខ្លាចរន្ទះ”*

*ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣០២-៣០៤] *បទថា* ***អសនិយា ផលន្តិយា*** *(វេលារន្ទះបាញ់) បានដល់ វេលារន្ទះបាញ់ ។ បទថា* ***ន សន្តសន្តិ*** *(មិនតក់ស្លុត) សេចក្តីថា រមែងមិនភ័យខ្លាច ព្រោះលះសក្កាយទិដ្ឋិបានហើយ ។ បណ្តាមនុស្ស និងសត្វទាំងពីរនោះ ព្រះខីណាស្រពមិនតក់ស្លុត ព្រោះលះសក្កាយទិដ្ឋិបានហើយ , ដំរីអាជានេយ្យមិនតក់ស្លុត ព្រោះមានសក្កាយទិដ្ឋិខ្លាំងក្លា ។*

ចប់អដ្ឋកថា សូត្រទី ៦

*អដ្ឋកថាសូត្រទី ៧-៨ ក៏ន័យដូចគ្នាក្នុងសូត្រទី ៦ ។*

# អដ្ឋកថាសូត្រទី ៩

## “កិន្នរឃើញប្រយោជន៍ ២ យ៉ាង ទើបមិននិយាយភាសាមនុស្ស”

ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣០៥] បទថា **កឹបុរិសា** បានដល់ កិន្នរ ។ បទថា **មានុសឹ វាចំ ន ភាសន្តិ** (មិននិយាយភាសាមនុស្ស) សេចក្តីថា មិនពោលពាក្យមនុស្ស ។

បានឮមកថា ពរាន្រ្តនាំកិន្នរម្នាក់មកសម្តែងដល់ព្រះបាទធម្មាសោក ។ ព្រះអង្គត្រាស់បង្គាប់ថា ពួកអ្នកចូរឲ្យកិន្នរនោះនិយាយ ។ កិន្នរមិនប្រាថ្នានឹងនិយាយ បុរសម្នាក់គិតថា យើងនឹងឲ្យកិន្នរនេះនិយាយ ទើបនាំកិន្នរចុះទៅកាន់ប្រាសាទជាន់ក្រោម ដោតបង្គោល ២ ហើយតាំងឆ្នាំងបាយឡើង ។ ឆ្នាំងបាយធ្លាក់ចុះខាងនេះខ្លះខាងនោះខ្លះ ។ កិន្នរឃើញដូច្នោះ ក៏ពោលពាក្យត្រឹមតែប៉ុណ្ណោះថា ដោតបង្គោលបន្ថែមទៀត មិនគួរឬ ។ វេលាតមក គេនាំកិន្នរមកសម្តែង ២ នាក់ទៀត ព្រះរាជាត្រាស់បង្គាប់ថា ពួកអ្នកឯងចូរឲ្យកិន្នរនិយាយ ។ កិន្នរទាំងពីរនោះ ក៏មិនប្រាថ្នានឹងនិយាយ ។ បុរសម្នាក់គិតថា យើងនឹងឲ្យកិន្នរទាំងពីរនេះនិយាយ ទើបបាននាំកិន្នរទាំងនោះទៅផ្សារ ។ នៅទីផ្សារនោះ កិន្នរមួយបានឃើញស្វាយទុំនិងត្រី កិន្នរមួយទៀត បានឃើញផ្លែខ្វិត និងផ្លែឈើមានរសជូរ ។ បណ្តាកិន្នរ

២ នោះ កិន្នរមួយនិយាយថា សម្លាញ់លំបាកណាស់ ពួកមនុស្សទំពារស៊ី (ផ្លែឈើមានស្វាយជាដើម) ពួកគេនឹងមិនកើតរោគស្រែងបានដូចម្តេច ។ កិន្នរមួយទៀតនិយាយថា មនុស្សទាំងនេះអាស្រ័យត្រី និងផ្លែឈើនោះ នឹងមិនកើតរោគឃ្លង់បានដូចម្តេច ។ កិន្នរទាំងឡាយ សូម្បីមិនអាចនិយាយភាសាមនុស្ស តែកាលឃើញប្រយោជន៍ ២ យ៉ាង ដូចពោលមកនេះក៏និយាយ ដូច្នេះឯង ។

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*"មាតុគ្រាមមិនឆ្អែតមិនទ្រាន់ក្នុងធម៌ ២ ប្រការ"*

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣០៦] បទថា **អប្បដិវាណោ** (មិនឆ្អែត) បានដល់ មិនចុះចាញ់ ។*

ចប់អដ្ឋកថា សូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

## *"ការនៅរួមជាមួយអសប្បុរស និងសប្បុរស"*

*ក្នុងសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣០៧] បទថា **អសន្តសន្និវាសំ** (ការនៅរួមរបស់អសប្បុរស) បានដល់ការនៅរួមគ្នារបស់ពួកអសប្បុរស ។ បទថា **ន វទេយ្យ** (មិនគួរពោលថា) សេចក្តីថា មិនគប្បីពោល អធិប្បាយថា ចូរកុំពោលដោយឱវាទក្តី ដោយអនុសាសនីក្តី ។ បទថា **ថេរំបាហំ ន វទេយ្យំ** (សូម្បីយើងក៏មិនគប្បីពោលនឹងភិក្ខុជាថេរៈ) សេចក្តីថា សូម្បីយើងក៏មិនគប្បីពោលនឹងភិក្ខុដែលជាថេរៈ ដោយឱវាទ និងអនុសាសនី ។ បទថា **អហិតានុកម្បី** (គប្បីប្រាថ្នាវត្ថុដែលមិនជាប្រយោជន៍) បានដល់ ប្រាថ្នាតែវត្ថុដែលមិនជាប្រយោជន៍ ។ បទថា **នោ ហិតានុកម្បី** (មិនមែនប្រាថ្នាវត្ថុដែលជាប្រយោជន៍) បានដល់ មិនប្រាថ្នាប្រយោជន៍ដ៏ធំ ។ បទថា **នោតិ នំ វទេយ្យំ** (យើងគប្បីនិយាយនឹងគេថា នឹងមិនធ្វើតាម) សេចក្តីថា គប្បីពោលថា ខ្ញុំនឹងមិនធ្វើតាមពាក្យរបស់លោក ។ បទថា **វិហេសេយ្យំ** (គប្បីបៀតបៀន) សេចក្តីថា គប្បីបៀតបៀនព្រោះហេតុនៃពាក្យសំដី ។ បទថា **បស្សម្បិស្ស ន បដិករេយ្យំ** (យើងសូម្បីឃើញហើយ ក៏មិនគប្បីធ្វើតាមពាក្យរបស់គេ) សេចក្តីថា សូម្បីយើង*

*ឃើញហើយក្ដី ដឹងហើយក្ដី នឹងមិនធ្វើតាមពាក្យរបស់ភិក្ខុនោះ ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួងដោយឧបាយនេះ ។ ឯក្នុងចំណែកល្អ បទថា* ***សាធូតិ នំ វទេយ្យំ*** *(យើងគប្បីនិយាយនឹងគេថា ល្អហើយ ដូច្នេះ) សេចក្ដីថា កាលយើងលើកសរសើរពាក្យរបស់គេ នឹងគប្បីពោលថា ល្អហើយ ចូរចម្រើន លោកពោលល្អហើយ ។*

ចប់អដ្ឋកថា សូត្រទី ១១

# អដ្ឋកថាសូត្រទី ១២

*"អធិករណ៍ជាហេតុឲ្យភិក្ខុនៅមិនជាសុខ និងនៅជាសុខ"*

*ក្នុងសូត្រទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣០៨] *បទថា* ***ឧភតោ វចីសំសារោ*** *(ការជេរគ្នា) សេចក្ដីថា វាចាដែលស៊កសៀតគ្នានិងគ្នា ចេញមកដោយការជេរគ្នាទាំងពីរចំណែក ឈ្មោះថា ការជេរគ្នា ។ បទថា* ***ទិដ្ឋិបឡាសោ*** *(ការលើកកម្ពស់ដោយទិដ្ឋិ) សេចក្ដីថា ការវាយឫកស្មើមានលក្ខណៈប្រៀបជាគូ ដែលកើតឡើងព្រោះអាស្រ័យទិដ្ឋិ ឈ្មោះថា ការវាយឫកស្មើដោយអំណាចទិដ្ឋិ ។ បទថា* ***ចេតសោ អាឃាតោ*** *(សេចក្ដីអាឃាតនៃចិត្ត) បានដល់ សេចក្ដីក្រោធ ។ ពិតហើយ សេចក្ដីក្រោធនោះ កើតឡើងធ្វើចិត្តឲ្យអាឃាត ។ បទថា* ***អប្បច្ចយោ*** *(ការមិនពេញចិត្ត) បានដល់ អាការដែលមិនត្រេកអរ អធិប្បាយថា ទោមនស្ស ។ បទថា* ***អនភិរទ្ធិ*** *(សេចក្ដីថ្នាំងថ្នាក់) បានដល់ សេចក្ដីក្រោធនោះឯង ។ ក៏សេចក្ដីក្រោធនោះ លោកហៅថា* ***អនភិរទ្ធិ*** *ព្រោះមិនត្រេកអរ ។ បទថា* ***អជ្ឈត្តំ អវូបសន្តំ ហោតិ*** *(មិនស្ងប់រម្ងាប់ចំណែកខាងក្នុង) សេចក្ដីថា រឿងទាំងអស់នោះមិនស្ងប់បាន ក្នុងចិត្តរបស់ខ្លួនដែលជាខាងក្នុងខ្លួន និងក្នុងបរិស័ទរបស់ខ្លួន គឺ សទ្ធិវិហារិក និងអន្តេវាសិក ។ បទថា* ***តស្មេតំ*** *កាត់*

*បទថា* **តស្មឹ ឯតំ** *ប្រែថា ប្រការដែលនឹងគប្បីប្រាថ្នាបានក្នុងរឿងអធិករណ៍នោះ ។*

*បទដ៏សេស គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១២

ចប់បុគ្គលវគ្គទី ១

ក្នុងវគ្គនេះមាន ១២ សូត្រ

ព្រះអដ្ឋកថាកែសេចក្តី ១០ សូត្រ

# សុខវគ្គទី ២

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣០៩] បទថា* ***គិហិសុខំ*** *(សុខរបស់គ្រហស្ថ) បានដល់ សេចក្តីសុខគ្រប់យ៉ាងរបស់គ្រហស្ថទាំងឡាយ ដែលមានសេចក្តីសម្រេចអំពីកាមជាមូល ។ បទថា* ***បព្វជ្ជាសុខំ*** *(សុខកើតពីបព្វជ្ជា) បានដល់ សេចក្តីសុខដែលមានការបព្វជ្ជាជាមូល ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*សូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣១០] បទថា **កាមសុខំ** (កាមសុខ) បានដល់ សេចក្តីសុខដែលកើតឡើងព្រោះប្រារព្ធកាម ។*

*បទថា **នេក្ខម្មសុខំ** (នេក្ខម្មសុខ) សេចក្តីថា បព្វជ្ជា លោកហៅថា នេក្ខម្ម: សុខដែលកើតឡើងព្រោះប្រារព្ធនេក្ខម្ម:នោះ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១១] *បទថា* **ឧបធិសុខំ** *(សុខលាយដោយកិលេស) បានដល់ សុខដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ បទថា* **និរូបធិសុខំ** *(សុខមិនលាយដោយកិលេស) បានដល់ សុខដែលជាលោកុត្តរៈ ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*សូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១២] *បទថា* ***សាសវសុខំ*** *(សុខមានអាសវៈ) បានដល់ សុខក្នុងវដ្តៈ ដែលជាបច្ច័យដល់អាសវៈទាំងឡាយ ។ បទថា* ***អនាសវសុខំ*** *(សុខមិនមានអាសវៈ) បានដល់ សុខក្នុងព្រះនិព្វាន ដែលមិនជាបច្ច័យដល់អាសវៈទាំងនោះ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

*សូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១៣] *បទថា* **សាមិសំ** *(អាស្រ័យអាមិស) បានដល់ សុខជាគ្រឿងឲ្យដល់វដ្តៈ នៅមានកិលេស ។ បទថា* **និរាមិសំ** *(មិនអាស្រ័យអាមិស) បានដល់ សុខជាគ្រឿងឲ្យដល់ព្រះនិព្វាន ប្រាសចាកកិលេស ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

*សូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១៤] *បទថា* ***អរិយសុខំ*** *(សុខរបស់ព្រះអរិយៈ) បានដល់ សុខរបស់អរិយបុគ្គល ។ បទថា* ***អនរិយសុខំ*** *(សុខរបស់បុគ្គលមិនមែនជាព្រះអរិយៈ) បានដល់ សុខរបស់បុថុជ្ជន ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

*សូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១៥] *បទថា* **កាយិកំ** *(ផ្លូវកាយ) បានដល់ សុខដែលកើតរួមជាមួយកាយវិញ្ញាណ ។ បទថា* **ចេតសិកំ** *(ផ្លូវចិត្ត) បានដល់ សុខដែលកើតផ្លូវមនោទ្វារ ។ គ្រាស់លាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*សូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១៦] *បទថា* ***សប្បីតិកំ*** *(ដែលកើតពីឈានទៅមានបីតិ) បានដល់ សុខក្នុងបឋមឈាន និងទុតិយឈាន ។ បទថា* ***និប្បីតិកំ*** *(ដែលកើតពីឈានមិនមានបីតិ) បានដល់ សុខក្នុងតតិយឈាន និងចតុត្ថឈាន ។ បណ្ដាសុខ ២ យ៉ាងនោះ គប្បីជ្រាបសេចក្ដីប្រសើរបំផុត ដោយមិនបែងចែកថ្នាក់យ៉ាងនេះ គឺ សុខប្រាសចាកបីតិដែលជាលោកិយៈ ប្រសើរជាងសុខមានបីតិដែលជាលោកិយៈ និងសុខប្រាសចាកបីតិជាលោកុត្តរៈ ប្រសើរជាងសុខមានបីតិដែលជាលោកុត្តរៈ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*សូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣១៧] *បទថា* ***សាតសុខំ*** *(សុខកើតពីសេចក្ដីត្រេកអរ) បានដល់ សុខក្នុងឈានទាំង ៣ ។ បទថា* ***ឧបេក្ខាសុខំ*** *(សុខកើតពីសេចក្ដីព្រងើយៗ) បានដល់ សុខក្នុងចតុត្ថឈាន (ចតុក្កន័យ) ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*សូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣១៨] បទថា **សមាធិសុខំ** (សុខមានសមាធិ) បានដល់ សុខដែលដល់អប្បនាសមាធិ ឬឧបចារសមាធិ ។*

*បទថា **អសមាធិសុខំ** (សុខមិនមានសមាធិ) បានដល់ សុខដែលមិនដល់សមាធិទាំងពីរនោះ ។*

ចប់អដ្ឋកថា សូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

*សូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣១៩] បទថា* ***សប្បីតិការម្មណំ*** *(កើតពីឈានមានបីតិជាអារម្មណ៍) បានដល់ សុខដែលកើតឡើងដល់អ្នកពិចារណាឈានទាំងពីរ ដែលមានបីតិជាអារម្មណ៍ សូម្បីក្នុងឈានដែលមិនមានបីតិជាអារម្មណ៍ ក៏ន័យនេះឯង ។*

ចប់អដ្ឋកថា សូត្រទី ១១

# អដ្ឋកថាសូត្រទី ១២

*សូត្រទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣២០] ក៏គប្បីជ្រាបសេចក្តីដោយឧបាយនេះ ។*

ចប់អដ្ឋកថា សូត្រទី ១២

# អដ្ឋកថាសូត្រទី ១៣

*សូត្រទី ១៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣២១] *បទថា* ***រូបារម្មណំ*** *(មានរូបជាអារម្មណ៍) បានដល់ សុខដែលកើតឡើង ព្រោះប្រារព្ធរូបណានីមួយ ដែលជាអារម្មណ៍របស់រូបាវចរចតុត្ថឈាន ។ បទថា* ***អរូបារម្មណំ*** *(មិនមានរូបជាអារម្មណ៍) បានដល់ សុខដែលកើតឡើងព្រោះប្រារព្ធអរូបណានីមួយ ដែលជាអារម្មណ៍របស់អរូបាវចរឈាន ។*

ចប់អដ្ឋកថា សូត្រទី ១៣

**ចប់សុខវគ្គទី ២**

**ក្នុងវគ្គនេះមាន ១៣ សូត្រ**

**ព្រះអដ្ឋកថាកែសេចក្តី ១២ សូត្រ**

# សនិមិត្តវគ្គទី ៣

## អដ្ឋកថាសូត្រទី ១

*វគ្គទី ៣ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣២២] *បទថា* ***សនិមិត្តា*** *(មាននិមិត្ត) បានដល់ មានហេតុ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២ ជាដើម

*[៣២៣-៣២៧] សូម្បីក្នុងសូត្រទី ២ ជាដើម ក៏ន័យនេះឯង ។ ក៏បទទាំងអស់ គឺ និទានហេតុ សម្ភារ បច្ច័យ រូប ទាំងអស់នេះជាវេវចនៈរបស់ការណៈនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ២ ជាដើម

# អដ្ឋកថាសូត្រទី ៧

*ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣២៨] *បទថា **សវេទនា** (មានវេទនា) សេចក្តីថា កាលសម្បយុត្តវេទនាដែលជាបច្ច័យនោះឯងមានហើយ ធម៌ដែលជាបាបអកុសលទាំងឡាយទើបកើតឡើង កាលមិនមានក៏មិនកើត ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨-៩

*ក្នុងសូត្រទី ៨-៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[*៣២៩-៣៣០*] *ក៏ន័យនេះឯង ។*

ចប់អដ្ឋកថា សូត្រទី ៨-៩

# អដ្ឋកថាសូត្រទី ១០

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៣១] *បទថា* ***សង្ខតារម្មណា*** *(មានសង្ខតធម៌ជាអារម្មណ៍) សេចក្ដីថា ធម៌ដែលជាបាបអកុសលទាំងឡាយកើតឡើង ព្រោះធ្វើសង្ខតធម៌ដែលកើតឡើងដោយបច្ច័យ ឲ្យជាអារម្មណ៍ ។*

*បទថា* ***នោ អសង្ខតារម្មណា*** *(មិនមានអសង្ខតធម៌ជាអារម្មណ៍) សេចក្ដីថា ធម៌ដែលជាបាបអកុសលនឹងមិនកើតឡើង ព្រោះប្រារព្ធព្រះនិព្វាន ដែលជាអសង្ខតៈ ។*

*បទថា* ***ន ហោន្តិ*** *(ទើបមិនមាន) សេចក្ដីថា ក្នុងខណៈនៃមគ្គ ធម៌ដែលជាបាបអកុសល ឈ្មោះថា មិនមាន កាលសម្រេចផលហើយ ក៏ឈ្មោះថា មិនមានហើយ ។ ក្នុងសូត្រទាំង ១០ នេះ ព្រះមានព្រះភាគទ្រង់សម្ដែងទេសនារហូតដល់ព្រះអរហត្តយ៉ាងនេះ ដោយប្រការដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០

**ក្នុងសនិមិត្តវគ្គ ទី ៣ មាន ១០ សូត្រ**
**ព្រះអដ្ឋកថាអធិប្បាយសេចក្ដី ៨ សូត្រ**

# ធម្មវគ្គទី ៤

## អដ្ឋកថាសូត្រទី ១

*វគ្គទី ៤ សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៣២] បទថា **ចេតោវិមុត្តិ** បានដល់ ផលសមាធិ (សមាធិដែលសម្បយុត្ត ដោយអរហត្តផល) ។*

*បទថា **បញ្ញាវិមុត្តិ** បានដល់ ផលបញ្ញា (បញ្ញាដែលសម្បយុត្តដោយ អរហត្តផល) ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៣៣] *បទថា **បគ្គាហោ** បានដល់ សេចក្តីព្យាយាម ។ បទថា **អវិក្ខេបោ** (ការមិនរាយមាយ) បានដល់ ការៈនៃចិត្តមានអារម្មណ៍តែមួយ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៣៤] បទថា* ***នាមំ*** *(នាម) បានដល់ អរូបក្ខន្ធ ទាំង ៤ ។*

*បទថា* ***រូបំ*** *(រូប) បានដល់ រូបក្ខន្ធ ។ ក្នុងសូត្រនេះ ទ្រង់ត្រាស់ដល់ញាណជាគ្រឿងកំណត់ចំណែកនៃធម៌ (កោដ្ឋាសៈ) ។*

ចប់អដ្ឋកថា សូត្រទី ៣

## អដ្ឋកថាសូត្រទី ៤

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៣៥] *បទថា* ***វិជ្ជា*** *បានដល់ ផលញាណ ។*

*បទថា* ***វិមុត្តិ*** *បានដល់ ធម៌ដ៏សេសដែលសម្បយុត្តជាមួយផលញាណនោះ ។*

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៣៦] បទថា *ភវទិដ្ឋិ* បានដល់ សស្សតទិដ្ឋិ ។

ចប់អដ្ឋកថា សូត្រទី៥

# អដ្ឋកថាសូត្រទី ៦-៧

*ក្នុងសូត្រទី ៦-៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៣៧-៣៣៨] *មានសេចក្តីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី៦-៧

# អដ្ឋកថាសូត្រទី ៨

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៣៩] *បទថា* ***ទោវចស្សតា*** *ប្រែថា ភាពជាបុគ្គលប្រដៅក្រ ។ បទថា* ***បាបមិត្តតា*** *(ភាពជាអ្នកមានមិត្តអាក្រក់) បានដល់ ការសេពបាបមិត្ត ។*

ចប់អដ្ឋកថា សូត្រទី៨

# អដ្ឋកថាសូត្រទី ៩

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៤០] *គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាដែលពោលហើយ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៤១] បទថា **ធាតុកុសលតា** (ភាពជាបុគ្គលឈ្លាសក្នុងធាតុ) បានដល់ដឹងធាតុ ១៨ យ៉ាង ថាជាធាតុ ។*

*បទថា **មនសិការកុសលតា** (ភាពជាបុគ្គលឈ្លាសក្នុងមនសិការ) បានដល់ដឹងធាតុទាំងនោះឯង លើកឡើងកាន់លក្ខណៈ ៣ មានអនិច្ចលក្ខណៈជាដើម ។*

ចប់អដ្ឋកថា សូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

ក្នុងសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៩២] បទថា ***អាបត្តិកុសលតា*** *(ភាពជាបុគ្គលឈ្លាសក្នុងអាបត្តិ) បានដល់ ដឹងអាបត្តិ ៥ កង និងអាបត្តិ ៧ កង ។ បទថា* ***អាបត្តិវុដ្ឋានកុសលតា*** *(ភាពជាអ្នកឈ្លាសក្នុងការចេញចាកអាបត្តិ) បានដល់ ដឹងក្នុងការចេញចាកអាបត្តិទាំងឡាយ ដោយការសម្តែងអាបត្តិក្តី ដោយសូត្រកម្មវាចាក្តី ។*

ចប់អដ្ឋកថា សូត្រទី ១១

### ក្នុងធម្មវគ្គ ទី ៤ មាន ១១ សូត្រ

### ព្រះអដ្ឋកថាអធិប្បាយសេចក្តី ៨ សូត្រ

# ពាលវគ្គទី ៥

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៤៣] *បទថា* ***អនាគតំ ភារំ វហតិ*** *(បុគ្គលទទួលភារៈដែលមិនទាន់មកដល់) សេចក្ដីថា ជានវកៈ ព្រះថេរៈមិនបានប្រើ ក៏ធ្វើការៈ ១០ យ៉ាង ក្នុងព្រះបាលីនេះថា បោសកេងឧបោសថ ១ តាំងប្រទីប ១ តាំងទឹកផឹក ១ តាំងអាសនៈ ១ នាំឆន្ទៈមក ១ នាំបារិសុទ្ធិមក ១ ប្រាប់រដូវ ១ រាប់ភិក្ខុ ១ ឱវាទភិក្ខុនី ១ សូត្របាតិមោក្ខ ១ លោកហៅថា ភារៈមុខនាទីរបស់ព្រះថេរៈ ដូច្នេះ ឈ្មោះថា ទទួលភារៈដែលនៅមិនទាន់មកដល់ ។*

*បទថា* ***អាគតំ ភារំ ន វហតិ*** *(បុគ្គលមិនទទួលភារៈដែលមកដល់) សេចក្ដីថា ជាព្រះថេរៈហើយ មិនធ្វើការៈ ១០ នោះ ដោយខ្លួនឯង ឬមិនបបួលប្រគល់ដល់អ្នកដទៃ ឈ្មោះថា មិនទទួលភារៈដែលមកដល់ហើយ ។*

ចប់អដ្ឋកថា សូត្រទី១

# អដ្ឋកថាសូត្រទី ២

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៤៤] *ក្នុងសូត្រនេះ មានសេចក្តីងាយហើយ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៤៥] បទថា **អកប្បិយេ កប្បិយសញ្ញី** (បុគ្គលសម្គាល់ថាគួរក្នុងរបស់ដែលមិនគួរ) បានដល់ បុគ្គលដែលមានសេចក្តីសម្គាល់ក្នុងវត្ថុដែលជាអកប្បិយៈ គឺ សាច់រាជសីហ៍ជាដើម យ៉ាងនេះថា នេះជាកប្បិយៈ ។ បទថា **កប្បិយេ អកប្បិយសញ្ញី** (បុគ្គលដែលសម្គាល់ថាមិនគួរក្នុងរបស់ដែលគួរ) បានដល់ បុគ្គលមានសេចក្តីសម្គាល់ក្នុងវត្ថុដែលជាកប្បិយៈ មានម្រឹគក្រពើ និងសាច់ឆ្មាជាដើម យ៉ាងនេះថា នេះជាអកប្បិយៈ ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*សូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៤៦] *ក្នុងសូត្រនេះ មានន័យងាយហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី៤

# អដ្ឋកថាសូត្រទី ៥

*សូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៤៧] *បទថា* ***អនាបត្តិយា អាបត្តិសញ្ញី*** *(សម្គាល់ថាអាបត្តិក្នុងប្រការមិនមែនអាបត្តិ) បានដល់ ជាអ្នកមានសេចក្ដីសម្គាល់ក្នុងរឿងដែលមិនជាអាបត្តិ ជាដើមថា ភិក្ខុធ្វើសេចក្ដីស្អាតកណ្ឋៈ ដុតបាត្រ កាត់សក់ ចូលស្រុកដោយបានប្រាប់លា នោះយ៉ាងនេះថា នេះជាអាបត្តិ ។ បទថា* ***អាបត្តិយា អនាបត្តិសញ្ញី*** *(សម្គាល់ថាមិនមែនអាបត្តិក្នុងប្រការដែលជាអាបត្តិ) បានដល់ ជាអ្នកមានសេចក្ដីសម្គាល់ក្នុងអាបត្តិ ព្រោះមិនអើពើដល់រឿងទាំងនោះ យ៉ាងនេះថា នេះមិនមែនជាអាបត្តិ ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

*សូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៤៨] ក្នុងសូត្រនេះ មានន័យងាយហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី៦

# អដ្ឋកថាសូត្រទី ៧ ជាដើម

*សូត្រទី ៧ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៤៩-៣៥២] មានសេចក្តីងាយហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៧ ជាដើម

# អដ្ឋកថាសូត្រទី ១១

*សូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៩៣] *បទថា* ***អាសវា*** *(អាសវៈ) បានដល់ កិលេស ។ បទថា* ***នកុក្កុច្ចាយិតព្វំ*** *(វត្ថុដែលមិនគួររង្កៀស) សេចក្តីថា សេចក្តីមិនប្រាថ្នា មិនពិចារណាចំណែកក្នុងសង្ឃ[១] ឈ្មោះថា វត្ថុដែលមិនគួររង្កៀស ។ បទថា* ***កុក្កុច្ចាយិតព្វំ*** *(វត្ថុដែលគួររង្កៀស) សេចក្តីថា មិនរង្កៀស ក្នុងសេចក្តីប្រាថ្នា សេចក្តីពិចារណាចំណែកក្នុងសង្ឃនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១១

---

*១ សង្ឃ ភាគស្ស ដីកាជា សង្ឃភោគស្ស ប្រែថា ភោគៈរបស់សង្ឃ ដូចជា ស្រូវអង្ករ និងប្រាក់ជាដើម កើតពីថ្ងៃស្រែដែលគេថ្វាយដើម្បីសង្ឃ ។*

# អដ្ឋកថាសូត្រទី ១២ ជាដើម

*សូត្រទី ១២ ជាដើម មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៥៤-៣៦២] គប្បីជ្រាបដោយន័យ ដែលបានពោលហើយក្នុងកាលមុន នុ៎ះឯង ។*

ចប់អដ្ឋកថា សូត្រទី ១២ ជាដើម

ក្នុងពាលវគ្គ ទី ៩ មាន ២០ សូត្រ

ព្រះអដ្ឋកថាអធិប្បាយសេចក្តី ៤ សូត្រ

## ចប់ទុតិយបណ្ណាសកៈ

# តតិយបណ្ណាសកៈ

## អាសាវគ្គទី ១

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៦៣] *បទថា* ***អាសា*** *(សេចក្តីប្រាថ្នា) បានដល់ តណ្ហា ។ បទថា* ***ទុប្បជហា*** *(លះបានលំបាក) បានដល់ លះបានលំបាក គឺ នាំចេញបានលំបាក ។ សត្វទាំងឡាយប្រើវេលា ១០ ឆ្នាំខ្លះ ២០ ឆ្នាំខ្លះ ៦០ ឆ្នាំខ្លះ បម្រើព្រះរាជា ធ្វើកសិកម្មជាដើម ចូលកាន់សមរភូមិច្បាំងប្រកៀកគ្នា ប្រព្រឹត្តអាជីវៈ ចិញ្ចឹមពពែ និងធ្វើលំពែងជាដើម ដើរសំពៅទៅកាន់មហាសមុទ្រ (ទាំងអស់នោះ) ព្រោះប្រាថ្នាថា ពួកយើងនឹងបានក្នុងថ្ងៃនេះ ពួកយើងនឹងបានក្នុងស្អែកនេះ ដូច្នេះ នេះព្រោះសេចក្តីប្រាថ្នាក្នុងលាភ ជារឿងលះបានលំបាក ។ សូម្បីកាលដល់វេលានឹងស្លាប់ ក៏នៅសម្គាល់ខ្លួនថា នឹងរស់នៅបាន ១០០ ឆ្នាំ សូម្បីនឹងឃើញកម្ម និងកម្មនិមិត្តជាដើម មានអ្នកបំណងល្អជាស់តឿនថា ចូរឲ្យទាន ចូរធ្វើការបូជាចុះ ក៏មិនជឿពាក្យរបស់នរណាៗ ដោយប្រាថ្នាយ៉ាងនេះថា យើងនឹងមិនស្លាប់ នេះព្រោះសេចក្តីប្រាថ្នាក្នុងជីវិត ជារឿងលះបានលំបាក ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*សូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៦៤] បទថា **បុព្វការី** បានដល់ អ្នកធ្វើឧបការៈមុន ។*

*បទថា **កតញ្ញូកតវេទី** បានដល់ អ្នកដឹងឧបការៈដែលគេធ្វើហើយ ធ្វើតបខាងក្រោយ ។ ក្នុងលោកទាំងពីរនោះ អ្នកធ្វើឧបការៈមុន រមែងសម្គាល់ថា យើងឲ្យខ្ចីបំណុល , អ្នកធ្វើតបខាងក្រោយ រមែងសម្គាល់ថា យើងនឹងសងបំណុល ។*

ចប់អដ្ឋកថា សូត្រទី២

# អដ្ឋកថាសូត្រទី ៣

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៦៥] បទថា **តិណ្ណោ ច តារេតា ច** (បុគ្គលអ្នកឆ្លែត ១ បុគ្គលអ្នកឲ្យគេឆ្លែត ១) សេចក្តីថា ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពជាសាវករបស់ព្រះតថាគត ឈ្មោះថា អ្នកឆ្លែតហើយ ។ ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ឈ្មោះថា អ្នកឆ្លែតហើយផង និងធ្វើអ្នកដទៃឲ្យឆ្លែតផង ។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*សូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៦៦] *បទថា* ***ទុត្តប្បយា*** *(ឲ្យឆ្អែតបានលំបាក) សេចក្តីថា ទាយកធ្វើឲ្យឆ្អែតបានលំបាក គឺ ការធ្វើឲ្យគេឆ្អែត ធ្វើមិនបានងាយ ។ បទថា* ***និក្ខិបតិ*** *(រក្សា) បានដល់ មិនឲ្យនរណា មិនប្រើប្រាស់ឯង ។ បទថា* ***វិសជ្ជេតិ*** *(លះបង់) បានដល់ ឲ្យដល់អ្នកដទៃ ។*

ចប់អដ្ឋកថា សូត្រទី ៤

## អដ្ឋកថាសូត្រទី ៥

*សូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៦៧] *បទថា* ន *វិស្សជ្ជេតិ (មិនលះបង់) សេចក្តីថា មិនឲ្យដល់អ្នកដទៃទាំងអស់តែម្តង តែឲ្យកាន់យកល្មមព្យាបាលអត្តភាពខ្លួន សល់ក្រៅពីនោះមិនឲ្យ ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

*សូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៦៨] *បទថា* ***សុភនិមិត្តំ*** *បានដល់ អារម្មណ៍ដែលគួរប្រាថ្នា ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

*សូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៦៩] *បទថា* ***បដិឃនិមិត្តំ*** *បានដល់ និមិត្តដែលមិនគួរប្រាថ្នា ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*សូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៧០] *បទថា **បរតោ ច ឃោសោ** (បរតោឃោសៈ) បានដល់ ការស្តាប់អសទ្ធម្មពីសម្នាក់អ្នកដទៃ ។*

ចប់អដ្ឋកថា សូត្រទី ៨

## អដ្ឋកថាសូត្រទី ៩

*សូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៧១-៣៧៤] បទថា **បរតោ ច ឃោសោ** (បរតោឃោសៈ) បានដល់ការស្ដាប់ព្រះសទ្ធម្មពីសម្នាក់អ្នកដទៃ ។*

ចប់អដ្ឋកថា សូត្រទី ៩

*ពាក្យដ៏សេសក្នុងទីទាំងពួង ងាយទាំងអស់នោះឯង ។*

## ចប់អាសាវគ្គទី ១

ក្នុងវគ្គនេះ មាន ១២ សូត្រ

ព្រះអដ្ឋកថាអធិប្បាយសេចក្ដី ៩ សូត្រ

# អាយាចនវគ្គទី ២

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៧៥] *បទថា* ***សទ្ធោ ភិក្ខវេ ភិក្ខុ ឯវំ សម្មា អាយាចមានោ អាយាចេយ្យ*** *(ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកមានសទ្ធា កាលបន់ស្រន់ដោយល្អ គប្បីបន់ស្រន់យ៉ាងនេះ) សេចក្តីថា ភិក្ខុអ្នកមានសទ្ធា កាលនឹងសូម គឺ ត្រូវប្រាថ្នាយ៉ាងនេះថា សូម្បីយើងក៏ចូរមានបញ្ញាដូចជាព្រះសារីបុត្តត្ថេរ សូម្បីយើងក៏ចូរមានឫទ្ធិដូចជាព្រះមោគ្គល្លានត្ថេរ ដូច្នេះ ឈ្មោះថា ការប្រាថ្នាដោយប្រពៃ ព្រោះប្រាថ្នាវត្ថុដែលមានហើយប៉ុណ្ណោះ ។ កាលប្រាថ្នាក្រៃលែងជាងនេះ គឺ ប្រាថ្នាខុស ព្រោះថា កាលលះបង់សេចក្តីប្រាថ្នា ២ យ៉ាងចេញ ប្រាថ្នាបែបនេះ រមែងឈ្មោះថា ប្រាថ្នាខុស ព្រោះប្រាថ្នាវត្ថុដែលមិនមាន ។ ព្រោះហេតុអ្វី ។ បទថា* ***ឯសា ភិក្ខវេ តុលា ឯតំ បមាណំ*** *(ម្នាលភិក្ខុទាំងឡាយ ភិក្ខុសារីបុត្ត និងភិក្ខុមោគ្គល្លាននេះ ជាជញ្ជីង ជាមាត្រដ្ឋាន) សេចក្តីថា កាលនឹងថ្លឹងមាស ឬប្រាក់ គប្បីប្រើជញ្ជីង កាលនឹងវាល់អង្ករ គប្បីប្រើគ្រឿងវាល់ ជញ្ជីងជាមាត្រដ្ឋានក្នុងការថ្លឹង និងគ្រឿងវាល់ជាមាត្រដ្ឋានក្នុងការវាល់ ដោយប្រការដូច្នេះ យ៉ាងណា សារីបុត្រ និងមោគ្គល្លាន ជាគ្រឿង*

*ប្ដឹង ជាគ្រឿងវាស់ សម្រាប់ពួកភិក្ខុជាសាវករបស់តថាគត កាន់យកអ្នកទាំងពីរនោះ ទើបអាចប្ដឹង ឬវាស់ខ្លួនបានថា សូម្បីយើងក៏ស្មើដោយញាណ ឬដោយឫទ្ធិ ក្រៅអំពីនេះ មិនអាចនឹងប្ដឹង ឬវាស់បាន ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២ ជាដើម

[៣៧៦-៣៧៨] សូម្បីក្នុងសូត្រទី ២ ជាដើម ក៏ន័យនេះដូចគ្នា ។ តែក្នុងសូត្រនេះ បែកគ្នាដូច្នេះ ។ បទថា **ខេមា ច ភិក្ខុនី ឧប្បលវណ្ណា ច** (ភិក្ខុនីខេមា និងឧប្បលវណ្ណា) សេចក្ដីថា ក៏បណ្ដាភិក្ខុនី ២ រូបនោះ ខេមាភិក្ខុនី ជាកំពូលផ្នែកខាងបញ្ញា ឧប្បលវណ្ណាភិក្ខុនី ជាកំពូលផ្នែកខាងឫទ្ធិ ដូច្នោះ កាលប្រាថ្នាដោយប្រពៃ គប្បីប្រាថ្នាថា សូមឲ្យយើងចូរជាយ៉ាងនេះ ផ្នែកបញ្ញាក្តី ផ្នែកឫទ្ធិក្តី ។ សូម្បីឧបាសិកាខុជ្ជុត្តរាក៏ប្រសើរ ព្រោះមានបញ្ញាច្រើន នន្ទមាតាប្រសើរព្រោះមានឫទ្ធិច្រើន ព្រោះដូច្នោះ កាលប្រាថ្នាដោយប្រពៃ គប្បីប្រាថ្នាថា សូម្បីយើងក៏ចូរជាយ៉ាងនេះ ខាងបញ្ញាក្តី ខាងឫទ្ធិក្តី ។

ចប់អដ្ឋកថា សូត្រទី ២ ជាដើម

# អដ្ឋកថាសូត្រទី ៥

មានវិនិច្ឆ័យដូចតទៅនេះ ៖

[៣៧៩] បទថា **ខតំ** (ត្រូវកម្ចាត់) សេចក្តីថា ឈ្មោះថាត្រូវកម្ចាត់ ព្រោះត្រូវកម្ចាត់គុណ គឺ សេចក្តីល្អ ។ បទថា **ឧបហតំ** (ត្រូវទម្លាយ) សេចក្តីថា ឈ្មោះថាត្រូវទម្លាយ ព្រោះត្រូវទម្លាយគុណ គឺ សេចក្តីល្អ អធិប្បាយថា ត្រូវកាត់គុណ គឺ សេចក្តីល្អ វិនាសគុណ គឺ សេចក្តីល្អ ។ បទថា **អត្តានំ បរិហរតិ** សេចក្តីថា រក្សាខ្លួនដែលប្រាសចាកគុណ គឺ សេចក្តីល្អ ។ បទថា **សាវជ្ជោ** (ប្រព្រឹត្តទៅដោយទោស) បានដល់ មានទោស ។ បទថា **សានុវជ្ជោ** (ត្រូវបណ្ឌិតតិះដៀល) បានដល់ ត្រូវតិះដៀល ។ បទថា **បសវតិ** (ប្រសព្វ) បានដល់ រមែងបាន ។ បទថា **អននុវិច្ច** មិនដឹង មិនពិចារណា ។ បទថា **អបរិយោគាហេត្វា** បានដល់ មិនជញ្ជាំងជាល សាកសួរ ។ បទថា **អវណ្ណារហស្ស** (របស់បុគ្គលដែលគួរតិះដៀល) សេចក្តីថា របស់តិរ្ថិយក៏ដោយ របស់សាវកតិរ្ថិយក៏ដោយ អ្នកបដិបត្តិខុស គួរតិះដៀល ។ បទថា **វណ្ណំ ភាសតិ** (និយាយសរសើរគុណ) សេចក្តីថា ពោលដល់គុណថា បុគ្គលនេះបដិបត្តិល្អ បដិបត្តិត្រូវ ដូច្នេះ ។ បទថា **វណ្ណារហស្ស** (បុគ្គលដែលគួរសរសើរ) សេចក្តីថា បណ្តាព្រះអរិយបុគ្គល មានព្រះពុទ្ធជាដើម អង្គណាមួយ

ដែលបដិបត្តិប្រពៃ ។ បទថា ***អវណ្ណំ ភាសតិ*** (ពោលទោស) សេចក្តីថា ពោលទោសថា បុគ្គលនេះបដិបត្តិអាក្រក់ បដិបត្តិខុស ដូច្នេះ ។ បទថា ***អវណ្ណារហស្ស អវណ្ណំ ភាសតិ*** (និយាយតិះដៀលបុគ្គលដែលគួរតិះដៀល) សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ពោលតិះដៀលតិរ្ថិយ សាវកតិរ្ថិយ អ្នកបដិបត្តិអាក្រក់ បដិបត្តិខុស ថាជាអ្នកបដិបត្តិអាក្រក់ព្រោះហេតុដូច្នេះខ្លះ ជាអ្នកបដិបត្តិខុសព្រោះហេតុដូច្នេះខ្លះ ឈ្មោះថា រមែងពោលតិះដៀលបុគ្គលដែលគួរតិះដៀល ។ បទថា ***វណ្ណារហស្ស វណ្ណំ*** (សរសើរបុគ្គលដែលគួរសរសើរ) សេចក្តីថា ពោលសរសើរព្រះពុទ្ធ និងពួកពុទ្ធសាវកអ្នកបដិបត្តិល្អ បដិបត្តិប្រពៃ ថាជាអ្នកបដិបត្តិល្អព្រោះហេតុដូច្នេះខ្លះ ជាអ្នកបដិបត្តិប្រពៃព្រោះហេតុដូច្នេះខ្លះ ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

*សូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៨០] *បទថា* ***អប្បសាទនីយេ ឋានេ*** *(ក្នុងឋានៈមិនជាទីតាំងនៃសេចក្តីជ្រះថ្លា) បានដល់ ក្នុងហេតុដែលធ្វើមិនឲ្យជ្រះថ្លា ។ បទថា* ***បសាទំ ឧបទុំសេតិ*** *(កើតសេចក្តីជ្រះថ្លា) សេចក្តីថា ឲ្យកើតសេចក្តីជ្រះថ្លាក្នុងវត្តបដិបត្តិអាក្រក់ វត្តបដិបត្តិខុស ថា នេះជាវត្តបដិបត្តិល្អ វត្តបដិបត្តិប្រពៃ ដូច្នេះ ។ បទថា* ***បសាទនីយេ ឋានេ អប្បសាទំ*** *(មិនជ្រះថ្លាក្នុងឋានៈជាទីតាំងនៃសេចក្តីជ្រះថ្លា) សេចក្តីថា ឲ្យកើតសេចក្តីមិនជ្រះថ្លាក្នុងវត្តបដិបត្តិល្អ វត្តបដិបត្តិប្រពៃថា នេះជាវត្តបដិបត្តិខុស ដូច្នេះ ។ ពាក្យដ៏សេសក្នុងសូត្រនេះ ងាយទាំងនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

*សូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៨១] បទថា* **ទ្វីសុ** *បានដល់ (ពីរជំពូក) បានដល់ ក្នុងឱកាសពីរ ក្នុងហេតុពីរ ។ បទថា* **មិច្ឆាបដិបជ្ជមានោ** *(បដិបត្តិខុស) បានដល់ កាន់យកវត្ថុបដិបត្តិខុស ។ បទថា* **មាតរិ ច បិតរិ ច** *(មាតា ១ បិតា ១) សេចក្តីថា បដិបត្តិខុសក្នុងមាតា ដូចនាយមិត្តវិន្ទុកៈ , បដិបត្តិក្នុងបិតា ដូចព្រះបាទអជាតសត្រូវ ។ ធម៌ចំណែកស គប្បីជ្រាបតាមន័យដែលពោលហើយនោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*សូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៨២] បទថា **តថាគតេ ច តថាគតសាវកេ ច** (ព្រះតថាគត ១ សាវកព្រះតថាគត ១) សេចក្តីថា បដិបត្តិខុសក្នុងព្រះតថាគត ដូចជាព្រះទេវទត្ត និងបដិបត្តិខុសក្នុងសាវករបស់ព្រះតថាគត ដូចជាព្រះកោកាលិកៈ ។ ក្នុងចំណែកសបដិបត្តិប្រពៃក្នុងព្រះតថាគត ដូចជាព្រះអានន្ទត្ថេរៈ និងបដិបត្តិប្រពៃក្នុងសាវករបស់ព្រះតថាគត ដូចជាបុត្តរបស់សេដ្ឋីអ្នកចិញ្ចឹមគោឈ្មោះនន្ទៈ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*សូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៨៣] បទថា **សចិត្តវោទានំ** (ការជម្រះចិត្តរបស់ខ្លួនឲ្យផូរផង់) ប្រែថា សេចក្ដីផូរផង់នៃចិត្តរបស់ខ្លួន ។ បទនេះ ជាឈ្មោះរបស់សមាបត្តិ ៨ ។ បទថា **ន ច កិញ្ចិ លោកេ ឧបាទិយតិ** (មិនប្រកាន់អ្វីៗ ក្នុងលោក) សេចក្ដីថា មិនប្រកាន់ គឺ មិនប្រកាន់បណ្ដាធម៌មានរូបជាដើម សូម្បីធម៌ណាទីមួយក្នុងលោក ។ ក្នុងសូត្រនេះ សេចក្ដីមិនប្រកាន់មាំ ជាធម៌ទី ២ ដោយប្រការដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០-១១

[៣៨៤-៣៨៥] *សូត្រទី ១០ និងសូត្រទី ១១ ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ១០-១១

## ចប់អាយាចនវគ្គទី ២

ក្នុងវគ្គនេះ មាន ១១ សូត្រ

ព្រះអដ្ឋកថាអធិប្បាយសេចក្តី ៩ សូត្រ

# ទានវគ្គទី ៣

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៨៦] បទថា **ទានានិ** (ទាន) សេចក្តីថា ឈ្មោះថា ទាន ដោយអំណាចនៃវត្ថុ មានទានជាដើមដែលគេឲ្យ បទនេះ ជាឈ្មោះរបស់ទេយ្យធម៌ ម្យ៉ាងទៀត ចេតនាព្រមដោយវត្ថុ ឈ្មោះថា ទាន បទនេះ ជាឈ្មោះនៃការបរិច្ចាគសម្បត្តិ ។ បទថា **អាមិសទានំ** សេចក្តីថា បច្ច័យ ៤ ឈ្មោះថា អាមិសទាន ព្រោះជារបស់ដែលគេឲ្យ ។ បទថា **ធម្មទានំ** សេចក្តីថា បុគ្គលខ្លះក្នុងលោកនេះ ពោលបដិបទាជាគ្រឿងសម្រេចអមតៈ នេះឈ្មោះថា ធម្មទាន ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*សូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៨៧] *បច្ច័យ ៤ ឈ្មោះថា* **យាគៈ** *ព្រោះជាគ្រឿងបូជា សូម្បីធម្មៈក៏គប្បីជ្រាបថា ឈ្មោះថា* **យាគៈ** *ព្រោះជាគ្រឿងបូជា ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៨៨] ការលះបង់អាមិស ឈ្មោះថា* ***អាមិសចាគះ*** *ការលះបង់ធម៌ ឈ្មោះថា* ***ធម្មចាគះ*** *។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

[៣៨៩] *សូត្រទី ៤ ប្លែកគ្នាត្រឹមតែឧបសគ្គ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

*សូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៩០] *ការបរិភោគបច្ច័យ ៤ ឈ្មោះថា **អាមិសភោគៈ** ការបរិភោគធម៌ ឈ្មោះថា **ធម្មភោគៈ** ។*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

[៣៩១] *សូត្រទី ៦ ប្លែកគ្នាត្រឹមតែឧបសគ្គ ។*

ចប់អដ្ឋកថា សូត្រទី ៦

# អដ្ឋកថាសូត្រទី ៧

*សូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៩២] ការចែកចាយបច្ច័យ ៤ ឈ្មោះថា **អាមិសសំវិភាគ** ការចែកចាយធម៌ ឈ្មោះថា **ធម្មសំវិភាគ** ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*សូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៩៣] *ការសង្គ្រោះដោយបច្ច័យ ៤ ឈ្មោះថា* ***អាមិសសង្គ្រោះ*** *ការសង្គ្រោះដោយធម៌ ឈ្មោះថា* ***ធម្មសង្គ្រោះ*** *ៗ*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*សូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៩៤] *ការអនុគ្រោះដោយបច្ច័យ ៤ ឈ្មោះថា* **អាមិសអនុគ្រោះ** *ការអនុគ្រោះដោយធម៌ ឈ្មោះថា* **ធម្មអនុគ្រោះ** ។

ចប់អដ្ឋកថា សូត្រទី ៩

## អដ្ឋកថាសូត្រទី ១០

*សូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៣៩៥] *ការសម្តែងសេចក្តីអើពើដោយបច្ច័យ ៤ ឈ្មោះថា* ***អាមិសអនុ-កម្បៈ*** *ការសម្តែងសេចក្តីអើពើដោយធម៌ ឈ្មោះថា* ***ធម្មអនុកម្បៈ*** *។*

ចប់អដ្ឋកថា សូត្រទី ១០

## ចប់ឆានវគ្គទី ៣

ក្នុងវគ្គនេះ មាន ១០ សូត្រ

ព្រះអដ្ឋកថាអធិប្បាយសេចក្តី ៨ សូត្រ

# សន្ថារវគ្គទី ៤

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៩៦] ការរាក់ទាក់ដោយបច្ច័យ ៤ ដោយបិទបាំងធ្វើមិនឲ្យមានចន្លោះប្រហោងរវាងខ្លួន និងអ្នកដទៃ ឈ្មោះថា **អាមិសសន្ថារ** ។ ការរាក់ទាក់ដោយធម៌ ឈ្មោះថា **ធម្មសន្ថារ** ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

[៣៩៧] *ក្នុងសូត្រទី ២ ប្លែកគ្នាត្រឹមតែឧបសគ្គ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

*សូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៣៩៨] ការស្វែងរកអាមិសមានប្រការដូចពោលហើយ ឈ្មោះថា* ***អាមិ-សេសនា*** *។ ការស្វែងរកធម៌ ឈ្មោះថា* ***ធម្មេសនា*** *។*

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

[៣៩៩] *ក្នុងសូត្រទី ៤ ប្លែកគ្នាត្រឹមតែឧបសគ្គ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

*សូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០០] *ការស្វែងរកអាមិសដល់ទីបំផុត លោកហៅថា* ***អាមិសបរិយេដ្ឋិ*** *ការស្វែងរកធម៌ដល់ទីបំផុត លោកហៅថា* ***ធម្មបរិយេដ្ឋិ*** *ៗ*

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦

*សូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០១] *ការបូជាដោយអាមិស ឈ្មោះថា* ***អាមិសបូជា*** *ការបូជាដោយធម៌ ឈ្មោះថា* ***ធម្មបូជា*** *។*

ចប់អដ្ឋកថា សូត្រទី ៦

## អដ្ឋកថាសូត្រទី ៧

*សូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០២] *បទថា **អតិថេយ្យានិ** (ទានដើម្បីភ្ញៀវ) បានដល់ ទានសម្រាប់អ្នកដើរមក ។ បាឋៈថា **អភិថេយ្យានិ** ដូច្នេះក៏មាន ។*

ចប់អដ្ឋកថា សូត្រទី ៧

# អដ្ឋកថាសូត្រទី ៨

*សូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០៣] *ការសម្រេចដោយអាមិស ឈ្មោះថា* ***អាមិសិទ្ធិ*** *ព្រោះឲ្យសម្រេចសព្វយ៉ាងដោយអាមិស សូម្បីធម៌ ក៏ឈ្មោះថា* ***ធម្មិទ្ធិ*** *ព្រោះឲ្យសម្រេចសព្វគ្រប់ ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*សូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០៤] *សេចក្តីចម្រើនដោយអាមិស ឈ្មោះថា* ***អាមិសវុឌ្ឍិ*** *សេចក្តីចម្រើនដោយធម៌ ឈ្មោះថា* ***ធម្មវុឌ្ឍិ*** *។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*សូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០៥] *អាមិសដែលធ្វើឲ្យកើតសេចក្ដីត្រេកអរ ឈ្មោះថា* ***អាមិសរតនៈ*** *ធម៌ ឈ្មោះថា* ***ធម្មរតនៈ*** *។*

ចប់អដ្ឋកថា សូត្រទី ១០

# អដ្ឋកថាសូត្រទី ១១

*សូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០៦] *ការសន្សំអាមិស ឈ្មោះថា* **អាមិសសន្និចយ:** *ការសន្សំធម៌ ឈ្មោះថា* **ធម្មសន្និចយ:** *។*

ចប់អដ្ឋកថា សូត្រទី ១១

# អដ្ឋកថាសូត្រទី ១២

*សូត្រទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០៧] *សេចក្តីសម្បូរនៃអាមិស ឈ្មោះថា **អាមិសវេបុល្លៈ** សេចក្តីសម្បូរនៃធម៌ ឈ្មោះថា **ធម្មវេបុល្លៈ** ដូច្នេះឯង ។*

ចប់អដ្ឋកថា សូត្រទី ១២

## ចប់សន្តានវគ្គទី ៤

ក្នុងវគ្គនេះ មាន ១២ សូត្រ

ព្រះអដ្ឋកថាអធិប្បាយសេចក្តី ១០ សូត្រ

# សមាបត្តិវគ្គទី ៥

## អដ្ឋកថាសូត្រទី ១

*សូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៤០៨] បទថា **សមាបត្តិកុសលតា** (ភាពជាអ្នកឈ្លាសក្នុងសមាបត្តិ) បានដល់ ជាអ្នកឈ្លាសក្នុងការកំណត់អាហារសប្បាយចូលសមាបត្តិ ។ បទថា **សមាបត្តិវុដ្ឋានកុសលតា** (ភាពជាអ្នកឈ្លាសក្នុងការចេញចាកសមាបត្តិ) សេចក្ដីថា កាលបានវេលាតាមកំណត់ជាអ្នកឈ្លាសក្នុងការចេញ ឈ្មោះថា ជាអ្នកឈ្លាសក្នុងការចេញចាកសមាបត្តិ ព្រោះដូច្នោះ បុគ្គលនេះ ឈ្មោះថា ឈ្លាស ដូច្នេះ ។*

ចប់អដ្ឋកថា សូត្រទី ១

# អដ្ឋកថាសូត្រទី ២

*ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤០៩] *បទថា* ***អាជ្ជវំ*** *(ភាពជាអ្នកស្មោះត្រង់) បានដល់ ភាពនៃចិត្តត្រង់ ។ បទថា* ***មទ្ទវំ*** *(ភាពជាអ្នកឱនលំទោន) បានដល់ ភាពនៃចិត្តទន់ ។*

ចប់អដ្ឋកថា សូត្រទី ២

# អដ្ឋកថាសូត្រទី ៣

ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤១០] បទថា **ខន្តិ** បានដល់ អធិវាសនខន្តិ ។ បទថា **សោរច្ចំ** បានដល់ សេចក្តីរៀបរយ សេចក្តីស្ងប់ស្ងៀម ។

ចប់អដ្ឋកថា សូត្រទី ៣

# អដ្ឋកថាសូត្រទី ៤

*ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

*[៤១១] បទថា* ***សាខល្យំ*** *(ភាពជាអ្នកមានវាចាពីរោះ) បានដល់ ការលើកសរសើរដោយប្រើវាចាពីរោះ ។*

*បទថា* ***បដិសន្ថារោ*** *(ការទទួលរាក់ទាក់) បានដល់ ការទទួលដោយអាមិសក្តី ដោយធម៌ក្តី ឈ្មោះថា បដិសន្ថារៈ ។*

ចប់អដ្ឋកថា សូត្រទី ៤

# អដ្ឋកថាសូត្រទី ៥

ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤១២] បទថា **អវិហឹសា** (ការមិនបៀតបៀន) បានដល់ ធម៌ដែលជាចំណែកខាងដើមរបស់ករុណា ។ បទថា **សោចេយ្យំ** (ភាពជាបុគ្គលស្អាត) បានដល់ សេចក្ដីស្អាតដោយសីល ។

ចប់អដ្ឋកថា សូត្រទី ៥

# អដ្ឋកថាសូត្រទី ៦-៧

[៤១៣-៤១៤] *ក្នុងសូត្រទី ៦-៧ មានសេចក្តីងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា សូត្រទី ៦-៧

# អដ្ឋកថាសូត្រទី ៨

*ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤១៥] *បទថា **បដិសង្ខានពលំ** បានដល់ កម្លាំង គឺ ការពិចារណា ។*

ចប់អដ្ឋកថា សូត្រទី ៨

# អដ្ឋកថាសូត្រទី ៩

*ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤១៦] *ឈ្មោះថា កម្លាំង គឺ សតិ ព្រោះការមិនមានសតិ ក៏មិនញាប់ញ័រ ។ ឈ្មោះថា កម្លាំង គឺ សមាធិ ព្រោះកាលវាយមាយ ក៏មិនញាប់ញ័រ ។*

ចប់អដ្ឋកថា សូត្រទី ៩

# អដ្ឋកថាសូត្រទី ១០

*ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤១៧] *បទថា **សមថោ** បានដល់ ភាពនៃចិត្តតម្កល់មាំ ។*

*បទថា **វិបស្សនា** បានដល់ ញាណកំណត់សង្ខារជាអារម្មណ៍ ។*

ចប់អដ្ឋកថា សូត្រទី ១០

## អដ្ឋកថាសូត្រទី ១១

*ក្នុងសូត្រទី ១១ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤១៨] *បទថា **សីលវិបត្តិ** បានដល់ ការទ្រុស្តសីល ។*

*បទថា **ទិដ្ឋិវិបត្តិ** បានដល់ មិច្ឆាទិដ្ឋិ ។*

ចប់អដ្ឋកថា សូត្រទី ១១

# អដ្ឋកថាសូត្រទី ១២

ក្នុងសូត្រទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ៖

[៤១៩] បទថា **សីលសម្បទា** បានដល់ ភាពសម្បូរនៃសីល ។

បទថា **ទិដ្ឋិសម្បទា** បានដល់ សម្មាទិដ្ឋិ ។ ដោយបទនោះ លោករួមយកសម្មាទិដ្ឋិសូម្បីទាំងពួង គឺ កម្មស្សកតាសម្មាទិដ្ឋិ ឈានសម្មាទិដ្ឋិ វិបស្សនាសម្មាទិដ្ឋិ មគ្គសម្មាទិដ្ឋិ ផលសម្មាទិដ្ឋិ ឈ្មោះថា **សម្មាទិដ្ឋិ** ។

ចប់អដ្ឋកថា សូត្រទី ១២

# អដ្ឋកថាសូត្រទី ១៣

*ក្នុងសូត្រទី ១៣ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២០] *បទថា* ***សីលវិសុទ្ធិ*** *បានដល់ សីលដែលអប់រំវិសុទ្ធិ ។ បទថា* ***ទិដ្ឋិវិសុទ្ធិ*** *បានដល់ សម្មាទិដ្ឋិក្នុងមគ្គទាំង ៤ ដែលអប់រំវិសុទ្ធិ ឬសម្មាទិដ្ឋិទាំង ៥ យ៉ាង ។*

ចប់អដ្ឋកថា សូត្រទី ១៣

# អដ្ឋកថាសូត្រទី ១៤

*ក្នុងសូត្រទី ១៤ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២១] *បទថា* ***ទិដ្ឋិវិសុទ្ធិ*** *បានដល់ សម្មាទិដ្ឋិដែលអប់រំវិសុទ្ធិនុ៎ះឯង ។ បទថា* ***យថាទិដ្ឋស្ស ច បធានំ*** *(សេចក្តីព្យាយាមសមគួរដល់ទិដ្ឋិ) សេចក្តីថា សេចក្តីព្យាយាមដែលសម្បយុត្តដោយមគ្គខាងក្រោម លោកពោលថា* ***សេចក្តីព្យាយាមសមគួរដល់ទិដ្ឋិ*** *ព្រោះអនុរូបដល់ទិដ្ឋិនោះ ។*

ចប់អដ្ឋកថា សូត្រទី ១៤

# អដ្ឋកថាសូត្រទី ១៥

*ក្នុងសូត្រទី ១៥ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២២] *បទថា* ***អសន្តុដ្ឋិតា ច កុសលេសុ ធម្មេសុ*** *(ភាពជាបុគ្គលមិនល្មមក្នុងកុសលធម៌) បានដល់ ភាពជាបុគ្គលមិនសន្តោសក្នុងកុសលធម៌ទាំងឡាយក្រៅពីអរហត្តមគ្គ ។*

ចប់អដ្ឋកថា សូត្រទី ១៥

# អដ្ឋកថាសូត្រទី ១៦

*ក្នុងសូត្រទី ១៦ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២៣] *បទថា* ***មុដ្ឋស្សច្ចំ*** *ប្រែថា ភាពជាបុគ្គលមិនមានសតិ ។ បទថា* ***អសម្បជញ្ញំ*** *បានដល់ សេចក្តីមិនដឹងខ្លួន ។*

ចប់អដ្ឋកថា សូត្រទី ១៦

# អដ្ឋកថាសូត្រទី ១៧

*ក្នុងសូត្រទី ១៧ មានវិនិច្ឆ័យដូចតទៅនេះ ៖*

[៤២៤] *សតិ មានចិត្តតាំងមាំជាលក្ខណៈ ។ **សម្បជញ្ញៈ** មានដឹងខ្លួនជាលក្ខណៈ ។*

ចប់អដ្ឋកថា សូត្រទី ១៧

## ចប់សន្តារវគ្គទី ៤

ក្នុងវគ្គនេះ មាន ១៧ សូត្រ

ព្រះអដ្ឋកថាអធិប្បាយសេចក្តី ១៥ សូត្រ

## ចប់តតិយបណ្ណាសកៈ

# អដ្ឋកថាមិនសង្គ្រោះក្នុងបណ្ណាសកៈ

[ ៤២៥ - ៤៣៩ ]

## អដ្ឋកថា កោធបេយ្យាល

*ក្នុងបទដទៃៗ អំពីនេះ **កោធៈ** មានក្រោធជាលក្ខណៈ **ឧបនាហៈ** មានភាពរឹងត្អឹងជាលក្ខណៈ **មក្ខៈ** មានការលុបគុណដែលគេធ្វើល្អហើយជាលក្ខណៈ **បឡាសៈ** មានការវាយឫកស្មើជាលក្ខណៈ **ឥស្សា** មានការច្រណែនជាលក្ខណៈ ភាពជាអ្នកកំណាញ់ ៥ យ៉ាង ឈ្មោះថា **មច្ឆរិយៈ** ទាំងអស់នោះ មានការលាក់ ទុកជាលក្ខណៈ **មាយា** មានការបិទបាំងវត្តដែលធ្វើទុកជាលក្ខណៈ **សាឋេយ្យៈ** មានការអួតអាងជាលក្ខណៈ អាការ គឺ ការមិនខ្មាសបាប ឈ្មោះថា **អហិរិកៈ** អាការ គឺ ការមិនខ្លាចដល់សេចក្តីតិះដៀល ឈ្មោះថា **អនោត្តប្បៈ** ធម៌មាន **អកោធៈ** ជាដើម គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងឧបក្កិលេសទាំងនោះ ។*

*បទថា **សេក្ខស្ស ភិក្ខុនោ** (ដល់ភិក្ខុដែលនៅជាសេក្ខៈ) បណ្ឌិតគប្បីជ្រាបថា ធម៌ ២ យ៉ាង រមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យ ចាកគុណដែលខ្ពស់ៗ ឡើងទៅ របស់ព្រះសេក្ខៈទាំង ៧ ពួក ទាំងរមែងប្រព្រឹត្តទៅដើម្បីសេចក្តីសាបសូន្យនៃបុថុជ្ជនអ្នកចូនក្នុងព្រះសទ្ធម្មដូចគ្នា ដូច្នេះ ។ បទថា **អបរិហានាយ***

*(ដើម្បីសេចក្ដីមិនសាបសូន្យ) សេចក្ដីថា ដើម្បីការមិនវិនាសចាកគុណដែលខ្ពស់ៗ ឡើងទៅ ។*

*ក្នុងបទថា* **យថាភតំ និក្ខិត្តោ** *(ដូចជាត្រូវគេនាំទៅដំកល់ទុក) នេះ គប្បីជ្រាបសេចក្ដីថា នៅក្នុងនរកដូចជាគេនាំទៅទម្លាក់ចោល ។*

*បទថា* **ឯកច្ចោ**[១] *(បុគ្គលពួកខ្លះ) សេចក្ដីថា សេចក្ដីក្រោធជាដើមទាំងនេះ មាននៅដល់បុគ្គលណា បុគ្គលនោះឈ្មោះថា បុគ្គលពួកខ្លះ ។*

ចប់អដ្ឋកថា កោធបេយ្យាល

---

១ *ក្នុងបិដក ឥធេកច្ចោ ។*

# អដ្ឋកថា អកុសលបេយ្យាល

*បទថា **សាវជ្ជា** (មានទោស) បានដល់ មានកំហុស ។ បទថា **អនវជ្ជា** (មិនមានទោស) មិនមានកំហុស ។ បទថា **ទុក្ខុទ្រយា** (មានទុក្ខជាកម្រៃ) បានដល់ មានទុក្ខជាផល ។ **សុខុទ្រយា** (មានសុខជាកម្រៃ) បានដល់ មានសុខជាផល ។ បទថា **សព្យាបជ្ឈា** (ប្រព្រឹត្តទៅជាមួយសេចក្តីបៀតបៀន) បានដល់ មានទុក្ខ ។ បទថា **អព្យាបជ្ឈា** (មិនមានសេចក្តីបៀតបៀន) បានដល់ គ្មានទុក្ខ ។ ព្រះមានព្រះភាគត្រាស់វដ្តៈ និងវិវដ្តៈនោះឯង ដោយព្រះតម្រាស់ត្រឹមប៉ុណ្ណោះ ។*

ចប់អដ្ឋកថា អកុសលបេយ្យាល

# អដ្ឋកថា វិនយបេយ្យាល

បទថា **ទ្វេមេ ភិក្ខវេ អត្ថវសេ បដិច្ច** (ម្នាលភិក្ខុទាំងឡាយ ព្រោះអាស្រ័យប្រយោជន៍ ២ យ៉ាង) សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ តថាគតអាស្រ័យប្រយោជន៍ ២ យ៉ាង គឺ សំដៅដល់ហេតុ ២ យ៉ាង ។ បទថា **សិក្ខាបទំ បញ្ញត្តំ** (ទ្រង់បញ្ញត្តិសិក្ខាបទ) សេចក្ដីថា ទ្រង់បញ្ញត្តិចំណែកនៃសិក្ខា ។ បទថា **សង្ឃសុដ្ឋុតាយ** (ដើម្បីសេចក្ដីល្អនៃសង្ឃ) សេចក្ដីថា ដើម្បីឲ្យសង្ឃទទួលថាល្អ អធិប្បាយថា ដើម្បីសង្ឃពោលទទួលថា ល្អហើយ ព្រះអង្គ ។ បទថា **សង្ឃផាសុតាយ** (ដើម្បីសេចក្ដីសុខនៃសង្ឃ) សេចក្ដីថា ដើម្បីការនៅជាសុខនៃសង្ឃ ។ បទថា **ទុម្មង្កូនំ** (បុគ្គលមិនដឹង) បានដល់ បុគ្គលទ្រុស្តសីល ។ បទថា **បេសលានំ** (បុគ្គលមានសីលជាទីស្រឡាញ់) បានដល់ បុគ្គលមានសីលជាទីពេញចិត្ត ។ បទថា **ទិដ្ឋធម្មិកានំ អាសវានំ** (អាសវៈដែលនឹងកើតក្នុងបច្ចុប្បន្ន) សេចក្ដីថា ដែលអាសវៈទាំងឡាយពោលគឺ ទុក្ខធម៌ មានការសម្លាប់ ការឃុំឃាំង និងការតិះដៀលជាដើម ដែលគប្បីបានទទួល ព្រោះការកន្លងល្មើសជាហេតុក្នុងបច្ចុប្បន្ន គឺ ក្នុងអត្តភាពនេះឯង ។ បទថា **សំវរាយ** (ដើម្បីសង្រួម) បានដល់ ដើម្បីបិទ ។ បទថា **សម្បរាយិកានំ** (ដែលនឹងកើតក្នុងអនាគត) សេចក្ដីថា អាសវៈដែលកើតក្នុងសម្បរាយភព ពោលគឺទុក្ខដែលប្រព្រឹត្តទៅក្នុងអបាយ ដូច្នោះឯង ។ បទថា **បដិឃាតាយ** (ដើម្បីកម្ចាត់)

បានដល់ ដើម្បីហាម ។ បទថា **វេរានំ** (ពៀរ) បានដល់ អកុសលដែលជាពៀរខ្លះ បុគ្គលដែលមានពៀរនឹងគ្នាខ្លះ ។ បទថា **វជ្ជានំ** (ទោស) បានដល់ កំហុសទាំងឡាយ ។ ម្យ៉ាងទៀត ទុក្ខធម៌ទាំងនោះឯង បំណងយកថា **វជ្ជៈ** (គឺទោស) ក្នុងទីនេះ ព្រោះជាវត្ថុចាំបាច់ត្រូវវៀរ ។ បទថា **ភយានំ** (ភ័យ) បានដល់ ភ័យគឺ ចិត្តតក់ស្លុតខ្លះ ទុក្ខធម៌ទាំងនោះឯងដែលជាហេតុនៃភ័យខ្លះ ។ បទថា **អកុសលានំ** បានដល់ ទុក្ខធម៌ទាំងឡាយ ពោលគឺ អកុសល ព្រោះអត្ថថា មិនក្សេម ។ បទថា **គិហីនំ អនុកម្បាយ** (ដើម្បីអនុគ្រោះដល់គ្រហស្ថ) សេចក្តីថា សិក្ខាបទដែលទ្រង់បញ្ញត្តិកាលពួកគ្រហស្ថពោលទោស ឈ្មោះថា ទ្រង់បញ្ញត្តិដើម្បីអនុគ្រោះគ្រហស្ថទាំងឡាយ ។ បទថា **បាបិច្ឆានំ បក្ខុបច្ឆេទាយ** (ដើម្បីចូលទៅកម្ចាត់បក្ខពួករបស់ភិក្ខុអ្នកមានសេចក្តីប្រាថ្នាលាមក) សេចក្តីថា ដើម្បីកាត់បក្ខពួករបស់ពួកភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក ដោយគិតថា ពួកភិក្ខុអ្នកមានសេចក្តីប្រាថ្នាលាមកអាស្រ័យបក្ខពួក គប្បីទម្លាយសង្ឃ ។ បទថា **អប្បសន្នានំ បសាទាយ** (ដើម្បីសេចក្តីជ្រះថ្លានៃអ្នកមិនទាន់ជ្រះថ្លា) សេចក្តីថា ដើម្បីឲ្យមនុស្សបណ្ឌិតសូម្បីមិនទាន់ជ្រះថ្លាមកអំពីមុន កើតសេចក្តីជ្រះថ្លា ព្រោះបានឃើញនូវសេចក្តីដល់ព្រមនៃការបញ្ញត្តិសិក្ខាបទ ។ បទថា **បសន្នានំ ភិយ្យោភាវាយ** (ដើម្បីសេចក្តីជ្រះថ្លាក្រៃលែងរបស់អ្នកដែលជ្រះថ្លាហើយ) សេចក្តីថា ដើម្បីឲ្យអ្នកជ្រះថ្លាហើយ ជ្រះថ្លា

ក្រៃលែងឡើង ។ បទថា **សទ្ធម្មដ្ឋិតិយា** (ដើម្បីសេចក្តីតាំងមាំនៃព្រះសទ្ធម្ម) សេចក្តីថា ដើម្បីឲ្យព្រះសទ្ធម្មតាំងនៅយូរ ។ បទថា **វិនយានុគ្គហាយ** (ដើម្បីអនុគ្រោះព្រះវិន័យ) សេចក្តីថា ដើម្បីអនុគ្រោះព្រះវិន័យទាំង ៥ យ៉ាង ។

បទថា **បាដិមោក្ខំ បញ្ញត្តំ** (ទ្រង់បញ្ញត្តិបាតិមោក្ខ) សេចក្តីថា ទ្រង់បញ្ញត្តិបាតិមោក្ខទាំងពីរយ៉ាង គឺ ភិក្ខុបាតិមោក្ខ ភិក្ខុនីបាតិមោក្ខ ។ បទថា **បាដិមោក្ខុទ្ទេសា** (ទ្រង់បញ្ញត្តិបាតិមោក្ខុទ្ទេស) សេចក្តីថា ទ្រង់បញ្ញត្តិបាតិមោក្ខុទ្ទេស ៩ គឺ ចំពោះភិក្ខុ ៥ ចំពោះភិក្ខុនី ៤ ។ បទថា **បាដិមោក្ខដ្ឋបនំ** (ការបញ្ឈប់បាតិមោក្ខ) បានដល់ វៀរឧបោសថ (ឈប់សូត្របាតិមោក្ខកាលមានហេតុភ្លាមៗ) ។ បទថា **បវារណា បញ្ញត្តា** (ទ្រង់បញ្ញត្តិបវារណា) សេចក្តីថា ទ្រង់បញ្ញត្តិបវារណា ២ គឺ បវារណាថ្ងៃ ១៤ និងវារណាថ្ងៃ ១៥ ។ បទថា **បវារណាដ្ឋបនំ បញ្ញត្តំ** (ទ្រង់បញ្ញត្តិការបញ្ឈប់បវារណា) សេចក្តីថា ទ្រង់បញ្ញត្តិការបញ្ឈប់បវារណាកាលភិក្ខុមានអាបត្តិ សូត្រញត្តិបវារណា ។

ក្នុងតជ្ជនីយកម្មជាដើម កាលភិក្ខុទាំងឡាយចាក់ដោតគ្នាដោយលំពែង គឺវាចា ទ្រង់បញ្ញត្តិតជ្ជនីយកម្មដល់ពួកភិក្ខុពួកបណ្ឌុកៈ និងពួកលោហិតកៈ ។ ទ្រង់បញ្ញត្តិនិស្សយកម្មដល់ភិក្ខុសេយ្យសកៈដែលជាពាលមិនឆ្លាត ។ ទ្រង់ប្រារព្ធភិក្ខុពួកអស្សជិបុនព្វសុកៈដែលទ្រុស្តត្រកូល បញ្ញត្តិបព្វាជនីយកម្ម ។ ទ្រង់បញ្ញត្តិបដិ-

សារណីយកម្មដល់ព្រះសុធម្មត្ថេរៈដែលជេរពួកគ្រហស្ថ ទ្រង់បញ្ញត្តិឧក្ខេបនីយ-កម្ម ព្រោះមិនឃើញអាបត្តិជាដើម ។

ទ្រង់បញ្ញត្តិការឲ្យបរិវាស ដើម្បីអាបត្តិដែលបិទបាំងទុកសម្រាប់ភិក្ខុដែលត្រូវគរុកាបត្តិ ទ្រង់បញ្ញត្តិមូលាយបដិកស្សនៈ ដល់ភិក្ខុដែលត្រូវអាបត្តិក្នុងរវាងនៅបរិវាស ។ ទ្រង់បញ្ញត្តិការឲ្យមានត្តដើម្បីអាបត្តិដែលបិទបាំងក្តី ដែលមិនបានបិទបាំងក្តី ។ ទ្រង់បញ្ញត្តិអព្ភានដល់ភិក្ខុដែលប្រព្រឹត្តមានត្តហើយ ។

ទ្រង់បញ្ញត្តិ ឱសារណីយកម្មដល់ឧបសម្បទាបេក្ខៈអ្នកបដិបត្តិត្រូវរបៀប ។ ទ្រង់បញ្ញត្តិនិស្សារណីយកម្ម ព្រោះបដិបត្តិមិនត្រូវរបៀបជាដើម ។

ទ្រង់បញ្ញត្តិឧបសម្បទា ៨ យ៉ាង គឺ ១ ឯហិភិក្ខុឧបសម្បទា, ២ សរណ-គមនឧបសម្បទា, ៣ ឱវាទឧបសម្បទា, ៤ បញ្ហាព្យាករណឧបសម្បទា, ៥ ញត្តិ-ចតុត្ថកម្មឧបសម្បទា, ៦ គរុធម៌ឧបសម្បទា, ៧ ឧភតោសង្ឃេឧបសម្បទា, ៨ ទូតេនឧបសម្បទា ។ ទ្រង់បញ្ញត្តិកម្មដែលប្រកបដោយឋានៈ ៩ យ៉ាងនេះថា ញត្តិកម្ម រមែងដល់ឋានៈ ៩ ដូច្នេះ ។ ទ្រង់បញ្ញត្តិញត្តិទុតិយកម្ម ដែលប្រកបដោយឋានៈ ៧ យ៉ាងនេះថា ញត្តិទុតិយកម្ម រមែងដល់ឋានៈ ៧ ដូច្នេះ ។ ទ្រង់បញ្ញត្តិញត្តិចតុត្ថកម្មដែលប្រកបដោយឋានៈ ៧ ដូចគ្នាយ៉ាងនេះថា ញត្តិចតុត្ថកម្ម រមែងដល់ឋានៈ ៧ ដូច្នេះ ។

កាលទ្រង់មិនទាន់បានបញ្ញត្តិសិក្ខាបទទុកមុន ព្រះអង្គទ្រង់បញ្ញត្តិសិក្ខាបទមានបឋមបារាជិកជាដើម ឈ្មោះថា បឋមប្បញ្ញត្តិ ។ កាលទ្រង់បញ្ញត្តិសិក្ខាបទទុកហើយ ទ្រង់បញ្ញត្តិបន្ថែមសិក្ខាបទទាំងនោះឯង ឈ្មោះថា អនុបញ្ញត្តិ ។

ទ្រង់បញ្ញត្តិសម្មុខាវិន័យ ដែលប្រកបដោយសេចក្តីព្រមព្រៀង ៤ យ៉ាងនេះគឺ សេចក្តីព្រមព្រៀងដោយធម៌ សេចក្តីព្រមព្រៀងដោយវិន័យ សេចក្តីព្រមព្រៀងដោយសង្ឃ សេចក្តីព្រមព្រៀងដោយបុគ្គល ។ ទ្រង់បញ្ញត្តិសតិវិន័យ ដើម្បីមិនឲ្យចោទព្រះខីណាស្រពអ្នកមានសតិបរិបូណ៌ ។ ទ្រង់បញ្ញត្តិអមូឡ្ហវិន័យសម្រាប់ភិក្ខុឆ្កួត ។ ទ្រង់បញ្ញត្តិបដិញ្ញាតករណៈ ដើម្បីមិនកាត់អាបត្តិដល់ភិក្ខុដែលត្រូវចោទដោយមិនមានបដិញ្ញា ។ ទ្រង់បញ្ញត្តិយេភុយ្យសិកា ដើម្បីរម្ងាប់អធិករណ៍ដោយការឃើញរបស់ពួកធម្មវាទីដែលច្រើនជាង ។ ទ្រង់បញ្ញត្តិតស្សបាបិយសិកា ដើម្បីគ្របសង្កត់បុគ្គលមានបាបច្រើន ។ ទ្រង់បញ្ញត្តិតិណវត្ថារកៈ ដើម្បីរម្ងាប់អាបត្តិដ៏សេស ក្រៅពីអាបត្តិដែលមានទោសធ្ងន់ និងដែលទាក់ទងនឹងគ្រហស្ថដល់ភិក្ខុដែលត្រូវអាបត្តិ ព្រោះប្រព្រឹត្តរឿងមិនសមគួរដល់សមណភេទដ៏ច្រើនដូចជា ឈ្លោះគ្នាជាដើម ។

ចប់អដ្ឋកថា វិនយបេយ្យាល

# អដ្ឋកថារាគបេយ្យាល

បទថា *រាគស្ស ភិក្ខវេ អភិញ្ញាយ* (ម្នាលភិក្ខុទាំងឡាយ ដើម្បីដឹងដោយបញ្ញាដ៏ក្រៃលែង) សេចក្តីថា ដើម្បីដឹងច្បាស់ គឺ ធ្វើឲ្យប្រចក្ស នូវរាគៈដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ នោះឯង ។ បទថា **បរិញ្ញាយ** (ដើម្បីកំណត់ដឹង) បានដល់ ដើម្បីដឹងដោយជុំវិញ ។ បទថា **បរិក្ខយាយ** (ដើម្បីការអស់ទៅដោយជុំវិញ) បានដល់ ដើម្បីដល់ទីបំផុត ។ បទថា **បហានាយ** (ដើម្បីលះជាសមុច្ឆេទ) បានដល់ ដើម្បីលះបង់ ។ បទថា **ខយវយាយ** (ដើម្បីសេចក្តីសាបសូន្យ ដើម្បីសេចក្តីវិនាស) បានដល់ ដើម្បីដល់ការអស់ទៅ វិនាសទៅ ។ បទថា **វិរាគាយ** (ដើម្បីនឿយណាយ) បានដល់ ដើម្បីប្រាសចាកតម្រេក ។ បទថា **និរោធាយ** (ដើម្បីរលត់) បានដល់ ដើម្បីរលត់ដោយមិនមានសល់ ។ បទថា **ចាគាយ** (ដើម្បីលះ) បានដល់ ដើម្បីលះបង់ ។ បទថា **បដិនិស្សគ្គាយ** ដើម្បីរលាស់ចោល ។

បទថា **ថម្ភស្ស** (នូវភាពរឹងត្អឹង) បានដល់ ភាពរឹងរូស ដោយអំណាចសេចក្តីក្រោធ និងមានះ ។ បទថា **សារម្ភស្ស** (នូវការវាយឫកស្មើ) បានដល់ ការប្រណាំងប្រជែងវាសនា ដែលមានលក្ខណៈប្រកាន់ហួសអំពីហេតុ ។ បទថា **មានស្ស** (នូវការប្រកាន់ខ្លួន) បានដល់ មានះ ៩ យ៉ាង ។ បទថា **អតិមានស្ស** (នូវការមើលងាយអ្នកដទៃ) បានដល់ ប្រកាន់ខ្លួនថាប្រសើរជាងគេ ។ បទថា **មទស្ស**

*(នូវការស្រវឹង) បានដល់ សេចក្តីស្រវឹង គឺ អាការស្រវឹង ។ បទថា* **បមាទស្ស** *(នូវសេចក្តីប្រមាទ) បានដល់ ប្រាសចាកសតិ ឬបណ្តោយចិត្តទៅក្នុងកាមគុណ ៥ ។ បទដ៏សេសក្នុងទីគ្រប់កន្លែង ងាយទាំងអស់នោះឯង ។*

ចប់អដ្ឋកថា រាគបេយ្យាល

## ចប់អដ្ឋកថាអង្គុត្តរនិកាយ ឯកនិបាត និងទុកនិបាត

## ឈ្មោះមនោរថបូរណី

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

| | |
|---|---|
| លោកគ្រូអគ្គបណ្ឌិត ប៊ុត សាវង្ស | $ 2.000 USA |
| -ភិក្ខុ ចៅ សៀប វត្តអូស្ត្រាលី | $ 500 AUS |
| -ភិក្ខុធម្មប្បញ្ញោ ជុំ សារឿន វត្តពន្លឺពុទ្ធចក្រ សហរដ្ឋអាមេរិក ព្រមទាំងពុទ្ធបរិស័ទ | $ 920 USA |
| -ឧបាសក សោម រតនៈ ព្រមទាំងភរិយា និងបុត្ត | $ 200 USA |
| -ឧបាសក តាំង សុជល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ | កុំព្យូទ័របត់មួយគ្រឿង |